

ក្រសួងអប់រំ យុវជន និងកីឡា

ស្បៃវរភៅគ្រូ
អក្សរសាស្ត្រខ្មែរ

ថ្នាក់ទី ១១



បោះពុម្ពផ្សាយដោយ

ក្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

គណៈកម្មការនិពន្ធ លោក យិន ធី លោកស្រី ម៉ៅ តាន់ណារី
លោក យ៉ង់ កំសាន លោក ព្រៃ សំបូរ
លោកស្រី ប៊ី គឹមសែន

អ្នកវាយអត្ថបទ លោក គង់ ចិត្រា

វិចិត្រករ លោក ឃុន សុវណ្ណរិទ្ធី

អ្នករៀបរៀង លោកជំទាវ ទន់ សាអ៊ីម

អ្នករចនាទំព័រ លោក គង់ ចិត្រា

គណៈកម្មការពិនិត្យ លោកបណ្ឌិត នៅ ស៊ុន លោក កែវ ណារិន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២១៤៥ អយក.ប្រក. ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បោះពុម្ពឆ្នាំ ២០១២ ចំនួន ១ ៣៣០ ច្បាប់

បញ្ជីអត្ថបទ

ទំព័រ

១. ផ្តត់គំនិត ១

២. ទំនៀមទម្លាប់ ២៧

៣. សេចក្តីក្លាហាន ៥១

៤. ការលះបង់ ៦៧

៥. អតីតកាល ៩៧

៦. ការគោរពបូជា ១២៣

៧. អក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ ១៤៧

៨. តថភាព ១៧៣

៩. អក្សរសិល្ប៍បរទេស ២០១

១០. សុទិដ្ឋិនិយម ២២៧

អារម្ភកថា

សៀវភៅអក្សរសាស្ត្រខ្មែរសម្រាប់គ្រូថ្នាក់ទី ១១ថ្មីនេះ ត្រូវបានរៀបចំឡើងស្របតាមលំដាប់លំដោយនៃសកម្មភាពដែលមាននៅក្នុងសៀវភៅសម្រាប់សិស្សដើម្បីជួយសម្រួលដល់លោកគ្រូ អ្នកគ្រូក្នុងការបង្រៀនសិស្សឱ្យមានប្រសិទ្ធភាពខ្ពស់ ។

នៅក្នុងសៀវភៅនេះ មានលំនាំបង្រៀនទៅតាមសមត្ថភាពនីមួយៗគឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ព្រមទាំងបំណិននិងវេយ្យាករណ៍ផងដែរ ។ សកម្មភាពនីមួយៗមានពីរយៈពេល វត្ថុបំណង សម្ភារៈបង្រៀន ព័ត៌មានជំនួយ និងចម្លើយនៃសំណួរឬលំហាត់ដែលមាននៅក្នុងសៀវភៅសិស្ស ។ ម្យ៉ាងវិញទៀត ក៏មានកំណែកំហុសខ្លះៗដែលមាននៅក្នុងសៀវភៅសិស្សផងដែរ ។ ដោយឡែក សមត្ថភាពស្តាប់មានអត្ថបទសម្រាប់ឱ្យសិស្សស្តាប់ថែមទៀត ។

គួបផ្សំនឹងខ្លឹមសារវិធីសាស្ត្រដែលមាននៅក្នុងសៀវភៅនេះ គណៈកម្មការនិពន្ធមានជំនឿថា ភាពឈ្លាសវៃប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូពិតជាធ្វើឱ្យការបង្រៀននិងរៀនប្រព្រឹត្តទៅប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់ថែមទៀត ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅអក្សរសាស្ត្រខ្មែរសម្រាប់គ្រូថ្នាក់ទី ១១នេះ អាចជាជំនួយស្មារតីដ៏មានសារៈសំខាន់សម្រាប់ការបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូជាពុំខាន ។

គណៈកម្មការនិពន្ធ



ផ្នត់គំនិត

អ្វីទៅដែលហៅថា ផ្នត់គំនិត ? ផ្នត់គំនិត គឺជាគំនិតរបស់ជាតិមួយ ដែលមានតាំងពីបុរាណកាលមកម្ល៉េះ ហើយត្រូវបានជាតិនោះប្រកាន់ជារៀងរហូតមក។ តែទោះជាយ៉ាងនេះក្តី ក៏ផ្នត់គំនិតទាំងនោះ ខ្លះក៏មាននៅសេសសល់រហូតបច្ចុប្បន្ន ហើយខ្លះទៀតក៏ត្រូវបាត់បង់ក្នុងសម័យកាលកន្លងមក។ មូលហេតុនេះ ក៏ដោយសារតែផ្នត់គំនិតខ្លះមានលក្ខណៈសក្តិសមគ្រប់បរិបទសង្គមខ្មែរត្រូវនឹងចំណង់ចិត្តខ្មែរភាគច្រើន ទើបស្ថិតនៅក្នុងសន្តានចិត្តខ្មែររហូតមក។ ដោយផ្នត់គំនិតខ្លះទៀត ដែលមិនសមស្របនឹងចិត្តគំនិតខ្មែរ ឬមួយដោយសារតែមិនបម្រើឧត្តមប្រយោជន៍មនុស្សទូទៅ ក៏ត្រូវថមថយឬបាត់បង់ទាំងស្រុង។ ទោះបីជាយ៉ាងនេះក្តីក៏ផ្នត់គំនិតខ្មែរជាច្រើន តែងតែមានអត្ថិភាពជាមួយជនជាតិខ្មែរមិនសាបសូន្យឡើយ ហើយថែមទាំងឆ្លុះបញ្ចាំងនូវវប្បធម៌ខ្មែរហូតបច្ចុប្បន្នទៀតផង។

ហេតុដូចនេះហើយ ទើបខ្លឹមសារមេរៀន "ផ្នត់គំនិត" បានប្រមូលយកផ្នត់គំនិតខ្មែរសំខាន់ៗមកចងក្រងជាស្នាដៃសម្រាប់ទុកអប់រំកូនចៅជំនាន់ក្រោយឱ្យបានយល់និងស្គាល់ពីខ្មែរកាន់តែច្បាស់ថែមទៀត ព្រមទាំងធ្វើឱ្យខ្មែរជំនាន់ក្រោយចងចាំប្រវត្តិសាស្ត្រនិងកេរមរតកដែលដូនតាខ្មែរបានបន្សល់ទុក។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	វិទ្យាសាស្ត្រ	វិទ្យាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	១	១
• អំណានទី ១ : ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ	២ម៉ោង	៤ម៉ោង	២-៤	២
• វេយ្យាករណ៍ : កម្លាយផ្នត់ដើម	២ម៉ោង	២ម៉ោង	៥-៨	៧
• បំណិន : វិភាគតួអង្គ	២ម៉ោង	២ម៉ោង	៩-១០	១១
• អំណានទី ២ : ភ្នំនាងកន្ទ្រី	២ម៉ោង	៤ម៉ោង	១១-១៤	១៥
• ការស្តាប់ : រឿង ព្រះពាន់	០ម៉ោង	២ម៉ោង	១៥-១៧	១៨
• ការនិយាយ : បញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង	១ម៉ោង	២ម៉ោង	១៨-២០	១៩
• សំណេរ : សំយោគ	២ម៉ោង	៣ម៉ោង	២១-២៦	២១

១. សិក្សាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១ បន្ទាប់មក គ្រូសរសេរចំណងជើងមេរៀន "ផ្នត់គំនិត" ដាក់លើក្តារខៀនរួចសួរ ៖

  - ដូចម្តេចហៅថា "ផ្នត់គំនិត" ?

  ចម្លើយ : គំនិតដែលជាតិសាសន៍នីមួយៗបានប្រកាន់ខ្ជាប់តាំងពីដើមរៀងមក។

២. សិក្សាលើរូបភាព

- គ្រូឱ្យសិស្សសង្កេតរូបភាពនៃមេរៀន រួចសួរ ៖

  - តើអ្នកឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

  ចម្លើយ : ពីឆ្វេងទៅស្តាំមានផ្ទាំងសិលាចារឹក សសរពេជ្រ រូបចម្លាក់ព្រះបាទជ័យវរ្ម័នទី ៧ រូបចម្លាក់លិង្គព្រះឥសូរ។



ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ

១. វត្ថុបំណង

- យល់បានពីការវិវត្តអក្សរសិល្ប៍ខ្មែរតាមសម័យកាល
- បង្ហាញពីអក្សរសិល្ប៍តាមសម័យកាលនីមួយៗបានច្បាស់លាស់
- ឱ្យតម្លៃខ្ពស់លើវប្បធម៌ជាតិដែលមានក្នុងស្នាដៃអក្សរសិល្ប៍នានា ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២-៦
- សៀវភៅអរិយធម៌ខ្មែរ អ្នកស្រី ត្រឹង ងា គ.ស. ១៩៧៥ ព.ស. ២៥១៨
- ប្រវត្តិសាស្ត្រខ្មែរសតវត្សទី ១៩ "ឃីង ហុកឌី" ឆ្នាំ ២០០៣
- វចនានុក្រមបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០៤ ។

៣. ព័ត៌មានដំឡូយ

លោកគ្រូ-អ្នកគ្រូកែសំណួរក្នុងសៀវភៅសិស្សទំព័រទី ៦ ត្រង់សំណួរទី ៤ : តើខ្លឹមសារណាមួយដែលអ្នកគិតថាបានផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតខ្មែរក្នុងការគោរព ? ទៅជា "**គោរពពុទ្ធសាសនា**" ។

៤. លំនាំបង្រៀន

ក. ត្រៀមអំណាន

- លោកគ្រូ-អ្នកគ្រូសរសេរចំណងជើង "ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ" ជាក់លើក្តារខៀន រួចសួរ ៖
  - តើអ្វីទៅដែលហៅថា "ការវិវត្តនៃអក្សរសិល្ប៍" ?

    ចម្លើយ : មានន័យថា ជាការប្រែប្រួលអក្សរសិល្ប៍ទៅតាមកាលនីមួយៗ ។
  - តាមរយៈចំណងជើងនេះ បើអ្នកប៉ាន់ស្មានមើលថា តើអក្សរសិល្ប៍ខ្មែរមានការវិវត្តប៉ុន្មានសម័យកាល ? អ្វីខ្លះ ?

    ចម្លើយ : អក្សរសិល្ប៍ខ្មែរវិវត្តបីសម័យកាលគឺ អក្សរសិល្ប៍បុរាណ អក្សរសិល្ប៍សម័យកណ្តាល អក្សរសិល្ប៍សម័យទំនើប ។
- លោក/អ្នកគ្រូឱ្យសិស្សសង្កេតរូបភាពរួចសួរ ៖
  - តើអ្នកបានឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

    ចម្លើយ : ពីឆ្វេងទៅស្តាំ មានផ្ទាំងសិលាចារឹក កុមារាម្នាក់អានសាស្ត្រាស្លឹករឹត កុមារីម្នាក់អានសៀវភៅ ខាងក្រោយខ្នងកុមារីមានទូផ្ទុកសៀវភៅមួយ ។
  - តើអ្នកយល់យ៉ាងដូចម្តេចចំពោះរូបភាពនិងចំណងជើងនៃអំណាននេះ ?

    ចម្លើយ : ខ្ញុំយល់ថា ដើម្បីស្វែងយល់ពីការវិវត្តអក្សរសិល្ប៍ ចាំបាច់យើងត្រូវចេះសិក្សាស្រាវជ្រាវ ដោយការអានឯកសារនានាដែលបន្សល់ទុកពីពេលមុនមក ។

ខ. អំណាន

- ឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ៣ រួចសួរ ៖
  - តើក្នុងអត្ថបទនេះតម្រូវឱ្យអ្នកយល់ដឹងពីអ្វី ?

    ចម្លើយ : យល់ដឹងពីការបែងចែកអក្សរសិល្ប៍ទៅតាមសម័យកាលនិងខ្លឹមសារអត្ថបទ ។
- ឱ្យសិស្សអានអត្ថបទអំណាន ក្នុងសៀវភៅសិស្សទំព័រទី ៣-៦ ដោយបញ្ជាក់បន្តគ្នា ។
- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ៦ ។

គ. ពង្រឹងអំណាន

ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ៦ ។

ចម្លើយ :

១. អត្ថបទនេះ បង្ហាញពីការវិវត្តអក្សរសិល្ប៍ទៅតាមសម័យកាលនីមួយៗ ។

២. តាមរយៈអត្ថបទនេះ គេអាចចែកអក្សរសិល្ប៍ខ្មែរជាបីសម័យកាលធំៗ :

- អក្សរសិល្ប៍សម័យបុរាណ មុនសម័យអង្គរ(សតវត្សទី ១-៨) និងសម័យអង្គរ(៨០២-១៤៣១) ។
- អក្សរសិល្ប៍សម័យកណ្តាល សម័យក្រោយអង្គរ(១៤៣១-១៨៦២) ។
- អក្សរសិល្ប៍សម័យទំនើប សម័យអាណាព្យាបាល(១៨៦៣-១៩៥៣) និងសម័យបច្ចុប្បន្ន(ចាប់ពីគ. ស. ១៩៥៣ រហូតមក) ។

៣. អក្សរសិល្ប៍សម័យកណ្តាលមានលក្ខណៈដូចតទៅ ៖

- ការរីកចម្រើនក្នុងកាលកន្លងទៅ តែក្រោយមកមានការខ្និនថយទៅវិញ ដោយសារតែមានសង្គ្រាម ។
- ការរីកចម្រើនឡើងវិញនៃអក្សរសិល្ប៍ខ្មែរក្នុងសតវត្សទី ១៧ តាមរយៈការកត់ត្រា ជាក្រាំង និងស្លឹករឹត ។
- ការជ្រួតជ្រាបកាន់តែរហ័សរបស់សាសនាក្នុងទឹកចិត្តប្រជារាស្ត្រខ្មែរ ។
- ការចាប់កំណើតនៃស្នាដៃប្រលោមលោកជាពាក្យកាព្យ ដែលមានចារនៅលើសាស្ត្រាស្លឹករឹត ។ អ្នកនិពន្ធនិងស្នាដៃ :
  + អ្នកប៉ាង : "ល្បើកអង្គរ" គ. ស. ១៦០៩ ។
  + ព្រះរាជសម្ភារ : "ច្បាប់ព្រះរាជសម្ភារ គ. ស. ១៦២២" "ហោមន្តមាស គ. ស. ១៦២៩" "ហិនលំក្ខណ៍ គ. ស. ១៦៣០" និង "កាព្យនិរាស គ. ស. ១៦៦០" ។
  + បណ្ឌិតជ័យនន្ទ សរសេរស្នាដៃជាភាសាខ្មែរមុនគេ (សិលាចារឹក គ. ស. ១៧០១) ។
  + ឧកញ៉ាកោសាធិបតីកៅ : រឿង "ក្រុងសុភមិត្រ" គ. ស. ១៧៩៨ ។
  + ឧកញ៉ាព្រះឃ្លាំងនង : "ច្បាប់សុភាសិត គ. ស. ១៧៩០" "លោកនេយ្យជាតក គ. ស. ១៧៩៤" "បុញ្ញសារសិរសា គ. ស. ១៧៩៧" និង "ភោគកុលកុមារ គ. ស. ១៨០៤" ។
  + ឧកញ៉ាសន្ធរវោហាម៉ុក : រឿងទេវន្ទ ល្បើកចចក រឿងទុំទាវ ។
  + វិសេសដួង : "ល្បើកជុចនិងត្រី និងល្បើកជូជក" ។
  + ព្រះបាទអង្គឌួង : "ចម្ប៉ាថោង គ. ស. ១៨១០" "រឿងកាកី គ. ស. ១៨១៥" "ច្បាប់ស្រី គ. ស. ១៨៣៧" និង "រឿងមហាវេស្សន្តរ"ជាពាក្យរាយ ។

៤. បើផ្អែកតាមចំណងជើងក្នុងអត្ថបទ "ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ" យើងឃើញមានខ្លឹមសារស្តាំដៃអក្សរសិល្ប៍ដែលបានផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតខ្មែរក្នុងការគោរពពុទ្ធសាសនា។ ក្នុងពេលនោះទៀត គេសង្កេតឃើញមានស្តាំដៃអក្សរសិល្ប៍សាមញ្ញកើតឡើងដូចជា រឿងព្រេង រឿងនិទានខ្លីៗ ដែលនាំឱ្យអ្នកស្រុកចូលចិត្តស្តាប់និងអានពាក្យពេចន៍ងាយយល់ ដូចជា ៖

- កំណាព្យ "ល្បើកអង្គរ" ដែលជាស្នាដៃរបស់អ្នកប៉ាងនៅគ.ស.១៦០៩ និយាយអំពីភាពអស្ចារ្យក្នុងការកសាងប្រាសាទអង្គរវត្ត។
- ស្នាដៃកំណាព្យរបស់ព្រះរាជសម្ភារដូចជា "ច្បាប់ព្រះរាជសម្ភារ" នៅគ.ស.១៦២២ ជាច្បាប់ដំបូន្មាន "ហោមន្តមាស" នៅគ.ស.១៦២៩ "ហិនល័ក្ខណ៍" នៅគ.ស.១៦៣០ និង "កាព្យនិរាស" នៅគ.ស.១៦៦០ ជាកាព្យដែលព្រះអង្គបាននិពន្ធដោយព្រះទ័យសោកសៅរលឹកដល់ព្រះនាងបុប្ផាវត្តី។
- កំណាព្យជាភាសាខ្មែររបស់ជ័យនន្ទ(សិលាចារឹក) នៅគ.ស.១៧០១ និយាយអំពីប្រវត្តិទឹកចិត្តនិងសេចក្តីប្រាថ្នារបស់កវីក្នុងពេលអនាគត។

ក្នុងសម័យនោះដែរ គេក៏ឃើញមានប្រលោមលោកជាពាក្យកាព្យកើតឡើងដែរ។ គេចារឿងរ៉ាវទាំងនោះលើស្លឹកឬត ហើយគេចម្លងតៗគ្នា ចែកគ្នាអានពេញទាំងស្រុកភូមិ។ ស្នាដៃប្រលោមលោកជាពាក្យកាព្យទាំងនោះមាន ៖

+ រឿង ក្រុងសុភមិត្រ របស់ឧកញ៉ាកោសាធិបតី កៅ ក្នុងឆ្នាំ ១៧៩៨។
+ ច្បាប់សុភាសិត(១៧៩០) លោកនេយ្យជាតក(១៧៩៤) បុញ្ញសារសិរសា(១៧០៧) អោគកុលកុមារ(១៨០៧) របស់ឧកញ៉ាព្រះឃ្លាំងនង។
+ រឿង ទេវន្ទ ល្បើកចចក រឿងទុំទាវ របស់ឧកញ៉ា សន្ធរវោហារម៉ុក។
+ សរសេរល្បើកអក ល្បើកជុចនិងត្រី ល្បើកជូជក របស់ឧកញ៉ា ទិសេសដួង។
+ មានចម្ប៉ាថោង(១៨១០) រឿងកាកី(១៨១៥) ច្បាប់ស្រី(១៨៣៧) របស់ព្រះបាទអង្គឌួង។
+ ពាក្យកាព្យនិងនិរាសអង្គរ(១៩២៦) របស់ឧកញ៉ាសុតន្តប្រីជាឥន្ទ។
+ រឿង ពិម្ពានិព្វាន(១៩២០) របស់ឧកញ៉ា នួកន។
+ រឿង ពិម្ពាពិលាប(១៩២០) របស់អ្នកស្រី សិទ្ធិ។
+ កំណាព្យសេកសោមបណ្ឌិត(១៩៣៣) របស់លោក គីម ហាក់។

៥. បង្ហាញពីមូលហេតុដែលនាំឱ្យអ្នកនិពន្ធមានគំនិតក្នុងការព្យាយាមនិពន្ធស្នាដៃគ្រប់ប្រភេទសម្រាប់កូនចៅជំនាន់ក្រោយ :

- រក្សាឯកសារប្រវត្តិពិតនៃការកកើតប្រវត្តិហេតុការណ៍ក្នុងសម័យកាលតាំងពីបុរាណកាលមក។
- រក្សាវប្បធម៌ដែលជាកេរដំណែលបុព្វបុរសយើងដែលធ្លាប់មានកន្លងមក។
- បញ្ជាក់ថា ខ្មែរជាជាតិសាសន៍មួយដែលមានវប្បធម៌ប្រពៃណីរបស់ខ្លួនយ៉ាងពិតប្រាកដ។
- មានមោទនភាពនិងមានគំនិតអភិរក្សមរតកវប្បធម៌ជាតិ។

កម្លាយពាក្យដោយប្រើផ្តុតដើម

១. វត្ថុបំណង

- ប្រាប់ពីបញ្ញត្តិនៃកម្លាយពាក្យដោយប្រើផ្តុតដើមបានត្រឹមត្រូវ
- ប្រាប់ពីទម្រង់ផ្សេងៗនៃកម្លាយពាក្យដោយប្រើផ្តុតដើមបានត្រឹមត្រូវ
- ប្រើប្រាស់ផ្តុតដើមនិងទម្រង់ក្នុងពាក្យខ្មែរបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៧-១០
- ជំនួយស្មារតី(ទម្រង់ផ្តុតដើមខ្មែរភាគ ១ ២ ៣ "សូ មុយយៀង" គ.ស.២០០៤
- វេយ្យាករណ៍ថ្នាក់ទី ៨ "ក្រសួងអប់រំ ឆ្នាំ ១៩៨៦"
- វេយ្យាករណ៍ថ្នាក់ទី ៥ "មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា ឆ្នាំ ១៩៨៣"
- សៀវភៅទម្រង់សូរវិទ្យាខ្មែរ ឃួន សុខម្ហូ បណ្ឌិតអក្សរសាស្ត្រ។

៣. ព័ត៌មានបន្ថែម

- ចំពោះសញ្ញាកត់សូរ [?] តាមលោក ឃួន សុខម្ហូ បណ្ឌិតអក្សរសាស្ត្រ ទំព័រទី ២៤ បន្ទាត់ទី ១
  - ឃ. បញ្ហាសូរព្យញ្ជនៈខ្សល់ចន្លោះខ្សែសំឡេង [?] ។
- ចំពោះសញ្ញាកត់សូរ [?] តាមសៀវភៅវេយ្យាករណ៍ថ្នាក់ទី ៨ បោះពុម្ពដោយក្រសួងអប់រំឆ្នាំ ១៩៨៦
- ក្នុងទំព័រទី ៥៦ បន្ទាត់ទី ៦-១០ :
  - ជ. ព្យញ្ជនៈចន្លោះខ្សែសំឡេង : ពន្យព្យញ្ជនៈចន្លោះខ្សែសំឡេង គឺជាព្យញ្ជនៈដែលកើតត្រង់សន្ទះខ្សែសំឡេង ។
    ព្យញ្ជនៈចន្លោះខ្សែសំឡេងមាន : អ អ៊ [?] ។ *ឧ.* អែម [aɛ:m] អោន [?ao:n] អុត [?ot] អះ [?ah]
- **ក្នុងទំព័រទី ៥៦ បន្ទាត់ទី ១៥-៣៣ :**
  - ក. ព្យញ្ជនៈខ្សល់ស្ទះ គឺជាព្យញ្ជនៈបន្លឺឡើងដោយមានបរិវឹង និងបំលាស់កន្លែងនៃប្រដាប់សំឡេង ។ ព្យញ្ជនៈខ្សល់ស្ទះមាន :
    + ព្យញ្ជនៈខ្សល់ស្ទះគ្មានខ្សល់ : កគ [k] ចជ [c] ដឌ [d] តទ [t] បប៊ [b] ប៉ព [p] អអ៊ [?]
    + ព្យញ្ជនៈខ្សល់ស្ទះមានខ្សល់ : ខឃ [kh] ឆឈ [ch] ឋឍថធ [th] ផភ [ph]

    ឧ. ក [kɒ:] គ [kə:] ចេះ [cẹh] ជោរ [co:] តា [ta:] ទា [ti:ə] អរ [?ɒ:] អ៊ូ [?u:] ខំ [khɒm] ឃុំ [khum]
  - ខ. ព្យញ្ជនៈខ្សល់ច្រមុះ គឺជាព្យញ្ជនៈបន្លឺឡើងដោយមានភាពរំពងក្នុងច្រមុះ ។
    + ព្យញ្ជនៈខ្សល់ច្រមុះមាន ៖ ងង៉ [ŋ] ញញ៉ [ɲ] ន៉ណន [n] ម៉ម [m]

    ឧ. ណា [na:] នំ [nəm] ង៉ា [ŋa:] ងារ [ŋi:ə] ម៉ត់ [mɒt] មុម [mum]
  - ព្យញ្ជនៈខ្សល់បង្ហូរត្រដុស គឺជាព្យញ្ជនៈបន្លឺឡើងដោយមានដំណើរខ្សល់ផ្លុំបង្ហូរត្រដុស ។
    + ព្យញ្ជនៈខ្សល់បង្ហូរត្រដុសមាន ៖ យ៉យ [j] រ៉រ [r] ល៉ឡល [l] វ៉វ [v] សស៊ [s] ហហ៊ [h]

    ឧ. យ៉ាប់ [jap] យូរ [ju:] រ៉ [rɒ:] រក [rək] ឡូឡា [lọ:la:] ល [lə:] ហា [ha:] ហ៊ីង [hi:ŋ]

- ចំពោះ "កម្លាយដោយផ្ដត់ដើម" តាមឯកសារ "ជំនួយស្មារតីវេយ្យាករណ៍ទម្រង់ផ្ដត់ដើមខ្មែរភាគ ១ ឆ្នាំ ២០០៤ ដោយលោក **សូ មុយឃៀង** អតីតសាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិ" ទំព័រទី ៦-១០(ក្នុងបន្សំរវាងព្យញ្ជនៈនិងព្យញ្ជនៈ មានលក្ខណៈបីយ៉ាងអាចកើតឡើង ៖ មូលភេទ លក្ខណៈខ្សល់ និងលក្ខណៈលឺ)។
- តាមបណ្ឌិត នៅ ស៊ុន : គ្រប់ទម្រង់ដែលសរសេរ ព- ពស- ពពស- ពសព- ដែលជាផ្ដត់ដើមត្រូវកែតម្រូវជា :
  + ទម្រង់ព្យញ្ជនៈ (ព.)
  + ទម្រង់ព្យញ្ជនៈ + ស្រៈ (ពស.)
  + ទម្រង់ព្យញ្ជនៈ + ព្យញ្ជនៈ + ស្រៈ (ពពស.)
  + ទម្រង់ព្យញ្ជនៈ + ស្រៈ + ព្យញ្ជនៈ (ពសព.)

  - ចំពោះពាក្យខ្លាយ ដើម្បីងាយស្វែងរកផ្ដត់ដើម ឬផ្ដត់ជែកដែលសរសេរជា API ត្រូវសរសេរ :
    + ម៉ៅ > ខ្មៅ [k-mau]
    + កើត > ខ្ចើយ [k-n-aəːj]
- លោកគ្រូអ្នកគ្រូកែពាក្យលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១០ ត្រង់លំហាត់ទី ១ : គ- តាមទម្រង់ "ពពស-" (ពីហាត់ ទៅជា ហាល់)។
- លោកគ្រូអ្នកគ្រូអាចអានបន្ថែមនូវតារាងសញ្ញាសូរវិទ្យាអន្តរជាតិ (API) :

សញ្ញានិងសូរវិទ្យាអន្តរជាតិ (API)

លេខរៀង		១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១
ព្យញ្ជនៈខ្សល់ស្ទះ	ពួក "អ"	ក	ខ	ច	ឆ	ជ	ត	ឋ	ប	ប៉	ផ	អ										
	ពួក "អ៊ិ"	គ	ឃ	ជ	ឈ	ឌ	ទ	ធ	ប៊	ព	ភ	អ៊										
កត់សូរ API		k	kh	c	ch	d	t	th	b	p	ph	?										
ព្យញ្ជនៈខ្សល់ច្រមុះ	ពួក "អ"	ង់	ញ់	ណ	ម់																	
	ពួក "អ៊ិ"	ង	ញ	ណ	ម																	
កត់សូរ API		ŋ	ɲ	n	m																	
ព្យញ្ជនៈខ្សល់បង្ហូរ	ពួក "អ"	យ់	រ់	ឡ	វ់	ស	ហ															
	ពួក "អ៊ិ"	យ	រ	ល	វ	ស	ហ															
កត់សូរ API		j	r	l	v	s	h															
សូរស្រៈវែង		អ	អា	អី	អូ	អើ	អេ	អែ	អោ	អ៊	អ៊ា	អ៊ី	អ៊ី	អ៊ូ	អើ	អេ	អែ	អោ	អ័	អួ	អឿ	អៀ
កត់សូរ API		ɒː	ɑː	œː	o̞ː	aəː	e̞ː	aɛː	aoː	əː	iːə	iː	wː	uː	ðː	eː	ɛː	oː	oaː	uːə	wːə	iːe
សូរស្រៈខ្លី		អ់	អា់	អិ	អឹ	អើ	អុ	អែ	អៅ	អ៊	អ៊ា	អ៊ិ	អ៊ឹ	អ៊ុ	អើ	អេ	អែ	អោ				
កត់សូរ API		ɒ	a	e̞	ɛi	œ	o̞	ai	au	ə	iə	i	w	u	ɛ	ei	əu					

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងវេយ្យាករណ៍ "កម្លាយពាក្យដោយប្រើផ្តត់ដើម" ដាក់លើក្តារខៀន រួចសួរ :
  - តាមអ្នកធ្លាប់សិក្សា តើក្នុងភាសាខ្មែរមានវិធីបង្កើតពាក្យអ្វីខ្លះ ?

    ចម្លើយ : វិធីកម្លាយដោយផ្តត់ដើម កម្លាយដោយផ្តត់ជែក វិធីបន្ថែមដើម វិធីបន្ថែមចុង វិធីគន្លាស់កាត់ ... ។
- គ្រូឱ្យសិស្សអានសេចក្តីពន្យល់អំពីផ្តត់កម្លាយដោយប្រើផ្តត់ដើមក្នុងសៀវភៅសិស្សទំព័រទី ៧-១០ ។
- គ្រូសួរសំណួរដូចខាងក្រោម ៖
  - ដូចម្តេចហៅថា ផ្តត់កម្លាយ ?

    ចម្លើយ : គឺជារូបសព្ទតាអសូយ័ត ដែលអាចភ្ជាប់ទៅនឹងពាក្យឫស ដើម្បីប្តូរប្រភេទនិងប្តូរន័យរបស់ពាក្យឫសនោះ ។
  - តើផ្តត់កម្លាយខ្មែរមានប៉ុន្មានយ៉ាង ?

    ចម្លើយ : មានពីរយ៉ាង គឺផ្តត់ដើម(បុព្វបទ) និងផ្តត់ជែក(អន្តេបទ) ។
  - ដូចម្តេចហៅថា ផ្តត់ដើម(បុព្វបទ) ?

    ចម្លើយ : ជាផ្តត់កម្លាយដែលអាចភ្ជាប់នៅខាងដើមពាក្យឫស ។

ខ. ការហ្វឹកហាត់

គ្រូចែកសិស្សជា ៤ក្រុម គឺឱ្យសិស្សធ្វើលំហាត់ទី ១ក្នុងសៀវភៅសិស្សទំព័រទី ១០ :

- ក្រុមទី ១ : ប្រើវិធីកម្លាយពាក្យដោយប្រើផ្តត់ដើម ដើម្បីបង្កើតពាក្យ តាមទម្រង់ "ព-" :

ផ្តត់ដើម		ពាក្យឫស	>	ពាក្យក្លាយ
[ក-] [k -]	+	កឺះ [koeh]	>	ឆ្កឺះ [ckoeh]
[ច-] [c-]	+	បង [bɒ:ŋ]	>	ច្បង [cbɒ:ŋ]
[ត-] [t-]	+	បារ [ba:]	>	ត្បារ [tba:]
[ប-] [b-]	+	អ្នួន [ʔo:n]	>	ប្អូន [pʔo:n]

- ក្រុមទី ២ : ប្រើវិធីកម្លាយពាក្យដោយប្រើផ្តត់ដើម ដើម្បីបង្កើតពាក្យ តាមទម្រង់ "ពស-" :

ផ្តត់ដើម		ពាក្យឫស	>	ពាក្យក្លាយ
[ក-] [kɒ:-]	+	កិត [kœt]	>	កកិត [kɒkœt]
[គ-] [kə:-]	+	ឃួស [khu:h]	>	គឃួស [kəkhu:h]
[ជ-] [cə:-]	+	ជីក [ci:c]	>	ជជីក [cəci:c]
[ទ-] [tə:-]	+	ទាក់ [teak]	>	ទទាក់ [təteak]
[ព-] [pə:-]	+	ពុះ [puh]	>	ពពុះ [pəpuh]
[ប៉-] [pɒ:-]	+	ប៉ាច់ [pac]	>	ប៉ប៉ាច់ [pɒpac]

- ក្រុមទី ៣ : ប្រើវិធីកម្លាយពាក្យដោយប្រើផ្នត់ដើម ដើម្បីបង្កើតពាក្យ តាមទម្រង់ "ពពស-" :

- ផ្នត់ដើម			ពាក្យឫស	>	ពាក្យក្លាយ
[ក្រ-]	[krɒ:-]	+	ចាប់ [cap]	>	ក្រចាប់ [krɒcap]
[គ្រ-]	[krə:-]	+	វី [vi:]	>	គ្រវី [krəvi:]
[ត្រ-]	[trɒ:-]	+	ឈឹង [chɯŋ]	>	ត្រឈឹង [trɒchɯŋ]
[ប្រ-]	[prɒ:-]	+	ចាក់ [cak]	>	ប្រចាក់ [prɒcak]

- ក្រុមទី ៤ : ប្រើវិធីកម្លាយពាក្យដោយប្រើផ្នត់ដើម ដើម្បីបង្កើតពាក្យ តាមទម្រង់ "ពសព-" :

- ផ្នត់ដើម			ពាក្យឫស	>	ពាក្យក្លាយ
[កញ្ជ-]	[kaɲ-]	+	ចាស់ [cah]	>	កញ្ជាស់ [kaɲcah]
[កន់-]	[kɒn-]	+	ដាច [da:c]	>	កណ្តាច [kɒnda:c]
[គន់-]	[kən-]	+	លាក់ [liək]	>	គន្លាក់ [kənliək]
[បន់-]	[bɒn-]	+	ដើរ [daə:]	>	បណ្តើរ [bɒndaə:]
[ជំ-]	[cəm-]	+	ទាស់ [toa:h]	>	ជំទាស់ [cəmtoa:h]

គ. ការវាយតម្លៃ

គ្រូឱ្យសិស្សធ្វើលំហាត់ទី ២ក្នុងសៀវភៅសិស្សទំព័រទី ១០ :

១. រកពាក្យឫស ដោយប្រាប់ពីទម្រង់ :

ចម្លើយ :

- ពាក្យក្លាយ		ពាក្យឫស	>	ទម្រង់ផ្នត់ដើម
ច្រាល	+	រាល	>	[c-] "ព-"
ឆ្នូល	+	មូល	>	[c-] "ព-"
ជ្រមុជ	+	មុជ	>	[crɔ:-] "ពពស-"
ស្កក	+	កក	>	[s-] "ព-"
ប្រវែង	+	វែង	>	[prɒ:-] "ពពស-"

២. ដោយស្រង់ពាក្យក្លាយក្នុងសម្រង់អត្ថបទ ដោយបញ្ជាក់ពីទម្រង់ :

ចម្លើយ :

- ពាក្យក្លាយ		ពាក្យឫស	>	ទម្រង់ផ្នត់ដើម
ប្រលោម	+	លោម	>	[prɒ:-] "ពពស-"



ការវិភាគតួអង្គ

១. វត្ថុបំណង

- ប្រាប់ពីបញ្ញត្តិនៃការវិភាគតួអង្គបានត្រឹមត្រូវ
- វិភាគតួអង្គក្នុងអត្ថបទបានច្បាស់លាស់និងត្រឹមត្រូវ
- ប្រាប់បានពីលក្ខណសម្បត្តិតួអង្គនីមួយៗក្នុងរឿង ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១១-១៤
- ប្រជុំរឿងព្រេងភាគ ៩ ឆ្នាំ ១៩៧៤
- រឿងភូមិតិរច្ឆាន របស់ក្រសួងអប់រំ ឆ្នាំ ១៩៨៧ ។

៣. ដំណាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងបំណិន "ការវិភាគតួអង្គ" ដាក់លើក្តារខៀនរួចសួរ :
  - ដូចម្តេចហៅថាតួអង្គ ?

    ចម្លើយ : តួអង្គគឺជាតួដែលមានវត្តមាននិងសកម្មភាពនៅក្នុងរឿង ។
  - ហេតុអ្វីបានជាតួអង្គក្នុងរឿងមួយមានសកម្មភាពតិចឬច្រើននិងមានបុគ្គលិកលក្ខណៈខុសៗគ្នា ?

    ចម្លើយ : ដោយសារគំនិតផ្តាល់របស់អ្នកនិពន្ធ ។
- គ្រូឱ្យសិស្សអានឧទាហរណ៍ក្នុងសៀវភៅសិស្សទំព័រទី ១១-១៤ ។
- គ្រូសួរសំណួរដូចខាងក្រោម ៖
  - ដើម្បីវិភាគតួអង្គ តើគេត្រូវវិភាគលើអ្វីខ្លះ ?

    ចម្លើយ : ត្រូវវិភាគលើអាកប្បកិរិយា ចរិតលក្ខណៈ សកម្មភាពតួអង្គ ។
  - ដើម្បីការវិភាគលើលក្ខណសម្បត្តិតួអង្គ គេត្រូវវិភាគលើអ្វីខ្លះ ?

    ចម្លើយ : ត្រូវវិភាគលើគុណសម្បត្តិនិងគុណវិបត្តិរបស់តួអង្គ ។

ខ. ការហ្វឹកហាត់

- គ្រូចែកសិស្សជាពីរក្រុមឱ្យធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១៤ :
  - ក្រុមទី ១ រកគុណសម្បត្តិនាងតន់ ។

    ចម្លើយ : ជានារីកំព្រារស់នៅអាស្រ័យដោយការអធ្យាស្រ័យពីអ្នកស្រុក ។ នាងសន្សំប្រាក់មិនហ៊ានចាយវាយទៅតាមតម្រូវការរបស់ខ្លួនឡើយ ។ នាងសម្រេចយកប្រាក់មកឱ្យសុវណ្ណ ដែលជាគូដណ្តឹងរបស់ខ្លួន ទោះបីនាងខកខានមិនបានធ្វើបុណ្យជូនខ្មោចឪពុកនាងក៏ដោយ ព្រោះថា ការបង់ពន្ធជាការបន្ទាន់ រីឯការធ្វើ

បុណ្យអាចពន្យារពេលបាន។ ដូច្នេះ រវាងកិត្តិយសនិងគុណធម៌ នាងជ្រើសរើសយកគុណធម៌ ពីព្រោះអ្នកគ្មានលុយបង់ពន្ធនឹងត្រូវទទួលទោស។ មួយវិញទៀត សុវណ្ណក៏ជាអនាគតប្តីរបស់នាងដែរ។ ដូច្នេះ នាងត្រូវសម្រេចចិត្តដូចខាងលើ។

- ក្រុមទី ២ រកគុណវិបត្តិនាងតន់។

ចម្លើយ : ទោះជាយ៉ាងណាក៏ដោយ ក៏នាងតន់គប្បីជម្រាបម្ចាស់ផ្ទះជាមុនៗនឹងចេញមកផ្ទះសុវណ្ណទាំងយប់។ ដោយសារតែនាងតន់ចេញទៅណាមកណាដោយគ្មានដំណឹងនេះហើយ ទើបម្ចាស់ផ្ទះបណ្តេញនាងចេញពីផ្ទះដោយគ្មានលក្ខខណ្ឌ។

គ. ការវាយតម្លៃ

- ឱ្យសិស្សវិភាគចរិតលក្ខណៈតួអង្គនាងតន់ ដោយភ្ជាប់ទៅនឹងលក្ខណៈជាតិ :

ចម្លើយ : នាងតន់ជានារីដែលពោរពេញទៅដោយ :

+ **កិត្តិយសឬភក្តីភាព :** តាមពិតនារីខ្មែរត្រូវតែគោរពប្រពៃណីជាតិ ស្រឡាញ់កិត្តិយសដែលជាសីលធម៌របស់នារីគ្រប់រូប ប៉ុន្តែពេលនេះ នាងសម្រេចចិត្តយកភក្តីភាព ព្រោះថាក្នុងស្ថានភាពនោះ នាងតន់ត្រូវលះបង់គ្រប់យ៉ាងចំពោះសុវណ្ណដែលជាអនាគតប្តីរបស់ខ្លួន។ មានន័យថា មានប្រាក់បង់ពន្ធទើបសុវណ្ណរួចផុតពីការដាក់ទោសទណ្ឌ។ ប្រឈមមុខនឹងបញ្ហានេះ នាងតន់ក៏កាត់ចិត្តចេញពីផ្ទះទាំងយប់ដើម្បីយកលុយមកឱ្យសុវណ្ណ ដើម្បីបង្គ្រប់ថ្លៃបង់ពន្ធ។
+ **ប្រពៃណីឬសុភមង្គល :** នាងតន់បានសម្រេចចិត្តឡើងមករស់នៅជាមួយសុវណ្ណ ដោយត្រឹមតែបានភ្ជាប់ពាក្យជាគូដណ្តឹងប៉ុណ្ណោះ គឺនាងមិនទាន់បានរៀបការនៅឡើយ។ ថ្វីត្បិតតែនាងមិនទាន់រៀបការក៏ដោយ តែផ្លូវជ្រើសរើសចុងក្រោយរបស់នាង គឺមករួមរស់នៅជាមួយសុវណ្ណ ព្រោះមានតែសុវណ្ណម្នាក់គត់អាចជួយឱ្យមានសុភមង្គលស្មារកិត្តិយសនាងឡើងវិញ អាចរួមរស់ជាប្តីប្រពន្ធប្រកបទៅដោយសុភមង្គលមួយ ដូចស្វាមីនិងភរិយានៃគ្រួសារដទៃទៀត។
+ **កតញ្ញូឬមនុស្សធម៌ :** ថ្វីត្បិតជីវភាពប្រជារាស្ត្រសម័យអាណានិគមបារាំង(១៩២៥) មានសភាពដុនដាបយ៉ាងណាក៏ដោយ ក៏តន់ខិតខំសន្សំប្រាក់ទុកធ្វើបុណ្យជូនអ្នកមានគុណដែរ។ ដោយសារតែសុវណ្ណដែលជាគូដណ្តឹងនាងត្រូវការបង់ពន្ធឱ្យបារាំងជាបន្ទាន់ នាងតន់ត្រូវបង្ខំចិត្តយកប្រាក់នោះមកឱ្យសុវណ្ណដើម្បីបង្គ្រប់បង់ពន្ធ។ បើពុំនោះទេ សុវណ្ណត្រូវមានទោស។ អំពើរបស់នាងតន់គឺជាអំពើកតញ្ញូផងនិងអំពើមនុស្សធម៌ផង។



រឿងភ្នំនាងកង្រី

១. វត្ថុបំណង

- បង្ហាញពីគំនិតសំខាន់បង្កប់ កាលអាកាស និងលក្ខណៈតួអង្គរបស់រឿងនីមួយៗបានត្រឹមត្រូវ
- ប្រាប់ពីប្រវត្តិឈ្មោះទីកន្លែងនានានៃប្រទេសកម្ពុជាបានត្រឹមត្រូវ
- មានមោទនភាពចំពោះប្រវត្តិកំណកំណើតទឹកដីខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៥-១៧
- ប្រជុំរឿងព្រេងខ្មែរភាគ ៥ ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៤៧ គ.ស. ២០០៣ ។

៣. ព័ត៌មានដំឆ្ងួយ

នៅឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានភ្នំមួយខ្ពស់ជាងគេ មើលពីចម្ងាយទៅឃើញដូចមនុស្សផ្កាប់មុខសណ្តូកខ្លួន ។ នៅលើភ្នំនោះមានរុក្ខជាតិតូចធំដុះជាច្រើន ដូចភ្នំឯទៀតនៅជុំវិញនោះដែរ តែប្លែកជាងគេនៅចង្កេះភ្នំនោះមានម្ទេមដុះច្រើនណែនតាន់តាប់ អ្នកស្រុកនៅជុំវិញភ្នំនោះគេមិនបរិភោគម្ទេមនោះទេ ព្រោះគេឮថាស៎ាំដំណាលថា ម្ទេមនោះកើតពីរោមនាងកង្រីជាមហេសីព្រះពុទ្ធិសែន ហើយគេសន្មតថា ម្ទេមនោះជារោមយោនីនៃនាងកង្រីនោះឯង ។ មិនតែប៉ុណ្ណោះ នៅលើជើងភ្នំនោះ មានត្បាល់ថ្មមួយធំ តាំងពីបុរាណមក មិនដឹងនរណាសាងទេ ។ ពួកជនដែលឡើងដល់ទីនោះត្រូវតែយកអង្រែថ្មបុកត្បាល់នោះ ទើបមិនចាញ់បារមី ហើយនឹងបានសុខសប្បាយ(នេះជាជំនឿរបស់អ្នកស្រុក ដែលមានមកតាំងពីបុរាណកាលមក) ។

៤. ឈំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៥ បន្ទាប់មកគ្រូសរសេរចំណងជើងអំណាន "រឿងនាងកង្រី" ដាក់លើក្តារខៀន រួចសួរ :
  - តើអ្នកធ្លាប់អានរឿងភ្នំនាងកង្រីឬទេ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើអ្នកគិតថា "ភ្នំនាងកង្រី" មានទីតាំងក្នុងខេត្តណា ? ចម្ងាយប៉ុន្មានគីឡូម៉ែត្រពីរាជធានីភ្នំពេញ ?

    ចម្លើយ : ខេត្តកំពង់ឆ្នាំង ចម្ងាយ ៩៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ ។
  - បើតាមទម្លាប់អ្នកស្រុករស់នៅតំបន់នោះពីសម័យដើម តើគេយល់ដូចម្តេចចំពោះម្ទេម ? តើការយល់នេះសមហេតុផលឬទេ ?

    ចម្លើយ : តាំងពីដើមមកអ្នកស្រុកនៅតំបន់នោះ យល់ថា ម្ទេមជារោមរបស់នាងកង្រី ។ ការយល់បែបនេះមិនសមហេតុផលទេ ។

- តើអ្នកបានឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

  ចម្លើយ : ពីឆ្ងេងទៅស្តាំ មាននារីម្នាក់ក្នុងកាយវិការដួលដេកផ្តៀងខ្លួនលើផែនដី លើកដៃម្ខាងជាសញ្ញាឱ្យបុរសម្នាក់កំពុងជិះសេះ វិលមកវិញ។ ឯបុរសនោះលើកដៃជាសញ្ញាថា លាសិនហើយ!

- តើអ្នកយល់ដូចម្តេចំពោះរូបភាពនិងចំណងជើងនៃអំណាននេះ ?

  ចម្លើយ : ខ្ញុំយល់ថា នារីនោះជានាងកង្រី បុរសនោះជាពុទ្ធិសែន ហើយនាងកង្រីបានសូមឱ្យពុទ្ធិសែនវិលមកវិញ កុំទៅចោលនាង។

- គ្រូឱ្យសិស្សធ្វើការសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ១៥ ឬពាក្យគន្លឹះដទៃទៀតក្នុងអំណាន។

ខ. ពង្រឹងអំណាន

គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៧ :

ចម្លើយ :

១. រឿងនេះចាត់ទុកជាអក្សរសិល្ប៍ប្រជាប្រិយ។ អំណះអំណាងបញ្ជាក់ :

+ ជារឿងតំណាលតៗគ្នា "កាលពីព្រេងនាយ មានសេដ្ឋី..."។
+ និយាយពីប្រវត្តិកកើតភ្នំនាងកង្រី។
+ និយាយទាក់ទងនឹងតថភាពនៃវប្បធម៌ជាតិខ្មែរតាំងពីបុរាណកាលមក(ជំនឿ ការគោរពបូជា ទំនៀមទម្លាប់)
+ ពុំមានប្រវត្តិអ្នកនិពន្ធពិតប្រាកដ។ល។ និង។ល។

២. ហេតុដែលនាំឱ្យគេផ្តៀលភ្នែកនាងទាំង ១១ទាំងសងខាង មកពីនាងទាំង ១១បានប្រព្រឹត្តបាបកម្មពីជាតិមុន គឺពួកនាងបានដោតភ្នែកត្រីទាំងសងខាង ហើយអំពើនោះក៏ហុចផលទៅពួកនាងក្នុងជាតិបច្ចុប្បន្ន។ រីឯនាងទី ១២ដោយសារនាងដោតភ្នែកត្រីតែម្ខាង ទើបមកជាតិបច្ចុប្បន្នត្រូវគេខ្វេះភ្នែកតែម្ខាង។ តាមគំនិតខ្ញុំៗយល់ថា ទស្សនៈនេះ មានឥទ្ធិពលពីព្រះពុទ្ធសាសនា ដែលនិយាយទាក់ទងនឹងកម្មផលបីយ៉ាងគឺ កម្មអតីតជាតិហុចផលទៅបច្ចុប្បន្នជាតិ កម្មបច្ចុប្បន្នជាតិហុចផលក្នុងបច្ចុប្បន្នជាតិ កម្មបច្ចុប្បន្នជាតិហុចផលទៅអនាគតជាតិ។

៣. ផ្តត់គំនិតសំខាន់ក្នុងអត្ថបទ ដែលនៅតែជាឧត្តមគតិដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយគឺ :

+ ការប្រកាន់អំពើល្អ ដោយប្រាសចាកអំពើបាប គឺការប្រមាថជីវិតអ្នកដទៃ(ដោតភ្នែកត្រី)។
+ ការមើលឃើញពីបាបកម្ម ដែលកើតឡើងដោយសារតែខ្លួនបានសាង(នាងទាំង ១១ដោតភ្នែកត្រីទាំងសងខាងក៏ត្រូវគេផ្តៀលភ្នែកទាំងសងខាង ឯនាងពៅដោតភ្នែកត្រីតែម្ខាង ក៏ត្រូវគេផ្តៀលភ្នែកត្រីតែម្ខាង)។
+ ផលអាក្រក់នៃអំពើបាប ដោយការច្រណែនឈ្នានីស ព្យាបាទ គំនុំគុំគួន(នាងសន្ធមារ ត្រូវស្លាប់)។
+ ការប្រកាន់កតញ្ញូតាចំពោះអ្នកមានគុណ(ពុទ្ធិសែន)។

ដោយហេតុថា ផ្តត់គំនិតនេះបានផ្សារភ្ជាប់ទៅនឹងគុណតម្លៃនៃសីលធម៌ពុទ្ធសាសនា ដែលមានឥទ្ធិពលមកលើសង្គមខ្មែរ ទើបធ្វើឱ្យសង្គមមានសន្តិភាព មានវប្បធម៌អហិង្សា មិនមានការរំលោភសិទ្ធិមនុស្ស និងធ្វើឱ្យមនុស្សរស់នៅប្រកបដោយសុភមង្គល។

៤. រឿងនេះបង្ហាញពីផ្តត់គំនិតខ្មែរដូចតទៅ :

+ ជំនឿអរូបី : ប្រជារាស្ត្រខ្មែរមានជំនឿទៅលើការបន់ស្រន់ចំពោះវត្ថុស័ក្តិសិទ្ធិ ដូចជាមហាសេដ្ឋីបានបន់ស្រន់ដើមជ្រៃ សូមឱ្យមានកូន "កាលពីព្រេងនាយ មានសេដ្ឋីនៅនគរមួយជាមនុស្សឥតកូន បាននាំប្រពន្ធទៅបន់សុំកូននៅដើមជ្រៃមួយ"។

+ ជំនឿកម្មផល : រាល់អំពើដែលនរណាម្នាក់បានសាងអំពើនោះនឹងផ្តល់ផលមកវិញជាមិនខាន ។ បើគេសាងអំពើអ្វីមួយទោះយូរនាប់គេនឹងទទួលផលនោះវិញ ដូចជានាងទាំង ១១ដែលបានដោតភ្នែកត្រីទាំងសងខាង ពួកនាងក៏ត្រូវគេខ្វេះភ្នែកទាំងសងខាងវិញ ។ រីឯនាងពៅឬនាងទី ១២ ដែលដោតភ្នែកត្រីតែម្ខាងក៏ត្រូវគេខ្វេះភ្នែកនាងតែម្ខាងដែរ ។
+ ប្រពៃណីអាពាហ៍ពិពាហ៍ : មង្គលការត្រូវធ្វើឡើងនៅផ្ទះខាងស្រី ។ មង្គលការថៅពុទ្ធសែននិងនាងកង្រីធ្វើឡើងនៅឯទីឋានដែលនាងកង្រីរស់នៅ ។ ក្រោយពីបានឃើញលិខិតនោះ "នាងកង្រីបានឃើញសំបុត្រក៏រៀបការជាមួយពុទ្ធិសែនភ្លាម" ។ នេះជាការបង្ហាញពីអត្តសញ្ញាណប្រពៃណីខ្មែរដែលគេតែងតែរៀបការនៅផ្ទះខាងស្រី ។
+ ភាពកតញ្ញូ : ការបែងចែករវាងវិចារណៈនិងសញ្ចេតនា ក៏បានផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតខ្មែរដែរគឺភាពកតញ្ញូ ចំណុចទាំងពីរនេះតម្រូវឱ្យពុទ្ធិសែនជ្រើសរើសបានតែមួយគត់គឺកតញ្ញូតា ដែលត្រូវនឹងផ្នត់គំនិតជនជាតិខ្មែរដែលនិយមគោរពនិងដឹងគុណចំពោះមាតាបិតា គ្រូឧបជ្ឈាយ៍ឬបុព្វបុរសខ្លួន ។ ដោយផ្អែកលើផ្នត់គំនិតនេះហើយ ទើបសង្គមខ្មែរតែងតែឱ្យតម្លៃខ្ពស់ទៅលើកូនថៅដែលមានការដឹងគុណមាតាបិតា ទំនុកបម្រុងមាតាបិតា ចេះស្តាប់បង្គាប់មាតាបិតា ក្នុងការប្រព្រឹត្តិអំពើល្អ ។ ទង្វើរបស់ថៅពុទ្ធិសែនដើម្បីសង្គ្រោះម្តាយធំនិងម្តាយបង្កើតដែលត្រូវនឹងផ្នត់គំនិតជនជាតិខ្មែរ ។
+ ភក្តីភាព : សង្គមខ្មែរឱ្យតម្លៃលើភក្តីភាពទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ស្ត្រីខ្មែរតែងតែរក្សានូវភាពស្មោះត្រង់ជានិច្ចចំពោះស្វាមី ។ ការប្រកាន់ភក្តីភាពនេះហើយ ដែលនាងកង្រីស៊ូលះបង់នគរមកតាមពុទ្ធិសែន ។ ដោយមិនសម្រេចប្រាថ្នានាងហ៊ានលះបង់ជីវិត ។

៥. ហេតុដែលនាំឱ្យនាងកង្រីរៀបការជាមួយពុទ្ធិសែន មកពីមហាឫសីក្លែងសំបុត្រនាងសន្ធមារដែលថា ៖ "បើពុទ្ធិសែនមកដល់ពេលយប់ឱ្យស៊ីទាំងយប់ បើដល់ថ្ងៃឱ្យស៊ីទាំងថ្ងៃ" ទៅជា "បើពុទ្ធិសែនមកដល់យប់ត្រូវរៀបការទាំងយប់ បើដល់ពេលថ្ងៃត្រូវរៀបការទាំងថ្ងៃ" ។

ការមិនឱ្យពុទ្ធិសែនបានរួមរស់ជាមួយនាងកង្រីជាគូអនាគត ដោយអ្នកនិពន្ធមានបំណងដូចតទៅ ៖

+ កតញ្ញូតាធម៌ : ពុទ្ធិសែនជាកូនកតញ្ញូចំពោះអ្នកមានគុណ ដែលលោកកំពុងរងការឈឺចាប់ ដោយទទួលទារុណកម្មពីនាងសន្ធមារចិត្តឫស្យានោះ ។ តួអង្គពុទ្ធិសែនត្រូវប្រឈមនឹងការសម្រេចចិត្តដ៏លំបាកមួយ ។ មានន័យថាម្ខាងគឺម្តាយ ហើយម្ខាងទៀតគឺប្រពន្ធ ។ បញ្ហាទាំងពីរនេះ តម្រូវឱ្យពុទ្ធិសែនជ្រើសរើសយកផ្លូវតែមួយគឺពុទ្ធិសែនសម្រេចចិត្តទៅសង្គ្រោះម្តាយជាមុន ព្រោះស្ថានភាពម្តាយកំពុងរងទុក្ខយ៉ាងខ្លាំងក្រោមទារុណកម្មរបស់នាងសន្ធមារ ។ ពុទ្ធិសែនត្រូវកាត់ចិត្តចាកចេញពីនាងកង្រី ទោះបីដឹងថាការចាកចេញនេះនឹងធ្វើឱ្យនាងឈឺចាប់ ។ ប៉ុន្តែ ជាកូនកតញ្ញូ ពុទ្ធិសែនត្រូវតែហ៊ានពុះពារ ដើម្បីអ្នកមានគុណគឺ "ការសង្គ្រោះជីវិតអ្នកមានគុណជាមុន" ។

៦. ការបញ្ចប់រឿងដោយនាងកង្រីស្លាប់ពិតជាសមស្រប ។ ដោយហេតុថា ឧត្តមភាពជីវិតកូនត្រូវផ្សារភ្ជាប់ទៅនឹងឧត្តមភាពជីវិតរបស់អ្នកមានគុណ ។ អ្នកមានគុណបីបាច់ថែរក្សាកូន ចុះកូនវិញត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះចំពោះលោក ? ក្នុងករណីអ្នកមានគុណកំពុងមានវិបត្តិដោយប្រការណាមួយ កូនត្រូវតែចេញមុខដោះស្រាយបញ្ហានោះ ដើម្បីឱ្យលោកបានសុបអារម្មណ៍រក្សាជីវិតលោកឱ្យមានសេចក្តីសុខសុប់ក្នុងជីវិត ជាពិសេសត្រូវជួយអ្នកមានគុណក្នុងគ្រាដែលគាត់មានទុក្ខលំបាកធ្ងន់ធ្ងរ ឬក៏ត្រូវអ្នកណាម្នាក់ប្រព្រឹត្តអំពើឃោរឃៅមកលើគាត់ ។

៧. សិក្សាកាលអាកាសនៃរឿង :

+ កាល : នៅពេលទៅបន់ស្រន់ នៅពេលបំបរបង់កូន នៅពេលយកនាងទាំង ១២ឱ្យទៅនៅបម្រើនាងកង្រី នៅពេលដែលយកនាងទាំង ១២ទៅខ្ទេះភ្នែក ។

+ អាកាស : នៅដើមជ្រៃ នៅព្រៃជ្រៅ នៅនគរសន្ធមារ នៅនគរព្រះរថសិទ្ធិ ។

៨. ស្រង់ពាក្យភ្ជាយឱ្យបានបួនពាក្យពីក្នុងអត្ថបទអំណានរឿង "ភ្នំនាងកង្រី" តំណែង បង្ហត់ ជំនួស ចំណេរ ។

+ ពាក្យឫស : តែង + [-អ៊ម/ន] > តំណែង "-សព/ព"
+ ពាក្យឫស : អត់ + [-ប៉ង] > បង្ហត់ "ពសព"
+ ពាក្យឫស : ជួស + [អ៊ំ/ណ] > ជំនួស "-សព/ព"
+ ពាក្យឫស : ចេរ + [អ៊ំមន/ណ] > ចំណេរ "-សព/ព"

គ. ការវាយតម្លៃ

គ្រូឱ្យសិស្សធ្វើសង្ខេបអត្ថបទឡើងវិញ :

មានសេដ្ឋីនៅនគរមួយឥតមានកូន បានទៅបន់សុំកូននៅជើមជ្រៃមួយ ។ លុះបានកូនហើយ សេដ្ឋីក៏ធ្លាក់ខ្លួនក្រ ។ ដោយសារភាពទ័លក្រ សេដ្ឋីក៏ដាច់ចិត្តយកកូនទាំង ១២នាក់ទៅប្រោសចោលក្នុងព្រៃជ្រៅមួយ ។ កូនទាំង ១២នាក់ក៏នាំគ្នាដើរក្នុងព្រៃទៅដល់នគរមួយជានគរយក្សស្រីឈ្មោះ នាងសន្ធមារ ដែលមានកូនស្រីមួយឈ្មោះនាងកង្រី ។ នាងសន្ធមារបានតំណែងខ្លួនជាមនុស្សស្រីនាំយកនាងទាំង ១២ទៅឱ្យបម្រើនាងកង្រីជាកូន ។ នាងទាំង ១២ដឹងថា នគរនោះជានគរយក្ស ក៏នាំគ្នារត់ចេញ ។ សន្ធមារតាមរកនាងទាំង ១២ ។ នៅពេលរកឃើញ នាងទាំង ១២ បានក្លាយជាមហេសីព្រះបាទរថសិទ្ធិទៅហើយ នាងសន្ធមារក៏តំណែងខ្លួនជាស្រីក្រមុំ ហើយបានធ្វើជាមហេសីព្រះបាទរថសិទ្ធិនោះដែរ ។ ដោយសារតែការគុំគួន នាងសន្ធមារក៏រកមធ្យោបាយដើម្បីព្យាបាទនាងទាំង ១២ ដោយនាងធ្វើពុតជាឈឺធ្ងន់ ញុះញង់ពេទ្យឱ្យទូលព្រះបាទរថសិទ្ធិឱ្យឆ្កៀលភ្នែកនាងទាំង ១២យកមកធ្វើថ្នាំព្យាបាលរោគខ្លួននិងយកនាងទាំង ១២នាក់ដែលមានគភ៌គ្រប់ៗគ្នា ទៅទុកបង្ហត់អាហារក្នុងរណ្តៅមួយ ។ នាងសន្ធមារក៏យកគ្រាប់ភ្នែកនាងទាំង ១២ទៅទុកក្នុងឃ្លាំងឯនគររបស់ខ្លួន ។ នាងបងៗ ១១នាក់ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ឯនាងពៅត្រូវគេឆ្កៀលភ្នែកតែម្ខាង ។ វេលានាងបងៗ កើតកូនមកភ្លាម ក៏នាំគ្នាបែកកូនចែកគ្នាស៊ីអស់ ចំណែកនាងពៅកើតកូនប្រុសមួយឈ្មោះ "ពុទ្ធិសែន" ។ នៅពេលពុទ្ធិសែនធំពេញជំទង់ នាងសន្ធមារក៏ដឹងថាជាកូននាងទី ១២ ក៏ប្រើពុទ្ធិសែនឱ្យជិះសេះនាំសំបុត្រទៅឱ្យនាងកង្រី ដោយបង្គាប់ឱ្យនាងកង្រីស៊ីពុទ្ធិសែន តែត្រូវមហាឫសីក្លែងសំបុត្រជាថ្មី ឱ្យនាងកង្រីរៀបការជាមួយពុទ្ធិសែនទៅវិញ ។ នាងកង្រីបានឃើញសំបុត្រក៏រៀបការជាមួយពុទ្ធិសែនភ្លាម ។ ដោយបានដឹងពីអាថ៌កំបាំងប្រស្រីភ្នែករបស់មាតានិងអំពីថ្នាំសម្រាប់ដាក់ភ្នែកឱ្យជា ព្រមទាំងមានវត្ថុទិព្វជាច្រើនទៀត ពុទ្ធិសែនក៏លួចយកវត្ថុទាំងនោះ រួចចាកចេញពីនគរនាងកង្រីទាំងអាធ្រាត្រ ។ នាងកង្រីដឹងក៏លើកពលសេនាដេញតាមពុទ្ធិសែន តែតាមមិនទាន់យំសោករហូតដល់ស្លាប់ខ្លួននៅកណ្តាលព្រៃ ។ ពុទ្ធិសែនមកដល់នគរវិញដាក់កែវភ្នែកម្តាយនិងម្តាយធំទាំងអស់ឱ្យជាឡើងវិញ ។ ព្រះអង្គក៏សម្លាប់នាងសន្ធមារទៅ ទ្រង់បានសោយរាជ្យជំនួសព្រះបិតាជាសុខក្សេមក្សាន្តរហូតតទៅ ។



រឿងព្រះពាន់

១. វត្ថុបំណង

- បញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង ក្រោយពីបានស្តាប់បានត្រឹមត្រូវ
- ប្រាប់ពីគុណសម្បត្តិនិងគុណវិបត្តិរបស់តួអង្គក្នុងរឿង
- ស្រង់បទពិសោធន៍ល្អៗពីសកម្មភាពរបស់តួអង្គក្នុងរឿង ក្រោយពីបានស្តាប់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៨
- សៀវភៅប្រជុំរឿងព្រេងខ្មែរភាគទី ៦ ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៧ គ.ស.២០០៣ ។

៣. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូសរសេរចំណងជើងអត្ថបទស្តាប់រឿង "រឿងព្រះពាន់" ដាក់លើក្តារខៀនរួចសួរ ៖
  - តើអ្នកធ្លាប់អានរឿងព្រះពាន់ទេ ?

    ចម្លើយ : អាស្រ័យលើសិស្សដែលធ្លាប់អាន ឬមិនធ្លាប់អាន ។
  - តាមរយៈចំណងជើងនេះ យល់បានអ្វីខ្លះ ?

    ចម្លើយ : ខេត្តព្រៃវែង ។
  - តាមការសង្កេតរូបភាព តើអ្នកបានឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

    ចម្លើយ : ពីឆ្វេងទៅស្តាំ មានព្រះពុទ្ធបដិមាជាច្រើន និងរូបបុរសម្នាក់កំពុងតែដាប់ឆ្លាក់បដិមាទាំងនោះ ។
  - តើអ្នកយល់ឃើញដូចម្តេចចំពោះរូបភាពនិងចំណងជើងនៃអំណាននេះ ?

    ចម្លើយ : បដិមានេះកើតឡើងដោយសារតែបុរសនោះដែលជាអ្នកដាប់ ឆ្លាក់ ដើម្បីបង្គ្រប់ចំនួន ១០០០ ព្រោះចំណងជើងដាក់ថាព្រះពាន់ ។
- គ្រូពន្យល់ន័យនៃពាក្យពិបាកខាងក្រោម ៖
  - អំណឹះ (កិ) : តមកឬតទៅ ចំណេរកាលមកឬចំណេរកាលទៅ ។
  - បង្អែបង្អង់ (កិ) : អែអង់ រេរង់ ឈប់ចាំ ។
  - ត្រឡោក (ន) : លលាដ៍ដួងដែលគេយកមករំលីងធ្វើជាប្រដាប់សម្រាប់ដាក់ទឹកប្រើប្រាស់ ។
  - ទ្រគោះ (គុ) : ដែលច្រឡើសបើស ។
  - ខមាទោស (ន) : ពាក្យសុំឱ្យអត់ទោសឬលើកទោសចោល ។
  - វដ្ដៈ ឬវដ្ដ (គុ) : ដែលវិលមូល ដែលជាវង់មូល ។
  - វដ្ដសង្សារ (ន) : ការវិលទៅមក ដំណើរវិលកើតវិលស្លាប់ វង់មូល ។
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៨ ដើម្បីត្រៀមឆ្លើយ ។
- អានអត្ថបទឱ្យសិស្សស្តាប់ :

រឿង ព្រះពាន

កាលពីអតីតកាលកន្លងយូរអង្វែងណាស់មកហើយនោះ មានត្រកូលមួយមិនប្រាកដឈ្មោះអ្វី បានរស់នៅក្នុងទីនោះ។ កាលអំណឹះ ឥតអំពីប្តីទៅ ប្រពន្ធបានទៅរួមរស់ជាមួយកូនប្រុស រកស៊ីចិញ្ចឹមជីវិត ដោយការធ្វើស្រែជារបរប្រចាំគ្រួសារ។ រៀងរាល់ព្រឹក ម្តាយតែងតែឱ្យកូនប្រុសនេះទៅភ្ជួររាស់ឯស្រែ លុះដល់ថ្ងៃបន្តិច ទើបម្តាយទូលបាយសម្លទៅឱ្យជាខាងក្រោយ។

ថ្ងៃមួយ ដោយជាប់រវល់ក្នុងកិច្ចការផ្ទះជាច្រើនផង ដោយអាងថាកូនប្រហែលជាមិនទាន់ឃ្លានបាយណាស់ណាផង ក៏បង្អែបង្អង់ឱ្យយឺតបន្តិចជាងរាល់ថ្ងៃ។ ចំណែកកូនប្រុសដែលទៅភ្ជួររាស់ឯស្រែនោះឃ្លានបាយណាស់ ទន្ទឹងមើលផ្លូវម្តាយស្ទើរក្រហមភ្នែក មិនឃើញម្តាយយកបាយទៅឱ្យសោះ ក៏បានពោលពាក្យប្រមាថមើលងាយជាច្រើន ដោយពាក្យពុំសមរម្យទៅលើម្តាយ។ ម្តាយ កាលដែលបានរួចរវល់អស់ហើយ ក៏រៀបចំដួសបាយដាក់ក្នុងត្រឡោក ហើយញាត់ឱ្យណែនដោយគាត់គិតថា កាលណាកូនគាត់ស៊ីបាយរួចហើយ និងយកត្រឡោកនេះដងទឹកផឹកតែម្តង ជាការងាយស្រួលជាងដាក់បាយនឹងចាន សោះនឹងយកផង ត្រឡោកផង នាំតែលំបាកនឹងយកមកវិញច្រើន។

កូនកំលោះគាត់ ដែលកំពុងឃ្លានបាយខ្លាំង កាលបើឃើញបាយក្នុងត្រឡោកដូចជាមិនសំណាំយកទៅឱ្យខ្លួនដូច្នោះក៏នឹកខឹងណាស់ ព្រោះគិតថាខ្លួនស៊ីមិនឆ្អែត ក៏និយាយពាក្យទ្រគោះ ទាំងជ្រលហួសវាយដំម្តាយ លុះត្រាម្តាយសន្លប់បាត់ស្មារតីក្នុងពេលនោះ។ លុះដល់ស៊ីបាយមិនអស់ពីត្រឡោក ទើបដឹងថាខ្លួនធ្វើនេះខុសហើយ ងាកមកសុំខមាទោសម្តាយវិញ។ ម្តាយឆ្លើយតបថា ម្តាយគ្មានទោសឱ្យកូនទេនេះគឺជាទោសរបស់វដ្ដៈ បើកូនចង់បានរួចកម្មពៀរនេះ កូនត្រូវកសាងព្រះពុទ្ធរូបមួយពាន់នៅលើផ្ទាំងថ្មដាមួយយ៉ាងធំ កាលណាបើព្រះពុទ្ធរូបទាំងនេះរបេះរលុបរលាយបាត់កាលណា ពេលនោះហើយដែលកូនរួចអំពើកម្មពៀរនេះ។ ម្តាយផ្តាំរួចស្រេចហើយក៏ធ្វើមរណកាលទៅកាន់បរលោកទៅ។

កូនប្រុសនោះក៏បានធ្វើតាមបណ្តាំម្តាយ ដោយយកដុំថ្មមួយធំមករចនារូបព្រះជុំវិញជាជាន់ៗ ជាច្រើនរយអង្គ ហើយតម្កល់ទុកកន្លែងនេះរហូតមកដល់សព្វថ្ងៃ។ អ្នកស្រុកជិតខាងបានសន្មតហៅកន្លែងនេះថា "ព្រះពាន់" រហូតមកដល់សព្វថ្ងៃនេះ។ នៅរាល់ឆ្នាំ អ្នកស្រុកជិតខាងគេតែងនាំគ្នាទៅធ្វើបុណ្យទានផ្សេងៗ នៅកន្លែងនេះពុំដែលខាន។

(ដកស្រង់ចេញពីប្រជុំរឿងព្រេងខ្មែរភាគ ៦ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៧ គ.ស.២០០៣)

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៨ :

ចម្លើយ :

១. រឿងនេះចាត់ទុកជាអក្សរសិល្ប៍ប្រភេទប្រជាប្រិយ។ អំណះអំណាងបញ្ជាក់ថា :
   + ជារឿងតំណាលតៗគ្នា "កាលពីព្រេងនាយ មានសេដ្ឋី..."។
   + និយាយពីប្រវត្តិកកើតរឿងព្រះពាន់។
   + និយាយទាក់ទងនឹងជំនឿរបស់ជនជាតិខ្មែរតាំងពីបុរាណកាលមក(ជំនឿ ការគោរពបូជា ទំនៀមទម្លាប់)។
   + ពុំមានប្រវត្តិអ្នកនិពន្ធពិតប្រាកដ។

២. អំពើរបស់កូនប្រុសដែលបានប្រព្រឹត្តចំពោះម្តាយនោះ ជាអំពើដែលកើតចេញពីទោសៈ ដោយពុំអាចទប់ស្កាត់នៅសេចក្តីស្រេកឃ្លានបាន។ ដោយហេតុថា មិនចេះពិចារណាបានត្រឹមត្រូវ ដោយសារតែឃ្លានបែរជាហ៊ានវាយដំម្តាយរហូតបាត់បង់ជីវិត។

៣. ម្តាយមានឥរិយាបថចំពោះអំពើកូនប្រុសគាត់ដូចតទៅ :
   + គាត់គ្មានទោសឱ្យកូនទេ ព្រោះវាជាទោសរបស់វដ្ដៈ។
   + ត្រូវកសាងព្រះពុទ្ធរូបមួយពាន់ នៅលើផ្ទាំងថ្មដាមួយយ៉ាងធំ បើកូនចង់បានរួចកម្មពៀរ។
   + បើព្រះពុទ្ធរូបទាំងនេះរបេះរលុបរលាយបាត់កាលណា ពេលនោះទើបកូនរួចអំពីកម្មពៀរនេះ។

៤. បានជាកូនប្រុសនោះសុំខមាទោសចំពោះម្តាយវិញ មកពីកូន :

+ មានវិប្បសារីចំពោះអំពើរបស់ខ្លួន ដោយសារតែការគិតខុស ។
+ ចង់សម្តែងឱ្យឃើញពីកំហុសឆ្គងរបស់ខ្លួនចំពោះម្តាយ មុនពេលលោកចែកឋានទៅ ។
+ ចង់រំដោះកម្មពៀរដែលខ្លួនបានប្រព្រឹត្តចំពោះម្តាយកន្លងមក ។

៥. ចំណុចដែលបញ្ជាក់ពីផ្នត់គំនិតខ្មែរដូចជា :

+ ប្រពៃណីនៃការសុំខមាទោសនៅពេលគេធ្វើកំហុសអ្វីមួយ ។
+ ការរំដោះកម្មពៀរដោយការទទួលស្គាល់កំហុសនិងកែកំហុសខ្លួន
+ ការគោរពបូជាចំពោះព្រះពុទ្ធសាសនា ។
+ ជឿទៅលើកម្មពៀរវេរា ។

៦. រឿងនេះបានបង្ហាញពីលក្ខណៈតថៈរបស់រឿងដូចតទៅ :

+ មោហៈជាមូលហេតុនៃទោសៈ ។
+ ទោសៈធ្វើមនុស្សបាត់បង់គុណធម៌ ។
+ អ្នកប្រព្រឹត្តកំហុស មិនអាចលើកលែងបានទេ ទាំងក្នុងផ្លូវធម៌ ទាំងផ្លូវលោក
+ ប្រព្រឹត្តអំពើហិង្សាធ្វើឱ្យបុគ្គលមានទោស មិនថាលើសាច់ញាតិ ឬលើអ្នកដទៃឡើយ ។

៧. សិក្សាកាលអាកាស :

+ កាល : ពេលភ្ជួរដី ថ្ងៃមួយ ។
+ អាកាស : នៅផ្ទះ នៅស្រែ នៅលើថ្មដា ។

ខ. ការវាយតម្លៃ

ឱ្យសិស្សសង្ខេបរឿងឡើងវិញ :

មានត្រកូលមួយក្រោយពីប្តីស្លាប់ទៅ ប្រពន្ធនោះបានទៅរស់ជាមួយកូនប្រុស ហើយធ្វើស្រែជារបរប្រចាំគ្រួសារ ។ រៀងរាល់ព្រឹក ម្តាយឱ្យកូនប្រុសទៅភ្ជួររាស់ស្រែ ថ្ងៃបន្តិចទើបម្តាយទូលបាយសម្លយកទៅឱ្យកូន ។ ថ្ងៃមួយម្តាយជាប់រវល់ ដោយគិតថាកូនប្រហែលជាមិនទាន់ឃ្លានបាយទេ ក៏បង្អង់យឺតបន្តិចជាងរាល់ថ្ងៃ ។ កូនប្រុសឃ្លានបាយណាស់ ទន្ទឹងមើលផ្លូវម្តាយមិនឃើញម្តាយក៏បានពោលពាក្យពុំសមរម្យប្រមាថមើលងាយ ។ ម្តាយមិនចង់យកចានផង ត្រឡោកផង ក៏ដួសបាយដាក់ក្នុងត្រឡោក ដើម្បីឱ្យកូនយកត្រឡោកនេះដងទឹកផឹកតែម្តង ។ កូនកំពុងឃ្លានបាយខ្លាំង ឃើញបាយដាក់ក្នុងត្រឡោក កូនក៏ខឹងណាស់ ដោយគិតថាវាស៊ីមិនឆ្អែត ។ គិតដូច្នេះ វាក៏និយាយពាក្យទ្រគោះជ្រុលហួសរហូតវាយម្តាយសន្លប់បាត់ស្មារតី ។ លុះដល់វាស៊ីបាយក្នុងត្រឡោកនោះមិនអស់ ទើបដឹងថា ខ្លួនធ្វើនេះខុស ហើយងាកមកសុំខមាទោសម្តាយវិញ ។ ម្តាយថា គាត់មិនដាក់ទោសឱ្យទេ តែកូនត្រូវទទួលកំហុស ទើបត្រូវឱ្យកូនកសាងព្រះពុទ្ធរូបមួយពាន់នៅលើថ្នាំងថ្ម ដោយសន្មតថា បើព្រះពុទ្ធរូបទាំងនេះរបេះរលុបរលាយបាត់កាលណា ពេលនោះទើបកូនក៏រួចដុតអំពើកម្មពៀរ ។ ម្តាយផ្តាំរួច ក៏ធ្វើមរណកាលទៅកាន់បរលោក ។ កូនប្រុសក៏ធ្វើតាមបណ្តាំម្តាយ ដោយឆ្លាក់រូបជាព្រះពុទ្ធជាច្រើនរយអង្គ ហើយតម្កល់ទុកកន្លែងនេះរហូតមកដល់សព្វថ្ងៃ ។



ការបញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង

១. វត្ថុបំណង

- បញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿងបានត្រឹមត្រូវដោយឈរលើអំណះអំណាងច្បាស់លាស់
- ប្រាប់ពីគុណសម្បត្តិនិងគុណវិបត្តិរបស់តួអង្គក្នុងរឿងបានត្រឹមត្រូវ
- បង្ហាញពីមូលហេតុក្នុងការគាំទ្រលក្ខណសម្បត្តិតួអង្គនីមួយៗ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៩
- ប្រជុំរឿងព្រេងខ្មែរភាគ ៥ ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៧ គ.ស.២០០៣ ។

៣. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៩ បន្ទាប់មកគ្រូសរសេរចំណងជើងការនិយាយ "ការបញ្ចេញមតិវាយតម្លៃ" ដាក់លើក្តារខៀន រួចគ្រូសួរ :
  - ដូចម្តេចដែលហៅថា ការបញ្ចេញមតិវាយតម្លៃ ?

    ចម្លើយ : ជាការបង្ហាញឱ្យឃើញគំនិត យោបល់ការយល់ឃើញរបស់បុគ្គលម្នាក់ៗដើម្បីវិនិច្ឆ័យរកចំណុចសកម្មឬអសកម្មនៃបញ្ហា អំពើ មតិ យោបល់ គំនិតផ្សេងៗ ។
  - តើការបញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿងណាមួយ មានសារៈសំខាន់យ៉ាងណាខ្លះ ?

    ចម្លើយ : បានផ្តល់ចំណុចសកម្មដែលជាបទពិសោធន៍សម្រាប់ជីវិតទាំងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។
- គ្រូឱ្យសិស្សអានការណែនាំនៅពេលនិយាយបញ្ចេញមតិ នៅផ្នែកខាងលើក្នុងសៀវភៅសិស្សទំព័រទី ២០ រួចសួរ :
  - នៅពេលនិយាយបញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង តើគេត្រូវអនុវត្តគោលការណ៍អ្វីខ្លះ ?

  ចម្លើយ :

  + កំណត់ស្គាដៃឬរឿងដែលត្រូវលើកយកមកសិក្សា
  + ត្រូវសិក្សាខ្លឹមលំអិតនៃរឿង
  + ស្វែងយល់ពីសកម្មភាពតួអង្គដែលត្រូវយកមកសិក្សា
  + ញែកគុណសម្បត្តិនិងគុណវិបត្តិតួអង្គ ។

- គ្រូឱ្យសិស្សអានសំនួនបញ្ចេញមតិក្នុងសៀវភៅទំព័រទី ២០ រួចសួរ :
  - តើអ្នកត្រូវប្រកាន់ជំហរយ៉ាងដូចម្តេច ដើម្បីជំរុញឱ្យការបញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿងមួយកាន់តែប្រសើរថែមទៀត ?

  ចម្លើយ : គេត្រូវ ៖

  + ស្វែងយល់សាច់រឿងឱ្យបានច្បាស់លាស់
  + ផ្អែកទៅលើសកម្មភាពតួអង្គជាមធ្យោបាយសំខាន់
  + ឈរលើឥរិយាបថជាអ្នកវិភាគត្រឹមត្រូវ មិនលំអៀង
  + ប្រើសំនួនបញ្ចេញមតិ ឬទស្សនៈឱ្យបានត្រឹមត្រូវដូចជា ខ្ញុំបញ្ជាក់ ... តាមយោបល់ខ្ញុំ ខ្ញុំគិតថា ... និយាយអីចឹងក៏ត្រូវម្យ៉ាងដែរ ... តែខ្ញុំគិតថា! ... ត្រឹមត្រូវហើយ! ខ្ញុំគាំទ្រគំនិត ... ព្រោះថា បើតាមគំនិតខ្ញុំ ខ្ញុំយល់ថា ... ។

ខ. ការនិយាយ

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗហ៊ឺកហ៊ាត់និយាយបញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង "ភ្នំនាងកង្រី" ម្នាក់ម្តងៗ សមាជិកក្រុមនីមួយៗត្រូវជួយកែលំអគ្នាទៅវិញទៅមក ។
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងនិយាយបញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង "ភ្នំនាងកង្រី" ។ គ្រូនិងសិស្សដទៃចូលរួមកែលំអ ។
- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ២០ ។

  ចម្លើយ :

១. ចំពោះមូលហេតុនៃការស្លាប់របស់នាងកង្រី មតិទី ១វាយតម្លៃថា : ដោយសារតែពុទ្ធិសែនបានចាកចេញទៅធ្វើឱ្យនាងយល់ច្រឡំថា នាងត្រូវពុទ្ធិសែនបោះបង់ចោល ព្រោះផ្តត់គំនិតខ្មែរតម្រូវឱ្យស្វាមីភរិយាមានចិត្តស្មោះត្រង់នឹងគ្នាគឺត្រូវមានភក្តីភាព ។ ពុទ្ធិសែន បានរៀបការជាមួយនាងកង្រីក្លាយជាប្តីប្រពន្ធទៅហើយ ដូច្នេះ ពុទ្ធិសែនត្រូវបញ្ជាក់ពីមូលហេតុនៃការចាកចេញរបស់ខ្លួនឱ្យបានច្បាស់លាស់ប្រាប់នាងកង្រីជាប្រពន្ធ ។

២. មតិទី ២វាយតម្លៃថា : ការស្លាប់របស់នាងកង្រីបណ្តាលមកពីនាងសន្ធមារជាម្តាយ មានចេតនាសម្លាប់មាតាធំទាំង ១១ និងមាតាបង្កើតរបស់ពុទ្ធិសែន ជាហេតុនាំឱ្យពុទ្ធិសែនត្រូវជ្រើសរើសយកអ្នកមានគុណជាការចាំបាច់គឺត្រូវស្រោចស្រង់ជីវិតលោកឡើងវិញ ។ ពុទ្ធិសែន មានទឹកចិត្តកតញ្ញូចំពោះអ្នកមានគុណ ដែលលោកកំពុងទទួលទារុណកម្មពីនាងសន្ធមារ ។

៣. គំនិតដែលឯកភាពគ្នាភាគច្រើន គឺការសម្រេចចិត្តរបស់ពុទ្ធិសែនក្នុងការជ្រើសរើសយកមាតាជាធំ ។

  + គំនិតនោះពួកគេបានឱ្យតម្លៃទៅលើកតញ្ញូតាធម៌
  + ការងារបន្ទាប់ គឺត្រូវដោះស្រាយជាមួយនាងកង្រី ពីព្រោះស្ថានភាពនាងកង្រីមិនបន្ទាន់ដូចការសង្គ្រោះជីវិតមនុស្ស ១២នាក់ទេ ដូច្នេះ ក្នុងនាមជាកូនកតញ្ញូ ពុទ្ធិសែនត្រូវតែហ៊ានពុះពារដើម្បីអ្នកមានគុណ ។

៤. ការវិភាគទាំងនោះ គេបានឈរលើកត្តា :

+ ការពិចារណាប្រកបទៅដោយមនសិការ ដោយការដឹងគុណ(កតញ្ញុតា)

+ ការទទួលខុសត្រូវចំពោះជោគវាសនានគរ(កំចាត់សន្ធមារដើម្បីភាពសុខសាន្តរបស់នគរទាំងមូល)

+ លក្ខណៈប្រាកដនិយម(មាតាកំពុងមានទុក្ខលំបាក កង្រឹមិនទទួលការលំបាកខ្លាំង) ។

កត្តាទាំងនេះសមស្រប ព្រោះជាដំណោះស្រាយតាមស្របតាមការពិចារណានិងតាមកាលៈទេសៈ ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សធ្វើលំហាត់បញ្ចេញមតិវាយតម្លៃតួអង្គក្នុងសៀវភៅសិស្សទំព័រទី ២០ :

- ក្រុមទី ១បញ្ចេញមតិវាយតម្លៃតួអង្គ "ព្រះបាទរថសិទ្ធិ"

ចម្លើយ : ព្រះអង្គពុំបានពិចារណាឱ្យល្អិតល្អន់ បណ្តោយតាមចិត្តនាងសន្ធមារដែលធ្វើឱ្យនាងទាំង ១២ស្ទើរតែបាត់បង់ជីវិត ។ ប៉ុន្តែក្រោយពេលដឹងច្បាស់ពីការពិត ព្រះអង្គក៏បានផ្តល់ឱកាសឱ្យពុទ្ធិសែនឡើងស្នងរាជ្យជំនួសព្រះអង្គ ។

- ក្រុមទី ២បញ្ចេញមតិវាយតម្លៃតួអង្គ "មហាឫសី" :

ចម្លើយ : មានការពិចារណាបានត្រឹមត្រូវ មានបំណងជួយបំពេញកតញ្ញុធម៌របស់ពុទ្ធិសែន រហូតបានសម្រេច ។ តួអង្គនេះ តំណាងអ្នកភាវសីលដែលឈរខាងភាវៈល្អ ។

សំយោគមតិ

១. វត្ថុបំណង

- ប្រាប់ពីបញ្ហត្តិនិងពីទម្រង់នៃសំណេរសំយោគបានត្រឹមត្រូវ
- សរសេរសំយោគគំនិត ឬទស្សនៈនានាបានច្បាស់លាស់និងត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២១-២៤
- ប្រជុំរឿងព្រេងខ្មែរភាគ ៥ ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៧ គ.ស.២០០៣ ។

៣. ដំណាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងសំណេរ "សំយោគមតិ" ដាក់លើក្តារខៀន រួចសួរ :
  - ដូចម្តេចដែលហៅថា ការសំយោគ ?

    ចម្លើយ : ជាការប្រមូលផ្តុំគំនិត ព័ត៌មាន ឬព្រឹត្តិការណ៍សំខាន់ៗដែលមាននៅក្នុងរបាយការណ៍ឬអត្ថបទនានា ។
  - តើការសំយោគនេះត្រូវធ្វើឡើងយ៉ាងដូចម្តេច ?

    ចម្លើយ : ត្រូវធ្វើឡើងសម្រាប់តែអត្ថបទឬគំនិតទាំងឡាយដែលស្ថិតក្នុងប្រធានបទរួមតែប៉ុណ្ណោះ ។
- គ្រូឱ្យសិស្សអានខ្លឹមសារសំយោគមតិគំរូក្នុងសៀវភៅសិស្សទំព័រទី ២១-២២ រួចគ្រូសួរសិស្ស :
  - តើសំយោគមតិនេះ មានទម្រង់យ៉ាងដូចម្តេច ?

    ចម្លើយ : មានទម្រង់ជាតែងសេចក្តី ដែលមានផ្តើមសេចក្តី តួសេចក្តី និងបញ្ចប់សេចក្តី ។
- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ២៣ :

  ចម្លើយ :

១. សំណេរនេះមាន ៤កថាខណ្ឌ ហើយមានផ្តើមសេចក្តី តួសេចក្តី បញ្ចប់សេចក្តី ។

២. កថាខណ្ឌនីមួយៗនិយាយពី :

ក. **កថាខណ្ឌទី ១ :**

+ ប្រភពអត្ថបទ : រឿងភ្នំនាងកង្រី ប្រជុំរឿងព្រេងខ្មែរភាគ ៥ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ និយាយទាក់ទងនឹងប្រវត្តិកកើត ទីកន្លែងក្នុងភូមិសាស្ត្រទីកដីខ្មែរនិងឆ្លុះបញ្ចាំងពីផ្នត់គំនិតខ្មែរ ។
+ ដំណើររឿង និយាយពីទស្សនៈពីរខុសគ្នាទៅលើមូលហេតុនៃការស្លាប់នាងកង្រី ។

ខ. **កថាខណ្ឌទី ២ :**

- **មតិទី ១ :** ការបាត់បង់ជីវិតរបស់នាងកង្រីបណ្តាលមកពីការចាកចេញរបស់ពុទ្ធិសែន :
  + នាំឱ្យនាងយល់ច្រឡំថា ពុទ្ធិសែនបោះបង់នាងចោល ព្រោះតាមផ្នត់គំនិតខ្មែរប្តីប្រពន្ធត្រូវរួមរស់ជាមួយគ្នានឹងស្មោះត្រង់នឹងគ្នាជារៀងរហូត ។
  + ពុទ្ធិសែនត្រូវបញ្ជាក់ពីមូលហេតុនៃការចាកចេញរបស់ខ្លួនឱ្យបានច្បាស់លាស់ ។

- **មតិទី ២** : ការបាត់បង់ជីវិតរបស់នាងកង្រីបណ្តាលមកពីនាងសន្ធមារ :
  + មានចេតនាសម្លាប់មាតាធំទាំង ១១ និងមាតាបង្កើតរបស់ពុទ្ធិសែន ដែលធ្វើឱ្យពុទ្ធិសែនត្រូវជ្រើសរើសយកអ្នកមានគុណជាការចាំបាច់ ដើម្បីឱ្យអ្នកមានគុណបានរួចផុតពីទារុណកម្មដ៏ឃោរឃៅដែលសន្ធមារបង្កឡើង(មាតាទាំងអស់ត្រូវគេខ្ទេះភ្នែក រស់នៅក្នុងរណ្តៅនិងអត់អាហារ)
  + ពុទ្ធិសែនត្រូវតែទៅជួយសង្គ្រោះអ្នកមានគុណ ដើម្បីបញ្ជាក់ថាខ្លួនជាកូនកតញ្ញូ ។
  + សន្ធមារជាសត្រូវរបស់គ្រួសារពុទ្ធិសែន ទោះជានាងកង្រីមានចិត្តចង់រស់នៅជាមួយនឹងពុទ្ធិសែនក៏ដោយ ក៏មិនប្រាកដថាមានសុភមង្គលដែរ ព្រោះពុទ្ធិសែនជាអ្នកសម្លាប់មាតានាង ។

គ. កថាខណ្ឌទី ៣ : បង្ហាញនូវគំនិតពីរផ្សេងគ្នា ៖

- ក្រុមទី ១ :
  + មិនគាំទ្រអំពើរបស់ពុទ្ធិសែន ដោយសារតែពុទ្ធិសែនដែលបានចាកចេញទៅធ្វើឱ្យនាងយល់ច្រឡំថាខ្លួនត្រូវពុទ្ធិសែនបោះបង់ចោល ។
  + តាមផ្នត់គំនិតខ្មែរតម្រូវឱ្យស្វាមីភរិយាមានចិត្តស្មោះត្រង់គឺរក្សាភក្តីភាពរវាងគ្នានឹងគ្នា ។
  + នាងកង្រីបានចាត់ទុកពុទ្ធិសែនជាប្តី ដែលនាំឱ្យនាងយំសោករហូតដល់ស្លាប់នៅកណ្តាលព្រៃ ។
- ក្រុមទី ២ :
  + គាំទ្រចំពោះអំពើពុទ្ធិសែន ព្រោះថាបើឱ្យនាងកង្រីដឹងផែនការរបស់ខ្លួននោះនឹងត្រូវបរាជ័យមិនខាន ព្រោះនាងកង្រីនឹងអាចរិះរកមធ្យោបាយរារាំងដំណើរពុទ្ធិសែនមិនឱ្យទៅជួយអ្នកមានគុណ ។
  + ព្រះអង្គមានទឹកចិត្តកតញ្ញូចំពោះអ្នកមានគុណ ដែលលោកកំពុងរងការឈឺចាប់ដោយទទួលទារុណកម្មពីនាងសន្ធមារ ។
  + ក្នុងស្ថានភាពនេះ ពុទ្ធិសែនត្រូវប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកបំផុត(ម្ខាងគឺម្តាយ ម្ខាងទៀតប្រពន្ធ) បញ្ហាទាំងពីរនេះ បានតម្រូវឱ្យពុទ្ធិសែនជ្រើសរើសយកផ្លូវតែមួយ ។
  + ការសម្រេចចិត្តនេះពិតជាត្រឹមត្រូវ ព្រោះស្ថានភាពនាងកង្រី មិនលំបាកដូចមាតាពុទ្ធិសែនទេ ។
  + ក្នុងនាមជាកូនកតញ្ញូ ពុទ្ធិសែនត្រូវតែហ៊ានពុះពារដើម្បីអ្នកមានគុណ ។

ឃ. កថាខណ្ឌទី ៤ : បង្ហាញនូវគំនិតពីរផ្សេងគ្នា

  + បានបង្ហាញឱ្យឃើញថា មូលហេតុនៃការស្លាប់របស់នាងកង្រីគឺបណ្តាលមកពីពុទ្ធិសែនមែន ។
  + តែទង្វើនេះ ពោរពេញទៅដោយអត្ថន័យសំខាន់ក្នុងការបញ្ជាក់ពីគំនិតរបស់ជនជាតិខ្មែរ តែងតែបណ្តុះនូវទឹកចិត្តកតញ្ញូរបស់កូនចំពោះអ្នកមានគុណ ។
  + ផ្នត់គំនិតនេះតែងតែដក់ជាប់ក្នុងក្រអៅបេះដូងកូនខ្មែរគ្រប់រូប ។
  + ដូច្នេះ ក្នុងនាមជាកូនល្អម្នាក់ គប្បីប្រកាន់នូវគុណធម៌ខាងលើនេះ ហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីសង្គ្រោះជីវិតមនុស្សច្រើននាក់ ។ ទង្វើបែបនេះ ទើបស័ក្តិសមជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អពិតប្រាកដ ។

២. ការអនុវត្ត

- ឱ្យសិស្សបង្កើតគម្រោងតែងលម្អិតក្នុងសំណេរសំយោគឧទាហរណ៍តាមគម្រោងក្នុងសៀវភៅសិស្សទំព័រទី ២៣-២៤ :

ក. ផ្តើមសេចក្តី

- បង្ហាញគំនិតអត្ថបទ : រឿងភ្នំនាងកង្រីក្នុងប្រជុំរឿងព្រេងខ្មែរភាគ ៥ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យនិយាយទាក់ទងនឹងប្រវត្តិកកើតភូមិសាស្ត្រទឹកដីខ្មែរនិងផ្នត់គំនិតខ្មែរ .... ។
- បញ្ជាក់ប្រធានបទ : ដំណើររឿងមានប្រធានមួយ ដែលនិយាយពីទស្សនៈពីរខុសគ្នាទៅលើមូលហេតុនៃការស្លាប់នាងកង្រី ។

ខ. តួសេចក្តី

- បញ្ជីគំនិតសំខាន់ក្នុងមតិទី ១ : ការបាត់បង់ជីវិតរបស់នាងកង្រីបណ្តាលមកពីការចាកចេញរបស់ពុទ្ធិសែន :
  + នាំឱ្យនាងយល់ច្រឡំថា ពុទ្ធិសែនបោះបង់នាងចោល ព្រោះតាមផ្នត់គំនិតខ្មែរ ប្តីប្រពន្ធត្រូវរួមរស់ជាមួយគ្នានិងស្មោះត្រង់នឹងគ្នាជារៀងរហូត ។
  + ពុទ្ធិសែនត្រូវបញ្ជាក់ពីមូលហេតុនៃការចាកចេញរបស់ខ្លួនឱ្យបានច្បាស់លាស់ ។
- បញ្ជីគំនិតសំខាន់ក្នុងមតិទី ២ : ការបាត់បង់ជីវិតរបស់នាងកង្រីបណ្តាលមកពីនាងសន្ធមារ :
  + មានចេតនាសម្លាប់មាតាធំទាំងដប់មួយនិងមាតាបង្កើតរបស់ពុទ្ធិសែនដែលធ្វើឱ្យពុទ្ធិសែនត្រូវជ្រើសរើសយកអ្នកមានគុណជាការចាំបាច់ ដើម្បីជួយអ្នកមានគុណឱ្យរួចផុតពីទារុណកម្មដ៏សាហាវដែលបង្កឡើងដោយនាងសន្ធមារ(មាតាទាំងអស់ត្រូវគេខ្វះភ្នែក រស់នៅក្នុងរណ្តៅអត់អាហារ) ។
  + សន្ធមារជាសត្រូវរបស់គ្រួសារពុទ្ធិសែន ទោះជានាងកង្រីមានចិត្តចង់រស់នៅជាមួយគ្នានឹងពុទ្ធិសែនក៏ដោយ ក៏មិនប្រាកដថា មានសុភមង្គលដែរ ព្រោះពុទ្ធិសែនជាអ្នកសម្លាប់មាតានាងកង្រី ។
- សរុប : ដូច្នេះ យើងអាចសំយោគពីមូលហេតុនៃការស្លាប់របស់នាងកង្រីដូចតទៅ ៖
  + មិនគាំទ្រអំពើរបស់ពុទ្ធិសែន ដោយសារតែពុទ្ធិសែន បានចាកចេញពីនាងកង្រីទៅធ្វើឱ្យនាងយល់ច្រឡំថា ខ្លួនត្រូវពុទ្ធិសែនបោះបង់ចោល ព្រោះតាមផ្នត់គំនិតខ្មែរ តម្រូវឱ្យស្វាមីភរិយាមានចិត្តស្មោះត្រង់ ចេះរក្សាភក្តីភាពរវាងគ្នានិងគ្នា ។
  + ពុទ្ធិសែនត្រូវបញ្ជាក់ពីមូលហេតុនៃការចាកចេញរបស់ខ្លួនឱ្យបានច្បាស់លាស់ ។
  + គាំទ្រចំពោះអំពើពុទ្ធិសែន ព្រោះថា បើឱ្យនាងកង្រីដឹងផែនការរបស់ខ្លួននោះនឹងត្រូវបរាជ័យជាមិនខាន ព្រោះនាងកង្រីនឹងអាចរារាំងពុទ្ធិសែនមិនឱ្យទៅជួយអ្នកមានគុណ ។
  + ព្រះអង្គមានទឹកចិត្តកតញ្ញូចំពោះអ្នកមានគុណ ដែលលោកកំពុងរងការឈឺចាប់ដោយទទួលទារុណកម្មពីនាងសន្ធមារ ។
  + ក្នុងស្ថានភាពនេះពុទ្ធិសែនត្រូវប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកបំផុត (ម្ខាងម្តាយ ម្ខាងទៀតប្រពន្ធ) បញ្ហាទាំងពីរនេះបានតម្រូវឱ្យពុទ្ធិសែនជ្រើសរើសយកផ្លូវតែមួយ ។
  + ការសម្រេចចិត្តរបស់ពុទ្ធិសែនពិតជាត្រឹមត្រូវ ព្រោះស្ថានភាពនាងកង្រីមិនលំបាកដូចមាតាពុទ្ធិសែនឡើយ ។
  + ក្នុងនាមជាកូនកតញ្ញូ ពុទ្ធិសែនត្រូវតែហ៊ានពុះពារនិងលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីអ្នកមានគុណ ។

គ. បញ្ចប់សេចក្តី

- បញ្ជាក់មូលហេតុនៃការជ្រើសរើសប្រធានបទមកសិក្សា : ការស្លាប់របស់នាងកង្រី គឺបណ្តាលមកពីពុទ្ធិសែនមែន តែទង្វើនេះ ពោរពេញទៅដោយអត្ថន័យសំខាន់ក្នុងការបញ្ជាក់ពីគំនិតរបស់ជនជាតិខ្មែរ តែងតែបណ្តុះនូវទឹកចិត្តកតញ្ញូរបស់កូនចំពោះអ្នកមានគុណ។ ផ្នត់គំនិតនេះតែងតែ ដក់ជាប់ក្នុងក្រអៅបេះដូងកូនខ្មែរគ្រប់រូប ដែលជាគុណធម៌របស់កូនចំពោះអ្នកមានគុណ។
- យោបល់របស់អ្នកសំយោគ :
  + ក្នុងនាមជាកូនល្អ ម្នាក់ៗគប្បីចេះប្រកាន់នូវគុណធម៌ខាងលើនេះ ហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីសង្គ្រោះជីវិតមនុស្សច្រើននាក់។
  + ក្នុងជីវភាពរស់នៅ ការសង្គ្រោះជីវិតមនុស្សទាមទារការលះបង់ តែគេក៏អាចរកវិធីល្អជាងនេះ ដើម្បីរស់នៅបានសុខទាំងអស់គ្នា ទើបសក្តិសមជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អពិតប្រាកដ។

គ. ការវាយតម្លៃ

- ឱ្យសិស្សរកគម្រោងលំអិតក្នុងលំហាត់សៀវភៅសិស្សទំព័រទី ២៣ :

គម្រោង : ខាងក្រោមនេះជាចម្លើយ ដោយយកតែផ្នែកផ្នត់គំនិតសំខាន់ៗក្នុងអំណាន "ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ" និង "ភ្នំនាងកង្រី" :

ក. ផ្តើមសេចក្តី

- បង្ហាញគំនិតអត្ថបទ : រឿងភ្នំនាងកង្រីក្នុងប្រជុំរឿងព្រេងខ្មែរភាគ ៥ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យនិយាយទាក់ទងនឹងប្រវត្តិកកើតភូមិសាស្ត្រទឹកដីខ្មែរនិងផ្នត់គំនិតខ្មែរ រីឯអត្ថបទការវិវត្តនៃអក្សរសិល្ប៍ខ្មែរ បានដកស្រង់ចេញពីសៀវភៅអរិយធម៌ខ្មែររបស់អ្នកស្រី ត្រឹងងា នៅឆ្នាំ ១៩៧៥ ក៏បានបង្កប់ផ្នត់គំនិតខ្មែរសំខាន់ៗជាច្រើនដែរ។
- បញ្ជាក់ប្រធានបទ : ចំពោះខ្លឹមសារនៃអត្ថបទទាំងពីរនេះ គឺមានប្រធានបទរួមមួយដែលនិយាយពីផ្នត់គំនិតខ្មែរ។

ខ. តួសេចក្តី

- បញ្ជីផ្នត់គំនិតសំខាន់ក្នុងរឿងភ្នំនាងកង្រី :
  + ជំនឿអរូបី : ប្រជារាស្ត្រមានជំនឿទៅលើការបន់ស្រន់ចំពោះវត្ថុសក្តិសិទ្ធិ ដូចជាមហាសេដ្ឋីបានបន់ស្រន់ដើមជ្រៃសូមឱ្យមានកូនក៏បានសម្រេចតាមបំណង "កាលពីព្រេងនាយ មានសេដ្ឋីនៅគនរមួយជាមនុស្សឥតកូនបាននាំប្រពន្ធទៅបន់សុំកូននៅដើមជ្រៃមួយ។ ក្រោយពីបន់ ប្រពន្ធមានកូន ១២នាក់សុទ្ធតែស្រី"។
  + ជំនឿកម្មផល : រាល់អំពើដែលគេបានកសាងនឹងបានទទួលផលពីអំពើនោះជានិច្ចនៅក្នុងពេលណាមួយ ដូចជានាងទាំង ១១ដោតភ្នែកត្រីទាំងសងខាង ក៏ត្រូវគេខ្វះភ្នែកទាំងសងខាង។ រីឯនាងពៅឬនាងទី ១២ដោតភ្នែកត្រីតែម្ខាងក៏ត្រូវគេខ្វះភ្នែកតែម្ខាងដែរ។
  + ប្រពៃណីអាពាហ៍ពិពាហ៍ : មង្គលការត្រូវរៀបចំឡើងនៅផ្ទះខាងស្រីដែលត្រូវទៅតាមអត្តសញ្ញាណនៃជនជាតិខ្មែរដែលមានប្រពៃណីរៀបចំមង្គលការនៅគេហស្ថានខាងស្រី។ តួយ៉ាងពុទ្ធិសែនរៀបការជាមួយនាងកង្រីនៅនគរនាងកង្រី។

+ ភាពកតញ្ញូ : ការបែងចែករវាងវិចារណៈនិងសញ្ចេតនា ក៏បានផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតខ្មែរដែរ ។ បើភាពកតញ្ញូ (កិត្តិយស) និងភក្តីភាព(ស្នេហា) ។ ចំណុចទាំងពីរនេះតម្រូវឱ្យពុទ្ធិសែនជ្រើសរើសបានផ្លូវតែមួយគត់ ។ ម្យ៉ាងវិញទៀត ជនជាតិខ្មែរនិយមគោរពនិងជឿងគុណចំពោះមាតាបិតា គ្រូឧបជ្ឈាយ៍ ឬបុព្វបុរសខ្លួន ។ ដូច្នេះហើយ ទើបពុទ្ធិសែនដែលសុខចិត្តចាកចេញពីនាងកង្រីទៅជួយសង្គ្រោះអ្នកមានគុណ ។
+ ភក្តីភាព : ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ក៏នារីខ្មែរតែងតែរក្សានូវភាពស្មោះត្រង់ជានិច្ចចំពោះស្វាមី ។ ដោយសារការរក្សាភក្តីភាពនិងភាពស្មោះត្រង់នេះ ទើបនាងកង្រីព្យាយាមរត់តាមពុទ្ធិសែនរហូតដល់បាត់បង់ជីវិតកណ្តាលព្រៃ ។

- បញ្ជីផ្នត់គំនិតសំខាន់ក្នុងអត្ថបទការវិវត្តនៃអក្សរសិល្ប៍ខ្មែរ ។
- ឥទ្ធិពលព្រះពុទ្ធសាសនាបានជំរុញឱ្យមានការតែងនិពន្ធជាស្នាដៃតាមគោលគំនិតអប់រំនៅក្នុងស្នាដៃនានាដូចជា :
  + "ល្បើកអង្គរ" គ.ស. ១៦០៩ របស់អ្នកប៉ាង
  + "ច្បាប់ព្រះរាជសម្ភារ"គ.ស. ១៦២២ "ហោមន្តមាស"គ.ស. ១៦២៩ "ហឺនលក្ខណ៍"គ.ស. ១៦៣០ "កាព្យនិរាស"គ.ស. ១៦៦០ របស់ព្រះរាជសម្ភារ
  + សិលាចារឹក គ.ស. ១៧០១ របស់បណ្ឌិតជ័យន្ទន
  + រឿង "ក្រុងសុភមិត្រ" គ.ស. ១៧៩៨ របស់ឧកញ៉ាកោសាធិបតីកៅ
  + "ច្បាប់សុភាសិត"គ.ស. ១៧៩០ "លោកនេយ្យជាតក"គ.ស. ១៧៩៤ "បុញ្ញសារសិរសា"គ.ស. ១៧៩៧ "ភោគកុលកុមារ"គ.ស. ១៨០៤ របស់ឧកញ៉ាព្រះឃ្លាំងនង
  + រឿងទេវន្ត ល្បើកចចក រឿងទុំទាវ របស់ឧកញ៉ាសន្ធរវោហារម៉ុក
  + ល្បើកជុចនិងត្រី ល្បើកជូជក របស់វិសេសជួង
  + "ចម្ប៉ាថោង" គ.ស. ១៨១០ "រឿងកាកី" គ.ស. ១៨១៥ "ច្បាប់ស្រី"គ.ស.១៨៣៧ "រឿងមហាវេស្សន្តរ" (ជាពាក្យរាយ) របស់ព្រះបាទអង្គឌួង ។
- គេនិយមប្រើភាសាបាលីសំស្ក្រឹតក្នុងការចារឹករឿងរ៉ាវ ព្រឹត្តិការណ៍ផ្សេងៗទាក់ទងនឹងប្រវត្តិសាស្ត្រ និងសាសនា ដូចជាសិលាចារឹករ៉ូកាញ់ សិលាចារឹកអង្គរបូរី (គ.ស.៦១១)សិលាចារឹកនានានៅសម័យមុនអង្គរ ។
  + គេឃើញមានការគោរពលទ្ធិព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយាន ហើយលទ្ធិទាំងនេះបានផ្សាយឥទ្ធិពលរបស់ខ្លួនទៅលើជីវភាពនិងចិត្តគំនិតខ្មែរទូទៅ ។
- សរុបការសំយោគ : ក្នុងអត្ថបទទាំងពីរខាងលើនេះបានបង្ហាញពី ៖
  + ជំនឿរាស្ត្រខ្មែរទៅលើការបន់ស្រន់ចំពោះវត្ថុស័ក្តិសិទ្ធ ទៅលើកម្មផល ។
  + ប្រពៃណីក្នុងការរៀបអាពាហ៍ពិពាហ៍នៅផ្ទះខាងស្រី ។
  + កតញ្ញូតាធម៌ ដែលជនជាតិខ្មែរនិយមប្រតិបត្តិចំពោះមាតាបិតា គ្រូឧបជ្ឈាយ៍ ឬបុព្វបុរសខ្លួន ។
  + ភក្តីភាព នារីខ្មែរតែងតែរក្សានូវភាពស្មោះត្រង់ជានិច្ចចំពោះស្វាមី ។
  + ឥទ្ធិពលរបស់ព្រះពុទ្ធសាសនាដែលមាននៅក្នុងការតែងនិពន្ធរឿងព្រេង ប្រលោមលោក និងអត្ថបទផ្សេងៗ ។

+ ការនិយមប្រើភាសាបាលីសំស្ក្រឹតក្នុងការចារឹកព្រឹត្តិការណ៍ រឿងរ៉ាវដែលភាគច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រនិងសាសនា ។

+ ការគោរពលទ្ធិព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយាន ។

- សរុប : ក្នុងអត្ថបទទាំងពីរខាងលើ យើងអាចសំយោគគំនិតដូចតទៅ :

+ រាស្ត្រខ្មែរជឿទៅលើការបន់ស្រន់ចំពោះវត្ថុស័ក្តិសិទ្ធិ ជឿទៅលើកម្មផល ។

+ គេនិយមរៀបអាពាហ៍ពិពាហ៍នៅផ្ទះខាងស្រី ។

+ ជនជាតិខ្មែរនិយមគោរព និងដឹងគុណទំនុកបម្រុងចំពោះមាតាបិតា គ្រូឧបជ្ឈាយ៍ ឬបុព្វបុរសខ្លួន ។

+ នារីខ្មែរតែងតែរក្សានូវភាពស្មោះត្រង់ជានិច្ចចំពោះស្វាមី ។

+ ព្រះពុទ្ធសាសនាមានឥទ្ធិពលលើការតែងនិពន្ធជាស្នាដៃផ្សេងៗ ។

+ អ្នកចេះដឹងខ្មែរនិយមប្រើភាសាបាលីសំស្ក្រឹតក្នុងការចារឹកព្រឹត្តិការណ៍ រឿងរ៉ាវផ្សេងៗ ។

+ ជនជាតិខ្មែរពេលនោះ គោរពលទ្ធិព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយាន ។

គ. បញ្ចប់សេចក្តី

- បញ្ជាក់មូលហេតុនៃការជ្រើសរើសប្រធានបទមកសិក្សា :

+ ផ្នត់គំនិតទាំងនោះសុទ្ធតែបង្ហាញពីជីវភាពខ្មែរពិតៗ ។

+ ការលើកយកផ្នត់គំនិតខ្មែរមកសិក្សា ដើម្បីស្វែងយល់ពីព្រលឹងជាតិ ដែលដូនតាខ្មែរបានបន្សល់ទុកឱ្យកូនខ្មែរជំនាន់ក្រោយសម្រាប់ធ្វើការសិក្សារៀនសូត្រ និងត្រិះរិះពិចារណា ។

- យោបល់របស់អ្នកសំយោគ :

ក្នុងនាមជាយុវជនជំនាន់ក្រោយ យើងគប្បីចេះប្រកាន់ឱ្យខ្ជាប់ខ្ជួននូវផ្នត់គំនិតជាតិខ្មែរណាដែលល្អ ដែលមានប្រយោជន៍និងដែលរីកចម្រើនដើម្បីឱ្យសង្គមជាតិយើងមានការអភិវឌ្ឍប្រកបដោយចីរភាព ។



ទំនៀមទម្លាប់

ប្រជាជនខ្មែរ ជាប្រជាជនដែលធ្លាប់មានវប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អផូរផង់តាំងពីយូរយារណាស់មកហើយ។

មេរៀននេះមានបំណងបង្ហាញឱ្យឃើញពីទំនៀមទម្លាប់ប្រពៃណីខ្មែរមួយចំនួន ដែលប្រជាជនយើងធ្លាប់គោរពប្រតិបត្តិ។ តាមរយៈមេរៀននេះ សិស្សនឹងទទួលបាននូវចំណេះដឹងនិងទស្សនៈយល់ឃើញមួយចំនួនទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ ជំនឿ សាសនា។ល។ ហើយមានស្មារតីចូលរួមថែរក្សាការពារនិងឱ្យតម្លៃទៅលើទំនៀមទម្លាប់និងប្រពៃណីជាតិរបស់ខ្លួន ប្រកបដោយស្មារតីជាតិនិយមនិងមោទនភាពជាតិខ្ពស់។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិវាសាស្ត្រ	ទិវាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	២៧	២៥
• រំលឹកបញ្ញត្តិ : សញ្ញាសំគាល់ប្រើក្នុងកំណាព្យ	១ម៉ោង	១ម៉ោង	២៨-២៩	២៦
• អំណានទី ១ : នំមិនធំជាងនាឡិ	២ម៉ោង	៤ម៉ោង	៣០-៣៤	២៨
• បំណិន : កំណាព្យបទទ្វេមាត្រ	២ម៉ោង	២ម៉ោង	៣៥-៣៦	៣៣
• វេយ្យាករណ៍ : កម្លាយផ្គត់ជែក	២ម៉ោង	២ម៉ោង	៣៧-៣៨	៣៦
• អំណានទី ២ : ប្រពៃណីនៅពេលកើត	៣ម៉ោង	៤ម៉ោង	៣៩-៤១	៣៨
• ការស្តាប់ : ជំនឿ	២ម៉ោង	២ម៉ោង	៤២-៤៥	៤២
• ការនិយាយ : ការបញ្ចេញមតិ	០ម៉ោង	២ម៉ោង	៤៦-៤៧	៤៣
• សំណេរ : ការតែងកំណាព្យ	០ម៉ោង	៤ម៉ោង	៤៨-៥០	៤៥

១. សិក្ខាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ២៥ មេរៀនទី ២ អានចំណងជើងមេរៀន។ លោកគ្រូ-អ្នកគ្រូ សរសេរចំណងជើងមេរៀន "ទំនៀមទម្លាប់" ដាក់លើក្តារខៀនរួចសួរ :
  - តើចំណងជើងមេរៀននេះមានន័យដូចម្តេច ?

    ចម្លើយ : មានន័យថាការធ្វើអ្វីមួយទៅតាមបែបបទ សណ្តាប់ធ្នាប់ ឬរបៀបរៀបរយ ដែលធ្លាប់មាន ធ្លាប់ប្រព្រឹត្តពីមុនមក។

២. សិក្ខាលើរូបភាព

- ឱ្យសិស្សពិនិត្យរូបភាពមេរៀនក្នុងសៀវភៅសិស្សទំព័រទី ៣៣ រួចសួរ ៖
  - តើនេះជារូបភាពអ្វី ?

    ចម្លើយ : ជារូបភាពបង្ហាញពីពិធីមង្គលការឬពិធីរៀបអាពាហ៍ពិពាហ៍។
  - តើមនុស្សទាំងអស់នៅក្នុងរូបភាពនេះកំពុងធ្វើអ្វី ?

    ចម្លើយ : មនុស្សទាំងអស់នៅក្នុងរូបភាពនេះ កំពុងសំពះព្រះសង្ឃសូត្រមន្ត ... ។
- ឱ្យសិស្សម្នាក់ៗអានសេចក្តីផ្តើមនៃមេរៀនក្នុងសៀវភៅសិស្សទំព័រទី ២៥ដោយស្ងៀមស្ងាត់។

រំលឹកបញ្ញត្តិ : សញ្ញាសំគាល់ដែលប្រើប្រាស់ក្នុងកំណាព្យនិងកាព្យរូបារម្មណ៍

១. វត្ថុបំណង

- ប្រាប់បានពីសញ្ញាជួន ផ្ទួន រណ្តំ ដែលប្រើក្នុងកំណាព្យនិងអក្សរកាត់
- កំណត់បានពីន័យនៃកាព្យរូបារម្មណ៍តាមរយៈឧទាហរណ៍បញ្ជាក់ឡើងវិញបានត្រឹមត្រូវ
- បញ្ជាក់បានច្បាស់លាស់ពីប្រភេទកាព្យរូបារម្មណ៍ផ្សេងៗដូចជា បំរៀបន័យរូបារម្មណ៍ ឧបមានរូបារម្មណ៍ និង រូបារូប្យារម្មណ៍ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២៦-២៧ ។

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀនរំលឹកបញ្ញត្តិ "សញ្ញាសំគាល់ដែលប្រើប្រាស់ក្នុងកំណាព្យនិងកាព្យរូបារម្មណ៍" លើក្តារខៀន រួចឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ២៦ អានចំណុច ក ខ និង គ ។
- គ្រូណែនាំសិស្សឱ្យសង្កេតនិងបកស្រាយឡើងវិញពីសញ្ញាគូសលើព្យាង្គជួន ផ្ទួន រណ្តំ សញ្ញាជួន ផ្ទួន រណ្តំ និងអក្សរកាត់ ព្យាង្គ : ព្យ , ឃ្លា : ឃ , និង វគ្គ : វ ។
- គ្រូលើកឧទាហរណ៍វគ្គដកស្រង់ខាងក្រោមឱ្យសិស្សម្នាក់ឬពីរនាក់ឡើងបង្ហាញគំនូសលើព្យាង្គ ដែលសំគាល់ពាក្យជួន ផ្ទួន រណ្តំ រួចបកស្រាយសញ្ញាជួន ផ្ទួន រណ្តំ ដោយប្រើប្រាស់សញ្ញាជួន ផ្ទួន រណ្តំ និងអក្សរកាត់ព្យាង្គ ឃ្លា វគ្គ ឱ្យបានត្រឹមត្រូវ ៖

មើលដងទំនងព្រៃស្រងាត់	ដូចបងព្រាត់បាត់ពៅពិសី
សុក្រំៗចិត្តប្រពន្ធប្តី	ន្ធនស្រីដូចស្រីស្រស់នោមនាយ ។
មើលភ្នំធំធេងវែងរលីក	មើលទឹករលកលាមសាយ
មើលដីៗដុះវែងអន្លាយ	មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី ។

(សេកសាវិកា កាព្យសាស្ត្រខ្មែរ របស់លោក អ៊ឹង យ៉ែង លោក ឃុន ស្រ៊ុន ទំព័រទី ១១៩ បោះពុម្ពឆ្នាំ ១៩៧២)

ខ. ការហ្វឹកហាត់

- គ្រូឱ្យសិស្សអានខ្លឹមសារបញ្ញត្តិ "កាព្យរូបារម្មណ៍" ក្នុងសៀវភៅសិស្សទំព័រទី ២៦-២៧ និងអានចំណុច ក , ខ , គ រំលឹកឡើងមួយសាសិន ។
- គ្រូសួរសំណួរ ៖
  - ដូចម្តេចហៅថា កាព្យរូបារម្មណ៍ ?

    ចម្លើយ : ជារូបារម្មណ៍ដែលមានក្នុងអត្ថបទកាព្យ ។ រូបារម្មណ៍អាចមានក្នុងកាព្យបាន លុះណាតែកវីចេះជ្រើសរើសពាក្យពេចន៍ សំនួនសេចក្តី សំនួនគំនិត ...មករចនាឱ្យពាក្យជួនទាំងនោះមានសម្ផស្ស មានភាពរស់រវើក ពីរោះរណ្តំ ទាក់ទាញអ្នកអាន អ្នកស្តាប់ឱ្យជក់ចិត្ត ជក់អារម្មណ៍ ។

- ដូចម្តេចហៅថា បំរៀបន័យរូបារម្មណ៍ឬមេតាផរ ?

ចម្លើយ : ជារូបារម្មណ៍នៃទំហៀបដែលកើតឡើងពីការប្រៀបធៀប ដោយមិនប្រើចំណងធៀបដូចជា ភ្នំឆ្ពឹងស្ទឹងឈាម សមុទ្រទឹកភ្នែក នាវាជីវិត ក្បូនជីវិត ... ។ ជួនកាល កវីប្រៀបធៀបរវាងរូបីនិងអរូបី ហើយកវីធ្វើបដិសំយោគរវាងតួអង្គទាំងពីរ ដើម្បីប្រែក្លាយអង្គអរូបីឱ្យមានជីវិត មានចលនា មានចេតនា មានវិញ្ញាណ ។ល។ បែបនេះបង្កើតបានជាបុគ្គលិកកម្មដូចជា វាយោថ្នូចថ្នូរ ខ្យល់តួញឆ្លើយឆ្លង កម្តៅដុតរោលខ្លោចអស់ធម្មជាតិ ... ។

- ដូចម្តេចហៅថា ឧបមានរូបារម្មណ៍ ?

ចម្លើយ : ជារូបារម្មណ៍ដែលកើតឡើងពីការប្រៀបធៀបអង្គបង្គោលនិងទំហៀបពីរឬច្រើនដោយប្រើចំណងធៀប ។ ចំណងធៀបមានដូចជា ពាក្យប្រៀបដូច ហាក់ដូច ហាក់ដូចជា ដូចជា ប្រៀបបាន ច្រឡំនឹង ប្រហែលជាយ៉ាងណា យ៉ាងនោះ មិនបាន មិនខុសពី មិនជាជាង ។

ឧទាហរណ៍ : ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា
រាជសីហ៍ចើបានលំនៅជា មិនឱ្យឃ្លាតឃ្លាគុហាឡើយ ។

- ដូចម្តេចហៅថា រូបារូប្យារម្មណ៍ ?

ចម្លើយ : ជារូបារម្មណ៍ដែលកើតឡើងពីកវីប្រើប្រាស់ពាក្យពេចន៍ ឃ្លា ល្បះ សំនួនទាំងឡាយដែលទាក់ទងនឹងឥន្ទ្រីយរូបារម្មណ៍ កាមរូបារម្មណ៍ និមិត្តរូបារម្មណ៍ ទេវនារូបារម្មណ៍ សោតរូបារម្មណ៍ ចក្ខុរូបារម្មណ៍ ... ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សបង្ហាញពីគំនូសសញ្ញាជួន ផ្ចួន រណ្តំ និងបកស្រាយលើគំនូសសញ្ញាទាំងនោះ ៖

សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកំឡោះចាស់មេម៉ាយ
ក្រមុំតួងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់សព្ទភាសា ។

.....

ទាវអើយទាវស្រីសេចក្តីនេះ មាននេននោះចេះមើលសាស្ត្រា
សំឡេងស្រួយស្រាប់ស្តាប់ភាសា ដូចសត្វសារិកាពិសាចេក ។

.....

រួចនេនស្តាប់ជាក់ភ្ញាក់ព្រើតប្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ
យល់ទាវឈរស្ទបដើរវេរា ស្ទុះស្ទាចូលក្នុងស្លុងចេញក្រៅ ។
អើតអើមដកកច្រហាមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្តូតស្តឹងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពានា ។
នេនយល់ដូច្នោះក្នុងពោះព្រួច កាន់កួចកើតទុក្ខចុកឱរា
ឱរូបហ្នឹងហើយទាវពុំងា មិនងាកបំពារបំពេរន ។



នំមិនធំជាងនាឡិ

១. វត្ថុបំណង

- ប្រាប់បានពីរង្វាស់កាព្យ ចំណាប់ចុងចួន ផ្ទួន រណ្តំ និងខ្លឹមសារសំខាន់នៃអត្ថបទតាមរយៈការអានអត្ថបទកាព្យដកស្រង់ពីរឿងទុំទាវ
- កំណត់បានរូបារម្មណ៍មួយចំនួនក្នុងអត្ថបទកាព្យ តាមរយៈការអានអត្ថបទដកស្រង់ពីរឿងទុំទាវ
- បណ្តុះស្មារតីសិស្សឱ្យយល់និងចេះឱ្យតម្លៃទៅលើផ្នត់គំនិតនិងទស្សនៈសង្គមទាក់ទងទំនៀមទម្លាប់ខ្មែរក្នុងការទុកដាក់កូនចៅឱ្យមានគួរស្រករ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២៨-៣២
- សៀវភៅរឿងទុំទាវ ទំព័រទី ៤៥ ។

៣. ព័ត៌មានជំនួយ

ក្នុងមេរៀននេះ សិស្សនឹងសិក្សាអត្ថបទកាព្យដកស្រង់ពីរឿងទុំទាវ របស់ភិក្ខុ ងួន សោម ឆ្នាំ ១៩១៥ ។ លោកគ្រូអ្នកគ្រូត្រូវមានរឿងទុំទាវ សម្រាប់អាននិងបំផុសឱ្យសិស្សស្រាវជ្រាវរឿង ដើម្បីស្វែងយល់ខ្លឹមសាររឿងទាំងមូល ឬសង្ខេបចំណុចពាក់ព័ន្ធមុននឹងបង្រៀនអត្ថបទ អំណានដកស្រង់ ហើយភ្ជាប់ទៅគំនិតអត្ថបទដកស្រង់តែម្តង ។

៤. ដំណាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូសរសេរចំណងជើងអំណានអត្ថបទកាព្យដកស្រង់ពីរឿងទុំទាវ "នំមិនធំជាងនាឡិ" ដាក់លើក្តារខៀនរួចសួរសំណួរ ៖
  - តើអ្នកធ្លាប់ដឹងអ្វីខ្លះពីរឿទុំទាវ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើចំណងជើងអត្ថបទកាព្យ "នំមិនធំជាងនាឡិ" មានន័យដូចម្តេច ?

    ចម្លើយ : "នំមិនធំជាងនាឡិ" បើតាមន័យត្រង់មានន័យថា នំដែលជាចំណីសម្រាប់បរិភោគ ទោះនំប្រភេទអ្វីក៏ដោយក៏មិនដែលធំជាងនាឡិ ដែលជារង្វាស់មួយប្រភេទសម្រាប់ដាក់របស់របរផ្សេងៗមានដូចជា អង្ករ ជាដើម ។ ដូច្នេះ អ្វីតែងតែតូចជាងនាឡិ ហើយអាចដាក់ក្នុងនាឡិបាន ពុំនោះទេវានឹងកំពប់ហៀរចេញក្រៅចោលទទេជាពុំខាន ។ តាមន័យធៀបគេចង់និយាយ ឬប្រដូចកូនទៅនឹងនំ ហើយនាឡិប្រដូចទៅនឹងម្តាយឪពុក អ្នកមានគុណ ។ល ។ ដែលតាមទំនៀមទម្លាប់ខ្មែរពាក្យនេះនិយមប្រើក្នុងគ្រួសារទូទៅតាំងពីសម័យដើមមកម្ល៉ះ ហើយរហូតក្លាយជាប្រពៃណី ទំនៀមទម្លាប់មួយសម្រាប់គ្រប់គ្រងកូនចៅ ទូន្មានកូនចៅនៅក្នុងគ្រួសារឱ្យធ្វើអ្វីមួយតាមពាក្យទូន្មាន ឬតាមបំណងឪពុកម្តាយដូចជា ក្នុងការរស់នៅហូបចុក ស្លៀកពាក់ជាដើមផង កុំឱ្យខុសឆ្គងរំលងចិត្ត រំលងប្រពៃណី ទំនៀមទម្លាប់ខ្មែរ ។ ម្យ៉ាងទៀត

ឪពុកម្តាយប្រដៅកូនចៅកុំព្រហើនកោងកាច ឥតសីលធម៌ ឥតគោរពកោតខ្លាចអ្នកមានគុណ គ្រូបាធ្យាយជាដើមឱ្យល្អ បើពុំនោះទេច្បាស់ជាគេថា "នំធំជាងនាឡិ" ជាពុំខានឡើយ។ ដូច្នេះ កូនត្រូវគោរពស្តាប់បង្គាប់តាមការអប់រំ ដំបូន្មានល្អៗរបស់ឪពុកម្តាយ លោកគ្រូអ្នកគ្រូ ហើយយកដំបូន្មានល្អៗនោះទៅអនុវត្តក្នុងជីវិតរស់នៅរបស់ខ្លួនឱ្យបានជាប់ជាប្រចាំ។

- ឱ្យសិស្សមើលរូបភាពអំណានក្នុងសៀវភៅសិស្សទំព័រទី ២៨ រួចសួរសំណួរ ៖

  - តើអ្នកឃើញអ្វីខ្លះនៅលើរូបភាពនេះ ?

  ចម្លើយ : ឃើញមានរូបស្ត្រី ៣នាក់ មានវ័យចំណាស់ជាងគេ ឯរូបស្រីពីរនាក់ទៀតមានវ័យក្មេង ម្នាក់កំពុងអង្គុយបត់ជើងលើត្រែ និងម្នាក់ទៀតកំពុងឈរជិតសសរហាក់កំពុងឈរស្តាប់គេនិយាយគ្នា។

  - តើរូបភាពនេះមានន័យដូចម្តេច ?

  ចម្លើយ : រូបភាពស្ត្រីវ័យចំណាស់ម្នាក់ដែលកំពុងឈរច្រត់ចង្កេះ សម្តែងទឹកមុខខឹងសម្បារ ទំនងជាកំពុងស្តីឱ្យនាងក្រមុំដែលអង្គុយលើត្រែ ហើយនាងក្រមុំនោះអង្គុយឱនមុខចុះហាក់មិនសូវសប្បាយចិត្តនឹងការស្តីបន្ទោស ឬការទូន្មាននោះ។ ឯស្រីម្នាក់ទៀតឈរជិតសសរ ហាក់ដូចជាលបស្តាប់ការនិយាយឆ្លើយឆ្លងគ្នារបស់អ្នកទាំងពីរ ... ។

- គ្រូឱ្យសិស្សសិក្សាពាក្យគន្លឹះ ក្នុងសៀវភៅសិស្សទំព័រទី ២៨ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារការអភិវឌ្ឍបំណិនក្នុងសិស្សទំព័រទី ២៩ ត្រង់ចំណុច (ខ)
- ឱ្យសិស្សអានសំណួរក្នុងសិស្សទំព័រទី ៣២
- ឱ្យសិស្ស ៤-៥ នាក់អានឮៗអត្ថបទកាព្យដកស្រង់ "នំមិនធំជាងនាឡិ" ក្នុងសៀវភៅសិស្សទំព័រទី ២៩-៣២ បន្តគ្នា ឬបណ្តាក់គ្នា ឯសិស្សដទៃទៀតអានដោយស្ងៀមស្ងាត់ ។

គ. ពង្រឹងអំណាន

ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ៣២ ។

ចម្លើយ :

១. អត្ថបទកាព្យនេះ ដកស្រង់ចេញពីរឿងទុំទាវ។ អ្នកនិពន្ធឈ្មោះ ងួន សោម និពន្ធនៅឆ្នាំ ១៩១៥ ។

២. អត្ថបទនេះមានគំនិតសំខាន់ៗចំនួន ៥ ៖

+ **គំនិតសំខាន់ទី ១ :** អរជួននិងភរិយាជំនុំគ្នារើសរកគូស្រករឱ្យ "ម៉ឺនងួន" ជាកូនដោយរកអ្នកចែចូវនាងទាវមកធ្វើជាកូនប្រសា ព្រោះតិតល្បីថា ទាវស្អាត ... ។

[...] យើងនឹងឈប់ស្លេះបង្អង់នៅ	រឿងពេជ្រទុំទៅដល់តួងឃ្មុំ
និងថ្លែងដំណើរអរជួនជំ-	នុំនឹងភរិយាជាប្រពន្ធ។
ថានែប្អូនស្ងួនឆួនខ្លឹមចិត្ត	យើងគួរគិតតិតបងមានបុណ្យ
មានបុត្រស្រីប្រុសរបស់ធន	បណ្តាមហាជនជុំក្រាស់ក្រួន ។

បងឮអស់រាស្ត្រប្រជាជាក់ នឹយាយមិនលាក់ដូចមាំមួន
ប្រាយប្រាប់ដោយស័ព្ទសក្តិសមសួន កូនគេផងខ្លួនដូចងួនយើង ។
នាងនោះមានម្តាយមេម៉ាយសោះ ប៉ុន្តែរបស់តាមទំនើង
មែនមានបាវព្រាវប្រើលាងជើង ថ្កុំថ្កើងគ្រប់សព្វចប់ដល់ចាស់ ។
ប្រពន្ធបានស្តាប់ចាប់ចិត្តធំ ជឿជាសួនសមមិនទាន់ច្បាស់

.....

ឱ្យទៅស្រដីខាងមេបា នាងទាវតើថាប្រការម្តេច ។

+ **គំនិតសំខាន់ទី ២ :** ប្រពន្ធអរជូន បន្ទាប់ពីដំនុំនិងប្តី រើសអ្នកចេះរោហារខាងចែចូវដើម្បីនាំផ្លូវស្តីដណ្តឹងទាវឱ្យ ម៉ឺនងួនរួច ក៏ឱ្យអ្នកបម្រើរៀបចំជំនូន បណ្ណាការសព្វសារពើដើម្បីធ្វើដំណើរទៅផ្ទះម្តាយទាវ ស្តីដណ្តឹងទាវតាម ប្រពៃណី ឯម្តាយទាវយល់ព្រមតែចាំសួរចិត្តកូនសិន ។

ប្រពន្ធអរជូនជំនូនស្រាប់ ភ្ញុំគ្នាប្រញាប់រាន់រំពេច
យកសព្វភោជផលថ្កល់និងវេច រៀបរួចស្រាប់ស្រេចគ្រាច់ចរចេញ ។
លីលាលយលង់ជានដងផ្លូវ ត្រូវត្រង់មាគ៌ាឃ្លាតខ្ទួលខ្ទាញ់
ខំស្រូតរូតរះកាត់ត្រោកត្រាញ់ អរញ្ញវាលព្រៃរំពៃយល់ ។
ក្រឡេកក្រលៀងឆ្ងៀងពីអាយ ច្បាស់ជានាងម្តាយទាវនិមល
នេះគឺមិនអ្នកដទៃទាល់ ទៅជិតទៀបស្គាល់ដល់ជាម្តង ។
នាងនោះសុះឡើងលើគ្រឹះស្ថាន ប្រមាណត្រូវមាត់ជាដន្លង
ថាអ្នកអញ្ជើញមកប៉ុនប៉ង បំណងបំណាច់ត្រាច់ទៅឆ្ងាយ ។

.....

ត្បិតលោកថៅហ្វាយនូវអ្នកស្រី ទាំងពីរទាំងបីមានវាចា
ចាត់ប្រើយើងខ្ញុំនាំបណ្តា ការមកប្រាថ្នាចងមេត្រី ។
ប្រៀបដូចថ្កល់ស្តានឈានរត់ដើរ សុំស្នើសុំស្នាក់អ្នកថាអ្វី
ដណ្តឹងកូនអ្នកត្បិតឮល្បី កូនស្រីស្តីផ្សំចំម៉ឺនងួន ។

+ **គំនិតសំខាន់ទី ៣ :** ម្តាយទាវបានស្តាប់ពេញចិត្តនឹងអរជូនមានបុណ្យធំលើសគេនៅស្រុកតួងឃ្មុំ ប៉ុន្តែឆ្លើយថា នឹងសួរចិត្តកូនសិន ... ។

នាងជាមេម៉ាយម្តាយទាវស្តាប់ ចំណាប់ចំណងត្រូវចិត្តជួន
ទទួលថាអើសរសើរខ្លួន អ្នកអើយច្បាប់ក្បួនកូនកបលក្ខណ៍ ។
វិស័យសព្វថ្ងៃលំបាកដែរ គេមកហួរហែដូចអត់អាក់
ប៉ុន្តែខ្ញុំថាកូនធុរៈ ញាតិផងប៉ងស្មុគ្រមកច្រើនគ្នា ។
មិនដឹងទាន់ព្រមល្មមមេត្រី ឱ្យទៅមន្ត្រីរាស្ត្រប្រជា

ព្រោះតែយើងរាស្ត្រគួរវាំងវា ឥឡូវទើបពារលើលោកធំ ។
ឧកញ៉ាអរជូនមួនមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំ

.....

គួរហើយខ្ញុំសុំជម្រាបបញ្ជាតិ ទៅសំពះបាទលោកប្រុសស្រី
ថាបើលោកចង់ចងមេត្រី គប្បីចាំខ្ញុំលបសួរកូន ។

+ **គំនិតសំខាន់ទី ៤** : ម្តាយទាវបង្ខំឱ្យទាវយល់ព្រម តែទាវប្រកែក ។

វេលាក្រោយនោះចំពោះជា ម្តាយទាវមិ្ញម្ខាដូចអរណាស់
ឃើញនំភ័ស្តុផលថ្កល់តុថាស រហ័សរៀបចំសន្សំទុក ។
ហើយសួរទៅកូនថាមាសម្តាយ សមយើងសប្បាយថ្ងារីកមុខ
ម្តាយឱ្យទៅកូនចៅហ្វាយស្រុក បានសុខដោយបុណ្យដោយបានថ្កើង ។

.....

ទាវឮម្តាយប្រាប់ចាប់ចាំទុក ស្ទើរធ្លាក់ថ្លើមក្តុកពុំរសាយ
ទើបមានវាចាថាម៉ែអាយ ខ្ញុំកូនដូចស្តាយបាយចំណី ។
ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ ។
ទទួលទទូចខួចការហើយ ខុសសោះហ៊ានឆ្លើយថាម៉ែកុំ
ម៉ែមានកូនគួរវៀបផ្សំផ្គុំ ឃើញលោកបុណ្យធំលើកខ្ញុំឱ្យ ។

+ **គំនិតសំខាន់ទី ៥** : ម្តាយទាវខឹងនឹងការប្រកែករបស់កូនដែលចចេស ហើយបង្រៀបកូនដោយព្រមានថា កុំឱ្យរឹងទទឹងដោយលើកយកទស្សនៈ "ពងមាន់កុំជល់នឹងថ្ម និង នំមិនធំជាងនាឡិ" មកគំរាមទាវ ។

នាងម្តាយចាំស្តាប់ស័ព្ទទាវឆ្លើយ ប្រាប់ថាទាវអើយគួរបណ្តោយ
បន្ទន់អន់អត់មើលមុខក្រោយ ធ្វើខ្សោយសិនចុះកុំផ្ទុញផ្ទាល់ ។
គិតក្រែងបែកបាក់ធ្លាក់ថ្លោះធ្លោយ ពងមាន់មកឱ្យមានអំពល់
ប្រមៀលត្រូវថ្មឆ្ងិតគ្មានសល់ ហ៊ានទល់ផ្ទាល់ផ្ទុញសង្កុញខឹង ។
នែទាវទំនៀមព្រេងប្រៀបស្រាប់ ថាកូនមិនស្តាប់ចចេសរឹង
លោកយកទាញមករកសន្តឹង របឹងរបាញសាញចណ្ឌាល ។
មិនដែលសោះឡើយទាវអើយនំ ច្រឡើសបើសធំម្តេចជាងនាឡិ
កូនគោកាចកៀចដោយព្រៃវាល រោលរាលឈឺខ្លួនជួនដល់ស្លាប់ ។

៣. អត្ថន័យឃ្លា : "កូនគោកាចកៀច" មានន័យថា កូនគោដែលក្រាញទម្រន់ ។ ធៀបមកន័យមួយទៀតមានន័យថា កូនដែលរឹងចចេសប្រកែកតវ៉ា ក្រាញមិនតាមបង្គាប់បញ្ជារបស់ម្តាយ ... ។

៤. តាមរយៈខ្លឹមសារអត្ថបទដកស្រង់ខាងលើនេះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវទស្សនៈឬផ្នត់គំនិតរបស់ម្តាយឪពុកនាសម័យនោះថា ពេលរៀបចំទុកដាក់កូនចៅឱ្យមានគូស្រករ ម្តាយឪពុករមែងប្រើទស្សនៈ "នំមិនធំជាងនាឡិ" មកបង្ខំកូន ហើយក៏ឆ្លុះបញ្ចាំងផងដែរអំពីអំណាចក្នុងការគ្រប់គ្រងគ្រួសារ ដោយឈរលើទស្សនៈ "ពងមាន់កុំជល់នឹងថ្ម" មកគំរាមកំហែង បង្ខិតបង្ខំកូនចៅ ឬអ្នកក្រោមអំណាចឱ្យគោរពកោតខ្លាចអំណាចបារមីខ្លួនផងដែរ ។

៥. រូបារម្មណ៍ដែលកវីបានប្រើក្នុងអត្ថបទកាព្យដកស្រង់នេះមានដូចជា

- ឧបមានរូបារម្មណ៍ :

+ កវីប្រើពាក្យជាចំណងធៀប "ប្រៀបដូច"

ត្បិតលោកថៅហ្វាយនូវអ្នកស្រី	ទាំងពីរទាំងបីមានវាចា
ចាត់ប្រើយើងខ្ញុំនាំបណ្តា	ការមកប្រាថ្នាចងមេត្រី ។
ប្រៀបដូចថ្នល់ស្ពានឈានរត់ដើរ	សុំស្នើសុំស្នាក់អ្នកថាអ្វី
ដណ្តឹងកូនអ្នកត្បិតឮល្បី	កូនស្រីស្តីផ្សំចំម៉ឺនងួន ។

+ កវីប្រើការប្រៀបធៀបអង្គបង្គោលនិងទំហៀបពីរ "មេឃនិងភ្នំ" ដោយប្រើចំណងធៀប "ជាង" ៖

ឧកញ៉ាអរជូនមួនមាំពេក	ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ	កាប់ចាក់វាយដំពុំប្រណី ។

+ កវីប្រើពាក្យជាចំណងធៀប "ប្រៀប" "ជាង" ៖

នែទាវទំនៀមព្រេងប្រៀបស្រាប់	ថាកូនមិនស្តាប់ចចេសរឹង
លោកយកទាញមករកសន្ធឹង	របឹងរបាញ់សាញចណ្ឌាល ។
មិនដែលសោះឡើយទាវអើយនំ	ច្រឡើសបើសធំម្តេចជាងនាឡិ
កូនគោកាចកៀចដោយព្រៃវាល	រោលរាលឈឺខ្លួនជួនដល់ស្លាប់ ។

៦. គំនិតសំខាន់បង្កប់ក្នុងវគ្គខាងក្រោម ៖

ថាបើម៉ែព្រមល្មមនឹងគេ	កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី	តាមម៉ែមេត្រីឱ្យថ្លៃខ្ញុំ ។

អត្ថន័យសំខាន់ក្នុងវគ្គនេះ ចង់បង្ហាញឱ្យឃើញថាទាវប្រកែកតវ៉ានឹងម្តាយមិនព្រមតាមម្តាយដែលលើកខ្លួនឱ្យទៅម៉ឺនងួនទេ ហើយថែមទាំងឆ្លើយបញ្ឈឺឱ្យម្តាយថា មានកូនប្រុសស្រីពីរបីក្រៅពីនាងលើកឱ្យគេទៅ ចំណែកនាងៗមិនព្រមជាដាច់ខាត ។

ឃ. ការវាយតម្លៃ

- គ្រូឱ្យសិស្សសង្ខេបអត្ថបទដកស្រង់ "នំមិនធំជាងនាឡិ" ជាសម្រាយឡើងវិញ
- គ្រូឱ្យសិស្សពន្យល់បកស្រាយវគ្គខាងក្រោម ៖

គិតក្រែងបែកបាក់ធ្លាក់ថ្នោះធ្លោយ	ពងមាន់មកឱ្យមានអំពល់
ប្រមៀលត្រូវថ្មល្អិតគ្មានសល់	ហ៊ានទល់ផ្ទាល់ផ្ទញ់សង្ខ្ញុញ្ញខឹង ។

កំណាព្យបទទ្វេមាត្រ

១. វត្ថុបំណង

- ប្រាប់បានពីនិយមន័យឬន័យនៃបទទ្វេមាត្រ តាមរយៈការសិក្សាវគ្គដកស្រង់នៃបទគោព័ទ្ធស្និងពាក្យ ៧ បទអក្សរលួនពាក្យ ៧ បទសត្វកាងស្លាប និងបទឆត្រចីជាន់ពាក្យ ៨ តាមឧទាហរណ៍បញ្ជាក់នីមួយៗបានច្បាស់លាស់
- កំណត់បានពីរង្វាស់កាព្យក្នុងបទនីមួយៗបានត្រឹមត្រូវ
- តែងកំណាព្យបទអក្សរលួនពាក្យ ៧ បទសត្វកាងស្លាប បទឆត្រចីជាន់ពាក្យ ៨ មួយបទៗចំនួនពីរវគ្គ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៣៣-៣៥ ។

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងចំណិន "កំណាព្យបទទ្វេមាត្រ" ដាក់លើក្តារខៀន រួចឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៣៣-៣៥ អានសេចក្តីផ្តើមចំណិន និងខ្លឹមសារនីមួយៗតាំងពីចំណុចទី ១-៤ និងក្បួនចងចាំ ។
- គ្រូសួរសំណួរ ៖
  - ដូចម្តេចហៅថា "បទទ្វេមាត្រ" ?

    ចម្លើយ : ជាបទដែលកវីប្រើកាព្យមាត្រ ២ ។ មួយជាកាព្យមាត្របទមូលដ្ឋាន ហើយបន្ថែមបទពាក្យ ៧ កាព្យមាត្រថ្មីមួយទៀតលើមូលដ្ឋានទាំងអស់នោះ ។
  - ដូចម្តេចហៅថា "បទអក្សរលួនពាក្យ ៧" ? ចូរលើកឧទាហរណ៍ ។

    ចម្លើយ : រង្វាស់កាព្យដូចបទពាក្យ ៧ដែរ តែប្លែកត្រង់នៅឃ្លានីមួយៗ បើកវីប្រើព្យញ្ជនៈណាមួយហើយ នោះត្រូវប្រើព្យញ្ជនៈនោះរហូតដល់ចប់ឃ្លា ដោយគ្រាន់តែផ្លាស់ប្តូរស្រៈនិងព្យញ្ជនៈប្រកបប៉ុណ្ណោះ ។

    ឧទាហរណ៍ : ចាស់ៗចូលចិត្តចេះចាត់ចែង ប្រឹងប្រែងប្រាយប្រាប់ប្រើប្រុសៗ
    ដាស់ដីដឹកដៀវដាក់ដាំដុះ បកបុសបបេះបោកបែនបារ ។
  - ដូចម្តេចហៅថា "បទគោព័ទ្ធស្និងពាក្យ ៧" ? ចូរលើកឧទាហរណ៍ ។

    ចម្លើយ : រង្វាស់កាព្យ ចំណាប់ចុងចួននិងចង្វាក់ដូចបទពាក្យ ៧ដែរ តែខុសពីបទពាក្យ ៧ត្រង់កវីប្រើពាក្យផ្ចួន ។

    ឧទាហរណ៍ : ប្រាសាទអង្គរគ្រឹះជាតិខ្មែរ ខ្មែរយើងត្រូវតែថែឱ្យគង់
    គង់កេរដំណែលតដៅពង្ស ពង្សយើងជាវង្សសាងប្រាង្គប្រា ។
    ប្រាសាទរាប់ពាន់លោកសាងទុក ទុកតទៅមុខតាងសាវតារ
    ដាដាក់ដាប់ឆ្លាក់ល្អថ្លៃថ្លា ថ្លាថ្លើងអស្ចារ្យជូនតាយើង ។

    (ដកស្រង់ចេញពីសិល្បៈតែងកំណាព្យរបស់ លោក ពេជ្រទុំ ក្រវិលឆ្នាំ ១៩៨៨ ទំព័រទី ៦១)

- ដូចម្តេចហៅ "បទសត្វកាងស្លាប" ? ចូរឱ្យឧទាហរណ៍បញ្ជាក់ ។

ចម្លើយ : រង្វាស់កាព្យ ចំណាប់ចួន និងចង្វាក់គោរពតាមបទពាក្យ ៧ធម្មតា ប៉ុន្តែនៅក្នុងគ្រប់ឃ្លាទាំងអស់មានពាក្យដដែលពីរដង ។

ឧទាហរណ៍ : គិតជាតិ ជាតិគិតមិត្តមិនខាន ជាតិថ្កាន ថ្កានជាតិញាតិបានសុខ
ជាតិទុក្ខ ទុក្ខជាតិញាតិក្តួលក្តុក ចុកទ្រូង ទ្រូងចុកក្តុកក្តៅផ្សា ។
ជាតិបាត់ បាត់ជាតិញាតិអើយចាំ សុំផ្តាំ ផ្តាំសុំ កុំសង្កា
គ្មានសុខ សុខគ្មានហ៊ានសន្យា ខ្លោចផ្សា ផ្សាខ្លោចហោចរហូត ។

(ដកស្រង់ចេញពីសៀវភៅសិល្បៈតែងកំណាព្យ លោក ពេជ្រទុំ ក្រវិល ១៩៨៨)

- ដូចម្តេចហៅ "បទឆត្របីជាន់ពាក្យ ៨" ? ចូរឱ្យឧទាហរណ៍បញ្ជាក់ ។?

ចម្លើយ : រង្វាស់កាព្យ ចំណាប់ចួន ចង្វាក់ដូចបទពាក្យ៨ដែរ តែស្លែកត្រង់ប្រើការផ្ទួនពាក្យ ក្នុងឃ្លានីមួយៗដូចជា ៖

ឧទាហរណ៍ : ខ្មែរអើយគួរធ្វើការគួរខ្មែរអើយ ក្រោកឆាប់ដេកដែរសើយដេកឆាប់ក្រោក
ដោកពេញស្រូវកុំអួតស្រូវពេញដោក ព្រួយក្រែងក្រោយស្រូវថោកក្រោយក្រែងព្រួយ ។

ខ. ការហ្វឹកហាត់

- ឱ្យសិស្សសូត្រអត្ថបទកាព្យដកស្រង់ជាឧទាហរណ៍ក្នុងសៀវភៅសិស្សទំព័រទី ៣៣-៣៥ ឡើងវិញម្តងមួយបទៗ រហូតចប់ទាំងបួនបទពីចំណុចលេខ ១-៤ ។ ឱ្យសិស្សធ្វើលំហាត់ទី ១ក្នុងសៀវភៅសិស្សទំព័រទី ៣៥ តែងបទ ៖
  + អក្សរលួនពាក្យ ៧ ចំនួន ២វគ្គ
  + សត្វកាងស្លាប ចំនួន ២វគ្គ
  + បទឆត្របីជាន់ ចំនួន ២វគ្គ តាមការជ្រើសរើស ។

ចម្លើយ : អាស្រ័យលើការជ្រើសរើសបទនីមួយៗដែលសិស្សចូលចិត្ត ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សបង្ហាញពីរង្វាស់កាព្យនិងគូសសញ្ញាចំណាប់ចុងចួន ផ្ទួន រណ្តំក្នុងអត្ថបទកាព្យដកស្រង់ខាងក្រោម ៖

បទសត្វកាងស្លាប : គិតជាតិ ជាតិគិតមិត្តមិនខាន ជាតិថ្កាន ថ្កានជាតិញាតិបានសុខ
ជាតិទុក្ខ ទុក្ខជាតិញាតិក្តួលក្តុក ចុកទ្រូង ទ្រូងចុកក្តុកក្តៅផ្សា ។
ជាតិបាត់ បាត់ជាតិញាតិអើយចាំ សុំផ្តាំ ផ្តាំសុំ កុំសង្កា
គ្មានសុខ សុខគ្មានហ៊ានសន្យា ខ្លោចផ្សា ផ្សាខ្លោចហោចរហូត ។

(ដកស្រង់ចេញពីសៀវភៅសិល្បៈតែងកំណាព្យ លោក ពេជ្រទុំ ក្រវិល ១៩៨៨)

ចម្លើយ : រង្វាស់កាព្យ : ១វគ្គមាន ៤ឃ្លា ១ឃ្លាមាន ៧ព្យាង្គ ។

+ គំនូសសញ្ញាចាប់ចុងចួន



+ ផ្ទួន

ព្យ១ = ព្យ៤
ព្យ២ = ព្យ៣
ព្យ៤ = ព្យ៥

ព្យ១ = ព្យ៤
ព្យ២ = ព្យ៣
ព្យ៤ = ព្យ៥

កម្លាយដោយផ្នត់ជែក

១. វត្ថុបំណង

- ប្រាប់បានពីនិយមន័យផ្នត់ជែកនិងកម្លាយផ្នត់ជែកទម្រង់ [-ព-] [-សព-] [-ស/ព-] [-អ៊ី/ន-] [-អ៊ី/ប-] [-អ៊ា/ប-] និង [-សព/ព-] បានត្រឹមត្រូវតាមរយៈឧទាហរណ៍បញ្ជាក់ទម្រង់ទាំងបួន
- រកពាក្យក្លាយដែលកើតឡើងពីពាក្យឫសតាមវិធីកម្លាយផ្នត់ជែកតាមរយៈលំហាត់បុគ្គល ឬក្រុម ។

២. សម្ភារៈ

- សៀវភៅសិស្សទំព័រទី ៣៦-៣៧ ។

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- សរសេរចំណងជើង "កម្លាយដោយផ្នត់ជែក" ដាក់លើក្តារខៀនឱ្យសិស្សអាន រួចឱ្យសិស្សអានសេចក្តីពន្យល់ឧទាហរណ៍និងនិយមន័យនៃផ្នត់ជែកក្នុងសៀវភៅសិស្សទំព័រទី ៣៦-៣៧ ។
- ឱ្យសិស្សឆ្លើយសំណួរ ៖
  - ដូចម្តេចហៅថា "ផ្នត់ជែក" ?

    ចម្លើយ : ផ្នត់ជែក គឺជាផ្នត់កម្លាយដែលជ្រែកពាក្យឫស ដើម្បីបង្កើតជាពាក្យក្លាយ ។
  - តើកម្លាយដោយផ្នត់ជែកមានទម្រង់អ្វីខ្លះ ?

    ចម្លើយ : កម្លាយដោយផ្នត់ជែកមានទម្រង់បួនគឺទម្រង់ [-ព-] , [-សព-] , [-ស/ព-] និងទម្រង់ [-សព/ព-] ។
  - តើទម្រង់ [-ព-]មានអ្វីខ្លះ ?

    ចម្លើយ : ផ្នត់ជែកទម្រង់ [-ព-]មានដូចជា កើយ > ខ្នើយ , សែង > ស្នែង , លាយ > ល្បាយ , លូន > ល្ងួន ។
  - តើទម្រង់ [-សព-]មានអ្វីខ្លះ ?

    ចម្លើយ : ផ្នត់ជែកទម្រង់ [-សព-]មានដូចជា ខ្វះ > កង្វះ , ផ្ញើ > បញ្ញើ , ក្តាប់ > កណ្តាប់ , ភ្លឺ > ពន្លឺ , ក្តៅ > កម្តៅ , ជ្រាប > ជម្រាប ។
  - តើទម្រង់ [-ស/ព-]មានអ្វីខ្លះ ?

    ចម្លើយ : ផ្នត់ជែកទម្រង់ [-ស/ព-]មានដូចជា រុក > រនុក , រៀន > របៀន ,លេង > ល្បែង , លើក > ល្បើក ។
  - តើទម្រង់ [-សព/ព-]មានអ្វីខ្លះ ?

    ចម្លើយ : ផ្នត់ជែកទម្រង់ [-សព/ព-]មានដូចជា [-អ៉ម/ន-] កាន់ > កំណាន់ , ចោទ > ចំណោទ និង [-អ៊ីម/ន-] គិត > គំនិត , ទួញ > ទំនួញ ។

ខ. ការហ្វឹកហាត់

គ្រូឱ្យសិស្សតាមក្រុមធ្វើលំហាត់ទី ១, ២ ក្នុងសៀវភៅសិស្សទំព័រទី ៣៧ ។

ចម្លើយ :

១. ពាក្យក្លាយដែលកើតពីឫស ៖

+ លង	>	ល្បង	ទម្រង់ [- ព-]
+ រាប	>	រនាប	ទម្រង់ [- ស/ ព-]
+ រាំង	>	រថាំង	ទម្រង់ [- ស/ ព-]
+ លាយ	>	ល្បាយ	ទម្រង់ [- ព-]
+ គិត	>	គំនិត	ទម្រង់ [- សព/ ព-]
+ សោក	>	សំណោក	ទម្រង់ [- សព/ ព-]

២. ពាក្យឫសនៃពាក្យក្លាយ ៖

+ ចំណែក	<	ចែក	ទម្រង់ [- សព/ ព-]
+ ល្បែង	<	លេង	ទម្រង់ [- ព-]
+ រនាស់	<	រាស់	ទម្រង់ [- ស/ ព-]
+ ស្នូម	<	សូម	ទម្រង់ [- ព-]
+ ជម្រាប	<	ជ្រាប	ទម្រង់ [- សព-]
+ សម្ព	<	ស្ព	ទម្រង់ [- សព-]
+ ខ្វើត	<	កើត	ទម្រង់ [- ព-]
+ កម្ទេច	<	ខ្ទេច	ទម្រង់ [- សព-]
+ រលើស	<	រើស	ទម្រង់ [- ស/ ព-]

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សធ្វើកិច្ចការនៅផ្ទះ ដោយរកពាក្យក្លាយដែលកើតឡើងពីពាក្យឫស ទម្រង់ [- ព-] , [- សព-] , [- ស/ ព-] និង [- សព/ ព-] ឱ្យបានក្នុងមួយទម្រង់ចំនួន ៥ពាក្យ ។



ប្រពៃណីនៅពេលកើត

១. វត្ថុបំណង

- ប្រាប់បានពីខ្លឹមសារអត្ថបទទាក់ទងប្រពៃណីនៅពេលកើតកូនតាមរយៈការអានអត្ថបទ
- កំណត់បានពីតម្លៃអប់រំក្នុងអត្ថបទទាក់ទងប្រពៃណី ទំនៀមទម្លាប់នៅពេលកើតកូន
- អភិវឌ្ឍស្មារតីសិស្សក្នុងការប្រកាន់យកប្រពៃណីទំនៀមទម្លាប់ណាដែលល្អគួរអភិរក្សនិងប្រពៃណីណាដែលគួរពិចារណា ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៣៨-៤១ ។

៣. លំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូសរសេរចំណងជើងអំណានអត្ថបទ "ប្រពៃណីនៅពេលកើតកូន"ដាក់លើក្តារខៀន រួចសួរសំណួរទាក់ទងចំណងជើង ៖
  - តើពាក្យថា "ប្រពៃណី" មានន័យដូចម្តេច ?

    ចម្លើយ : មានន័យថា ទំនៀមទម្លាប់តវង្សត្រកូលដែលគេប្រតិបត្តិតាមៗគ្នា ជារៀងរហូតតាំងពីសម័យមុនមក ។
  - តើពាក្យថា "ប្រពៃណីនៅពេលកើតកូន" មានន័យដូចម្តេច ?

    ចម្លើយ : ប្រពៃណីនៅពេលកើតកូនមានន័យថា ជាទំនៀមឬទំនៀមទម្លាប់បែបបទនានាដែលគេអនុវត្តតៗគ្នានៅពេលដែលកើតកូន ។
- ឱ្យសិស្សមើលរូបភាពក្នុងសៀវភៅសិស្សទំព័រទី ៣៨រួចសួរសំណួរ ៖
  - តើអ្នកឃើញអ្វីខ្លះនៅលើរូបភាពនេះ ?

    ចម្លើយ : ឃើញរូបមនុស្សបីនាក់ ស្រីពីរនាក់ បុរសម្នាក់ ។
  - តើពួកគេកំពុងធ្វើអ្វី ?

    ចម្លើយ : ក្នុងចំណោមពួកគេទាំងបី មានស្ត្រីម្នាក់កំពុងសម្រាកលើគ្រែ ឯបុរសម្នាក់អង្គុយជិតគ្រែកំពុងកាន់ចំពង់ផ្តុំភ្លើងដែលកំពុងដុតភ្លើងនៅក្រោមគ្រែ ហើយស្ត្រីវ័យចំណាស់ម្នាក់ទៀតដែលអង្គុយនៅខាងឆ្វេងបុរសនោះទំនងជាឆ្មបកំពុងរើសម្ភារៈក្នុងប្រអប់មួយនិងទំនងជាចង់ធ្វើអ្វីមួយដែរ ។
  - តើរូបភាពនេះមានន័យដូចម្តេច ?

    ចម្លើយ : រូបភាពនេះបង្ហាញឱ្យឃើញថា មនុស្សទាំងពីរនាក់ដែលកំពុងនៅខាងក្រោមត្រៀមបម្រើដោយយកចិត្តទុកដាក់ដល់ស្ត្រីលើគ្រែ អាំងភ្លើងកម្តៅសរសៃនៅពេលឆ្លងទន្លេ ឬកើតកូនរួច ។
- គ្រូឱ្យសិស្សសិក្សាពាក្យគន្លឹះ ។

ខ. អំណាន

- ឱ្យសិស្សអានខ្លឹមសារការអភិវឌ្ឍបំណិនក្នុងសៀវភៅសិស្សទំព័រទី ៣៩ ត្រង់ចំណុច (ខ)
- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ៤១ ដើម្បីត្រៀមឆ្លើយ
- ឱ្យសិស្ស ៤-៥ នាក់អានអត្ថបទក្នុងសៀវភៅសិស្សទំព័រទី ៣៩-៤១ ឯសិស្សដទៃអានតាមរៀងៗខ្លួនដោយស្ងៀមស្ងាត់ ដោយអានបណ្តាក់ ឬបន្តគ្នា ។

គ. ពង្រឹងអំណាន

- ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ៤១ ។

ចម្លើយ :

១. ប្រពៃណីនៅពេលកើតកូនចែកចេញជា ៣តំណាក់កាល គឺមុនពេលកើត ពេលកើត និងក្រោយពេលកើត ។

២. ស្ត្រីមានផ្ទៃពោះ មុនពេលកើតកូនត្រូវប្រកាន់ត្រណមមួយចំនួនដូចតទៅ ៖

+ មិនត្រូវបរិភោគអាហារមានរសជាតិហឹរ នាំឱ្យក្រហាល់ក្រហាយដល់កូនក្នុងផ្ទៃ
+ មិនត្រូវស្លៀកពាក់តឹងចង្កេះពេក នាំឱ្យរឹតនិងធ្វើឱ្យចង្កេះចង្អល់ដល់កូនក្នុងផ្ទៃ
+ មិនត្រូវបរិភោគបបរ នាំឱ្យកូនកើតមកមិនស្អាត(មិនជ្រះ)
+ បើមានសួរ្យគ្រាសឬចន្ទគ្រាស ត្រូវយកកំបោរមកលាបលើផ្ទៃពោះ ដើម្បីជួយសង្កត់ទារកនៅក្នុងផ្ទៃកុំឱ្យភ្ញាក់ផ្អើលនិងមហិទ្ធិឫទ្ធិរាហូ បើមិនបានធ្វើបែបនេះទេ កូនកើតមកនឹងទៅជាលើលើមិនគ្រប់ដប់(អ្នកខ្លះហៅថា កូនគ្រាសកន្លង)នៅតំបន់ខ្លះគេឱ្យដាក់អកកំបោរនៅនឹងថ្ពក់សំពត់ ។
+ មិនត្រូវដេកថ្ងៃ ងូតទឹកយប់ នាំឱ្យកូនថ្លោសពិបាកកើត
+ មិនត្រូវអង្គុយនៅមាត់ទ្វារឬមាត់ជណ្តើរខ្លាចកូនកើតមិនរួច
+ មិនត្រូវជំអក់ ត្រូវរហ័សរហួនក្រោកមុនប្តី ទើបកូនកើតបានស្រួល
+ លើសពីនេះ ត្រូវរកថ្នាំជំនួយដើម្បីសម្រាលកូនបានរហ័សទុកស្ងោរផឹកនៅពេលជិតគ្រប់ខែ ។

៣. នៅពេលស្ត្រីមានផ្ទៃពោះសម្រាលកូនឬពេលកើត ៖

+ បុរសជាប្តី ឪពុកឬបងប្អូនត្រូវរត់ទៅតាមយាយឆ្មបដែលនៅក្នុងភូមិជិតឬឆ្ងាយ ឱ្យមកជួយសម្រាល
+ នៅតំបន់ខ្លះ ក្នុងពេលឈឺពោះគេតែងរៀបពិធីបន់ស្រន់មួយដល់វត្ថុស័ក្តិសិទ្ធិឬអ្នកដួនអ្នកតា សុំឱ្យការឆ្លងទន្លេប្រព្រឹត្តទៅដោយសេចក្តីសុខសប្បាយ ផុតគ្រោះថ្នាក់ឬឧសគ្គណាមួយ ។

៤. ផ្នែកតាមគំនិតសំខាន់នៃអត្ថបទ ពិធីមួយចំនួនដែលខ្មែរយើងតែងតែនិយមប្រារព្ធធ្វើឡើងនៅក្រោយពេលកើតកូនគឺ ៖

+ ស្ត្រីជាម្តាយត្រូវអាំងភ្លើងចំនួន ៣ថ្ងៃឬមួយអាទិត្យ(បើកូនដំបូង)ដើម្បីកម្តៅសរសៃ
+ អញ្ជើញអាចារ្យសូត្រមន្តអាគមព័ទ្ធអំបោះនៅជុំវិញ(ព័ទ្ធសីមា) ។ គេអាចគួសខ្សែងនៅលើសសរដោយកំបោរឬបិទខ្សែងដោយក្រមួនសុទ្ធក៏បាន
+ គេយកកាំបិត កន្ត្រៃ ទៅដាក់លើក្បាលដំណេកកូនខ្ចី
+ មិនឱ្យអ្នកអាំងភ្លើងក្រោកពីដំណេក និយាយឆ្លើយឆ្លងជាមួយភ្ញៀវឬញាតិមិត្តដែលមកសាកសួរសុខទុក្ខនោះទេ ប៉ុន្តែគេអាចនិយាយជាមួយអ្នកថែរក្សាភ្លើងបាន ។

+ ពិធីទម្លាក់ចង្កាន ជាពិធីដែលឆ្មបប្រារព្ធឡើងដោយពួតបាយជាបួនពំនូតដាក់លើស្លឹកចេក ហើយសូត្របន់ស្រន់ដល់ព្រះធរណីនិងមេបាសុំឱ្យជួយការពារម្តាយនិងកូនខ្ចីនោះ រួចបោះពំនូតបាយនោះទៅដី ព្រមទាំងសូត្រអង្ករខ្មោចព្រាយបិសាចកុំឱ្យមកយាយី។ លុះចប់ពិធីនេះហើយ ភ្លើងចង្ក្រានត្រូវពន្លត់ដោយអ្នកដែលបានដុតបង្កាត់ភ្លើងពីដំបូង។
+ បន្ទាប់ពីនេះ ស្ត្រីជាម្តាយក៏បានប្រារព្ធពិធីជូនរង្វាន់និងពិធីសុំខមាទោសចំពោះឆ្មប ដែលមានការឿយហាត់និងការលំបាកផ្សេងៗពេលបង្កើតកូន។ នៅតំបន់ខ្លះ បុរសជាប្តីក៏បានចូលរួមក្នុងពិធីនេះដែរ។ គេតែងតែជឿថាបើស្ត្រីអ្នកឆ្លងទន្លេមិនបានបំពេញការសុំខមាទោស នោះស្ត្រីជាម្តាយនោះនឹងត្រូវទទួលរងទណ្ឌកម្មនៅជាតិខាងមុខទៀត ដោយត្រូវទូលកន្ទេលរត់តាមសុំទោសឆ្មប ហើយឆ្មបនោះមិនទាំងមើលនិងឆ្លើយតបមកវិញផង។
+ តាមទំនៀមទម្លាប់គ្រួសារខ្លះទៀត ឪពុកទារកត្រូវយកសុកទៅកប់ឬដុត ឬដាក់ប្រគាបឈើដោយជ្រើសរើសនូវទិសណាដែលល្អ ហើយនៅថ្ងៃដដែលនេះផងដែរ។ មានពិធីផ្សេងៗជាច្រើនទៀតដូចជា ពិធីបង្កកឡដើម្បីប្រសិទ្ធិដល់ទារក ដោយគេដាក់ទារកនៅចំកណ្តាលបន្ទប់ក្បែរម្តាយបែរទៅរកទិសខាងកើត។ នៅចុងជើងទារកមានស្រូវពន្លៃនិងថាសតង្វាយដូចជា ម្ហូប សម្លៀកបំពាក់ និងគ្រឿងអលង្ការជាដើម។ ឆ្មបចាប់ផ្តើមអុជធូបទៀនអញ្ជើញព្រះធរណីដើម្បីជួយទារកឱ្យបានជោគជ័យគ្រប់ប្រការទៅអនាគត រួចឆ្មបយកទឹកខ្មៅចិនដែលលាយនឹងទឹកដោះម្តាយឬស្រាទៅលាបចិញ្ចើមនិងទងផ្ចិតទារក។ ពិធីនេះហៅថា "ពិធីបើកភ្នែក"។
+ ពិធីកាត់សក់ព្រៃ គឺជាពិធីដែលគេកាត់សក់បន្តិចនៅលើបង្កើយកូនខ្ចីដាក់ក្នុងកូនកន្ទោងមួយដែលគេបន្ថែមម្ហូបចំណីនិងច្រូចស្រាបន្តិច រួចគេយកកន្ទោងនោះចេញទៅក្រៅសម្រាប់ថ្វាយដល់ព្រះធរណី។
+ ពិធីហៅឬជញ្ជក់ព្រលឹងទារកដែលកើតភ្លាមៗ គេយកចិញ្ចៀនមាសមួយវង់ចងអំបោះនៅហើយសំបួងសង្រួងហៅព្រលឹង ១៩ឱ្យលែងនៅក្នុងព្រៃ ហើយមកថែរក្សាខ្លួនទារកនោះវិញ រួចគេចងចិញ្ចៀនដែលជាតំណាងនេះទៅនឹងកដៃទារកម្ខាង កដៃម្ខាងទៀតគេចងអំបោះនៅ។
+ បន្ទាប់មក គេត្រូវយកពន្លៃបិទត្រង់បង្កើយរបស់ទារក ហើយផ្លាស់ប្តូរវារាល់ថ្ងៃ។ ការបិទពន្លៃនេះមានរយៈពេលរហូតដល់ ៧-៨ ខែ។
+ នៅទីបញ្ចប់ ឆ្មបដែលជាអ្នកដឹកនាំពិធីក៏បានអុជទៀនធូបដោតលើតង្វាយផ្សេងៗ ហើយអញ្ជើញអស់ជូនតាឱ្យមកទទួលតង្វាយនេះនិងប្រសិទ្ធពរដល់កូនចៅ។ ឪពុកម្តាយ បងប្អូន មិត្តភក្តិ ចូលមកម្នាក់ម្តងៗទៅប្រោះព្រំឱ្យពរជ័យដល់ទារកនិងចងដៃទារកតាមធនធានដែលខ្លួនមាន។

៥. តាមការសង្កេត ពិធីទាំងអស់ដែលប្រជាជនខ្មែរយើងនិយមក្រោយពេលកើតកូន ក៏មានពិធីខ្លះស្ទើរតែបាត់បង់ទៅហើយ ហើយពិធីខ្លះទៀតដែលខ្មែរយើងយល់ថាល្អ ងាយប្រតិបត្តិតាមក៏មាននៅសល់ខ្លះរហូតដល់បច្ចុប្បន្នដូចជា ៖

- ពិធីដែលស្ទើរតែបាត់បង់មាន ៖ ពិធីអាំងភ្លើង ពិធីទម្លាក់ចង្ក្រាន ពិធីកប់សុក ពិធីបើកភ្នែក ពិធីជូនរង្វាន់និងសុំខមាទោសឆ្មប ពិធីកាត់សក់ព្រៃ។
- ពិធីដែលខ្មែរយើងនិយមហើយនៅតែបន្តប្រតិបត្តិរហូតដល់បច្ចុប្បន្ននេះមាន ៖ ពិធីបង្កក់កូន ពិធីហៅព្រលឹង ការយកកាំបិត កន្ត្រៃដាក់លើក្បាលដំណេកទារក។ល។

៦. ការសម្រាលកូនតាមបែបសម័យបច្ចុប្បន្នមានសុវត្ថិភាពជាងការសម្រាលកូនតាមបែបបុរាណ ព្រោះគ្រូពេទ្យសម័យបច្ចុប្បន្នមានចំណេះដឹងវេជ្ជសាស្ត្រទូទៅទូលំទូលាយ មានបទពិសោធន៍ មានសម្ភារៈប្រើប្រាស់ សម្ភារៈសង្គ្រោះបន្ទាន់ល្អ មានអនាម័យគ្រប់គ្រាន់ ទាន់ពេលវេលា មានថ្នាំព្យាបាលល្អត្រឹមត្រូវ ធានាបាននូវសុខសុវត្ថិភាពរបស់ម្តាយនិងទារកបានគ្រប់ពេលវេលា។ យើងគួរជ្រើសរើសការសម្រាលកូនបែបបច្ចុប្បន្នដើម្បីធានានូវសុខមាលភាព និងសុខសុវត្ថិភាពមាតានិងទារក។



ជំនឿ

១. វត្ថុបំណង

- ប្រាប់បានពីប្រភពនៃជំនឿទៅលើព្រលឹងម្តាយឪពុកតាមរយៈការស្តាប់អត្ថបទដោយយកចិត្តទុកដាក់
- ប្រាប់បានពីហេតុផលនិងគុណវិបត្តិនៃជំនឿងប់ងល់ខ្លះការពិចារណាតាមរយៈការឆ្លើយសំណួរបញ្ចេញមតិផ្ទាល់ខ្លួន
- អភិវឌ្ឍស្មារតីសិស្សឱ្យចេះពិចារណាទៅលើការគោរពប្រតិបត្តិនៃជំនឿទាំងឡាយ ដែលមានលក្ខណៈសមស្រប សមហេតុផល ហើយចៀសវាងជំនឿទាំងឡាយណាដែលមិនសមហេតុផលនិងផ្តល់គុណវិបត្តិដល់យើង ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៤២
- សៀវភៅអរិយធម៌ខ្មែរ វប្បធម៌ និងសង្គមធម៌សម្រាប់ឆ្នាំសិក្សាមូលដ្ឋាន របស់លោក សូ មុយឃៀង លោក ទិត សៀង លោក ជា ឈិន ទំព័រទី ២១-២២ បោះពុម្ពលើកទី ២ ឆ្នាំ ២០០៨ ។

៣. ព័ត៌មានបន្ថែម

លោកគ្រូអ្នកគ្រូ អាចស្រាវជ្រាវបន្ថែមទៅលើបញ្ហាជំនឿដែលបង្ហាញក្នុងឯកសារ "អរិយធម៌ខ្មែរ" របស់លោក សូ មុយឃៀង បោះពុម្ពឆ្នាំ ២០០៨ បន្តទៀតដើម្បីមានគំនិតច្រើនជាជំនួយស្មារតីក្នុងការបង្រៀនសិស្ស ជាពិសេស បញ្ហាជំនឿជាច្រើនទៀតដែលបានទាក់ទងទៅនឹងប្រធានបទសំណេរ ដែលនឹងត្រូវដាក់ឱ្យសិស្សជ្រើសរើសមកសរសេរក្នុងសំណេរតែងកាព្យទាក់ទងបញ្ហាជំនឿទាំងនោះថែមទៀតផង ។

៤. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូសរសេរចំណងជើងអត្ថបទស្តាប់រឿង "ជំនឿ" ដាក់លើក្តារខៀនរួចសួរ ៖
  - តើជំនឿមានន័យដូចម្តេច ?

    ចម្លើយ : មានន័យថា ការជឿ ការទុកចិត្តទៅលើអ្វីមួយ ដែលយល់ថាល្អត្រឹមត្រូវមានសារៈសំខាន់ឬប្រយោជន៍ដល់មនុស្សក្នុងការរស់នៅមានតម្លៃគួរឱ្យគោរពប្រតិបត្តិនិងត្រូវបានកំណត់ថាជាខឿនវប្បធម៌ អរិយធម៌របស់ជាតិ ... ។
  - តើអ្នកធ្លាប់ជឿទៅលើអ្វីខ្លះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ហេតុអ្វីបានជាមនុស្សគ្រប់គ្នាតែងមានជំនឿ ?

    ចម្លើយ : ព្រោះកាលបើមនុស្សគោរពនិងប្រតិបត្តិតាមជំនឿល្អនោះគេនឹងមានសេចក្តីសុខចម្រើន ។

- គ្រូពន្យល់ន័យនៃពាក្យពិបាកខាងក្រោម ៖
  - ជំនឿ (ន) : សេចក្តីដែលគួរជឿ ដំណើរនៃការជឿ ។
  - ព្រលឹង (ន) : ដំណើរជីវិត ស្មារតី វិញ្ញាណ សេចក្តីសុខចម្រើន ។
  - គុណ (ន) : សេចក្តីចម្រើន សភាវធម៌ដែលនាំឱ្យមានសេចក្តីចម្រើនកើតឡើង ដោយលក្ខណៈរបស់ខ្លួន គួរគោរពតបស្នងនឹងខានពុំបានដូចជា គុណមាតាបិតា គុណគ្រូ ។ល។
  - បង្សុកូល (ន) : ខ្មែរយើងប្រើតាមទម្លាប់ប្រទេសហៅថា ដំណើរដែលគេនិមន្តភិក្ខុសាមណេរឱ្យមកកាន់អំបោះ ឬផ្ទាំងសំពត់ដែលតភ្ជាប់ពីសាកសពឬពីអដ្ឋិធាតុ មកសូត្រធម៌ ។ ឯសព្វថ្ងៃប្រជាជនយើងនិយមការបង្សុកូលដោយគ្រាន់តែនិមន្តព្រះសង្ឃសូត្រធម៌នៅទីវត្តអារាម ឬនៅមុខផ្នូរសាកសពដើម្បីឧទ្ទិសកុសលដល់ព្រលឹងដែលចែកឋានទៅនិងសុំសេចក្តីសុខចម្រើន ។
  - សែន (កិ) : ដាក់ភោជនាហារសំបូងសង្រួងចំពោះទៅមតកបុគ្គល ឬដាក់ក្រយាបូជា ពោលពាក្យអំពាវនាវចំពោះខ្មោចបិសាច ដូចជាសែនខ្មោច សែនដូចតា សែនពែ សែនព្រេន សែនអ្នកតា ។
  - ព្រេន (ន) : សែនខ្មោចបន្តិចបន្តួច ច្រើននិយាយជាមួយនឹងពាក្យសែនថា សែនព្រេន ។
  - ផ្នូរ (ន) : ពំនូកដីដែលពូនលើរណ្តៅសាកសព ។ *ឧទាហរណ៍ :* ពូនផ្នូរ ពូនផ្នូរខ្មោច ។
  - ចេតិយ (ន) : ទីដែលគេគោរពបូជា គឺទីណាមួយទោះមានដើមឈើធំជាប្រធាន ជាទីសំគាល់ក្តី មានថ្មធំៗជាទីចំណាំក្តី ដែលអ្នកផងគេសន្មត គេជឿថា ជាទីស័ក្តិសិទ្ធិ គេតែងធ្វើសក្ការបូជាគោរពក៏ហៅថា ចេតិយទាំងអស់ តែចំពោះប្រទេសយើងសព្វថ្ងៃនេះ ចំពោះតែគារវវត្ថុដែលគេគរដោយឥដ្ឋជាដើមសម្រាប់តម្កល់ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាដើមហៅថា ចេតិយដែរ ។ ម្យ៉ាងទៀត ចេតិយជាកន្លែងដែលគេបានសាងសង់មានសណ្ឋានជាប្រាង្គកំពូលខ្ពស់ នៅតាមទីវត្តអារាមដែលមានរបងព័ទ្ធជុំវិញ ហើយនៅខាងក្នុងមានតម្កល់ឆ្អឹង ឬធាតុសាកសពរបស់ជីដូន ជីតា ឪពុកម្តាយ ... ដើម្បីជាទីសក្ការបូជារំលឹកគុណនិងសុំសេចក្តីសុខសប្បាយចម្រុងចម្រើន ។

២. ការស្តាប់

- ឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៤២ពិនិត្យរូបភាព រួចអានសេចក្តីពន្យល់និងសំណួរដើម្បីត្រៀមឆ្លើយ ។
- លោកគ្រូអ្នកគ្រូអានអត្ថបទ "ជំនឿ"ខាងក្រោមឱ្យសិស្សស្តាប់ដោយល្បឿនធម្មតា ។

ជំនឿ

កាលពីយូរលង់កន្លងមក មនុស្សលោកតែងជួបប្រទះបាតុភូតធម្មជាតិផ្សេងៗដែលខ្លួនពុំអាចជំនះបាន ។ ដោយមានការភ័យខ្លាចចំពោះអសន្តិសុខ មនុស្សចេះតែមានសេចក្តីសង្ឃឹយយ៉ាងនេះយ៉ាងនោះ ។ ពួកគេតែងសង្ឃឹយថា មានកម្លាំងក្រៅខ្លួនដ៏ខ្លាំងក្លា អាចធ្វើឱ្យមនុស្សបានសេចក្តីសុខនិងអាចធ្វើឱ្យមនុស្សមហន្តរាយ ។ ពួកគេចាប់ផ្តើមមានជំនឿលើកម្លាំងទាំងនោះ ហើយសន្មតឈ្មោះនិងបង្កើតជារូបរាងផ្សេងៗតាមសមត្ថភាពរបស់ពួកគេ ។ កម្លាំងក្រៅខ្លួនទាំងនោះក្លាយជាទីពឹងរលឹក ។ ដើម្បីបានសេចក្តីសុខសប្បាយពួកគេតែងធ្វើអំពើល្អនិងធ្វើពិធីបូជា បន់ស្រន់ អង្វរករតាមរបៀបផ្សេងៗ ។ ខ្មែរយើងមានជំនឿច្រើនដូចជា ជំនឿលើព្រលឹងម្តាយឪពុក ។

ម្តាយឪពុកមានគុណធ្ងន់មកលើកូន ទុកដូចជាព្រះនៅក្នុងផ្ទះ កូនត្រូវដឹងគុណនិងសងគុណគាត់។ ក្រោយមរណកាលទៅ ព្រលឹងលោកតែងតែនៅជួយថែរក្សាកូនចៅតទៅទៀត។ កូនៗចូលចិត្តសុំធ្មេញម្តាយឪពុកមកស្រោបមាសឬស្លាក់រូបព្រះពាក់នៅក បើម្បីនឹកឃើញគុណលោកជាប្រចាំ។ ការរំលឹកនឹកឃើញគុណរបស់ម្តាយឪពុក នាំឱ្យព្រលឹងគាត់តាមជួយឱ្យបានសេចក្តីសុខជានិច្ច។ រាល់ថ្ងៃសីល កូនៗតែងដុតធូប ទៀនថ្វាយផ្លែឈើនិងផ្កា។ រៀងរាល់ឆ្នាំ កូនចៅតែងនាំគ្នាទៅសែនព្រេននិងបង្សុកូលនៅតាមផ្ទះឬចេតិយម្តាយឪពុក ដើម្បីរំលឹកគុណលោក សុំសេចក្តីសុខ និងឧទ្ទិសកុសលទៅជូនលោក។ ពេលណាមានទុក្ខលំបាក កូនចៅតែងបន់ស្រន់រកជំនួយពីលោកមុនគេបង្អស់។

(ដកស្រង់ចេញពីសៀវភៅ "អរិយធម៌ខ្មែរ" វប្បធម៌ និងសង្គមធម៌ សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

របស់លោក សួ មុយឃៀង លោក ទិត សៀង លោក ជា ឈិន ទំព័រទី ២១-២២ បោះពុម្ពឆ្នាំ ២០០៨)

- ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស ទំព័រទី ៤២ :

ចម្លើយ :

១. ក្នុងអត្ថបទនេះ បានបង្ហាញពីប្រភពនៃជំនឿដោយសារមនុស្សជួបប្រទះនឹងបាតុភូតធម្មជាតិ ហើយពុំអាចដំនះលើបាតុភូតទាំងនោះបាន ក៏គិតសង្ឃឹមនិងមានការភ័យខ្លាចមហន្តរាយអស់ជំនឿលើសមត្ថភាពខ្លួនឯង ក៏ចាប់យកការបន់ស្រន់ អង្វរករ ...ដើម្បីសុំសេចក្តីសុខ។

២. ប្រជាជនខ្មែរយើងមិនត្រឹមតែការជឿលើការបន់ស្រន់ទៅលើបញ្ហាផ្សេងៗដែលខ្លួនខ្លាចនិងជួបប្រទះប៉ុណ្ណោះទេ សូម្បីតែឪពុកម្តាយដែលបានស្លាប់ចែកឋានទៅហើយក្តី ក៏នៅតែមានជំនឿទៅលើព្រលឹងរបស់ពួកគាត់ ហើយបន់ស្រន់សូមសេចក្តីសុខចម្រើនពីគាត់ផងដែរ។ ការជឿលើព្រលឹងឪពុកម្តាយបែបនេះ មកពីប្រជាជនយើងយល់ច្បាស់ថា ឪពុកម្តាយជាអ្នកមានគុណដ៏ធ្ងន់មកលើកូនដែលប្រៀបបានជាព្រះនៅក្នុងផ្ទះ តែងតែចាំជួយថែរក្សានិងផ្តល់សេចក្តីសុខសប្បាយ ភាពចម្រុងចម្រើនដល់កូនចៅគ្រប់ពេលវេលា។ គេក៏យល់ដែរថា វត្ថុនៅក្នុងខ្លួនឪពុកម្តាយដូចជា ធ្មេញជាដើម កាលបើកូនៗបានសុំពីលោកទាំងពីរ ហើយយកមកស្រោបមាសឬស្លាក់ជាព្រះបន្តោងខ្សែកពាក់នឹងក នោះនឹងបានសេចក្តីសុខចម្រើន ព្រោះព្រលឹងគាត់តាមជួយថែរក្សា។ ការរំលឹកគុណម្តាយឪពុក នាំឱ្យព្រលឹងគាត់បានមកតាមជួយឱ្យសេចក្តីសុខជានិច្ច។ ដូច្នេះហើយបានជារាល់ថ្ងៃសីលកូនៗចៅៗតែងដុតទៀនធូបថ្វាយផ្កាផ្លែឈើ។ល។ ដើម្បីជាការរំលឹកគុណនិងសុំសេចក្តីសុខចម្រើនពីលោកផងនិងឧទ្ទិសកុសលជូនទៅលោកផង ដើម្បីឱ្យលោកតាមជួយទ្រទ្រង់ថែរក្សាគ្រប់ពេលវេលា និងសុំចៀសផុតពីជំងឺតម្កាត់និងទុក្ខលំបាកផ្សេងៗថែមទៀតផង។

៣. ប្រជាជនខ្មែរយើងតែងជឿលើជំនឿផ្សេងៗដែលធ្លាប់មានដូចជា ៖

+ ជំនឿលើព្រលឹងម្តាយឪពុក
+ ជំនឿលើព្រលឹងមេបា
+ ជំនឿលើគ្រូអាចារ្យ បាធ្យាយ
+ ជំនឿលើអ្នកជូនអ្នកតា(ជូនតា)
+ ជំនឿលើបារមីវត្ថុស័ក្តិសិទ្ធិ

+ ជំនឿលើមន្តអាគមអូមអាម ឬមន្តអាគមគាថា "គាថាសម្រាប់សូត្រស្តោះផ្លុំស្រោចទឹក គាថាមន្តស្នេហ៍ គាថាការពារខ្លួន
+ ជំនឿលើគ្រូទាយ
+ ជំនឿលើសត្វ
+ ជំនឿលើត្រណមផ្សេងៗ
+ ជំនឿលើយ័ន្ត ។ល ។

៤. ក្នុងចំណោមជំនឿទាំងឡាយរបស់ខ្មែរ សិស្សមានសិទ្ធិបង្ហាញនូវការគោរពនិងប្រតិបត្តិទៅលើជំនឿណាមួយ អាស្រ័យលើចម្ងើយសិស្សម្នាក់ៗ ហេតុផលបញ្ជាក់របស់សិស្សម្នាក់ៗដែលអាចដូចគ្នានិងខុសគ្នា គ្រូគ្រាន់តែសម្របសម្រួលចម្ងើយ ។

៥. ការងប់ងល់នឹងជំនឿផ្សេងៗដោយខ្វះការត្រិះរិះពិចារណា នាំឱ្យមានគុណវិបត្តិជាច្រើនដូចជា ៖

+ ងាយចាញ់បោកបញ្ឆោតគេ
+ ងាយគេទាក់ទាញចូលក្នុងទង្វើឬសកម្មភាពមិនល្អណាមួយ ដែលជាទង្វើខុសនឹងច្បាប់សង្គម
+ ខូចខាតទ្រព្យសម្បត្តិ លុយកាក់ មាសប្រាក់ ពេលវេលា និងប៉ះពាល់ដល់អាយុជីវិត ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សសង្ខេបអត្ថបទឡើងវិញ ។
- គ្រូឱ្យសិស្សឆ្លើយសំណួរ ៖
  - តើអ្វីជាជំនឿ ?
  - តើជំនឿលើព្រលឹងម្តាយឪពុក មានសារៈសំខាន់ដូចម្តេច ?
  - តើប្រជាជនខ្មែរយើងតែងមានជំនឿទៅលើអ្វីខ្លះ ?



ការបញ្ចេញមតិ

១. វត្ថុបំណង

- បញ្ចេញមតិយោបល់ ទស្សនៈ ដើម្បីការគាំទ្រគំនិត ទស្សនៈ មតិយោបល់ ឬសកម្មភាពណាមួយដែលទាក់ទងនឹងបញ្ហាជំនឿដោយឈរលើការវិនិច្ឆ័យវាយតម្លៃសមហេតុសមផល
- ចូលរួមសកម្មភាពក្នុងការបញ្ចេញមតិ យោបល់ ទស្សនៈនានាទាក់ទងនឹងបញ្ហាជំនឿ ប្រពៃណី ទំនៀមទម្លាប់ ដោយមានអំណះអំណាងឬភ័ស្តុតាងបញ្ជាក់ត្រឹមត្រូវ
- បង្កើនស្មារតីយល់ដឹងខ្ពស់ ចេះត្រិះរិះពិចារណា វិនិច្ឆ័យត្រឹមត្រូវមុននឹងសម្រេចចិត្តធ្វើអ្វីមួយ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៤៣-៤៤ ។

៣. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូសរសេរចំណងជើងការបញ្ចេញមតិផ្ទាល់ខ្លួនដាក់លើក្តារខៀនរួចសួរ ៖
  - តើដូចម្តេចហៅថាការបញ្ចេញមតិ ?

  ចម្លើយ : ជាការនិយាយបង្ហាញបកស្រាយនូវគំនិត យោបល់ ទស្សនៈយល់ឃើញទៅលើអ្វីមួយ គាំទ្រទៅលើគំនិត យោបល់ ទស្សនៈណាមួយ ដោយមានអំណះអំណាង ភ័ស្តុតាងបញ្ជាក់ច្បាស់លាស់ សមហេតុសមផល ឱ្យនរណាម្នាក់ស្តាប់ តាមរយៈការពិចារណា និងវិនិច្ឆ័យបានត្រឹមត្រូវ ។

ខ. ការនិយាយ

- ឱ្យសិស្សអានសេចក្តីផ្តើមនិងអត្ថបទគំរូក្នុងសៀវភៅសិស្ស ទំព័រទី ៤៣ ។
- ឱ្យសិស្សឆ្លើយសំណួរក្នុងអត្ថបទគំរូក្នុងសៀវភៅសិស្សសិស្សទំព័រទី ៤៣ ។
- គ្រូសប្រសប្រួលនិងកែលំអចម្លើយសិស្ស ។

ចម្លើយ :

១. គំនិតអត្ថបទខាងលើ គឺជាការបញ្ចេញមតិនៅលើបញ្ហាជំនឿ ។ ការជឿគឺជាសិទ្ធិរបស់បុគ្គលម្នាក់ៗ ហើយខុសៗគ្នា ដូចជាអ្នកខ្លះជឿលើមនោគមវិជ្ជាមួយ ឬនយោបាយមួយ ខ្លះជឿលើជំនឿអរូបីដូចជាជឿលើអារក្ខអារក្សអ្នកតា ខ្មោចព្រាយបិសាច វត្ថុស័ក្តិសិទ្ធិ មន្តអាគមគាថា ។ល។ អ្នកខ្លះជឿទៅលើការបញ្ចុះបញ្ចូលរបស់អ្នកដទៃយ៉ាងងប់ងល់មិនបានពិចារណា ជាឱកាសធ្វើឱ្យជនខិលខូចឆ្លៀតកេងបន្លំ បោកប្រាស់ ។ អ្នកខ្លះទៀតជឿលើការយល់សប្តិ ស្រមើស្រមៃហួសហេតុ ។ អ្នកខ្លះទៀត យកបញ្ហាជំនឿដែលជាប្រពៃណីដ៏ល្អផូរផង់របស់ជាតិធ្វើជារបាំង ជាមធ្យោបាយដើម្បីស្វែងរកលាភសក្ការៈនិងផលប្រយោជន៍របស់ខ្លួន ប្រព្រឹត្តខុសនឹងច្បាប់សង្គមក៏មាន ។

២. តាមមតិខាងលើការងប់ងល់នឹងជំនឿអ្វីមួយដោយមិនបានពិចារណាឱ្យបានច្បាស់លាស់ គឺជាការផ្តល់ឱកាសឱ្យជនខិលខូចមួយចំនួនឆ្លៀតឱកាសកេងបន្លំភូតភរ កុហក បោកប្រាស់ ដើម្បីបម្រើឱ្យផលប្រយោជន៍របស់ពួកគេ ។

៣. អ្នកខ្លះដោយមានជំនឿលើការយល់សប្តិហួសហេតុ ក៏យកការយល់សប្តិនេះមកធ្វើជាការពិត ទៅប្រព្រឹត្តអំពើអបាយផ្សេងៗដូចជាការលេងល្បែង ការភ្នាល់ ចាក់ឆ្នោត ចាក់បាល់ ឬប្រព្រឹត្តអបាយមុខផ្សេងទៀតខុសច្បាប់ដែលនាំឱ្យគ្រួសារនិងសង្គមជួបនឹងមហន្តរាយ ។

៤. ដោយយកជំនឿធ្វើជាមធ្យោបាយ ជនខិលឆ្លៀតឱកាសរកប្រយោជន៍ឬលាភសក្ការៈ ឬបិទបាំងអំពើអាក្រក់របស់ខ្លួន ។

៥. ចុងបញ្ចប់ មតិនេះបញ្ជាក់ថា ដើម្បីចៀសវាងការខាតបង់ផលប្រយោជន៍និងចៀសផុតពីមហន្តរាយផ្សេងៗ យើងត្រូវពិចារណាស្វែងយល់ឱ្យបានច្បាស់លាស់ជាមុនសិន មុននឹងធ្វើអ្វីមួយ ឬក៏ជឿនរណាម្នាក់ ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្ស ២-៣ នាក់ឡើងនិយាយបញ្ចេញមតិយោបល់ទៅលើបញ្ហាជំនឿនៅពេលមុនកើត ពេលកើតកូន និងក្រោយពេលកើតកូន ដែលសិស្សបានសិក្សាអំណាន ក្នុងសៀវភៅសិស្សទំព័រទី ៣៩-៤១ ។
- គ្រូកែលំអការបញ្ចេញមតិយោបល់របស់សិស្សដោយផ្អែកលើគំនិតសំខាន់ៗនៃអត្ថបទដែលស្តីពីបញ្ហាជំនឿទាំងនោះឱ្យបានត្រឹមត្រូវនិងសមហេតុផល ។



ការតែងកំណាព្យ

១. វត្ថុបំណង

- ប្រាប់ឡើងវិញបានពីកំណាព្យបទទ្វេមាត្រ តាមរយៈសំណួរបំផុស
- កំណត់បានពីទម្រង់ឬក្បួនតែងកាព្យ មូលដ្ឋានបទពាក្យ ៧ និងកំណាព្យបទទ្វេមាត្រដទៃទៀតដូចជាបទ គោព័ទ្ធស្និង ពាក្យ ៧ តាមរយៈទម្រង់គំរូ
- តែងកំណាព្យបទទ្វេមាត្រ គោព័ទ្ធស្និងពាក្យ ៧តាមប្រធានបទមួយជាកំណត់និងតាមទម្រង់ក្បួនតែងកំណាព្យបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៤៥-៤៦ ។

៣. ដំណាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងសំណេរ "ការតែងកំណាព្យ" ដាក់លើក្តារខៀន ។
- ឱ្យសិស្សអានសេចក្តីផ្តើមមេរៀននិងទម្រង់(ក្បួនតែង) ក្នុងសៀវភៅសិស្សទំព័រទី ៤៥ រួចសួរសំណួរ ៖
  - តើដូចម្តេចហៅថា កំណាព្យបទទ្វេមាត្រ ?

    ចម្លើយ : កំណាព្យបទទ្វេមាត្រគឺជាកំណាព្យដែលកវីប្រើកាព្យមាត្រពីរ គឺកាព្យមាត្របទមូលដ្ឋាននិងបន្ថែម និងកាព្យមាត្រថ្មីមួយទៀត គឺកាព្យមាត្របទមូលដ្ឋាន ។
  - តើកាព្យមាត្របទមូលដ្ឋាននិងបន្ថែមមានអ្វីខ្លះ ?

    ចម្លើយ : កាព្យមាត្រមូលដ្ឋាននិងបន្ថែម មានបទគោព័ទ្ធស្និងពាក្យ ៧ បទអក្សរលួនពាក្យ ៧ បទសត្វកាងស្លាបនិងបទឆត្របីជាន់ពាក្យ ៨ ។

ខ. ការអនុវត្ត

- គ្រូឱ្យសិស្សធ្វើលំហាត់សំណេរតែងកំណាព្យបទមូលដ្ឋានពាក្យ ៧ និងបទគោព័ទ្ធស្និងពាក្យ ៧បន្ថែមលើបទពាក្យ ៧ ក្នុងសៀវភៅសិស្សទំព័រទី ៤៥ ។
- គ្រូឱ្យសិស្សអានលំណែនាំសំណេរក្នុងសៀវភៅសិស្សទំព័រទី ៤៥-៤៦ ។
- ការព្រាង :

១. ណែនាំសិស្សឱ្យជ្រើសរើសប្រធានបទមួយសម្រាប់ក្រុម ឬបុគ្គល តាមការពេញចិត្ត ។

២. ណែនាំសិស្សឱ្យរកគំនិតដើម្បីសរសេរឱ្យស្របនឹងប្រធានបទឱ្យបាន ៥វគ្គយ៉ាងតិច ដែលផ្តោតសំខាន់ទៅលើ ៖

- **ស្ថានភាពទូទៅនៃប្រធានបទ** ដែលទាក់ទងនឹងប្រធានបទទាំងបី គឺពិធីបុណ្យប្រពៃណីរបស់ខ្មែរ ជំនឿផ្សេងៗ និងប្រពៃណីទំនៀមទម្លាប់ខ្មែរមួយចំនួន ។

- **ការប្រតិបត្តិ** ប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរ ក្នុងពិធីណាមួយដែលប្រជាជនខ្មែរធ្លាប់ប្រតិបត្តិដោយការគោរពពេញចិត្ត ដោយការជឿជាក់ ... ជាអត្តសញ្ញាណជាតិ និងជាខឿនវប្បធម៌ អរិយធម៌ជាតិដ៏រុងរឿង និងវិសេសវិសាលថ្លៃថ្លា ។
- **ចំណាប់អារម្មណ៍** អ្នកសរសេរត្រូវធ្វើការចាប់អារម្មណ៍ក្នុងន័យស្ថាបនា និងសម្តែងនូវអំពើមោទនភាពចំពោះប្រពៃណី ទំនៀមទម្លាប់ទាំងឡាយណាដែលល្អ មានតម្លៃ មានប្រយោជន៍និងសារៈសំខាន់ចំពោះខ្លួន ចំពោះសង្គម និងចំពោះជាតិដទៃទៀត ។

៣. ក្នុងការសរសេរ គ្រូគប្បីណែនាំសិស្សឱ្យអនុវត្តតាមលំនាំដូចខាងក្រោម ៖

ក. ទម្រង់ឬក្បួនតែងកាព្យ

- កំណាព្យមូលដ្ឋានបទពាក្យ ៧ : ១វគ្គ មាន ៤ឃ្លា , ១ឃ្លា មាន ៧ព្យាង្គ ។

ជួនក្នុងវគ្គ :

+ ព្យាង្គទី ៧ ឃ្លាទី ១ វគ្គទី ១ ⟹ ព្យាង្គទី ២ ឬ ៤ ឃ្លាទី ២ វគ្គទី ១
+ ព្យាង្គទី ៧ ឃ្លាទី ៣ វគ្គទី ១ ⟹ ព្យាង្គទី ២ ឬ ៤ ឃ្លាទី ៤ វគ្គទី ១ មានគ្រប់វគ្គ ។


ជួនឆ្លងវគ្គ :

+ ព្យាង្គទី ៧ ឃ្លាទី ៤ វគ្គទី ១ ⟹ ព្យាង្គទី ៧ ឃ្លាទី ២ វគ្គទី ២ ⟹ ព្យាង្គទី ៧ ឃ្លាទី ៣ វគ្គទី ២ ⟹ ព្យាង្គទី ២ ឬ ៤ វគ្គទី ២ គ្រប់វគ្គ ។

- កំណាព្យបទទ្វេមាត្រគោព័ទ្ធស្នឹងពាក្យ ៧បន្ថែមលើបទពាក្យ ៧មូលដ្ឋានទូវ :

+ ព្យាង្គទី ៧ ឃ្លាទី ១ វគ្គទី ១ ⟹ ព្យាង្គទី ១ ឃ្លាទី ២ វគ្គទី ១
+ ព្យាង្គទី ៧ ឃ្លាទី ២ វគ្គទី ១ ⟹ ព្យាង្គទី ១ ឃ្លាទី ៣ វគ្គទី ១
+ ព្យាង្គទី ៧ ឃ្លាទី ៣ វគ្គទី ១ ⟹ ព្យាង្គទី ១ ឃ្លាទី ៤ វគ្គទី ១
+ ព្យាង្គទី ៧ ឃ្លាទី ៤ វគ្គទី ១ ⟹ ព្យាង្គទី ១ ឃ្លាទី ១ វគ្គទី ២ ។

- គំនូសតាងបទទ្វេមាត្រ :



ខ. ការណែនាំ

+ ឱ្យសិស្សសរសេរព្រាងនិងប្រមូលគំនិតសំខាន់ៗមកតាក់តែងជាអត្ថបទកាព្យឱ្យស្របនឹងប្រធានបទនិងខ្លឹមសារណែនាំខាងលើក្នុងចំណុចទី ២ ។

+ ឱ្យសិស្សរៀបចំនិងចងក្រងគំនិតទៅតាមលំដាប់លំដោយ ជាអត្ថបទកាព្យទ្វេមាត្រ បទគោព័ទ្ធស្មឹងពាក្យ ៧ ។

៤. ការរៀបរៀងនិងកែលំអ : ណែនាំឱ្យសិស្សសរសេរកែលំអសំណេររបស់ខ្លួនឡើងវិញដោយពិនិត្យទៅលើលំណែនាំក្នុងសៀវភៅសិស្សទំព័រទី ៤៥-៤៦ អំពី ៖

+ ទម្រង់

+ ខ្លឹមសារ

+ ពាក្យពេចន៍

+ ឃ្លា ល្បះត្រឹមត្រូវ ។

៥. ការសរសេរសម្រេច ៖

- ណែនាំសិស្សឱ្យសរសេរសម្រេចសំណេរចុងក្រោយ ដោយចម្លងចូលសន្លឹកកិច្ចការ ក្រដាសថ្មី

- គ្រូកែលំអនិងដាក់ពិន្ទុ ព្រមទាំងលើកទឹកចិត្តសិស្សដែលសរសេរបានល្អ ។

គ. ការវាយតម្លៃ

- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងសូត្រនិងបកស្រាយអត្ថន័យឬខ្លឹមសារសំណេររបស់ក្រុមខ្លួន ។



សេចក្តីក្លាហាន

មេរៀននេះមានបំណងឱ្យសិស្សសិក្សាអំពីសេចក្តីក្លាហានរបស់ពលរដ្ឋខ្មែរដែលតស៊ូពុះពារគ្រប់កាល:ទេស:ប្រឆាំងរាល់ការរំលោភបំពានពីខ្មាំងសត្រូវគ្រប់រូបភាពក្នុងស្មារតីសុទិដ្ឋិនិយមជានិច្ច ដើម្បីផលប្រយោជន៍ប្រទេសជាតិនិងមាតុភូមិជាទីស្នេហា។ សេចក្តីក្លាហាន ជាកត្តាជំរុញឱ្យមានជ័យជំនះ។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិន្នាសាស្ត្រ	ទិន្នាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	៥១	៤៧
• អំណានទី ១ : យប់មួយនៅភូមិក្រាំងលាវ	៣ម៉ោង	៤ម៉ោង	៥២-៥៤	៤៨
• វេយ្យាករណ៍ : ការបន្លឺសំឡេង	០ម៉ោង	២ម៉ោង	៥៥-៥៦	៥៤
• អំណានទី ២ : ទឹកចិត្តពោធិ៍កំបោរ	២ម៉ោង	៤ម៉ោង	៥៧-៥៨	៥៧
• ការស្តាប់ : រឿងអ្នកតាឃ្លាំងមឿង	១ម៉ោង	២ម៉ោង	៥៩-៦១	៦២
• ការនិយាយ : សង្ខេបអត្ថបទ	១ម៉ោង	២ម៉ោង	៦២-៦៣	៦៣
• សំណេរ : វិភាគអត្ថបទ	៤ម៉ោង	៤ម៉ោង	៦៤-៦៦	៦៧

១. សិក្ខាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៤៧។ លោកគ្រូ-អ្នកគ្រូ សរសេរចំណងជើងមេរៀន "សេចក្តីក្លាហាន" ដាក់លើក្តារខៀនរួចសួរ :

  - ដូចម្តេចហៅថា "សេចក្តីក្លាហាន" ?

  ចម្លើយ : សេចក្តីក្លាហានគឺជាការហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីឧត្តមប្រយោជន៍ណាមួយ។ ការហ៊ានលះបង់ដើម្បីការពារជាតិមាតុភូមិ គឺជាសេចក្តីក្លាហានដើម្បីឧត្តមប្រយោជន៍ជាតិ។

២. សិក្ខាលើរូបតាង

- ក្នុងមេរៀននេះអ្នកបានឃើញរូបអ្វីខ្លះ ?

  ចម្លើយ : មានរូបមនុស្សជាច្រើន។ ខ្លះកាន់ដំបង ខ្លះកាន់ដាវមានសម្លៀកបំពាក់ជាមេទ័ពសម័យបុរាណ។ រូបភាពនេះទំនងជាការជួបជុំគ្នាមួយ ដើម្បីរៀបចំប្រយុទ្ធ។

- តើរូបភាពនេះ មានន័យដូចម្តេច ?

  ចម្លើយ : បញ្ជាក់ឱ្យឃើញពីស្មារតីសាមគ្គីភាព ការរួមកម្លាំងប្រកបដោយសេចក្តីក្លាហានរបស់ប្រជាជនខ្មែរក្នុងបុព្វហេតុការពារមាតុភូមិ។

យប់មួយនៅភូមិក្រាំងលាវ

១. វត្ថុបំណង

- រៀបរាប់ពីប្រភពអត្ថបទនិងកាលអាកាស តាមរយៈអត្ថបទដកស្រង់បានច្បាស់លាស់
- រកឃើញមូលន័យ មូលបញ្ហា និងតម្លៃអប់រំតាមរយៈការវិភាគអត្ថបទបានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យមានទឹកចិត្តស្រឡាញ់ជាតិមាតុភូមិ តាមរយៈសកម្មភាពតួអង្គក្នុងអត្ថបទដកស្រង់បានជាក់លាក់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៤៨ ដល់ ៥៣

៣. ព័ត៌មានជំនួយ

សូមលោកគ្រូ/អ្នកគ្រូរកសៀវភៅរឿងភូមិតិរច្ឆាន ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពឆ្នាំ ១៩៩៧ ដើម្បីប្រើប្រាស់ជាជំនួយដល់ការសិក្សាអត្ថបទនិងការធ្វើលំហាត់ ។

៤. ដំណាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៤៨ ហើយអានចំណងជើង រួចគ្រូសរសេរ " យប់មួយនៅភូមិក្រាំងលាវ" ដាក់លើក្តារខៀននិងសួរ :
  - តើចំណងជើងអត្ថបទអំណាននិយាយពីអ្វី ?

    ចម្លើយ : យប់មួយនៅភូមិក្រាំងលាវ ។
  - តើភូមិក្រាំងលាវនៅឯណា ?

    ចម្លើយ : នៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។
- លោកគ្រូអ្នកគ្រូឱ្យសិស្សសង្កេតរូបភាពរួចសួរ :
  - តើរូបភាពនេះបង្ហាញពីអ្វី ?

    ចម្លើយ : បង្ហាញពីមនុស្សមួយក្រុម ខ្លះអង្គុយ ខ្លះឈរ ភាគច្រើនជាបុរសហាក់ដូចជាកំពុងជជែកគ្នាពីរឿងអ្វីមួយ ។
  - តើចំណងជើងនិងរូបភាពនេះមានការទាក់ទងគ្នាដូចម្តេច ?

  ចម្លើយ : ចំណងជើងអត្ថបទទាក់ទងនឹងរូបភាព គឺយប់មួយមានមនុស្សមួយក្រុមកំពុងជួបជុំជជែកគ្នាពីរឿងអ្វីមួយនៅកន្លែងមួយ ។
- គ្រូឱ្យសិស្សសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ៤៨-៤៩ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិន ក្នុងសៀវភៅសិស្សទំព័រទី ៤៩ ។
- គ្រូឱ្យសិស្សអានអត្ថបទអំណាន(អានឮ ឬអានស្ងាត់តាមស្ថានភាពជាក់ស្តែង) ក្នុងសៀវភៅសិស្សទំព័រទី ៤៩ ។
- គ្រូឱ្យសិស្សអានសំណួរ ក្នុងសៀវភៅសិស្សទំព័រទី ៥៣ ។

គ. ពង្រឹងអំណាន

គ្រូឱ្យសិស្សឆ្លើយសំណួរ ក្នុងសៀវភៅសិស្សទំព័រទី ៥៣ :

ចម្លើយ :

១. រឿងភូមិតិរច្ឆាន និពន្ធដោយលោក ខៀក អំ(ខឿក អំ) និងលោក ឌឹក គាម រៀបរៀងនៅឆ្នាំ ១៩៦៤-១៩៦៥ ។

២. អ្នកភូមិក្រាំងលាវប្រកបរបរកសិកម្មធ្វើស្រែនិងឡើងត្នោត ។ ក្រោយរដូវច្រូតកាត់ អ្នកភូមិនេះកំពុងប្រញឹកដៃធ្វើត្នោតគ្រប់កន្លែង ។ ពេលយប់ទំនេរពីការងារគេចូលចិត្តលេងល្បែងប្រជាប្រិយដូចជា បោះអង្គញ់ ចោលឈូង លោតអន្ទាក់ ចាប់កូនខ្លែង ។ល។ អ្នកខ្លះទៀតហាត់វិជ្ជាគុន ចំបាប់ ។

៣. ជួននិងនៅ ជាអ្នកភូមិព្រៃខ្មែរ ។ គេទាំងពីរមានបំណងបញ្ចុះបញ្ចូលអ្នកភូមិក្រាំងលាវឱ្យចូលរួមក្នុងគម្រោងការណ៍សម្លាប់ រ៉េស៊ីដង់បារដេស ។

៤. ដំណើររឿងប្រព្រឹត្តទៅនៅទីវាលមួយ ក្នុងភូមិផ្លូវគោ ឃុំក្រាំងលាវ ។

៥. មូលន័យក្នុងអត្ថបទនេះ គឺជីវិតប្រជារាស្ត្រខ្មែរក្នុងសម័យអាណានិគមនិយមបារាំង ។ មូលបញ្ហាក្នុងអត្ថបទនេះ គឺការប្រើអំណាចរបស់រ៉េស៊ីដង់បារដេស ធ្វើបាបប្រជារាស្ត្រតាមរយៈការជិរីតទារពន្ធហួសហេតុ ។

៦. អត្ថបទនេះមានតម្លៃអប់រំដូចតទៅ ៖

+ បណ្តុះស្មារតីកូនខ្មែរឱ្យស្រឡាញ់ជាតិមាតុភូមិ
+ ហ៊ានលះបង់ជីវិតដើម្បីជាតិមាតុភូមិនៅពេលណាមានបរទេសឈ្លានពាន
+ សុខចិត្តស្លាប់ខ្លួន ឱ្យតែជាតិរស់
+ ស្លាប់ដើម្បីរស់ ចាញ់ដើម្បីឈ្នះ ។

៧. គម្រោងការណ៍របស់ ជួននិងនៅ ក្នុងបំណងសម្លាប់រ៉េស៊ីដង់បារដេសនឹងបានទទួលជោគជ័យព្រោះ ៖

+ ជួននិងនៅ មានការប្តេជ្ញាចិត្តខ្ពស់ ។ សម្តីជួន "...ខាងខ្ញុំទាំងពីរនាក់នេះ ...បានស្រុះចិត្តគ្នាជាស្រេចថានឹងសម្លាប់បារាំងកំណាចឈ្មោះ បារដេស នេះឱ្យបាន..." ។
+ ក្រុមអ្នកភ្លាហានមានការឈឺចាប់ចំពោះសកម្មភាពអមនុស្សធម៌ "...ប៉ុន្តែ គំនិត ជួន ដែលចង់សម្លាប់បារាំងកំណាចនេះគឺក្នុងនាមខ្មែរម្នាក់ដែលមិនសុខចិត្តនឹងអំពើជិះជាន់យ៉ាងអមនុស្សធម៌ពីសំណាក់បារាំង..." ។
+ ក្រុមអ្នកភ្លាហានស្ម័គ្ររួមសាមគ្គីគ្នាជាធ្លុងមួយ ។ ក្រោយពី ជួន បង្ហាញហេតុដែលគេចង់សម្លាប់រ៉េស៊ីដង់បារដេស រួចមក អ្នកស្តាប់ទាំងអស់ស្រែកព្រមគ្នាថា "...ខ្ញុំសុំចូលដៃផងៗ" ។

+ ក្រុមអ្នកក្លាហានមានគំនិតសុទិដ្ឋិនិយម។ សម្តីនៅ " ...រឿងនេះពុំមែនជាឆាកកំប្លែង ...មានស្លាប់មានរស់ ព្រោះបារាំងមានអំណាចលើខ្មែរ បើយើងសម្លាប់គេបានមួយគេក៏ហ៊ានសម្លាប់យើងបានដប់ម្តែដែរ"។ អ្នកក្រាំងលាវម្នាក់បាននិយាយថា "ល្បងជួន ល្បងនៅចេះចង់សម្លាប់បារាំងដើម្បីបុព្វហេតុដ៏ត្រឹមត្រូវនៃប្រជាជនខ្មែរ ចុះអ្នកក្រាំងលាវមិនមែនខ្មែរទេឬ ? ចំពោះរូបខ្ញុំមួយ ខ្ញុំមិនស្ពោះទឹកមាត់ហើយលេបមកវិញជាដាច់ខាត!" អ្នកឯទៀតក៏ស្រែកព្រមគ្នាថា "ខ្ញុំក៏អ៊ីចឹងដែរៗ"។

៨. វិភាគតួអង្គ

- ជួននិងនៅ :

  + គុណសម្បត្តិ : ជាអ្នកក្លាហានមិនខ្លាចស្លាប់ ព្រោះការស្លាប់របស់គាត់គឺដើម្បីបុព្វហេតុប្រជាជន។ មានគំនិតស្នេហាជាតិជ្រាលជ្រៅ ចេះវិភាគច្បាស់លាស់ពីស្ថានភាពនៃសកម្មភាពរបស់ខ្លួន ក្រោយពេលសម្លាប់បារាំង។ ចេះបង្ហាញហេតុផលច្បាស់លាស់និងឱ្យអ្នករួមដៃជាមួយយល់ពីចំណងរបស់ខ្លួន ដើម្បីរួមគ្នាជាកម្លាំងក្នុងការសម្លាប់រ៉ៃស៊ីដង់បារដេស។

  + គុណវិបត្តិ : មានស្នាមចរិតជាអ្នកលេងខាងក្បាច់គុន កាប់ចាក់(ជើងឯកអ្នកស្រុកព្រៃខ្មែរ)។

- លោករ៉ៃស៊ីដង់បារដេស(តួអង្គនេះពុំមានសកម្មភាពទេ តែយើងវិភាគតាមរយៈសម្តីតួអង្គក្នុងអត្ថបទ) : ជាមន្ត្រីបារាំង អ្នកប្រចាំការក្នុងខេត្តកំពង់ឆ្នាំង ៖

  + គុណវិបត្តិ : បានធ្វើការលើសតួនាទីរបស់ខ្លួនគឺដើរទារពន្ធពីប្រជារាស្ត្រខ្មែរក្នុងខេត្តដោយខ្លួនឯង(ការទារពន្ធពីប្រជារាស្ត្រក្នុងឃុំ ជាតួនាទីមេឃុំ)។ ប្រើអំណាចផ្តាច់ការក្នុងការទារពន្ធអាករពីប្រជារាស្ត្រដោយការបង្ខិតបង្ខំកាចសាហាវ(វាយដំ ច្រំធាក់រាស្ត្រទាំងកម្រោល)។

- ឱ្យសិស្សកត់ចម្លើយចូលក្នុងសៀវភៅ

ឃ. ការវាយតម្លៃ

- ឱ្យសិស្សសង្ខេបអត្ថបទឡើងវិញ
- សំណួរសម្រាប់ស្រាវជ្រាវ :

  - តាមរយៈសកម្មភាពតួអង្គឯកទាំងពីរ ព្រមទាំងបក្សពួករបស់គាត់ខាងលើអាចនឹងផ្តល់បទពិសោធន៍អ្វីខ្លះដល់អ្នកសិក្សាសម័យនេះ។

  ចម្លើយ : សកម្មភាពជួននិងនៅ និងបក្សពួករបស់គាត់បានផ្តល់បទពិសោធន៍ដល់មនុស្សសម័យក្រោយដូចជា ៖

  + ឱ្យចេះស្រឡាញ់ជាតិមាតុភូមិ ស្រឡាញ់ជាតិសាសន៍ខ្លួនឯង
  + ឱ្យចេះឈឺចាប់ចំពោះការប្រមាថមើលងាយរបស់បរទេសមកលើជាតិខ្លួនឯង
  + ឱ្យមានស្មារតីសាមគ្គីភាពរវាងខ្មែរគ្នាឯងដើម្បីកំចាត់បរទេសឈ្លានពាន "សាមគ្គីរស់ បែកសាមគ្គីស្លាប់"។
  + ...

ការបន្ថឺសំឡេង

១. វត្ថុបំណង

- រៀបរាប់ពីនិយមន័យនៃលក្ខណៈបន្ថឺសំឡេង លក្ខណៈខ្សល់បានត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន
- ទីបន្ថឺព្យញ្ជនៈបានត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៥៤-៥៦

៣. ព័ត៌មានដំឆ្លួយ

សូមលោកគ្រូ/អ្នកគ្រូមើលសៀវភៅវេយ្យាករណ៍ ថ្នាក់ទី ៥ បោះពុម្ពឆ្នាំ ១៩៨១ដើម្បីប្រើប្រាស់ជាជំនួយដល់ការសិក្សាអត្ថបទនិងការធ្វើលំហាត់ ។

៥. ឈានាំមបង្រៀន

ក. ការបង្ហាញ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៥៤ ហើយសរសេរចំណងជើង "ការបន្ថឺសំឡេង" ជាក់លើក្តារខៀន ។
  - តើសំឡេងជាអ្វី ?

    ចម្លើយ : គឺជាសូររលកដែលបានមកពីការប៉ះគ្នារវាងវត្ថុពីរ ឬច្រើនរសាត់មកប៉ះនឹងក្រដាសត្រចៀក ។
  - តើការបន្ថឺសំឡេងជាអ្វី ?

    ចម្លើយ : ជាការបញ្ចេញសូរសព្ទឱ្យលាន់ឮខ្លាំងឡើង ធ្វើឱ្យខ្ទរលាន់ឮសាយ ។
- ឱ្យសិស្សអានសេចក្តីពន្យល់ឧទាហរណ៍និងសំណួរក្នុងសៀវភៅសិស្ស
  - ដូចម្តេចហៅថា ការបន្ថឺសំឡេង ?

    ចម្លើយ : មានក្នុងសៀវភៅសិស្សទំព័រទី ៥៥ ។
  - តើការបង្កើតសូរសំឡេងត្រូវប្រកបដោយលក្ខណៈប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

    ចម្លើយ : មាននៅក្នុងសៀវភៅសិស្សទំព័រទី ៥៥ ។

ខ. ការហ្វឹកហាត់

- ឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ៥៦ ។

  ចម្លើយ :

១. ការបន្ថឺបន្ថឺសូរត្រូវពឹងផ្អែកលើការរៀបចំប្រដាប់បន្ថឺលើចលនាខ្សល់និងលើភាពឮ ។

២. លក្ខណៈបន្ថឺសំដៅយករបៀបរៀបចំនិងចលនានៃប្រដាប់បន្ថឺ ។ លក្ខណៈបន្ថឺមានការចូលរួមរបស់ប្រដាប់បន្ថឺនិងទីបន្ថឺ ។

៣. តាមលក្ខណៈខ្យល់ សូរសំឡេងចែកជា ៖

+ សូរមានខ្យល់និងគ្មានខ្យល
+ សូរខ្យល់ស្ទះ
+ សូរខ្យល់ច្រមុះ
+ សូរខ្យល់បង្ហូរត្រដុស
+ សូរខ្យល់រែងនិងសូរខ្យល់ខ្លី ។

៤. ព្យញ្ជនៈ ក[k] ខ[kh] ជ[c] ឈ[ch] ញ[ɲ] យ[j] រ[r] ហ[h] ស្ថិតក្នុងព្យញ្ជនៈសូរឮតាមភាពញ័រនៃខ្សែសំឡេង ។

៥. សិក្សាមូលភេទ អ-អ៊ ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងស្រៈ ព្យញ្ជនៈក្នុងការសរសេរនិងក្នុងវិធីអានសំណេរភាសាខ្មែរ ។

- សិស្សកត់ត្រាចម្លើយត្រឹមត្រូវក្នុងសៀវភៅ ។

គ. ការវាយតម្លៃ

- សួរសំណួរបញ្ជាក់ការយល់ដឹងទៅលើបញ្ញត្តិ

  - តើសិក្សាអំពីការបន្លឺសំឡេងដើម្បីអ្វី ?

  ចម្លើយ : ការសិក្សាអំពីការបន្លឺសំឡេងដើម្បីឱ្យស្គាល់លក្ខណៈបន្លឺ លក្ខណៈខ្យល់ និងលក្ខណៈឮ ។

- ដាក់លំហាត់ឱ្យសិស្សធ្វើក្នុងថ្នាក់
- ចូរជ្រើសរើសព្យាង្គខាងក្រោមដាក់តាមពួក អ-អ៊ ៖

  - ពេលយប់នោះមានការជួបជុំជនមួយក្រុមនៅទីវាលមួយក្នុងភូមិផ្លូវគោ ។

  ចម្លើយ :

  + ព្យាង្គពួក អ : ការ ក្រុម ក្នុង ផ្លូវ ។
  + ព្យាង្គពួក អ៊ : ពេល យប់ នោះ មាន ជួប ជុំ ជន មួយ នៅ ទី វាល មួយ ភូមិ គោ ។

  - ថៅ សុខ ដើរ រត់ លោត លេង តាម សួន ។

  ចម្លើយ :

  + ព្យាង្គពួក អ : ថៅ សុខ ដើរ តាម សួន ។
  + ព្យាង្គពួក អ៊ : រត់ លោត លេង ។

- ដាក់លំហាត់ឱ្យសិស្សស្រាវជ្រាវ ។

  - ចូរស្រង់សញ្ញាស្រៈពួក អ និងពួក អ៊ ពីក្នុងព្យាង្គខាងក្រោមដោយមានសេចក្តីពន្យល់ផង ៖ កូន គោ កាច ដោយ វាល ជូន ។

  ចម្លើយ :

  + "កូន កាច ដោយ" ដឹងថាជាសញ្ញាស្រៈពួក អ គឺ "◌ូ ◌ា និង ◌ោ" ដោយសារតែសញ្ញាព្យញ្ជនៈ "ក ដ" ។
  + "គោ វាល ជូន" ដឹងថាជាសញ្ញាស្រៈពួក អ៊ គឺ "◌ោ ◌ា និង ◌ូ" ដោយសារតែសញ្ញាព្យញ្ជនៈ "គ វ ជ" ។



ទឹកចិត្តពោធិ៍កំបោរ

១. វត្ថុបំណង

- រៀបរាប់ពីកាលអាកាសនិងតួអង្គ តាមរយៈអត្ថបទដកស្រង់បានត្រឹមត្រូវ
- ដោះស្រាយបញ្ហានិងវិភាគតួអង្គ តាមរយៈខ្លឹមសារអត្ថបទបានច្បាស់លាស់
- បណ្តុះស្មារតីស្រឡាញ់ជាតិមាតុភូមិ តាមរយៈសកម្មភាពតួអង្គក្នុងអត្ថបទបានច្បាស់លាស់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៥៧-៦១

៣. ព័ត៌មានជំនួយ

សូមលោកគ្រូ/អ្នកគ្រូរកឯកសារប្រវត្តិសាស្ត្រ ពោធិ៍កំបោរ រៀបរៀងចងក្រងដោយលោក ស៊ូ ចំរើន ដើម្បីប្រើប្រាស់ជាជំនួយដល់ការសិក្សាអត្ថបទនិងការធ្វើលំហាត់ ។

៤. ដំណាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៥៧ រួចសរសេរចំណងជើង "ទឹកចិត្តពោធិ៍កំបោរ" ដាក់លើក្តារខៀននឹងសួរ :
  - តើពោធិ៍កំបោរជានរណា ?

    ចម្លើយ : ពោធិ៍កំបោរគឺជាឈ្មោះវីរជនខ្មែរនៅសម័យអាណានិគមនិយមបារាំង ។
  - តើចំណងជើងអត្ថបទនេះមានន័យដូចម្តេច ?

    ចម្លើយ : ន័យចំណងជើងគឺនិយាយពីស្មារតី គំនិត សកម្មភាពរបស់ពោធិ៍កំបោរដើម្បីបុព្វហេតុប្រជារាស្ត្រនិងជាតិមាតុភូមិនាសម័យអាណានិគម ។
- លោក/អ្នកគ្រូឱ្យសិស្សសង្កេតរូបភាពរួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

    ចម្លើយ : ឃើញមនុស្សប្រុសស្រីជាច្រើនកាន់ដំបង កាំបិត ចបកាប់ ចបជីក ... ដើរទៅមុខក្នុងភូមិមួយ ។
  - តាមសកម្មភាពនៃរូបភាពនេះមានន័យដូចម្តេច ?

    ចម្លើយ : ក្រុមមនុស្សទាំងអស់នេះកំពុងប្រុងប្រៀបប្រយុទ្ធទាមទារអ្វីមួយដែលគេចង់បាន ។
  - តើចំណងជើងនិងរូបភាពនេះមានការទាក់ទងគ្នាដូចម្តេចខ្លះ ?

    ចម្លើយ : ប្រជារាស្ត្រខ្មែរដែលមានពោធិ៍កំបោរជាអ្នកដឹកនាំកំពុងរួមគ្នាដើរជាក្បួនធ្វើការតស៊ូប្រឆាំងពួកអាណានិគមបារាំង ។
- គ្រូឱ្យសិស្សសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ៥៧-៥៨ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ៥៨ ។
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ៦១

- គ្រូឱ្យសិស្សអានអត្ថបទ(អានឮឬអានស្ងាត់តាមលទ្ធភាពជាក់ស្តែង) ។

គ. ពង្រឹងអំណាន

លោកគ្រូ-អ្នកគ្រូឱ្យសិស្សឆ្លើយសំណួរ ក្នុងសៀវភៅសិស្សទំព័រទី ៦១

ចម្លើយ :

១. ពោធិ៍កំបោរជាអ្នកក្លាហាន ហ៊ានលះបង់ជីវិតដើម្បីប្រទេសជាតិដូចសម្តីដែលថា "យើងជាខ្មែរចាំបាច់ត្រូវការពារទឹកដីខ្មែរឱ្យគង់វង្សរហូតទៅ ..." ។ "...ខ្ញុំមិនចង់បានបុណ្យសក្តិ ក្រៅពីចង់បានឯករាជ្យជូនមាតុភូមិនិងប្រជាជនខ្មែរនោះទេ ទោះជា មួយជំហានស្លាប់ក៏ខ្ញុំនៅតែតស៊ូប្រឆាំងជាមួយបារាំងដាច់ខាត" ។

២. ពោធិ៍កំបោរមានគំនិតស្នេហាជាតិនៅត្រង់សម្តីដែលថា " ...ឱ! មាតុភូមិខ្មែរដែលឱ្យកំណើតដល់រូបអញមក មិនបើគួរសសៀរទៅរកហាយនភាពដោយសារតែជាតិសាសន៍ដទៃជាអាណាព្យាបាលអ៊ីចឹងសោះ ។ យើងជាខ្មែរចាំបាច់ត្រូវការពារទឹកដីឱ្យគង់វង្សរៀងរហូតទៅ ..." ។

៣. អត្ថបទនេះមានតួអង្គ : ពោធិ៍កំបោរ , មេក្រុមឆន , ក្រុមការសៅ , ក្រុមអ្នកតស៊ូ , បក្សពួកក្រុមការសៅកងទ័ពបារាំង , តួអង្គឯកមាន មេក្រុមឆន និងក្រុមការសៅ ។

៤. កាល : ថ្ងៃនេះ មួយរំពេចនោះ ។ អាកាស : ភូមិសុរិល ភូមិពាមមង្គល ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ស្វាយ ។

៥. វិភាគតួអង្គពោធិ៍កំបោរ :

- គុណសម្បត្តិ : ជនស្នេហាជាតិពិតប្រាកដ ,វីរជនអង់អាចក្លាហានមិនខ្លាចស្លាប់ , មានចិត្តអាណិតអាសូរជនជាតិរបស់ខ្លួនដែលសម្លាប់គ្នាឯង , មានចំណេះដឹងទូលំទូលាយ មើលឃើញអំពើអាក្រក់របស់ពួកអាណានិគមនិយមបារាំងដែលធ្វើមកលើរាស្ត្រខ្មែរ , ជាមេដឹកនាំឈ្លាស្គាប់មតិសមូហភាពមុននឹងធ្វើអ្វីមួយ , មានគំនិតសុទិដ្ឋិនិយមចំពោះទង្វើរបស់ខ្លួន ។
- គុណវិបត្តិ : ឆាប់ជឿទុកចិត្តមនុស្សអាក្រក់ដោយមិនបានស៊ើបសួរឱ្យច្បាស់មុនទទួលចូលក្នុងក្រុម ។

៦. តម្លៃអប់រំ : បណ្តុះស្មារតីស្នេហាជាតិ , ពេលប្រទេសមានការឈ្លានពានត្រូវហ៊ានលះបង់ជីវិត , រួមសាមគ្គីគ្នាការពារទឹកដី , ស្អប់ខ្ពើមពួកលក់ខ្លួនបម្រើបរទេសពួកពូកែអែបអប ... ។

- ឱ្យសិស្សកត់ចម្លើយចូលក្នុងសៀវភៅ ។

ឃ. ការវាយតម្លៃ

- សង្ខេបអត្ថបទឡើងវិញ
- ដាក់លំហាត់ឬសំណួរថ្មីសម្រាប់ស្រាវជ្រាវ
  - តើអ្នករៀបរៀងចងក្រងឯកសារប្រវត្តិសាស្ត្រពោធិ៍កំបោរឈ្មោះអ្វី ? ចូរនិយាយពីទស្សនៈរបស់គាត់តាមរយៈអត្ថបទនេះ ។

    ចម្លើយ : ឈ្មោះ ស៊ូ ចំរើន ។ ទស្សនៈរបស់គាត់គឺ ចង់បង្ហាញពីទិដ្ឋភាពសង្គមដែលប្រជារាស្ត្រមានការបែកបាក់គ្នាប្រទេសជាតិឆ្ពោះទៅរកភាពវិនាសខ្ទោចផ្សា ។(តាមគំនិតរបស់តួអង្គពោធិ៍កំបោរ) , ត្រូវបញ្ឈប់ការកាប់សម្លាប់ជនជាតិគ្នាឯង(ខ្មែរត្រូវស្រឡាញ់អាណិតឈាមខ្មែរដូចគ្នា),ទីណាមានការជិះជាន់ ទីនោះត្រូវតែមានការតស៊ូរើបម្រះ ... ។
- ដាក់សំណួរផ្សារភ្ជាប់នឹងជីវភាពជាក់ស្តែង ... ។
- ចូរស្រង់ឃ្លាដែលពោធិ៍កំបោរគិតថាជាប្រផ្នូលអាក្រក់ ហើយវិភាគឃ្លានេះទៅនឹងដំណើររឿង រួចសាកល្បងរកប្រផ្នូលផ្សេងទៀតដែលមានលំនាំប្រហាក់ប្រហែលគ្នា ហើយជាជំនឿរបស់ប្រជារាស្ត្រជាយូរមកហើយ ។ (ផ្កាយដុះកន្ទុយ ស្រុកកើតសង្គ្រាម ...) ។



រឿង អ្នកតាឃ្លាំងមឿង

១. វត្ថុបំណង

- រៀបរាប់បានអំពីកាលអាកាសតាមរយៈអត្ថបទស្តាប់បានច្បាស់លាស់
- វិភាគតួអង្គនិងរកឃើញគំនិតសំខាន់តាមរយៈអត្ថបទស្តាប់បានត្រឹមត្រូវ
- បណ្តុះស្មារតីស្នេហាជាតិនិងមានសាមគ្គីរឹងមាំតាមរយៈសំណួរបំផុស ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៦២

៣. ព័ត៌មានបំនួយ

សូមលោកគ្រូ/អ្នកគ្រូមើលប្រជុំរឿងព្រេងខ្មែរភាគទី ៨ (ប្រវត្តិអ្នកតាឃ្លាំងមឿង) ដើម្បីប្រើប្រាស់ជាជំនួយដល់ការសិក្សាអត្ថបទនិងការធ្វើលំហាត់ ។

៤. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៦២ ហើយសរសេរចំណងជើង "រឿងអ្នកតាឃ្លាំងមឿង" ដាក់លើក្តារខៀន រួចសួរសំណួរ :
  - តើពាក្យអ្នកតាមានន័យដូចម្តេច ?

    ចម្លើយ : អ្នកតាគឺពាក្យសម្រាប់ភូតបិសាច ឬទេពរក្សប្រុសដែលមានខ្មមឬរោងអាស្រ័យជាលំនៅឬឥតលំនៅយ៉ាងនោះក៏មាន ។
  - តើរឿងអ្នកឃ្លាំងមឿងនិយាយពីអ្វី ?

    ចម្លើយ : គឺនិយាយពីប្រវត្តិរបស់ឃ្លាំងមឿងដែលក្លាយជាអ្នកតា ។
- ឱ្យសិស្សមើលរូបភាពរួចសួរសំណួរ ។
  - តើអ្នកបានឃើញរូបអ្វីខ្លះ ?

    ចម្លើយ : មនុស្សស្លៀកពាក់ជាកងទ័ពបែបបុរាណ ខ្លះជិះលើដំរី ខ្លះជិះសេះ ខ្លះទៀតឈរលើដី កាន់ដាវ កាន់លំពែងក្នុងសម្លៀកបំពាក់កំពុងប្រយុទ្ធគ្នា ។
  - តើចំណងជើងអត្ថបទមានទាក់ទងទៅនឹងរូបភាពយ៉ាងណាខ្លះ ?

    ចម្លើយ : អាចទាក់ទងគ្នាក្នុងបណ្តាកងទ័ពដែលកំពុងប្រយុទ្ធគ្នាអាចមានអ្នកក្លាហានមឿងក្នុងនោះដែរ ។
- សិក្សាពាក្យគន្លឹះមួយចំនួន ។

ខ. ការស្តាប់

- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ៦២
- គ្រូអានអត្ថបទដោយល្បឿនធម្មតាឱ្យសិស្សស្តាប់ ។

អ្នកតាឃ្លាំងមឿង

[...] ជ័យអស្ចារ្យ លុះបានទទួលស្បៀងបន្ថែមអំពីព្រះថៅ ក៏បន្តដំណើរទៅទៀត។ ចំនួន ៥ថ្ងៃក្រោយមក ក៏បានដល់ស្រុកបាត់ដំបងដែលជាដីខ្មែរ។ មានអ្នកស្រុកជិតឆ្ងាយគ្រប់តំបន់ រត់មកចុះចូលថ្វាយខ្លួនជាពលសេនា ព្រមទាំងសេនាចាស់ម្នាក់ ធ្លាប់បម្រើព្រះវរបិតា ឈ្មោះ មឿង និងកូនប្រុស ៤នាក់ បានចូលមកថ្វាយខ្លួនដែរ ក៏មានមនុស្សច្រើនល្មមតទល់នឹងព្រះថៅសៀមបាន។

[...] បីខែក្រោយមក ទើបជ័យអស្ចារ្យប្រកាសខ្លួនឱ្យអ្នកស្រុកដឹងថា ខ្លួនហ្នឹងហើយជាព្រះរាជបុត្ររបស់ព្រះចន្ទរាជា គង់នៅបន្ទាយលង្វែក ឥឡូវនេះវិលមកគ្រងរាជ្យស្នងព្រះបិតា។ រឿងនេះ មិនបាត់ស្ងាត់ជ្រាបដល់ព្រះថៅសៀម ទ្រង់ព្រះពិរោធយ៉ាងខ្លាំងពន់ពេក នឹកតូចព្រះទ័យក្រៃលែង ទ្រង់ប្រជុំពួកសេនាយោធាប្រាប់ថា ជ័យអស្ចារ្យ ប្រើឧបាយកលបោកបញ្ឆោតយកព្រះខ័នសឹកព្រមទាំងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណរត់ទៅស្រុកខ្មែរ ហេតុនេះត្រូវលើកទ័ពតាមទៅដណ្តើមយកមកវិញឱ្យបាន ហើយចាប់ជ័យអស្ចារ្យសម្លាប់ឱ្យផុតពូជព្រះចន្ទរាជា ព្រមទាំងពួករាជការទាំងប៉ុន្មានកុំឱ្យសល់។

ជ័យអស្ចារ្យ បានដំណឹងច្បាស់ថា ព្រះថៅសៀមលើកទ័ពមកតាមដូចនោះទ្រង់ជំនុំនឹងសេនាបតី ឥឡូវពលសេនាយើងនិងគ្រឿងអាវុធយុទ្ធភណ្ឌរបស់យើងពុំបរិបូណ៌ តើអ្នករាល់គ្នាគិតរកឧបាយកលបែបណាឱ្យបានជ័យជំនះពេលនេះ ? សេនាទាំងអស់មិនមានអ្នកណាមួយហ៊ានឆ្លើយទទួលធានាអះអាងសោះ មានតែសេនាមឿង ឆ្លើយធានាអះអាង ហ៊ានតទល់នឹងទ័ពសៀមដោយឧបាយមួយដ៏ចម្លែក គឺហ៊ានបូជាជីវិតដើម្បីនឹងទៅកេណ្ឌពលខ្មោច ធ្វើជាទ័ពច្បាំងនឹងពលសៀម។ ទើបលោកបង្គាប់ឱ្យជីករណ្តៅទំហំ ៤ម៉ែត្របួនជ្រុង រួចឱ្យដាំគ្រឿងសស្ត្រាវុធក្នុងរណ្តៅនោះ ដើម្បីនឹងលោតទៅឱ្យជង់ស្លាប់ក្នុងរណ្តៅ។ តែនៅពេលមុននឹងលោតសម្លាប់ខ្លួននោះ សេនាមឿង បង្គាប់ឱ្យពួកពលទាំងអស់មកស្តាប់ពាក្យឱវាទលោក។ លោកប្រកាស "សូមឱ្យអស់លោកខំប្រឹងយកចិត្តទុកដាក់ក្នុងរឿងពេលនេះ ដើម្បីរំដោះដែនដីខ្មែរឱ្យបានរួចអំពីកណ្តាប់ដៃនៃបច្ចាមិត្ត។ ចំណែកខ្ញុំ ខ្ញុំធានាខាងទ័ពខ្មោចសូមអស់លោកសង្ឃឹមទុកចុះ។ បើខ្ញុំស្លាប់ទៅបាន ៧ថ្ងៃ ឮសូរសន្ធឹកហ៊ោកញ្ជ្រៀវបីដូចជាសំឡេងផ្គរលាន់ យើងនឹងមានជ័យហើយ"។ លុះផ្តាំរួច ក៏លោតចុះរណ្តៅព្រឹប ប្រពន្ធឃើញប្តីលោតដូចនោះ ក៏លោតទៅជាមួយនឹងប្តី ព្រមទាំងកូនប្រុសពីរនាក់ស្លាប់ជាមួយគ្នា។ ដល់ថ្ងៃជាគម្រប់ ក៏លាន់ឮសូរសន្ធឹកដូចកាលផ្តាំមែន។

ទ័ពសៀមចូលមកដល់បាត់ដំបង ឆ្លងចូលមកដល់អូរមួយ(សព្វថ្ងៃ គេហៅថា "អូរស្វាយដូនកែវ") ជួបគ្នានឹងទ័ពជ័យអស្ចារ្យ។ ទ័ពខ្មោចចេញទៅមុនសម្តែងឫទ្ធិ ធ្វើឱ្យពលសៀមវិលមុខ ចុកពោះ ចុះក្អួតជួលខ្លួនឯងស្រួសៗ។ ទ័ពព្រះជ័យអស្ចារ្យចូលទៅកាប់សម្លាប់អស់។ ពួកកងទ័ពសៀមទប់ទល់មិនបានថយទៅដល់បាត់ដំបង ធ្វើសារទៅក្រាបទូលព្រះថៅតាមដំណើរសព្វគ្រប់។ ព្រះថៅទ្រង់ជ្រាបឱ្យទ័ពថយត្រឡប់ទៅស្រុកសៀមវិញ។

ចំណែកកងទ័ពព្រះជ័យអស្ចារ្យ នាំគ្នាត្រឡប់មកកាន់បន្ទាយវិញ(សព្វថ្ងៃ គេហៅថា "បន្ទាយជ័យ")។ ចាប់ដើមពីពេលនោះមក ព្រះជ័យអស្ចារ្យបានទទួលរាជាភិសេកសោយរាជ្យនិងទទួលនាមថា ព្រះថៅក្រុងកម្ពុជាធិបតី គង់នៅបន្ទាយជ័យ។ លុះព្រះអង្គបានឡើងសោយរាជ្យសម្បត្តិសុខសាន្តហើយ ទ្រង់នឹកឃើញគុណូបការៈ សេនាមឿង ដែលស៊ូប្តូរជីវិតចំពោះព្រះអង្គនិងចំពោះទឹកដីខ្មែរ ទ្រង់ក៏ចាត់ឱ្យធ្វើបុណ្យឧទ្ទិសផលដល់ដួងវិញ្ញាណក្ខន្ធរបស់ សេនាមឿង យ៉ាងឱឡារិកអស្ចារ្យ ជាប់ជាទំនៀមដរាបមកដល់សព្វថ្ងៃនេះហៅថា ធ្វើបុណ្យឡើងអ្នកតាឃ្លាំងមឿងទៅវិញ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស ទំព័រទី ៦២ ។

ចម្លើយ :

១. ក្រោយមរណភាពរបស់សេនាមឿង គេឮសូរសន្ធឹកហ៊ោកញ្ជ្រៀវដូចសំឡេងផ្គរលាន់ ហាក់ដូចជាសំឡេងទ័ពខ្មោចដែលសេនាមឿងកេណ្ឌមកច្បាំងតាមការសន្យារបស់គាត់កាលនៅរស់ ។

២. កាល : ចំនួន ៥ថ្ងៃក្រោយមក ៣ខែក្រោយមក ដល់ថ្ងៃជាគម្រប់ ៧ថ្ងៃ ។ អាកាស : ខេត្តបាត់ដំបង អូរ(អូរស្វាយដូនកែវ) ស្រុកសៀម បន្ទាយជ័យ ។

៣. លក្ខណៈតួអង្គនៃអត្ថបទសម្រង់គឺ :

+ ឈ្មោះអ្នកតាឃ្លាំងមឿងនៅខេត្តពោធិ៍សាត់ ។
+ សង្គ្រាមខ្មែរ សៀមនៅសម័យលង្វែក(ប្រវត្តិសាស្ត្រ)

៤. គំនិតសំខាន់នៃអត្ថបទសម្រង់គឺសេនាមឿងបូជាជីវិតក្នុងបុព្វហេតុស្នេហាជាតិ រំដោះប្រទេសជាតិចេញពីការឈ្លានពានរបស់ខ្មាំងសត្រូវ ។

៥. វិភាគតួអង្គសេនាមឿង :

+ ជាវីរជនស្នេហាជាតិ
+ ជាជនអង់អាចក្លាហាន
+ លះបង់ជីវិតដើម្បីបុព្វហេតុជាតិ
+ លើកទឹកចិត្តកងទ័ពឱ្យក្លាហានមានជំហរឹងមាំ
+ មានគំនិតស្មោះត្រង់ទាំងកាយចិត្តចំពោះថៅហ្វាយនាយ
+ តម្កល់ផលប្រយោជន៍ជាតិធំជាងប្រយោជន៍ផ្ទាល់ខ្លួន ។

៦. បទពិសោធន៍ក្នុងអត្ថបទដកស្រង់នេះគឺ :

+ គំនិតស្នេហាជាតិជ្រាលជ្រៅរបស់តួអង្គទាំងអស់ក្នុងរឿង
+ ប្រាជ្ញាជាអារុធ(តួអង្គជ័យអស្ចារ្យប្រើប្រាស់ល្បិចទាក់ជំរឿព្រៃថ្វាយស្តេចសៀម តែព្រះអង្គភៀសព្រះកាយមកស្រុកខ្មែរបង្កើតទ័ពប្រឆាំងនឹងស្តេចសៀម)
+ បុព្វបុរសខ្មែរហ៊ានធ្វើគ្រប់យ៉ាងដើម្បីជាតិមាតុភូមិ(សេនាមឿង ប្រពន្ធ និងកូនប្រុសរបស់គាត់ទាំងពីរ) ។

- ឱ្យសិស្សកត់ចម្លើយចូលក្នុងសៀវភៅ
- សង្ខេបអត្ថបទឡើងវិញ
- ដាក់លំហាត់ឬសំណួរថ្មីសម្រាប់ស្រាវជ្រាវ
  - តើអ្នកតាឃ្លាំងមឿងជារឿងប្រឌិតឬរឿងពិត ? ចូរបង្ហាញ ។

  ចម្លើយ : រឿងប្រឌិត ប្រភេទព្រេងកថា ។ ព្រឹត្តិការណ៍រឿង ជាព្រឹត្តិការណ៍ដែលគេស្រង់ចេញពីប្រវត្តិសាស្ត្រគឺសង្គ្រាមរវាងខ្មែរនិងសៀម ។
- ដាក់សំណួរផ្សារភ្ជាប់នឹងជីវភាពជាក់ស្តែង
  - តើគេរៀបចំបុណ្យឡើងអ្នកតាឃ្លាំងមឿងរបៀបណាខ្លះ ?

  ចម្លើយ : មាននៅក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរភាគទី ៨ ។



សង្ខេបអត្ថបទ

១. វត្ថុបំណង

- សិស្សកំណត់ខ្លឹមសារអត្ថបទសំខាន់ៗបានជាក់លាក់
- ស្រង់ចំណុចសំខាន់ៗនៃអត្ថបទមកនិយាយសង្ខេប ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៦៣-៦៦

៣. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូសរសេរចំណងជើង "សង្ខេបអត្ថបទ" ដាក់លើក្តារខៀន ហើយសួរសំណួរបំផុស ។
  - តើសង្ខេបមានន័យដូចម្តេច ?

    ចម្លើយ : សង្ខេបមានន័យថា សេចក្តីបំព្រួញ សេចក្តីយ៉ាៗ ។ សង្ខេបអត្ថបទមានន័យថា បំព្រួញអត្ថបទឱ្យខ្លីៗមានន័យគ្រប់គ្រាន់ហើយស្តាប់បាន ។ ***ឧទាហរណ៍*** សង្ខេបរឿង ដែលមានច្រើនទំព័រឱ្យនៅខ្លីតែមានន័យគ្រប់គ្រាន់ហើយស្តាប់បានពីឃ្លាមួយទៅឃ្លាមួយ ពីឃ្លះមួយទៅឃ្លះមួយ ឬពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត ។
- ឱ្យសិស្សអានសេចក្តីពន្យល់នៃអត្ថបទគំរូ ។
- សួរសំណួរបញ្ជាក់ការយល់របស់សិស្ស ។
  - តើសេចក្តីសង្ខេបអត្ថបទសម្រង់ខាងលើមានខ្លឹមសារអ្វីខ្លះ ?

    ចម្លើយ :

    + "ដំបូង ... ចូលទៅជួប" ។
    + "លោករ៉ៃស៊ីដង់ ... ចលាចលកើតឡើង" ។
    + "ចុងក្រោយ ... បារដេស" ។
  - ចូរបង្ហាញឃ្លះក្នុងអត្ថបទដែលលើកមកសង្ខេបក្នុងចំណុចទី ១ ២ និង ៣ ?

    ចម្លើយ :

    + "ក្រោយពីបានទទួលដំណឹងថា ... ដាច់មេត្តាខ្លាំងម្ល៉េះ ! " ។
    + "លោករ៉ៃស៊ីដង ... រហ័សដូចប្រាថ្នា" ។
    + "ទាហាននោះហៀប ... យ៉ាងរហ័ស" ។
  - ចូររកសំនួនពាក្យដែលប្រើក្នុងសង្ខេបអត្ថបទសម្រង់ ។

    ចម្លើយ : សំនួនពាក្យក្នុងអត្ថបទសម្រង់នេះគឺដំបូង បន្ទាប់មក និងចុងក្រោយ ។

ខ. ការនិយាយ

- គ្រូឱ្យសិស្សហាត់និយាយសង្ខេបតាមអត្ថបទគំរូ
- ឱ្យសិស្សធ្វើលំហាត់ទំព័រទី ៦៦
- អានអត្ថបទដកស្រង់ "ទឹកចិត្តពោធិ៍កំបោរ" មួយចប់
- ឱ្យសិស្សប្រើសម្តីផ្ទាល់ខ្លួនសង្ខេបអត្ថបទដកស្រង់ :

សង្ខេបអត្ថបទដកស្រង់ : ទឹកចិត្តពោធិ៍កំបោរ

ពោធិ៍កំបោរកំពុងលង់អារម្មណ៍នឹកគិតដល់វាសនាប្រទេសជាតិ។ មានគេមកប្រាប់ដំណឹងថាពួកបារាំងកំពុងបញ្ចុះបញ្ចូលមហាជន។ គាត់បានហៅសមាជិកក្រុមទាំងអស់មកកាន់រោងជំនុំ។ ពោធិ៍កំបោរ មេក្រុមឆន និងសហការីនៃក្រុមអ្នកតស៊ូបានសម្រេចនាំក្រុមអ្នកតស៊ូចាកចេញពីភូមិសុរិល ឆ្លងកាត់ក្រចេះទៅកាន់ខេត្តកំពង់ស្វាយ។

បន្ទាប់មក ពោធិ៍កំបោរបានបន្តការបញ្ចុះបញ្ចូលអ្នកភូមិឱ្យចូលរួមក្នុងចលនារបស់ពួកគាត់។ នៅខេត្តកំពង់ស្វាយ ក្រមការសៅប្រើឧបាយកលធ្វើជាចុះចូលជាមួយក្រុមអ្នកតស៊ូ។ ក្រមការសៅបានបញ្ចុះបញ្ចូលពោធិ៍កំបោរឱ្យចុះចូលជាមួយទ័ពបារាំង នោះនឹងបានឡើងបុណ្យសក្តិ។ ពោធិ៍កំបោរពន្យល់ក្រមការសៅនិងអ្នកឯទៀតកុំឱ្យជឿបារាំងនិងបញ្ជាក់ពីជំហររបស់គាត់ សុខចិត្តស្លាប់ហើយអំពាវនាវខ្មែរកុំឱ្យសម្លាប់ខ្មែរគ្នាឯង។ មុនចូលមកប្រជុំជាជាងនៅបម្រើបារាំង ក្រមការសៅបានប្រាប់ទ័ពបារាំងរួចជាស្រេច។ ទីបំផុត ទ័ពបារាំងនិងក្រុមអ្នកតស៊ូប្រយុទ្ធគ្នាស្លាប់រស់ដេកដួលក្នុងថ្លុកឈាមរណែល។

គ. ការវាយតម្លៃ

- ឱ្យសិស្សអាន(ស្ងាត់)មួយចប់ បន្ទាប់មកឱ្យនិយាយសង្ខេបផ្ទាល់មាត់

សង្ខេបអត្ថបទដកស្រង់ : ភ្នំទាងកង្រី

យក្សស្រីសន្ធមារបានរកឃើញនាងទាំង ១២ ជាមហេសីស្តេចព្រះបាទរថសិទ្ធិ។ នាងនេះបានតំណែងខ្លួនជាស្រីក្រមុំ ហើយធ្វើជាមហេសីព្រះបាទរថសិទ្ធិដែរ។ នាងសន្ធមារប្រើកលមាយាឱ្យព្រះបាទរថសិទ្ធិធ្វើបាបនាងទាំង ១២ ដូចជាឆ្មៀលភ្នែកនាងទាំង ១២រួចយកទៅដាក់ក្នុងរណ្តៅមួយជាមួយគ្នា ដោយបង្អត់ទឹកជាដើម។

បន្ទាប់មកនាងទាំង ១១បានប្រសូត្របុត្រមក ក៏ហែកសាច់កូនចែកគ្នាធ្វើជាអាហារ។ នាងពៅត្រូវគេឆ្មៀលគ្រាប់ភ្នែកតែម្ខាង។ នាងប្រសូត្របានបុត្រាមួយដែលជាព្រះពោធិ៍សត្វមាន ព្រះនាមថា "ពុទ្ធិសែន"។

បន្តមកទៀត នាងសន្ធមារក៏ប្រើឧបាយកលសម្លាប់ពុទ្ធិសែនទៀតដោយឱ្យពុទ្ធិសែននាំសារទៅនគរសន្ធមារ ក្នុងសារនោះសន្ធមារបញ្ជាឱ្យនាងកង្រីជាកូនសម្លាប់ពុទ្ធិសែន។ មហាឫសីបានជួយយកអាសារដោយក្លែងសេចក្តីក្នុងសារ ធ្វើឱ្យពុទ្ធិសែនបានក្លាយជាស្វាមីនាងកង្រី។ ពុទ្ធិសែនបានសោយរាជ្យនៅនគរយក្ស បានដឹងពីប្រវត្តិប្រស្រីភ្នែកម្តាយធំ ម្តាយបង្កើត និងថ្នាំព្យាបាល ក៏លួចរបស់ទាំងនោះរួមទាំងវត្ថុទិព្វមួយចំនួន។ នាងកង្រីរត់តាមពុទ្ធិសែនមិនទាន់ក៏យំសោករហូតដល់ស្លាប់កណ្តាលព្រៃ។

ពុទ្ធិសែនបានមកដល់នគរព្យាបាលភ្នែកម្តាយនិងម្តាយធំបានជាសះស្បើយ រួចបានសម្លាប់នាងសន្ធមារ។ ទ្រង់បានឡើងសោយរាជ្យបន្តពីព្រះបិតារៀងមក។

- ដាក់លំហាត់ឬសំណួរថ្មីសម្រាប់ស្រាវជ្រាវ
- ចូរនិយាយសង្ខេប "ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ" ឱ្យខ្លីល្មមស្តាប់បាន។

វិភាគអត្ថបទ

១. ភត្តុចំណេះ

- ពណ៌នាបានអំពីគម្រោងសិក្សាអត្ថបទតាមរយៈគម្រោងអត្ថបទគំរូ
- វិភាគអត្ថបទបានត្រឹមត្រូវតាមរយៈការវិភាគអត្ថបទដកស្រង់គំរូ "យប់មួយនៅក្រាំងលាវ"
- សិស្សចូលចិត្តស្តាដៃអក្សរសិល្ប៍ខ្មែរតាមរយៈការវិភាគអត្ថបទដកស្រង់គំរូ "យប់មួយនៅក្រាំងលាវ" ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៦៧-៦៨

៣. ពត៌មានជំនួយ

សូមលោកគ្រូអ្នកគ្រូមើលសៀវភៅភាសាខ្មែរថ្នាក់ទី ១០ ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរ "វិភាគអត្ថបទ" ដាក់លើក្តារខៀន ហើយសួរ :
  - តើអត្ថបទក្នុងមេរៀននេះសំដៅលើអ្វី ?

    ចម្លើយ : អត្ថបទក្នុងមេរៀននេះ គឺសំដៅលើអត្ថបទដកស្រង់ចេញរឿងណាមួយ ។
  - តើវិភាគអត្ថបទមានន័យដូចម្តេច ?

    ចម្លើយ : វិភាគអត្ថបទ គឺការត្រិះរិះពិចារណាល្អិតល្អន់ទៅលើកអត្ថបទដកស្រង់ ។
- ឱ្យសិស្សអានខ្លឹមសារមេរៀន ។
  - តើក្នុងគម្រោងសិក្សាអត្ថបទអ្នកធ្លាប់បានឃើញចំណុចណាខ្លះ ?

    ចម្លើយ : ធ្លាប់បានឃើញ "អ្នកនិពន្ធ" កាលកំណត់តែង សង្គមបរិយាកាសនៃរឿង វិធីតែងនិពន្ធ ចលនាអក្សរសិល្ប៍ ប្រធានរឿង មូលបញ្ហារឿង ... ។

ខ. ការអនុវត្ត

គម្រោងវិភាគអត្ថបទ : យប់មួយនៅភូមិក្រាំងលាវ

១. ការបង្ហាញដកស្រង់អត្ថបទ

- ចលនា : ខេមរនិយម
- អ្នកនិពន្ធ : លោក **ឌៀក អំ** និង លោក **ឌីក គាម**
  + ជីវប្រវត្តិលោក **ឌៀក អំ** : លោក **ឌៀក អំ** កើតនៅឆ្នាំ ១៩៣៤ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង លោកបានបន្តការសិក្សានៅពុទ្ធិកមហាវិទ្យាល័យភ្នំពេញ ដោយស្នាក់នៅវត្តឧណ្ណាលោម កុដិលេខ ១ ។ មុនមកនៅភ្នំពេញ លោកបានបួសនៅវត្តពោធិ៍វាល ស្នាក់នៅកុដិរបស់លោកគ្រូមេគណព្រះនាម **អ៊ីវ ឡូត** នៅខេត្តបាត់ដំបង ។ នៅភ្នំពេញលោកបានបន្តការសិក្សានៅមហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ ។ ពេលចប់

លោកនិពន្ធរឿង ភូមិតិរច្ឆាន គឺពេលដែលលោកប្រឡងជាប់សញ្ញាប័ត្រឆ្នាំទី ២ ។ លោកចេះភាសាបារាំង អង់គ្លេស យ៉ាងស្ទាត់ជំនាញ ។ ក្រោយមក លោកបានចាកសិក្ខាបទ ហើយស្នាក់នៅម្តុំផ្សារគីឡូលេខ ៤ ។ នៅឆ្នាំ ១៩៦៤-១៩៦៥ លោកជាអ្នកជំនួយការសរសេរទស្សនាវដ្តីកងទ័ព ដើម្បីបានប្រាក់កម្រៃចិញ្ចឹមជីវិត ។

(ស្នាដៃ : មានឯកសារមួយចំនួនដែលលោកសរសេរលើទំព័រទស្សនាវដ្តីកងទ័ព)

+ ជីវប្រវត្តិលោក **ឌឹក គាម** : លោក **ឌឹក គាម** កើតនៅថ្ងៃទី ៩ ខែមករា ឆ្នាំ ១៩៣៦ នៅសង្កាត់ឫស្សីកែវ ស្រុកឆ្លូង ខេត្តក្រចេះ ។ លោកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ផ្នែកស្រាវជ្រាវ ។ តាមយោបល់របស់លោកនៅក្នុងសេចក្តីផ្តើមនៃរឿងភូមិតិរច្ឆាន យើងអាចសន្និដ្ឋានបានថា លោកគឺជាអ្នកស្នេហាជាតិមួយរូបដែលមានការឈឺចាប់និងចង្កៀងកំហឹងនឹងពួកអាណានិគមនិយមបារាំងយ៉ាងខ្លាំង ពិសេសគឺលោកជាខ្មែរមួយរូបដែលអាណិតនិងស្រឡាញ់ប្រជាជនខ្មែរពិតៗ ។ ***(ស្នាដៃមាន វេយ្យាករណ៍ដោយរូបភាព ព្រះនាងឥន្ទ្រទេវី រឿងចៅពញាហុក អក្ខរានុក្រម វេវចនាស័ព្ទខ្មែរឆ្នាំ ១៩៦៥ រឿងភូមិតិរច្ឆាន ១៩៦៤-៦៥)***

- កាលកំណត់តែង : និពន្ធនៅឆ្នាំ ១៩៦៤-១៩៦៥
- សង្គមបរិយាកាស
  + សង្គមប្រវត្តិ : ដំណើររឿងប្រព្រឹត្តទៅក្នុងឆ្នាំ ១៩២៥ គឺនៅក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ(១៩០៤-១៩២៧) ។ កាលនោះ មាតុភូមិរបស់យើងស្ថិតក្រោមអាណានិគមបារាំង ។
  + ព្រឹត្តិការណ៍សំខាន់ៗ : មានចលនាតស៊ូដោយអាវុធពីសំណាក់ប្រជាជនប្រឆាំងនឹងពួកអាណានិគមនិយមបារាំង ។
- អត្ថបទនិងប្រភព
  + ចំណងជើង "យប់មួយនៅក្រាំងលាវ" វគ្គទី ៨ : បក្សពួករួមអាវុធ ។
  + ប្រភពអត្ថបទ : ដកស្រង់ចេញពីរឿងភូមិតិរច្ឆាន ដែលជាប្រលោមលោកលំនាំប្រវត្តិសាស្ត្រ ។ ស្នាដៃនេះបានសរសេរនៅឆ្នាំ ១៩៦៤-៦៥ តែបោះពុម្ពផ្សាយនៅឆ្នាំ ១៩៧១ ។
  + សៀវភៅដើម រឿងភូមិតិរច្ឆាន មាន ១៧វគ្គ ។
- ប្រភេទអក្សរសិល្ប៍ទំនើប

២. វិភាគអត្ថបទ

- សង្ខេបអត្ថបទ : រដូវនេះជារដូវចម្រូត ។ ក្រោយរដូវចម្រូត អ្នកស្រុក អ្នកភូមិច្រើនប្រកបរបរធ្វើស្មោត ។ រួចពីកិច្ចការប្រចាំថ្ងៃ នៅពេលយប់មានការជួបជុំរវាងអ្នកភូមិក្រាំងលាវ ចំនួន ២០នាក់និងអ្នកភូមិព្រៃខ្មែរគឺ **ជួន** និង **នៅ** ។ ការជួបជុំនេះ គឺនៅក្នុងផ្លូវគោ ឃុំក្រាំងលាវ ក្រោមពន្លឺព្រះចន្ទពេញវង់ ។ ក្រោយពី កិច្ចពិភាក្សាគ្នាជាសម្ងាត់មក ពួកគេបានឯកភាពគ្នា ប្តេជ្ញាចិត្តបួរស្លាប់រស់ជាមួយគ្នាដើម្បីអនុវត្តគម្រោងការណ៍ធ្វើឃាតលើរូបបារដេស ។
- តួអង្គមានក្រុមអ្នកក្លាហាន ២០នាក់ មានឈ្មោះ :

១. ឈួន អាយុ ២៧ឆ្នាំ	២. សំ ប៊ីន	៣. ប៉ាង អាយុ ២២ឆ្នាំ	៤. ពត៥. សន ស៊ិន
៦. មិញ ខ្ចៅ	៧. ឌី ម៉ោ អាយុ ២៥ឆ្នាំ	៨. អ៊ុំ ពុំ អាយុ ២៧ឆ្នាំ	៩. ប៊ុត អាយុ ២៨ឆ្នាំ
១០. អ៊ុយ អាយុ ១៧ឆ្នាំ	១១. អ៊ុំ ជួន	១២. ឈុំ	១៣. ប៊ិត ហៅ ប៉ាង
១៤. គង ជិម អាយុ ២៦ឆ្នាំ	១៥. ជា ប៊ុត	១៦. គង់ មៀច	១៧. ស៊ីម ប៉ាល់
១៨. ហង់ ប៊ី	១៩. ញ៉ែម ប៊ិត	២០. ជា ប៊ុត	

ជួន និង នៅ អ្នកភូមិព្រៃខ្មែរ និងបារដេស(តួអង្គក្នុងសន្ទនាឬតួអង្គរំឭក) ។

- កាលអាកាស :
  + កាល : យប់មួយ ក្រោមពន្លឺចន្ទពេញវង់
  + អាកាស : ភូមិផ្លូវគោ ឃុំក្រាំងលាវ
  + បញ្ហាសង្គម : ការដំឡើង និងការទារពន្ធរបស់ពួកបារាំង(បារដេស) ប្រជាជនក្រីក្រ ប្រកបមុខរបរមិនបានផល ពីរបីឆ្នាំជាប់គ្នា ។

៣. អត្ថន័យ

- ប្រធានរឿង : ទុក្ខរបស់ប្រជារាស្ត្រខ្មែរនៅសម័យអាណានិគមបារាំង ។
- មូលបញ្ហារឿង :
  + តើសុខចិត្តទ្រាំរស់នៅក្រោមអាណានិគមផ្តាច់ការឃោរឃៅរបស់បារាំង ហើយសុខចិត្តស្លាប់នៅក្រោមអំណាចពួកអាណានិគមបារាំងនេះ ?
  + ចំពោះបញ្ហានេះ **ជួន** បានជ្រើសរើសយកផ្លូវស្លាប់ ដោយពន្យល់ប្រាប់សំឡាញ់ខ្លួនថា " ...ដែលចង់សម្លាប់បារាំងកំណាចពេលនេះ គឺក្នុងនាមខ្មែរម្នាក់ដែលមិនសុខចិត្តនឹងអំពើជិះជាន់យ៉ាងអមនុស្សធម៌ពីសំណាក់បារាំង ... " ។
  + ការដំឡើងពន្ធដារនិងការទារពន្ធដោយប្រើអំណាចផ្តាច់ការរបស់បារដេស ។ បារដេសចុះទៅទារពន្ធដល់ទីណាទីនោះប្រាក់ពន្ធកាន់តែកើន ឯមនុស្សជាប់ខ្នោះក៏កាន់តែសម្បើម ។
- ទំនាស់ : គឺជាទំនាស់រវាងប្រជារាស្ត្រខ្មែរជាមួយមន្ត្រីរាជការអាណាព្យាបាលបារាំងដែលតំណាងដោយបារដេស ។
- វិភាគតួអង្គ : យកតាមចម្លើយក្នុងអត្ថបទ "យប់មួយនៅភូមិក្រាំងលាវ" ។ (ជួន , នៅ , បារដេស)
- តម្លៃអប់រំ : យកតាមចម្លើយក្នុងអត្ថបទ "យប់មួយនៅភូមិក្រាំងលាវ" ។

៤. អត្ថរូប : វិធីតែង

- ផ្តើមរឿង : អត្ថបទដកស្រង់ "ភូមិក្រាំងលាវ ភូមិនេះ គឺជាតួឃុំក្រាំងលាវហ្នឹងឯង ..." ភ្ជាប់ទៅនឹងដំណើររឿង
- ដំណើររឿង
  + សំវាទវិធី : គឺជាការសន្ទនារវាងតួអង្គនិងតួអង្គ ។

    ឧទាហរណ៍ : ការសន្ទនារវាង **ជួន នៅ** និងក្រុមអ្នកភ្លាហាន ២០នាក់ ។
  + ពណ៌នាវិធី : ការរៀបរាប់ពីទីតាំងភូមិក្រាំងលាវ ។ "ភូមិក្រាំងលាវ ...ពីរបីឆ្នាំជាប់ៗគ្នារួចមកហើយ" ។
  + បដិវិធី : វិធីធ្វើឱ្យមានការផ្ទុយគ្នា

    ប្រជាជនខ្មែរស្លូតបូត ≠ បារដេសឃោរឃៅ

    កសិកម្មមិនសូវបានផល ≠ ពន្ធចេះតែឡើងថ្លៃ
  + វឌ្ឍមានវិធី : វិធីធ្វើឱ្យដំណើររឿងកាន់តែវិវត្តឡើង កំហឹងឈឺចាប់របស់ប្រជាជនកាន់តែខ្លាំងឡើងៗរហូតដល់ហ៊ានសម្លាប់បារដេស ។
  + សន្ទេហាវិធី : វិធីធ្វើឱ្យមានចម្ងល់

    ១. តើក្រុមអ្នកភ្លាហានអាចសម្រេចបំណងរបស់គេបានដែរឬទេ ?

    ២. ក្រោយការតស៊ូ តើក្រុមអ្នកភ្លាហានទាំងនោះមានជោគវាសនាបែបណាដែរ ?

ឃ. ការវាយតម្លៃ

- ចូរវិភាគអត្ថបទដកស្រង់ : "នំមិនធំជាងនាឡិ" , ទឹកចិត្តពោធិ៍កំពោរ" ។
- យកគំរូតាមអត្ថបទវិភាគខាងលើ ។

មេរៀនទី ៩

ការលេងបង់

បុព្វបុរសយើង បានបន្សល់ទុកកេរដំណែលជាច្រើនរហូតដល់សព្វថ្ងៃដូចជា អក្សរសាស្ត្រ អក្សរសិល្ប៍ សិលាចារឹក ចម្លាក់ រូបចម្លាក់ ប្រព័ន្ធធារាសាស្ត្រ ប្រាសាទបុរាណនានា ពិសេសគឺប្រាសាទអង្គរវត្ត។ អក្សរសាស្ត្រ ជាមរតកដ៏សំខាន់មួយ ដែលបុព្វបុរសបានទុកឱ្យកូនចៅជំនាន់ក្រោយ។ នេះជាមោទនភាពរបស់ជាតិយើង។ ខ្មែរគ្រប់រូបត្រូវមានស្មារតីស្នេហាជាតិ ថែរក្សាការពារលើកតម្កើងវប្បធម៌ អរិយធម៌ជាតិឱ្យបានស្ថិតស្ថេរគង់វង្សនិងធ្វើឱ្យមានការអភិវឌ្ឍ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីកេរដំណែលអក្សរសាស្ត្ររបស់ខ្មែរមួយចំនួន ហើយទន្ទឹមនឹងនោះអ្នកនឹងបានសិក្សាផងដែរពីការបញ្ចុះបញ្ចូល ការអួសទាញ និយមន័យអក្សរសាស្ត្រ សង្គមបរិយាកាស កាលកំណត់តែង អ្នកនិពន្ធ និងខ្លឹមសារអត្ថបទ។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិទ្យាសាស្ត្រ	ទិទ្យាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	៦៧	៦៩
• បំណិន : ឈុតនិងឆាក	២ម៉ោង	២ម៉ោង	៦៨-៧០	៧០
• អំណានទី ១ : ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ	៣ម៉ោង	៤ម៉ោង	៧១-៧៤	៧១
• ការនិយាយ : ការសម្តែងតួរឿងល្ខោន	១ម៉ោង	២ម៉ោង	៧៥-៧៧	៨០
• វេយ្យាករណ៍ : សូរស្រៈ	២ម៉ោង	២ម៉ោង	៧៨-៨១	៨៤
• អំណានទី ២ : រឿងចៅកែចិត្តចោរ	២ម៉ោង	៤ម៉ោង	៨២-៨៦	៨៧
• ការស្តាប់ : រឿងតេជោយ័ត	០ម៉ោង	២ម៉ោង	៨៧-៩៣	៩៥
• សំណេរ : ការតែងរឿងល្ខោនខ្លី	២ម៉ោង	៤ម៉ោង	៩៤-៩៦	៩៦

១. សិក្សាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៦៩។ គ្រូសរសេរចំណងជើងមេរៀន "ការលេងបង់" ជាក់លើក្តារខៀនរួចសួរ :
  - ដូចម្តេចហៅថា "ការលេងបង់" ?

    ចម្លើយ : ជាការហ៊ានធ្វើពលិកម្មប្រកបដោយគុណធម៌ ដើម្បីសម្រេចកិច្ចការណាមួយ។
  - តើក្នុងកាលៈទេសៈណាដែលគេត្រូវធ្វើការលេងបង់ ? លេងបង់អ្វី ?

    ចម្លើយ : ក្នុងពេលមានសង្គ្រាម មានគ្រោះធម្មជាតិ... គឺលេងបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងសម្ភារៈ។

២. សិក្សាលើរូបភាព

- តើអ្នកឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

  ចម្លើយ : ខឿនប្រាសាទនិងតួប្រាសាទព្រះវិហារ ដែលមានទង់ជាតិខ្មែរបក់រវិចៗ ហើយមានយុទ្ធជនឈរការពារ។
- តើអ្នកគិតថាមនុស្សនៅក្នុងរូបភាពនេះហ៊ានលេងបង់ដូចម្តេច ?

  ចម្លើយ : ខ្ញុំគិតថា នេះគឺជាការលេងបង់របស់យុទ្ធជនខ្មែរដើម្បីរក្សាបូរណភាពទឹកដី។

ឈុតនិងឆាក

១. វត្ថុបំណង

- ប្រាប់បញ្ញត្តិ ឈុតនិងឆាកបានត្រឹមត្រូវ
- បង្ហាញទម្រង់សំណេរអត្ថបទល្ខោនបានត្រឹមត្រូវ
- បង្ហាញចំនួនឈុត ឆាក និងការផ្លាស់ប្តូរឆាករបស់រឿងល្ខោនបានត្រឹមត្រូវ
- បណ្តុះស្មារតីឱ្យចូលចិត្ត ស្រឡាញ់ ថែរក្សា និងយកចិត្តទុកដាក់ស្រាវជ្រាវអំពីរឿងល្ខោនខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៧០
- អត្ថបទ : រឿងល្ខោនខ្មែរ ឬបរទេសសម្រាប់យកមកធ្វើលំហាត់ ។

៣. ពិភាក្សាជំនួយ

- ដូចម្តេចដែលហៅថាឈុត ?

  ចម្លើយ : ឈុត គឺជាសាច់រឿងដែលគេរៀបចំឡើងមានច្រើនឆាក ។ ឈុតមានការផ្លាស់ប្តូរនៅពេលមានការផ្លាស់ប្តូរស្ថានភាពធំៗនៃរឿង ។ ឈុត គឺជាវគ្គធំៗនៃការសម្តែងល្ខោន ។

- ដូចម្តេចដែលហៅថា ឆាក ?

  ចម្លើយ : ឆាកមានន័យពីរយ៉ាងគឺ :

  + ន័យទីមួយឆាក គឺជាកន្លែងសម្រាប់សម្តែងរឿង ។ ឆាកល្ខោនត្រូវបានគេរៀបចំតុបតែងលម្អនិងផ្លាស់ប្តូរដោយប្រើផ្ទាំងរូបភាព ផ្ទាំងទេសភាព ឬដើមឈើ ដើម្បីឱ្យស៊ីទៅនឹងស្ថានភាពសាច់រឿង ។
  + ន័យទីពីរឆាកគឺជាសាច់រឿងដែលជាផ្នែកតូចមួយនៃឈុត ។ កាលណាមានការផ្លាស់ប្តូរបន្ថែម ឬបន្ថយតួអង្គក្នុងការសម្តែងនោះក៏មានការផ្លាស់ប្តូរឆាកថ្មីផងដែរ ។

- តើឈុតនិងឆាកខុសគ្នាដូចម្តេច ?

  ចម្លើយ : ឈុត គឺជាវគ្គធំៗនៃការសម្តែងល្ខោន រីឯឆាក គឺជាវគ្គតូចៗនៃការសម្តែងក្នុងឈុតរបស់ល្ខោន ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងបំណិន "ឈុតនិងឆាក" ដាក់លើក្តារខៀន ។
  - តើអ្នកធ្លាប់បានសិក្សាអត្ថបទរឿងល្ខោន ឬទេ ?

    ចម្លើយ : ធ្លាប់បានសិក្សា ឬមិនធ្លាប់មិនបានសិក្សា ។

  - ក្នុងអត្ថបទរឿងប្រលោមលោកអ្នកនិពន្ធប្រើវគ្គ ភាគ ចុះក្នុងអត្ថបទរឿងល្ខោនវិញ តើអ្នកនិពន្ធប្រើវគ្គឬភាគដែរឬទេ ?

    ចម្លើយ : ក្នុងអត្ថបទរឿងល្ខោនអ្នកនិពន្ធមិនប្រើភាគ ឬវគ្គទេ តែប្រើឈុត ឬឆាក ។

- គ្រូឱ្យសិស្សអានខ្លឹមសារបំណិន ក្នុងសៀវភៅសិស្សទំព័រទី ៧០ រួចសួរ ៖

- ដូចម្តេចដែលហៅឈុត ? ហើយឈុតនៃសាច់រឿងល្ខោនមានការផ្លាស់ប្តូរយ៉ាងដូចម្តេច ?

  ចម្លើយ : ឈុតជាសាច់រឿងដែលគេរៀបចំឡើងមានច្រើនឆាក ហើយឈុតនៃសាច់រឿងល្ខោនមានការផ្លាស់ប្តូរគឺនៅពេលដែលការមានផ្លាស់ប្តូរស្ថានភាពធំៗនៃរឿង ។

- ដូចម្តេចដែលហៅឆាក ហើយមានប៉ុន្មានយ៉ាង ?

  ចម្លើយ : ឆាកគឺជាសាច់រឿងដែលជាផ្នែកតូចមួយនៃឈុត ហើយមានពីរយ៉ាង គឺឆាកសម្រាប់សម្តែងរឿង និងឆាកជាសាច់រឿងរបស់ល្ខោននៅក្នុងឈុត ។

- តើឈុតនិងឆាកខុសគ្នាដូចម្តេច ?

  ចម្លើយ : ឈុត គឺជាវគ្គធំៗនៃការសម្តែងល្ខោន រីឯឆាក គឺជាវគ្គតូចៗនៃការសម្តែងក្នុងឈុតរបស់ល្ខោន ។

- តើគេរៀបចំឈុតឆាកនៅក្នុងរឿងល្ខោនខ្មែរមានលក្ខណៈដូចម្តេច ?

  ចម្លើយ : ការរៀបចំជាឈុតជាឆាកក្នុងរឿងល្ខោនរបស់ខ្មែរយើងពុំមានឯកភាពគ្នាទេគឺអាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ ។ រឿងវែងមានច្រើនឈុតច្រើនឆាក ឯរឿងខ្លីមានឈុតតិចនិងឆាកក៏តិចដែរ ។ ក្នុងឈុតនីមួយៗក៏មិនបានកំណត់ថាត្រូវតែមានចំនួនឆាកស្មើៗគ្នានោះដែរ ។ ជាពិសេសទៅទៀត គឺនៅក្នុងអត្ថបទរឿងល្ខោនជាច្រើនពុំឃើញមានបែងចែកជាឈុតនៅក្នុងអត្ថបទរឿងនោះទេ ។ ***ឧទាហរណ៍ :*** អត្ថបទល្ខោនបាសាក់រឿងតេជោយ៉ត ដែលនិពន្ធនៅឆ្នាំ ១៩៨៣ដោយលោក **ទី ជីហួត** មាន១៨ឆាក ពុំឃើញមានការបែងចែកជាឈុតទេ ។ អត្ថបទល្ខោននិយាយរឿង "ថៅកែចិត្តចោរ" ដែលអ្នកនិពន្ធនៅឆ្នាំ ១៩៥៦ដោយលោក **ពៅ យូឡេង** និងលោក **អ៊ុំ ឈឿន** មាន ៧ឆាកក៏ពុំឃើញមានការបែងចែកជាឈុតដែរ ។

២. ការហ្វឹកហាត់

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ៧០
- ក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ ។ បន្ទាប់ពីពិភាក្សាចប់ ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូធ្វើការបូកសរុបនិងកែលម្អ ។

ចម្លើយ :

- ចំណងជើងរឿង : តាមជាក់ស្តែងនៃរឿង ដែលបានជ្រើសរើសយកមកធ្វើលំហាត់ ។
- ទម្រង់សំណេររឿងល្ខោន : ទម្រង់សំណេររបស់អត្ថបទល្ខោនខុសពីទម្រង់សំណេររបស់អត្ថបទរឿងប្រលោមលោក ។ ទម្រង់សំណេររបស់អត្ថបទល្ខោនមានលក្ខណៈដូចខាងក្រោម ៖
  + អត្ថបទល្ខោនចែកជា ឈុត និងឆាក
  + នៅខាងដើមអត្ថបទល្ខោននីមួយៗមានបញ្ជីរាយនាមតួអង្គនិងឋានៈ ឬប្រភពកំណើតរបស់តួអង្គ
  + អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយ ដែលជាពំនោល ឬការសន្ទនារបស់តួអង្គ
  + ក្នុងអត្ថបទល្ខោននិយាយ ការអ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក ។
- ចំនួនឈុតឆាក : តាមភាពជាក់ស្តែងនៃរឿងដែលបានជ្រើសរើសយកមកធ្វើលំហាត់ ។
- ការផ្លាស់ឈុត : ឈុតមានការផ្លាស់ប្តូរនៅពេលមានការផ្លាស់ប្តូរស្ថានភាពធំៗនៃរឿង ។
- ការផ្លាស់ឆាក : ការផ្លាស់ប្តូរឆាកនៅពេលមានបន្ថែម ឬបន្ថយតួអង្គក្នុងការសម្តែង ។

គ. ការវាយតម្លៃ

- គ្រូសួរសំណួរដើម្បីវាយតម្លៃការយល់ដឹងរបស់សិស្ស ៖
  - ដូចម្តេចដែលហៅថាឈុត ? ដូចម្តេចដែលហៅថានាក ?
  - តើឈុតនិងនាកខុសគ្នាដូចម្តេច ? តើគេសម្គាល់ការផ្លាស់ ឈុតនិងនាកបានយ៉ាងដូចម្តេច ?
- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូណែនាំសិស្សពីរបៀបធ្វើលំហាត់ រួចឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់នេះ : ចូរអ្នកអានអត្ថបទល្ខោនបាសាក់រឿង "តេជោយ៉ត"រួចប្រាប់ពី : ទម្រង់សំណេរអត្ថបទល្ខោនចំនួននាកនិងការផ្លាស់ប្តូរនាករបស់រឿង
- ក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ ។ បន្ទាប់ពីពិភាក្សាចប់ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូធ្វើការបូកសរុបនិងកែលម្អ ។

ចម្លើយ :

ទម្រង់សំណេរអត្ថបទល្ខោន ៖

- សំណេរអត្ថបទល្ខោនរឿង តេជោយ៉ត ចែកជានាក
- នៅខាងដើមអត្ថបទល្ខោននីមួយៗមានបញ្ជីរាយនាមតួអង្គនិងឋាន: ឬប្រភពកំណើតរបស់តួអង្គ
  - + តេជោមាស : ជាស្វាមីជំទាវស្រែន្យ មានងារជាតេជោបរមរាជត្រួតខេត្តកំពង់ស្វាយ ។
  - + តេជោយ៉ត : ជាសិស្សតេជោមាសមានងារជាតេជោត្រួតខេត្តកំពង់ស្វាយពេលតេជោមាសស្លាប់ទៅ ។
  - + ជំទាវស្រែន : ជាភរិយារបស់តេជោមាស ជាស្ត្រីដែលមានល្បិចឆ្លើមអាចចាប់ស្តេចសំរែកប្តត់ជាតិយកទៅកាត់ទោស ។
  - + ព្រះចៅជ័យចេស្តា : មហាក្សត្រខ្មែរគង់នៅក្រុងឧដុង្គមានជ័យ ។
  - + អ្នកម្នាងនួ : បងស្រីម៉ឺនចៃចុងរ៉ាក់និងជាអ្នកម្នាងរបស់ព្រះចៅជ័យចេស្តា ។
  - + ស្តេចសំរែ : មេបះបោរបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា ។
  - + ឧកញ៉ាពិភា : មន្ត្រីជំនិតរបស់ស្តេចសំរែ ។
  - + ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ : បម្រើការងារជាមួយតេជោមាសនិងតេជោយ៉ត ។
  - + នាងម៉ៃ : បុត្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់និងជាអ្នកស្រឡាញ់តេជោយ៉តតែមិនបានសម្រេចក្លាយទៅជាប្អូនធម៌របស់តេជោយ៉តទៅវិញ ។
  - + នាយឈិត : ឈ្លើយសឹកសៀមនិងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ ។
  - + ម៉ឺនចៃចុងរ៉ាក់ : ប្អូនអ្នកម្នាងនួប្រឆាំងតេជោយ៉ត ហើយត្រូវបានតេជោយ៉តចាប់យកទៅសម្លាប់ចោលនិងមានតួអង្គរំឭកជាច្រើនទៀត ។
- អត្ថបទល្ខោនរឿង "តេជោយ៉ត"បទសន្ទនារវាងតួអង្គនិងតួអង្គ
- ចំនួននាក : រឿង តេជោយ៉តចែកជា ១៨នាក

ការផ្លាស់នាក : ការផ្លាស់ប្តូរនាកទី ១ ទៅនាកទី ២ នៅត្រង់ចុងបញ្ចប់នៃការសន្ទនាអំពីការចេញទៅធ្វើសង្គ្រាមរបស់តួអង្គបី គឺតេជោមាស យ៉ត និងជំទាវស្រែន ហើយលេចចេញតួអង្គថ្មីគឺ ស្តេចសំរែ ឧកញ៉ាពិភា និងពួកមន្ត្រីក្នុងការសម្តែងសកម្មភាពថ្មី ។



ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ

១. វត្ថុបំណង

- អានលើកដាក់សំឡេងគោរពតាមរចនាបថល្ខោនបានត្រឹមត្រូវ
- ប្រាប់ពីតួអង្គ មុខងារ សកម្មភាព និងវិភាគតួអង្គបានត្រឹមត្រូវ
- បង្ហាញពីកាលអាកាសរឿង និមិត្តរូបវិធី ឧបមានវិធី បានត្រឹមត្រូវ
- បណ្តុះស្មារតីលើកកម្ពស់តួនាទីស្ត្រីខ្មែរនៅក្នុងសង្គម ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៧១-៧៩
- អត្ថបទល្ខោនរឿង "តេជោយ៉ត"ដែលនិពន្ធនៅឆ្នាំ ១៩៨៣ដោយលោក ទី ជីហួត

៣. ព័ត៌មានជំនួយ

ដោយក្នុងសៀវភៅសិស្សពុំមានលទ្ធភាពសរសេររឿងទាំងមូលបាន ដូច្នេះសូមលោក/អ្នកគ្រូរកអត្ថបទល្ខោនរឿង "តេជោយ៉ត"ដែលនិពន្ធនៅឆ្នាំ ១៩៨៣ដោយលោក ទី ជីហួត ដើម្បីប្រើប្រាស់ជាជំនួយដល់ការឆ្លើយនឹងសំណួរ ។

៤. លំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ៤ទំព័រទី ៧១បន្ទាប់មកគ្រូសរសេរចំណងជើងអំណាន "ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ"ដាក់លើក្តារខៀន រួចសួរ ៖
  - តើចំណងជើង "ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ"មានអត្ថន័យដូចម្តេច ? ចូរលើកឧទាហរណ៍ក្នុងសង្គមជាក់ស្តែងមកបញ្ជាក់ ។

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ៧១រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះ នៅក្នុងរូបភាពនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើមនុស្សនៅក្នុងរូបភាពនេះជាអ្នកណា ? តើពួកគេកំពុងធ្វើអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើរូបភាពនេះចង់និយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- ការប៉ាន់ស្មានខ្លឹមសារអត្ថបទ : គ្រូសួរសំណួរឱ្យសិស្សប៉ាន់ស្មានខ្លឹមសារអត្ថបទ "ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ" តើអត្ថបទនេះនិយាយអំពីអ្វី ? សិស្សឆ្លើយតាមការយល់ឃើញរបស់ពួកគេ ។ គ្រូសរសេរចម្លើយប៉ាន់ស្មានរបស់សិស្សដាក់លើក្តារខៀនដើម្បីទុកផ្ទៀងផ្ទាត់ ។
- ការសិក្សាពាក្យគន្លឹះ
- គ្រូឱ្យសិស្សរកពាក្យពិបាកនៅក្នុងអត្ថបទ រួចសរសេរពាក្យទាំងនោះនៅលើក្តារខៀន
- គ្រូឱ្យសិស្សអានការពន្យល់ពាក្យពិបាកទាំងនោះនៅក្នុងសៀវភៅសិស្សទំព័រទី ៧១ត្រង់ចំណុច ក សិក្សាពាក្យគន្លឹះ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ៧២ រួចសួរសំណួរដើម្បីទាញបម្រុងប្រយ័ត្នរបស់សិស្ស ៖
  - តើនៅក្នុងអត្ថបទនេះគេតម្រូវឱ្យអ្នកយល់ដឹងអំពីអ្វីខ្លះ ?

    ចម្លើយ : ឆាក តួអង្គ កាលអាកាស ការវិភាគតួអង្គ និងខ្លឹមសារអត្ថបទ ។
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ៧៩ រួចសួរ ៖
  - តើសំណួរទាំងអស់មានប៉ុន្មាន ? តើសំណួរនីមួយៗផ្តោតសំខាន់ទៅលើអ្វីខ្លះ ?

គ. ពង្រឹងអំណាន

- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលំអិតនៃអត្ថបទទាំងមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
- គ្រូឱ្យសិស្សឆ្លើយនឹងសំណួរពីទី ១ ដល់ទី ៦ ក្នុងសៀវភៅសិស្សទំព័រទី ៧៩ ។

ចម្លើយ :

១. តួអង្គស្តេចសំរែ ៖
   - តួនាទី : មេបះបោរដោយតាំងខ្លួនជាស្តេចបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា ។
   - សកម្មភាព : ដឹកនាំចលនាបះបោរដោយតាំងខ្លួនជាស្តេចរៀបចំសកម្មភាពបះបោរធ្វើសង្គ្រាម ដើម្បីដណ្តើមរាជពីព្រះចៅជ័យចេស្តា ។ ស្តេចសំរែខ្លាំងពូកែប្រយុទ្ធឈ្នះតេជោមាសនិងតេជោយ័តដែលជាមេទ័ពរបស់ព្រះចៅចេស្តា ។ ជាអ្នកតាមលួងលោមចង់បានជំទាវស្រែនយកមកធ្វើជាមហេសី ជាចុងក្រោយចាញ់កលជំទាវស្រែនត្រូវតេជោមាសនិងយ័តចាប់ខ្លួនបាន ។
   - ចរិតលក្ខណៈ : ល្មោភអំណាចចង់ដណ្តើមរាជធ្វើជាស្តេច ។ ល្មោភស្នេហ៍ត្រូវគេលួងលោមធ្វើឱ្យចិត្តទន់បាត់បង់ការពិចារណារហូតត្រូវអន្តរាយដោយសារស្រី ។

២. ការធ្វើសង្គ្រាមរវាងតេជោមាសជាមួយស្តេចសំរែ ៖
   - តេជោមាសជាអ្នកឈ្នះ
   - តេជោមាសឈ្នះដោយសារជំទាវស្រែនជាប្រពន្ធចេះប្រើល្បិចកលធ្វើឱ្យស្តេចសំរែលង់ស្នេហ៍បាត់ការពិចារណារហូតធ្វើឱ្យតេជោមាសចាប់ខ្លួនបាន ។

៣. តួអង្គក្នុងរឿងតេជោយ័ត ៖
   - រឿងតេជោយ័ត មានតួអង្គចំនួន ១១នាក់គឺ តេជោមាស តេជោយ័ត ជំទាវស្រែន ព្រះចៅជ័យចេស្តា អ្នកម្នាងនួ ស្តេចសំរែ ឧកញ៉ាពិភា ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ នាងម៉ៃ នាយឈិត ម៉ឺនចៃចុងរ៉ាក់ និងមានតួអង្គរំឭកជាច្រើនទៀត ។
   - តេជោយ័ត ជាតួអង្គឯក រីឯតេជោមាស ជំទាវស្រែន ស្តេចសំរែ និងតួអង្គដទៃទៀតជាតួអង្គរង ។
   - តួនាទីរបស់តួអង្គនីមួយៗ ៖
     + តេជោមាស : ជាស្វាមីជំទាវស្រែន មានងារជាតេជោបរមរាជត្រួតខេត្តកំពង់ស្វាយ ។
     + តេជោយ័ត : ជាសិស្សតេជោមាស មានងារជាតេជោត្រួតខេត្តកំពង់ស្វាយពេលតេជោមាសស្លាប់ទៅ ។
     + ជំទាវស្រែន : ជាភរិយារបស់តេជោមាស ជាស្ត្រីដែលមានល្បិចឆ្លើមអាចចាប់ស្តេចសំរែក្បត់ជាតិយកទៅកាត់ទោស ។
     + ព្រះចៅជ័យចេស្តា : មហាក្សត្រខ្មែរគង់នៅក្រុងឧដុង្គមានជ័យ ។
     + អ្នកម្នាងនួ : បងស្រីម៉ឺនចៃចុងរ៉ាក់និងជាអ្នកម្នាងរបស់ព្រះចៅជ័យចេស្តា ។

+ ស្តេចសំរែ : មេបះបោរបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា ។
+ ឧកញ៉ាពិភា : មន្ត្រីជំនិតរបស់ស្តេចសំរែ ។
+ ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ : បម្រើការងារជាមួយតេជោមាសនិងតេជោយ៉ត ។
+ នាងម៉ៃ : បុត្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ និងជាអ្នកស្រឡាញ់តេជោយ៉ត តែមិនបានសម្រេចក្លាយទៅជាប្អូនធម៌របស់តេជោយ៉តទៅវិញ ។
+ នាយឈិត : ឈ្លើយសឹកសៀមនិងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ ។
+ ម៉ឺនចៃចុងរ៉ាក់ : ប្អូនអ្នកម្នាងនួប្រឆាំងតេជោយ៉ត ហើយត្រូវតេជោយ៉តចាប់យកទៅសម្លាប់ចោលនិងមានតួអង្គរំឭកជាច្រើនទៀត ។

៤. តួអង្គជំទាវស្រែន ៖

- ជំទាវស្រែន ជាស្ត្រីមានរូបសម្ផស្សស្អាត មានចិត្តត្រជាក់ ស្លូតបូត ទន់ភ្លន់ រួសរាយរាក់ទាក់ មានឥរិយាបថល្អប្រពៃ មានភក្តីភាពចំពោះស្វាមី ចេះទំនុកបម្រុងស្វាមីជាមេទ័ព ហើយមានល្បិចកលស៊ីជម្រៅ ។
- ជំទាវស្រែន បានជួយកិច្ចការប្រទេសជាតិរបស់ស្វាមីខ្លួន (តេជោមាស)យ៉ាងធំធេង ដែលភារកិច្ចនេះស្វាមីខ្លួនមិនអាចធ្វើបានគឺការកម្ចាត់ស្តេចសំរែមេបះបោរបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា ។
- យើងយល់ថា បេសកកម្មរបស់ជំទាវស្រែន គឺជាបេសកកម្មមួយដ៏ធំធេង ដែលបង្ហាញពីស្ត្រីជាភរិយាដ៏ទន់ភ្លន់តែមានទឹកចិត្តក្លាហានអាចជួយកិច្ចការប្រទេសជាតិរបស់ស្វាមីក្នុងការកម្ចាត់សត្រូវ ។ តាមរយៈបេសកកម្មនេះ បានឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការចូលរួមបំពេញភារកិច្ចជូនជាតិមាតុភូមិ ។ បេសកកម្មរបស់ជំទាវស្រែនក៏ជាអំណះអំណាងផងដែរសម្រាប់ការឱ្យតម្លៃស្ត្រីជាភរិយាក្នុងសង្គមខ្មែរ ដែលតែងតែជួយលើកតម្កើងស្វាមីខ្លួនដូចសុភាសិតបានពោលថា "សំណាបយោងដីស្ត្រីយោងប្រុស" ។

៥. ប្រភេទអត្ថបទ :

- អត្ថបទនេះជាប្រភេទអត្ថបទរឿងល្ខោន ។
- ប្រភេទអត្ថបទរឿងល្ខោនមានរចនាបថខុសពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទានត្រង់ ៖
  + អត្ថបទរឿងល្ខោនចែកជាឈុតនិងឆាក
  + នៅខាងដើមអត្ថបទរឿងល្ខោននីមួយៗមានបញ្ជីរាយនាមតួអង្គនិងឋាន: ឬប្រភពកំណើតរបស់តួអង្គ
  + អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយ ឬជាពំនោល
  + ក្នុងអត្ថបទល្ខោននិយាយ អ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក ។

៦. អត្ថបទល្ខោនដកស្រង់នេះមាន ៣ឆាកគឺ ឆាកទី ៥ ឆាកទី ៦ និងឆាកទី ៧ ។

ការផ្លាស់ប្តូរឆាក ៖

- ការផ្លាស់ប្តូរឆាកពីឆាកទី ៥ ទៅឆាកទី ៦ កើតនៅពេលបញ្ចប់ការសន្ទនារបស់តួអង្គពីរគឺ ស្តេចសំរែនិងឧកញ៉ាពិភាអំពីការទៅទាក់ទងលួងលោមបញ្ចុះបញ្ចូលជំទាវស្រែន ដើម្បីយកមកធ្វើជាមហេសីរបស់ស្តេចសំរែ ហើយលេចចេញតួអង្គថ្មី គឺជំទាវស្រែននិងខ្ញុំបម្រើស្រីប្រុសក្នុងការសម្តែងសកម្មភាពថ្មី ។
- ការផ្លាស់ប្តូរឆាកទី ៦ ទៅឆាកទី ៧ កើតនៅពេលបញ្ចប់ការសន្ទនារបស់តួអង្គពីរគឺ ជំទាវស្រែននិងឧកញ៉ាពិភាអំពីការយាងស្តេចសំរែឱ្យមកចូលរួមក្នុងពិធីមង្គលការក្មួយរបស់ជំទាវស្រែនប្តូរទៅសម្តែងសកម្មភាពថ្មីគឺសកម្មភាពក្នុងពិធីមង្គលការដែលមានតួអង្គជំទាវស្រែន ឧកញ៉ាពិភា ខ្ញុំបម្រើស្រីប្រុស ស្តេចសំរែ កងទ័ពតេជោមាសនិងយ៉ត ។

ឃ. ការវាយតម្លៃ

- គ្រូឱ្យសិស្សឆ្លើយសំណួរពីទំព័រទី ៧ ទី ៨ និងទី ៩ក្នុងសៀវភៅសិស្សទំព័រទី ៧៩ (ជាក្រុម ឬជាបុគ្គល) ។

ចម្លើយ :

៧. តួនាទីរបស់ស្ត្រីខ្មែរក្នុងការអភិវឌ្ឍសង្គម តាមរយៈសកម្មភាពតួអង្គជំទាវស្រែន ៖

- សកម្មភាពជំទាវស្រែនក្នុងការជួយស្វាមី ៖
  + ជំទាវស្រែនជួយទំនុកបម្រុងនិងលើកទឹកចិត្តស្វាមី (តេជោមាស)ពេលចេញទៅធ្វើសឹកសង្គ្រាម។
  + ជំទាវស្រែនប្រើកលយុទ្ធក្នុងការកម្ចាត់ស្តេចសំរែ ដោយធ្វើកលល្បិចជាលែងលះជាមួយតេជោមាស រួចអួសទាញស្តេចសំរែឱ្យចូលក្នុងអន្ទាក់តេជោមាស។
- សង្គមខ្មែរឱ្យតម្លៃស្ត្រីជាធំ ៖
  + ប្រពន្ធជួយប្តី ដូចសុភាសិតខ្មែរចែងថា សំណាបយោងដីស្រីយោងប្រុស ...
  + សង្គមខ្មែរចាត់ទុកស្ត្រីជាមេ ពាក្យខ្មែរប្រើ មេបា មេបក្ស មេទ័ព ... គោរពមេ (តាមរយៈរឿងព្រេង ព្រះថោងនាងនាគ) ... ដូចពាក្យភាសិតថា "សូវស្លាប់បា កុំឱ្យតែស្លាប់មេ ..."។
- សង្គមបច្ចុប្បន្នផ្តោតលើយែនឌ័រគឺ លើកតម្កើងស្ត្រីឱ្យចូលរួមក្នុងការងារសង្គមគ្រប់ផ្នែកដូចជា គណៈគ្រប់គ្រងភូមិ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខេត្ត ស្ថាប័ន ក្រសួង អង្គការជាតិ និងអន្តរជាតិ ...

សរុបមក សកម្មភាពជំទាវស្រែន បានបង្ហាញពីតួនាទីរបស់ស្ត្រីខ្មែរក្នុងការចូលរួមអភិវឌ្ឍសង្គម និងការការពារជាតិ។

៨. កាលអាកាសនៃរឿង ៖

- កាល (ពេលវេលា) : រឿងរ៉ាវទាំងអស់ប្រព្រឹត្តទៅក្នុងរជ្ជកាលព្រះបាទជ័យចេស្តា (គ.ស. ១៥៧៥-១៥៩៣)
- អាកាស (ទីកន្លែង) : រាជធានីឧដុង្គ ខេត្តកំពង់ស្វាយ (ស្ទឹងព្រៃប្រស់)ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង (កំពង់ហៅលង្វែក)។
- និមិត្តរូបវិធី : ការយកតួអង្គជំទាវស្រែនជាតំណាងឱ្យស្ត្រីខ្មែរ ដែលជួយស្វាមីតាំងពីកិច្ចការក្នុងផ្ទះរហូតដល់កិច្ចការក្នុងសង្គមដូចសុភាសិតខ្មែរចែងថា "សំណាបយោងដីស្រីយោងប្រុស" (ជំទាវស្រែនជួយកម្ចាត់ស្តេចសំរែ)
- ឧបមានវិធី : អ្នកនិពន្ធធ្វើការប្រៀបធៀបរូបសម្ផស្សជំទាវស្រែនទៅនឹងទេពកញ្ញា ដូចស្តេចសំរែនិយាយ ៖ "លើសពីនេះទៀតឮថានាងស្អាតដូចទេពអប្សរ អ៊ីចឹង ហ៊ឺ ... ហ៊ឺ ..."។

៩. តើ "ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ" ដែលជាចំណងជើងអត្ថបទអំណាននេះ មានន័យដូចតទៅ ៖

- ក្តៅ : ក្តៅក្នុងពេលនេះគឺជាពាក្យន័យធៀបដែលមានន័យថា ការធ្វើកិច្ចការអ្វីមួយដោយតក់ក្រហល់ឆេវឆាវ ការវាយតប់ ការប្រើកម្លាំង ហិង្សា ដាក់ទណ្ឌកម្ម ការប្រយុទ្ធ ការធ្វើចម្បាំងជាដើម។
- ស៊ីរាក់ : ស៊ីរាក់ក្នុងចំណងជើងខាងលើជាពាក្យន័យធៀបដែលមានន័យថា ការធ្វើអ្វីមួយដែលតិចបានផលឬមិនបានសម្រេច។
- ត្រជាក់ : ត្រជាក់ក្នុងចំណងជើងខាងលើជាពាក្យន័យធៀបដែលមានន័យថា ភាពទន់ភ្លន់ សម្តីពីរោះ ភាពអត់ធ្មត់ភាពផ្អែមល្អែម ការលួងលោម។
- ស៊ីជ្រៅ : ស៊ីជ្រៅក្នុងន័យខាងលើជាពាក្យន័យធៀបដែលមានន័យថា ការធ្វើអ្វីមួយដែលទទួលបានជោគជ័យ។

ចំណងជើងខាងលើមានន័យថា ការធ្វើកិច្ចការអ្វីមួយដោយតក់ក្រហល់ ឆេវឆាវ ការវាយតប់ការប្រើកម្លាំង ហិង្សា ដាក់ទណ្ឌកម្ម ការប្រយុទ្ធ ការធ្វើចម្បាំងមិនបានទទួលជោគជ័យឡើយ។ ផ្ទុយទៅវិញ ការធ្វើកិច្ចការអ្វីមួយប្រើវិធីទន់ភ្លន់ សម្តីពីរោះ ផ្អែមល្អែម ការលួងលោមនឹងបានជោគជ័យ។

ដូច្នេះ ក្នុងស្នាដៃអក្សរសិល្ប៍រឿង តេជោយ៉ត បានលាតត្រដាងពីសកម្មភាពមេទ័ពតេជោមាស ចេញទៅច្បាំងដើម្បីកម្ចាត់ស្តេចសំរែដែលជាមេបះបោរចង់ដណ្តើមរាជ្យ តែត្រូវទទួលបរាជ័យ។ ក្រោយមក ជំទាវស្រែនជាភរិយាតេជោមាសបានប្រើកលធ្វើជាលែងលះប្តី ដើម្បីទាក់ទាញស្តេចសំរែ។ ជាចុងក្រោយ ស្តេចសំរែចាញ់កលជំទាវស្រែនរហូតដល់ចាប់ខ្លួនបាន។



ការសម្តែងល្ខោន

១. វត្ថុបំណង

- អានលើកដាក់សំឡេង គោរពសញ្ញាសម្ព័ន្ធតាមប្រភេទអត្ថបទសន្ទនារបស់រឿងល្ខោន
- សម្តែងល្ខោនបាសាក់រឿងតេជោយ៉ត បានល្អ
- បណ្តុះស្មារតីសិស្សឱ្យស្រឡាញ់ល្ខោនបាសាក់ខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៨០-៨៣
- អត្ថបទល្ខោនរឿង តេជោយ៉ត ដែលនិពន្ធនៅឆ្នាំ ១៩៨៣ ដោយលោក ទី ជីហួត
- កាសែតថតសំឡេងការសម្តែងល្ខោនរឿង តេជោយ៉ត របស់ស្ថានីយវិទ្យុជាតិកម្ពុជា
- ដី វី ឌី (DVD) រឿងល្ខោនផ្សេងៗសម្រាប់ឱ្យសិស្សយកជាគំរូ ។

៣. ព័ត៌មានដំឡូយ

ដើម្បីជាជំនួយដល់សិស្សក្នុងការសម្តែងល្ខោនបាសាក់រឿង តេជោយ៉ត សូមលោកគ្រូអ្នកគ្រូ ៖

- ឱ្យសិស្សហ្វឹកហាត់ច្រៀងឱ្យចាំស្ទាត់និងឱ្យត្រូវតាមលំនាំបទជាមុន
- ឱ្យសិស្សហ្វឹកហាត់ទន្ទេញសម្តីរបស់តួអង្គនីមួយៗឱ្យចាំស្ទាត់ជាមុន
- ឱ្យសិស្សហ្វឹកហាត់ធ្វើកាយវិការបានស្ទាត់ជាមុន
- គួរចែកក្រុមសិស្សឱ្យរកគ្រឿងតុបតែង សម្លៀកបំពាក់ និងសម្ភារៈផ្សេងៗទៀតសម្រាប់សម្តែង
- បើមានលទ្ធភាពគួរអញ្ជើញអ្នកជំនាញខាងសិល្បៈល្ខោន នៅក្នុងសហគមន៍ឱ្យមកដឹកនាំការសម្តែង ។

៤. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូសរសេរចំណងជើង "ការសម្តែងតួរឿងល្ខោន" ដាក់លើក្តារខៀន ហើយសួរសំណួរបំផុស ។
  - តើអ្នកធ្លាប់ទស្សនាឬស្តាប់ការសម្តែងល្ខោនឬទេ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើខ្មែរយើងនិយមសម្តែងល្ខោនអ្វីខ្លះ ?

    ចម្លើយ : ល្ខោនបាសាក់ ល្ខោននិយាយ យីកេ ... ។
  - តើការសម្តែងល្ខោនបាសាក់មានរបៀបដូចម្តេច ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សអានបញ្ញត្តិក្នុងសៀវភៅសិស្សទំព័រទី ៨០ នៅផ្នែកខាងលើអត្ថបទសន្ទនា រួចសួរ ៖

- ដូចម្តេចហៅថា ល្ខោន ?

ចម្លើយ : ល្ខោន គឺជាសិល្បៈមួយប្រភេទដែលគេយកទៅសម្តែងលើឆាក តាមរយៈកាយវិការរបស់តួអង្គនីមួយៗ នៅពីមុខទស្សនិកជន ។ ដើម្បីសម្តែងល្ខោនបានល្អ គេត្រូវរៀបចំជាឈុត ឆាកឱ្យបានត្រឹមត្រូវ ។

- គ្រូឱ្យសិស្សអានសេចក្តីពន្យល់ក្នុងសៀវភៅសិស្សទំព័រទី ៨២-៨៣ (ត្រង់លំហាត់) ។
- គ្រូសួរសំណួរដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្សលើសេចក្តីណែនាំ៖
  - តើគេត្រូវជ្រើសរើសអ្នកដឹកនាំសម្តែងយ៉ាងដូចម្តេច ?

  ចម្លើយ : ជ្រើសរើសអ្នកដែលអាចជួយកែលំអចំណុចខ្វះខាតរបស់តួសម្តែងនិងចាត់ចែងបញ្ចេញតួសម្តែង ។

  - តើគេត្រូវជ្រើសរើសតួអង្គសម្រាប់សម្តែងយ៉ាងដូចម្តេច ?

  ចម្លើយ :

  + ជ្រើសរើសចំនួនតួអង្គតាមចំនួនតួអង្គក្នុងរឿង ដូចជាក្នុងអត្ថបទឆាកល្ខោនដកស្រង់ខាងលើមានតួអង្គ ៣នាក់ គឺ តេជោមាស តេជោយ៉ត និងជំទាវស្រែន ។
  + តួអង្គឯក ត្រូវជ្រើសរើសអ្នកមានរូបរាងស្អាត សំឡេងពីរោះ តួអង្គកាចត្រូវជ្រើសរើសអ្នកមានទឹកមុខកាច តួអង្គកំប្លែងត្រូវជ្រើសមនុស្សក្រមាច់ក្រមើមប្រសប់និយាយកំប្លែង និងតួអង្គផ្សេងៗទៀតត្រូវជ្រើសរើសមនុស្ស ដែលមានទេពកោសល្យតាមលក្ខណៈតួអង្គនៅក្នុងសាច់រឿង ។

  - តើគេត្រូវរៀបចំនិងហ្វឹកហាត់ដូចម្តេចខ្លះ មុននឹងសម្តែង ?

  ចម្លើយ :

  + រៀបចំសាច់រឿងជាឈុត ឆាកឱ្យបានត្រឹមត្រូវ
  + ត្រៀមសម្ភារៈសម្រាប់ប្រើប្រាស់ពេលសម្តែងដូចជា ដាវ កាំបិត លំពែង ដំបង សម្លៀកបំពាក់ជាដើម ឱ្យបាន សមស្របតាមកាលអាកាសរឿង
  + ឱ្យតួអង្គនីមួយៗទន្ទេញពាក្យសម្តីដែលខ្លួនត្រូវនិយាយនិងច្រៀងចម្រៀងឱ្យបានចាំស្ទាត់មុនពេលសម្តែង
  + រៀបចំតុបតែងខ្លួនមុខមាត់ រាងកាយ សម្លៀកបំពាក់ អាវុធ ឱ្យស្របតាមលក្ខណៈតួអង្គនីមួយៗ និងកាល អាកាសនៃរឿង
  + ឱ្យតួអង្គនីមួយៗចងចាំពេលវេលាក្នុងឆាកដែលត្រូវចេញមកសម្តែងនិងត្រូវត្រឡប់ទៅវិញ ។ ***ឧទាហរណ៍*** តួអង្គ តេជោយ៉ត ត្រូវចេញមកសម្តែងពេលណាជាមួយអ្នកណា អ្នកណាចេញមុន អ្នកណាចេញក្រោយ
  + ឱ្យតួអង្គហ្វឹកហាត់ធ្វើកាយវិការឱ្យបានសមស្របតាមលក្ខណៈល្ខោននិងតាមស្ថានភាពរឿង ។

  - តើគេត្រូវរៀបចំឆាកសម្តែងយ៉ាងដូចម្តេច ?

  ចម្លើយ : ក្នុងការសម្តែង គេត្រូវជ្រើសរើសឆាកធំទូលាយនិងរៀបចំតុបតែងឆាកឱ្យបានស្អាត សមស្របតាមស្ថាន ភាពសាច់រឿង ។ គប្បីប្រើប្រាស់ផ្ទាំងរូបភាពនិងវត្ថុខ្លះៗ ដើម្បីឱ្យការសម្តែងមើលទៅហាក់ដូចជាស្ថិតក្នុង ទីកន្លែងនិងសម័យកាលមួយជាក់លាក់ ។ ការរៀបចំតុបតែងឆាកសម្តែងនេះ គប្បីផ្គាស់ទៅតាមស្ថានភាព នៃទីកន្លែងក្នុងសាច់រឿង ។

- តើគេត្រូវរៀបចំឆាកសម្តែងយ៉ាងដូចម្តេច ?

ចម្លើយ :

+ តួអង្គនីមួយៗត្រូវតុបតែងនិងប្រើប្រាស់សម្ភារៈ ព្រមទាំងចេញសម្តែងលើឆាកតាមពេលវេលាដែលបានកំណត់នៅក្នុងឆាកនីមួយៗ
+ តួអង្គនីមួយៗត្រូវនិយាយ សន្ទនា ច្រៀងដោយធ្វើកាយវិការឱ្យបានសមស្រប ។

ខ. ការនិយាយ

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងសមាជិក ៣នាក់ម្តងៗ ដោយឱ្យអ្នកទី ១ដើរតួជាតេជោមាស អ្នកទី ២ដើរតួជាតេជោយ៉ត និងអ្នកទី ៣ដើរតួជាជំទាវស្រែន ។
- គ្រូឱ្យក្រុមនីមួយៗហ្វឹកហាត់និយាយតាមអត្ថបទគំរូដោយមើលសៀវភៅ ។ បន្ទាប់មក ជ្រើសរើសសមាជិកក្រុមនីមួយៗឡើងនិយាយតាមអត្ថបទគំរូដោយមើលសៀវភៅ បង្ហាញសិស្សទាំងអស់ ។
- គ្រូសួរសំណួរទាក់ទងនឹងខ្លឹមសារលំអិតអត្ថបទ ៖
  - តើអត្ថបទនេះ ជាប្រភេទអត្ថបទអ្វី ?

  ចម្លើយ : អត្ថបទរឿងល្ខោន ។
  - តើអត្ថបទនេះ ដកស្រង់ចេញមកពីរឿងអ្វី ? មានប៉ុន្មានឆាក ? ជាឆាកទីប៉ុន្មាន ?

  ចម្លើយ : ដកស្រង់ចេញពីល្ខោនបាសាក់រឿងតេជោយ៉ត មានមួយឆាក ជាឆាកទី ១ ។
  - តើក្នុងឆាកទី ១នេះមានតួអង្គសម្តែងប៉ុន្មាននាក់ ? តួអង្គណាខ្លះ ?

  ចម្លើយ : មានតួអង្គ ៣នាក់ គឺតេជោមាស តេជោយ៉ត និងជំទាវស្រែន ។
  - តើតួអង្គណាចេញសម្តែងមុនគេ តួអង្គណាបន្ទាប់និងតួអង្គណាក្រោយគេ ?

  ចម្លើយ : តួអង្គតេជោមាសចេញសម្តែងមុនគេ បន្ទាប់មកតេជោយ៉ត និងចុងក្រោយគឺជំទាវស្រែន ។
  - តើការសម្តែងនេះមានចម្រៀងប៉ុន្មានបទ ? តើតួអង្គណាខ្លះជាអ្នកច្រៀង ? តើគេច្រៀងនៅពេលណា ?

  ចម្លើយ : មានចម្រៀងពីរបទ ។ បទទី ១តេជោមាសជាអ្នកច្រៀងគឺច្រៀងនៅពេលចេញសម្តែងបន្ទាប់ពីប្រាប់ឈ្មោះនិងមុខងាររួចមក ។ បទទី ២ ជំទាវស្រែនជាអ្នកច្រៀង គឺច្រៀងជូនពរស្វាមី(តេជោមាស) នៅពេលចេញទៅច្បាំង ។
- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងសមាជិក ៣នាក់ម្តងៗ ដោយឱ្យអ្នកទី ១ដើរតួជាតេជោមាស អ្នកទី ២ដើរតួជាតេជោយ៉ត និងអ្នកទី ៣ដើរតួជាជំទាវស្រែន ។
- គ្រូឱ្យក្រុមនីមួយៗហ្វឹកហាត់និយាយតាមអត្ថបទគំរូដោយមិនមើលសៀវភៅ ។ បន្ទាប់មក ជ្រើសរើសសមាជិកក្រុមនីមួយៗ ឡើងនិយាយដោយសម្តីផ្ទាល់ខ្លួនមិនមើលសៀវភៅ បង្ហាញសិស្សទាំងអស់ ។ សមាជិកក្រុមជួយកែលំអ ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សក្នុងថ្នាក់រួមគ្នាធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ៨២ រួមគ្នារៀបចំសម្តែងល្ខោនបាសាក់រឿង តេជោយ៉ត ឆាកទី ១ ។
- គ្រូឱ្យសិស្សឡើងសម្តែងទៅតាមការរៀបចំទុក ។
- គ្រូដឹកនាំសិស្សឱ្យធ្វើការវាយតម្លៃនិងកែលំអ ។

សូរស្រៈ

១. វត្ថុបំណង

- ប្រាប់បញ្ញត្តិស្រៈវែង ស្រៈខ្លី ស្រៈទោល និងស្រៈផ្សំបានត្រឹមត្រូវ
- បង្ហាញពីស្រៈវែង ស្រៈខ្លី ស្រៈទោល ស្រៈផ្សំ និងស្រៈពួក អ និងពួក អ៊ បានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យមានគំនិតអភិរក្សនិងអភិវឌ្ឍវេយ្យាករណ៍ខ្មែរ

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៨៤-៨៦
- ឯកសារវេយ្យាករណ៍ថ្នាក់ទី ៥របស់ក្រសួងអប់រំ បោះពុម្ពឆ្នាំ ១៩៨៣
- សៀវភៅទម្រង់សូរវិទ្យាខ្មែរ ឃួន សុខម្ហូ បណ្ឌិតអក្សរសាស្ត្រ
- សៀវភៅវេយ្យាករណ៍ថ្នាក់ទី ៨ បោះពុម្ពដោយក្រសួងអប់រំ ឆ្នាំ ១៩៨៦ ។

៣. ព័ត៌មានជំនួយ

- ដើម្បីឱ្យសិស្សយល់កាន់តែច្បាស់ សូមលោកគ្រូអ្នកគ្រូដាក់លំហាត់បន្ថែមទៀត ។
- សូមធ្វើការកែតម្រូវត្រង់ចំណុចទី ១ បញ្ចេក អ-អ៊ "ក.ស្រៈពួក អ" ក្នុងសៀវភៅសិស្សទំព័រទី ៨៤ ពុំមាន[អុំ]ទេ
- សូមធ្វើការកែតម្រូវត្រង់ចំណុចទី ១ បញ្ចេក អ-អ៊ "ខ.ស្រៈពួក អ៊" ក្នុងសៀវភៅសិស្សទំព័រទី ៨៤ ពុំមាន[អុំ]ទេ
- សូមធ្វើការកែតម្រូវត្រង់ចំណុចទី ១ បញ្ចេក អ-អ៊ "ខ.ស្រៈពួក អ៊" ក្នុងសៀវភៅសិស្សទំព័រទី ៨៤ សូមបន្ថែម[អ័]
- សូមធ្វើការកែតម្រូវត្រង់ចំណុចទី ២ បញ្ចេក វែង-ខ្លី "ក.ស្រៈវែងបន្លឺឡើងដោយដំណើរខ្យល់បង្ហូរវែង" ក្នុងសៀវភៅសិស្សទំព័រទី ៨៥ សូមប្តូរពី[អុ] ទៅជា[អុ] វិញ
- សូមធ្វើការកែតម្រូវត្រង់ចំណុចទី ៣ បញ្ចេក ទោល-ផ្សំ "ស្រៈផ្សំ" ក្នុងសៀវភៅសិស្សទំព័រទី ៨៦ សូមប្តូរពី[អ] ទៅជា [អ័] វិញ ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្ស ទំព័រទី ៨៤ បន្ទាប់មកគ្រូសរសេរចំណងជើងវេយ្យាករណ៍ "សូរស្រៈ" ដាក់លើក្តារខៀន រួចសួរ ៖
  - តើក្នុងភាសាខ្មែរយើងមានស្រៈអ៊ីខ្លះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើគេប្រើប្រាស់ស្រៈទាំងនោះយ៉ាងដូចម្តេច ?

    ចម្លើយ : អាស្រ័យលើសិស្ស ។

- គ្រូឱ្យសិស្សអានបញ្ញត្តិស្រៈក្នុងសៀវភៅសិស្សទំព័រទី ៨៤ផ្នែកខាងលើ រួចសួរ ៖
  - ដូចម្តេចហៅថា ស្រៈ ?

    ចម្លើយ : ស្រៈគឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេងបន្លឺឡើងដោយគ្មានទំនប់ ប្រកបដោយភាពច្បាស់លាស់ ។
- គ្រូឱ្យសិស្សអានចំណុចទី ១ "បញ្ចែក អ-អ៊" ក្នុងសៀវភៅសិស្សទំព័រទី ៨៤ រួចសួរ ៖
  - តាមមូលប្រភេទស្រៈចែកចេញជាប៉ុន្មានពួក ? អ្វីខ្លះ ?

    ចម្លើយ : តាមមូលភេទ ស្រៈចែកចេញជាបីពួកគឺ ស្រៈពួក [អ] ស្រៈពួក [អ៊] និងស្រៈពួក [អ-អ៊] ។
  - តើស្រៈពួក [អ] មានអ្វីខ្លះ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

    ចម្លើយ : ស្រៈពួក អ មាន : [អ] [អ់] [អា] [អា់] [អិ] [អី] [អឹ] [អឺ] [អុ] [អូ] [អើ] [អេ] [អែ] [អៃ] [អោ] [អៅ] ។

    ឧទាហរណ៍ ការ កើត ឡើង ។ ក្នុងពាក្យទាំងនេះសញ្ញាស្រៈ "◌ា ◌ើ ◌ើ" ប្រើជាមួយតួព្យញ្ជនៈពួក អ កត់សូរស្រៈពួក អ " [អា] [អើ] [អើ]" ។
  - តើស្រៈពួក [អ៊] មានអ្វីខ្លះ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

    ចម្លើយ : ស្រៈពួក អ៊ មាន : [អ៊] [អ៊់] [អ៊ា] [អ៊ា់] [អ៊ិ] [អ៊ី] [អ៊ឹ] [អ៊ឺ] [អ៊ុ] [អ៊ូ] [អ៊ើ] [អ៊េ] [អ៊ែ] [អ៊ៃ] [អ៊ោ] [អ៊ៅ] [អ៊ំ] ។

    ឧទាហរណ៍ ទា ឃើញ គេ ។ ក្នុងពាក្យទាំងនេះសញ្ញាស្រៈ "◌ា ◌ើ ◌ើ" ប្រើជាមួយតួព្យញ្ជនៈពួក អ៊ កត់សូរស្រៈពួក អ៊ " [អ៊ា] [អ៊ើ] [អ៊ើ]" ។
  - តើស្រៈពួក [អ-អ៊] មានអ្វីខ្លះ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

    ចម្លើយ : ស្រៈពួក អ-អ៊ មាន [អួ] [អឿ] [អៀ] ។

    ឧទាហរណ៍ គួរ កួ ខឿន កៀក ទៀត ជឿ សៀរ ។ ក្នុងពាក្យទាំងនេះសញ្ញាស្រៈ "◌ួ ◌ឿ ◌ៀ" ប្រើជាមួយតួព្យញ្ជនៈពួក អ ឬពួក អ៊ កត់សូរស្រៈពួក អ-អ៊ "[អួ] [អឿ] [អៀ]" ។
- គ្រូឱ្យសិស្សអានចំណុចទី ២ "បញ្ចែកវែង-ខ្លី" ក្នុងសៀវភៅសិស្សទំព័រទី ៨៥ រួចសួរ ៖
  - តាមលក្ខណៈខ្យល់ ស្រៈចែកចេញជាប៉ុន្មានពួក ? អ្វីខ្លះ ?

    ចម្លើយ : ចែកជាពីរពួកគឺ ស្រៈវែងនិងស្រៈខ្លី ។
  - តើស្រៈវែងមានអ្វីខ្លះ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

    ចម្លើយ : ស្រៈវែងមាន [អ] [អា] [អី] [អូ] [អើ] [អេ] [អែ] [អោ] [អ៊] [អ៊ា] [អ៊ី] [អ៊ឺ] [អ៊ូ] [អ៊ើ] [អ៊ែ] [អ៊ោ] [អ៊ំ] [អួ] [អឿ] [អៀ] ។

    ឧទាហរណ៍ យើង រៀន មួយ សប្បាយ បាន ។

- តើស្រៈខ្លីមានអ្វីខ្លះ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

ចម្លើយ : ស្រៈខ្លីមាន [អ់] [អា់] [អិ] [អឺ] [អឹ] [អុ] [អែ] [អៅ] [អ៉] [អ៉ា] [អុំ] [អុឺ] [អុះ] [អែ៉] [អ៉ៃ] [អ៉ោ] ។ ***ឧទាហរណ៍*** ក្បត់ រនាំង ប្រឹង ពង្រឹង មាត់ កប់ ។

- ដូចម្តេចហៅថាស្រៈវែង ? ដូចម្តេចហៅថាស្រៈខ្លី ?

ចម្លើយ : ស្រៈវែងបន្លឺឡើងដោយដំណើរខ្យល់បង្ហូរវែង ។ រីឯស្រៈខ្លីបន្លឺឡើងដោយដំណើរខ្យល់បង្ហូរខ្លី កាត់យ៉ាងរហ័សដោយបំណិទនៃខ្សែសំឡេង ។

- គ្រូឱ្យសិស្សអានចំណុចទី ៣ "បញ្ចេកទោល-ផ្សំ" ក្នុងសៀវភៅសិស្សទំព័រទី ៨៥ រួចសួរ ៖

- តើស្រៈទោលមានអ្វីខ្លះ ?

ចម្លើយ : ស្រៈទោលមាន [អ] [អ់] [អា] [អា់] [អិ] [អី] [អឺ] [អុ] [អូ] [អេ] [អែ] [អ៉] [អ៉ា] [អុំ] [អុឹ] [អុះ] [អឹ] [អុ] [អូ] [អើ] [អើ] [អែ] [អែ៉] [អោ] ។

- តើស្រៈផ្សំមានអ្វីខ្លះ ?

ចម្លើយ : ស្រៈផ្សំមាន [អឺ] [អើ] [អែ] [អៃ] [អោ] [អៅ] [អ៊ា] [អ៊ា់] [អ៊ៃ] [អ៊ើ] [អ៊ឺ] [អួ] [អឿ] [អៀ] ។

- ដូចម្តេចហៅថាស្រៈទោល ? ដូចម្តេចហៅថាស្រៈផ្សំ ?

ចម្លើយ : ស្រៈទោលកើតឡើងតែម្នាក់ឯង ។ ស្រៈផ្សំកើតឡើងដោយស្រៈទោលពីរយ៉ាងតិចចូលគ្នា ។

ខ. ការហ្វឹកហាត់

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ទី ១ , ២ , ៣ ក្នុងសៀវភៅសិស្សទំព័រទី ៨៦
- គ្រូណែនាំសិស្សពីរបៀបធ្វើលំហាត់ទី ១ , ២ , ៣ ក្នុងសៀវភៅសិស្សទំព័រទី ៨៦
- ក្រុមនីមួយៗធ្វើកិច្ចការ ។ បន្ទាប់ពីពិភាក្សាចប់ ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូធ្វើការបូកសរុបនិងកែលំអ ។

ចម្លើយ :

១. ពាក្យស្រៈពួក ៖

+ [អ] : សប្បាយ តារា រណារ ឆ្នាំង ចាប៉ី សសរ សរសើរ ។
+ [អ៊] : របៀន ទាហាន ស្ពាន ស៊ី ពាង មៀន ជញ្ជីង ហ៊ឹង គ្រូ ទុក្ខ វិជ្ជា ។
+ [អ-អ៊] : ជឿនលឿន រលួស កៀន ក្បឿង តឿ បង្គួរ មៀន សួរ ញញួរ ជឿ ។

២. ពាក្យស្រៈពួក ៖

+ [អ] : កករ ចាន តែង សង់ ក្វាន ដួង ថែ ប៉ុន្មាន បណ្តាច់ ប្រហារ ។
+ [អ៊] : រាក ឃាត់ ងាប់ គុក ញញឹម ជាប់ ឈឺ ពីងពាង មុត និយាយ ។
+ [អ-អ៊] : គ្រួសារ ជួប កួរស្រូវ រឿង លឿង ខឿន បៀតបៀន ចៀន ទៀងទាត់ សៀង ។

៣. សួរស្រៈ ៖

+ វែង : បង ទេ រង ឡើង លើក សាង ដេក ដែក លា ទា រៀន ... ។

+ ខ្លី : អន្ទិត ញញឹម ប្រគល់ របាំង រឹង ហាត់ ដាក់ មោះមុត រនាំង សំណាញ់ ស្រវឹង លិច ឱទិន ខ្ទឹង បាល់ កង់ ទុន ... ។

គ. ការវាយតម្លៃ

- គ្រូសួរបញ្ជាក់ឡើងវិញ ៖
  - ដូចម្តេចហៅថាស្រៈ ? បើយោងតាមការសរសេរនិងការអានអក្សរខ្មែរ គេចែកស្រៈជាប៉ុន្មានពួក ? អ្វីខ្លះ ? តើស្រៈពួក អ មានអ្វីខ្លះ ?
  - តើស្រៈពួក អ៊ មានអ្វីខ្លះ ? តើស្រៈពួក អ-អ៊ មានអ្វីខ្លះ ? តាមលក្ខណៈខ្យល់ស្រៈចែកចេញជាប៉ុន្មានពួក ? អ្វីខ្លះ?
  - តើស្រៈវែងមានអ្វីខ្លះ ? តើស្រៈទោលមានអ្វីខ្លះ ? ដូចម្តេចហៅថាស្រៈវែង ? ដូចម្តេចហៅថាស្រៈខ្លី ?
  - តើស្រៈទោលមានអ្វីខ្លះ ? តើស្រៈផ្សំមានអ្វីខ្លះ ? ដូចម្តេចហៅថាស្រៈទោល ? ដូចម្តេចហៅថាស្រៈផ្សំ ?
- គ្រូឱ្យសិស្សធ្វើលំហាត់ទី ៤ , ៥ ក្នុងសៀវភៅសិស្សទំព័រទី ៨៦
- គ្រូណែនាំសិស្សពីរបៀបធ្វើលំហាត់ទី ៤ , ៥ ក្នុងសៀវភៅសិស្សទំព័រទី ៨៦
- សិស្សធ្វើកិច្ចការរៀងៗខ្លួន បន្ទាប់ពីធ្វើលំហាត់ចប់ គ្រូប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ
- គ្រូធ្វើការកែលំអនិងវាយតម្លៃ។

ចម្លើយ :

៤. ពាក្យដែលមានសួរ

+ ស្រៈវែង : សូម ក្រាបទូល យើង យ៉ត មាស ស្រែន រូបរាង ប្រសើរ រឿង

+ ស្រៈខ្លី : គាល់ លក់ កំពង់ ពិត ព្រះអង្គ ឈ្លុយឈ្លប់ ស្រវឹង ស្លាប់ ផ្តាល់ ប្រុស។

៥. ពាក្យកើតឡើងពីស្រៈ

+ ទោល : តារា ពពិច ក្រមា ភ្នែក ទ្រអ៊ូ ខុស ទទឹក របេង ចាន ជ្រីង

+ ផ្សំ : ខោ អំពៅ ជម្រៅ ជំនឿ ប្រពៃ បង្កៃ សរសើរ សម្លៀកបំពាក់ ប្រៃ ក្រអូន។



ថៅកែចិត្តចោរ

១. វត្ថុបំណង

- បង្ហាញពីប្រភេទអត្ថបទ កាលអាកាស ឬតួអង្គក្នុងរឿងបានត្រឹមត្រូវ
- វិភាគតួអង្គបានត្រឹមត្រូវ
- បកស្រាយទស្សន:មួយចំនួនតាមរយៈសំដីតួអង្គក្នុងរឿងបានត្រឹមត្រូវ
- បណ្តុះស្មារតីមនុស្សធម៌សម្រាប់ការរស់នៅក្នុងសង្គម ស្អប់ខ្ពើមអំពើយុត្តិធម៌ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៨៧-៩៤
- អត្ថបទរឿង "ថៅកែចិត្តចោរ"ដែលនិពន្ធនៅឆ្នាំ ១៩៥៦ដោយលោក ពៅ យូឡេង និងលោក អ៊ំ ឈឿន ។

៣. ពត៌មានបន្ថែម

ដោយក្នុងសៀវភៅសិស្សពុំមានលទ្ធភាពសរសេររឿងទាំងមូលបាន ដូច្នេះ សូមលោកអ្នកគ្រូរកអត្ថបទល្ខោនរឿង "ថៅកែចិត្តចោរ"ដែលនិពន្ធនៅឆ្នាំ ១៩៥៦ដោយលោក ពៅ យូឡេង និងលោក អ៊ុំ ឈឿន ដើម្បីប្រើប្រាស់ជាជំនួយដល់ការឆ្លើយសំណួរ ។

៤. លំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ៤ទំព័រទី ៨៧ បន្ទាប់មក គ្រូសរសេរចំណងជើងអំណាន "រឿងថៅកែចិត្តចោរ"ដាក់លើក្តារខៀនរួចសួរ ៖
  - តើចំណងជើង "ថៅកែចិត្តចោរ"មានអត្ថន័យដូចម្តេច ?

  ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ៨៧រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ ?

  ចម្លើយ : មនុស្សបីនាក់កំពុងជជែកគ្នាពីបញ្ហាអ្វីមួយ ។ បុរសម្នាក់មានសម្លៀកបំពាក់ស្អាតមានក្រវាត់ក ទំនងជាអ្នកមានឬថៅកែ ។
- គ្រូសួរសំណួរឱ្យសិស្សប៉ាន់ស្មានខ្លឹមសារអត្ថបទ "រឿងថៅកែចិត្តចោរ" :
  - តើអត្ថបទនេះនិយាយពីអ្វី ?

  ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូសរសេរចម្លើយប៉ាន់ស្មានរបស់សិស្សដាក់លើក្តារខៀន ដើម្បីទុកផ្ទៀងផ្ទាត់ ។
- គ្រូឱ្យសិស្សរកពាក្យពិបាកនៅក្នុងអត្ថបទ រួចសរសេរពាក្យទាំងនោះនៅលើក្តារខៀន ។
- គ្រូឱ្យសិស្សអានពាក្យគន្លឹះនៅក្នុងសៀវភៅសិស្សទំព័រទី ៨៧ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិន ក្នុងសៀវភៅសិស្សទំព័រទី ៨៨រួចសួរសំណួរដើម្បីទាញបម្រុងប្រយ័ត្នរបស់សិស្ស ។
  - តើនៅក្នុងអត្ថបទនេះគេតម្រូវឱ្យអ្នកយល់ដឹងអំពីអ្វីខ្លះ ?

    ចម្លើយ : ឆាក តួអង្គ កាលអាកាស ការវិភាគតួអង្គ និងខ្លឹមសារអត្ថបទ ។
- គ្រូឱ្យសិស្សអានសំណួរ ក្នុងសៀវភៅសិស្សទំព័រទី ៩៤ រួចសួរ ៖
  - តើសំណួរទាំងអស់មានប៉ុន្មាន ?

    ចម្លើយ : សំណួរមានចំនួន ១១ ។
- គ្រូឱ្យសិស្សអានអត្ថបទអំណាន ក្នុងសៀវភៅសិស្សទំព័រទី ៨៨-៩៣ ។

គ. ពង្រឹងអំណាន

- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលម្អិតនៃអត្ថបទទាំងមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
- គ្រូឱ្យសិស្សឆ្លើយនឹងសំណួរពីទី ១ដល់ទី ៩ក្នុងសៀវភៅសិស្សទំព័រទី ៩៤ ។

ចម្លើយ :

១. តួអង្គពូហាំ ៖
   - តួនាទី : ជាតៃកុងឡាន
   - សកម្មភាព : មកផ្ទះថៅកែ ដើម្បីទារលុយពីថៅកែចំនួន ១០០០០រៀល ជាលុយដែលថៅកែជួលគាត់ឱ្យបើកឡានបុកឡានអុងប៉ាងហុងលីរហូតធ្វើឱ្យស្លាប់មនុស្សចំនួន ៣នាក់ ។ ឈ្លោះទាស់ទែងជាមួយថៅកែ ព្រោះថៅកែមិនព្រមឱ្យលុយគាត់ ។

២. បានជាពូហាំបើកឡានបុកឡាន អុងប៉ាងហុងលី ព្រោះថៅកែសន្យាថាឱ្យប្រាក់ពូហាំចំនួន ១០០០០រៀលដើម្បីដោះស្រាយជីវភាព ។

៣. បានជាពូហាំមានទំនាស់ជាមួយថៅកែ ព្រោះថៅកែក្បត់សន្យាមិនព្រមឱ្យប្រាក់ ១០០០០រៀល ជាថ្លៃឈ្នួលឱ្យពូហាំបើកឡានបុកឡានអុងប៉ាងហុងលី ។

៤. រឿង ថៅកែចិត្តចោរ មានតួអង្គចំនួន ៩នាក់គឺ ៖
   - នាយផានីត អាយុ ១៧ឆ្នាំ ធ្វើការក្នុងហាងឡាន
   - ពូហាំអាយុកណ្តាលមនុស្ស ជាតៃកុងឡាន
   - ថៅកែឡាន
   - នាង យ៉ាន ប្រពន្ធពូហាំ
   - សុខ កម្មករ
   - មាន កម្មករ

- ទ្រី កម្មករ
- គង់ កម្មករ
- ក្រុមនគរបាល ៣នាក់និងមានតួអង្គរំឭកផ្សេងទៀត ។
  + ពូហំ ជាតួអង្គឯក
  + ថៅកែឡាន នាយផានីត នាងយ៉ាន សុខ មាន ទ្រី គង់ ក្រុមនគរបាល ៣នាក់ជាតួអង្គរង ។

៥. ការវិភាគតួអង្គ ពូហំ និងថៅកែ ៖

- ការវិភាគតួអង្គ ពូហំ ៖
  + គុណសម្បត្តិ : ជាមនុស្សស្គាល់តួនាទីក្នុងគ្រួសារច្បាស់លាស់ (យកចិត្តទុកដាក់ចំពោះម្តាយ ប្រពន្ធ កូន) ។ មានចរិតមុឺងម៉ាត់ដាច់ខាត ហ៊ានទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន ប្រកាន់ពាក្យសច្ចៈ។ មានចិត្តកតញ្ញូចង់ឱ្យម្តាយធ្វើបុណ្យ ។ រិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយជីវភាពគ្រួសារ គិតគូរពីអនាគតកូនស្រី ស្រឡាញ់ចំណេះដឹង គិតគូរពូជពង្សរង្សត្រកូល ។
  + គុណវិបត្តិ : ព្រោះតែលុយ ១ម៉ឺនរៀល ពូហំ ហ៊ានប្រព្រឹត្តអំពើឧក្រិដ្ឋដោយបើកឡានបំបុកឡានមួយទៀតធ្វើឱ្យមនុស្សស្លាប់ ។ អំពើនេះ ជាអំពើអមនុស្សធម៌និងជាអំពើផ្ទុយនឹងច្បាប់សង្គម ។
- ការវិភាគតួអង្គថៅកែ ៖
  + គុណសម្បត្តិ : ផ្តល់ការងារឱ្យកម្មកធ្វើ ជួយជាតិដូចជាសាងសង់សាលា ធ្វើបុណ្យជាដើម ដូចនៅក្នុងឆាកទី ២ សម្តីថៅកែថា "អញអស់ប៉ុណ្ណឹងហើយ! មើលនាយ ផានីត ឯនេះគ្មានការធ្វើអញយកមកឱ្យធ្វើការជាមួយអញជួយយុវជន ។ រឿងអ្វីដែលរាជការហៅឱ្យជួយជាតិ អញមិនដែលខានទេ តាំងពីសង់សាលា ទិញឆ្នោតវត្ថុជួយសមាគម សង់សាលាបាលី សង់វត្ត ធ្វើបុណ្យទានគ្រប់សព្វនៅតែមិនដឹងអញទៀត" ។
  + គុណវិបត្តិ : មានគំនិតលោភលន់ បោកប្រាស់ កេងប្រវ័ញ្ចជិះជាន់ ពុករលួយ ធ្វើឱ្យខូចប្រយោជន៍អ្នកប្រកួតប្រជែងនឹងខ្លួន ។ មិនទទួលខុសត្រូវនឹងទង្វើរបស់ខ្លួន ។ មើលស្រាលមាក់ងាយអ្នកក្រ មើលស្រាលច្បាប់ ប្រមាថយុត្តិធម៌ ទិញទឹកចិត្តអ្នកក្រីក្រតូចតាចដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ។

៦. ប្រភេទអត្ថបទ ៖

- អត្ថបទនេះ ជាប្រភេទអត្ថបទរឿងល្ខោន
- ប្រភេទអត្ថបទរឿងល្ខោន មានរចនាបថខុសពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទានត្រង់ ៖
  + អត្ថបទរឿងល្ខោនចែកជាឈុតនិងឆាក
  + នៅខាងដើមអត្ថបទរឿងល្ខោននីមួយៗ មានបញ្ជីរាយនាមតួអង្គ និងឋាន: ឬប្រភពកំណើតរបស់តួអង្គ
  + អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយ បង្ហាញពីពំនោល ឬបទសន្ទនារវាងតួអង្គនិងតួអង្គ
  + ក្នុងអត្ថបទល្ខោននិយាយ អ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក ។

៧. ខ្លឹមសារអត្ថបទ ៖

- អត្ថបទល្ខោនដកស្រង់នេះមាន ២ឆាកគឺ ឆាកទី ២និងឆាកទី ៣
- ការផ្លាស់ប្តូរឆាក : ការផ្លាស់ប្តូរឆាកទី ២ទៅឆាកទី ៣កើតនៅពេលពេលប្តូរព្រឹត្តិការណ៍ជម្លោះរវាងតួអង្គពីរគឺ ថៅកែនិងពូហំ មកបង្ហាញព្រឹត្តិការណ៍ដែលមានតួអង្គថ្មីទៀតគឺ នាយផានីត សុខ មាន ទ្រី គង់ ជជែកគ្នាអំពីជម្លោះរបស់ថៅកែនិងពូហំ ។

៨. ប្រភេទអត្ថបទដកស្រង់ ៖

- អត្ថបទនេះ ជាប្រភេទអត្ថបទរឿងល្ខោន
- ប្រភេទអត្ថបទរឿងល្ខោនមានរចនាបថដូចខាងក្រោម ៖
  + អត្ថបទរឿងល្ខោនចែកជា ឈុតនិងឆាក
  + នៅខាងដើមអត្ថបទរឿងល្ខោននីមួយៗ មានបញ្ជីរាយនាមតួអង្គ និងឋាន: ឬប្រភពកំណើតរបស់តួអង្គ
  + អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយ បង្ហាញពំនោល ឬបទសន្ទនារវាងតួអង្គនិងតួអង្គ
  + ក្នុងអត្ថបទល្ខោននិយាយ អ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក ។

៩. កាលអាកាសនៃរឿង ៖

- កាល (ពេលវេលា) : រឿងរ៉ាវទាំងអស់ប្រព្រឹត្តទៅក្នុងរវាងឆ្នាំ ១៩៥៤-១៩៥៦ ។
- អាកាស (ទីកន្លែង) : ដំណើររឿងប្រព្រឹត្តទៅនៅផ្ទះថៅកែ ។

ឃ. ការវាយតម្លៃ

- គ្រូឱ្យសិស្សម្នាក់ៗធ្វើសំណួរទី ១០និងទី ១១ (ជាតែងសេចក្តី) ក្នុងសៀវភៅសិស្សទំព័រទី ៩៤ដាក់ក្រដាសរៀងៗខ្លួន

ចម្លើយ :

១០. ការបកស្រាយពី "អំពើរបស់តួអង្គថៅកែ តួអង្គហំ ជាអំពើខុសឆ្គងនឹង ..."

- ផ្លូវពុទ្ធចក្រ : អំពើរបស់អ្នកទាំងពីរកើតចេញពីលោភៈដោយចេតនា ព្រោះ
  + ថៅកែ : "អញឱ្យបុកមែន តែមិនមែនឱ្យបុកទាល់តែស្លាប់មនុស្សឯណា! " ។
  + ហំ : "ចុះថៅកែសន្យាថា បើខ្ញុំបុកឡានអាហុងលីបាន ឱ្យខ្ញុំ ១ម៉ឺន" ។

  ដូច្នេះដើម្បីតែផលប្រយោជន៍ខ្លួន អ្នកទាំងពីរបានប្រមាថអាយុជីវិតមនុស្ស គឺស្លាប់អស់ ៣នាក់ និងរបួសមួយចំនួនទៀត ។ តាមព្រះពុទ្ធសាសនាអំពើបែបនេះ ជាអំពើបាបកម្មមួយយ៉ាងធ្ងន់ធ្ងរ ដូចមានចែងក្នុងនិច្ចសីល "បាណាតិបាតា" ហាមសម្លាប់សត្វដែលមានជីវិត ។

- ផ្លូវអាណាចក្រ : អ្នកទាំងពីររួមគ្នាប្រព្រឹត្តអំពើទុច្ចរិត(ថៅកែរៀបផែនការ ហំអនុវត្តផែនការ) :
  + ថៅកែ : "អញឱ្យបុកមែន តែមិនមែនឱ្យបុកទាល់តែស្លាប់មនុស្សឯណា! " ។
  + ហំ : "ខ្ញុំក៏មិនមែនចង់ឱ្យមានមនុស្សស្លាប់ដែរ តែនរណាប៉ាន់គ្រោះថ្នាក់" ។

  ដូច្នេះ ដើម្បីតែផលប្រយោជន៍ខ្លួន អ្នកទាំងពីរមើលងាយផ្លូវច្បាប់ ល្មើសច្បាប់បើកបរ បង្កអស្ថិរភាពសង្គម មិនទទួលខុសត្រូវ ។ ជាពិសេស មានចេតនាគេចចេញពីសំណាញ់ច្បាប់ទៀតផង ។ ដូចសំដីថៅកែ "អាឯងចង់ទៅប្តឹងៗទៅ អាឯងនិយាយឱ្យបែកមេឃ ក៏គ្មានលោកណាជឿឯងដែរ ។ នាម៉ឺនគេជឿអញ អាសម្លុយ" ។ ឯហំវិញ "ខ្ញុំដឹងថាគេរកចាប់ខ្លួនខ្ញុំហើយ បានជាខ្ញុំឆ្លៀតមកបើកលុយរង្វាន់រួចនឹងអាលគេច" ។

- ផ្លូវសីលធម៌ : តួអង្គទាំងពីរបាត់បង់អស់មនសិការ វិចារណៈ សម្បជញ្ញៈ និងស្មារតីមនុស្សធម៌ ។ ពួកគេពុំបានគិតពីមនោសញ្ចេតនាមនុស្សជាតិសោះឡើយ ព្រោះថា បើសិនជាជនរងគ្រោះជាម្តាយ ជាកូន និងជាប្រពន្ធរបស់អ្នកទាំងពីរវិញ ពួកគេពិតជាមានអារម្មណ៍ឈឺចាប់ និងសោកស្តាយដូចជាសាច់ញាតិជនរងគ្រោះជាមិនខានឡើយ ។ អ្នកទាំងពីរមិនត្រឹមតែមិនភ្ញាក់រលឹក ថែមទាំងនិយាយដោយក្តីសោកស្តាយនោះទៀតផងដូចជា ហាំបានបញ្ជាក់ "ជីវិតខ្ញុំថ្លៃតែ ១ម៉ឺនរៀលទេ ។ ... ឱ្យខ្ញុំភ្លាមមក ១ម៉ឺនដូចជាបោះចោលឱ្យសត្វលង់ទឹកទៅចុះ ។ រីឯថៅកែវិញ "ពួកអាអស់នោះវាមិនមែនឆ្កួតទៅសម្លាប់អញឱ្យអាឯងរស់នោះទេ ។ ទុកជាវាឮមែន ឱ្យលុយវាខ្លះទៅ វាទៅជាមិនឮវិញហើយ" ។

១១. ពន្យល់សម្តីតួអង្គ :

- ហាំ "កុំអាងទឹកប្រាក់ហើយមើលងាយមនុស្ស" មានន័យថា ដោយសំអាងទឹកប្រាក់ បែរជាមិនឱ្យតម្លៃអំពើល្អ តាមរយៈទឹកចិត្ត ព្រោះថាមនុស្សគ្រប់រូបចាំបាច់ត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ទំនាក់ទំនងនេះ ត្រូវបានផ្សារភ្ជាប់ទៅនឹងស្មារតីមនុស្សធម៌ គឺកើតចេញពីការជួយគ្នាទៅវិញទៅមកក្នុងគ្រាមានអាសន្ន ការអធ្យាស្រ័យគ្នាជាដើម ។ ទន្ទឹមនឹងនេះ មិត្តភាព សាមគ្គីភាព សេចក្តីស្នេហា ឬស្មារតីជាតិនិយមសុទ្ធសឹងតែផ្តើមចេញពីទឹកចិត្តដ៏ស្មោះត្រង់ ពុំអាចយកប្រាក់មកទិញបានឡើយ ។ ប៉ុន្តែ បើសិនជាគេយកលុយទៅប្រើប្រាស់ជាមធ្យោបាយក្នុងការអូសទាញពីតម្រូវការដូចខាងលើនេះ នោះវាមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ នៅពេលណាមួយដែលអស់លុយ វានឹងអស់តម្លៃដែរ ។ ប្រការនេះហើយ ដែលជាហេតុធ្វើឱ្យថៅកែមិនអាចយកលុយមកទិញទឹកចិត្តស្នេហាយុត្តិធម៌របស់កម្មករទាំងនោះបានឡើយ ។
  + សរុបសេចក្តីមក ទឹកប្រាក់ពិតជាពុំមានតម្លៃដូចទឹកចិត្តមនុស្សធម៌ឡើយ ព្រោះទឹកប្រាក់គ្រាន់តែជាគ្រឿងបញ្ឆោតចិត្ត បានធូរតែមួយគ្រាៗប៉ុណ្ណោះ ។ បើសិនជាភាពយូរអង្វែងអមតៈនោះ គឺទឹកចិត្តមនុស្សធម៌ ដែលអាចបង្កើតអនុស្សាវរីយ៍ ប្រកបដោយខ្លឹមសារជីវិត ហើយមិនងាយសាបសូន្យទៀតផង ។
- ថៅកែ "កុំអាងទឹកចិត្តមនុស្សធម៌ ហើយមើលងាយកម្លាំងប្រាក់" មានន័យថា ដោយសំអាងទៅលើអំពើល្អតាមរយៈទឹកចិត្តនោះ បែរជាមិនឱ្យតម្លៃទៅលើទឹកប្រាក់ទៅវិញ ។ តាមពិតមនុស្សក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីរស់នៅប្រកបទៅដោយសេចក្តីសុខ គេចាំបាច់ត្រូវការប្រាក់ ព្រោះវាបានបំពេញតម្រូវការចំពោះមុខដល់មនុស្ស ។ ក្នុងជីវភាពប្រចាំថ្ងៃ បុគ្គលគ្រប់រូប គ្រប់ស្រទាប់ជាន់ថ្នាក់ តែងតែស្រវាស្រទេញព្យាយាមរិះរកវិធី ដើម្បីរកប្រាក់ទៅតាមមុខងារ ឬជំនាញស្របច្បាប់នីមួយៗ ដែលខ្លួនមាន ។ អាចនិយាយដោយខ្លីថា ពេលឃ្លានគេត្រូវបរិភោគ ពេលស្វែងរកចំណេះ គេត្រូវបន្តវិជ្ជាទៅទៀត ពេលព្យាបាលជំងឺរក្សាសុខភាព គេត្រូវទៅមន្ទីរពេទ្យដើម្បីព្យាបាលជាដើម ។ ទាំងអស់នេះ គឺទាមទារឱ្យមានប្រាក់ បើពុំដូច្នោះទេ គេពុំអាចសម្រេចតាមបំណងខ្លួនឡើយ ។
  + សរុបសេចក្តីមក លុយពិតជាមានតម្លៃ ដែលអាចជំរុញឱ្យមនុស្សសម្រេចបានតាមបំណងខ្លួនយ៉ាងល្អប្រសើរបំផុត ។
  + សន្និដ្ឋាន : តាមសម្តីហាំក្តី ថៅកែក្តី ជាសម្តីដែលឆ្លុះបញ្ចាំងពីតថភាពសង្គម ពុំអាចបោះបង់ណាមួយបានឡើយ ។ ដោយហេតុថា ទឹកចិត្តនិងទឹកប្រាក់សុទ្ធតែជាកត្តាសំខាន់ ក្នុងការកំណត់សុភមង្គលរបស់មនុស្សម្នាក់ៗ ។ ប៉ុន្តែ គ្រាន់តែភាពចាំបាច់ នៃកត្តាទាំងពីរនេះមានតម្រូវការខុសគ្នាបន្តិចទៅតាមកាលៈទេសៈ គឺពេលខ្លះទឹកចិត្តឈានមុខទឹកប្រាក់ ហើយពេលខ្លះទៀតត្រូវទឹកប្រាក់ឈានមុខទឹកចិត្ត និងពេលខ្លះទៀតទាំងទឹកចិត្តនិងទឹកប្រាក់ដើរទន្ទឹមគ្នាតែម្តង ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវរក្សាតម្លៃពិតប្រាកដ គឺទាំងទឹកចិត្តនិងទាំងទឹកប្រាក់ត្រូវផ្តើមចេញពីភាពស្មោះត្រង់សុច្ចរិត និងមានសីលធម៌ថែមទៀត ទើបជាការប្រសើរ ។



ការស្តាប់ : រឿង តេជោយ៉ត

១. វត្ថុបំណង

- ប្រាប់ពីតួអង្គ មុខងារ និងសកម្មភាពបានត្រឹមត្រូវ
- វិភាគតួអង្គបានត្រឹមត្រូវ
- ប្រាប់ពីកាលអាកាសរឿងបានត្រឹមត្រូវ
- បណ្តុះស្មារតីស្អប់ខ្ពើមអំពើបក្ខពួកនិយមនៅក្នុងសង្គម ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៩៥
- អត្ថបទល្ខោនរឿង "តេជោយ៉ត"ដែលនិពន្ធនៅឆ្នាំ ១៩៨៣ដោយលោក ទី ជីហួត

៣. ព័ត៌មានជំនួយ

ដោយក្នុងសៀវភៅសិស្សពុំមានលទ្ធភាពសរសេររឿងទាំងមូលបាន ដូច្នេះសូមលោក/អ្នកគ្រូរកអត្ថបទល្ខោនរឿង "តេជោយ៉ត"ដែលនិពន្ធនៅឆ្នាំ ១៩៨៣ដោយលោក ទី ជីហួត ដើម្បីប្រើប្រាស់ជាជំនួយដល់ការឆ្លើយនឹងសំណួរ ។

៤. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ៤ទំព័រទី ៩៥ បន្ទាប់មកគ្រូសរសេរចំណងជើងការស្តាប់ដាក់លើក្តារខៀន "រឿង តេជោយ៉ត" រួចសួរ ៖
  - តើអ្នកធ្លាប់អានរឿង តេជោយ៉ត ឬទេ ? តើរឿងនោះមានខ្លឹមសារដូចម្តេចខ្លះ ?

  ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ៩៥រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

  ចម្លើយ : ឃើញមនុស្សមានឯកសណ្ឋានជាទ័ពសម័យបុរាណ ។
  - តើអ្នកគិតថា មនុស្សនៅក្នុងរូបភាពនេះកំពុងធ្វើអ្វី ?

  ចម្លើយ : អាស្រ័យលើសិស្ស ។
- ការសិក្សាពាក្យគន្លឹះ
  - ឧបមា (ន) : ការប្រៀបប្រដូច សេចក្តីប្រៀបធៀប ។
  - អាជ្ញា (ន) : អំណាច ការគ្រប់គ្រង ការបង្គាប់បញ្ជា ច្បាប់បញ្ញត្តិ ។
  - កំណែន (ន) : ការកែន ។
  - ពល (ន) : សេនា ទាហាន កងទ័ព ។
  - កេណ្ឌ (កិ) : បង្គាប់ ប្រមូលហៅរកដោយអាជ្ញា ។
  - អាជ្ញាសឹក (ន) : ច្បាប់ដែលបញ្ញត្តិប្រើក្នុងពេលកើតសង្គ្រាម ។
  - ឧកញ៉ាចក្រី (ន) : ងារសេនាបតីក្នុងកម្ពុជរដ្ឋ សម្រេចកិច្ចខាងក្រសួងការពារជាតិ ។

- ឈ្លើយសឹក (ន) : កងទ័ពដែលគេចាប់បានពេលសង្គ្រាម ។
- បះបោរ (ន) : បះរជើបរជោរឹងទទឹង របែររបោរ មិនព្រមប្រតិបត្តិតាមបញ្ញត្តិរបស់រាជការ ។
- សន្និដ្ឋាន (ន) : ការរួមគំនិតជាមួយ ឬការបង្រួមគំនិតដើម្បីឱ្យបានជាយោបល់មួយ ។
- យុទ្ធវិធី (ន) : វិធីចម្បាំង កលឧបាយសង្គ្រាម ។
- ក្បួនតម្រា (ន) : ក្បួនដែលគេកត់ត្រាទុក ។
- ពិជ័យសង្គ្រាម (ន) : ពួកយោធាក្រុមទ័ពស្រួច ឈ្មោះក្បួនសម្រាប់រៀនកលល្បិចធ្វើសង្គ្រាមឱ្យមានជ័យជំនះ ។
- សង្គ្រាមវណ្ណៈ (ន) : សង្គ្រាមរវាងពួកមនុស្សដែលមានវណ្ណៈខុសគ្នានៅក្នុងសង្គម ។

ខ. ការស្តាប់

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ៩៥ ។
- គ្រូអានអត្ថបទខាងក្រោមឱ្យសិស្សស្តាប់ ។

រឿង តេជោយ័ត

ម៉ឺនចៃចុងរ៉ាក់ : មានងារជាម៉ឺនចៃចុងរ៉ាក់ ឪពុកខ្ញុំជាអ្នកមានមុខណាស់ក្នុងខេត្តលង្វែកនេះ ។ (ច្រៀង) នឹកឡើងក្តៅចិត្តឥតឧបមានឹងបទអាជ្ញាៗ ជាប់កំណែនពលធ្លាប់តែសប្បាយឥតមានខ្វាយខ្វល់ ឥឡូវធ្លាក់ដល់ៗចូលធ្វើកងទ័ព ។ ឯណាពួកយើង ... !

អ្នកទី ១ : បាទ! ម៉ឺនចៃចុងរ៉ាក់គិតយ៉ាងម៉េចទៅ បើយើងត្រូវគេកេណ្ឌឱ្យធ្វើពលសឹកយ៉ាងនេះ ។

អ្នកទី ២ : ហ្នឹងហើយ! ពួកយើងសុទ្ធតែជាកូនអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភមានមុខមានមាត់នៅក្នុងខេត្តលង្វែកនេះ ។ ប៉ុន្តែធ្វើយ៉ាងម៉េចនឹងហ៊ានប្រឆាំងនឹងរាជអាជ្ញាសឹក ។

អ្នកទី ១ : មែនហើយបង! កាលលោកឧកញ៉ាក្រឡាហោមនិងលោកឧកញ៉ាចក្រីមកកេណ្ឌកាលពីលើកមុននោះ យើងបាននាំគ្នារត់ត្រឡប់មកផ្ទះវិញម្តងរួចទៅហើយ ។ ប៉ុន្តែលើកនេះមិនដឹងយ៉ាងណាទេ ព្រោះមើលទៅឧកញ៉ាតេជោយ័ត ស្អីគេនឹងមើលទៅហាក់ដូចជាម៉ឺងម៉ាត់ណាស់!

បក្សពួកឯទៀត : មែនហើយបង! ដូចជាម៉ឺងម៉ាត់មែនហ្នឹង!

ម៉ឺនចៃចុងរ៉ាក់ : ពួកយើង! បងរបស់យើងបានផ្តាំមកហើយ!

អ្នកទី ២ : ពួកខ្ញុំសង្ឃឹមលើបងម៉ឺនចៃចុងរ៉ាក់ហើយ ព្រោះបងជាប្អូនអ្នកម្នាងនួបង្កើត ។

អ្នកទី ១ : មែនហើយម៉ឺនចៃ ជាប្អូនថ្លៃស្តេចទោះបីយ៉ាងណាក៏អាចជួយពួកយើងឱ្យបានរួចខ្លួនពីការធ្វើសឹកសង្គ្រាមនេះដែរ!

ម៉ឺនចៃចុងរ៉ាក់ : បងរបស់យើងបានផ្តាំថាអាជ្ញាសឹកយើងមិនអាចប្រឆាំងបានទេ ប៉ុន្តែបើមានឱកាសល្អយើងរត់ទៅដល់ព្រះរាជធានី គាត់នឹងជួយការពារយើងហើយ ។

ទាំងអស់គ្នា : ហ៎ា! ល្អ! ល្អ! មានសង្ឃឹមហើយ ប៉ុន្តែកុំភ្លេចធ្វើដូចមុន ។ ពេលទៅនោះ យើងត្រូវយកវត្ថុដែលមានតម្លៃគ្រប់ៗគ្នាទៅជូនដល់អ្នកម្នាងជាសគុណផងណា៎ ។

អ្នកទី ១ : មែនហើយរឿងនេះកុំភ្លេចឱ្យសោះ ។

ម៉ឺនចៃចុងរ៉ាក់ : អើ! ពួកឯងទៅប្រាប់គ្នាយើងទៅថា បើយើងឱ្យធ្វើម៉េចចាំធ្វើតាម ឮទេ!

អ្នកទី ២ : បាទ! បាទ! បង ។

តេជោយ័ត : មកដល់លង្វែកនេះកេណ្ឌទ័ពទាំងត្រើយខាងលិចនិងត្រើយខាងកើត បានតែមួយពាន់នាក់បូករួម

ទាំងមកពីកំពង់ស្វាយ គឺបានតែមួយពាន់ប្រាំមួយរយនាក់ប៉ុណ្ណោះ ឃើញថានៅចាញ់ចំនួនទ័ព សត្រូវច្រើនណាស់ ប៉ុន្តែខ្ញុំជឿជាក់ថា (ច្រៀង) កងទ័ពមោះមុតមិនស្លុតស្មារតីគោរពវិន័យមាន សណ្តាប់ធ្នាប់ (២ដង) ភូមិសាស្ត្រពួកខ្មាំងយើងក្តាប់បានជាប់ មុខជាកងទ័ពទទួលជោគជ័យ។ (និយាយ) លោកឧកញ៉ាព្រហ្មស្រី!

ឧកញ៉ាព្រហ្មស្រី : បាទ! តេជោ មានការអីទាន!

តេជោយ៉ត : យ៉ាងម៉េចទៅ លោកបានត្រួតពិនិត្យស្បៀងអាហាររបស់យើងរួចហើយ ឬនៅ ?

ឧកញ៉ាព្រហ្មស្រី : តាមការប៉ាន់ស្មានមើលទៅចំនួនទ័ពប៉ុណ្ណោះ ស្បៀងអាហារយើងអាចផ្គត់ផ្គង់បានរយៈពេលបួនខែណា៎។

នាយទិននាយតយ : សូមជម្រាបសួរលោកម្ចាស់!

តេជោយ៉ត : អូ! ពូទាំងពីរត្រឡប់មកវិញហើយអី!

នាយទិន : បាទ! មកវិញហើយទាន បានជាលោកម្ចាស់ឃើញទាន!

នាយតយ : ឃី! អានេះវុី ម៉េចឯងនិយាយគ្មានដឹងខ្យល់អីអីចឹង!

នាយទិន : អីចឹងឱ្យអញនិយាយថាម៉េច ?

នាយតយ : តាមការពិតព្រោះតែពួកខ្ញុំមកហើយ បានលោកម្ចាស់ឃើញទាន!

តេជោយ៉ត : តើបានការយ៉ាងម៉េចទៅ ?

នាយទិន : ជម្រាបប្រសាសន៍លោកម្ចាស់ពួកខ្ញុំធ្វើការបានជោគជ័យ!

នាយតយ : ទុកឱ្យអញនិយាយវិញអាទិន!

នាយទិន : កុំកាត់ប្រសាសន៍ ខ្ញុំណាអាតយ!

នាយតយ : អញ វាអាយុច្រើនជាងបីខែ អញត្រូវនិយាយមុន។

ឧកញ៉ាព្រហ្មស្រី : ពូទាំងពីរកុំនិយាយច្រើនឥតប្រយោជន៍ពេក ឆាប់និយាយភ្លាមមក!

នាយទិន : លោកម្ចាស់ឱ្យនិយាយម្តងម្នាក់។

នាយតយ : បើនិយាយអីចឹងយើង និយាយម្នាក់បីម៉ាត់។

នាយទិន : អើ អីចឹងឯងនិយាយមុនទៅអាតយ។

នាយតយ : បើ អីចឹងយើងនិយាយហើយណា៎!

នាយទិន : ជម្រាបប្រសាសន៍លោកម្ចាស់។

នាយតយ : ទ័ពឈ្លើយសឹក កំពុងតែខ្វះខាតស្បៀងតែបន្ទាយរបស់វាមាំមួនណាស់ ឯពលទាំងអស់...

នាយទិន : អាតយឯងនិយាយលើសពាក្យហើយ អាតយ!

នាយតយ : ពិបាកណាស់ ឯងនិយាយតែម្នាក់ឯងទៅបានហើយ!

ឧកញ៉ាព្រហ្មស្រី : ឥឡូវជម្រាបលោកតេជោឱ្យច្បាស់ថាយ៉ាងម៉េច!

នាយទិន : បើអីចឹងក៏បាន។ លោកម្ចាស់ស្បៀងអាហាររបស់ពួកគេពុំធានាបានយូរខែទេទាន ហើយទាហានរបស់ពួកគេកំពុងតែក្លាហានណាស់ ព្រោះគេទើបតែឈ្នះទ័ពឧកញ៉ាចក្រី និងឧកញ៉ាក្រឡាហោមថ្មីនេះបាទទាន!

តេជោយ៉ត : លោកពូទាំងពីរធ្វើការបានល្អណាស់! លោកឧកញ៉ាព្រហ្មស្រី! ឧកញ៉ាចក្រី និងឧកញ៉ាក្រឡាហោម លើកទ័ពរាប់ម៉ឺននាក់មកបង្ក្រាបទ័ពឈ្លើយសឹកបះបោរ តែត្រូវបរាជ័យតើលោកដឹងពីមូលហេតុនៃបរាជ័យនោះទេ ?

ឧកញ៉ាព្រហ្មស្រី : បាទ! ខ្ញុំមិនបានដឹងសោះ។

តេជោយ៉ត : ព្រោះពេលធ្វើសឹកសង្គ្រាមនោះគាត់មានខ្មាំងពីក្រោយខ្នងផង ខ្ញុំបានស៊ើបសួរដឹងអស់ហើយ។

ឧកញ៉ាព្រហ្មស្រី : យី! ខ្មាំងក្រោយខ្នង! (ឧទានដោយភ្ញាក់ផ្អើល)។

តេជោយ៉ត : ដូច្នេះពេលនេះ មុននឹងវាយខ្មាំងពីមុខយើងត្រូវរកខ្មាំងពីក្រោយខ្នងជាមុនសិន។

ឧកញ៉ាព្រហ្មស្រី : តើយើងត្រូវធ្វើយ៉ាងណា៎! ដើម្បីឱ្យដឹងខ្មាំងពីក្រោយខ្នងនោះលោកតេជោ!

តេជោយ៉ត : លោកត្រូវប្រជុំពលទាហានទាំងអស់ហើយបញ្ជាឱ្យនាំគ្នាទៅកាប់ឫស្សី ដើម្បីយកមកសង់បន្ទាយ រាយចម្រុងការពារមូលដ្ឋានរបស់យើង ព្រោះខ្លាចក្រែងមានការវាយឆ្មក់ពីពួកសៀមបះបោរក្នុងពេលដែលយើងកំពុងហាត់ក្បួនចម្បាំង ក៏ប៉ុន្តែសំខាន់បំផុតឫស្សីដែលកាប់ហើយទាំងនោះហាមមិនឱ្យលួសមែកជាដាច់ខាត ហើយត្រូវអូសមកបញ្ចាសចុង ហាមមិនឱ្យអូសពីគល់ទេណា៎!

ឧកញ៉ាព្រហ្មស្រី : រួចហេតុអីក៏ធ្វើអីចឹងលោកតេជោ?

តេជោយ៉ត : ធ្វើតាមតែខ្ញុំទៅ ហើយចែកគ្នាដើរត្រួតពិនិត្យមើល បើឃើញអ្នកណាអូសឫស្សីបណ្តោយចុងត្រូវមកប្រាប់ខ្ញុំភ្លាម។

ឧកញ៉ាព្រហ្មស្រី : បាទ! បាទ! មិនអីទេលោកតេជោ។

ម៉ឺនចៃចុងវ៉ាក់ : ឫយ! តាំងពីកើតពីពោះម៉ែមកមិនដែលឃើញអាណាអូសឫស្សីបញ្ចាសចុងទេរ៉ឺ!

បក្សពួកម៉ឺនចៃចុងវ៉ាក់ : មែនហើយលោកបង!

ម៉ឺនចៃចុងវ៉ាក់ : អញខ្ជិលណាស់រ៉ឺ! ដឹងអូសស្អីអីចឹងទេ!

បក្សពួកម៉ឺនចៃចុងវ៉ាក់ : មែនហើយ! តេជោស្អីគេនេះ មិនដឹងបញ្ជាស្អីផ្តេសផ្តាសអីចឹងទេឱ្យពួកយើងអូសឫស្សីបញ្ចាសចុងទាល់តែទទាក់។

ម៉ឺនចៃចុងវ៉ាក់ : ពួកយើងជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ មានទ្រព្យសុកស្តម្ភមានមុខមាត់ យើងត្រូវការសប្បាយហ៊ឺហា។ យើងអត់ត្រូវការគិតពីរឿងប្រទេសជាតិរឿងនគរស្អីទេ។ បែបនេះយើងរង់ចាំតែឱកាសរត់ទៅព្រះរាជធានីទៅរកអ្នកបងនូដើម្បីឱ្យរួចខ្លួនពីកំណែនសឹកប៉ុណ្ណោះ។ ឈប់គោរពទៅ។ ដូច្នេះចាំបាច់គោរពបញ្ជាឱ្យនឿយហត់នាំអស់កម្លាំងធ្វើអីទេរ៉ឺ។ ឈប់គោរពទៅ! ឥឡូវនេះប្រាប់ពួកយើងឱ្យអូសឫស្សីបណ្តោយទៅវិញមានម៉ែអាណាអូសបញ្ចាសចុងទេចាំមើលវាធ្វើអីខ្ញុំ។ ស្រេចនឹងខ្ញុំ!

បក្សពួកម៉ឺនចៃចុងវ៉ាក់ : ប្រាប់ពួកយើងទាំងអស់គ្នាអូសបណ្តោយចុងវិញ។

នាយទិន : អាតយអើយ! អើយអាតយ!

នាយតយ : បាទ! លោកម្ចាស់អានេះគ្នាឯងសោះរ៉ឺ!

នាយទិន : យី! អានេះគ្រាន់តែឆ្លើយក៏ឃ្លេរដែរ មកជិតអញមើល អញមានមតិបន្តិច អញឆ្ងល់! អញឆ្ងល់!

នាយតយ : ឆ្ងល់យ៉ាងម៉េច!

នាយទិន : ហេតុអីលោកមេទ័ពឱ្យអូសឫស្សីបញ្ចាសចុង? (រួចចង្អុលទៅម៉ឺនចៃចុងវ៉ាក់)តែឯងមើលពួកទាំងនោះ ឯងឃើញទេ?

នាយតយ : អញក៏ឆ្ងល់ដែរ អាសម្លាញ់អាប់ ក៏ប៉ុន្តែអញមានការសន្និដ្ឋានមួយណា៎!

នាយទិន : ឯងសន្និដ្ឋានយ៉ាងម៉េច?

នាយតយ : អញសន្និដ្ឋានថា លោកឧកញ៉ាតេជោយ៉តនោះជាមនុស្សអផ្សុក បានជាគាត់បង្កើតរឿងចម្លែកយ៉ាងនេះណា៎។

នាយទិន : ន៎ែ! អាតយរួចគាត់អផ្សុកយ៉ាងម៉េច!

នាយតយ : ឯងសាកគិតមើល សេចក្តីអផ្សុកនោះវាគ្មានលំនឹងទេ ប្រៀបដូចរាត្រីខែកត្តិកវារងាហើយយើងដេកដណ្តប់ក្រមាវាខ្លី បើទាញក្រមាមកគ្របក្បាលវារងាចុងជើង បើទាញក្រមាមកគ្របចុងជើងវារងាក្បាល ។

នាយទិន : អញដូចមិនយល់ទេ ថាវាយ៉ាងម៉េច!

នាយតយ : ឥឡូវអញលើកឧទាហរណ៍ពាក់កណ្តាលជាក់ស្តែងមួយ ។ និយាយពីមនុស្សខ្លះបើមានសង្គ្រាមរោលរាលខ្លាំង គេនាំគ្នាស្វែងរកសន្តិភាពតាមវិធីផ្សេងៗ ។ ប៉ុន្តែពួកមនុស្សលោភលន់មានសម្បត្តិច្រើនពេក បែរជាអផ្សុកនាំគ្នាបង្កសង្គ្រាមទៅវិញ ។

នាយទិន : អាតយ! អញស្តាប់ឯងនិយាយយូរៗទៅវាឈឺបត់ជើង ។ អញមិនចង់ដឹងអីវែងឆ្ងាយអីចឹងទេ ។ អញគ្រាន់តែចង់ដឹងពីផែនការរបស់លោកតេជោប៉ុណ្ណោះ ។

នាយតយ : អញប្រាប់លោកតេជោយ៉ាតហ្នឹងគាត់អផ្សុក ។ តែការអផ្សុកខ្លះ រកឃើញនូវការរីកចម្រើន ។ ម្នាលមិត្តភក្តិកុំនិយាយពីលោកអផ្សុក ។ កុំចង់ដឹងអី បើគាត់ឱ្យធ្វើយ៉ាងម៉េចយើងធ្វើតាមគាត់ទៅ! ព្រោះកងទ័ពដ៏ខ្លាំងក្លាគឺជាកងទ័ពដែលចេះគោរពតាមបទបញ្ជាត្រឹមត្រូវ ។

នាយទិន : បទបញ្ជាអូសឫស្សីបញ្ច្រាសចុងហ្នឹងឬ ?

នាយតយ : យី! អានេះចេះតមាត់ទៀ! យុទ្ធវិធីសង្គ្រាមមានច្រើនណាស់ ។ ឯងមិនទាន់រៀនក្បួនតម្រាពិជ័យសង្គ្រាមទេ ។ ដូច្នេះ ឯងត្រូវទុកចិត្តលើលោកមេទ័ពទៅចុះ ព្រោះគាត់ធ្លាប់មានបទពិសោធន៍ក្នុងការធ្វើសង្គ្រាម ។

នាយទិន : ន៎ែ! អាតយឯងឃើញម៉ឺនចៃចុងវ៉ាក់អូសឫស្សីបណ្តោយចុង!

នាយតយ : ម៉េចឯងចង់អូសអីចឹងដែរឬអី ?

នាយទិន : អាតយ! អាតយ! ឯងមើលតេជោយ៉ាតនិងឧកញ៉ាព្រហ្មស្រីមកដល់ហើយ!

ឧកញ៉ាព្រហ្មស្រី : ម៉ឺនចៃចុងវ៉ាក់! ហេតុអីពួកលោកអូសឫស្សីបណ្តោយចុងវិញ ?

ម៉ឺនចៃចុងវ៉ាក់ : ន៎ែ! តាំងពីដូចតាមកគ្មានអ្នកណាអូសឫស្សីបញ្ច្រាសចុងទេ!

តេជោយ៉ាត : ក្នុងពេលធ្វើសឹកសង្គ្រាមបញ្ជាមេទ័ពរឹងដូចភ្នំមិនអាចឱ្យអ្នកណាប្រឆាំងបានទេ!

ម៉ឺនចៃចុងវ៉ាក់ : ន៎ែ!តេជោយ៉ាត ពួកយើងជាកូនឧកញ៉ាមន្ត្រី!

តេជោយ៉ាត : ខ្ញុំធ្លាប់ទទួលពាក្យមើលងាយថាជាជនជាតិភាគតិចអស់រយៈពេលជាងម្ភៃឆ្នាំមកហើយ ។ តាំងពីខ្ញុំធំទើបតែពេលនេះខ្ញុំតាំងចិត្តលែងខឹង ឱ្យសង្គមយល់ដឹងខ្លួនឯងតាមពេលវេលា ប៉ុន្តែអំពើរបស់ម៉ឺនចៃចុងវ៉ាក់នៅពេលនេះមិនមែនរឿងសង្គ្រាមវណ្ណៈទេ គឺពួកលោកជាសត្រូវក្រោយខ្នងរបស់ប្រទេសជាតិដែលខ្ញុំកំពុងរកមុខ ។

ម៉ឺនចៃចុងវ៉ាក់ : តេជោយ៉ាត ខ្ញុំជាប្អូនប្រុសបង្កើតរបស់អ្នកម្នាងនួណា៎!

តេជោយ៉ាត : ខ្ញុំដឹងហើយលោកជាប្អូនអ្នកម្នាងនួ ។ លោកឧកញ៉ាព្រហ្មស្រីរាប់ចាប់ម៉ឺនចៃចុងវ៉ាក់!

ឧកញ៉ាព្រហ្មស្រី : បាទ! លោកតេជោ!

តេជោយ៉ាត : យើងសម្លាប់មនុស្សម្នាក់ដើម្បីច្បាំងឈ្នះសត្រូវយកសេចក្តីសុខជូនប្រជាជនក្នុងនគរ ។

(ម៉ឺនចៃចុងវ៉ាក់ត្រូវសម្លាប់ចោលនាពេលនោះទៅ)

(ដកស្រង់ដោយកត់ត្រាចេញពីល្ខោនបាសាក់សម្តែងតាមទិដ្ឋ តេជោយ៉ាត របស់លោក ទី ជីហួត)

- គ្រូសួរសំណួរទាក់ទងនឹងខ្លឹមសារលម្អិតរបស់អត្ថបទ ៖

- តើម៉ឺនចៃចុងរ៉ាក់រស់នៅឯណា ? មានស្ថានភាពគ្រួសារដូចម្តេច ?

ចម្លើយ : រស់នៅក្នុងខេត្តលង្វែក ជាគ្រួសារអ្នកមានមុខមាត់

- តើម៉ឺនចៃចុងរ៉ាក់ខ្វល់ខ្វាយរឿងអ្វី ?

ចម្លើយ : ខ្វល់ខ្វាយរឿងដែលខ្លួនជាប់កំណែនពលចូលធ្វើកងទ័ព

- តើបក្សពួកម៉ឺនចៃចុងរ៉ាក់បានធ្វើដូចម្តេចខ្លះ កាលពីលោកឧកញ៉ាក្រឡាហោម និងលោកឧកញ៉ាចក្រីមកកេណ្ឌពល ?

ចម្លើយ : នាំគ្នារត់ត្រឡប់មកផ្ទះវិញ

- តើបងរបស់ម៉ឺនចៃចុងរ៉ាក់បានផ្តាំដូចម្តេច ?

ចម្លើយ : ផ្តាំថាអាជ្ញាសឹកយើងមិនអាចប្រឆាំងបានទេ ប៉ុន្តែបើមានឱកាសល្អយើងរត់ទៅដល់ព្រះរាជធានី គាត់នឹងជួយការពារ ។

- តើតេជោយ៉ាតកេណ្ឌទ័ពនៅឯណា ? កេណ្ឌបានប៉ុន្មាននាក់ ?

ចម្លើយ : នៅលង្វែកទាំងត្រើយខាងលិច និងត្រើយខាងកើតនិងនៅកំពង់ស្វាយ ។ នៅលង្វែក កេណ្ឌបានចំនួនមួយពាន់នាក់នៅកំពង់ស្វាយមួយពាន់ប្រាំមួយរយនាក់ ។

- តើស្បៀងរបស់កងទ័ពមានលក្ខណៈដូចម្តេច ?

ចម្លើយ : អាចផ្គត់ផ្គង់ទ័ពបានបួនខែ ។

- តើតេជោយ៉ាតប្រើនាយទិននិងនាយតយឱ្យធ្វើអ្វី ?

ចម្លើយ : ស៊ើបការណ៍

- តើនាយទិននិងនាយតយរាយការណ៍ដូចម្តេចខ្លះ ?

ចម្លើយ : រាយការណ៍ថា ស្បៀងអាហាររបស់ពួកទ័ពសៀមពុំធានាបានយូរខែទេ ហើយទាហានរបស់ពួកគេកំពុងតែក្លាហានណាស់ ព្រោះគេទើបតែឈ្នះទ័ពឧកញ៉ាចក្រីនិងឧកញ៉ាក្រឡាហោមថ្មីៗនេះ ។

- ហេតុអ្វីបានជា លោកឧកញ៉ាព្រហ្មស្រី! ឧកញ៉ាចក្រី និងឧកញ៉ាក្រឡាហោមច្បាំងចាញ់ទ័ពសៀម ?

ចម្លើយ : ព្រោះមានសត្រូវក្រោយខ្នង ។

- តើតេជោយ៉ាតប្រើវិធីអ្វី ដើម្បីកម្ចាត់សត្រូវក្រោយខ្នង ?

ចម្លើយ : អូសបស្ស៊ីបញ្ជ្រាសចុង ។

- តើអ្នកណាជាសត្រូវក្រោយខ្នង ?

ចម្លើយ : ម៉ឺនចៃចុងរ៉ាក់ ។

- តើតេជោយ៉ាតកាត់ទោសម៉ឺនចៃចុងរ៉ាក់ដូចម្តេច ?

ចម្លើយ : ប្រហារជីវិត ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សធ្វើសង្ខេបរឿងឡើងវិញ
- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រ ៩៥ ។

ចម្លើយ :

១. តួអង្គតេជោយ៉ាត ៖

- តួនាទី : ជាមេទ័ពមានងារជាតេជោ

- សកម្មភាព : កេណ្ឌទ័ព , កាត់ទោសប្រហារជីវិតសត្រូវក្រោយខ្នង(ម៊ឺនចៃចុងរ៉ាក់) , ដឹកនាំទ័ពកម្ចាត់ពួកសៀមបះបោរ ។

២. តួអង្គម៊ឺនចៃចុងរ៉ាក់ ៖

- តួនាទី : ពលសេនាជាប់កំណែនទ័ព ជាប្អូនអ្នកម្នាងនួ ត្រូវជាប្អូនថ្លៃស្តេច
- សកម្មភាព : បបួលបក្សពួករត់ចោលជួរទ័ព , ធ្វើកងទ័ពរបស់តេជោយ៉ត , ប្រឆាំងនឹងបញ្ជាតេជោយ៉ត , ត្រូវតេជោយ៉តប្រហារជីវិត

៣. បានជាតេជោយ៉តសម្លាប់ម៊ឺនចៃចុងរ៉ាក់ព្រោះតេជោយ៉តចាត់ទុកជាសត្រូវក្រោយខ្នង ។

៤. តួអង្គក្នុងរឿងតេជោយ៉ត ៖

- រឿងតេជោយ៉ត មានតួអង្គចំនួន ១១នាក់គឺ តេជោមាស តេជោយ៉ត ជំទាវស្រែន ព្រះចៅជ័យចេស្តា អ្នកម្នាងនួ ស្តេចសំរែ ឧកញ៉ាពិភា ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ នាងម៉ៃ នាយឈិត ម៊ឺនចៃចុងរ៉ាក់ និងតួអង្គរំឭកជាច្រើនទៀត ។
- តេជោយ៉ត ជាតួអង្គឯក រីឯតេជោមាស ជំទាវស្រែន ស្តេចសំរែ និងតួអង្គដទៃទៀតជាតួអង្គរង ។
- តួនាទីរបស់តួអង្គនីមួយ ៗ ៖
  + តេជោមាស : ជាស្វាមីជំទាវស្រែន មានងារជាតេជោបរមរាជត្រួតខេត្តកំពង់ស្វាយ ។
  + ជំទាវស្រែន : ជាភរិយារបស់តេជោមាស ជាស្ត្រីដែលមានល្បិចឆ្មើមអាចចាប់ស្តេចសំរែក្បត់ជាតិយកទៅកាត់ទោស ។
  + ព្រះចៅជ័យចេស្តា : មហាក្សត្រខ្មែរគង់នៅក្រុងឧដុង្គមានជ័យ ។
  + អ្នកម្នាងនួ : បងស្រីម៊ឺនចៃចុងរ៉ាក់និងជាអ្នកម្នាងរបស់ព្រះចៅជ័យចេស្តា ។
  + ស្តេចសំរែ : មេបះបោរបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា ។
  + ឧកញ៉ាពិភា : មន្ត្រីជំនិតរបស់ស្តេចសំរែ ។
  + ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ : បម្រើការងារជាមួយតេជោមាសនិងតេជោយ៉ត ។
  + នាងម៉ៃ : បុត្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ និងជាអ្នកស្រឡាញ់តេជោយ៉ត តែមិនបានសម្រេចក្លាយទៅជាប្អូនធម៌របស់តេជោយ៉តទៅវិញ ។
  + នាយឈិត : ឈ្លើយសឹកសៀមនិងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ ។
  + ម៊ឺនចៃចុងរ៉ាក់ : ប្អូនអ្នកម្នាងនួប្រឆាំងតេជោយ៉ត ហើយត្រូវតេជោយ៉តចាប់ទៅសម្លាប់ចោលនិងមានតួអង្គរំឭកជាច្រើនទៀត ។

៥. តួអង្គតេជោយ៉ត : មានឧត្តមគតិស្នេហាជាតិជ្រាលជ្រៅ , ជាមេទ័ពដ៏អង់អាចក្លាហាន , ជាមេទ័ពចេះកលយុទ្ធយ៉ាងស្ទាត់ជំនាញ , យើងយល់ថាទង្វើរបស់តេជោយ៉ត ជាវីរសកម្មភាពដ៏កម្រកបាន ។

- ប្រទេសកម្ពុជាបច្ចុប្បន្នកំពុងត្រូវការមេទ័ពដ៏ខ្លាំងពូកែដូចតេជោយ៉ត ដើម្បីកម្ចាត់ពួកឈ្លានពាន

៦. អត្ថបទដកស្រង់នេះមានមួយឆាក ។

៧. កាលអាកាសនៃរឿង ៖

- កាល (ពេលវេលា) : រឿងរ៉ាវទាំងអស់ប្រព្រឹត្តទៅក្នុងរជ្ជកាលព្រះបាទជ័យចេស្តា (គ.ស. ១៥៧៥-១៥៩៣)
- អាកាស (ទីកន្លែង) : រាជធានីឧដុង្គ ខេត្តកំពង់ស្វាយ(ស្ទឹងព្រៃប្រស់) ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង (កំពង់ហៅលង្វែក)

ការតែងរឿងល្ខោនខ្លី

១. វត្ថុបំណង

- ប្រាប់បញ្ញត្តិនៃរឿងល្ខោនបានត្រឹមត្រូវ
- ប្រាប់ទម្រង់សំណេរនៃរឿងល្ខោនបានត្រឹមត្រូវ
- ព្រាងរឿងល្ខោនបានត្រឹមត្រូវ
- រៀបរៀងនិងកែលម្អរឿងល្ខោនបានត្រឹមត្រូវ
- សរសេរសម្រេចរឿងល្ខោនបានត្រឹមត្រូវ
- បណ្តុះស្មារតីស្រឡាញ់ អភិរក្ស និងអភិវឌ្ឍរឿងល្ខោន ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៩៦
- អត្ថបទល្ខោនរឿង "តេជោយ៉ត"ដែលនិពន្ធនៅឆ្នាំ ១៩៨៣ ដោយលោក ទី ជីហួត
- អត្ថបទរឿង "ចៅកែចិត្តចោរ"ដែលនិពន្ធនៅឆ្នាំ ១៩៥៦ ដោយលោក ពៅ ឃួឡេង និងលោក អ៊ុំ ឈឺន ។

៣. ព័ត៌មានជំនួយ

ដើម្បីជាជំនួយដល់សិស្សក្នុងការតាក់តែងរឿងល្ខោនខ្លី សូមលោក/អ្នកគ្រូ ៖

- រកអត្ថបទល្ខោនរឿង "តេជោយ៉ត"ដែលនិពន្ធនៅឆ្នាំ ១៩៨៣ ដោយលោក ទី ជីហួត ដើម្បីប្រើប្រាស់ជាជំនួយដល់ការតាក់តែងរឿងល្ខោនខ្លី
- អត្ថបទរឿង "ចៅកែចិត្តចោរ"ដែលនិពន្ធនៅឆ្នាំ ១៩៥៦ ដោយលោក ពៅ ឃួឡេង និងលោក អ៊ុំ ឈឿន ដើម្បីប្រើប្រាស់ជាជំនួយដល់ការតាក់តែងរឿងល្ខោនខ្លី

៤. ណែនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀនក្នុងសៀវភៅសិស្សទំព័រទី ៩៦ "ការតែងរឿងល្ខោនខ្លី"ដាក់លើក្តារខៀន រួចសួរសំណួរ ៖
  - តើអ្នកធ្លាប់ស្តាប់ អាន ឬទស្សនាល្ខោនអ្វីខ្លះ ?
    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ចូរប្រាប់ឈ្មោះរឿងល្ខោនដែលអ្នកធ្លាប់ស្តាប់ អាន ឬទស្សនា ។
    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ដូចម្តេចដែលហៅថាល្ខោន ?
    ចម្លើយ : អាស្រ័យលើសិស្ស ។

- គ្រូឱ្យសិស្សអានសេចក្តីបកស្រាយអំពីល្ខោនក្នុងសៀវភៅសិស្សទំព័រទី ៩៦ផ្នែកខាងលើ រួចសួរ ៖
  - តើខ្មែរយើងមានប្រភេទល្ខោនអ្វីខ្លះ ?

    ចម្លើយ : ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល "ស្បែកតូច" ។
  - ដូចម្តេចដែលហៅថា អត្ថបទល្ខោន ?

    ចម្លើយ : អត្ថបទល្ខោន គឺជាអត្ថបទអក្សរសិល្ប៍មួយប្រភេទដែលអ្នកនិពន្ធចងក្រងឡើងសម្រាប់យកទៅសម្តែងជាសិល្បៈល្ខោន ។
  - តើអត្ថបទល្ខោន មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងអត្ថបទរឿងធម្មតាលើចំណុចណាខ្លះ ?

    ចម្លើយ : អត្ថបទល្ខោនស្រដៀងគ្នានឹងអត្ថបទរឿងធម្មតាចំពោះធាតុសំខាន់ៗដូចជា ចំណោទបញ្ហា តួអង្គ កាល អាកាស និងមូលន័យ ។
  - តើអត្ថបទល្ខោនមានទម្រង់សំណេរខុសពីរឿងធម្មតាដូចម្តេចខ្លះ ?

    ចម្លើយ : ទម្រង់សំណេរអត្ថបទរឿងល្ខោន ៖
  - អត្ថបទរឿងល្ខោនចែកជាឈុតនិងឆាក
  - នៅខាងដើមអត្ថបទរឿងល្ខោននីមួយៗ មានបញ្ជីរាយនាមតួអង្គ និងឋាន: ឬប្រភពកំណើតរបស់តួអង្គ
  - អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយ បង្ហាញពីពំនោល ឬបទសន្ទនារវាងតួអង្គនិងតួអង្គ
  - អត្ថបទល្ខោននិយាយអ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក ។

២. ការអនុវត្ត

- គ្រូឱ្យសិស្សអានលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ៩៦
- គ្រូសួរសំណួរឱ្យសិស្សឆ្លើយ ៖
  - តើលំហាត់នេះ តម្រូវឱ្យយើងធ្វើដូចម្តេច ?

    ចម្លើយ : តម្រូវឱ្យយើងធ្វើការជាក្រុមពិភាក្សាពីការតែងរឿងល្ខោននិយាយ ឬល្ខោនបាសាក់ ឬយីកេខ្លីមួយរឿងទាក់ទងនឹងប្រធានបទ ៖

    + សេចក្តីក្លាហាន
    + ការហ៊ានលះបង់ របស់តួអង្គក្នុងបុព្វហេតុណាមួយ (គ្រួសារ សហគមន៍ ...)
  - តើក្នុងការសរសេរគេត្រូវផ្តោតទៅលើចំណុចអ្វីខ្លះ ?

    ចម្លើយ :

    + ការរាយឈ្មោះតួអង្គនិងតួនាទីមុខងារនៅខាងដើមរឿង
    + ការរៀបចំសាច់រឿងជាឈុតឆាក
    + រៀបចំសំណេរជាអត្ថបទសន្ទនារវាងតួអង្គនិងតួអង្គ
    + បញ្ជាក់ពីសកម្មភាព កាយវិការ ទឹកមុខ សំឡេងតួអង្គ (ដោយសរសេរក្នុងវង់ក្រចក) ។

- ការធ្វើគម្រោងអត្ថបទ ៖
  - ការព្រាង : គ្រូចែកសិស្សជាក្រុម ឱ្យក្រុមនីមួយៗសរសេរព្រាងគម្រោងរឿងល្ខោនខ្លីមួយទាក់ទងនឹងប្រធានបទខាងលើ ។
  - ការកែលម្អ :
    + គ្រូឱ្យក្រុមនីមួយៗប្តូរកិច្ចការគ្នាដើម្បីធ្វើការកែលម្អ ។ ក្នុងការកែលម្អ បើពិនិត្យឃើញថា កិច្ចការក្រុមដទៃមានកំហុស ឬមានចំណុចខ្វះខាតត្រូវមកពិភាក្សារកចំណុចឯកភាពគ្នាជាមួយក្រុមដើមជាមុនសិនមុននឹងធ្វើការកែលម្អ
    + គ្រូឱ្យក្រុមនីមួយៗប្រគល់កិច្ចការឱ្យម្ចាស់ដើមវិញ ។
  - ការសរសេរសម្រេច : គ្រូឱ្យក្រុមនីមួយៗកែលម្អគម្រោងឱ្យបានត្រឹមត្រូវ ។

គ. ការវាយតម្លៃ

- គ្រូចែកសិស្សជាក្រុម រួចឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូណែនាំឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ៩៦ ដោយប្រើគម្រោងខាងលើ
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាតែងរឿងល្ខោនខ្លី
- បន្ទាប់ពីធ្វើកិច្ចការចប់ គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូនិងសិស្សធ្វើការបូកសរុបនិងកែលម្អ ។



អតីតកាល

អតីតកាល ជាកាលវេលាកន្លងហួសមកហើយ។ អតីតកាលមិនអាចត្រឡប់ថយក្រោយបានវិញទេ។ ប៉ុន្តែ អតីតកាលបានបន្សល់ទុកនូវបទពិសោធន៍មេរៀនជីវិតជាច្រើនដល់អ្នកជំនាន់ក្រោយសម្រាប់ធ្វើការឆ្លុះបញ្ចាំង សិក្សាស្រាវជ្រាវ និងពិចារណាដើម្បីជាមធ្យោបាយដោះស្រាយបញ្ហាឬកែលម្អរឿងរ៉ាវ បទពិសោធន៍មិនល្អមួយចំនួនឱ្យមានភាពល្អប្រសើរឡើង ដោយមានការរៀបចំអភិវឌ្ឍទស្សនៈ ផ្តត់គំនិត បញ្ញាស្មារតី ឱ្យទទួលបានជោគជ័យទាំងក្នុងបច្ចុប្បន្ន ក៏ដូចទៅអនាគត។

ក្នុងមេរៀននេះសិស្សនឹងសិក្សាអំពីអតីតកាលនៃសង្គមខ្មែរ តាមរយៈការសិក្សាអត្ថបទកាព្យដកស្រង់រឿងទុំទាវ ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទំនុកច្រៀង និងរបាំប្រពៃណីជាតិ ព្រមទាំងបណ្តុះស្មារតីស្នេហាជាតិដល់សិស្សថែមទៀតផង។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិឡាសាស្ត្រ	ទិឡាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	៩៧	៩៧
• បំណិន : វិធីផ្ទួនពាក្យនិងវិធីរណ្តំ	២ម៉ោង	២ម៉ោង	៩៨-៩៩	៩៨
• អំណានទី ១ : ដកស្រង់រឿងទុំទាវ	០ម៉ោង	៤ម៉ោង	១០០-១០៣	១០១
• វេយ្យាករណ៍ : សញ្ញាស្រៈ(ស្រៈនិស្ស័យ ស្រៈពេញតួ)	២ម៉ោង	២ម៉ោង	១០៤-១០៥	១០៧
• បំណិន : បដិវិធី	២ម៉ោង	២ម៉ោង	១០៦-១០៨	១១០
• អំណានទី ២ : ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ	៣ម៉ោង	៤ម៉ោង	១០៩-១១២	១១៤
• ការស្តាប់ : ទំនុកច្រៀងនិងរបាំស្នែងទន្សោង	១ម៉ោង	២ម៉ោង	១១៣-១១៨	១២០
• ការនិយាយ : សង្ខេបអត្ថបទកាព្យជាពាក្យរាយ	១ម៉ោង	២ម៉ោង	១១៩-១២០	១២១
• សំណេរ : អត្ថាធិប្បាយ បែបពន្យល់	២ម៉ោង	៣ម៉ោង	១២១-១២២	១២៥

១. សិក្សាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៩៧ គ្រូសរសេរចំណងជើងមេរៀន"អតីតកាល"ដាក់លើក្តារខៀនរួចសួរ ៖
  - តើចំណងជើងមេរៀននេះឈ្មោះអ្វី ? មានន័យដូចម្តេច ?

  ចម្លើយ : មានចំណងជើងថា "អតីតកាល"។ អតីតកាលមានន័យថា ជាកាលឬពេលវេលាដែលកន្លងផុតទៅហើយ។

២. សិក្សាលើរូបភាព

- គ្រូឱ្យសិស្សសង្កេតរូបភាពនៃមេរៀន រួចសួរ ៖
  - តើរូបភាពក្នុងមេរៀននេះជារូបភាពអ្វី ?

    ចម្លើយ : រូបភាពក្នុងមេរៀននេះ ជារូបភាពគ្រែស្នែង ដែលគេសែងដង្ហែមនុស្សចាស់កាលពីសម័យដើមក្នុងពិធីមួយ។
  - តើមនុស្សទាំងអស់នៅក្នុងរូបភាពនេះកំពុងធ្វើអ្វី ?

    ចម្លើយ : មានមនុស្សប្រុសចំណាស់ម្នាក់កំពុងអង្គុយនៅលើគ្រែស្នែង ហើយមានអ្នកសែងខាងក្រោយពីរនាក់និងមនុស្សស្រីប្រុសជាច្រើននាក់ទៀតកំពុងដើរអមដង្ហែតាមក្រោយ។

វិធីផ្ដួនពាក្យនិងវិធីរណ្ដំ

១. វត្ថុបំណង

- ប្រាប់បានពីវិធីផ្ដួនពាក្យនិងវិធីរណ្ដំ តាមរយៈឧទាហរណ៍គំរូ
- បង្ហាញបានពីវិធីផ្ដួនពាក្យនិងវិធីរណ្ដំព្យញ្ជនៈនិងស្រៈ តាមរយៈការហ្វឹកហាត់ធ្វើលំហាត់
- បណ្ដុះស្មារតីស្រឡាញ់ចូលចិត្តការសិក្សាកំណាព្យខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ៩៨-១០០
- សិល្បៈតែងកំណាព្យរបស់លោក ពេជ្រ ទុំក្រវិល ឆ្នាំ ១៩៨៨
- កំណាព្យខ្មែរភាគ ២ ក្រសួងអប់រំ របស់លោក ស កាពុន ឆ្នាំ ១៩៨៤
- ចិត្តក្រមុំ របស់លោក កេង វ៉ាន់សាក់ ទំព័រទី ៦ ។

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងបំណិន "វិធីផ្ដួនពាក្យនិងវិធីរណ្ដំ"ដាក់លើក្ដារខៀន រួចឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ៩៨-១០០ អានសេចក្ដីផ្ដើមបំណិន និងខ្លឹមសារបំណិន "វិធីផ្ដួនពាក្យ" និង "វិធីរណ្ដំ" (រណ្ដំព្យញ្ជនៈ រណ្ដំស្រៈ) ក្នុងចំណុចទី ១ ទី ២ និងក្បួនចងចាំ ។
- គ្រូសួរសំណួរ ៖
  - ដូចម្ដេចហៅថា វិធីផ្ដួនពាក្យ ?

    ចម្លើយ : វិធីផ្ដួនពាក្យ គឺជាវិធីដែលកវីតាក់តែងដោយប្រើពាក្យ(ព្យាង្គ) តែមួយដងក្នុងឃ្លាឬវគ្គ ដើម្បីបង្ហាញនិងសង្កត់ន័យ ព្រមទាំងបង្កើតសញ្ចេតនានិងរូបារម្មណ៍នៅក្នុងអត្ថបទកាព្យរបស់ខ្លួន ។
  - ដូចម្ដេចហៅថា វិធីរណ្ដំ ?

    ចម្លើយ : គឺជាវិធីដែលកវីប្រើព្យញ្ជនៈដដែលៗឬស្រៈដដែលៗក្នុងឃ្លាឬវគ្គ ដើម្បីបង្កើតសំឡេងពីរោះនិងបង្កើតរូបារម្មណ៍មួយ គឺសោតរូបារម្មណ៍ ។

ខ. ការហ្វឹកហាត់

- ឱ្យសិស្សសូត្រអត្ថបទកាព្យដកស្រង់ខាងក្រោមក្នុងសៀវភៅសិស្សទំព័រទី ៩៨ ក្នុងឧទាហរណ៍ទី ១ និងអត្ថបទកាព្យដកស្រង់ក្នុងសៀវភៅសិស្សទំព័រទី ៩៩ ក្នុងចំណុច(ក) វិធីរណ្ដំព្យញ្ជនៈ និងចំណុច(ខ) វិធីរណ្ដំស្រៈ ឡើងវិញ ៖

ឧទាហរណ៍ :

ខ្លួនខ្ញុំខំហាត់ ខំលះខំកាត់ ខំពត់លត់ដំ
ខំជំនះចិត្ត ខំឥតបន្ទំ ខំអើយសែនខំ
សាងខ្លួនជានិច្ច ។

(កំណាព្យខ្មែរភាគ ២ ក្រសួងអប់រំ ១៩៨៤)

ស្រីស្រីស្រុកស្រែស្រុះស្រស់ស្រាយ　　កកេះកកាយកាន់កិច្ចការ
តូចៗតាក់តែងតាមតាតា　　បូតបេះបោចបារបានបែនបុក ។

(សិល្បៈតែងកំណាព្យ ពេជ្រទុំ ក្រវិល ១៩៨៨)

ស្តាយសាច់ស្រអែមកែមសម្តី　　ទ្រលន់ទន់ខ្ចីទាំងមំសា
ទ្រលុកម្ល៉េះសមទុក្ខខ្លោចផ្សា　　អនិច្ចាមិនគួរឃ្លាតគ្នាបាន ។
ស្តាយសាច់ទ្រលន់ទន់ត្រជាក់　　ស្តាយភក្ត្រផូរផង់បុប្ផាផាន
ស្តាយសៀងសំនៀងយ៉ុតយោរមានៀ　　ប្រៀបបាននឹងសៀងសត្វកង្រុក ។

(សិល្បៈតែងកំណាព្យ ពេជ្រ ទុំក្រវិល)

- ឱ្យសិស្សធ្វើលំហាត់ទី ១,២ ក្នុងសៀវភៅសិស្សទំព័រទី ៩៩ និង ១០០ ។

ចម្លើយ :

១. កវីបានប្រើវិធីផ្ទួនពាក្យ "ត្រី" ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីការពណ៌នា រៀបរាប់អំពីត្រីដែលច្រើនសម្បូរហូរហៀរឥតខ្វះ ផ្សារភ្ជាប់នឹងខ្លឹមសារអត្ថបទកាព្យទាំងមូលបង្កើតបានទូវភាពពីរោះ ណែងណងក្នុងរូបារម្មណ៍យើងគ្រប់គ្នា ដោយគ្រាន់តែប្រើពាក្យត្រីដដែលៗ ។

២. កវីបានប្រើវិធីរណ្តំព្យញ្ជនៈនិងស្រៈដដែលៗក្នុងឃ្លាឬវគ្គនៃអត្ថបទកាព្យ ដើម្បីបង្កើតភាពពីរោះរណ្តំណែងណងក្នុងរូបារម្មណ៍ តាមរយៈសោតរូបារម្មណ៍ដែលគួរឱ្យជក់ចិត្ត ជិតអារម្មណ៍ ចង់ស្តាប់ក្រៃលែងដូចជា ៖

+ វគ្គទី ១ : រណ្តំក្នុងវគ្គ ដោយកវីប្រើវិធីរណ្តំព្យញ្ជនៈ "ល ដ ត្រ ឌ្ឍ និង រ" (លីលាលយ ជានដង ត្រូវត្រង់ ខ្ជួលខ្ចាញ់ រួតរះ)
+ វគ្គទី ២ : កវីប្រើវិធីរណ្តំព្យញ្ជនៈ "ក្រ(ក្រឡេកក្រលៀង) ស្រៈ ◌ៀ និងស្រៈ ◌ៀ (លៀង ឆៀង)"
+ វគ្គទី ៣ : កវីប្រើវិធីរណ្តំព្យញ្ជនៈ ប៉(ប៉ុនប៉ង) ប(បំណងបំណាច់)
+ វគ្គទី ៤ : កវីប្រើវិធីរណ្តំព្យញ្ជនៈ រ(រ៉ាប់រ៉ាយ) ច(ចែកចាយ) ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សបង្ហាញពីវិធីផ្ទួនពាក្យ និងវិធីរណ្តំ(ព្យញ្ជនៈនិងស្រៈ)ក្នុងលំហាត់ ៖

អ្នកមានមានឡាន　　សប្បាយគ្មានស្រាន្ត　　មានវិមានស្តុក
ក្រគ្មានស្បែកជើង　　ការស្តើងតត្រុក　　រស់គ្មានស្រណុក
　　ក្នុងខ្មួមសោកា ។

ចម្លើយ : កវីបានបង្ហាញពីវិធីផ្ទួនពាក្យក្នុងអត្ថបទកាព្យដកស្រង់ខាងលើត្រង់វគ្គទី ១ ឃ្លាទី ១ ដែលប្រើព្យាង្គដដែលៗ "មានមាន" ។ រណ្តំស្រៈនិងស្រៈ គឺ ឡាន ស្រាន្ត វិមាន គឺស្រៈ ◌ា និង ន ដូចគ្នា ។



រឿងទុំទាវ

១. វត្ថុបំណង

- ប្រាប់បានពីប្រភព ប្រភេទអត្ថបទកាព្យដកស្រង់រឿងទុំទាវ
- កំណត់បានពីវិធីបង្កើតរូបារម្មណ៍កំណាព្យតាមរយៈវិធីផ្ទួនពាក្យ វិធីរណ្តំ ព្រមទាំងខ្លឹមសារអត្ថបទ តាមរយៈការឆ្លើយសំណួរ
- អភិវឌ្ឍស្មារតីសិស្សឱ្យចេះពិចារណាទៅលើបញ្ហាប្រពៃណី ជំនឿ សាសនា និងទំនៀមទម្លាប់រស់នៅរបស់សង្គមខ្មែរនាសម័យលង្វែក ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១០១-១០៦
- សៀវភៅរឿងទុំទាវ ទំព័រទី ៥-៩ របស់ភិក្ខុ សោម ឆ្នាំ ១៩១៥ ។

៣. ព័ត៌មានដំឆ្ងួយ

ក្នុងមេរៀននេះ សិស្សនឹងសិក្សាអត្ថបទដកស្រង់រឿទុំទាវរបស់ភិក្ខុសោម និពន្ធឆ្នាំ ១៩១៥ ។ លោកគ្រូអ្នកគ្រូ គប្បីមានសៀវភៅរឿងនេះនៅនឹងដៃ ហើយសង្ខេបអត្ថបទដកស្រង់នេះជាពាក្យសម្រាយ ដើម្បីបង្ហាញសិស្ស ដែលទាក់ទងនឹងការបង្ហាញខ្លឹមសារ(ដកស្រង់) ក្នុងសំណួរ ជាជំនួយដល់ការបង្រៀនសិស្សជាចាំបាច់ ។ សូមលោកគ្រូអ្នកគ្រូកែលម្អកំហុសពាក្យនៅក្នុងអត្ថបទកាព្យត្រង់វគ្គទី ៤៣ ឃ្លាទី ៣ ព្យាង្គទី ៧ "សោះ" មកជា "នោះ" ក្នុងសៀវភៅសិស្សទំព័រទី ១០៦ ។

៤. លំនាំបង្រៀន

ក. ត្រៀមអំណាន

- លោកគ្រូ-អ្នកគ្រូសរសេរចំណងជើង "អត្ថបទដកស្រង់ រឿងទុំទាវ"ដាក់លើក្តារខៀន រួចសួរ ៖
  - តើអ្នកធ្លាប់ដឹងអ្វីខ្លះ ពីរឿងទុំទាវ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ចូរអ្នកស្មានមើល តើអត្ថបទដកស្រង់នេះនឹងនិយាយពីអ្វី ?

    ចម្លើយ : និយាយពីរឿងទុំទាវ ។
  - ចូរអ្នកស្មានមើល តើអត្ថបទនេះគួរដាក់ចំណងជើងដូចម្តេច ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- លោក/អ្នកគ្រូឱ្យសិស្សសង្កេតរូបភាព ទំព័រទី ១០១ រួចសួរ ៖
  - តើអ្នកបានឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

    ចម្លើយ : ឃើញមានរូបព្រះសង្ឃពីរអង្គ រូបរទេះមានដាក់ភ្នមឆ្នាំង ឬតោក និងរូបស្រីចំណាស់ពីរបីនាក់ កំពុងឈរក្បែរនោះ ។

- តើរូបភាពនេះមានន័យដូចម្តេច ?

ចម្លើយ : រូបភាពនេះចង់បង្ហាញពីន័យដែលព្រះសង្ឃទាំងពីរអង្គ(នេនទុំ-ពេជ្រ) បានធ្វើដំណើរមកដល់(ត្បូងឃ្មុំ) ដើម្បីលក់តោក ហើយមានប្រជាជនមកចោមរោមទិញ ។

- ឱ្យសិស្សសិក្សាពាក្យគន្លឹះ ក្នុងសៀវភៅសិស្សទំព័រទី ១០១-១០២ ។

ខ. អំណាន

- ឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ១០២
- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ១០៦
- ឱ្យសិស្ស ៤-៥នាក់អានបន្តគ្នា ឬបណ្តាក់គ្នានូវអត្ថបទកាព្យដកស្រង់ក្នុងសៀវភៅសិស្សទំព័រទី ១០២-១០៦ ឯសិស្សដទៃទៀតអានដោយស្ងៀមស្ងាត់រៀងៗខ្លួន ។

គ. ពង្រឹងអំណាន

ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១០៦ ៖

ចម្លើយ :

១. អត្ថបទកាព្យដកស្រង់ខាងលើមានប្រភពមកពីរឿងទុំទាវរបស់ភិក្ខុសោម និពន្ធក្នុងឆ្នាំ ១៩១៥ ។ ប្រភេទអត្ថបទដកស្រង់ខាងលើគឺជាប្រភេទប្រលោមលោកពាក្យកាព្យ ។

២. អត្ថបទខាងលើនេះ បានបង្ហាញពីទំនៀមទម្លាប់ខ្មែររស់នៅតាំងពីអតីតកាលសម័យលង្វែក ដែលប្រជាជនយើងនៅសម័យលនោះ កាលបើចិញ្ចឹមបីបាច់កូនប្រុសបានធំពេញវ័យហើយ ម្តាយឪពុកច្រើនយកកូនឱ្យទៅបួសរៀននៅឯវត្ត ដើម្បីរៀនសូត្រចំណេះដឹងផ្លូវលោក ផ្លូវធម៌ បម្រើព្រះពុទ្ធសាសនាផ្ញើខ្លួនប្រាណនិងព្រះសង្ឃឱ្យទូន្មានប្រៀនប្រដៅ ព្រមទាំងរៀន បន្តអាគមគាថា ចេះស្មូត ចេះផ្តុំប៊ី ចេះធ្វើតោក ។ល។ ពីសំណាក់គ្រូអាចារ្យ និងព្រះសង្ឃ និងគោរពប្រណិបតន៍ តាមគន្លងពុទ្ធសាសនាឥតមានឃ្លាតពីធម្មវិន័យ ឬមិនឱ្យខុសនឹងវិន័យព្រះសព្វញ្ញូឡើយ ។

៣. នៅក្នុងអត្ថបទកាព្យដកស្រង់ខាងលើកវីបានប្រើវិធីនិពន្ធបែប "ពណ៌នា" ដែលជាវិធីមួយដែលកវីសរសេររៀបរាប់ពីប្រវត្តិដើមរបស់តួអង្គ "ទុំ ពេជ្រ" ក្នុងការបួសរៀន បម្រើព្រះពុទ្ធសាសនាផងនិងការខិតខំកិច្ចការជំនាញ "ធ្វើតោក" លក់ផង ... ដែលមានលំនាំដូចជារឿងប្រលោមលោកដែរ ។

៤. បង្ហាញវិធីបង្កើតរូបារម្មណ៍ដោយវិធីផ្ទួនរណ្តំក្នុងអត្ថបទកាព្យដកស្រង់រឿងទុំទាវ ៖

ក. វិធីផ្ទួនពាក្យ : កវីបានប្រើវិធីផ្ទួន "មួយៗ" ៖

អកុសលដល់គ្របសង្កត់កាយ ជួបនេនពេជ្ររាយដូចខ្លួនមួយ
ថានេនពេជ្រអើយចូរគាត់ជួយ យើងលក់តោកមួយៗយូរហើយ ។

ខ. វិធីរណ្តំ : កវីប្រើវិធីរណ្តំ ស្រៈនិងព្យញ្ជនៈ "ស្រៈ" ៖

បៀតបែរស្នេហ៍ស្និទ្ធជិតអណ្តូង ជ្រួលច្រូងស្រើបស្រួលទីទួលម្លប់
ឈ្មោះពោធិ៍ជើងខាលត្រកាលគ្រប់ មើលសព្វស្រីប្រុសស្រុះស្រើបស្រាល ។ ...

ឈរទ្រឹងរឹងខ្លួនពួនចាំស្តាប់ ពីរោះហាក់ផ្តាប់មុខដល់ដី
ស្រងាកស្រងោចស្រងែលស្រី នោនឹកបេតីមិនស្តីសោះ ។

៥. លក្ខណសម្បត្តិរបស់ :

- នេនទុំ : នេនទុំគឺជាសាមណេរដែលមានកត្តញ្ញូចំពោះអ្នកមានគុណ ដែលខិតខំចិញ្ចឹមបីបាច់ថែរក្សារហូតដល់ធំពេញវ័យ ហើយចូលបួសរៀនក្នុងវត្តតាមគន្លងព្រះពុទ្ធសាសនា ជាកិច្ចតបស្នង ។ នេនទុំជាសាមណេរដែលមានរូបស្អាត ក្មេង សំឡេងពីរោះ ខិតខំយកចិត្តទុកដាក់រៀនធម៌អាថ៌ និងកិច្ចការធ្វើតោកបានយ៉ាងល្អ ។ លើសពីនេះ នេនទុំថែមទាំងចេះអាគម ស្ទូតយ៉ាងពីរោះធ្វើឱ្យក្មេងចាស់ ប្រុសស្រី ទាំងក្រមុំ មេម៉ាយឈូឆរ មកចោមរោមស្តាប់តាំងពីត្បូងឃ្មុំដល់ពោធិ៍ជើងខាល និងល្ពីដល់ទាវនិងម្តាយនាង ...

កើតឡើងលុះធំល្មមប្រមាណ ឆ្នាំច្រើនសោតបានម្តាយតុបតែង
យកទៅឱ្យរៀនចោលគ្រឿងល្បែង សូរស្ងែរកវត្តវិហារធំ ។
លោកគ្រូទទួលស្រួលព្រះទ័យ ប្រឹតប្រៀនទុំវែខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជញ្ជុំ ខិតខំចង់បួសផ្នួសសាមណេរ ។ .....
ទុំមានវោហារប្រាជ្ញាផ្សេង មានទាំងសំឡេងរូបខ្ចីល្ងក់
ល្អទ្រង់អង្គកាយសាយទឹកមុខ រួចទុកនេនពេជ្រស្រេចជាប្អូន ។ .....
សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកំលោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់សព្ទភាសា ។

- នេនពេជ្រ : នៅវត្តវិហារធំក៏មាននេនមួយអង្គគ្រាន់បើដែរ គឺនេនពេជ្រ ។ នេនពេជ្រ ជាសាមណេរមានវ័យក្មេង មិនចាញ់នេនទុំប៉ុន្មានទេ រាប់ទាំងប្រាជ្ញាឈ្លាសវៃពូកែខាងផ្ចុំប៉ី លេងភ្លេងចេះប្រាកដ និងចេះធ្វើតោកលក់ដូចនេនទុំដែរ ។ នេនពេជ្រត្រូវបាននេនទុំចាត់ទុកជាសិស្សប្អូន ។ នេនពេជ្រជាសាមណេរដែលសង្វាតរៀនសូត្រ គោរពប្រតិបត្តិធម៌វិន័យតាមគន្លងពុទ្ធសាសនាពុំរវាត ជាពិសេសព្រះថៅអធិការនិងស្តាប់ដំបូន្មានព្រះគ្រូថៅអធិការមិនឱ្យថ្លោះធ្លោយនឹងវិន័យសង្ឃ ទោះជាដើរហើរលក់តោកហើយក្តី ក៏នេនពេជ្រត្រងត្រាប់ស្តាប់គ្រូមិនឱ្យឆ្គងរំលងកេរ្តិ៍ខ្មាសដែរ ... ។

សំណាក់ចិតវេរចំណេរលង់ មាននេនមួយអង្គគ្រាន់បើដែរ
នាមឈ្មោះនេនពេជ្រលេចក្រសែ នេនទាំងពីរកែតែតោកលក់ ។ .....
នេនពេជ្រចេះស្រេចខាងផ្ចុំប៉ី ឈ្លាសវៃប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគុំគួន ចំណេះក្នុងខ្លួនប្រហែលគ្នា ។
ធ្វើតោកធ្វើទុកលក់ដាច់ខ្លះ នៅផ្ទះទៀបវត្តជាមីងមា
លុះដល់រដូវត្រូវរងា ព្រឹប្រុងអង្គាជាទុក្ខព្រួយ ។ .....

នេនពេជ្រនេនទុំជំនុំព្រម　　នេនពេជ្រថាល្មមឆាន់ទៅដែរ

ទុំថាចុះគោនៅក្នុងស្រែ　　ដាច់ខ្សែស៊ីស្រូវត្រូវសងគេ ។

៦. សិក្សានិងបង្ហាញខ្លឹមសារ :

"ថាដើរមានបួនខ្លួនជាសង្ឃ　　ទើបបានត្រូវត្រង់ឥតមានមោះ

បើដើរទៅក្តីបាសកសោះ　　កេរកោះថ្លោះធ្លោយឱ្យមានប្រាំ ។"

- វិធីតែងកាព្យ(ចួន ផ្ចួន រណ្តំ) ក្នុងវគ្គខាងលើនេះមានភាពសមស្រប ពីព្រោះកវីបានតាក់តែងអត្ថបទកាព្យនេះឡើងជាបទពាក្យ ៧ ដែលគោរពបានត្រឹមត្រូវនូវក្បួនខ្នាត ចាប់ចុងចួន ផ្ចួន រណ្តំ ទៅតាមរង្វាស់កាព្យ និងការចួនល្អរវាងព្យញ្ជនៈពួកអនិងពួកអ ពួកអ៊ិនិងពួកអ៊ ប៉ុន្តែនៅមានតក់ ដោយការចាប់ចុងចួនពីព្យាង្គទី ៨ នៃឃ្លាទី ៣ ទៅព្យាង្គទី ៣ នៃឃ្លាទី ៤ ។
  + ព្យាង្គទី ៧នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៤នៃឃ្លាទី ២
  + ព្យាង្គទី ២នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៧នៃឃ្លាទី ៣ ហើយទី ៨នៃឃ្លាទី ៣ ត្រូវចួននឹងព្យាង្គទី ៤នៃឃ្លាទី ៤ ។
- ប៉ុន្តែកវីបែរជាឱ្យព្យាង្គទី ៨នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៣នៃឃ្លាទី ៤ទៅវិញ ដែលការចាប់ចុងចួនព្យាង្គទី ៨នៃឃ្លាទី ៣ ត្រង់ព្យាង្គទី ៣នោះមិនត្រឹមត្រូវតាមក្បួនរង្វាស់កាព្យ ដែលត្រូវមានគឺព្យាង្គទី ៧នៃឃ្លាទី ៣ ត្រូវចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៤ វិញ ។

បើដើរទៅក្តីឧបាសកនោះ　　កេរកោះថ្លោះធ្លោយឱ្យមានប្រាំ ។

- ម្យ៉ាងទៀតចំពោះព្យាង្គនៅក្នុងឃ្លាទី ៣នេះ មានរហូតទៅ ៨ព្យាង្គដែលជាការលើសចំនួនព្យាង្គក្នុងកាព្យ ជាហេតុធ្វើឱ្យមានការលំបាកដល់ការសូត្រនិងអានថែមទៀតផង ។

៧. តាមរយៈអត្ថបទកាព្យដកស្រង់ខាងលើនេះ យើងឃើញថា ស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនខ្មែរនៅសម័យនោះ កូនប្រុសដែលធំធាត់ពេញវ័យត្រូវតែទៅបួសរៀននៅវត្ត រៀនធម៌អាថ៌ គោរពពុទ្ធសាសនា និងធ្វើកិច្ចការជំនាញផ្សេងៗដូចជា ការធ្វើគោកជាដើម ដើម្បីជីវភាពនិងជាកិច្ចតបស្នងសងគុណដល់អ្នកមានគុណមានមាតាបិតាជាដើម ។ ចំណែក ផលិតផលដែលផលិតបានត្រូវបានប្រើប្រាស់ដោយមធ្យោបាយដឹកជញ្ជូនតាមរទេះគោ ដើរលក់តាមស្រុកតាមភូមិ ពីភូមិមួយទៅភូមិ"យ ពីស្រុកមួយទៅស្រុកមួយរហូតអស់ ។ ចំណែកកូនស្រីពេញវ័យ ត្រូវតែគោរពទំនៀមទម្លាប់បែបបុរាណដោយ "ចូលម្លប់" ។ ម្យ៉ាងទៀត ទំនៀមទម្លាប់ប្រជាជនដែលនិយមមួយទៀតគឺការនិមន្តលោកទេស "ស្មូត"សាស្ត្រាផ្សេងៗ ។ ដូចម្តាយទាវនិមន្តនេនទុំ ហៅឆាន់ស្លានិងស្មូតឱ្យស្តាប់ដូច្នេះដែរ ។

សញ្ញាស្រៈ

១. វត្ថុបំណង

- ប្រាប់បានសញ្ញាស្រៈនិស្ស័យ និងស្រៈពេញតួ តាមរយៈឧទាហរណ៍បញ្ជាក់
- បង្ហាញនិងសរសេរបានពីសញ្ញាស្រៈ សូរស្រៈ តាមរយៈការធ្វើលំហាត់
- មានគំនិតនិងស្មារតីយល់ដឹងខ្ពស់ទៅលើការប្រើប្រាស់សញ្ញាស្រៈទៅក្នុងភាសាខ្មែរបានច្បាស់លាស់ត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១០៧-១០៩

៣. ដំណាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងវេយ្យាករណ៍ "សញ្ញាស្រៈ" ដាក់លើក្តារខៀន រួចឱ្យសិស្សអានសេចក្តីផ្តើមមេរៀន ឧទាហរណ៍ និងនិយមន័យ សញ្ញាស្រៈនិស្ស័យ សញ្ញាស្រៈពេញតួ ក្នុងសៀវភៅសិស្សទំព័រទី ១០៧-១០៩ ។
- គ្រូឱ្យសិស្សឆ្លើយសំណួរ ៖
  - ដូចម្តេចហៅថាស្រៈ

    ចម្លើយ : គឺជាសូរសំឡេងដែលកើតចេញពីដំណើរខ្យល់តាមបំពង់សំឡេងបន្តឹងឡើង ដោយគ្មានទំនប់ប្រកបដោយភាពច្បាស់លាស់ ។
  - តើគេចែកសញ្ញាស្រៈជាប៉ុន្មានពួក ? អ្វីខ្លះ ?

    ចម្លើយ : សញ្ញាស្រៈមានពីរពួក គឺសញ្ញាស្រៈនិស្ស័យ និងសញ្ញាស្រៈពេញតួ ។
  - តើសញ្ញាស្រៈនិស្ស័យមានប៉ុន្មានបែប ?

    ចម្លើយ : សញ្ញាស្រៈនិស្ស័យមានពីរបែប គឺស្រៈនិស្ស័យគ្មានសញ្ញា និងស្រៈនិស្ស័យដែលគ្មានសញ្ញា ឬសញ្ញាស្រៈភ្ជាប់តួ ។
  - តើស្រៈដែលគ្មានសញ្ញាមានអ្វីខ្លះ ?

    ចម្លើយ : គឺជាសញ្ញាស្រៈ [អ] [អ៉] [អ៊] [អ៊៉] ដែលក្នុងការសរសេរ ឬក្នុងការគេសន្មតថាមានកប់(បង្កប់)នៅក្នុងព្យញ្ជនៈ ។
  - ដូចម្តេចហៅស្រៈភ្ជាប់តួ ?

    ចម្លើយ : ស្រៈភ្ជាប់តួគឺសញ្ញាស្រៈដែលគេយកប្រើបានជាមួយនឹងសញ្ញាព្យញ្ជនៈពួក អ ផងនិងពួក អ៊ ផង ។

ខ. ការហ្វឹកហាត់

- គ្រូចែកសិស្សជាក្រុមឱ្យឆ្លើយសំណួរ ?
  - តើសញ្ញាស្រៈភ្ជាប់តួមានអ្វីខ្លះ ?

    ចម្លើយ : សញ្ញាស្រៈភ្ជាប់តួមាន ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ។
  - ចូរបង្ហាញសញ្ញាស្រៈភ្ជាប់តួ។

    ចម្លើយ : សញ្ញាស្រៈភ្ជាប់តួមាន ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ ◌ុះ ◌េះ ◌ោះ ◌ិះ ◌ឹះ ◌ើះ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សធ្វើលំហាត់ទី ១-៤ ក្នុងសៀវភៅសិស្សទំព័រទី ១០៩ ៖

  ចម្លើយ :

១. ព្យាង្គ "ខ" "គ" "ង" "ញ" និង "ច"។

២. ចម្លើយអាស្រ័យលើសិស្ស

៣. នាមកិរិយាក្នុងអត្ថបទកាព្យដកស្រង់មានឈ្មោះថា "សោម"។

៤. សរសេរសូរនៃសញ្ញាស្រៈពេញតួនៃពាក្យ ៖

+ ឣសាន គឺ [អីសាន]
+ ឥន្ទ្រ គឺ [អិន]
+ ឧក្រឹដ្ឋ គឺ [អុកក្រិត]
+ ឬក គឺ [រលឹក]
+ ឯវំ គឺ [អេវ័ង] ឬ [អែវ័ង]
+ ឪជ្ឈា គឺ [អ៊ិចឆា]
+ ឳម៉ាល់ គឺ [អូម៉ាល់]
+ ឰវារ៉ណ គឺ [អេវ៉ាវ៉ាន់] ឬ [អែវ៉ាវ៉ាន់]

- គ្រូដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើនៅផ្ទះទាក់ទង ៖ សញ្ញាស្រៈភ្ជាប់តួ។

បដិវិធី

១. ឥស្តុបំណង

- ប្រាប់បានពីបដិវិធី តាមរយៈឧទាហរណ៍គំរូ
- កំណត់បានពីបដិវិធីដែលកវីប្រើប្រាស់ក្នុងកម្ពុនតែងកាព្យតាមរយៈឧទាហរណ៍និងលំហាត់តាមក្រុម
- មានមោទនភាពចំពោះស្នាដៃនិងវិធីតែងនិពន្ធកាព្យដោយកវីចេះប្រើប្រាស់បដិវិធីមួយបែបទៀតក្នុងកំណាព្យរបស់ខ្លួន ប្រកបដោយភាពពីរោះនិងការទាក់ទាញឱ្យស្រឡាញ់ចូលចិត្តកំណាព្យខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១១០-១១៣
- សៀវភៅកំណាព្យខ្មែរភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥ ។

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងបំណិន "បដិវិធី"ដាក់លើក្តារខៀន រួចឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី៩៨-១០០ អានខ្លឹមសារបំណិននិងនិយមន័យ ។
- គ្រូសួរសំណួរ ៖
  - ដូចម្តេចហៅថា បដិវិធី ?

    ចម្លើយ : បដិវិធី ជាវិធី ឬល្បិចមួយបែបដែលកវីលើកយកមកបង្ហាញក្នុងស្នាដៃកាព្យរបស់ខ្លួនទាក់ទងគុណភាព អំពីចលនា ឬសកម្មពីរ សំនួនសេចក្តីពីរ មតិពីរ ទស្សនៈពីរ ... ដែលមានភាពផ្ទុយ មកដាក់ប្រឈមគ្នា ដើម្បីជាមធ្យោបាយធ្វើឱ្យឃើញនូវតម្លៃអ្វីមួយដែលកវីចង់បង្ហាញ ។
  - តើបដិវិធីមានប៉ុន្មានបែប ? អ្វីខ្លះ ?

    ចម្លើយ : បដិវិធី មានពីរបែប :

    + បែបទី ១ គឺកវីលើកយកអង្គពីរដែលមានគុណភាព អំពើ មតិ ទស្សនៈ ផ្ទុយគ្នាមកបង្ហាញ ។ ដូចជាការបង្ហាញពីភាពផ្ទុយគ្នាក្នុងសង្គមថាស់ រវាងការមាននិងក្រ ដែលមានភាពខុសគ្នាឆ្ងាយពីគ្នាពន់ពេក ។

      ក្នុងសង្គមថាស់

      នគរថ្កើងណាស់ ថ្កើងថ្កានហួសហេតុ
      ផ្ទះថ្មក៏ច្រើន លូតកើនហួសមេឃ
      មានសប្បាយពេក ក្រវែកទុក្ខកុក ។

      (ដកស្រង់ពីកំណាព្យភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥)

+ បែបទី ២ គឺការប្រឈមស្ថិតនៅត្រង់ការយកអង្គតែមួយដែលមានគុណភាពអំពើ មតិ ទស្សនៈ ប្រឈមគ្នាមកបង្ហាញ។ ដូចជាការបង្ហាញពីបញ្ហាសង្គមទាក់ទងនឹងសីលធម៌ គុណធម៌ ភាពថ្លៃថ្នូរនៅក្នុងសង្គមដែលមនុស្សត្រូវបាត់បង់ លែងស្គាល់ខុសត្រូវ ល្អ អាក្រក់ ដោយចិត្តយង់ឃ្នង ពោលគឺខ្លួនជាមនុស្សចិត្តជាសត្វ។

មនុស្សធម៌បង់បាត់

ខ្លួនមនុស្សចិត្តសត្វ លែងស្គាល់ប្អូនបង
ជាតិជាមួយគ្នា ប្រហារចាប់ចង
ចិត្តពាលយង់ឃ្នង មោហ៍ចាំងជុំជិត។

(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉ែន ទំព័រ ១៧)

២. ការហ្វឹកហាត់

- គ្រូឱ្យសិស្សអានន័យមន័យ "បដិវិធី" ក្នុងសៀវភៅសិស្សទំព័រទី ១១២ឡើងវិញ
- គ្រូឱ្យសិស្សធ្វើលំហាត់ទី ១-៤ ក្នុងសៀវភៅសិស្សទំព័រទី ១១៣តាមក្រុម។

ចម្លើយ : បង្ហាញពីវិធីប្រឈម (បដិវិធី) ក្នុងវគ្គនីមួយៗនៃកាព្យខាងក្រោម ៖

១. ខ្លួនស៊ីតាមឃ្លាន

ប្រើគេបំពាន គ្មានក្តីអាណិត
ខ្លួនធាត់ថ្លាថ្លោស គ្មាចុះស្គមស្វិត
សម្រុកឥតគិត ខ្លួនស្រែកតែមាត់។

(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉ែន)

ចម្លើយ : វគ្គដកស្រង់ខាងលើនេះ កវីបានបង្ហាញនូវបដិវិធីឬវិធីប្រឈមពីសកម្មភាពការងារនៃសម័យកម្ពុជាប្រជាធិបតេយ្យ ដែលបក្សពួកកម្មាភិបាលមានស៊ីចុកតាមចិត្ត ប្រជាជនគ្មានអ៊ីស៊ីស្គមស្វិត គិតតែធ្វើការឥតឈប់ឈរ ឯពួកអ្នកមានអំណាចមិនធ្វើបានតែប្រើ។ ត្រង់នេះ កវីបង្ហាញឱ្យឃើញនូវការប្រឈមរវាងអត្ត:ខាងក្រៅ(រូបរាងកាយ) និងអត្ត:ខាងក្នុង(ចិត្ត)។

២. វាយតែជាតិខ្លួន

ហើយស្រែកផ្ទួនៗ ថាខ្លួនវាយខ្លាំង
ឃើញសុទ្ធខ្មោចខ្មែរ នៅតែស្រែវាំង
ងងើលភាន់ភាំង ថាខ្មែរអប្រិយ។

(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉ែន)

ចម្លើយ : វគ្គដកស្រង់ខាងលើនេះ កវីបានឆ្លុះបញ្ចាំងឱ្យឃើញនូវទង្វើដ៏អាក្រក់របស់មនុស្សដែលស្អប់ជាតិសាសន៍ឯង។ កវីបានបង្ហាញឱ្យឃើញការធ្វើទុក្ខទារុណកម្មជាតិខ្មែរដូចគ្នាដោយយកលេសថា "វាយខ្លាំង" ដែលជាវិធីប្រឈមរវាងអត្ត:ខាងក្នុង(ចិត្ត) ផ្ទុយនឹងសកម្មភាព "វាយ" សម្លាប់។

៣. អ្នកស្រែធ្វើស្រូវ

ក្រោមភ្លៀងផ្គរត្រូវ សួរៗសែងចំហាយ
ផលហូបបបរ ត្រដរខ្វះបាយ
អ្នកនៅសុខកាយ បាយដូចសំឡី ។

(ដកស្រង់ពីកំណាព្យភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥)

ចម្លើយ : អត្ថបទកាព្យដកស្រង់ខាងលើនេះ ក៏ជាវិធីបង្ហាញនូវបដិវិធីមួយបែបទៀតដែលកវីចង់លើកឡើងពីភាពប្រឈមគ្នារវាងអ្នកដែលខិតខំធ្វើស្រែនិងអ្នកមិនខំធ្វើស្រែ មានការប្រឈមគ្នាត្រង់ថាខំធ្វើបានហូបត្រឹមតែបបរ ឯអ្នកនៅស្ងៀម(អ្នកនៅសុខកាយ) បែរជាបានហូបបាយឆ្ងាញ់សដូចសំឡីទៅវិញ ។ នេះគឺជាភាពបដិបក្ខ ឬបដិវិធីដែលកវីលើកឡើង ។

៤. សក់ចេះតែស

ចិត្តចង់តែល្អ មិនព្រមបណ្តោយ
ឱ្យសាច់ឈាមផ្ងាស់ ឱ្យចាស់ទន់ខ្សោយ
រត់តែតាមក្រោយ ចាស់រត់លឿនជាង ។

(ដកស្រង់ពីកំណាព្យ កេង វ៉ាន់សាក់ គុកកាមកិលេស ទំព័រ ៧៦)

ចម្លើយ : វគ្គដកស្រង់ខាងលើនេះ កវីចង់បញ្ជាក់ពីបដិវិធីក្នុងការបង្ហាញពី ចិត្ត មនុស្ស ទោះបីខ្លួន "អត្តៈ" ដែលសក់ចេះតែស ខ្លួនកាន់តែចាស់ ប៉ុន្តែមនុស្សមានចិត្តមិនចង់ផ្ងាស់ឱ្យចាស់ទេ ហើយវាផ្ទុយនឹងវ័យទោះខំយ៉ាងណាក្តី ក៏នៅតែចាស់ មិនក្មេងដូចចិត្តចង់ឡើយ ពោលគឺកវីយកចិត្តដែលជាអត្តៈខាងក្នុងចង់រក្សាភាពល្អឱ្យនៅដដែលទៅប្រឈមនឹងដំណើរវិវត្តនៃសរីរាង្គ "ខ្លួន" ដែលជាអត្តៈខាងក្រៅ ។

គ. ការវាយតម្លៃ

- គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ ។
- ចូរបង្ហាញពីបដិវិធីឬវិធីប្រឈមក្នុងវគ្គខាងក្រោម ៖

ដែកដុលរនាំង

តូចបួនជញ្ជាំង ធំសោអស្ចារ្យ
ខាងលើដំបូល ខាងក្រោមថ្មដា
ងាកមើលទៅណា អ្នកយាមមើលដែរ ។

ចម្លើយ : អត្ថបទកាព្យដកស្រង់ខាងលើនេះ កវីបានបង្កើតអង្គពីរនៅកន្លែងតែមួយក្នុងស្ថានភាពតែមួយ ដោយយកគុណភាពវត្ថុ "តូច និង ធំ" ដែលមានលក្ខណៈប្រឈមគ្នាមកប្រើ ដើម្បីបង្កើតរូបារម្មណ៍មួយដែលធ្វើឱ្យយើងរំភើប អាណិតអាសូរនិងបង្ហាញឃើញវិតតែច្បាស់នូវការគាបសង្កត់របស់អ្នកជិះជាន់គេមកលើអ្នកដែលត្រូវគេជិះជាន់ ។



ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

១. ឥតុបំណង

- ប្រាប់បានពីប្រវត្តិតែងនិពន្ធ សង្គមបរិយាកាសនៃអត្ថបទ
- បង្ហាញបានពីវិធីបង្កើតរូបារម្មណ៍ក្នុងកំណាព្យឬកាព្យរូបារម្មណ៍
- មានទស្សនៈវិភាគទៅលើសកម្មភាពដែលកើតឡើងក្នុងរបបអតីតកាលបានត្រឹមត្រូវនិងសមហេតុផល ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១១៤-១១៩
- សៀវភៅមើលផែនដីខ្មែររបស់ក្រសួង ជួន ម៉ែន ឆ្នាំ ១៩៨០ ។

៣. ដំណាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូសរសេរចំណងជើងអំណាន "ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ដាក់លើក្តារខៀន រួចសួរសំណួរ :
  - តើអ្នកដឹងទេថា របបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយនរណា ? ចាប់ផ្តើមពីឆ្នាំណាដល់ឆ្នាំណា ?

    ចម្លើយ : របបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយលោកប៉ុល-ពតហៅសាឡុតស ។ ចាប់ផ្តើមពីឆ្នាំ ១៩៧៥-១៩៧៩ ។
  - តើអ្នកធ្លាប់ដឹងអ្វីខ្លះ ពីរបបកម្ពុជាប្រជាធិបតេយ្យនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។ ដឹង/មិនដឹង ។
- ឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១១៤ ពិនិត្យលើរូបភាពរួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះ នៅលើរូបភាព ?

    ចម្លើយ : ឃើញមានរូបភាពមនុស្សស្រីប្រុស វ័យកណ្តាល ស្លៀកពាក់ ខោអាវពណ៌ខ្មៅ ។
  - តើមនុស្សទាំងអស់នៅក្នុងរូបភាពនេះកំពុងធ្វើអ្វី ?

    ចម្លើយ : មនុស្សទាំងអស់ក្នុងរូបភាពនេះ ខ្លះកំពុងកាប់ដី ខ្លះរែកដី ខ្លះកំពុងដឹកនាំការងារ ។
  - តើរូបភាពនេះ មានន័យដូចម្តេច ?

    ចម្លើយ : រូបភាពបង្ហាញពីការធ្វើការកាប់គាស់រែកសែងដីយ៉ាងសស្រោកសស្រាំ គ្មានឈប់ឈរ ។
- គ្រូឱ្យសិស្សធ្វើការសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ១១៤-១១៥ ។

ខ. ពង្រឹងអំណាន

- ឱ្យសិស្សអានខ្លឹមសារនៃការអភិវឌ្ឍបំណិនក្នុងសៀវភៅសិស្សទំព័រទី ១១៥-១១៩
- ឱ្យសិស្ស ៤-៥នាក់ អានអត្ថបទកាព្យបន្តគ្នាឬបណ្តាក់គ្នានូវអត្ថបទកាព្យដកស្រង់ក្នុងសៀវភៅសិស្សទំព័រទី ១១៥-១១៩ ឯសិស្សដទៃទៀតអានតាមដោយស្ងៀមស្ងាត់ ។

គ. ការវាយតម្លៃ

- ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១១៩ ។

ចម្លើយ :

១. ប្រវត្តិនៃការតាក់តែងរបស់អ្នកនិពន្ធនិងការបោះពុម្ពផ្សាយ "ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" គឺជាចំណងជើងមួយដែលអ្នកនិពន្ធសៀវភៅភាសាខ្មែរថ្នាក់ទី ១១នេះ បានដកស្រង់ចេញពីកម្រងកំណាព្យ "មើលផែនដីខ្មែរ" របស់អ្នកនិពន្ធ **ជួន ម៉ែន** យកមកសិក្សា ។

+ ស្នាដៃនិពន្ធកម្រងកំណាព្យ "មើលផែនដីខ្មែរ"នេះជាវណ្ណកម្មមួយដ៏សំខាន់ក្នុងចំណោមវណ្ណកម្មដទៃទៀតក្រោយសម័យឆ្នាំ ១៩៧៩ ។ អ្នកនិពន្ធជួន ម៉ែន បានរចនាឡើងដោយឆ្លងកាត់ការលំបាកជាច្រើនជាទីបំផុតនិងចំណាយពេលវេលាដ៏យូរថែមទៀតផង ។ សោកនាដកម្មយ៉ាងឈឺចាប់ខ្លោចផ្សា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ បានដក់ជាប់ក្នុងដួងចិត្តប្រជាជនខ្មែរជាប់ជានិច្ច ។ កំហឹងឈឺចាប់ទាំងនោះបានពុះកញ្ជ្រោលក្នុងអារម្មណ៍របស់អ្នកនិពន្ធ ហើយបានជំរុញឱ្យអ្នកនិពន្ធ ខិតខំចងក្រងជាកម្រងកំណាព្យនេះឡើង ។
+ ថ្ងៃ ៧មករា ឆ្នាំ ១៩៧៩ ប្រជាជនខ្មែរបានត្រូវរំដោះផុតពីច្រវាក់ខ្មោះឃ្មាងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយវិលមកជួបជុំគ្រួសារនិងរស់នៅប្រកបដោយភាពសុខដុមរមនា ។
+ នេះជាឱកាសមួយដ៏ល្អ ដែលអាចឱ្យអ្នកនិពន្ធរំឭកឡើងវិញពីអនុស្សាវរីយ៍ដ៏លឿងជូរចត់និងបំផុសនូវកំហឹងឈឺចាប់ដែលខ្លួនខំលាក់ទុកពីអតីតកាលជាយូរមកហើយ ដោយខិតខំផ្ចង់សរសេរចងក្រងនូវពាក្យពេចន៍ដែលខ្លួនគាត់បានខំរក្សាទុក ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយបានដឹង បានស្គាល់ បានយល់ពីរបបព្រៃផ្សៃនេះ ។
+ ដោយយល់ឃើញថា ផ្ទៃកំណាព្យទាំងមូលប្រកបដោយអត្ថន័យនិងអត្ថរសយ៉ាងសំខាន់ដែលបានរៀបរាប់ពីជីវិតពិតជាក់ស្តែងរស់ក្នុងរបបដ៏សែនឈឺចាប់នេះ អ្នកនិពន្ធក៏បានសម្រេចចិត្តពិនិត្យឡើងវិញត្រឹមត្រូវ បោះពុម្ពសៀវភៅកម្រងកំណាព្យ "មើលផែនដីខ្មែរ" សម័យកម្ពុជាប្រជាធិបតេយ្យនេះឡើងដើម្បីរក្សាទុកឱ្យកូនចៅជំនាន់ក្រោយបានយល់ដឹង សិក្សាស្វែងយល់ពីការពិតក្នុងរបបអតីតកាលនេះ ។

(ស្នាដៃនេះត្រូវបានបោះពុម្ពនៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៨០)

២. វគ្គដែលទ្រទ្រង់ចំណងជើងកំណាព្យដកស្រង់នេះ គឺវគ្គទី ១ និងទី ២ ៖

មេសាចិតប្រាំ	នគររងកម្ម	សិទ្ធិសេរីចុះ
សីលធម៌ជាតិ	ឃ្លាតធ្លាក់ផ្លូវខុស	ជនទាំងស្រីប្រុស
	ជាប់ទោសពេញដី ។	
គុកខ្មោះថាគ្មាន	ភរទាំងបំពាន	លាក់មិនឱ្យស្តី
អំពើបាញ់កាប់	ចងចាប់ប្រក្រតី	ច្បាប់នៅសម្តី
	អ្វីៗស្រេចថា ។	

៣. តាមរយៈអត្ថបទកាព្យដកស្រង់នេះ យើងឃើញថា អ្នកនិពន្ធបានរៀបរាប់យ៉ាងច្បាស់ពីការពិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងខែមេសា ឆ្នាំ ១៩៧៥ ដល់ខែមករា ឆ្នាំ ១៩៧៩ ដែលធ្វើឱ្យប្រជាជនកម្ពុជាទូទាំងប្រទេសត្រូវរស់រងកម្មដោយការធ្វើទារុណកម្មកាប់សម្លាប់ ដាក់គុក ដាក់ច្រវាក់ បង្ខំឱ្យធ្វើការទាំងយប់ ទាំងថ្ងៃ គ្មានត្រាប្រណី។ ពួកគេបានប្រមូលផ្តុំប្រជាជនឱ្យរស់នៅជាសមូហភាព ធ្វើការធ្ងន់ធ្ងរ បង្អត់អាហារ បំបាត់សិទ្ធិសេរីភាព ដកហូតកម្មសិទ្ធិឯកជន។ ក្នុងរបបនោះ អង្គការត្រូវបានពួកគេចាត់ទុកជាអ្នកមានគុណ មហាលោតផ្លោះ មហាអស្ចារ្យ។ ពួកអង្គការបានបង្ខិតបង្ខំឱ្យរើរុះផ្ទះសម្បែង សាលារៀន ដុតផ្សារ វត្តអារាម បំផ្លាញទ្រព្យសម្បត្តិជាតិ ... ។ ទំនាក់ទំនងក្នុងគ្រួសារក៏ត្រូវកាត់ផ្តាច់ អាពាហ៍ពិពាហ៍គឺអង្គការជាអ្នករៀបចំឱ្យ បើប្រកែកនឹងត្រូវចោទថាជាខ្មាំង ត្រូវគេយកទៅសម្លាប់ចោល។ សង្គមបរិយាកាសនាសម័យកាលនោះពោរពេញដោយសោកនាដកម្ម។ ការសម្លាប់រង្គាលដ៏គួរឱ្យឈឺចាប់គឺជារបបប្រល័យពូជសាសន៍ សម្លាប់ជាតិសាសន៍ឯងពិតៗ។ ប្រទេសជាតិនៅពេលនោះស្ថិតក្នុងនរកអវិចីយ៉ាងពិតប្រាកដ។

៤. ក្នុងអត្ថបទកាព្យខាងលើកវីបានបង្ហាញ :

ក. ឧបមាវិធី : កវីប្រើពាក្យ "ដូច ហាក់" ៖

វគ្គទី ៨ : ក្តៅដូចអុសគល់ អវិចីពុំដល់ គ្មានព្រហ្មវិហារ
ចិត្តជាត្រីឆ្នោ ជាចោរហិង្សា អ្នតអាងអាត្មា
ជាគ្រូមនុស្សជាតិ។

វគ្គទី ១០ : ហាក់សជានិច្ច ទោះបីគគ្រិច ខ្មៅខ្នុរអាស្រូវ
ដូចអាទិទេព មានបែបត្រឹមត្រូវ បរិសុទ្ធគ្រប់ផ្លូវ
ត្រូវជាសាកល។

ខ. បំរៀបន័យ : កវីប្រើពាក្យ "ស្មើ វាយចោល ដកដាក់ ដកចេញ" ៖

វគ្គទី ៤ : សម្តីថាស្មើ តែឃើញអំពើ គឺជាចោរប្លន់
អ្នកម្ចាស់មិនឱ្យ នឹងត្រូវអាសន្ន ជាប់ទោសយ៉ាងអន់
ជាន់កវាយចោល។

វគ្គទី ៥ : ដកដាក់អង្គការ គាត់មានខ្លឹមសារ តែដូចស្រមោល
ភូតភរប្រវឹក មិនអាចដេញដោល ប្រើឱ្យរត់បោល
បម្រើអាត្មា។

វគ្គទី ៣២ : ស្លោកគេប្រមាថ ដកចេញមិនខាត ទុកមិនចំណេញ
គេពោលញ័រមាត់ សង្កត់ខាំធ្មេញ ចិត្តអរលេញ
តែខាងសម្លាប់។

៥. ដើម្បីបង្កើតកាព្យរូបារម្មណ៍ក្នុងអត្ថបទកាព្យនេះ កវីបានប្រើវិធី ៖

- វិធីដួន "រើ" និងពាក្យ "កុំ ថា" ៖

វគ្គទី ១២ : ធ្វើហើយរើរុះ រើឡើងរើចុះ រើទាល់តែអស់
ដូចត្រីពុលភក់ រុលរុកផ្លេកផ្លោះ រើទាល់តែអស់
ខ្សោះក្រៀមស្រកា ។

វគ្គទី ២៧ : កុំមានវាចា កុំដឹងហេតុការណ៍ កុំគិតរាក់ជ្រៅ
ថាឈប់ត្រូវឈប់ ថាទៅត្រូវទៅ កុំយល់សខ្មៅ
មនុស្សដូចតិរច្ឆាន ។

- វិធីបញ្ជាស :

វគ្គទី ២៤ : ល្បិចសុទ្ធប្រហារ លាក់ខ្លួនដូចខ្លា សំងំលួចប្លន់
ដេកនៅមិនសុខ ជាទុក្ខស្ងោស្ងន់ ទិសទាសដូចមាន់
រាន់រកភាកពង ។

វគ្គទី ៣៣ : សុទ្ធខ្មាំងខ្មៅអែ ខ្មែរសម្លាប់ខ្មែរ ជ័យយោសអឹងអាប់
ភរនឹងជាតិឯង វង្វេងជឿផ្តាប់ លែងគិតរស់ស្លាប់
ដូចមមាចនិងភ្លើង ។

៦. ខ្ញុំយល់ថា របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបប្រល័យពូជសាសន៍ដែលមានភាពឃោរឃៅព្រៃផ្សៃ ធ្វើបាប កាប់សម្លាប់ប្រជាជនគ្មានត្រាប្រណី ជារបបដែលគ្មានច្បាប់ គ្មានសិទ្ធិសេរីភាពក្នុងការរស់នៅ ជារបបដែលគ្មានផ្សារ គ្មានសាលារៀន គ្មានវត្តអារាម ...មានតែសហករណ៍ដែលជាកន្លែងធ្វើការរួម ដោយអំពីផ្តាច់បានបង្ខិតបង្ខំ មិនឱ្យឈប់សម្រាកនិងហូបចុកគ្រប់គ្រាន់ ជារបបដែលកាប់សម្លាប់ជាតិសាសន៍ឯង ចោទសាសន៍ឯងជាសត្រូវ ពោលគឺជារបបប្រល័យពូជសាសន៍ដែលប្រជាជននៅហាក់ដូចជារស់ក្នុងនរកអវិចី ក្នុងភាពអន្ធការ ... ។

៧. ចម្លើយទី ៧នេះ គ្រូឱ្យសិស្សស្រាវជ្រាវពីជីវប្រវត្តិអ្នកនិពន្ធបន្ថែមទៀត ។

៨. បើអ្នកមានឱកាសជួបលោកជួន ម៉ែន អ្នកអាចសាកសួរពីការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលអ្នកចង់ដឹងបន្ថែមទៀតបាន ឬសួរចាស់ទុំដែលធ្លាប់រស់នៅនិងឆ្លងកាត់ការលំបាកក្នុងរបបនេះ ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ។



ទំនុកច្រៀងនិងរបាំស្នែងទន្សោង

១. វត្ថុបំណង

- ប្រាប់បានពីទំនុកច្រៀង របាំស្នែងទន្សោង តាមរយៈការស្តាប់អត្ថបទ
- កំណត់បានពីអត្ថន័យនៃចម្រៀងរបាំស្នែងទន្សោងតាមរយៈការឆ្លើយសំណួរ
- បណ្តុះស្មារតីសិស្សឱ្យស្រឡាញ់និងថែរក្សាចម្រៀងរបាំប្រពៃណីខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១២០
- សៀវភៅ "របាំប្រជាប្រិយខ្មែរ" វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៤ ។

៣. ដំណាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូសរសេរចំណងជើងអត្ថបទស្តាប់រឿង "ទំនុកច្រៀងរបាំស្នែងទន្សោង" ដាក់លើក្តារខៀន រួចសួរ ៖
  - តើអ្នកធ្លាប់ដឹងឮពីរបាំស្នែងទន្សោងឬទេ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើដឹងទេថាគេលេងរបាំស្នែងទន្សោងនេះនៅពេលណា ?

    ចម្លើយ : គេលេងរបាំស្នែងទន្សោងសម្រាប់ជាការលំហែកម្សាន្តរបស់ជនជាតិព័រនៅពេលបុណ្យចូលឆ្នាំ ។
  - ហេតុអ្វីបានជាគេដាក់ឈ្មោះថារបាំស្នែងទន្សោង ?

    ចម្លើយ : បានជាគេដាក់ឈ្មោះថា របាំស្នែងទន្សោង ពីព្រោះ របាំនេះមានក្បាច់រាំត្រាប់តាមកាយវិការសត្វទន្សោង ហើយមានអ្នកសម្តែងពាក់ស្នែងទន្សោងនៅលើក្បាល ។
- គ្រូពន្យល់ន័យនៃពាក្យពិបាកខាងក្រោម ៖
  - របាំ (ន) : ល្បែងច្រៀងរបាំ ។
  - ទន្សោង (កិ) : ឈ្មោះសត្វជើងបួន ពួកគោព្រៃ ។
  - រាជបញ្ជា (ន) : បញ្ជារបស់ព្រះរាជា បញ្ជារបស់ស្តេច ។
  - ប្រទក្សិណ (គុ) : ការដើរជុំវិញ ។
  - ទស្សនីយភាព (ន) : ភាពដែលទស្សនាគួរជាទីចាប់ចិត្តចាប់អារម្មណ៍ ។
  - ព្រះសណ្តាប់ (គុ) : ការស្តាប់ (ការស្តាប់របស់ព្រះរាជា) ។
  - ទំនុក (ន) : ដំណើរទុកដាក់ របៀបទុកដាក់ ពាក្យប្រកបក្នុងបទដែលច្រៀង ឧទាហរណ៍ រាយទំនុក ទំនុកច្រៀង ។

ខ. ការស្តាប់

- គ្រូឱ្យសិស្សបើកសៀវភៅទំព័រទី ១២០ ពិនិត្យរូបភាព អានសេចក្តីណែនាំ ដើម្បីត្រៀមឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១២០ ។
- គ្រូអានអត្ថបទនិងទំនុកច្រៀងរបាំស្នែងទន្សោងឱ្យសិស្សស្តាប់ដោយយឺតៗ ៖

របាំស្នែងទន្សោង

នៅតាមស្រុកភ្នំក្នុងព្រះរាជាណាចក្រ ជាពិសេសភូមិភាគដែលស្ថិតនៅត្រើយខាងត្បូងទន្លេសាប គេឃើញមានសេសសល់របាំប្រជាប្រិយមួយបែបដែលអ្នកស្រុកសន្មតហៅរត់មាត់ថា "របាំស្នែងទន្សោង" ។ សព្វថ្ងៃគេឃើញមានរបាំនេះនៅតាមខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងពោធិ៍សាត់ ។ បានជារបាំនេះឈ្មោះថា "របាំស្នែងទន្សោង" ព្រោះរបៀបរាំមានក្បាច់ត្រាប់តាមកាយវិការសត្វទន្សោង ហើយអ្នកសម្តែងមួយ ឬពីរនាក់(លើក្បាលពាក់ស្នែងទន្សោង) ។

តាមការដេញដោលរកដើមកំណើតនៃរបាំនេះ គេឃើញថា របាំនេះមានប្រភពលេចឡើងច្រើនទាក់ទងទៅខាងរឿងនិទានទៅវិញ ដូចជាអ្នកភូមិអញ្ចញរួង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង បាននិទានថា ៖

កាលនោះ មានព្រានព្រៃម្នាក់ឈ្មោះ "ព្រានពរ" ទទួលព្រះបញ្ជាពីព្រះរាជា ឱ្យចេញទៅរកបាញ់ទន្សោង ។ ព្រានទៅបាត់យូរណាស់ ទើបត្រឡប់ចូលមកគាល់ព្រះរាជាវិញ ដោយដៃទទេ គ្មានបានអ្វីឡើយ ។ ព្រះអង្គក៏ត្រាស់សួរថា ហេតុអ្វីក៏ពុំបានទន្សោងមួយសោះដូច្នេះ ។ ព្រានពរ ក្រាបបង្គំទូលថា ខ្លួនបានដើរទៅដល់ព្រៃដែលសម្បូណ៌ទៅដោយសត្វទន្សោងនិងម្រឹគជទៃទៀត ។ ប៉ុន្តែ ដោយទូលព្រះបង្គំរវល់តែមើលទស្សនីយភាពមួយយ៉ាងចម្លែកអស្ចារ្យណាស់ គឺសត្វទន្សោងមួយគូញីឈ្មោល ចេះរាំយ៉ាងល្អ នាំឱ្យជក់មិនអាចបាញ់កើតឡើយ ។ ទូលព្រះបង្គំផ្គងស្មាលើស្មាលបៗចូលទៅ ប្រុងតែនឹងបាញ់ដែរ តែដោយល្អមើលក្បាច់ចង្វាក់រេរាំរបស់សត្វនេះពេកក៏ខកខាន រកតែតម្លោះព្រួញឱ្យរត់ទៅមិនកើត ។ មិនតែប៉ុណ្ណោះ មានខ្លាធំមួយដែលមកលបប្រុងនឹងចាប់ទន្សោងដែរនោះ ក៏ចាប់មិនកើត បែរជាជួយគោះជើងជាចង្វាក់ឱ្យសត្វនេះទៅវិញ ។ ជាមួយក្បាច់រាំរបស់ទន្សោងមានកន្ទង់មួយហ្វូងហើរស្រែកប្រទក្សិណជុំវិញទន្សោងទាំងពីរ ជួយធ្វើជាសួរសំនៀងពីរោះល្វែងល្វើយ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ព្រះអង្គត្រាស់ប្រើឱ្យព្រានពរធ្វើត្រាប់តាមទស្សនីយភាពនោះថ្វាយព្រះអង្គ ។ ព្រានពរក៏ខំធ្វើត្រាប់ឱ្យបានត្រប់កាយវិការនិងសួរសំនៀងសត្វ ថ្វាយព្រះរាជាទ្រង់ទតនិងព្រះសណ្តាប់គ្មានសល់ចន្លោះអ្វី ។

ការសម្តែងកាយវិការ របស់ព្រានពរនេះហើយ ដែលកើតបានទៅជារង់របាំនេះឡើងគឺ ៖

+ អ្នកពាក់ស្នែងពីរនាក់ តំណាងទន្សោងញី-ឈ្មោល
+ សំឡេងស្គរ តំណាងសន្ធឹកខ្លាធំ
+ សំឡេងពួយ តំណាងសួរសព្វសត្វកន្ធង់ ។

រីឯរង់របាំនេះ គេហៅឈ្មោះភ្លេងគេថា "ភ្លេងមហោពរ" គឺគេសម្គាល់តាមឈ្មោះព្រានពរ ជាអ្នកបង្កើតរង់នេះ ។

ប៉ុន្តែ បើយើងដេញដោលរិះរេ គិតស្រាវជ្រាវតាមការសិក្សាបែបជាតិពន្ធុសាស្ត្រវិញ យើងយល់បានម្យ៉ាងទៀតថា ជនជាតិដើមនៅក្នុងប្រទេសកម្ពុជាយើង មានជនជាតិមួយហៅថា "ព័រ" ដែលច្រើនរស់នៅតាមជួរភ្នំក្រវាញ ត្រង់ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និងស្រុកកំពង់សោម ខេត្តកោះកុង កាលពីសម័យមុនបានបង្កើតរបាំស្នែងទន្សោង ព្រោះគេឃើញ របាំនេះមាននៅតែត្រង់តំបន់ជនជាតិព័ររស់នៅ ។ គេអាចសន្និដ្ឋានបានថា

"ព្រានពរនេះគឺជាព្រានសាសន៍ព័រនោះឯង"។ ដូច្នេះ របាំប្រជាប្រិយនេះ កកើតឡើងពីជនជាតិព័រ។ ហេតុនេះ យើងសរុបបានថា របាំទន្សោងជាកេរដំណែមកពីពួកព័រសម្រាប់លេងនៅពេលប្រកបពិធីអ្វីមួយ ដែលយកលំនាំតាមរបរពួកគេជាអ្នកប្រមាញ់។

តាមសេចក្តីអធិប្បាយយ៉ាងវែងរបស់លោក **រ.បារាដាត់** ជាតិបារាំង ដែលបានធ្វើសេចក្តីសង្កេតអំពីជីវភាពរបស់ជនជាតិសំរែនិងព័រ ហើយសរសេរចុះផ្សាយក្នុងព្រឹត្តិប័ត្រសាលាបារាំងនៅចុងបូព៌ាប្រទេសថា "របាំស្នែងទន្សោងនេះ ប្រាកដជាកើតឡើងពីពួកព័រមែន ដោយលោកបានទៅធ្វើសេចក្តីសង្កេតដល់ទីកន្លែងរស់នៅជាមួយពួកព័រនេះអស់ពេលយ៉ាងយូរ។ លោកបានអះអាងទៀតថា "លោកធ្លាប់ឃើញពួកព័រលេងរបាំនេះផ្ទាល់ភ្នែក" ហើយលោកមានទាំងថតរូប ចុះផ្សាយជាមួយអត្ថបទលោកផង។ ដូច្នេះ សរុបសេចក្តីបានថា បណ្តាជនដែលរស់នៅលើទឹកដីយើងពីបុរាណ មានសាសន៍ពីរនេះជាអាទិ៍ សុទ្ធតែបានបង្កើតរបាំសម្រាប់លំហែចិត្ត ដោយប្រឌិតយកតាមលំនាំនៃការប្រកបជីវិត គឺថាកាលនោះ គេរស់នៅក្នុងព្រៃ មានតែម្រឹគជាញាតិមិត្តឬជាចំណីអាហារប្រចាំថ្ងៃ ម្ល៉ោះហើយការប្រឌិតក្បាច់រាំវែកនិងប្រដាប់តាក់តែងកាយត្រូវតែដេកដួលទៅរករូបភាព និងកាយវិការម្រឹគទាំងនោះផងដែរ។

តាមឯកសារលោក **រ.បារាដាត់** បន្ថែមថា គេលេងរបាំនេះនៅក្នុងភូមិដែលសំខាន់ៗ ប៉ុន្តែតាមមតិខ្មែរយើងខ្លះចាំថាគេលេងតែនៅក្នុងវាំង ក្នុងព្រះរាជពិធីបុណ្យចូលឆ្នាំប៉ុណ្ណោះ។

អំពីទំនុកច្រៀង

ទំនងមើលទៅបទចម្រៀងពិតជាមានច្រើនបែបច្រើនយ៉ាងតាមការតាក់តែងនៃអ្នកស្រុកផ្សេងៗគ្នា។ ក្នុងទីនេះ យើងលើកយកតែទំនុកណាដែលគេស្គាល់ច្រើន មកបង្ហាញប៉ុណ្ណោះ ៖

ទន្សោងស្នែងនប់	រកស៊ីតែយប់
ទន្សោងស្នែងនប់	ថ្ងៃឡើងពួនព្រៃ។
ទន្សោងស្នែងកែក	ស៊ីបែកពីហ្វូង
ទន្សោងស្នែងច្រូង	វិធហ្វូងបែកខ្ចាយ។
ទន្សោងគោបា	ស៊ីបន្លាជង្គុំ
ទន្សោងព្រៃភ្នំ	លេបក្រមុំទាំងមូល។

(តាមឯកសារលោក រ.បារាដាត់ ឆ្នាំ ១៩៤១)

សូរិយាល្ងាចថ្ងៃ	សូរិយាល្ងាចថ្ងៃ
ទន្សោងគោព្រៃ	រកស៊ីជើងភ្នំ។
តូចស៊ីដោយតូច	ធំស៊ីដោយធំ
ស៊ីតាមជើងភ្នំ	ល្បាស់ព្រិចខ្ចីល្ហ។
ស៊ីហើយវាជល់	ជល់គ្នាវីវរ
សុទ្ធតែឡើងក	អួតមានកម្លាំង។

(តាមការចាំរបស់លោក កេត រឿន គ្រូនៅសាលាវិចិត្រសិល្បៈខេមរៈ)

បងដើរព្រៃស្តុក បងរុកព្រៃស្មាត
ដើរកាត់ព្រៃញាត លេចវាលចូលព្រៃ ។
ឡើងភ្នំចុះភ្នំ ថ្មដាធំក្រៃ
ទាំងបន្លាឈ្លៃ ល្បាស់ព្រៃចលាស់ល្ហ ។
ទន្សោងគោព្រៃ កៀងញីវែរ
ល្បាស់ព្រៃចលាស់ល្ហ ស្រណោះខែពិសាខ ។
កន្ត្រែតៗអើយ ទន្សោងគោបា
លេបបន្លាជើងភ្នំ លេបក្រមុំទាំងមួល ។
ជំនោរខ្យល់បក់ ត្រជាក់ខ្យល់ជួន
កាប់ឫស្សីចងក្បួន ជួនប្អូនទៅស្រុក ។
កន្ទែងបងបាត់ បងកាត់មិនស្តាយ
បំណាច់ឃ្លាតឆ្ងាយ បងស្តាយតែប្អូនស្រី ។

(តាមឯកសារលោក ខ្លង អ៊ូច)

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១២០ ។

ចម្លើយ :

១. របាំស្នែងទន្សោងមានប្រវត្តិពីជនជាតិដើមភាគតិច "ព័រ" ដែលរស់នៅក្នុងបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ ។ របាំនេះមានប្រវត្តិទាក់ទងនៅនឹងការបរបាញ់សត្វ ដែលមានក្នុងរឿងនិទានមួយ ព្រានម្នាក់ឈ្មោះ "ពរ" ត្រូវបានព្រះរាជាបញ្ជាឱ្យទៅបរបាញ់សត្វ ។ ព្រានចេញទៅបរបាញ់អស់ពេលយ៉ាងយូរ តែដល់ពេលត្រឡប់មកវិញពុំឃើញបានសត្វអ្វីសោះ ព្រះរាជាក៏ត្រាស់សួរព្រានពីរឿងហេតុដែលបរបាញ់មិនបានសត្វ ។ ព្រានពរក៏ទូលតាមដំណើររឿងថា ពេលខ្លួនទៅដល់ព្រៃឃើញមានសត្វជាច្រើនដូចជាសត្វទន្សោង និងម្រឹគជនិទេ ។ ប៉ុន្តែ ដោយរវល់តែសត្វទន្សោងញីឈ្មោល មួយគូឡើងរាំក៏ជក់ចិត្ត ភ្លេចបាញ់ ។ បន្ទាប់មកឃើញមានទាំងខ្លាធំគោះជើង ជាចង្វាក់ភ្លេង ហើយឃើញកន្លង់យំងូងៗហើរប្រទក្សិណជុំវិញទន្សោង ទាំងពីរ ជួយធ្វើជាសំនៀងពីរោះលេងល្វើយជក់ចិត្តពេក ។ ទស្សនីយភាពបែបនេះធ្វើឱ្យព្រានមិនដាច់ចិត្តបាញ់ទន្សោង ហើយត្រឡប់មកវិញដៃទទេ ។ ព្រះរាជាទ្រង់បានព្រះសណ្តាប់ការរៀបរាប់ ក៏សព្វព្រះទ័យឱ្យព្រានធ្វើជាកាយវិការត្រាប់តាមសត្វទាំងនោះ ។ តមកក៏កើតបានជារបាំនេះឡើង ។

២. បានជាគេដាក់ឈ្មោះថា "របាំស្នែងទន្សោង" ព្រោះអ្នករាំមួយ ឬពីរនាក់មានពាក់ស្នែងទន្សោងលើក្បាល និងមានកាយវិការរាំត្រាប់តាមសត្វទន្សោង ។

៣. របាំស្នែងទន្សោងស្ថិតនៅក្នុងទម្រង់សិល្បៈទី ៧ ។

៤. ទំនុកច្រៀងនៃរបាំស្នែង ទន្សោងមាន ៣ផ្នែក ។

ផ្នែកទី ១ : ទន្សោងស្នែងនប់ រកស៊ីតែយប់
ទន្សោងស្នែងនប់ ផ្លែឡើងពួនព្រៃ ។
ទន្សោងស្នែងកែក ស៊ីបែកពីហ្វូង
ទន្សោងស្នែងច្រូង វិធហ្វូងបែកខ្ចាយ ។
ទន្សោងគោបា ស៊ីបន្លាជង្គុំ
ទន្សោងព្រៃភ្នំ លេបក្រមុំទាំងមូល ។
(តាមឯកសារលោក រ. បារាជាត៍ ឆ្នាំ ១៩៤១)

ផ្នែកទី ២ : សូរិយាល្ងាចថ្ងៃ សូរិយាល្ងាចថ្ងៃ
ទន្សោងគោព្រៃ រកស៊ីជើងភ្នំ ។
តូចស៊ីដោយតូច ធំស៊ីដោយធំ
ស៊ីតាមជើងភ្នំ ល្អាស់ព្រេចខ្ចីល្អ ។
ស៊ីហើយវាជល់ ជល់គ្នាវីរវរ
សុទ្ធតែឡើងក អួតមានកម្លាំង ។
(តាមការចាំរបស់លោក កេត រឿន គ្រូនៅសាលាវិចិត្រសិល្បៈខេមរៈ)

ផ្នែកទី ៣ : បងដើរព្រៃស្តុក បងរុកព្រៃស្មាត
ដើរកាត់ព្រៃញាត លេចវាលចូលព្រៃ ។
ឡើងភ្នំចុះភ្នំ ថ្មដាធំក្រៃ
ទាំងបន្លាឈ្លៃ ល្អាស់ព្រេចលាស់ល្អ ។
ទន្សោងគោព្រៃ កៀងញ៉ីរវីរវរ
ល្អាស់ព្រេចលាស់ល្អ ស្រណោះខែពិសាខ ។
កន្ត្រែតៗអើយ ទន្សោងគោបា
លេបបន្លាជើងភ្នំ លេបក្រមុំទាំងមូល ។
ជំនោរខ្យល់បក់ ត្រជាក់ខ្យល់ជួន
កាប់ឫស្សីចងក្តួន ជូនប្អូនទៅស្រុក ។
កន្ទែងបងបាត់ បងកាត់មិនស្តាយ
បំណាច់ឃ្លាតឆ្ងាយ បងស្តាយតែប្អូនស្រី ។
(តាមឯកសារលោក ខួង អ៊ូច)

៥. អត្ថន័យនៃចម្រៀងរបាំងស្នែងទន្សោង គឺជាការច្រៀងរៀបរាប់ពីការរស់នៅចិញ្ចឹមជីវិតដែលអាស្រ័យរុក្ខជាតិ ធម្មជាតិព្រៃភ្នំ ជ្រលងដងអូរ ទៅតាមរដូវកាល ពេលវេលា ជាក្រុម ជាហ្វូង មានតូច មានធំ។ ចួនកាល គេឃើញមានទំនាស់រវាងគ្នានិងគ្នាផងដែរ ដោយការអួតអាងកម្លាំង អួតអាងឫទ្ធិអំណាច ... ។ ទន្ទឹមនឹងនេះ កវីតាក់តែងទំនុកនេះឡើងដើម្បីប្រៀបធៀបនឹងការរស់នៅរបស់មនុស្សក្នុងសង្គមដែលចួនកាលរួមរស់សុខសាន្តនឹងគ្នា ចួលកាលមានទំនាស់ទាស់ទែងគ្នាដោយភាពអួតអាងអំណាចទ្រព្យសម្បត្តិ បុណ្យសក្តិ ដោយការរំលោភសិទ្ធិគ្នាទៅវិញទៅមក ដោយការដណ្តើមផលប្រយោជន៍ ... ។

៦. ខ្ញុំយល់ថា ទំនុកច្រៀងនិងរបាំស្នែងទន្សោង ទោះជាបុព្វបុរសយើងបានបង្កើតឡើងមកច្រើនតំណមកហើយក៏ដោយ ក៏របាំនេះនៅតែមានតម្លៃរហូតដល់បច្ចុប្បន្ន។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញនូវតម្លៃអមត:សិល្ប:វប្បធម៌ខ្មែរ បង្ហាញឱ្យឃើញនូវស្នាដៃ ទេពកោសល្យ ទស្សន: និងផ្នត់គំនិតសង្គមពីអតីតកាលដ៏សម្បូណ៌បែបនិងប្រកបភាពឈ្លាសវៃរបស់បុព្វបុរសយើងដែលចេះច្នៃប្រឌិតបង្កើតសិល្ប:របាំ ដោយភ្ជាប់ទៅនឹងធម្មជាតិ។

៧. ក្នុងនាមកុលបុត្រធីតាខ្មែរ ខ្ញុំគិតថាអ្វីដែលជាមរតកវប្បធម៌ដ៏រុងរឿងពីដូនតា សុទ្ធតែបង្កប់នូវការអប់រំយ៉ាងជ្រាលជ្រៅឆ្លុះបញ្ចាំង ឬបង្ហាញនូវបទពិសោធន៍ ទស្សន:ផ្នត់គំនិតឧត្តមគតិមនុស្សសម័យមុន។ យើងទាំងអស់គ្នាគួរយកចិត្តទុកដាក់ថែរក្សាការពារនិងអភិរក្សមរតកដ៏មានតម្លៃនេះឱ្យនៅគង់វង្សជារៀងរហូត សមដូចពាក្យពំនោលថា "វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន"។



ការសង្ខេបអត្ថបទកាព្យជាពាក្យរាយ

១. ឥស្តិបំណង

- ប្រាប់បានពីខ្លឹមសារលម្អិតសំខាន់ៗក្នុងវគ្គនីមួយៗនៃអត្ថបទកាព្យ
- សង្ខេបអត្ថបទកាព្យមកជាអត្ថបទពាក្យរាយបានត្រឹមត្រូវ តាមរយៈការសួរត្រួតអាន និងការកំណត់ចំណុចសំខាន់ៗក្នុងវគ្គនីមួយៗ តាមរយៈការងារជាក្រុម
- បណ្តុះស្មារតីស្រឡាញ់ចូលចិត្តការសិក្សាកំណាព្យខ្មែរ និងចេះឱ្យតម្លៃលើស្នាដៃកាព្យល្បីៗរបស់បុព្វបុរសខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១២១-១២៤

៣. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូសរសេរចំណងជើងមេរៀន "ការសង្ខេបអត្ថបទកាព្យជាពាក្យរាយ"ដាក់លើក្តារខៀន រួចគ្រូសួរ :
  - តើអ្វីជាអត្ថបទកាព្យ ?

    ចម្លើយ : អត្ថបទកាព្យគឺជាអត្ថបទដែលកវីតាក់តែងនិពន្ធឡើងជាអត្ថបទរៀបរាប់ ពណ៌នារឿងរ៉ាវផ្សេងៗជាកំណាព្យទៅតាមលំនាំបទផ្សេងៗ ដែលមានការចាប់ចុងចួន ផ្ទួនរណ្តំ មានភាពពីរោះរណ្តំ ណែងណាងធ្វើឱ្យអ្នកស្តាប់ជក់ចិត្តចាប់អារម្មណ៍ ។
  - តើអ្វីជាអត្ថបទពាក្យរាយ ?

    ចម្លើយ : គឺជាអត្ថបទដែលអ្នកនិពន្ធបាននិពន្ធតាក់តែងឡើងជារឿងរ៉ាវផ្សេងៗតាមបែបសម្រាយ មិនមែនជាកំណាព្យ មិនមានការចាប់ចុងចួន គោរពក្បួនខ្នាត ដូចកំណាព្យទេ ពោលគឺជាអត្ថបទដែលអ្នកនិពន្ធសរសេររៀបរាប់ធម្មតា ជាពាក្យពេចន៍សម្រាយទៅតាមដំណើររឿងនីមួយៗទៅតាមមនោគតិ ឧត្តមគតិរបស់អ្នកនិពន្ធ ។
  - តើការសង្ខេបអត្ថបទកាព្យជាពាក្យរាយមានន័យដូចម្តេច ?

    ចម្លើយ : មានន័យថា ជាការសង្ខេបអត្ថបទដែលសរសេរជាកំណាព្យមកជាអត្ថបទសម្រាយធម្មតា ដោយមិនរក្សាទម្រង់កាព្យ មិនមានការចាប់ចុងចួន ផ្ទួន រណ្តំ ... ដូចកំណាព្យឡើយ ។

ខ. ការនិយាយ

- ឱ្យសិស្សអានសេចក្តីផ្តើមមេរៀន
- ឱ្យសិស្សអានអត្ថបទកាព្យដកស្រង់ទំព័រទី ១២១-១២២ និងអានសេចក្តីពន្យល់លម្អិតទាក់ទងចំណុចសំខាន់ៗនៃវគ្គទី ១ ដល់វគ្គទី ៨ ក្នុងសៀវភៅសិស្សទំព័រទី ១២២-១២៤ ជាឧទាហរណ៍ និងអត្ថបទសម្រាយគំរូ ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១២៤

ចម្លើយ :

១. សង្ខេបអត្ថបទដកស្រង់អំណានទី ១ "រឿងទុំទាវ" ក្នុងសៀវភៅសិស្សទំព័រទី ១០២-១០៦ ៖

និយាយពីបុរសម្នាក់ឈ្មោះទុំនៅខេត្តបាភ្នំ លុះធំពេញវ័យក៏បានត្រូវម្តាយនាំយកទៅឱ្យបួសរៀននៅវត្តវិហារធំ ជាមួយព្រះថៅអធិការ។ ទុំជាអ្នកមានវោហារប្រាជ្ញាឆ្លាតវាងវៃ ខិតខំរៀនចេះទាំងមន្តអាគម និងចេះធ្វើតោកលក់ផងរហូតបានបួសជាសាមណេរ។ ចំណែកពេជ្រ ក៏បានបួសរៀននៅទីនោះដែរ។ នេនទាំងពីរស្រឡាញ់គ្នា រាប់គ្នាជាបងប្អូន ហើយចេះធ្វើតោកលក់ដូចគ្នា។ នេនទាំងពីរសុទ្ធតែមានចំណេះដឹងរៀងៗខ្លួន ប្រកបដោយប្រាជ្ញាវៃឆ្លាត។ នេនទុំ មានវោហារប្រាជ្ញាខ្ពស់ មានសំឡេងពីរោះ រូបក្មេងខ្ចី ឯនេនពេជ្រមានជំនាញខាងផ្តុំប៊ី លេងភ្លេង។

លុះរដូវរងាមកដល់ នេនទាំងពីរនឹកអផ្សុកចង់ដើរចេញទៅលក់តោកឯក្រៅភូមិ ក៏ទៅលាព្រះថៅអធិការ។ ព្រះថៅអធិការបានអនុញ្ញាតហើយ បានផ្តែផ្តាំឱ្យនេនទាំងពីរឱ្យប្រយ័ត្នប្រយែងខ្លួន កុំឱ្យខូចកេរ្តិ៍ឈ្មោះនិងខុសវិន័យព្រះ ព្រោះខ្លួនជាសង្ឃ។ លុះធ្វើដំណើរដល់តំរួងឃ្មុំ នេនទាំងពីរក៏លក់តោកអស់ជាបណ្តើរៗ ហើយតែងតែមានញាតិញោមឆ្ងាយជិតចោមរោមទិញ ដោយសារទុំមានសម្តីពីរោះ និងថែមទាំងចេះមើលសាស្ត្រាទៀត។ នេនទុំចេះទេសន៍យ៉ាងពីរោះនិងចេះឡែបខាយពាក្យសម្តីធ្វើឱ្យក្មេងចាស់ប្រុសស្រីក្នុងភូមិមកចោមរោមស្តាប់។ នាងនោដែលជាភីលៀងនាងទាវ បានពួនស្តាប់រួចក៏ពាំនាំសព្ទវាចាទៅប្រាប់ទាវនិងម្តាយទាវថា មាននេនក្មេងសំឡេងពីរោះ ដើរលក់តោកនិងចេះទេសន៍សាស្ត្រាយ៉ាងពីរោះជក់ចិត្ត។ ទាវឮដូច្នេះ ក៏សុំម្តាយទៅស្តាប់ដែរ។ ម្តាយទាវមិនអស់ចិត្តក៏ទាញស្បែជណ្តប់ដើរទៅ មើលឃើញជាក់នឹងភ្នែកក៏ទូលសួរនិងនិមន្តនេនទុំទៅផ្ទះគាត់ដើម្បីឆាន់ស្លា។ នេនទុំបានស្តាប់រួចព្រមនិមន្ត រួចក៏ពិគ្រោះនឹងនេនពេជ្រថាលួមទៅដែរ តែសុំឱ្យនេនពេជ្រនៅមើលគោនិងរទេះផង។ នេនទាំងពីរក៏ពិចារណាផងដែរខ្លាចមានការជ្រុលជ្រួសខុសនឹងវិន័យ ក្រែងលោគ្រូជេរនៅពេលវិលត្រឡប់ទៅវត្តវិញ។ នេនពេជ្រទូន្មាននេនទុំឱ្យប្រុងប្រយ័ត្ន ព្រោះខ្លួនជាសង្ឃ ខ្លាចក្រែងចោះធ្លោយ កើតក្តីក្តាំ ដូចទំនៀមចាស់ស្តីមិនខុសថា "បើដើរឱ្យមានបួន ខ្លួនជាសង្ឃ តែបើដើរទៅក្តីនិងកេរចោះធ្លោយឱ្យមានប្រាំ" រួចនេនទុំសម្រេចចិត្តទៅតាមការនិមន្តរបស់ម្តាយទាវ។

២. កាលពីខែមេសា ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជាត្រូវធ្លាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជនគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់។ ប្រជាជនកម្ពុជាទាំងអស់សុទ្ធតែត្រូវបានអង្គការចោទជាអ្នកទោស(ខ្មាំង)។ អ្នកដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពុំបានប្រើប្រាស់ច្បាប់ទម្លាប់អ្វីទាំងអស់ក្នុងការដឹកនាំប្រទេស។ ពួកគេប្រើអំណាចយោរយៅផ្តាច់ការកាប់សម្លាប់ប្រជាជនឯងគ្មានត្រាប្រណី។ ពួកគេចង់ថាអ្វីគឺបានទាំងអស់។ សម្តីរបស់ពួកគេប្រៀបដូចសម្តីអាទិទេព។ គេចង់ឱ្យយំគឺត្រូវតែយំ ចង់ឱ្យពេបគឺត្រូវតែពេប ចង់ឱ្យអត់អាហារគឺអត់អាហារ។ ឯពាក្យថា "ស្មើ" គឺជាពាក្យដែលគេប្រើក្នុងការដែលពួកគេចង់បានរបស់របរអ្វីមួយពីប្រជាជន បើម្ចាស់មិនឱ្យនឹងត្រូវគេយកទៅសម្លាប់។ ម្យ៉ាងទៀតសូម្បីតែរបស់របរឬសម្ភារៈប្រើប្រាស់ដូចជា ខោអាវ នាឡិកា។ល។ គេពុំឱ្យប្រជាជនប្រើប្រាស់ទេ គឺត្រូវបានអង្គការស្មើយកទាំងអស់ នោះគឺជាការភូតភរតែប៉ុណ្ណោះរបស់អង្គការ តាមពិតពួកគេយកទៅប្រើយ៉ាងហ៊ឺហាសម្រាប់ខ្លួនឯងទៅវិញ។

ប្រធានអត្ថាធិប្បាយបែបពន្យល់

១. វត្ថុបំណង

- ប្រាប់បានពីប្រភេទនិងទម្រង់សំណេរអត្ថាធិប្បាយបែបពន្យល់ តាមរយៈគម្រោងសំណេរគំរូ
- សរសេរតែងសេចក្តីតាមបែបពន្យល់បានត្រឹមត្រូវ
- បណ្តុះបំណិនសំណេរអត្ថាធិប្បាយពន្យល់ ដើម្បីជាគ្រឹះសំខាន់ក្នុងការប្រើប្រាស់គមនាគមន៍ភាសានិងការសរសេរបានល្អត្រឹមត្រូវនិងប៉ិនប្រសប់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១២៥-១២៨

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងសំណេរ "ប្រធានអត្ថាធិប្បាយបែបពន្យល់" ដាក់លើក្តារខៀន
- គ្រូឱ្យសិស្សអានសេចក្តីផ្តើមសំណេរនិងគម្រោងតែងគំរូក្នុងសៀវភៅសិស្ស
- គ្រូសួរសំណួរ ៖
  - តើគម្រោងតែងសេចក្តីមានប៉ុន្មានផ្នែកធំៗ ?

    ចម្លើយ : គម្រោងតែងសេចក្តីមានបីផ្នែកធំៗ គឺសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ឬបញ្ចប់សេចក្តី ។
  - តើនៅក្នុងសេចក្តីផ្តើមមានអ្វីខ្លះ ?

    ចម្លើយ : ក្នុងសេចក្តីផ្តើមមានបីចំណុចសំខាន់ៗគឺ លំនាំបញ្ហា ចំណុលបញ្ហា និងចំណោទបញ្ហា ។
  - តើនៅតួសេចក្តីមានចំណុចសំខាន់ៗអ្វីខ្លះ សម្រាប់សរសេរបកស្រាយ ?

    ចម្លើយ : នៅតួសេចក្តីមានចំណុចសំខាន់ៗដូចជា ឃ្លាភ្ជាប់សេចក្តី ការពន្យល់ពាក្យពិបាកឬពាក្យគន្លឹះ កន្សោមពាក្យ ឬល្បះ ពន្យល់ន័យប្រធាន ការបកស្រាយប្រធាន និងការសរុបមតិ ។
  - តើនៅបញ្ចប់សេចក្តី ឬសេចក្តីបញ្ចប់ អ្នកសរសេរត្រូវសរសេរយ៉ាងដូចម្តេច ?

    ចម្លើយ : គឺត្រូវមានការវាយតម្លៃប្រធាន និងការបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនចំពោះទស្សនៈរបស់ប្រធាន ... ។

ខ. ការអនុវត្ត

- គ្រូឱ្យសិស្សធ្វើលំហាត់សំណេរតែងសេចក្តីបែបប្រធានពន្យល់ក្នុងសៀវភៅទំព័រទី ១២៨ ។
- គម្រោង : គ្រូឱ្យសិស្សពិនិត្យលើគម្រោងតែងគំរូក្នុងសៀវភៅសិស្សទំព័រ ១២៥-១២៨ឡើងវិញ
- ការព្រាង :
  - គ្រូណែនាំសិស្សឱ្យធ្វើគម្រោងឬប្លង់តែងតាមលំនាំ គម្រោងតែងគំរូក្នុងសៀវភៅសិស្សទំព័រ១២៥-១២៨

- ណែនាំសិស្សឱ្យរកគំនិត ហេតុផល អំណះអំណាង ឬភ័ស្តុតាងសម្រាប់បញ្ជាក់លើគំនិតប្រធាន "ថាដើរឱ្យមានបួនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ បើដើរទៅក្តីឧបាសកនោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ" ។ ដោយបញ្ជាក់ប្រាប់សិស្សថា "ដើរឱ្យមានបួនខ្លួនជាសង្ឃ" មានន័យដូចម្តេច "កេរកោះថ្លោះធ្លោយឱ្យមានប្រាំ" គឺអ្វីខ្លះ និងគួរលើកឧទាហរណ៍ឬអំណះអំណាង ដើម្បីបញ្ជាក់ ។
- ណែនាំសិស្សរៀបចំគំនិតសរសេរបកស្រាយប្រធានទៅតាមគម្រោងតែងគំរូក្នុងសៀវភៅសិស្សទំព័រទី ១២៥-១២៨ ដោយមានការព្រាងលើកទី ១
- ណែនាំសិស្សសរសេរព្រាងលើកទី ២ និងលើកទី ៣ ដោយផ្ទៀងផ្ទាត់លើលំដាប់គំនិតឬខ្លឹមសារ ពិនិត្យទៅលើកំហុសឆ្គងអក្ខរាវិរុទ្ធ ។
- ការរៀបរៀងនិងកែលម្អ
- ណែនាំសិស្សឱ្យសរសេរសម្រេចសំណេរឡើងវិញ ដោយផ្ទៀងផ្ទាត់ឡើងវិញលើ ៖
  + ឃ្លា ល្បះ ពាក្យពេចន៍ប្រើប្រាស់ ចៀសវាងកំហុសអក្ខរាវិរុទ្ធ
  + តើខ្លឹមសារគំនិតមានអំណះអំណាងបញ្ជាក់សមហេតុផលឬទេ ?
  + តើការបកស្រាយស្របនឹងប្រធានហើយឬនៅ ?
  + តើសំណេររបស់អ្នកមានឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ និងមានការសរុបដែរឬទេ ?
  + តើនៅបញ្ចប់សេចក្តីអ្នកមានការចាប់អារម្មណ៍ដូចម្តេច ចំពោះមតិប្រធានដែលលើកឡើង ?
- ការសរសេរសម្រេច : បន្ទាប់ពីកែលម្អរួច គ្រូណែនាំសិស្សសរសេរសម្រេចនិងដាក់ពិន្ទុ ។

គ. ការវាយតម្លៃ

លោកគ្រូ-អ្នកគ្រូដាក់កិច្ចការឱ្យសិស្សធ្វើដើម្បីវាយតម្លៃកម្រិតយល់ដឹងរបស់សិស្សទៅលើតែងសេចក្តីអត្ថាធិប្បាយពន្យល់ ។

ឧទាហរណ៍ :

១. ប្រធាន : ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ លោករដ្ឋមន្ត្រីសម្លឹងមើលមុខសម ហើយនិយាយឡើងយឺតៗ ៖ "មនុស្សយើងត្រូវមានសិទ្ធិសេរីភាពស្មើគ្នា តែសិទ្ធិសេរីភាពនោះត្រូវមានព្រំដែន" ។
ចូរបកស្រាយសំដីលោករដ្ឋមន្ត្រីខាងលើដោយលើកឧទាហរណ៍ក្នុងរឿងនិងក្នុងសង្គមជាក់ស្តែងមកបញ្ជាក់ ។

២. ប្រធាន : ក្នុងរឿងចៅកែចិត្តចោរ ពូហាំបានបញ្ជាក់ថា "លុយ ៥០០រៀលចាយតែមួយភ្លែតអស់ហើយ ។ រីឯសេចក្តីយុត្តិធម៌ បើយើងយកមកដាក់ក្នុងខ្លួនបានហើយមិនចេះសាបសូន្យទេ" ។
ចូរបកស្រាយសំដីពូហាំខាងលើ ដោយលើកឧទាហរណ៍មកបញ្ជាក់ ។



ការគោរពបូជា

ការគោរពបូជា គឺជាសេចក្តីលំអុតលំឱន ការប្រតិបត្តិតាមឬជំណើរយកចិត្តទុកដាក់ចំពោះឱវាទ ការប្រព្រឹត្តតាមឱវាទរបស់បុគ្គលគួរជាទីគោរពដូចជា ការគោរពជំនឿ ទំនៀមទម្លាប់ ប្រពៃណី សាសនា។

ក្នុងមេរៀននេះ សិស្សនឹងសិក្សាពីការគោពបូជា។ ការគោរពបូជាមានឥទ្ធិពលយ៉ាងធំធេងនិងចាក់គ្រឹះយ៉ាងរឹងមាំនៅក្នុងផ្នត់គំនិតសង្គមខ្មែរតាំងពីបុរាណរហូតដល់បច្ចុប្បន្ន។ មេរៀននេះ មានចំណងឆ្លុះបញ្ចាំងឱ្យឃើញឡើងវិញនូវលក្ខណៈនិងឥទ្ធិពលនៃការគោរពបូជានៅក្នុងសង្គមខ្មែរ ដែលដោតជ្រៅតាមរយៈស្មាដៃរឿងមួយចំនួនទាក់ទងនឹងសាសនាព្រះពុទ្ធនិងសាសនាព្រាហ្មណ៍។ សិស្សនឹងចេះសិក្សាពិចារណា វិភាគទៅលើបញ្ហាសាសនាក្នុងការគោរពបូជានិងចេះទាញយកហេតុផលល្អៗសម្រាប់អភិវឌ្ឍគំនិតក្នុងការរស់នៅប្រកបដោយជោគជ័យ។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិន្នាសាស្ត្រ	ទិន្នាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	១២៣	១២៩
• បំណិន : លក្ខណៈអក្សរសិល្ប៍	១ម៉ោង	២ម៉ោង	១២៤-១២៦	១៣០
• រំលឹកបញ្ញត្តិ : លក្ខណៈសម្គាល់រឿងបែបព្រាហ្មណ៍ និយមនិងពុទ្ធនិយម	១ម៉ោង	១ម៉ោង	១២៧-១២៨	១៣២
• អំណានទី ១ : លទ្ធិផ្សេងៗក្នុងសាសនាព្រាហ្មណ៍	៣ម៉ោង	៤ម៉ោង	១២៩-១៣០	១៣៤
• វេយ្យាករណ៍ : អំពីព្យញ្ជនៈទោល	២ម៉ោង	២ម៉ោង	១៣១-១៣២	១៣៨
• អំណានទី ២ : គោលគំនិតសំខាន់ៗនៃសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា	០ម៉ោង	៤ម៉ោង	១៣៣-១៣៥	១៤១
• ការនិយាយ : ប្រៀបធៀប	១ម៉ោង	២ម៉ោង	១៣៦	១៤៦
• ការស្តាប់ : រឿងសុវណ្ណសាម	២ម៉ោង	២ម៉ោង	១៣៧-១៤២	១៤៧
• សំណេរ : តែងសេចក្តីប្រៀបធៀប	២ម៉ោង	៣ម៉ោង	១៤៣-១៤៦	១៤៨

១. សិក្ខាចំណងជើង

- គ្រូឱ្យសិស្សអានចំណងមេរៀន បន្ទាប់មកសរសេរចំណងជើងមេរៀន "ការគោរពបូជា"ដាក់លើក្តារខៀន រួចសួរ ៖
  - តើចំណងជើងនេះមានន័យដូចម្តេច ?

  ចម្លើយ : មានន័យថា ការប្រតិបត្តិឬអនុវត្តតាមដំណើរ យកចិត្តទុកដាក់ចំពោះឱវាទ ការប្រព្រឹត្តិតាមឱវាទរបស់បុគ្គលគួរជាទីគោរព ... ។

២. សិក្ខាលើរូបភាព

- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ១២៩ រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ ? កំពុងធ្វើអ្វី ? នៅឯណា ?

  ចម្លើយ : ឃើញរូបភាពលោកជំទាវ ប៊ុនរ៉ានីហ៊ុនសែននិងអាចារ្យ ព្រមទាំងឯកឧត្តមលោកជំទាវ លោក លោកស្រី នាងកញ្ញា ព្រមទាំងប្រជាពលរដ្ឋខ្មែរជាច្រើនកំពុងប្រារព្ធពិធីសែនព្រេននៅទីធ្លាមុខប្រាសាទព្រះវិហារ ។

លក្ខណៈអក្សរសិល្ប៍

១. វត្ថុបំណង

- ប្រាប់បានលក្ខណៈអក្សរសិល្ប៍តាមរយៈការអានខ្លឹមសារមេរៀននិងឧទាហរណ៍បញ្ជាក់
- បង្ហាញលក្ខណៈអក្សរសិល្ប៍តាមរយៈការធ្វើលំហាត់ក្នុងរឿងរាមកេរ្តិ៍ រឿងព្រះវេស្សន្តរ និងរឿងចៅកែចិត្តចោរ
- មានបំណិនសម្គាល់និងចេះកត់ចំណាំពីលក្ខណៈផ្សេងៗរបស់អក្សរសិល្ប៍ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៣០-១៣១

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងបំណិន "លក្ខណៈអក្សរសិល្ប៍" ដាក់លើក្តារខៀន រួចឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៣០-១៣១ អានត្រង់ចំណុច ១-២ និងឧទាហរណ៍បញ្ជាក់ :
- គ្រូសួរសំណួរ ៖
  - ដូចម្តេចហៅថា លក្ខណៈអក្សរសិល្ប៍ ?

    ចម្លើយ : លក្ខណៈអក្សរសិល្ប៍ គឺជាការសម្គាល់ពីអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងនូវលក្ខណៈដោយឡែករបស់ជាតិសាសន៍នីមួយៗ ដោយផ្អែកលើតឹកតាងរឿងរ៉ាវផ្សេងៗ ។
  - តើអក្សរសិល្ប៍មានលក្ខណៈអ្វីខ្លះ ?

    ចម្លើយ : លក្ខណៈអក្សរសិល្ប៍មានដូចជា លក្ខណៈមនុស្ស លក្ខណៈជាតិ លក្ខណៈអន្តរជាតិ លក្ខណៈសង្គម ។ល។
  - តើលក្ខណៈមនុស្សក្នុងអក្សរសិល្ប៍មានន័យដូចម្តេច ?

    ចម្លើយ : លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍គឺជាការសិក្សាអំពីមនុស្សក្នុងសម័យកាលដ៏ជាក់លាក់ណាមួយ ។ លក្ខណៈមនុស្សបង្ហាញឱ្យឃើញតាមរយៈទង្វើ សកម្មភាព ពាក្យសម្តី អាកប្បកិរិយា មនោសញ្ចេតនា ចិត្តគំនិត ... របស់មនុស្ស ឬតួអង្គក្នុងសង្គមឬក្នុងអក្សរសិល្ប៍និងរឿងរ៉ាវផ្សេងៗ ។
  - តើលក្ខណៈសង្គមក្នុងអក្សរសិល្ប៍មានន័យដូចម្តេច ?

    ចម្លើយ : លក្ខណៈសង្គមក្នុងអក្សរសិល្ប៍ គឺជាការបង្ហាញនូវរាល់ខ្លឹមសារអត្ថបទរឿងរ៉ាវនានា ដែលបានលើកយកបញ្ហាមនុស្សនៅក្នុងសង្គមណាមួយមកចោទនិងស្រាយ ស្របតាមសភាពលក្ខណៈនៃសង្គមនីមួយៗ ។ បញ្ហាសង្គមដែលអ្នកនិពន្ធលើកឡើង គឺជាមតិយោបល់ ឬគំនិតទាំងឡាយដែលតំណាងឱ្យព្រឹត្តិការណ៍សង្គមទាំងមូល ។

ខ. ការហ្វឹកហាត់

- គ្រូឱ្យសិស្សបង្ហាញលក្ខណៈអក្សរសិល្ប៍ក្នុងលំហាត់ទី ១ និងទី ២ ក្នុងសៀវភៅសិស្សទំព័រទី ១៣១ ។

ចម្លើយ :

១. បង្ហាញលក្ខណៈមនុស្សនិងលក្ខណៈសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍ ៖

ក. រឿងរាមកេរ្តិ៍

នៅក្នុងរឿងរាមកេរ្តិ៍ ទោះបីអ្នកនិពន្ធបង្ហាញនូវលក្ខណៈតួអង្គមានគ្រប់ប្រភេទតាំងពីតួអង្គមនុស្ស សត្វ អារក្ខ អ្នកតា ទេវតា យ៉ាងច្រើនលើសលុបយ៉ាងណាក្តី ក៏សុទ្ធតែតំណាងឱ្យមនុស្សក្នុងសង្គមគ្រប់ស្រទាប់វណ្ណៈ។ លក្ខណៈមនុស្សក្នុងរឿងរាមកេរ្តិ៍បានឆ្លុះបញ្ចាំងនូវលក្ខណៈរួមរបស់មនុស្សដូចជា ព្រះរាមសប្បាយរីករាយ ឬខឹងប្រច័ណ្ឌនាងសីតាជាមួយក្រុងរាពណ៍ ព្រះរាមយំសោកនឹករឭកដល់នាងសីតា។ ព្រះរាមចេះខឹងនិងឈ្លោះជាមួយកូនក្មេង(រាមលក្ឃ្មណ៍ និងជបលក្ឃ្មណ៍ជាដើម)។

លក្ខណៈសង្គមក្នុងរឿងរាមកេរ្តិ៍ បានឆ្លុះបញ្ចាំងឱ្យឃើញនូវខ្លឹមសាររឿងត្រង់ចំណុចខ្លះដែលអ្នកនិពន្ធបានលើកយកបញ្ហាចោទ និងស្រាយក្នុងរឿងមកបង្ហាញដូចជា បញ្ហាចោទទៅលើការស្តងរាជសម្បត្តិ ដែលព្រះបាទទសរថលើកឱ្យព្រះរាមឡើងស្តងរាជ ប៉ុន្តែត្រូវបាននាងកៃកេសីជំទាស់ ដោយយកពាក្យសត្យ(ពាក្យពិត) ដែលព្រះបាទទសរថធ្លាប់សន្យានឹងនាងកៃកេសីថានឹងឱ្យព្រះភរិវតឡើងស្តងរាជ ប្រសិនបើព្រះអង្គច្បាំងឈ្នះព្រះអាទិត្យ។ អ្នកនិពន្ធបានស្រាយមកវិញដោយឱ្យព្រះបាទទសរថយល់ព្រមតាមសំណើនាងកៃកេសី ហើយបណ្តេញព្រះរាមឱ្យទៅបួសក្នុងព្រៃមួយរយៈសិនដែលជាវិធីដោះស្រាយមួយក្នុងសង្គម ដើម្បីបញ្ចៀសនូវទំនាស់ ឬសង្គ្រាមដោយសារវាជ្យសម្បត្តិ។ បញ្ហាទំនាស់រវាងព្រះលក្ឃ្មណ៍និងនាងសូបនខាដោយសារតែសេចក្តីស្នេហារបស់នាងទៅលើព្រះលក្ឃ្មណ៍ នាងចេះតែតាមរំខានឆាទៅព្រះលក្ឃ្មណ៍។ ព្រះលក្ឃ្មណ៍មិនព្រមរហូតដល់ទ្រាំមិនបានក៏កាត់ត្រចៀកនាង ហើយនាងខឹងក៏ទៅប្រាប់បងប្រុសនាង ដែលធ្វើឱ្យមានទំនាស់កើតឡើងជាដើម។ ទាំងនេះគឺសុទ្ធតែឆ្លុះបញ្ចាំងឱ្យឃើញនូវទង្វើ និងសកម្មភាពដែលតែងតែកើតមានពិតក្នុងសង្គមរវាងទំនាក់ទំនងមនុស្សក្នុងសង្គមដូចជា ស្នេហាមនុស្សប្រុសស្រី ការសងសឹកនឹងការរំលោភអំណាចនានា(រាមាសងសឹកព្រះរាមដោយសារព្រះលក្ឃ្មណ៍កាត់ត្រចៀកនាងសូបនខា ជាប្អូនស្រីខ្លួន)។

ខ. រឿងព្រះវេស្សន្តរ

នៅក្នុងរឿងព្រះវេស្សន្តរ តាមរយៈផ្ទៃរឿងទាំងមូលយើងឃើញថា អ្នកនិពន្ធបានបង្ហាញតួអង្គព្រះបាទវេស្សន្តរដែលជាព្រះពោធិ៍សត្វដែលបំពេញទានបារមីនឹងបានត្រាស់។ តែទោះជាយ៉ាងណា ព្រះវេស្សន្តរបង្ហាញពីលក្ខណៈមនុស្សក្នុងសង្គមដូចជានៅពេលព្រះអង្គធ្វើបុត្របរិច្ចាគ គឺជាព្រះពុទ្ធ ជាខ្ញុំបម្រើតាជូជកទៅហើយក្តី ក៏ទីបំផុតព្រះអង្គខឹងនឹងជូជក វាយដំ ធ្វើបាបជាលីក្រិស្នា រហូតព្រះអង្គទ្រាំមិនបានស្ទុះយកសរបម្រុងប្រហារតាជូជក។ ចំណុចត្រង់នេះ បង្ហាញឱ្យឃើញច្បាស់ពីលក្ខណៈមនុស្សរបស់តួអង្គពោធិ៍សត្វដែលអត់ទ្រាំមើលទុក្ខសោកវេទនារបស់កូនព្រះអង្គមិនបាន។ អ្នកនិពន្ធបានយកសង្គមលក្ខណៈឬលក្ខណៈសង្គមនៃសាច់រឿងនេះ ទៅស្រាយវិញតាមលក្ខណៈសង្គមដែលស្ថិតក្នុងឥទ្ធិពលនៃពុទ្ធសាសនា ដែលធ្វើឱ្យចិត្តតួអង្គវេស្សន្តរសូបវិញ ដោយការរំលត់កំហឹងប្រកបដោយសន្តិវិធី និងដោយចិត្តខន្តី អហិង្សាតាមគន្លងព្រះពុទ្ធសាសនា ដែលជាវិធីដោះស្រាយមួយដ៏ល្អតាមលក្ខណៈព្រះពុទ្ធសាសនា។

២. បង្ហាញលក្ខណៈសង្គមតាមរយៈស្នាដៃរឿង "ថៅកែចិត្តចោរ" ៖

តាមរយៈអត្ថបទដកស្រង់រឿងថៅកែចិត្តចោរ ក្នុងសៀវភៅសិស្សទំព័រទី ១៣១នេះ បានបង្ហាញឱ្យឃើញនូវលក្ខណៈសង្គមត្រង់ចំណុចដែលថៅកែបានជួលពូហាំឱ្យបុកឡានថៅកែហុងលី ហើយសន្យាឱ្យលុយពូហាំមួយម៉ឺនរៀល។ ប៉ុន្តែថៅកែមិនគ្រាន់តែមិនឱ្យប្រាក់ពូហាំតាមសន្យា បែរជាចោទពូហាំថាបុកគេរហូតដល់ស្លាប់មនុស្សបីនាក់ទៀត។ ទោះបីពូហាំខំអង្វរកថាគាត់ត្រូវការលុយដើម្បីផ្គត់ផ្គង់គ្រួសារក៏ដោយ ក៏ថៅកែនៅតែប្រកែកមិនព្រមឱ្យដាច់ខាត។ វគ្គដកស្រង់នេះ ឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវសង្គមលក្ខណៈឬលក្ខណៈសង្គមមួយ ដែលពន្លេចឱ្យឃើញការជិះជាន់ កេងប្រវ័ញ្ចរបស់ថៅកែមកលើកម្មករ អំពើរំលោភសីលធម៌ និងច្បាប់សង្គមរបស់អ្នកមានប្រាក់មួយចំនួន និងអយុត្តិធម៌សង្គម។ ថៅកែក្នុងរឿងនេះជាតំណាងថៅកែដទៃទៀតដែលមានគំនិតកេងប្រវ័ញ្ចមកលើកម្មករខ្លួនដោយជារឿយៗថៅកែប្រើកម្មករឱ្យបម្រើនូវអំពើលោភលន់ប្រណាំងប្រជែងលើដៃគូ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន មិនទទួលខុសត្រូវលើទង្វើរបស់ខ្លួន។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សឆ្លើយដោយមានអំណះអំណាងគ្រប់គ្រាន់និងសមហេតុផលក្នុងការបកស្រាយពីលក្ខណៈមនុស្សនិងលក្ខណៈសង្គមដែលមានក្នុងលំហាត់ទី ១និងទី ២ ក្នុងសៀវភៅសិស្សទំព័រទី ១៣១ និងកែលម្អចម្លើយសិស្សឱ្យបានត្រឹមត្រូវ។
- គ្រូដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ ដោយឱ្យសិស្សរកលក្ខណៈមនុស្សនិងលក្ខណៈសង្គមក្នុងរឿងទុំទាវ។

រំលឹកបញ្ញត្តិ : លក្ខណៈសម្គាល់រឿងបែបព្រាហ្មណ៍និយម និងពុទ្ធនិយម

- គ្រូឱ្យសិស្សរំលឹកបញ្ញត្តិលក្ខណៈសម្គាល់រឿងបែបពុទ្ធនិយម រឿងបែបព្រាហ្មណ៍និយមក្នុងសៀវភៅសិស្ស ទំព័រទី ១៣២-១៣៣ ដោយឱ្យសិស្សអានដោយស្ងៀមស្ងាត់រៀងៗខ្លួន ។
- គ្រូឱ្យសិស្សឆ្លើយសំណួរ

១. ដូចម្តេចហៅថា អក្សរសិល្ប៍បែបព្រាហ្មណ៍និយម ? តើអក្សរសិល្ប៍បែបនេះមានលក្ខណៈសម្គាល់ដូចម្តេច ?

ចម្លើយ : លក្ខណៈសម្គាល់អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយមមាន ៖

ក. ផ្តើមរឿង

ការផ្តើមរឿងចាប់ផ្តើមឡើងដោយការបង្ហាញពីឈ្មោះរបស់អាទិទេពធំៗ ទាំងបីដូចជាព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ ពិធីបូជាយញ្ញ ឬពិធីសាសនាផ្សេងៗទៀត ។

ឧទាហរណ៍ : ក្នុងរឿងរាមកេរ្តិ៍ អ្នកនិពន្ធផ្តើមរឿងដោយរៀបរាប់ពីយក្សកាកនាសូរកាឡាខ្លួនជាសត្វក្អែកហើរមកចឹកនំខានហោមពិធីរបស់ឥសីពិស្វាមិត្រៈ "ដងនោះមានអសុរសា មានឈ្មួយនាមា ហៅកាកនាសូរស្តែង ។ ឮស័ព្ទសង្ខធុជថ្កើងថ្កាន ព្រតព្រះគម្ពែង ឥសូរដ៏រាមឬទ្ធា ។ អសុរនោះនិរ-មិត្ររូបាជាកាកមួយសា ហោះហើរនូវតេជបីពន្លឺក ។ មកចឹកហោម សាស្ត្រាធម្មិក ឮស័ព្ទគគ្រឹក ស្លឹកស្មឹភ្ញីរ៉ុះរោយ ។ ស្រែកស័ព្ទកាកនោះឮឆ្ងាយ ធុជធោងព្រាត់ព្រាយ ក៏ភិតពួនពឹងនៅនិត្យ..." ។

ខ. តួរឿង

- តួអង្គ : ជាអាទិទេព ឬអវតារនៃព្រះវិស្ណុមកយោនយកកំណើតជាមនុស្សជាបុរសអស្ចារ្យ និងជានារីអស្ចារ្យ ឯតួអង្គផ្សេងទៀតមានឥសី ទេវតា យក្ស គ្រុឌ ... ។ល ។
- ដំណើររឿង : ដំណើររឿងមានភាពអច្ឆរិយៈដូចជា ជប ប្រោះ ហោះហើរ ផ្លែងសរ ... ។
- ទីកន្លែង : ព្រៃហោមពាន្ត ឋានមនុស្ស ស្ថានសួគ៌ ស្ថានបាតាល ស្ថានសិម្ពលី(គ្រុឌ) ។
- ដំណោះស្រាយបញ្ហា : ដោះស្រាយបញ្ហាដោយយុទ្ធវិធីឬសង្គ្រាម ។
- បញ្ហាទំនាស់ : ទំនាស់កើតឡើងរវាងសភាវៈល្អនិងសភាវៈអាក្រក់ ។
- ឧត្តមគតិរឿង ៖
  + អប់រំមនុស្សឱ្យជឿលើអាទិទេព
  + អប់រំឱ្យមនុស្សមានជំនឿថា ទុក្ខសោក សំណាងល្អអាក្រក់របស់ខ្លួនបានមកពីអាទិទេព ជាអ្នកកំណត់ (ព្រហ្មលិខិត) ។

គ. បញ្ចប់រឿង

ការបញ្ចប់រឿងបែបព្រាហ្មណ៍និយម គឺតួអង្គតំណាងអាទិទេព (សភាវៈល្អ) មានជ័យជំនះលើសភាវៈអាក្រក់ យក្ស អសុរៈ ។ល ។

២. ដូចម្តេចហៅថា អក្សរសិល្ប៍បែបពុទ្ធនិយម ? តើមានលក្ខណៈសម្គាល់ដូចម្តេច ?

ចម្លើយ : អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមជាអត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា គឺការលើកយកសកម្មភាពរបស់ពោធិសត្វក្នុងការកសាងបារមី ឬដែលបានលើកយកទស្សនៈសំខាន់ៗក្នុងពុទ្ធសាសនាដូចជាបញ្ហាកម្ម ផល បុណ្យ បាប ជាដើមមកបង្ហាញ។ អក្សរសិល្ប៍បែបពុទ្ធនិយមមានលក្ខណៈដូចតទៅ ៖

ក. ផ្តើមរឿង

រឿងផ្តើមឡើងដោយធ្វើបទនមស្ការ និងមានពាក្យថាមានតំណាលថា ព្រះពុទ្ធគង់នៅក្នុងអារាមណាមួយទ្រង់សម្តែងឡើងនូវរឿងអតីតជាតិរបស់ព្រះអង្គទៅកាន់សាវក ឬពុទ្ធបរិស័ទ ។ល។

ខ. តួរឿង ឬដំណើររឿង

- តួអង្គ : តួអង្គប្រុសជាពោធិសត្វ ឯតួអង្គស្រីជាកន្សែសារពេជ្ជ។ តួអង្គរងមានមនុស្ស ទេវៈ អសុរៈ ... ។
- ទីកន្លែង : ដំណើររឿងប្រព្រឹត្តទៅនៅនគរណាមួយ ព្រៃហោមពាន្ត ឋានទាំង បី ... ។
- បញ្ហាទំនាស់ : ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស ទំនៀមទម្លាប់ កម្មពៀរ អំពើ បាប ... ។
- ដំណោះស្រាយបញ្ហា : ព្យាយាមតស៊ូប្រឹងប្រែងដោយយកសីលធម៌ ខន្តីការសន្តោសប្រណី មិនប្រើហិង្សា ដើម្បីដោះស្រាយបញ្ហាជានិច្ច ។
- ឧត្តមគតិរឿង : អប់រំមនុស្សឱ្យស្គាល់និងជឿបុណ្យបាប ឱ្យធ្វើអំពើល្អ ខំប្រឹងតស៊ូព្យាយាមដោយជឿជាក់លើខ្លួនឯង ។

គ. បញ្ចប់រឿង

ការបញ្ចប់រឿងដោយមានការសរជាតិរបស់តួអង្គព្រះពោធិសត្វនិងកន្សែសារពេជ្ជ ។



លទ្ធិផ្សេងៗក្នុងសាសនាព្រាហ្មណ៍

១. វត្ថុបំណង

- ប្រាប់បានពីប្រភពអត្ថបទ តួអង្គ លក្ខណៈមនុស្សនិងតម្លៃអប់រំក្នុងអត្ថបទតាមរយៈការសិក្សាអត្ថបទអំណាន ដកស្រង់រឿងរាមកេរ្តិ៍ខ្សែទី ១
- កំណត់បានពីមូលន័យនិងគំនិតសំខាន់ៗក្នុងអត្ថបទ តាមរយៈការឆ្លើយសំណួរក្នុងអត្ថបទ
- មានស្មារតីយល់ដឹងទៅលើបញ្ហាលទ្ធិសាសនានានាក្នុងសាសនាព្រាហ្មណ៍និងអភិវឌ្ឍគំនិតបានល្អត្រឹមត្រូវទៅលើបញ្ហាជំនឿសាសនាបានល្អប្រសើរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៣៤-១៣៧
- ដកស្រង់រឿងរាមកេរ្តិ៍ខ្មែរ ខ្សែទី ១ ទំព័រទី ១-១១ របស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ។

៣. ដំណាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូសរសេរចំណងជើងអំណាន "លទ្ធិផ្សេងៗក្នុងសាសនាព្រាហ្មណ៍" ដាក់លើក្តារខៀន រួចសួរសំណួរ ៖
  - ដូចម្តេចហៅថា លទ្ធិ ?

    ចម្លើយ : ការឃើញ សេចក្តីយល់ឃើញ សេចក្តីប្រកាន់ជំនឿ ជំនឿសាសនា ការប្រកាន់តាមយោបល់របស់ខ្លួន ឬតាមទម្លាប់ ពិធីបែបបទ ការនិយម ...) ។
  - ដូចម្តេចហៅថា សាសនា ?

    ចម្លើយ : សាសនា គឺជាពាក្យបណ្តាំ ពាក្យផ្តាំផ្ញើ ពាក្យប្រៀនប្រដៅ ពាក្យបង្គាប់ ពាក្យបង្គាប់បញ្ជា ជាលទ្ធិ ... ។
  - តើសាសនាព្រាហ្មណ៍មានន័យដូចម្តេច ?

    ចម្លើយ : គឺជាសាសនាដែលពួកព្រាហ្មណ៍កំណត់តាមលទ្ធិបុរាណពីព្រេងនាយប្រកាន់យកឬមានជំនឿជាក់ទៅលើអ្វីដែលថាសាសនានេះដែលកើតពីព្រះឱស្ឋព្រហ្ម ... ។
  - តើលទ្ធិផ្សេងៗក្នុងព្រាហ្មណ៍សាសនាមានអ្វីខ្លះ ?

    ចម្លើយ : លទ្ធិផ្សេងៗក្នុងសាសនាព្រាហ្មណ៍ឬសាសនាព្រាហ្មណ៍មានដូចជាការជឿទៅលើការធ្វើពិធីផ្សេងៗ ដូចជាហោមពិធីគីពិធីសែនទេវតា ពិធីបូជាយញ្ញ ។ល ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ១៣៤ រួចសួរ ៖
  - តើនេះជារូបភាពអ្វី ?

    ចម្លើយ : នេះជារូបភាពផ្ទាំងគំនូរ ក្នុងបរិវេណវត្តមួយ ។
  - តើរូបភាពនេះមានន័យដូចម្តេច ?

    ចម្លើយ : រូបភាពនេះមានន័យថា វត្តគឺជាទីកន្លែងសម្រាប់គោរពប្រតិបត្តិខាងសាសនា ។
- ឱ្យសិស្សសិក្សាពាក្យគន្លឹះក្នុងទំព័រទី ១៣៤ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ១៣៥
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៣៧
- គ្រូឱ្យសិស្សអានអត្ថបទក្នុងសៀវភៅសិស្សទំព័រទី ១៣៤-១៣៧ ដោយស្ងៀមស្ងាត់ ។

គ. ការពង្រឹងអំណាន

ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៣៧ ៖

ចម្លើយ :

១. អត្ថបទខាងលើនេះមានប្រភពដកស្រង់ចេញពីរឿងរាមកេរ្តិ៍ខ្មែរទី ១ ទំព័រទី ១១របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ អត្ថបទនេះមានលំនាំបទសំរេប បទសំណាដើតហើយច្រេះ បទច្រេះជុក បទដើត បទសំណាខម បទសម្តេចភាណ បទសំណាខរ ។

២. តួអង្គក្នុងអត្ថបទនេះមានតួអង្គ ព្រះភិរុត កាកនាសូរ ព្រះឥសូរ ឥសីពិស្វាមិត្រ ព្រះនរាយណ៍ ព្រះបាទទសរថ ព្រះរាម ព្រះលក្ឃ្មណ៍ ព្រះចៅក្រុងមិថិលា ព្រះនាងសីតា ព្រះសុរិយាធុជ ព្រះរាម ។

៣. អត្ថបទនេះមានតែក្នុងសម័យបុរាណ ។

៤. មូលន័យនៃអត្ថបទនិយាយអំពី ៖

+ ការដែលព្រះបាទទសរថច្បាំងឈ្នះព្រះអាទិត្យ (ព្រះសុរិយាធុជ)
+ កាកនាសូរ រំខានហោមពិធីរបស់ឥសីពិស្វាមិត្រ
+ ការប្រកួតលើកធ្នូបាញ់ចូលក្នុងរង្វង់មណ្ឌលចក្រ ដែលព្រះចៅក្រុងមិថិលារៀបចំឡើង ដើម្បីជ្រើសរើសរាជសុណិសា ឬរើសស្វាមីឱ្យនាងសីតា ជាព្រះរាជបុត្រី ។

៥. គំនិតសំខាន់នៃអត្ថបទកាព្យដកស្រង់នេះគឺ បង្ហាញអំពីជ័យជំនះរបស់ព្រះអភិរម្យ និងព្រះរាមដែលមានវិទ្ធិអំណាចដ៏ឧត្តុង្គឧត្តមក្នុងការច្បាំងឈ្នះសុរិយាធុជ និងលើកធ្នូបាញ់ឈ្នះក្នុងការប្រកួត ដើម្បីបានជាព្រះសុណិសាព្រះចៅក្រុងមិថិលា ។

៦. លក្ខណៈមនុស្សក្នុងអត្ថបទដកស្រង់នេះ មានដូចជាត្រង់ចំណុចដែលអ្នកនិពន្ធបានលើយកបញ្ហាទំនាស់រវាងឥសីពិស្វាមិត្រនិងកាកនាសូរដែលមកបំផ្លាញហោមពិធីរបស់លោក ធ្វើឱ្យឥសីខឹងហើយបង្កើតជាសង្គ្រាម ។ ឯព្រះរាមដែលកំពុងនៅក្នុងហោមពិធីជាមួយឥសីពិស្វាមិត្រដែរបានលើកធ្នូសរបាញ់សំដៅកាកនាសូរ រហូតដល់ស្លាប់បាត់បង់ជីវិត ។ មនុស្សលក្ខណៈមួយទៀត គឺការប្រកួតប្រជែងគ្នាលើកធ្នូសម្តែងឫទ្ធិបាញ់ឱ្យចូលក្នុងរង្វង់មណ្ឌលចក្រ ប្រឡងថ្វីដៃដើម្បីបាននាងសីតាជាព្រះអគ្គមហេសីរៀងៗខ្លួន ។

៧. តម្លៃអប់រំក្នុងអត្ថបទដកស្រង់រាមកេរ្តិ៍ខ្មែរទី ១នេះបង្ហាញឱ្យឃើញនូវការអប់រំដែលទាក់ទងទៅនឹងជំនឿក្នុងលទ្ធិសាសនាព្រាហ្មណ៍ដូចជា ការជឿទៅលើហោមពិធីរបស់ឥសីពិស្វាមិត្រ ពិធីច្រត់ព្រះនង្គ័លរបស់ព្រះចៅក្រុងមិថិលា ដើម្បីភ្ជួររាស់ដាស់ដីធ្វើស្រែឱ្យដល់ប្រជានុរាស្ត្របានសុខក្សេមក្សាន្ត បានភោគផលល្អពីការធ្វើស្រែចម្ការ ជាប្រពៃណីដ៏ល្អពីបុរាណ ពិធីប្រកួតលើកធ្នូសដើម្បីសម្តែងឫទ្ធិតេជបារមីប្រឡងថ្វីដៃកំពូលខាងវិជ្ជាគុណ សិល្ប៍សាស្ត្រ ដែលព្រះចៅក្រុងមិថិលាធ្វើឡើងក្នុងគោលបំណងជ្រើសរើសបុត្រសុណិសា ទៅតាមលទ្ធិព្រាហ្មណ៍ដែលជាទម្លាប់ដ៏ល្អតាំងពីបុរាណមកម្ល៉េះ ។ ម្យ៉ាងទៀត អ្នកនិពន្ធក៏បង្ហាញផងដែរនូវទង្វើអាក្រក់ដែលតែងតែចាញ់អំពើឬទង្វើល្អ ដូចជាកាកនាសូរតំណាងភាវៈអាក្រក់គឺពួកយក្សមកបំផ្លាញហោមពិធីរបស់ឥសីពិស្វាមិត្រ ត្រូវព្រះរាមផ្លែងសរផ្ចាញ់កាកនាសូររហូតមរណា ។ ទាំងនេះជាការបង្ហាញឱ្យឃើញនូវរាល់ទង្វើអាក្រក់តែងនិនាសឬបរាជ័យ អំពើល្អតែងឈ្នះអំពើអាក្រក់ហើយទទួលបានជោគជ័យជានិច្ច ។

អំពីព្យញ្ជនៈទោល

១. វត្ថុបំណង

- ប្រាប់បានពីព្យញ្ជនៈទោលនិងសូរព្យញ្ជនៈ
- កំណត់ពីលក្ខណៈបន្លឺនៃព្យញ្ជនៈទោលតាមរយៈអត្ថបទ
- យល់ដឹងពីការប្រើប្រាស់និងការបន្លឺសូរព្យញ្ជនៈក្នុងភាសាជាតិបានច្បាស់លាស់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៣៨-១៤០

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងវេយ្យាករណ៍ "អំពីព្យញ្ជនៈទោល"ដាក់លើក្តារខៀន រួចឱ្យសិស្សអានសេចក្តីផ្តើមមេរៀន ឧទាហរណ៍ និងសេចក្តីសន្និដ្ឋានពីលក្ខណៈបន្លឺនៃព្យញ្ជនៈទាំង ៨ចំណុចក្នុងសៀវភៅសិស្សទំព័រទី ១៣៨-១៣៩ ។
- គ្រូឱ្យសិស្សឆ្លើយសំណួរ ៖
  - តើលក្ខណៈបន្លឺនៃព្យញ្ជនៈទោលមានអ្វីខ្លះ ?

    ចម្លើយ : តាមលក្ខណៈបន្លឺព្យញ្ជនៈទោលអាចចែកចេញជា ៨គឺ ព្យញ្ជនៈបបូរមាត់ ព្យញ្ជនៈធ្មេញមុខ ព្យញ្ជនៈក្រអូមមុខ ព្យញ្ជនៈគន្លាក់ក្រអូម ព្យញ្ជនៈក្រអូមកណ្តាល ព្យញ្ជនៈក្រអូមក្រោយ ព្យញ្ជនៈដើមមាត់ ។
  - ដូចម្តេចហៅថាព្យញ្ជនៈបបូរមាត់ ?

    ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់បបូរមាត់ មាន [b] បប៊ , [p]ប៉ព , [ph]ផភ , [m]ម៉ម ។
  - ដូចម្តេចហៅថាព្យញ្ជនៈធ្មេញ ?

    ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់ធ្មេញមុខ មាន [v]វ៉-វ ។
  - ដូចម្តេចហៅថាព្យញ្ជនៈគន្លាក់ក្រអូម ?

    ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់គន្លាក់ក្រអូម មាន [d]ដឌ , [t]តទ , [th]ថធ , [th]ឋឍ , [n]ណន , [s]សស៊ , [l]លឡ ។
  - ដូចម្តេចហៅថាព្យញ្ជនៈក្រអូមកណ្តាល ?

    ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់ក្រអូមកណ្តាល មាន [c]ចជ , [ch]ឆឈ , [ɲ]ញ៉ញ , [j]យ៉យ ។
  - ដូចម្តេចហៅថាព្យញ្ជនៈក្រអូមមុខ ?

    ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់ក្រអូមមុខ មាន រ៉រ ។
  - ដូចម្តេចហៅថាព្យញ្ជនៈក្រអូមក្រោយ ?

    ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់ក្រអូមក្រោយ មាន [k]កគ , [kh]ខឃ , [ŋ]ង៉ង ។

- ដូចម្តេចហៅថាព្យញ្ជនៈដើមមាត់ ?

  ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់សន្ទុះដើមមាត់ មាន [h]ហាហ៊ ។

- ដូចម្តេចហៅថាព្យញ្ជនៈចន្លោះខ្សែសំឡេង ?

  ចម្លើយ : គឺជាព្យញ្ជនៈដែលកើតត្រង់សន្ទុះខ្សែសំឡេង មាន អអ៊ ។

ខ. ការហ្វឹកហាត់

- គ្រូចែកសិស្សជាក្រុមឱ្យឆ្លើយសំណួរក្នុងលំហាត់ទី ១ និងទី ២ក្នុងសៀវភៅសិស្សទំព័រទី ១៤០ ។

  ចម្លើយ :

១. ជ្រើសរើសពាក្យមួយព្យាង្គទៅតាមលក្ខណៈបន្ទីដែលមានក្នុងអត្ថបទដកស្រង់ក្នុងសៀវភៅទំព័រទី ១៤០ ៖

+ ពាក្យ "គរ គុណ បាប" ព្យញ្ជនៈក្រអូមក្រោយ
+ ពាក្យ "ភ្ញា មាន" ព្យញ្ជនៈបបូរមាត់
+ ពាក្យ "ដល់ នៃ ទូល នួរ" ព្យញ្ជនៈគន្លាក់ក្រអូម
+ ពាក្យ "រួម រាជ" ព្យញ្ជនៈក្រអូមមុខ ។

២. ពាក្យដែលជាព្យញ្ជនៈទោល : ដើរ ទាន រៀន លេង សើច ។

៣. ពាក្យដែលជាព្យញ្ជនៈបបូរមាត់ : បាញ់ មើល មេ ម៉ែ ផើង រុំ ។

៤. ពាក្យដែលជាព្យញ្ជនៈដើមមាត់ : ហ៊ីហា ហ៊ោ ។

គ. ការវាយតម្លៃ

គ្រូដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើដោយឱ្យសិស្សជ្រើសរើសពាក្យទាក់ទងនឹង

១. ព្យញ្ជនៈបបូរមាត់ ឱ្យបាន ៣ពាក្យ

២. ព្យញ្ជនៈធ្មេញ ឱ្យបាន ៣ពាក្យ

៣. ព្យញ្ជនៈក្រអូមមាត់ ឱ្យបាន ៣ពាក្យ

៤. ព្យញ្ជនៈគន្លាក់ក្រអូម ឱ្យបាន ៣ពាក្យ

៥. ព្យញ្ជនៈក្រអូមកណ្តាល ឱ្យបាន ៣ពាក្យ

៦. ព្យញ្ជនៈក្រអូមក្រោយ ឱ្យបាន ៣ពាក្យ

៧. ព្យញ្ជនៈដើមមាត់ ឱ្យបាន ៣ពាក្យ

៨. ព្យញ្ជនៈចន្លោះខ្សែសំឡេង ឱ្យបាន ៣ពាក្យ ។



គោលគំនិតសំខាន់នៃសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា

១. វត្ថុបំណង

- ប្រាប់ពីខ្លឹមសារសំខាន់ៗនៃអត្ថបទ តាមរយៈការឆ្លើយសំណួរ
- បង្ហាញតម្លៃអប់រំ តាមរយៈការអប់រំសាសនា
- មានទស្សនៈទូលំទូលាយក្នុងការកំណត់ពីគោលគំនិតសំខាន់ៗក្នុងសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៤១-១៤៥
- ដកស្រង់ពីឯកសារវប្បធម៌ អរិយធម៌ខ្មែរ ភាគ ២ របស់លោក សរ សារុន ទំព័រទី ១៦០-២០៥ ។

៣. លំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូសរសេរចំណងជើងអំណានដាក់លើក្តារខៀន "គោលគំនិតសំខាន់នៃសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា" ។
- គ្រូសួរសំណួរទាក់ទងនឹងចំណងជើង ៖
  - តើគោលគំនិតសំខាន់នៃសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនាជាអ្វី ?

    ចម្លើយ : គោលគំនិតសំខាន់នៃសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធ គឺជាការបង្ហាញនូវគំនិតធំៗ ចាំបាច់នៅក្នុងសាសនាទាំងពីរ គឺសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនាដែលមានលក្ខណៈខុសៗគ្នា ។
  - តើសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធដូចគ្នាឬទេ ?

    ចម្លើយ : សាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធមិនដូចគ្នាទេ ព្រោះសាសនាព្រាហ្មណ៍គឺជាការគោរពប្រតិបត្តិជំនឿ តាមបែបព្រាហ្មណ៍សាសនា ឯសាសនាព្រះពុទ្ធគឺជាការគោរពប្រតិបត្តិទៅតាមលក្ខណៈនៃព្រះពុទ្ធសាសនា ។
- គ្រូឱ្យសិស្សសង្កេតរូបភាព នៅក្នុងសៀវភៅសិស្សទំព័រទី ១៤១រួចសួរ :
  - តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ ?

    ចម្លើយ : នៅក្នុងរូបភាពនេះ ខ្ញុំឃើញបដិមាព្រះព្រហ្មមួយនិងរូបបដិមាព្រះពុទ្ធបីអង្គ ។
  - តើរូបបដិមាទាំងពីរប្រភេទនេះដូចគ្នាដែរឬទេ ? ព្រោះអ្វី ?

    ចម្លើយ : រូបបដិមាទាំងពីរប្រភេទនេះមិនដូចគ្នាទេ ។ ព្រោះរូបបដិមាព្រះព្រហ្មមានព្រះភ័ក្ត្របួនខុសពីរូបព្រះភ័ក្ត្រព្រះពុទ្ធ ដែលមានតែមួយទាំងកាយវិការ ... ។
  - តើរូបបដិមាទាំងពីរប្រភេទនេះមានន័យដូចម្តេច ?

    ចម្លើយ : រូបបដិមាទាំងពីរប្រភេទនេះ ស្តែងឱ្យឃើញនូវភាពខុសគ្នា មិនត្រឹមតែលក្ខណៈរូបរាងបដិមាប៉ុណ្ណោះទេ គឺអាចខុសគ្នាទាំងគោលគំនិតនៅក្នុងសាសនាទៀតផង ។ តាមសាសនាព្រាហ្មណ៍ ព្រះព្រហ្មជាអ្នកបង្កើតលោក ជាអ្នកថែរក្សាពិភពលោកទើបមានព្រះភក្ត្របួន ឯព្រះពុទ្ធជាមនុស្សធម្មតាមិនមែនជាអ្នកបង្កើតឬថែរក្សាលោក ។ ព្រះអង្គគ្រាន់តែជាអ្នកត្រាស់ដឹងធម៌ប៉ុណ្ណោះ ។

- ឱ្យសិស្សសិក្សាពាក្យគន្លឹះ ក្នុងទំព័រទី ១៤១ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ១៤១
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៤៥
- គ្រូឱ្យសិស្សអានអត្ថបទក្នុងសៀវភៅសិស្សទំព័រ ១៤២-១៤៥ បណ្តាក់គ្នាឬអានបន្តគ្នា ឯសិស្សដទៃទៀតអានដោយស្ងៀមស្ងាត់ ។

គ. ការពង្រឹងអំណាន

ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៤៥

ចម្លើយ :

១. តាមរយៈអត្ថបទខាងលើ សាសនាព្រាហ្មណ៍មានកំណើតនៅប្រទេសឥណ្ឌាប្រមាណ ១៥០០ ឆ្នាំមុនគ.ស. ដែលនាំចូលដោយពួកអារ្យន ។ សាសនាព្រាហ្មណ៍នេះទៀតសោតបានហូរចូលមកក្នុងដែនដីសុវណ្ណភូមិចំនួនពីរលើកធំៗ គឺដើមសតវត្សរ៍ទី១ តាមរយៈព្រះបាទ ហ៊ុន ទៀន និង នាង លីវ យី ។ ចំណែកលើកទីពីរនៅដើមសតវត្សរ៍ទី ៥ ។

២. សាសនាព្រាហ្មណ៍ត្រូវបានគេចែកជាបីដំណាក់កាលធំៗគឺ សម័យវេទនិយម (១៥០០ឆ្នាំមុនគ.ស.ដល់ ៥៥០ឆ្នាំមុនគ.ស.)គឺសម័យព្រាហ្មណ៍និយម(៥៥០ឆ្នាំមុន គ.ស. ដល់សតវត្សរ៍ទី ១០នៃគ.ស.) និងដំណាក់កាលទី ៣ សម័យហិណ្ឌូនិយម(សតវត្សរ៍ទី១០នៃគ.សដល់សម័យបច្ចុប្បន្ននេះ) ។

៣. គម្ពីរវេទទាំងអស់មានបី ហៅថាត្រៃវេទ ។ គម្ពីរទីមួយ គឺឫគវេទ គឺជាគម្ពីរដែលនិយាយសរសើរ បួងសួង អង្វរករទេវតាផ្សេងៗនិងអាទិទេពដែលស្ថិតនៅក្នុងធម្មជាតិយើងនេះដូចជា ព្រះអាទិត្យ ព្រះចន្ទ ព្រះពាយ ព្រះធរណី ព្រះអគ្គី ព្រះពិរុណ ។ គម្ពីរឫគវេទចែកជា ១០២៨ សូត្រ ឬមណ្ឌល ១សូត្រមាន ៥៨គាថា ។ ទីពីរ គឺគម្ពីរយជុរវេទ គឺជាគម្ពីរនិយាយពីការបន់ស្រន់អង្វរករទេវតានៅឋានលើឱ្យចុះមកជួយ ដើម្បីមានឫទ្ធីតេជបារមី ផ្នែកខ្លះទៀតនិយាយដូចគម្ពីរឫគវេទដែរ ។ គម្ពីរយជុរវេទចែកជាពីរផ្នែក គឺយជុរវេទខ្មៅសម្រាប់ធ្វើការបូជាក្បួត្រក្នុងពិធីរាជាភិសេក បូជាក្នុងខណៈពេលដែលមានព្រះមហាក្សត្រពង្រីកទឹកដី ។ ចំណែកយជុរវេទស គឺជាគាថាសម្រាប់បូជាយញ្ញ ។ ទីបីគម្ពីរសាមវេទ គឺជាគម្ពីរដែលមាន លក្ខណៈជាពាក្យកាព្យសម្រាប់សូត្របន្ទន់ចិត្តទេវៈ អាទិទេព ស្តីអំពីពិធីបូជាយញ្ញនិងមន្តអាគមផ្សេងៗ ។ មន្តអាគម មានពីរបែប គឺទីមួយមន្តអាគមសម្រាប់រៀនក្នុងស្រុកនិងមួយទៀតសម្រាប់រៀនក្នុងព្រៃព្រោះអាចមានគ្រោះថ្នាក់ចង្រៃផ្សេងៗកើតមានឡើង ។ ក្រៅពីនោះ មានអត្ថបទកំណាព្យខ្លះទៀតនិយាយសរសើរព្រះអាទិទេពដូចគម្ពីរឫគវេទដែរ ។ គម្ពីរអថិវេទ (អថិវេទ គឺសំគាល់លើឈ្មោះព្រាហ្មណ៍ម្នាក់) ជាគម្ពីរបន្ថែមពេលក្រោយ ។ គម្ពីរអថិវេទមាន ២០សៀវភៅចែកជា ២០កណ្ឌរួមមាន ៦០០០គាថា ។ គម្ពីរនេះបង្រៀនពីមន្តអាគមដើម្បីសម្រេចបំណងដែលជាសេចក្តីត្រូវការរបស់អ្នកស្រុក ។ គម្ពីរអថិវេទនេះមានដូចជា មន្តអាគមស្តោះពិសពស់ មន្តអាគមហៅពស់ មន្តអាគមបណ្តោះគ្រោះ មន្តអាគមលើករាសី មន្តអាគមស្នេហ៍ មន្តអាគមឱ្យពរពេលរៀបអាពាហ៍ពិពាហ៍ និងមន្តអាគមសម្រាប់បូជាសពជាដើម ។

៤. ក្នុងព្រះពុទ្ធសាសនា ទស្សនទ្រឹស្តី លទ្ធិទាំងប៉ុន្មានរបស់ព្រះពុទ្ធ ត្រូវបានគេចងក្រងជាគម្ពីរដែលហៅថាព្រះត្រៃបិដក។ គម្ពីរព្រះត្រៃបិដក គឺជាឃ្លាំងផ្ទុកពុទ្ធវចនៈរបស់ព្រះពុទ្ធ ដែលទ្រង់ទេសនាទូន្មានរវាង ៤៥ ព្រះវស្សាចាប់តាំងពីទ្រង់បានត្រាស់ដឹងព្រះសម្ពោធិញ្ញាណរហូតដល់ព្រះអង្គបានចូលនិព្វាន។ វចនៈដែលទ្រង់សម្តែងនេះហៅថាធម្មវិន័យ។ ធម្មវិន័យនេះចែកជាបី (សុត្តន្ត វិន័យនិងអភិធម្ម)។ ទាំងបីចំណែកនេះព្រះថេរៈទាំងឡាយបានសង្គាយនា(ផ្ទៀងផ្ទាត់) ចងក្រងទុកដាក់មួយក្រុមៗ ហៅថាបិដក ឬព្រះត្រៃបិដក (កញ្ចើបី)។ ពាក្យថាបិដក បើប្រែជាបណ្ណាល័យក៏សឹងតែបានដែរ។ គម្ពីរព្រះត្រៃបិដកមានចំនួនច្រើនជាងគម្ពីរវេទច្រើនណាស់ ច្រើនជាងគម្ពីរបីប១១ដង។ **គម្ពីរព្រះត្រៃបិដក** គឺគម្ពីរដែលជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈចំនួន ៨៤០០០ធម្មក្ខន្ធ ហើយពុំមានជាវចនៈអាទិទេពនោះទេ ហើយក៏មិនមែនជាពាហិរសាសនាដែរ។ ក្រោយព្រះពុទ្ធបរិនិព្វានភ្លាម មានការធ្វើសង្គាយនាផ្ទៀងផ្ទាត់ព្រះពុទ្ធវចនៈនិងធ្វើឱ្យបានត្រឹមត្រូវបរិសុទ្ធដូចដើមពុំមានការបន្ថែមឡើយ។ គម្ពីរព្រះត្រៃបិដកមានបី គឺវិន័យបិដក (១៣ ភាគ មាន ២១០០០ ធម្មក្ខន្ធ) សុត្តន្តបិដក (១៤ ភាគ មាន ២១០០០ធម្មក្ខន្ធ) អភិធម្មបិដក (៣៣ ភាគ មាន៤២០០០ធម្មក្ខន្ធ)។

៥. ភាពខុសគ្នានៃការគោរពគម្ពីរ ៖

ព្រះពុទ្ធសាសនា	ព្រាហ្មណ៍សាសនា
• គម្ពីរព្រះត្រៃបិដកមានបី ៖ វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក។ • ជឿលើកម្មផលលើទង្វើរបស់មនុស្ស។ ជឿលើការទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ។	• គម្ពីរវេទ(ហៅថាត្រៃវេទ)មានបី ឫគវេទ យជុរវេទ សាមវេទ • ជឿលើអាទិទេពជាច្រើនខុសៗគ្នា ក្រៅពីព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុ គឺមានរហូតដល់អាទិទេពតូចតាចទៀតដូចជា ព្រះអាទិត្យ ព្រះចន្ទ ព្រះធរណី ព្រះគង្គា។ល។

៦. តម្លៃនៃគោរពសាសនា ៖

ព្រះពុទ្ធ	ព្រាហ្មណ៍
• ឱ្យតម្លៃទៅលើកម្មផលឬអំពើ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ តាមទ្រឹស្តីព្រះពុទ្ធឬពុទ្ធវចនៈឬការទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់	• ឱ្យតម្លៃលើអាទិទេព។ មានតែអាទិទេពទេដែលអាចបង្កើតមនុស្ស បង្កើតលោក ឬបំផ្លាញលោកបាន។ • ការគោរពអាទិទេពផ្សេងគ្នា ឯការឱ្យតម្លៃអាទិទេពក៏ខុសគ្នាដែរ។

៧. នៅក្នុងពិធីមង្គលការ ដែលជាប្រពៃណីទំនៀមទម្លាប់ប្រជាជនខ្មែរយើង ដែលតែងតែប្រារព្ធធ្វើក្នុងការរៀបចំទុកដាក់កូនចៅឱ្យមានគូស្រករតាំងពីបុរាណរហូតមកដល់សព្វថ្ងៃ យើងឃើញថា ឥទ្ធិពលនៃសាសនាព្រាហ្មណ៍ដូចជា ពិធីសែនក្រុងពាលី ពិធីសំពះផ្ទឹម ការបង្វិលពពិល ការអុជទៀនធូប ពិធីសែនព្រេន ពិធីផ្សំដំណេក។ល។



ការនិយាយប្រៀបធៀប

១. វត្ថុបំណង

- ប្រាប់បានពីសេចក្តីលំអិតសំខាន់ៗក្នុងការប្រៀបធៀបរវាងគំនិតទស្សនៈ មតិយោបល់ ឬវត្ថុពីរដែលមានលក្ខណៈដូចគ្នានិងខុសគ្នា
- ប្រៀបធៀបបានពីប្រធានបទលំហាត់តាមក្រុមពិភាក្សា ផ្អែកតាមការបង្ហាញពីលំណែនាំក្នុងសៀវភៅសិស្ស
- មានចំណិនប្រសប់ក្នុងការប្រៀបធៀបដើម្បីរកចំណុចដូចគ្នា ចំណុចខុសគ្នាទៅតាមប្រធានបទដែលលើកឡើងយ៉ាងស្ទាត់ជំនាញ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៤៦

៣. ដំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូសរសេរចំណងជើងការនិយាយដាក់លើក្តារខៀន "ការនិយាយប្រៀបធៀប" រួចគ្រូសួរ :
  - ដូចម្តេចដែលហៅថា ការប្រៀបធៀប ?

  ចម្លើយ : ការប្រៀបធៀបគឺជាការប្តូរនូវគំនិតពីរ ទស្សនៈពីរ មតិពីរ យោបល់ពីរ បញ្ហាពីរ វត្ថុពីរ។ល។ ដើម្បីបង្ហាញឬរកឱ្យឃើញនូវចំណុចដូចគ្នា ស្រដៀងគ្នា និងចំណុចខុសគ្នា ... ។

ខ. ការនិយាយ

- គ្រូឱ្យសិស្សអានសេចក្តីផ្តើមនៃមេរៀននិងលំណែនាំក្នុងសៀវភៅសិស្សទំព័រទី ១៤៦
- គ្រូចែកសិស្សជាក្រុមៗ រួចឱ្យក្រុមនីមួយៗជ្រើសរើសប្រធានបទក្នុងលំហាត់សៀវភៅសិស្សទំព័រទី ១៤៦ មកពិភាក្សា
- គ្រូសម្របសម្រួលការពិភាក្សាតាមក្រុមនិងលើកទឹកចិត្តសិស្សក្នុងការនិយាយ។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សធ្វើកិច្ចការផ្ទះដោយប្រៀបធៀបចំណុចដូចនិងខុសគ្នានៃការគោរពសាសនាព្រះពុទ្ធនិងសាសនាព្រាហ្មណ៍នៅក្នុងអំណានទី ២ឡើងវិញ។



រឿងសុវណ្ណសាម

១. វត្ថុបំណង

- ប្រាប់បានប្រភេទរឿងទាក់ទងជំនឿ សាសនា ប្រពៃណី ទំនៀមទំលាប់ និងការគោរពបូជា តាមរយៈខ្លឹមសាររឿងដែលបានស្តាប់រួច
- បង្ហាញបានពីការគោរពប្រណិប័តន៍ក្នុងលទ្ធិសាសនា តាមរយៈការស្តាប់អត្ថបទរឿងសុវណ្ណសាម
- មានគំនិតចេះវិភាគ ពិចារណាបានត្រឹមត្រូវចំពោះកិរិយាគោរពប្រណិប័តន៍ចំពោះអ្នកមានគុណតាមរយៈការអប់រំសាសនា ផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្តែង ។

២. សម្ភារៈ

- សៀវភៅសិស្សទំព័រទី ១៤៧
- សៀវភៅសង្ខេបទសជាតករបស់បណ្ឌិតមហា ឈឹម ស៊ុម ទំព័រទី ៥៩-៧៦ បោះពុម្ពឆ្នាំ ១៨៥៩ ។

៣. ព័ត៌មានជំនួយ

សូមលោកគ្រូ អ្នកគ្រូកែលំអកំហុសពាក្យត្រង់ឈ្មោះតួអង្គ "ព្រះបាទ កបិលយក្ខ"នៅក្នុងសៀវភៅសិស្សសំណួរទី ២ ទី ៣ និងទី ៧ មកជា "ព្រះបាទ បិលយក្ខ"វិញ ទំព័រទី ១៤៧ មុននឹងឱ្យសិស្សស្តាប់អត្ថបទរឿងនិងឆ្លើយទៅនឹងសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៤៧ ។

៤. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូសរសេរចំណងជើងអត្ថបទស្តាប់រឿង "សុវណ្ណសាម"ដាក់លើក្តារខៀន រួចសួរ ៖
  - តើប្អូនធ្លាប់បានស្តាប់ ឬអានរឿងនេះដែរឬទេ ?

    ចម្លើយ : អាស្រ័យលើសិស្ស ធ្លាប់/មិនធ្លាប់ ។
  - ចូរប្អូនស្មានមើលថា តើរឿងនេះនឹងនិយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូពន្យល់ពាក្យពិបាកៗ ៖
  - **ត្រើយខាងអាយ(សព្ទ)** : ដែលទីទៃ ពីពាក្យថា នាយ ឬខាងនាយ គឺខាងនេះ ខាងឯណេះ ដូចជាស្រុកអាយ រៀងរាយ ... ។
  - **ត្រើយខាងនាយ(សព្ទ)** : ខាងម្ខាងទីទៃពីខាងអាយ គឺឯនោះ ខាងណោះ ដូចជាត្រើយនាយ ស្រុកនាយ ខ្ញុំនៅឯនាយ ... ។
  - **បាណាតិបាត (ន)** : ការញុំាងជីវិតឱ្យធ្លាក់កន្លងទៅគឺការផ្តាច់ជីវិតសត្វ ការសម្លាប់សត្វ ។

- កិលេស (ន) : សេចក្តីសៅហ្មងចិត្ត ។
- វិស្សកម្ម (ន) : ទាំងអស់ ទាំងមូល សព្វគ្រប់ គ្រប់មុខ គ្រប់យ៉ាង ។
- និម្មិត (ន) : បង្កើតដោយឫទ្ធិ កាឡាខ្លួន តំណែងខ្លួន ។
- ភាវនា (ន) : ការចម្រើន ការនឹកចំពោះ ត្រង់អារម្មណ៍ដ៏ល្អតែមួយដដែលៗឱ្យច្រើនគឺនឹកហើយនឹកទៀតរឿយៗជាអនេក ។
- អានុភាព (ន) : អំណាច តេជៈ សេចក្តីអង់អាច សេចក្តីក្លាហាន ។
- ព្រះនេត្រ (ន) : ភ្នែក ។
- ពិតទូល (កិ) : ប្រាប់ ឱ្យដឹង ទទួលឱ្យជ្រាបសេចក្តីពិតប្រាប់ឱ្យដឹងសេចក្តីពិត ។
- ឧទរ (ន) : ពោះ ។
- ច្យុត (កិ) : ឃ្លាត របួត ស្លាប់ ច្រើននិយាយចំពោះទេវតាអស់ជីវិត ទេពច្យុត ។
- បដិសន្ធិ (ន) : កំណកំណើតសត្វ ការចាប់កំណើត ។
- ប្រសូត (ន) : កើត ។
- ព្រះជន្ម (ន) : អាយុ ។
- ពោធិសត្វ (ន) : អ្នកដែលមានចិត្ត ឬសេចក្តីប្រាថ្នាជាប់ក្នុងពោធិ គឺអ្នកដែលកំពុងខំប្រឹងបំពេញបារមីបម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។
- មហន្តរាយ (ន) : សេចក្តីវិនាសជាធំ អន្តរាយធំ ។
- ព្រះឱស្ឋ (ន) : មាត់ ។
- ព្រះសិរ (ន) : ក្បាល ។
- មច្ចុរាជ (ន) : ស្តេចនៃសេចក្តីស្លាប់ ។
- ទត (កិ) : មើល ។
- ពិលាប (ន) : សេចក្តីខ្សឹកខ្សួលរៀបរាប់ ដំណើរយំទួញបួរបាច់ឮខ្លាំងៗដោយស្តាយអាល័យ ឬដោយកើតទុក្ខតូចចិត្តណាស់ ។
- កាំសរ (ន) : គ្រាប់ព្រួញ ។
- រត្តិន្ទិព (ន) : យប់និងថ្ងៃ ឬមួយយប់មួយថ្ងៃ ។
- ឱរា (ន) : ទ្រូង ។
- សុគតិភព (ន) : ឋានសួគ៌ ។
- សច្ចវាចា (ន) : វាចា សម្តីពិត ។
- ព្រះអារុណ (ន) : ព្រះអាទិត្យ ។

ខ. ការស្តាប់

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៤៧ អានសេចក្តីពន្យល់នៅក្នុងសេចក្តីផ្តើមនៃមេរៀន ពិនិត្យរូបភាព ហើយអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៤៧ ដើម្បីត្រៀមឆ្លើយ ។
- គ្រូអានអត្ថបទរឿង សុវណ្ណសាម ឱ្យសិស្សស្តាប់ដោយល្បឿនយឺតៗ ៖

រឿង សុវណ្ណសាម

ក្នុងកាលកន្លងទៅហើយ មានស្រុកពួកអ្នកនេសាទមួយ នាត្រើយខាងអាយនៃស្ទឹង ជិតនគរពារាណសី។ មានស្រុកពួកអ្នកនេសាទមួយទៀតនាត្រើយខាងនាយនៃស្ទឹងអ្នកស្រុកទាំងពីរ ជាសំឡាញ់នឹងគ្នា ហើយបាននិយាយគ្នាថានឹងធ្វើជាដន្លងនឹងគ្នាក្នុងគ្រាដែលមានកូនប្រុសស្រី។

តមក នាយនេសាទក្នុងស្រុកនាត្រើយខាងអាយ បានកូនប្រុសឱ្យឈ្មោះថា "ទុកូល"។ ឯនាយនេសាទក្នុងស្រុកនាត្រើយខាងនាយបានកូនស្រីឱ្យឈ្មោះថា "បារិកា"ជនទាំងពីរនោះទោះបីកើតក្នុងត្រកូលនេសាទ ក៏ឥតធ្វើបាណាតិបាតសោះដល់ពេញក្រមុំពេញកំលោះ មាតាបិតារៀបអាពាហ៍ពិពាហ៍ឱ្យទាំងបង្ខំ ក៏ទ្រាំនៅជាមួយគ្នាដូចជាស្វាមីភរិយា តែថាមិនព្រមឆ្លងសមុទ្រកិលេសសោះដូចជាមហាព្រហ្មដូច្នោះ។

ចំណេរកាលមកខាងក្រោយ ទុកូលបណ្ឌិតនិងនាងបារិកា លាមាតាបិតាចេញទៅបួសជាឥសី គង់នៅក្នុងអាស្រមបទដែលព្រះឥន្ទឱ្យវិស្សកម្មទេវបុត្រនិម្មិតក្នុងទីជិតនៃស្ទឹងមិគសម្មតា ត្រង់កន្លែងដែលស្ទឹងនេះចុះពីព្រៃហោមពាន្ត មកជួបគ្នានឹងទន្លេគង្គា។ ឥសីទាំងពីរអង្គផ្ចង់ព្រះទ័យចម្រើនមេត្តា ភាវនា។ ដោយអានុភាពនៃសេចក្តីមេត្តា ក៏សព្វសត្វម្រឹគបក្សីនៅក្នុងព្រៃបាននូវក្តីមេត្តា ដែរឥតមានសត្វណាបៀតបៀនគ្នាឡើយហើយចោមរោមអាស្រមឥសីដោយក្តីទុកចិត្ត។

ចំណែកខាងព្រះឥន្ទ តែងមកកាន់ទីបម្រើតាបសទាំងពីរ។ ថ្ងៃមួយទ្រង់ប្រមើលមើលឃើញនូវសេចក្តីអន្តរាយនៃតាបសទាំងពីរ ថាមុខជានឹងខ្វាក់ព្រះនេត្រ ទើបទ្រង់ចូលទៅជិតទុកូលបណ្ឌិតពិតទូលនូវសេចក្តីអន្តរាយគ្រប់ប្រការ ហើយអង្វរសូមឱ្យលោកសេពនូវលោកធម៌ ដើម្បីឱ្យតែបាននូវកូនមួយគ្រាន់បម្រើ។ តាបសពុំព្រមធ្វើនូវអំពើនោះ។ ព្រះឥន្ទថា : បើដូច្នោះសូមលោកម្ចាស់គ្រាន់តែស្មាបឧទរនាងបារិកាតែម្តងក៏បានដែរ។ តាបសក៏ព្រមស្មាប តាមសេចក្តីអង្វរនៃព្រះឥន្ទ។ គ្រានោះពោធិ៍សត្វច្យុតចាកទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងបារិកានោះ។ លុះកន្លង ១០ខែទៅ នាងក៏ប្រសូត្របុត្រមានសម្បុរដូចមាស។ ព្រោះហេតុនោះ ទើបតាបសជាព្រះមាតាបិតាសន្ទតនាមថា សុវណ្ណសាម។[...]

លុះពោធិ៍សត្វមានព្រះជន្ម ១៦ឆ្នាំ បានបួសជាឥសី។ មាតាបិតាទៅព្រៃដើម្បីស្វែងរកផលានុផល ត្រឡប់មកវិញជិតដល់អាស្រម ជួនជាមហាមេឃបង្អុរភ្លៀងដ៏ធំ។ ឥសីទាំងពីរ ចូលទៅជ្រកលើដំបូកក្រោមដើមឈើធំមួយ ត្រូវពស់វែងព្រួសពិសចូលព្រះនេត្រខ្វាក់ទាំងពីរអង្គ រាវរកផ្លូវចេញមកពុំឃើញ ក៏នៅជាទុក្ខខ្សឹកខ្សួលក្នុងទីនោះ។ គ្រានោះ ពោធិ៍សត្វ កាលបើបាត់មាតាបិតា ក៏យាត្រាតាមទៅរក ស្រែកបង្ហូកពាសពេញព្រៃ។ តាបសឮសម្តីកូនក៏ឆ្លើយ កាលបើកូនចូលមកជិតហើយក៏ប្រាប់ថា ៖ ទីនេះមានមហន្តរាយ។ ពោធិសត្វបិតនៅពីចម្ងាយហុចឈើច្រត់មួយដ៏វែង ឱ្យមាតាបិតាគោងចុះអំពីដំបូករួចមកក៏ឃំសោកសង្រេងសង្រៃ ដោយក្តីអាណិតមាតាបិតា ហើយបែរជាសើចវិញ ដោយគិតថានឹងបានបម្រើមាតាបិតាជាប់មិនដាច់។ ចាប់ពីថ្ងៃនោះមក សុវណ្ណសាមទុកមាតាបិតាក្នុងអាស្រមទៅសន្សឹមួលផលាក្នុងព្រៃព្រឹក្សាជាប្រក្រតី។ ព្រឹកៗលោកបោសលំនៅនៃមាតាបិតា ហើយកណ្តៀតក្អមចុះទៅក្នុងស្ទឹងមិគសម្មតា ដងទឹកសម្រាប់មាតាបិតាឆាន់ប្រើប្រាស់ ហុចទឹកខ្ពុរព្រះឱស្ឋនិងឈើស្ទន់ហើយប្រគេនមធុរផលានុផល។ លុះមាតាបិតាឆាន់ឆ្អែតស្កប់ស្កល់ ទើបយកសំណល់មកឆាន់ខ្លួនឯង ហើយលាទៅស្វែងរកមូលផលាមានពួកម្រឹគចោមរោមជាបរិវារចូលទៅក្នុងព្រៃព្រឹក្សាជាប្រក្រតី។[...]

សម័យនោះ ព្រះបាទបិលយក្ខ ព្រះចៅក្រុងពារាណសីសព្វព្រះរាជហឫទ័យចំពោះសាច់ម្រឹគ ទ្រង់ចូលទៅព្រៃហោមពាន្តបានដល់ស្ទឹងមិគសម្មតា ទ្រង់ទស្សនាឃើញសុវណ្ណសាមមានពួកម្រឹគដើរតាមកំពុងធ្វើម្រឹគមួយគូឱ្យទន្ទឹមគ្នាដាក់ក្អមលើខ្នងវា យាត្រាមកកាន់កំពង់ទឹក ទ្រង់ឆឹតឆ្ងល់ថា "គាត់នេះជាអ្វី" ទើបចក្រីទ្រង់បាញ់សំដៅត្រូវសុវណ្ណសាមត្រង់ចំហៀងខាងស្តាំធ្លាយទៅខាងឆ្វេង។ ពោធិសត្វនៅម្នាក់ឯង ខំផ្ចង់ស្មារតីកំណត់ទិសហើយដួលបែរព្រះសិរទៅទិសដែលមាតាបិតាគង់នៅស្រែកសួរទៅថា : លោកណាអើយ! បាញ់ខ្ញុំកំពុងដងទឹក ? សាច់ខ្ញុំនេះមិនជារបស់គួរស៊ីទេ ទាំងស្បែកខ្ញុំក៏មិនជារបស់ដែលគេត្រូវការដែរ តើលោកសម្គាល់ខ្ញុំដូចម្តេចបានជាបាញ់ហើយពួន ?

ព្រះបាទបិលយក្ខទ្រង់ព្រះសណ្តាប់ពាក្យនោះហើយទ្រង់ព្រះចិន្តាថា ៖ "បុរសនេះអញបាញ់ដួលច្រងាងម្ល៉ឹងហើយ នៅតែមិនជេរអញ ថ្នមចិត្តអញ និយាយពាក្យគួរជាទីស្រឡាញ់ បើដូច្នេះអញចូលទៅមើលអេះ"ទ្រង់ព្រះចិន្តាយ៉ាងនេះហើយទ្រង់ចូលទៅមានព្រះរាជឱង្ការថា : ខ្ញុំជាព្រះរាជារបស់អ្នកដែន កាសីឈ្មោះបិលយក្ខ ចុះអ្នកជាអ្វី ? ជាបុត្រនរណា ?

ព្រះពោធិសត្វថា : ទូលព្រះបង្គំឈ្មោះ សាម ជាកូនឥសីថ្ងៃនេះទូលព្រះបង្គំដល់មាត់មច្ចុរាជហើយ សូមទ្រង់ទតចុះទូលព្រះបង្គំទទួលព្រះរាជទានដំណេកត្រាំក្នុងឈាមរបស់ខ្លួន មានព្រួញមុតពីខាងស្តាំធ្លាយទៅខាងឆ្វេង មានឈាមខ្ពុរចេញតាមមាត់ ចាប់ពើតណាស់ ព្រះអង្គអើយព្រះអង្គ! បានជាសួរព្រះអង្គរឿយៗថា : ម្តេចក៏បានជាបាញ់ហើយពួន ? តើព្រះអង្គសម្គាល់ទូលព្រះបង្គំថាគួរបាញ់ដោយហេតុដូចម្តេច ?

ព្រះរាជថា : ម្រឹគមកចំមុខព្រួញរបស់ខ្ញុំហើយផ្អើលបោលអស់ទៅ ព្រោះហេតុនោះទើបបានខ្ញុំខឹង ខ្ញុំបាញ់ទៅ ។[...]

ពោធិសត្វថា : សូមទ្រង់ព្រះមេត្តាប្រោស មាតាបិតានៃទូលព្រះបង្គំជាមនុស្សខ្វាក់ ទូលព្រះបង្គំចិញ្ចឹមលោកក្នុងព្រៃដងទឹកដើម្បីលោកអ្នកមានគុណទាំងឡាយនោះបានជាមកដល់ស្ទឹងនេះ ។

ស្រីបានតែប៉ុណ្ណោះក៏ពិលាបទួញយំថ្លែងយោបំភ្លេចឱ្យអាសូរថា : ឱមាតាបិតាជាទីគោរពរបស់កូនអើយ! លោកមានជីវិតយ៉ាងយូរណាស់ត្រឹម ៦ ថ្ងៃប៉ុណ្ណោះ ព្រោះមានត្រឹមតែភោគជន៍ជាផលានុផល ងងឹតងងល់រកទឹកពុំបានមុខជានឹងស្លាប់ដោយឥតទឹកពុំខានឡើយ ។ ព្រះអង្គអើយព្រះអង្គ! ការត្រូវកាំសរនេះ មិនជាសេចក្តីទុក្ខធ្ងន់ដ៏ក្រៃលែងរបស់ទូលព្រះបង្គំឱមាតាបិតា! ម្ល៉េះសមលោកនៅកំព្រា ទួញយំសព្វរត្តិន្ទិពអស់វេលាដ៏អង្វែង រឹងស្ងួតហើយលោកអើយ! ...ទូលព្រះបង្គំនឹងស្លាប់ឥឡូវនេះពុំខាន ។

ព្រះបាទបិលយក្ខថា : ម្នាលសាម អ្នកកុំយំខ្លាំងពេកមាតាបិតាអ្នកនៅត្រង់ណា ខ្ញុំនឹងចិញ្ចឹមនូវជនទាំងនោះឱ្យដូចជាអ្នកឯងដែលធ្លាប់ចិញ្ចឹមលោកយ៉ាងនោះ ។[...]

គ្រានោះទេវធីតាព្រះនាមវសុន្ធរី នៅនាភ្នំគន្ធមាទន៍បានឃើញដូច្នោះក៏គិតថា "បើអាត្មាអញមិននៅក្នុងទីនោះសមជាសុវណ្ណសាមនឹងវិនាស ព្រះបាទបិលយក្ខនឹងបែកឱរា មាតាបិតាឥតអាហារនឹងរឹងស្ងួតស្លាប់" គិតហើយក៏ចូលមកប្រញាប់ប្រាប់ថា : បពិត្រមហារាជ ព្រះអង្គបានធ្វើហើយនូវបាបដ៏ធ្ងន់ព្រោះជនទាំងបីនាក់ គឺមាតាបិតានិងបុត្រ ដែលជាបុគ្គលឥតប្រទូសសោះ ព្រះអង្គបានសម្លាប់ដោយព្រួញតែមួយ សូមទ្រង់មកអាយខ្ញុំនឹងពន្យល់ឱ្យរួចពីនរក បានទៅកើតក្នុងសុគតិភព សូមព្រះអង្គចិញ្ចឹមនូវជនខ្វាក់ទាំងពីរនាក់ ដោយធម៌កុំខានទើបបានរួចខ្លួន ។[...]

នាងវសុន្ធរីទេវធីតា ប្រកាសនូវសច្ចវាចាថា : ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ អស់កាលដ៏យូរអង្វែងហើយ ឥតមាននរណាដទៃជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងសាមទេ ដោយការពោលនូវពាក្យសច្ចៈនេះសូមឱ្យពិសរបស់សាមសាបរលាបទៅ! ។

លុះចប់សច្ចកិរិយានៃជនទាំងនោះ សាមជាតាបសកំលោះក៏ក្រោកឡើងភ្លាម បាត់ឈាមបាត់ស្នាមពីរាងកាយ ជំងឺទាំងឡាយក៏ជាជ្រះស្រឡះ ដូចជាទឹកហូរចេញអំពីកញ្ចប់ស្លឹកឈូកដូច្នោះ ។ ដោយអានុភាពនៃទេវតា ក៏ហេតុទាំង ៤ យ៉ាងនេះគឺ : ការជាជ្រះស្រឡះចាករោគនៃពោធិសត្វមួយ ការបាននូវភ្នែកភ្លឺឡើងវិញនៃមាតាបិតាទាំងឡាយមួយ ការរះឡើងនៃព្រះអរុណមួយ ការមានប្រាកដក្នុងអាស្រមបទនៃជនទាំងបួននាក់មួយ បានសម្រេចព្រមគ្នា ។

សុវណ្ណសាមមានសេចក្តីស្រស់ស្រាយរីករាយរកជនទាំងនោះថា "សេចក្តីចម្រើនចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសួស្តីហើយ សូមលោកទាំងឡាយកុំខ្សឹកខ្សួលឡើយ" ថាហើយក៏ពោលវាចាស្វាគមន៍ ជាសម្តីគួរសមចំពោះព្រះបាទបិលយក្ខដោយកិរិយារាក់ទាក់គួរឱ្យជាប់មេត្រី ... ។

(ដកស្រង់និងកែសម្រួលសង្ខេបចេញពីសង្ខេបទសជាតករបស់លោក ឈឹម ស៊ុម

បោះពុម្ពដោយក្រុមពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩៥៩ ទំព័រទី ៥៩-៧៦)

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៤៧ ៖

ចម្លើយ :

១. រឿងសុវណ្ណសាម ជាប្រភេទអក្សរសិល្ប៍រឿងបែបពុទ្ធនិយម ។ តាមរយៈដំណើររឿងបានបង្ហាញឱ្យឃើញថា តួអង្គសុវណ្ណសាមគឺជាតួអង្គដែលមានសកម្មភាពជាតួអង្គពោធិសត្វបានកសាង ឬបំពេញបារមី ដោយការគោរពប្រណិប័តន៍ចំពោះមាតាបិតាដែលពិការភ្នែក ដើម្បីជាកិច្ចតបស្នងសងគុណដល់អ្នកមានគុណទាំងពីរ នៅក្នុងដំណើររឿងទៀតសោតអ្នកនិពន្ធបានបង្ហាញឱ្យឃើញនូវដំណើរប្រព្រឹត្តិទៅនៃរឿងដែលកើតឡើងនៅនគរពារាណសី ព្រៃហោមពន្ត ។ បញ្ហាទំនាស់ក្នុងរឿងគឺជាទំនាស់រវាងព្រះពោធិសត្វ "សុវណ្ណសាម" និងសង្គមមនុស្សគឺ "ព្រះបាទបិលយក្ខ" ហើយដោយអំពើបាបដែលព្រះបាទបិលយក្ខបាញ់ព្រួញត្រូវសុវណ្ណសាមត្រូវមានបាបទទួលខុសត្រូវចិញ្ចឹមបីបាច់មាតាបិតាសុវណ្ណសាមដែលពិការ ។ ការដឹងកំហុសរបស់ព្រះបាទបិលយក្ខនិងអន្តរាគមន៍ពីទេពធីតាវសុន្ធរីតាមការប្រកាសសច្ចវាចាសូមឱ្យសុវណ្ណសាមរួចពីសេចក្តីស្លាប់ដោយពិសព្រួញត្រូវសាបរលាប ហើយបានជួបជុំគ្នាវិញ ។ ទីបញ្ចប់នៃរឿងបែបពុទ្ធនិយមមានលក្ខណៈសម្គាល់ទៅលើការបង្ហាញពីជំនឿលើអំពើ បុណ្យ បាប ធ្វើឱ្យអំពើល្អរបស់សុវណ្ណសាមចំពោះអ្នកមានគុណនិងអំពើល្អរបស់ព្រះបាទបិលយក្ខដែលធ្វើតបនឹងបាបរបស់ខ្លួនបានសាងដោយការបូជានូវទឹកចិត្តសប្បុរស ទទួលចិញ្ចឹមមាតាបិតាសុវណ្ណសាមដើម្បីសង ឬលាងបាបបានទទួលជោគជ័យគួបផ្សំនឹងអន្តរាគមន៍ពីទេពធីតាវសុន្ធរីដែលមើលឃើញបានជួយឱ្យអ្នកទាំងអស់បានរួចរស់ជីវិត ដូចជា សុវណ្ណសាមបាត់ស្នាមរបួសពីរាងកាយ ចាករោគ មាតាបិតាបានភ្លឺភ្នែកឡើងវិញនេះជាដើម ។

២. សុវណ្ណសាមបានត្រូវព្រះបាទបិលយក្ខបាញ់នៅពេលដែលសុវណ្ណសាមដាក់ក្អមលើខ្នងម្រឹគ ធ្វើដំណើរទៅកាន់កំពង់ទឹកដើម្បីដងទឹកទៅឱ្យមាតាបិតាប្រើប្រាស់នៅស្ទឹងមិគសម្មតា ។

៣. ហេតុដែលព្រះបាទបិលយក្ខបាញ់សុវណ្ណសាម គឺមកពីព្រះអង្គនឹកឆ្ងល់ថា ៖ "គាត់នេះជាអ្វី" ព្រោះពេលព្រះអង្គពេញសព្វហឫទ័យចំពោះសាច់ម្រឹគ ទ្រង់ចូលទៅព្រៃហោមពន្ត ស្រាប់តែឃើញសុវណ្ណសាមមានពួកម្រឹគដើរតាមកំពុងធ្វើម្រឹគមួយគូឱ្យទន្ទឹមគ្នាដាក់ក្អមលើខ្នងវា ... ក៏នឹកឆ្ងល់ថា "គាត់នេះជាអ្វី" ទើបចក្រីទ្រង់បាញ់សំដៅទៅត្រូវព្រះសុវណ្ណសាមទៅវិញ ... ។ ហើយម្រឹគមកចំមុខព្រួញរបស់ខ្ញុំហើយផ្តើលបោលអស់ទៅព្រោះហេតុនេះហើយទើបខ្ញុំខឹងខ្ញុំបាញ់ទៅ ។

៤. រឿងនេះបង្ហាញពីលក្ខណៈតថៈត្រង់បញ្ហាជំនឿ បុណ្យ និងបាប ។ ដោយសារអំពើបុណ្យដែលសុវណ្ណសាមបានបំពេញក្នុងនាមជាពោធិសត្វចំពោះអ្នកមានគុណទាំងពីរ បានធ្វើឱ្យពោធិសត្វទទួលបានវិញនូវកុសលល្អ ទោះបីជាព្រះបាទបិលយក្ខបានបាញ់ព្រួញធ្លាយពីចំហៀងខ្លួនខាងស្តាំធ្លាយទៅខាងឆ្វេងដេកត្រាំក្នុងថ្លុកឈាមយ៉ាងវេទនាក្តី តែដោយសារអំពើល្អ ជាកុសលដែលព្រះអង្គបានបំពេញក្នុងកិច្ចប្រណិប័តន៍ចំពោះមាតាបិតាបានធ្វើឱ្យព្រះអង្គទទួលបានមកវិញនូវសេចក្តីចាកទុក្ខទោស សេចក្តីមរណៈ និងថែមទាំងសង្គ្រោះជីវិតអ្នកមានគុណទាំងពីរចាកផុតពីភាពពិការថែមទៀតផង ។ នេះបញ្ជាក់ឱ្យឃើញថា ការគោរពបូជា ការជឿលើទង្វិពុទ្ធសាសនា និងការប្រណិប័តន៍តាមគន្លងពុទ្ធសាសនាសាងកុសល ផលបុណ្យនឹងរំដោះទុក្ខទោសយើងបានពោលគឺ ធ្វើល្អបានល្អ ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាបនេះឯង ។

៥. ក្នុងការគោរពប្រណិប័តន៍អ្នកមានគុណ សុវណ្ណសាមបានបំពេញនូវកុសលដ៏ច្រើនចំពោះគាត់ទាំងពីរដូចជាការចិញ្ចឹមបីបាច់ថែរក្សាអ្នកមានគុណទាំងពីរ ដោយការស្វែងរកផលានុផលក្នុងព្រៃមកឱ្យលោកហូបចុក ការបោសសំអាតលំនៅមាតាបិតារស់នៅឱ្យបានស្អាតបាត ដងទឹកដាក់ឱ្យមាតាបិតាប្រើប្រាស់ហូបចុកម្ហូបអាហារគ្រប់គ្រាន់ឆ្អែតស្កប់ស្កល់ បម្រើលោកទាំងយប់ថ្ងៃមិនឱ្យមានដំងឺផ្សេងៗ ។ល ។

៦. ការគោរពប្រណិប័តន៍ចំពោះអ្នកមានគុណ ចាត់ទុកថាជាផ្នត់គំនិតខ្មែរដែលធ្លាប់មានតាំងពីរបុរាណកាលមកម្ល៉េះ។ បានជាយើងពោលបែបនេះព្រោះថា មាតាបិតាជាអ្នកមានគុណចំពោះបុត្រធីតា លោកធ្លាប់បានចិញ្ចឹមបីបាច់ថែរក្សាបុត្រធីតាតាំងពីតូចក្រូចឆ្មារមករហូតដល់ធំពុំឱ្យមានខ្វះ ឬទាស់ខុសអ្វីឡើយ។ ដូច្នេះ ក្នុងនាមជាកូនកតញ្ញូ ក្នុងនាមជាកូនខ្មែរ យើងត្រូវតែគោរពប្រណិប័តន៍ចំពោះអ្នកមានគុណ ជាកិច្ចតបស្នងសងដល់អ្នកដែលមានគុណដោយខានពុំបាន បើពុំដូចនោះទេ នឹងចាត់ទុកថាជាកូនអកតញ្ញូ ជាកូនរមិលគុណ ហើយចាត់ទុកថាជាបាបមួយផងដែរ ព្រោះឪពុកម្តាយជាអ្នកមានគុណដ៏លើសលប់ចំពោះបុត្រធីតា ដូចពាក្យចាស់លោកពោលថា "ម៉ែឪមានគុណ គុណមានទម្ងន់ធ្ងន់ដូចប្រថពី គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគីរី ផ្លែពុំស្មើហោង"។

៧. គុណសម្បត្តិរបស់តួអង្គសុវណ្ណសាម ៖

- សុវណ្ណសាម ជាតួអង្គពោធិសត្វដែលមានសកម្មភាពជាអ្នកបំពេញនូវបារមី ដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធ។ សុវណ្ណសាម ជាកូនកតញ្ញូមានសេចក្តីរីករាយជ្រះថ្លាក្នុងការបម្រើមាតាបិតាដែលពិការភ្នែកដោយពុំខ្លាចនឿយហត់។ រាល់ថ្ងៃ សុវណ្ណសាមតែងតែទៅព្រៃដើម្បីរកផ្លែឈើ ដងទឹក បំរើមាតាបិតាមិនឱ្យទាស់ចិត្ត។ ទោះបីខ្លួនត្រូវរបួសដោយព្រួញរបស់ព្រះបាទបិលយក្ខ ដេកក្នុងថ្លុកឈាមយ៉ាងណាក្តី ក៏ព្រះអង្គមិនតក់ស្លុត ហើយបានសុំឱ្យព្រះបាទបិលយក្ខជួយចិញ្ចឹមមាតាបិតារបស់ខ្លួនផង ដោយព្រះអង្គមិនខឹង មិនជេរប្រមាថដល់ព្រះបាទបិលយក្ខឡើយ។ ផ្ទុយទៅវិញ សុវណ្ណសាមបែរជានិយាយទៅកាន់ព្រះបាទបិលយក្ខដែលបាញ់សរត្រូវខ្លួនយ៉ាងពីរោះ ៖ "បុរសនេះអញបាញ់ជួលច្រងាងម្ខឹងហើយ នៅតែមិនជេរអញ ថ្នមចិត្តអញនិយាយពាក្យគួរជាទីស្រឡាញ់..."។ សុវណ្ណសាមជាកូនដែលកតញ្ញូនឹងបារម្ភពីឪពុកម្តាយគ្រប់ពេល ទោះដឹងខ្លួនជិតស្លាប់ក៏ដោយក៏មិនគិតពីខ្លួនឯងទេ គឺគិតពីអ្នកមានគុណ "...ព្រះអង្គអើយ ព្រះអង្គ! ការត្រូវកាំសរនេះមិនជាសេចក្តីទុក្ខធ្ងន់របស់ទូលបង្គំទេមានតែការខានឃើញមាតាបិតា ទើបជាសេចក្តីទុក្ខដ៏ធ្ងន់ដ៏ក្រៃលែងរបស់ទូលព្រះបង្គំ..."។
- ចំណែកតួអង្គព្រះបាទបិលយក្ខ ជាតួអង្គដែលមានលក្ខណសម្បត្តិល្អ បានធ្វើកំហុសទៅលើសុវណ្ណសាម ដោយការបាញ់ព្រួញ ហើយបានដឹងនិងស្គាល់កំហុសរបស់ខ្លួន ទទួលស្គាល់ការពិត ចេះមានចិត្តអាណិត មេត្តាករុណា ទទួលយកនូវការអង្វរកពីសុវណ្ណសាម និងសន្យាថានឹងទទួលចិញ្ចឹមមាតាបិតាសុវណ្ណសាម ដើម្បីលុបលាងកំហុស និងបាបកម្មដែលខ្លួនបានប្រព្រឹត្ត "ម្នាលសាមអ្នកកុំយំខ្លាំងពេក មាតាបិតាអ្នកនៅត្រង់ណា ខ្ញុំនឹងចិញ្ចឹមនូវជនទាំងនោះឱ្យដូចជាអ្នកឯងដែលធ្លាប់ចិញ្ចឹមលោកយ៉ាងនោះដែរ។"

៨. ចំពោះខ្ញុំវិញ ខ្ញុំនឹងត្រងត្រាប់និងធ្វើតាមកិច្ចគោរពប្រណិប័តន៍ចំពោះមាតាបិតា ឬអ្នកមានគុណដូចជាសុវណ្ណសាមដែរ ពីព្រោះខ្ញុំយល់ថា យើងជាបុត្រធីតាត្រូវតែធ្វើកិច្ចប្រណិប័តន៍និងតបស្នងសងគុណលោកដោយទឹកចិត្តសប្បាយរីករាយ និងមិនខ្លាចនឿយហត់អ្វីឡើយ ដើម្បីសក្តិសមជាកូនកតញ្ញូ ចេះដឹងគុណមាតាបិតានឹងមានឈ្មោះថាជាអ្នកស្គាល់បុណ្យបាបគុណទោស ហើយបុណ្យនឹងតាមជួយទ្រទ្រង់ដោយធម៌ដែលយើងម្នាក់ៗបានប្រព្រឹត្តនិងទទួលវិញជាក់ជាពុំខាន។

គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សរាប់តួអង្គសំខាន់ៗក្នុងរឿងនិងសកម្មភាពរបស់តួអង្គនីមួយៗឡើងវិញ។

តែងសេចក្តីប្រៀបធៀប

១. ឥតុបំណង

- ប្រាប់បាននិយមន័យសំណេរប្រៀបធៀប
- សរសេរតែងសេចក្តីប្រៀបធៀបបានល្អតាមរយៈអត្ថបទគំរូនិងលំណែនាំសំណេរ ដោយផ្អែកតាមការប្រើសំណួរប្រៀបធៀប
- មានស្មារតីនិងទម្លាប់ក្នុងការធ្វើការប្រៀបធៀបនិងវិភាគបានពីចំណុចដូចគ្នានិងខុសគ្នាបានល្អត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៤៨-១៥៣

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងសំណេរដាក់លើក្តារខៀន "តែងសេចក្តីប្រៀបធៀប" រួចឱ្យសិស្សអានសេចក្តីផ្តើមនៃមេរៀននិងអានអត្ថបទគំរូ "ការប្រៀបធៀបលក្ខណសម្បត្តិនាងសីតាក្នុងរឿងបែបព្រាហ្មណ៍និយមនិងតួអង្គនាងមទ្រីក្នុងរឿងបែបពុទ្ធនិយម" ក្នុងសៀវភៅសិស្សទំព័រទី ១៤៨-១៤៩ ។
- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៥០

ចម្លើយ :

១. សំណេរប្រៀបធៀបគឺជាសំណេរដែលពន្យល់រៀបរាប់ឱ្យឃើញនូវចំណុចដូចគ្នាឬប្រហែលគ្នា និងចំណុចខុសគ្នា ... ។ សំណេរប្រៀបធៀបមានពីរផ្នែក គឺលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា ។

២. ក្នុងតួសេចក្តីត្រូវមានសេចក្តីពន្យល់ពី ៖

ក. បង្ហាញលក្ខណៈដូចគ្នា (មានឧទាហរណ៍ ឬអំណះអំណាងបញ្ជាក់)

ខ. បង្ហាញលក្ខណៈខុសគ្នា(និយាយដោយឡែក)

+ បញ្ហាទី ១ (មានឧទាហរណ៍ ឬអំណះអំណាងបញ្ជាក់)

+ បញ្ហាទី ២ (មានឧទាហរណ៍ ឬអំណះអំណាងបញ្ជាក់)

+ សរុបសេចក្តីក្នុងតួសេចក្តី និយាយពីខ្លឹមសារសរុបនៃលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នាលើបញ្ហាទស្សនៈ មតិយោបល់តួអង្គទាំងពីរ ... ។

៣. តាមរយៈការអានសំណេរតែងសេចក្តីគំរូខាងលើ យើងអាចធ្វើគម្រោងតែងមួយដូចខាងក្រោម ។

- **ផ្តើមសេចក្តី**
  - + លំនាំបញ្ហា :និយាយឱ្យទាក់ទងនឹងគំនិតប្រធាន ។
  - + ចំណូលបញ្ហា:បង្ហាញបញ្ហារបស់ប្រធាន ។
  - + ចំណោទបញ្ហា : បំផុសសំណួរតាមបែបប្រធានប្រៀបធៀប (តើ ...មានលក្ខណៈដូចគ្នាឬខុសគ្នាយ៉ាងណាខ្លះ) ?
- **តួសេចក្តី**
  - + ឃ្លាភ្ជាប់សេចក្តី
  - + ពន្យល់ពាក្យ
  - + ពន្យល់ន័យប្រធាន
  - + បកស្រាយ

ក. បង្ហាញលក្ខណៈដូចគ្នា (មានឧទាហរណ៍) ។

ខ. បង្ហាញលក្ខណៈខុសគ្នា (និយាយដោយឡែក)

+ បញ្ហាទី ១ (មានឧទាហរណ៍)

+ បញ្ហាទី ២ (មានឧទាហរណ៍)

+ **សរុប** : និយាយសរុបខ្លីអំពីលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នាលើបញ្ហា ទស្សនៈ មតិ ... ។

- **បញ្ចប់សេចក្តី**
  - + សន្និដ្ឋាន : ឱ្យតម្លៃទៅលើប្រធានបទ (មួយណាមានតម្លៃជាងមួយណា ឬមានតម្លៃដូចគ្នា) ដោយបញ្ជាក់ពីហេតុផលនៃការឱ្យតម្លៃនោះផង ។
  - + មតិផ្ទាល់ខ្លួន : ជាទស្សនៈរបស់អ្នកធ្វើតែងសេចក្តីប្រៀបធៀប ថាតើគំនិតប្រធានបានផ្តល់គុណប្រយោជន៍ឬផ្តល់បទពិសោធន៍ក្នុងការអប់រំដល់គ្រួសារ សហគមន៍ សង្គម ។

២. ការអនុវត្ត

- គ្រូឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១៥០ ផ្អែកតាមលំណែនាំក្នុងសៀវភៅសិស្សទំព័រទី ១៥០-១៥២ ។
- គម្រោង : គ្រូឱ្យសិស្សតាមក្រុមឬបុគ្គលជ្រើសរើសប្រធានបទណាមួយក្នុងចំណោមប្រធានបទទាំងបីក្នុងលំហាត់ ដែលគេពេញចិត្តដើម្បីតែង ។
- ការព្រាង :
  - គ្រូណែនាំសិស្សឱ្យធ្វើគម្រោងឬបង្កង់តែងតាមលំណែនាំគំរូក្នុងសៀវភៅសិស្សទំព័រទី ១៥០-១៥១
  - គ្រូណែនាំសិស្សឱ្យរកគំនិត ហេតុផល ឬអំណះអំណាងទុកបញ្ជាក់តាមប្រធានបទនីមួយៗក្នុងចំណុចបង្ហាញពីលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នាជាចំណុចៗគោល ក្រោយពីការគ្រោងគំនិតផ្តើមសេចក្តី ។

- គ្រូណែនាំសិស្សឱ្យរៀបចំលំដាប់លំដោយគំនិតតាមចំណុចនីមួយៗក្នុងតួសេចក្តី តាំងពីឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យ ពន្យល់ន័យប្រធាន ទើបបកស្រាយប្រធាន ដោយលើកឡើងនូវចំណុចដូចគ្នា ចំណុចខុសគ្នា តាមលំដាប់គំនិតនិង មានអំណះអំណាងឬឧទាហរណ៍បញ្ជាក់ ។
- គ្រូណែនាំសិស្សឱ្យសរុបមតិបកស្រាយក្នុងតួសេចក្តីយ៉ាងខ្លីទាំងចំណុចរួមដូចគ្នានិងចំណុចដោយឡែកៗខុសគ្នា ។
- គ្រូណែនាំសិស្សឱ្យគ្រោងគំនិតសម្រាប់ធ្វើសំណេរបញ្ចប់សេចក្តីដោយមានការសន្និដ្ឋានវាយតម្លៃ មតិ ទស្សនៈ យោបល់របស់ប្រធាន និងបង្ហាញគំនិតយោបល់ឬមតិផ្ទាល់ខ្លួន ដែលបញ្ជាក់នូវគុណប្រយោជន៍ បទពិសោធន៍ល្អៗ ក្នុងសង្គម ។
- គ្រូណែនាំសិស្សឱ្យសរសេរលំអិតសេចក្តីព្រាងលើកទី ១ លើកទី ២ និងលើកទី ៣ ដោយពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ទៅលើកំហុសពាក្យពេចន៍ឃ្លា ល្បះ និងខ្លឹមសារបកស្រាយថាតើមានលក្ខណៈសមហេតុផលនិងអំណះអំណាង បញ្ជាក់គ្រប់គ្រាន់ហើយឬនៅ ។

• ការរៀបរៀងនិងកែលំអ : គ្រូណែនាំឱ្យសរសេរសម្រេចសំណេរចុងក្រោយផ្អែកតាមលំណែនាំក្នុងសៀវភៅសិស្ស ទំព័រទី ១៥០-១៥១ឡើងវិញ ហើយឆ្លើយសំណួរ ៖

- តើសំណេររបស់អ្នកមានកំហុសអក្ខរាវិរុទ្ធដែរឬទេ ?
- តើអ្នកបានរៀបចំលំដាប់លំដោយគំនិតនិងឧទាហរណ៍បញ្ជាក់តាមចំណុចនីមួយៗបានត្រឹមត្រូវដែរឬទេ ? ដូចជា ៖

ក. លក្ខណៈដូចគ្នា

លក្ខណសម្បត្តិខាងក្រៅ :

+ រូបសម្បត្តិខាងក្រៅ
+ សកម្មភាព
+ ឥរិយាបថ
+ អាកប្បកិរិយា

លក្ខណសម្បត្តិខាងក្នុង :

+ ចិត្តគំនិត
+ ឧត្តមគតិ
+ ឧត្តមប្រយោជន៍

ខ. លក្ខណៈខុសគ្នា

លក្ខណសម្បត្តិខាងក្រៅ :

+ រូបសម្បត្តិខាងក្រៅ
+ សកម្មភាព
+ ឥរិយាបថ
+ អាកប្បកិរិយា

លក្ខណសម្បត្តិខាងក្នុង :

+ ចិត្តគំនិត
+ ឧត្តមគតិ
+ ឧត្តមប្រយោជន៍ ។

- តើការបកស្រាយរបស់អ្នកនៅតួសេចក្តី មានឃ្លាភ្ជាប់សេចក្តី មានពន្យល់ពាក្យពិបាកឬពន្យល់ន័យប្រធាន និងសរុបមតិបានសមស្របត្រឹមត្រូវដែរឬទេ ?
- តើមតិបកស្រាយនេះស្របនឹងប្រធានបទហើយឬនៅ ?
- តើការបកស្រាយរបស់អ្នកមានប្រើប្រាស់សំនួនប្រៀបធៀបដែរឬទេ ?
- តើនៅបញ្ចប់សេចក្តីអ្នកមានការសន្និដ្ឋាននិងចំណាប់អារម្មណ៍ដូចម្តេច ? សមស្របនឹងគំនិតប្រធានដែលលើកឡើងហើយឬនៅ ?

• ការសរសេរសម្រេច

- បន្ទាប់ពីផ្ទៀងផ្ទាត់និងឆ្លើយសំណួរខាងលើ រួចគ្រូណែនាំសិស្សឱ្យសរសេរសម្រេចឡើងវិញនិងកែឱ្យស្អាត
- គ្រូដាក់ពិន្ទុនិងលើកទឹកចិត្តសិស្សក្នុងការសរសេរ ដើម្បីអភិវឌ្ឍស្មារតីសិស្សក្នុងការសរសេរឱ្យមានបំណិនប្រសប់ខ្ពស់និងប្រកបដោយប្រសិទ្ធភាព ។

គ. ការវាយតម្លៃ

គ្រូដាក់ប្រធានតែងសេចក្តីប្រៀបធៀបឱ្យសិស្សធ្វើ ដើម្បីវាយតម្លៃកម្រិតយល់ដឹងរបស់សិស្សទៅលើប្រភេទតែងសេចក្តីប្រៀបធៀប ។ ចំណែកប្រធានតែងសេចក្តីអាស្រ័យលើលទ្ធភាពលោកគ្រូ-អ្នកគ្រូ ។



អក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ

ប្រវត្តិសាស្ត្របានបង្ហាញថា ខ្មែរយើងមានវប្បធម៌អរិយធម៌រុងរឿងល្បីល្បាញពេញពិភពលោក។ បុព្វបុរសជាតិយើងបានបន្សល់ទុកកេរដំណែលជាច្រើនរហូតដល់សព្វថ្ងៃដូចជា អក្សរសាស្ត្រ អក្សរសិល្ប៍ សិលាចារឹក ចម្លាក់ រូបបដិមា ប្រព័ន្ធធារាសាស្ត្រ ប្រាសាទបុរាណនានា ពិសេសគឺប្រាសាទអង្គរវត្ត។ អក្សរសាស្ត្រអក្សរសិល្ប៍ ជាមរតកដ៏សំខាន់មួយដែលបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយរហូតដល់បច្ចុប្បន្ន នេះជាមោទនភាពរបស់ជាតិយើង។ ខ្មែរត្រូវប្រកប់រូបត្រូវមានស្មារតីស្នេហាជាតិ ថែរក្សាការពារលើកតម្កើងវប្បធម៌ អរិយធម៌ជាតិឱ្យបានស្ថិតស្ថេរគង់វង្សនិងធ្វើឱ្យមានការអភិវឌ្ឍ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីកេរដំណែលអក្សរសាស្ត្រមួយចំនួនរបស់ខ្មែរ ហើយទន្ទឹមនឹងនោះអ្នកនឹងបានសិក្សាផងដែរពីការបញ្ចុះបញ្ចូល ការអួសទាញ និយមន័យអក្សរសាស្ត្រ សង្គមបរិយាកាស កាលកំណត់តែង អ្នកនិពន្ធ និងខ្លឹមសារអត្ថបទ។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិវាសាស្ត្រ	ទិវាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	១៤៧	១៥៣
• អំណានទី ១ : អក្សរសិល្ប៍ខ្មែរ	៣ម៉ោង	៤ម៉ោង	១៤៨-១៥៥	១៥៤
• អំណានទី ២ : សិលាចារឹកជ័យនន្ទ	២ម៉ោង	៤ម៉ោង	១៥៦-១៦០	១៦០
• រំលឹកបញ្ញត្តិ	១ម៉ោង	១ម៉ោង	១៦១-១៦២	១៦៦
• វេយ្យាករណ៍ : សូរព្យញ្ជនៈ	០ម៉ោង	២ម៉ោង	១៦៣-១៦៧	១៦៧
• ការនិយាយ : ការយោសនាបញ្ចុះបញ្ចូល	១ម៉ោង	២ម៉ោង	១៦៨-១៧០	១៧១
• សំណេរ : ការយោសនាបញ្ចុះបញ្ចូល	៣ម៉ោង	៣ម៉ោង	១៧១-១៧២	១៧៣

១. សិក្សាចំណងជើង

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៥៣។ គ្រូសរសេរចំណងជើងមេរៀន "អក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ" ដាក់លើក្តារខៀនរួចសួរ :
  - ដូចម្តេចហៅថា "អក្សរសាស្ត្រខ្មែរនិងអក្សរសិល្ប៍ខ្មែរ" ?

  ចម្លើយ : អាស្រ័យលើសិស្ស។

២. សិក្សាលើរូបភាព

- ក្នុងមេរៀននេះអ្នកបានឃើញរូបអ្វីខ្លះ ?

  ចម្លើយ : សិលាចារឹក។
- តើរូបភាពនេះ មានន័យដូចម្តេច ?

  ចម្លើយ : បុព្វបុរសខ្មែរយើងបានបន្សល់ទុកកេរតំណែលជាច្រើនរហូតដល់សព្វថ្ងៃដូចជាអក្សរសាស្ត្រ អក្សរសិល្ប៍ សិលាចារឹក ចម្លាក់ ប្រាសាទបុរាណ។ល។



អក្សរសិល្ប៍ខ្មែរ

១. វត្ថុបំណង

- បកស្រាយទស្សនៈរបស់អក្សរសិល្ប៍ តាមប្រភេទនីមួយៗបានត្រឹមត្រូវ
- ប្រាប់ពីប្រភេទអក្សរសិល្ប៍និងចលនាអក្សរសិល្ប៍បានត្រឹមត្រូវ
- បកស្រាយទស្សនៈរបស់អ្នកនិពន្ធស្តីពីបញ្ហាសុខៈក្នុងអក្សរសិល្ប៍បានត្រឹមត្រូវ
- ពណ៌នាលក្ខណៈអក្សរសិល្ប៍បានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យស្រឡាញ់ ថែរក្សាការពារអភិរក្ស និងអភិវឌ្ឍអក្សរសិល្ប៍ខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៥៤-១៥៩
- ឯកសារអរិយធម៌ខ្មែររបស់លោក សូ មុយឃៀង លោក ទិត សៀង លោក ជា ឈិន គ.ស.២០០៥ ។

៣. ពាក្យអាន

ដោយក្នុងសៀវភៅសិស្សពុំមានលទ្ធភាពសរសេរអត្ថបទទាំងមូលបាន ដូច្នេះសូមលោកគ្រូអ្នកគ្រូយកឯកសារអរិយធម៌ខ្មែររបស់លោក សូ មុយឃៀង លោក ទិត សៀង លោក ជា ឈិន គ.ស.២០០៥ ដើម្បីប្រើប្រាស់ជាជំនួយដល់ការឆ្លើយនឹងសំណួរ ។

៤. ជំហានបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៥៤ ហើយអានចំណងជើង រួចគ្រូសរសេរ " អក្សរសិល្ប៍ខ្មែរ" ដាក់លើក្តារខៀននិងសួរ :
  - ដូចម្តេចហៅថា អក្សរសិល្ប៍ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើអក្សរសិល្ប៍ខ្មែរយើងមានអ្វីខ្លះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សសង្កេតរូបភាពរួចសួរ :
  - តើអ្នកឃើញអ្វីខ្លះ នៅក្នុងរូបភាពនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើរូបភាពនេះចង់និយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។

- គ្រូសួរសំណួរឱ្យសិស្សប៉ាន់ស្មាន់ខ្លឹមសារអត្ថបទ "អក្សរសិល្ប៍ខ្មែរ" ។
- គ្រូសរសេរចម្លើយប៉ាន់ស្មានរបស់សិស្សដាក់លើក្តារខៀន ដើម្បីទុកផ្ទៀងផ្ទាត់ ។
- គ្រូឱ្យសិស្សអានពាក្យគន្លឹះនៅក្នុងសៀវភៅសិស្សទំព័រទី ១៥៤-១៥៥ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិន ក្នុងសៀវភៅសិស្សទំព័រទី ១៥៥ ។
  - តើនៅក្នុងអត្ថបទនេះគេតម្រូវឱ្យអ្នកយល់ដឹងអំពីអ្វីខ្លះ ?

    ចម្លើយ : និយមន័យអក្សរសិល្ប៍ ប្រភេទអក្សរសិល្ប៍ និងលក្ខណៈអក្សរសិល្ប៍ ។
- គ្រូឱ្យសិស្សអានសំណួរ ក្នុងសៀវភៅសិស្សទំព័រទី ១៥៩ រួចសួរ ៖
  - តើសំណួរទាំងអស់មានប៉ុន្មាន ?

    ចម្លើយ : សំណួរមានចំនួន ៩
- គ្រូឱ្យសិស្សអានអត្ថបទអំណាន ក្នុងសៀវភៅសិស្សទំព័រទី ១៥៥-១៥៩ ។

គ. ពង្រឹងអំណាន

- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលំអិតនៃអត្ថបទទាំមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
- គ្រូបែងចែកជាក្រុមឱ្យសិស្សឆ្លើយនឹងសំណួរ ទី ១ ២ ៣ ៤ ៥ ៧ ៨ ក្នុងសៀវភៅសិស្សទំព័រទី ១៥៩ ។
- គ្រូចែកសិស្សជា ៦ក្រុម ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់ ។
- គ្រូបែងចែកកិច្ចការឱ្យក្រុមនីមួយៗដូចខាងក្រោម ៖
  - ក្រុមទី ១និងទី ២ : ពិភាក្សារកចម្លើយសំណួរទី ១ ២ និងទី ៣
  - ក្រុមទី ៣និងទី ៤ : ពិភាក្សារកចម្លើយសំណួរទី ៤ និងទី ៥
  - ក្រុមទី ៥និងទី ៦ : ពិភាក្សារកចម្លើយសំណួរទី ៧ និងទី ៨
- គ្រូណែនាំរបៀបឆ្លើយសំណួរពីទី ១-៥
- ក្រុមនីមួយៗពិភាក្សាគ្នារកចម្លើយ បន្ទាប់ពីពិភាក្សាចប់ ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន ។
- គ្រូដឹកនាំសិស្សធ្វើការបូកសរុបនិងកែលំអ ។

ចម្លើយ :

១. អក្សរសិល្ប៍ជាអត្ថបទរឿង ដែលតុបតែងឡើងប្រកបដោយសិល្ប៍ ពោលគឺបំណិនប្រសប់ក្នុងការតែងរបស់អ្នកនិពន្ធ ដែលឱ្យអ្នកអានឬអ្នកស្តាប់ចូលចិត្ត ចាប់អារម្មណ៍ រំភើបញាប់ញ័រទៅតាមបញ្ហារបស់រឿង ។

២. អក្សរសិល្ប៍មានវត្ថុបំណង ស្វែងរកសោភ័ណ សច្ចៈ និងសុខៈ ។

៣. ទស្សនៈផ្សេងៗអំពីសុខៈ ៖

- ទស្សនៈទី ១ : ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវគោរពបន់ស្រន់អាទិទេព ធ្វើសមាធិបំពេញមោក្ខៈ(ការរំដោះ) ដើម្បីផ្តាច់អាត្មានចេញពីវដ្តសង្សារ ឱ្យវិលទៅជួបនឹងព្រហ្មន ។

- ទស្សនៈទី ២ : ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើន ដោយគ្រប់វិធី ទោះបីសង្គមជាតិត្រូវធ្លាក់ដុនដាបយ៉ាងណាក៏ដោយ ។
- ទស្សនៈទី ៣ : សុខៈពុំស្ថិតនៅលើការបន់ស្រន់ គោរពអាទិទេព ឬការប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើននោះទេ សុខៈសំដៅលើការអភិវឌ្ឍសង្គមនោះឯង ។ ដូច្នេះ អក្សរសិល្ប៍ដែលបណ្តុះការងារនិយម អភិវឌ្ឍន៍សង្គមហៅថា អក្សរសិល្ប៍មានបំណងស្វែងរក "សុខៈ" សម្រាប់សង្គមមនុស្ស ។
- សុខៈក្នុងអក្សរសិល្ប៍មានទំនាក់ទំនងនឹងសង្គមស្ទើរតែគ្រប់វិស័យដូចជា ប្រវត្តិសាស្ត្រ សាសនា សិល្បៈ បច្ចេកទេស សីលធម៌ នយោបាយ សង្គ្រាម ច្បាប់ជាដើម ។ យើងសង្កេតឃើញថា គ្រប់ស្នាដៃអក្សរសិល្ប៍បានបង្កប់នូវបញ្ហាសុខៈសម្រាប់មនុស្ស ព្រោះអក្សរសិល្ប៍ចោទនិងដោះស្រាយពីបញ្ហាមនុស្ស ។ ***ឧទាហរណ៍ :***
  + រឿងព្រះវេស្សន្តរ និយាយពីការធ្វើទានដើម្បីបំពេញបារមី ដើម្បីស្វែងរកសុខៈតាមផ្លូវព្រះពុទ្ធសាសនា ។
  + រឿងកុលាបប៉ែលិន តួអង្គចៅចិត្រខិតខំស៊ូក្នុងឆាកជីវិត ដើម្បីស្វែងរកសុខៈសម្រាប់ខ្លួន ។
  + រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ បានបង្ហាញពីនយោបាយគ្រប់គ្រងនិងអភិវឌ្ឍសង្គមសំដៅស្វែងរកសុខៈសម្រាប់មនុស្សនៅក្នុងសង្គម ។

៤. គេចែកអក្សរសិល្ប៍ ៥ប្រភេទគឺ ៖

- **សន្ទស្សន៍អក្សរសិល្ប៍ :** ស្នាដៃសរសេរសម្រាប់ប្រាប់បង្ហាញរៀបរាប់ដូចជា ៖
  + ពណ៌នាកថា រៀបរាប់ពីមនុស្ស សត្វ វត្ថុ ...
  + វណ្ណនាកថា រៀបរាប់ពីការធ្វើបុណ្យ ការធ្វើដំណើរ អំពីខ្យល់ព្យុះ ភ្លើងឆេះផ្ទះ ...
  + និទានកថា រៀបរាប់អំពីអនុស្សាវីយ៍ ការផ្សងព្រេង ការប្រឈុទ្ធ ...
  + សារកថា ជាអត្ថបទមានលក្ខណៈជាសំបុត្រឆ្លងឆ្លើយក្នុងគ្រួសារឬវាងមិត្តភក្តិ ក្នុងបំណងលាតត្រដាងបញ្ហាអ្វីមួយ ។
- **ប្រលោមអក្សរសិល្ប៍ :** ស្នាដៃដែលតែងតែអំពីវិបត្តិក្នុងគ្រួសារ ដោយប្រើវិធីប្រលោមធ្វើឱ្យអណ្តែតអណ្តូងតក់ស្លុត ញាប់ញ័រ រំភើបខុសធម្មតា ។ ក្នុងស្នាដៃប្រភេទនេះមានដូចជា ៖
  + ព្រេងកថា អ្នកនិពន្ធប្រឌិតចងក្រងដោយយករឿងរ៉ាវផ្សេងៗដូចជា រឿងឈ្លោះប្រកែកគ្នា រឿងច្រណែនប្រច័ណ្ឌជាដើម ដើម្បីលើកមកជាសេចក្តីតំណាល ទូន្មានប្រាប់អនុជន
  + វីរកថា ជារឿងមួយបែបដែលបង្ហាញតួឯកជាវីរជន ដែលមានចិត្តតស៊ូអង់អាចក្លាហាន ក្នុងនោះមានរឿងរាមកេរ្តិ៍ជាដើម
  + នវកថា គេច្រើនតែងរឿងដែលមានក្នុងព្រឹត្តិការណ៍ថ្មីៗក្នុងជីវភាពសង្គមនាពេលបច្ចុប្បន្នដូចជា បញ្ហាកសាងជាតិ សាមគ្គីភាព ។
- **នាដ្យអក្សរសិល្ប៍ :** ជាស្នាដៃដែលតែងសម្រាប់យកទៅលេងល្ខោនមានដូចជា ៖
  + នាដ្យកថា ជាអត្ថបទល្ខោនដែលលើកយករឿងវិបត្តិទំនាស់របស់មនុស្សក្នុងសង្គម នាសម័យណាមួយមកធ្វើជាប្រធានរឿង

+ ហាសកថា ជាអត្ថបទរឿងល្ខោនដែលប្រកបដោយសកម្មភាពនិងដំណើរវីរកវាយសប្បាយដោយកំប្លុកកំប្លែងធ្វើឱ្យសើច ។
+ ទារុណកថា ជារឿងល្ខោនដែលមានសកម្មភាពដំណើររឿងវីរកវរកម្សត់ធ្វើឱ្យអ្នកអាន អ្នកទស្សនាញាប់ញ័ររន្ធត់ចិត្ត អាណិតអាសូរតួអង្គខ្សោយដែលត្រូវតួអង្គខ្លាំងធ្វើបាប ។

- **ឧបទេសអក្សរសិល្ប៍ :** អត្ថបទបែបច្បាប់ទូន្មានសម្រាប់អប់រំប្រដៅណែនាំក្នុងនោះមាន ៖
  + សុភាសិតកថា ជាកម្រងពាក្យពេចន៍ចងក្រងឡើងសម្រាប់និយាយអប់រំក្រើនរំឭកចំពោះប្រជាជន ដោយប្រើវិធីធ្វើឱ្យចេះត្រិះរិះពិចារណាដូចជា "ចេះមកពីរៀនមានមកពីរក" ឬ "លួចគេបានវាគ្រាន់ ម្ចាស់គេទាន់វាក្រែល"
  + ទូន្មានកថា ជាច្បាប់អប់រំណែនាំប្រជាជនឱ្យដើរក្នុងផ្លូវល្អ ផ្លូវត្រូវ ។ *ឧទាហរណ៍* ច្បាប់ក្រម ។
  + ល្បើកកថា អ្នកនិពន្ធច្រើនយកតួអង្គសត្វ រុក្ខជាតិ មកដើរតួតំណាងមនុស្សដូចជា រឿងរៃនិងស្រមោច កូនចៀមនិងឆ្កែចចក ...
  + សុន្ទកថា ជាអត្ថបទដែលមានខ្លឹមសារល្អសម្រាប់ថ្លែងពិធីអ្វីមួយដូចជា ពិធីសម្ពោធ ពិធីបើក ឬបញ្ចប់ការងារ សន្និបាត សិក្ខាសាលាជាដើម ។
- **ទិដ្ឋិអក្សរសិល្ប៍ :** ស្នាដៃបែបអត្ថាធិប្បាយ ឬការបញ្ចេញមតិយោបល់របស់អ្នកនិពន្ធ អ្នកវិះគន់អក្សរសិល្ប៍ដូចជា
  + អត្ថាធិប្បាយកថា គឺអត្ថាធិប្បាយអំពីពាក្យសុភាសិតនានា អំពីគំនិតផ្សេងៗរបស់អ្នកប្រាជ្ញ អ្នកនិពន្ធ ...
  + សិក្សាកថា គឺអត្ថបទដែលលើកយកប្រវត្តិ ស្នាដៃនានា និងគំនិតរបស់អ្នកនិពន្ធ កវី ទស្សនវិទូក្នុងសម័យណាមួយមកសិក្សា ...
  + អក្សរសិល្ប៍កថា គឺអត្ថបទដកស្រង់ចេញអំពីរឿង ដែលជាស្នាដៃរបស់អ្នកនិពន្ធនាសម័យណាមួយ ។ ជួនកាលអក្សរសិល្ប៍កថានេះ មានសភាពជាអត្ថបទតាក់តែងខ្លីល្មម អំពីបញ្ហាអ្វីមួយសម្រាប់ធ្វើជាអត្ថបទអំណាន ឬធ្វើជាអត្ថបទសរសេរតាមអានជាដើម ។

៥. ប្រភេទអក្សរសិល្ប៍និងចលនាអក្សរសិល្ប៍ខុសគ្នា ៖

- ចលនាអក្សរសិល្ប៍ សំដៅយកដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈឬស្រទាប់សង្គមថ្នាក់លើ ទ្រឹស្តីទស្សនៈ គោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ។ គេចែកចលនាអក្សរសិល្ប៍ជា ៤គឺ អក្សរសិល្ប៍បែបព្រាហ្មណ៍និយមឬហិណ្ឌូនិយម អក្សរសិល្ប៍បែបពុទ្ធនិយម អក្សរសិល្ប៍បែបខ្មែរនិយមឬខេមរនិយម និងអក្សរសិល្ប៍បែបបរទេសនិយម ។ *ឧទាហរណ៍ :*
  + រឿងរាមកេរ្តិ៍ ស្ថិតក្នុងចលនាអក្សរសិល្ប៍បែបព្រាហ្មណ៍និយម
  + រឿងសុវណ្ណសាម ស្ថិតក្នុងចលនាអក្សរសិល្ប៍បែបពុទ្ធនិយម
  + រឿងថៅកែចិត្តចោរ ស្ថិតក្នុងចលនាអក្សរសិល្ប៍បែបខ្មែរនិយម ។
- ប្រភេទអក្សរសិល្ប៍ គឺជាការបែងចែកស្នាដៃអក្សរសិល្ប៍ឱ្យស្របទៅតាមរចនាបថ ។ អក្សរសិល្ប៍មាន ៥ប្រភេទ
  + សន្ទស្សន៍អក្សរសិល្ប៍
  + ប្រលោមអក្សរសិល្ប៍
  + នាដ្យអក្សរសិល្ប៍
  + ទិដ្ឋិអក្សរសិល្ប៍ ... ។



សិលាចារឹកបណ្ឌិតជ័យនន្ទ

១. វត្ថុបំណង

- អានអត្ថបទសិលាចារឹកបានត្រឹមត្រូវ
- ប្រាប់អ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាសនិងប្រាប់ពីគំនិតសំខាន់របស់អត្ថបទបានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យយកចិត្តទុកដាក់ថែរក្សាកេរដំណែលវប្បធម៌ខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៦០-១៦៥
- ឯកសារសិលាចារឹកជ័យនន្ទ
- ឯកសារប្រវត្តិអក្សរសាស្ត្រខ្មែររបស់លោក លាង ហាប់អាន

៣. ព័ត៌មានដំឡូយ

ដោយក្នុងសៀវភៅសិស្សពុំមានលទ្ធភាពសរសេរអត្ថបទទាំងមូលបាន ដូច្នេះសូមលោកគ្រូអ្នកគ្រូរកឯកសារសិលាចារឹកជ័យនន្ទ និងឯកសារប្រវត្តិអក្សរសាស្ត្រខ្មែររបស់លោក លាង ហាប់អាន ដើម្បីប្រើប្រាស់ជាជំនួយដល់ការឆ្លើយនឹងសំណួរ ។

៤. លំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៦០ ហើយអានចំណងជើង រួចគ្រូសរសេរ " សិលាចារឹកបណ្ឌិតជ័យនន្ទ" ដាក់លើក្តារខៀននិងសួរ :
  - តើអ្នកស្គាល់សិលាចារឹកឬទេ ?

    ចម្លើយ : អាស្រ័យលើសិស្ស
  - ដូចម្តេចហៅថា សិលាចារឹក ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ចូររាប់ឈ្មោះសិលាចារឹកដែលអ្នកធ្លាប់ស្គាល់ ។

    ចម្លើយ : អាស្រ័យលើសិស្ស ។
- លោក/អ្នកគ្រូឱ្យសិស្សសង្កេតរូបភាពរួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើរូបនេះចង់និយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។

- គ្រូសួរសំណួរឱ្យសិស្សប៉ាន់ស្មានខ្លឹមសារអត្ថបទ "សិលាចារឹកបណ្ឌិតជ័យនន្ទ" :
  - តើអត្ថបទនេះនិយាយពីអ្វី ?

  ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូសរសេរចម្លើយប៉ាន់ស្មានរបស់សិស្សដាក់លើក្តារខៀន ដើម្បីទុកផ្ទៀងផ្ទាត់ ។
- គ្រូឱ្យសិស្សអានពាក្យគន្លឹះនៅក្នុងសៀវភៅសិស្សទំព័រទី ១៦០-១៦១ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិន ក្នុងសៀវភៅសិស្សទំព័រទី ១៦១ ។
  - តើនៅក្នុងអត្ថបទនេះគេតម្រូវឱ្យអ្នកយល់ដឹងអំពីអ្វីខ្លះ ?

  ចម្លើយ : អ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាស និងខ្លឹមសារអត្ថបទ ។
- គ្រូឱ្យសិស្សអានសំណួរ ក្នុងសៀវភៅសិស្សទំព័រទី ១៦៥ រួចសួរសំណួរបញ្ជាក់ពីខ្លឹមសារនីមួយៗ ។
- គ្រូឱ្យសិស្សអានអត្ថបទអំណាន ក្នុងសៀវភៅសិស្សទំព័រទី ១៦១-១៦៥ ។

គ. ពង្រឹងអំណាន

- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលំអិតនៃអត្ថបទទាំងមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
- គ្រូបែងចែកជាក្រុមឱ្យសិស្សឆ្លើយនឹងសំណួរ ទី ១ ២ ៣ ៤ ៥ ៦ ក្នុងសៀវភៅសិស្សទំព័រទី ១៦៥ ។
- គ្រូចែកសិស្សជា ៦ក្រុម ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់ ។
- គ្រូបែងចែកកិច្ចការឱ្យក្រុមនីមួយៗដូចខាងក្រោម ៖
  - ក្រុមទី ១និងទី ២ : ពិភាក្សារកចម្លើយសំណួរទី ១ , ២
  - ក្រុមទី ៣និងទី ៤ : ពិភាក្សារកចម្លើយសំណួរទី ៣ , ៤
  - ក្រុមទី ៥និងទី ៦ : ពិភាក្សារកចម្លើយសំណួរទី ៥ , ៦
- គ្រូណែនាំរបៀបឆ្លើយសំណួរពីទី ១-៦
- ក្រុមនីមួយៗពិភាក្សាគ្នារកចម្លើយ បន្ទាប់ពីពិភាក្សាចប់ ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន ។
- គ្រូដឹកនាំសិស្សធ្វើការបូកសរុបនិងកែលំអ ។

ចម្លើយ :

១. សិលាចារឹកនេះ ជាស្នាដៃរបស់បណ្ឌិតជ័យនន្ទ ។

២. អត្ថបទនិយាយពី ៖
  - ពណ៌នាពីការលាចាកអំពើបាប លាទុក្ខសោក ភាពឆ្គាំឆ្គង ភាពល្ងង់ខ្លៅ រោគា ភាពក្រខ្សត់ ...
  - ការបួងសួងសុំនូវសេចក្តីសុខចម្រើនមគ្គផលក្នុងការធ្វើកុសលផ្សេងៗ ... ។

៣. តាមរយៈអត្ថបទបណ្ឌិតជ័យមានគោលបំណងទៅអនាគតដែលមានសេចក្តីជាអាទិ៍ដូចតទៅ ៖
  - ទី ១ : លាចាកពីជីវភាពរស់នៅជាមនុស្សធម្មតា ក្នុងសង្គមដែលមានអំពើបាប ភាពឆ្គាំឆ្គង ភាពល្ងង់ខ្លៅ រោគា ក្រខ្សត់ ... ។

+ ខ្ញុំលាត្រង់កំណើតថោក កើតមកអស់លោក សើចដៀលសន្តាន ។
+ ខ្ញុំលាសព្វជាតិពៀរស្តាន ក្តីអាស្រូវស្តាន កុំមានឡើយណា ។
+ ខ្ញុំលាត្រង់ឥតប្រាជ្ញា ឆ្លៅខ្លៅមោហា ខ្មាសគេអៀនប្រៀន ។
+ ខ្ញុំលាត្រង់ឥតរបៀន ចូលជំនុំស្ងៀម ពុំចេះឆ្លើយថា ។
+ ខ្ញុំលាពិសព្យាធិ៍រោគា ប្រាសបុត្រភរិយា ស្លាប់ឧបាសប្រាណ ។
+ ខ្ញុំលាវិបាកបុរាណ ជាទុក្ខក្នុងប្រាណ ស្រែកឃ្លានគោះផង ។
+ ខ្ញុំលាអស់បាបពៀរហោង ចតុរាបាយផង បួនកុំទៅសោយ ។
+ ខ្ញុំលាត្រង់គំនិតឆ្គោយ លាខ្ជិលកុំសោយ ហើយស្មារតីតិច ។
+ ខ្ញុំលាពុំចេះកលកិច្ច សិល្ប៍សាស្ត្រការស្រេច ពាក្យពេចន៍នោះណា ។
+ ខ្ញុំលាត្រង់ឥតប្រាជ្ញា ពុំចេះភាសា ស្រដីនឹងគេ ។ ...

- ទី ២ : ការបួងសួងសុំនូវសេចក្តីសុខចម្រើនសម្រេចមគ្គផលក្នុងការធ្វើកុសលផ្សេងៗ ... ។

អញខ្ញុំនេះនៃ	នាមដើមឈ្មោះជ័យ	វៀរភ័យបុរាណ
សូមបានត្រាស់ស្រេច	សរពេជ្ឈតាញ្ញាណ	សូមបាននិញ្ជន
	នាំអស់សត្វផង ។	
ជាតិមុខច្រើនក្រៃ	កើតជាអសង្ខេយ្យ	ឆ្នាំនៃកប្បហោង
ខ្ញុំសូមប្រាថ្នា	សទ្ធាទានផង	តាមដានគន្លង
	ព្រះសិអារ្យមេត្រី ។	
ទោះគេប្រាថ្នា	សុំអស់អង្គា	សាច់បញ្ចឥន្ទ្រិយ
សួតថ្លើមបេះដូង	ពុងពោះឈាមថ្មី	ភ្នែកឆ្អឹងខ្ញុំក្តី
	ឱ្យទានគេហោង ។	

វិភាគចរិតលក្ខណៈរបស់តួអង្គក្នុងកំណាព្យ : ជាអ្នកនិពន្ធដ៏ល្បីល្បាញក្នុងរជ្ជកាលព្រះករុណាព្រះបាទធម្មរាជាទី ១ សតវត្សទី ១៥ ចន្លោះឆ្នាំ ១៤៧៤-១៤៩៨ ។ បណ្ឌិតជ័យនន្ទ ជាអ្នកមានទឹកចិត្តជ្រះថ្លានឹងព្រះពុទ្ធសាសនា ដោយលាចាកពីរឿងសៅហ្មងទាំងឡាយនៅក្នុងជីវភាពរស់នៅជាមនុស្សធម្មតាក្នុងសង្គម ហើយប្រាថ្នាការលះបង់គ្រប់បែបយ៉ាងដើម្បីស្វែងរកសេចក្តីសុខតាមផ្លូវព្រះពុទ្ធសាសនា ។

៤. សិលាចារឹកនេះតាក់តែងឡើងនៅក្នុងរជ្ជកាលព្រះករុណាព្រះបាទធម្មរាជាទី ១ សតវត្សទី ១៥ ចន្លោះឆ្នាំ ១៤៧៤-១៤៩៨(ឯកសារប្រវត្តិអក្សរសាស្ត្រខ្មែររបស់លោក លាង ហាប់អាន) ។

៥. សង្គមបរិយាកាសតាមរយៈអត្ថបទ ៖ សិលាចារឹកនេះ ស្ថិតនៅក្នុងរជ្ជកាលព្រះករុណាព្រះបាទធម្មរាជាទី ១ សតវត្សទី ១៥ ចន្លោះឆ្នាំ ១៤៧៤-១៤៩៨(ឯកសារប្រវត្តិអក្សរសាស្ត្រខ្មែររបស់លោក លាង ហាប់អាន) ។ ព្រះបាទធម្មរាជាឡើងគ្រងរាជសម្បត្តិដោយសារមានការជួយជ្រោមជ្រែងពីស្តេចថៃ បន្ទាប់ពីបានព្រមព្រៀងឱ្យដីចន្ទបុរីនិងនគរាជសីមាទៅប្រទេសថៃ ។ បន្ទាប់មក ព្រះបាទធម្មរាជាបានទៅរៀនសូត្រធម៌អាថ៌នៃព្រះពុទ្ធសាសនា ហើយបានចេញទៅបំពេញផ្នួសនៅវត្តអារាមដោយមានព្រះរាជបុត្រ នាមព្រះបាទស្រីសុគន្ធរ ឬស្រីសុគន្ធរបទឡើងសោយរាជ្យបន្ត(ឯកសារប្រវត្តិ

សាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ចងក្រងដោយបណ្ឌិត ឡុង សៀម) ។ តាមរយៈប្រវត្តិសាស្ត្រនេះបង្ហាញថា ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងសម័យក្រោយអង្គរ គឺសម័យលង្វែក ។ សម័យកាលនោះ ប្រទេសកម្ពុជាទទួលឥទ្ធិពលព្រះពុទ្ធសាសនា ដូច្នេះហើយ ទើបអ្នកនិពន្ធពណ៌នាពីទឹកចិត្តរបស់ខ្លួនចំពោះព្រះពុទ្ធសាសនា ។

៦. ខ្លឹមសារអត្ថបទ ៖

- លាលោភ ទោស ភ័យអន្តរាយ ព្រាត់ប្រាស ទុក្ខសោក កំណើតថោក ពៀរស្ថាន ក្តីអាស្រូវ ឆ្លល់ខ្លៅ មោហាឥតប្រាជ្ញា ពុំចេះភាសា ខ្សត់ ចិត្តប្រត្យក្ស ឆ្កួត លង់ភិប្រាយ ពាក្យឆ្គង ប្រមាថមេបា គ្រូបាធ្យាយ ក្តីឆ្គាំឆ្គង ប្រមាថសង្ឃ ព្រះពុទ្ធព្រះធម៌ ចិត្តសាហាវ ញុះញង់ សត្រូវ ក្បាលតំពែក សក់ស្កូវ ធ្មេញបាក់ ខ្វាក់ ឃ្លង់ វេរាស្រែក ឃ្លង់ជំពៅ ក្លិនក្តាល់ឆ្អេះ ភរិយាអាក្រក់ ទ្រព្យអាក្រក់ វេរភ័យវេរា ។
- ប្រាថ្នាសូមចិត្តសទ្ធា អំណោយទាន ត្រាស់ជាសរពេជ្ឈតាញ្ញាណ និព្វាន ឱ្យទានសាច់បញ្ចឥន្ទ្រិយ ទេវតាជួយយល់ឥន្ទព្រហ្មជ្រោមជ្រែងពន្យល់ ថ្វាយបទុមា ចេះដោះស្រាយប្រស្នាដូចព្រះនាគសេន ចិត្តល្អស្រគត់ដូចព្រះតេមិយ មានម្ខាច ឫទ្ធីអំណាច អានុភាព សិល្ប៍ជប់ឆុតដូចព្រះឥសូរ ម្ខាចឮឆ្ងាយ កម្លាំងអានុភាពខ្លាំង សិល្ប៍សាស្ត្រឆុតឆាំ ទ្រព្យធន មាស ប្រាក់ កែវមណី ខៀន ព្រៃ កាសា ចៀមព្រំពេញផ្ទះ ពួកពិតានមន: ចង់បានបរិពារ ចង់បានស្រីស្រីង្គារ ។

ឃ. ការវាយតម្លៃ

- គ្រូឱ្យចែកសិស្សជាក្រុមតូចៗ ឆ្លើយសំណួរទី ៧-១០ ក្នុងសៀវភៅសិស្សទំព័រទី ១៦៥ ជាក្រុម ឬជាបុគ្គល ។

ចម្លើយ :

៧. អត្ថបទនេះផ្តល់បទពិសោធន៍ ៖

- ចេះកត់ត្រាទុកនូវរាល់ព្រឹត្តិការណ៍ទាំងឡាយនៅក្នុងសង្គម ...
- ខិតខំកសាងខ្លួនឱ្យចៀសផុតពីអំពើអាក្រក់ ទុក្ខសោក អំពើសៅហ្មងទាំងឡាយ ...
- ត្រូវខិតខំរៀនសូត្រដើម្បីចៀសឱ្យផុតពីភាពល្ងង់ខ្លៅ មានប្រាជ្ញាវាងវៃ ...
- មានទឹកចិត្តជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ...
- ខិតខំសិក្សាស្រាវជ្រាវសិលាចារឹកខ្មែរ ... ។

៨. វប្បធម៌ជាតិឆ្លុះបញ្ចាំងតាមរយៈសិលាចារឹកជ័យនន្ទ ៖

- បង្ហាញថា ខ្មែរយើងមានមរតកសិលាចារឹកជាច្រើន ...
- បង្ហាញថា ខ្មែរយើងមានអ្នកប្រាជ្ញអក្សរសាស្ត្រតាំងពីយូរលង់ណាស់មកហើយ ...
- បង្ហាញថា ខ្មែរយើងមានតួអក្សរសម្រាប់កត់ត្រាភាសារបស់ខ្លួនតាំងពីយូរលង់ណាស់មកហើយ ...
- បង្ហាញថា ខ្មែរយើងមានការរីកចម្រើនខាងវិស័យអក្សរសាស្ត្រ អក្សរសិល្ប៍ កំណាព្យ
- បង្ហាញថា ខ្មែរយើងចេះកត់ត្រារឿងរ៉ាវផ្សេងៗ ...
- បង្ហាញថា ខ្មែរយើងមានប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា ...
- បង្ហាញថា ខ្មែរយើងមានទឹកចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ... ។

៩. ឈ្មោះសិលាចារឹកខ្មែរចំនួនប្រាំ អ្នកនិពន្ធ កាលបរិច្ឆេទ និងខ្លឹមសារចម្បងនៃសិលាចារឹកនីមួយៗ ៖

- សិលាចារឹកកណ្តាលដើម
  + អ្នកនិពន្ធ : បណ្ឌិត សិវសោម
  + កាលបរិច្ឆេទ : តាក់តែងឡើងរវាងគ.ស.៨៧៧-៨៨៩ សតវត្សទី ៩ នៃគ.ស.ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី ១
  + អត្ថន័យ : អត្ថបទនេះសរសើរព្រះបាទឥន្ទ្រវរ្ម័ននិងសិវសោមខ្លួនឯង។ បណ្ឌិតនេះជាចៅរបស់ព្រះបាទជ័យន្ទ្រាធិបតីវរ្ម័ន ដែលត្រូវជាមាតានៃព្រះបាទជ័យវរ្ម័នទី ២ ។ គ្រូរបស់សិវសោមគឺ ភគវតីរុត្រៈ។ លោកបានរៀនអក្សរសាស្ត្រអំពីព្រះគ្រូ ភគវត័សង្កៈ។
- សិលាចារឹកភ្នំបាយ៉ង់
  + អ្នកនិពន្ធ : បណ្ឌិត យតិអមរភាវៈ
  + កាលបរិច្ឆេទ : តាក់តែងឡើងរវាងគ.ស.៨៨៩-៩០០ សតវត្សទី ៩ និងដើមសតវត្សទី ១០ នៃគ.ស.ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន
  + អត្ថន័យ : អួតសរសើរព្រះឥសូរ ហើយសំបួងសង្រួងសុំឱ្យព្រះឥសូរជួយថែរក្សាប្រជានុរាស្ត្រឱ្យប្រកបដោយសេចក្តីសុខ។
- សិលាចារឹកប្រាសាទកំពីស
  + អ្នកនិពន្ធ : បណ្ឌិត ទិវាករ
  + កាលបរិច្ឆេទ : តាក់តែងឡើងរវាងគ.ស.៩៤៤-៩៦៨ ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី ១
  + អត្ថន័យ : សរសើរព្រះបារមីនៃព្រះបាទជ័យវរ្ម័នទី ៥ ដែលត្រូវជាព្រះរាជបុត្រ ព្រះបាទរាជេន្ទ្រវរ្ម័នទី ១(សោយរាជ្យក្នុងគ.ស.៩៨៦-១០០២)។
- សិលាចារឹកប្រាសាទខ្នា
  + អ្នកនិពន្ធ : បណ្ឌិត កវិន្ទ្រៈ
  + កាលបរិច្ឆេទ : តាក់តែងឡើងរវាងគ.ស.១០០២-១០៥០ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១
  + អត្ថន័យ : សរសើរតេជៈបារមីរបស់ព្រះបាទសូរ្យវរ្ម័នទី ១ ក្សត្រសិកដ៏ក្លាហានមោះមុតក្នុងចម្បាំង។
- សិលាចារឹកប្រាសាទទរ
  + អ្នកនិពន្ធ : បណ្ឌិត ភូបន្ទ្រៈ
  + កាលបរិច្ឆេទ : តាក់តែងឡើងរវាងគ.ស.១១៨១-១២១៨ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១
  + អត្ថន័យ : សរសើរកិត្តិគុណរបស់ព្រះបាទជ័យវរ្ម័នទី ៧ ព្រមទាំងសមិទ្ធផលធំៗ ជាស្នាព្រះហស្តនៃព្រះមហាវីរក្សត្រ។

១០. អត្ថបទដែលបញ្ជាក់ថា តួអង្គដែលទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធគឺ រឿងព្រះវេស្សន្តរ ដែលមានខ្លឹមសារបញ្ជាក់នៅត្រង់ ៖

- ទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា គឺដំណើររឿងទាក់ទងទៅនឹងការបំពេញទានបារមី ជាទស្សនៈរបស់ពុទ្ធសាសនា
- ទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍ គឺពេលតួអង្គព្រះវេស្សន្តរទ្រាំមិនបាននឹងជូជក់ធ្វើបាបជាលើ ក្រឹស្នា ក៏លើកធ្នូបម្រុងបាញ់ជូជក ទង្វើនេះជាដំណោះស្រាយបញ្ហាបែបសាសនាព្រាហ្មណ៍។

រំលឹកបញ្ញត្តិ

១. វត្ថុបំណង

- ប្រាប់ឡើងវិញអំពី កាលអាកាស លក្ខណៈតួ: អ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាស អក្សរសិល្ប៍បែប ព្រាហ្មណ៍និយម ចលនាអក្សរសិល្ប៍ អក្សរសិល្ប៍បែបពុទ្ធនិយមបានត្រឹមត្រូវ ។

២. សម្ភារៈ

- សៀវភៅសិស្សទំព័រទី ១៦៦

៣. លំនាំបង្រៀន

- គ្រូឱ្យសិស្សអានខ្លឹមសារអត្ថបទក្នុងសៀវភៅសិស្សទំព័រទី ១៦៦ មួយចំណុចម្តងៗ ។
- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលំអិតនៃអត្ថបទទាំងមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបាន លោកគ្រូអ្នកគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
  - ដូចម្តេចហៅថា កាលអាកាសនៃរឿង ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

    ចម្លើយ : កាលអាកាសរឿង គឺជាពេលវេលានិងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។ ពេលវេលានិងទីកន្លែងជួនកាលអ្នកនិពន្ធលើកឡើងតាមស្ថានភាពពិតជាក់ស្តែង ជួនកាលប្រឌិតឡើងតាមមនោគតិរបស់ខ្លួន ។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។
  - ដូចម្តេចហៅថា លក្ខណៈតួ:នៃរឿង ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

    ចម្លើយ : គឺជារឿងរ៉ាវ ហេតុការណ៍ ព្រឹត្តិការណ៍ ឈ្មោះទីកន្លែង សកម្មភាព ... ដែលមានពិតនៅក្នុងសង្គមជាក់ស្តែង ហើយត្រូវបានអ្នកនិពន្ធបញ្ចូលឬផ្សារភ្ជាប់ទៅនឹងដំណើររឿងដោយរួមផ្សំនឹងមនោគតិរបស់អ្នកនិពន្ធ ។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។
  - ដូចម្តេចហៅថា អ្នកនិពន្ធរឿង ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

    ចម្លើយ : អ្នកសរសេរឬអ្នកកត់ត្រា ។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។
  - ដូចម្តេចហៅថា កាលកំណត់តែងនៃរឿង ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

    ចម្លើយ : គឺជាពេលវេលា ថ្ងៃខែឆ្នាំ ដែលអ្នកនិពន្ធបានសរសេរចប់សព្វគ្រប់ ហើយបានបញ្ជាក់នៅក្នុងស្នាដៃរបស់ខ្លួនយ៉ាងពិតប្រាកដ ។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។
  - ដូចម្តេចហៅថា សង្គមបរិយាកាសនៃរឿង ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

    ចម្លើយ : គឺជាដំណើររឿងដែលអ្នកនិពន្ធលើកមកបង្ហាញ ស្ថិតក្នុងសម័យកាលណាមួយ ហើយមានព្រឹត្តិការណ៍សង្គមខ្លះនៅក្នុងរឿងដែលគួរឱ្យកត់សម្គាល់ក្នុងស្នាដៃរបស់ខ្លួន ។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។

- ដូចម្តេចហៅថា អក្សរសិល្ប៍បែបព្រាហ្មណ៍និយម ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

ចម្លើយ : គឺអត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងលទ្ធសាសនាព្រាហ្មណ៍ ដោយការផ្តើមរឿងច្រើនលើកសរសើរពីឫទ្ធិអំណាចរបស់ព្រះឥសី ព្រះឥសូរ ទេវៈ អាទិទេពជាដើម។ ឯតួរឿងឬដំណើររឿងមានភាពអច្ឆរិយហួសហេតុ ហើយតួអង្គប្រុសជាអវតារនៃព្រះនារាយណ៍ ស្ត្រីជាកំពូលនារីល្អឯក និងបញ្ចប់រឿងអ្នកនិពន្ធដោយសភាវៈល្អឈ្នះតួអង្គអាក្រក់ ។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។

- ដូចម្តេចហៅថា ចលនាអក្សរសិល្ប៍ ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

ចម្លើយ : គឺជាដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមលើទ្រឹស្តី ទស្សនៈ គោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ។ គេចែកចលនាអក្សរសិល្ប៍ជាបួនប្រភេទគឺ ៖

+ ចលនាអក្សរសិល្ប៍បែបព្រាហ្មណ៍និយម
+ ចលនាអក្សរសិល្ប៍បែបពុទ្ធនិយម
+ ចលនាអក្សរសិល្ប៍បែបខេមរនិយម
+ ចលនាអក្សរសិល្ប៍បរទេសនិយម។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។

- ដូចម្តេចហៅថា អក្សរសិល្ប៍បែបពុទ្ធនិយម ? ចូរផ្តល់ឧទាហរណ៍ក្នុងរឿងណាមួយ ។

ចម្លើយ : គឺសម្គាល់អត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា ដោយការផ្តើមរឿងគឺបទនមស្ការរំលឹកគុណព្រះរតនត្រ័យមាន ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ តួរឿង ឬដំណើររឿងតួអង្គបុរសជាពោធិសត្វ នារីជាកន្សែរពេជ្ជ និងការបញ្ចប់រឿងដោយមានការសរជាតិរបស់តួអង្គពោធិសត្វទៅជាព្រះពុទ្ធ ឯកន្សែរពេជ្ជទៅជានាងពិម្ពា។ ចំពោះតួអង្គអាក្រក់វិញ បើតួអង្គនោះប្រឆាំងនឹងទៅជាទេវទត្ត ឯតួអង្គស្រីទៅជានាងចិញ្ចា។ ***ឧទាហរណ៍ :*** អាស្រ័យលើសិស្ស ។

សូរព្យញ្ជនៈ

១. វត្ថុបំណង

- ប្រាប់បញ្ជាតិព្យញ្ជនៈបានត្រឹមត្រូវ
- ប្រាប់បញ្ជាតិព្យញ្ជនៈខ្យល់ស្ទះ ខ្យល់ច្រមុះ ខ្យល់បង្ហូរត្រដុស ព្យញ្ជនៈឮ និងព្យញ្ជនៈថ្លង់បានត្រឹមត្រូវ ។
- ប្រាប់ព្យញ្ជនៈខ្យល់ស្ទះមានខ្យល់និងខ្យល់ស្ទះគ្មានខ្យល់ ខ្យល់ច្រមុះ ខ្យល់បង្ហូរត្រដុស ព្យញ្ជនៈឮ និងព្យញ្ជនៈថ្លង់បានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យមានគំនិតអភិរក្ស អភិវឌ្ឍ និងប្រើប្រាស់វេយ្យាករណ៍ខ្មែរបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៦៧-១៧០
- ឯកសារវេយ្យាករណ៍ថ្នាក់ទី ៥ របស់ក្រសួងអប់រំ បោះពុម្ពឆ្នាំ ១៩៨៣
- សៀវភៅវេយ្យាករណ៍ថ្នាក់ទី ៨ បោះពុម្ពដោយក្រសួងអប់រំ ឆ្នាំ ១៩៨៦ ។

៣. ព័ត៌មានជំនួយ

- ដើម្បីជាជំនួយដល់សិស្សក្នុងការធ្វើលំហាត់ សូមលោកគ្រូអ្នកគ្រូរកឯកសារវេយ្យាករណ៍ថ្នាក់ទី ៥ របស់ក្រសួងអប់រំ បោះពុម្ពឆ្នាំ ១៩៨៣ ដើម្បីឱ្យសិស្សយល់កាន់តែច្បាស់ ។ សូមលោកគ្រូអ្នកគ្រូដាក់លំហាត់បន្ថែមទៀត ។
- សូមលោកគ្រូអ្នកគ្រូធ្វើការកែតម្រូវលំហាត់ **ខ** ក្នុងសៀវភៅសិស្សទំព័រទី ១៦៩ បន្ទាត់ទី ៣ ក្នុងតារាង រាប់ពីក្រោម សូមបំប្លែព្យញ្ជនៈ **ណ** ទៅជាព្យញ្ជនៈ **ន** វិញ ព្រោះព្យញ្ជនៈខ្យល់ច្រមុះមាន **ន៎ណន** មិនមែន **ន៎ណណ** ទេ ។
- សូមលោកគ្រូអ្នកគ្រូ ធ្វើការកែតម្រូវលំហាត់ **គ** ក្នុងសៀវភៅសិស្សទំព័រទី ១៧០ បន្ទាត់ទី ៣ ក្នុងតារាង រាប់ពីលើ សូមបំប្លែកន្សោមពាក្យ **ព្យញ្ជនៈខ្យល់ច្រមុះ** ទៅជាកន្សោមពាក្យ **ព្យញ្ជនៈខ្យល់បង្ហូរត្រដុស** វិញ ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៦៧ បន្ទាប់មកគ្រូសរសេរចំណងជើងវេយ្យាករណ៍ "សូរព្យញ្ជនៈ" ដាក់លើក្តារខៀន រួចសួរ ៖
  - តើក្នុងភាសាខ្មែរយើងមានព្យញ្ជនៈប៉ុន្មានតួ ? អ្វីខ្លះ ?

    ចម្លើយ : ៣៣តួ គឺ កខគឃង ចឆជឈញ ដឋឌឍណ តថទធន បផពភម យរលវសហឡអ ។
  - តើសូរព្យញ្ជនៈចែកជាប៉ុន្មានពួក ? អ្វីខ្លះ ?

    ចម្លើយ : ២ពួក គឺ ពួក[អ] និងពួក[អ៊] ។
  - តើព្យញ្ជនៈពួក អ មានប៉ុន្មានតួ ? អ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈពួក អ មាន ១៥តួ គឺ កខ ចឆ ដឋណ តថ បផ សហឡអ ។
  - តើព្យញ្ជនៈពួក អ៊ មានប៉ុន្មានតួ ? អ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈពួក អ៊ មាន ១៨តួ គឺ គឃង ជឈញ ឌឍ ទធន ពភម យរលវ ។

- គ្រូឱ្យសិស្សអានបញ្ញត្តិព្យញ្ជនៈក្នុងសៀវភៅសិស្សទំព័រទី ១៦៧ ផ្នែកខាងលើ រួចគ្រូសួរ ៖
  - ដូចម្តេចហៅថា ព្យញ្ជនៈ ?
    ចម្លើយ : ព្យញ្ជនៈគឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេង បន្តឹឡើងដោយមានទំនប់ ប្រកបដោយភាពពុំច្បាស់លាស់ ។
  - តើគេចែកព្យញ្ជនៈយ៉ាងដូចម្តេច ?
    ចម្លើយ : ព្យញ្ជនៈអាចចែកតាមទីបន្តឹ និងតាមបន្តឹខ្យល់ឬរបៀបបន្តឹ ។
- គ្រូឱ្យសិស្សអានចំណុចទី ១ ត្រង់ចំណុច ក , ខ , គ ក្នុងសៀវភៅសិស្សទំព័រទី ១៦៨ រួចសួរ ៖
  - តាមលក្ខណៈបន្តឹ តើព្យញ្ជនៈចែកចេញជាប៉ុន្មាន ? អ្វីខ្លះ ?
    ចម្លើយ : ចែកចេញជា ៣ គឺព្យញ្ជនៈខ្យល់ស្ទះ ខ្យល់ច្រមុះ និងខ្យល់បង្ហូរត្រដុស ។
  - តើការបន្តឹព្យញ្ជនៈស្ទះចែកចេញជាប៉ុន្មានដំណាក់កាល ? អ្វីខ្លះ ?
    ចម្លើយ : មាន ៣យ៉ាងគឺ ការរៀបចំស្ថានភាពនៃប្រដាប់បន្តឹ ការប្រឹងនៃប្រដាប់បន្តឹ និងការផ្លាស់កន្លែងនៃប្រដាប់បន្តឹពីទីបន្តឹដើម្បីពន្លែងសន្ទុះខ្យល់ ។
  - តើព្យញ្ជនៈខ្យល់ស្ទះ មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?
    ចម្លើយ : មាន ២ផ្នែក គឺព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់ និងព្យញ្ជនៈខ្យល់ស្ទះមានខ្យល់ ។
  - តើព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់មានអ្វីខ្លះ ? ផ្តល់ឧទាហរណ៍ ។
    ចម្លើយ : ព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់ មាន កគ[k] ចជ[c] ដឌ[d] តទ[t] បប[b] ប៉ព[p] អអ[ʔ] ។
    ឧទាហរណ៍ : កង់ គាប ចូល ជុច ដាំ តាំង ទូក បុក ប៉ាន់ ពាង អួរ ។
  - តើព្យញ្ជនៈខ្យល់ស្ទះមានខ្យល់មានអ្វីខ្លះ ? សូមផ្តល់ឧទាហរណ៍ ។
    ចម្លើយ : ព្យញ្ជនៈខ្យល់ស្ទះមានខ្យល់ មាន ខឃ[kh] , ឆឈ[ch] , ឋឍ[th] , ថធ[th] , ផភ[ph] ។
    ឧទាហរណ៍ : ឃាំង ឆាប់ ឈើ ឋាន ធុង ផង ភួយ ។
  - ដូចម្តេចហៅថា ព្យញ្ជនៈខ្យល់ស្ទះ ?
    ចម្លើយ : គឺជាព្យញ្ជនៈបន្តឹឡើងដោយមានរបៀបចំបម្រឹង និងបំលាស់កន្លែងនៃប្រដាប់សំឡេង ។
  - តើព្យញ្ជនៈខ្យល់ច្រមុះមានអ្វីខ្លះ ? ផ្តល់ឧទាហរណ៍ ។
    ចម្លើយ : ព្យញ្ជនៈខ្យល់ច្រមុះមាន ង៉ង[ŋ] , ញ៉ញ[ɲ] , ន៉ណន[n] , ម៉ម[m] ។ ***ឧទាហរណ៍ :*** ញឹក នាង ណា មាន ង៉ែះៗ ។
  - ដូចម្តេចហៅថា ព្យញ្ជនៈខ្យល់ច្រមុះ ?
    ចម្លើយ : គឺជាព្យញ្ជនៈបន្តឹឡើងដោយលំហូរខ្យល់សូរក្នុងច្រមុះ ។
  - តើព្យញ្ជនៈខ្យល់បង្ហូរមានលក្ខណៈដូចម្តេច ?
    ចម្លើយ : ការបន្តឹព្យញ្ជនៈក្នុងពាក្យខាងលើ មានដំណើរខ្យល់ផ្តុំបង្ហូរដែលធ្វើឱ្យឮឡើងដោយត្រដុស ។
  - តើព្យញ្ជនៈខ្យល់បង្ហូរមានអ្វីខ្លះ ? ផ្តល់ឧទាហរណ៍ ។
    ចម្លើយ : ព្យញ្ជនៈខ្យល់បង្ហូរមាន យ៉យ រ៉រ ឡ្វល់ល វ៉វ សស៊ ហហ៊ ។ ***ឧទាហរណ៍ :*** យាយ យំ រ៉ៃ វា រ៉ាំរ៉ៃ ស្រូវ លក់ ឡ្វឡា ហាង ហ៊ាន ។
  - ដូចម្តេចហៅថា ខ្យល់បង្ហូរ ?
    ចម្លើយ : គឺជាព្យញ្ជនៈបន្តឹឡើងដោយមានដំណើរខ្យល់ផ្តុំបង្ហូរ ។
- គ្រូឱ្យសិស្សអានចំណុចទី ២ "ក , ខ" ក្នុងសៀវភៅសិស្សទំព័រទី ១៦៨ និង ១៦៩ រួចសួរ ៖
  - តាមលក្ខណៈឮ តើគេចែកព្យញ្ជនៈជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?
    ចម្លើយ : តាមលក្ខណៈឮ គេចែកព្យញ្ជនៈជាពីរផ្នែកគឺ ព្យញ្ជនៈឮនិងព្យញ្ជនៈថ្លង់ ។

- ដូចម្តេចហៅថាព្យញ្ជនៈឮ ?

  ចម្លើយ : ព្យញ្ជនៈឮគឺជាព្យញ្ជនៈដែលក្នុងការបន្លឺខ្សែសំឡេងញាប់ញ័រខ្លះៗ ។

- តើព្យញ្ជនៈឮមានអ្វីខ្លះ ? ឧទាហរណ៍ ។

  ចម្លើយ : ព្យញ្ជនៈឮមាន ដឌ [d] បប៊ [b] ង៉ង [ŋ] ញញ៉ [ɲ] ណន៑ [n] មម៉ [m] យយ៉ [j] ររ៉ [r] ឡល៉ល [l] វ៉វ [v] ។ ***ឧទាហរណ៍ :*** ដោយ បាច បិច ងងុយ ង៉ាៗ ញញឹម ញ៉ាំ មាន ម៉ៅ នាង ណា យាង ឡើង វា យ៉ាង រាវ រ៉ាំរ៉ៃ រលំ ... ។

- ដូចម្តេចហៅថា ព្យញ្ជនៈថ្លង់ ?

  ចម្លើយ : ព្យញ្ជនៈថ្លង់ គឺជាព្យញ្ជនៈពុំធ្វើឱ្យខ្សែសំឡេងញាប់ញ័រ ។

- តើព្យញ្ជនៈថ្លង់មានអ្វីខ្លះ ? ឧទាហរណ៍ ។

  ចម្លើយ : ព្យញ្ជនៈថ្លង់មាន កគ [k] , ខឃ [kh] , ចជ [c] , ឆឈ [ch] , តទ [t] , ឋឍ [th], ថធ [th] ប៉ព [p] , ផភ [ph] , សស៊ [s] , ហហ៊ [h] , អអ៊ [ʔ] ។ ***ឧទាហរណ៍ :*** កេងកង គគ្រឹក ខិតខំ ឃុំឃាំង ចរចា ជជុះ ឆានៅ ឈើ តតាំង ទទឹក ឋាន ថា ណាលិន ធំធេង ប៉ប្រឹម ពពក ផាយផាត់ ភូមិ សសៀរ ស៊ី ហាល ហ៊ាន អ៊ូអរ ។

ខ. ការហ្វឹកហាត់

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ ក , ខ ក្នុងសៀវភៅសិស្សទំព័រទី ១៦៩
- គ្រូណែនាំពីរបៀបធ្វើលំហាត់ ក , ខ ក្នុងសៀវភៅសិស្សទំព័រទី ១៦៩
- ក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ បន្ទាប់ពីពិភាក្សាធ្វើចប់ ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូធ្វើការបូកសរុបនិងកែលំអ ។

ចម្លើយ :

ក. ព្យញ្ជនៈខ្សល់ស្ទះមានខ្សល់ និងព្យញ្ជនៈខ្សល់ស្ទះគ្មានខ្សល់មានដូចជា ៖

+ **ព្យញ្ជនៈខ្សល់ស្ទះមានខ្សល់ :** ភ្លឺភ្លើ ខកខាន ឃោរឃៅ ស្តាង ឈ្នាន់ ឋិត ណាមរា ថាំង ធ្នូ ភ្នាល់ ផង នានៅ ។
+ **ព្យញ្ជនៈខ្សល់ស្ទះគ្មានខ្សល់ :** អ៊ូអែ កោងកាច អាំង គាត់ ពព្រិច ប៉ប្រេះ ចូល បាយ ជាង ប៊ិច ទទឹក តឹង ជីង ឌុប តុបតែង ចចេស ទំ ។

ខ.

ព្យញ្ជនៈខ្សល់ច្រមុះ	ពាក្យ	ពាក្យ
ង៉	ង៊ុកង៉ក់	ង៉ាៗ
ង	ង្វួត	ង្វិត
ញ៉	ញ្ជ៉ែញ្ជ៉ង	ញ៉ាំ
ញ	ញញឹម	ញញួរ
ន៑	សេនា	វាសនា
ណ	ណែនាំ	ណា
ណ	និង	នាំ
ម៉	ម៉ុម	ម៉ាប់
ម	មុន	មមៃ

គ. ការវាយតម្លៃ

- គ្រូសួរបញ្ជាក់ឡើងវិញ ៖
  - ដូចម្តេចហៅថា ព្យញ្ជនៈ ?

    ចម្លើយ : ព្យញ្ជនៈគឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេង បន្តឹឡើងដោយមានទំនប់ និងប្រកបដោយសូរពុំច្បាស់លាស់ ។
  - តើគេចែកព្យញ្ជនៈយ៉ាងដូចម្តេច ?

    ចម្លើយ : ព្យញ្ជនៈអាចចែកតាមលក្ខណៈបន្តឹ តាមលក្ខណៈខ្យល់ និងលក្ខណៈឮ ។
  - តាមលក្ខណៈមានខ្យល់និងគ្មានខ្យល់ តើចែកព្យញ្ជនៈជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

    ចម្លើយ : ចែកចេញជា ៤ គឺព្យញ្ជនៈស្ទះ ច្រមុះមាត់ និងបង្ហូរ ។
  - តើការបន្តឹព្យញ្ជនៈស្ទះចែកចេញជាប៉ុន្មានដំណាក់កាល ? អ្វីខ្លះ ?

    ចម្លើយ : មាន ៣យ៉ាងគឺ ការរៀបចំស្ថានភាពនៃប្រដាប់សំឡេង ការប្រឹងនៃប្រដាប់សំឡេង និងការផ្លាស់កន្លែងនៃប្រដាប់សំឡេងពីទីបន្តឹដើម្បីលែងសន្ទុះខ្យល់ ។
  - តើព្យញ្ជនៈស្ទះ មានប៉ុន្មានផ្នែក ? អ្វីខ្លះ ?

    ចម្លើយ : មាន ២ផ្នែក គឺព្យញ្ជនៈស្ទះគ្មានខ្យល់ និងព្យញ្ជនៈស្ទះមានខ្យល់ ។
  - តើព្យញ្ជនៈស្ទះគ្មានខ្យល់មានអ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈស្ទះគ្មានខ្យល់ មាន កគ [k] ចជ [c] ដឌ [d] តទ [t] បប [b] ប៉ព [p] ។
  - តើព្យញ្ជនៈស្ទះមានខ្យល់មានអ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈស្ទះមានខ្យល់ មាន ខឃ [kh] ឆឈ [ch] ឋឍ [th] ថធ [th] ផភ [ph] ។
  - ដូចម្តេចហៅថា ព្យញ្ជនៈស្ទះ ?

    ចម្លើយ : គឺជាព្យញ្ជនៈបន្តឹឡើងដោយមានបម្រឹង និងបំលាស់កន្លែងនៃប្រដាប់សំឡេង ។
  - តើព្យញ្ជនៈខ្យល់ច្រមុះមានអ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈខ្យល់ច្រមុះមាន ង៉ង ញ៉ញ ន៉ណន ម៉ម ។
  - ដូចម្តេចហៅថា ព្យញ្ជនៈខ្យល់ច្រមុះ ?

    ចម្លើយ : គឺជាព្យញ្ជនៈបន្តឹឡើងដោយមានភាពរំពងក្នុងច្រមុះ ។
  - តើព្យញ្ជនៈខ្យល់បង្ហូរត្រដុសមានលក្ខណៈដូចម្តេច ?

    ចម្លើយ : ការបន្តឹព្យញ្ជនៈក្នុងពាក្យខាងលើ មានដំណើរខ្យល់ផ្តុំបង្ហូរដែលធ្វើឱ្យឮឡើងដោយត្រដុស ។
  - តើព្យញ្ជនៈខ្យល់បង្ហូរត្រដុសមានអ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈខ្យល់បង្ហូរត្រដុសមាន យ៉យ រ៉រ ឡ្យល វ៉វ សស៊ ហហ៊ ។
  - ដូចម្តេចហៅថា ខ្យល់បង្ហូរត្រដុស ?

    ចម្លើយ : គឺជាព្យញ្ជនៈបន្តឹឡើងដោយមានដំណើរខ្យល់ផ្តុំបង្ហូរត្រដុស ។
  - តាមលក្ខណៈឮ តើគេចែកព្យញ្ជនៈជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

    ចម្លើយ : តាមលក្ខណៈឮ គេចែកព្យញ្ជនៈជាពីរផ្នែកគឺ ព្យញ្ជនៈឮនិងព្យញ្ជនៈថ្លង់ ។

- តើព្យញ្ជនៈឮមានអ្វីខ្លះ ? សូមផ្តល់ឧទាហរណ៍ ។

  ចម្លើយ : ព្យញ្ជនៈឮមាន ដឌ [d] បប៊ [b] ង៉ង [ŋ] ញញ៉ [ɲ] ណន៑ន [n] មម៉ [m] យយ៉ [j] រ៉រ [r] ឡល៉ល [l] វ៉វ [v] ។

- ដូចម្តេចហៅថាព្យញ្ជនៈឮ ?

  ចម្លើយ : ព្យញ្ជនៈឮគឺជាព្យញ្ជនៈធ្វើចន្លោះខ្យែសំឡេងឱ្យញាប់ញ័រ ។

- តើព្យញ្ជនៈថ្លង់មានអ្វីខ្លះ ? សូមផ្តល់ឧទាហរណ៍ ។

  ចម្លើយ : ព្យញ្ជនៈថ្លង់មាន កគ ខឃ ចជ ឆឈ តទ ប ថ ផ ឍ ធ ប៉ព ផភ សស៊ ហហ៊ អអ៊ ។

- ដូចម្តេចហៅថា ព្យញ្ជនៈថ្លង់ ?

  ចម្លើយ : ព្យញ្ជនៈថ្លង់ គឺជាព្យញ្ជនៈពុំធ្វើចន្លោះខ្យែសំឡេងឱ្យញាប់ញ័រ ។

- គ្រូឱ្យសិស្សធ្វើលំហាត់ គ , ឃ ក្នុងសៀវភៅសិស្សទំព័រទី ១៧០ ដាក់ក្នុងសៀវភៅរៀងៗខ្លួន
- គ្រូណែនាំពីរបៀបធ្វើលំហាត់ គ , ឃ ក្នុងសៀវភៅសិស្សទំព័រទី ១៧០
- សិស្សធ្វើកិច្ចការរៀងៗខ្លួន បន្ទាប់ពីធ្វើលំហាត់ចប់ គ្រូប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ ធ្វើការកែលំអ និងវាយតម្លៃ ។

គ.

ព្យញ្ជនៈខ្យល់ច្រមុះ	ពាក្យ	ពាក្យ
យ៉	យ៉ាប់	យ៉ាង
យ	យួរ	យាង
រ៉	រ៉ាប់រង	រ៉ែៗ
រ	រៃ	រឿង
ឡ	ឡាន	ឡើយ
ល	លាន	លួច
ល៉	តុលា	សាលា
រ៉	រ៉ើយ	រ៉ៃ
រ	វាយ	វាល
ស	សរសេរ	សាប
ស៊	ស៊ុប	តស៊ូ
ហ	ហួស	ហេតុ
ហ៊	ហ៊ឹង	ហ៊ុន

ឃ. ចូររកព្យញ្ជនៈឮនិងព្យញ្ជនៈថ្លង់ក្នុងពាក្យខាងក្រោម ៖

+ ប៊ូល ប្រោយ ម៉ឺន ឱន ង៉ាវ ងាប់ ញ៉ាំ ញញួរ ណាស់ នាំ សយនា ឡាន សាលា យាន យ៉ាប់យ៉ឺន មីនា មមៃ កកាយ ប៉ើង ពង គាស់ ដុំ ខូច ឃ្លាង តតេះ ទូក ជួល ឋិត ថ្នាក់ ធាង រវល់ ហ៊ឹង ហួស សក ស៊ុប អន់ អ៊ឹកអ៊ាក រ៉ៗ រីករវរ ផ្សារ ភ្ញី ទាល់ ធេងធោង តែង ជញ្ជីង ពពុះ ។



ការយោសនាបញ្ចុះបញ្ចូល

១. វត្ថុបំណង

- ប្រាប់និងប្រើប្រាស់សំនួនក្នុងការយោសនាបញ្ចុះបញ្ចូលបានត្រឹមត្រូវ
- និយាយយោសនាបញ្ចុះបញ្ចូលប្រកបដោយប្រសិទ្ធភាព
- មានទំនុកចិត្តក្នុងការនិយាយបញ្ចុះបញ្ចូល ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៧១-១៧២
- ប័ណ្ណយោសនាជាក់ស្តែង រូបថតផ្ទាំងផ្សព្វផ្សាយសម្រាប់ធ្វើការយោសនា និងប័ណ្ណផ្សព្វផ្សាយផ្សេងៗ ។

៣. ព័ត៌មានជំនួយ

ដើម្បីជាជំនួយដល់សិស្សក្នុងការស្វែងយល់ខ្លឹមសារមេរៀនឱ្យកាន់តែច្បាស់និងដើម្បីជាជំនួយក្នុងការធ្វើលំហាត់ សូមលោកគ្រូអ្នកគ្រូប្រើប្រាស់ប័ណ្ណយោសនាជាក់ស្តែង រូបថតផ្ទាំងផ្សព្វផ្សាយសម្រាប់ធ្វើការយោសនា និងប័ណ្ណផ្សព្វផ្សាយផ្សេងៗ ។

៤. ឈានំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូសរសេរចំណងជើង "ការយោសនាបញ្ចុះបញ្ចូល" ដាក់លើក្តារខៀន ហើយសួរសំណួរបំផុស ៖
  - ដូចម្តេចហៅថា ការយោសនាបញ្ចុះបញ្ចូល ? គេបញ្ចុះបញ្ចូលឱ្យធ្វើអ្វីខ្លះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សអានសេចក្តីពន្យល់ក្នុងសៀវភៅសិស្សទំព័រទី ១៧១ រួចសួរសំណួរ ៖
  - តើគេយោសនាបញ្ចុះបញ្ចូលតាមរយៈអ្វីខ្លះ ?

    ចម្លើយ : តាមរយៈវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ខិតប័ណ្ណ បដា ... ។
  - តើគេយោសនាបញ្ចុះបញ្ចូលអំពីអ្វីខ្លះ ?

    ចម្លើយ : អំពីការផ្សព្វផ្សាយពាណិជ្ជកម្ម ការយោសនានយោបាយ ការយោសនាផ្សព្វផ្សាយការអប់រំជាដើម ។
  - តើគេយោសនាបញ្ចុះបញ្ចូលដើម្បីអ្វីខ្លះ ?

    ចម្លើយ : ដើម្បីទាក់ទាញអតិថិជន ឬសមាជិកឱ្យគាំទ្រផលិតផល ឬអង្គការសមាគមផ្សេងៗ ។
  - ដើម្បីយោសនាបញ្ចុះបញ្ចូលឱ្យមានប្រសិទ្ធភាព តើយោសនិកត្រូវធ្វើដូចម្តេចខ្លះ ?

    ចម្លើយ : ការប្រើប្រាស់ប្រព័ន្ធយោសនាមានដូចជា តាមវិទ្យុ ទូរទស្សន៍ ផ្ទាំងរូបភាព ខិតប័ណ្ណ បដា និងការប្រើប្រាស់សំនួនវោហារសព្ទល្អៗដូចជា សំនួនអួតសរសើរ សំនួនបញ្ចើចបញ្ចើជាដើម ដើម្បីទាក់អារម្មណ៍និងទឹកចិត្តឱ្យគេគាំទ្រ ។

ខ. ការនិយាយ

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗហាត់និយាយក្នុងក្រុមដោយអានតាមអត្ថបទគំរូក្នុងសៀវភៅសិស្ស ។
- គ្រូឱ្យជ្រើសរើសសមាជិកក្រុមនីមួយៗឡើងនិយាយតាមអត្ថបទគំរូដោយមើលសៀវភៅ បង្ហាញសិស្សទាំងអស់
- គ្រូសួរសំណួរទាក់ទងនឹងខ្លឹមសារលំអិតរបស់អត្ថបទ ៖
  - តើក្នុងអត្ថបទ ក គេផ្សព្វផ្សាយពីអ្វី ?

    ចម្លើយ : ការបញ្ចាំងខ្សែភាពយន្ត ។
  - តើគេប្រើសំនួនដូចម្តេចខ្លះ ?

    ចម្លើយ : កំពូលវណ្ណកម្មថ្មីល្អគ្មានពីរមិនធ្លាប់មានពីមុនមក ខ្សែភាពយន្តខ្លាតធំ ពណ៌ធម្មជាតិ មើលឃើញច្បាស់ត្រជាក់ភ្នែក សម្តែងដោយតារាងកល្បីៗកំពុងពេញនិយម គ្រប់ឈុតគ្រប់ឆាកសុទ្ធតែធ្វើឱ្យទស្សនិកជនរំភើប ទប់អារម្មណ៍មិនបាន កំប្លែងសើចចុកពោះ កំសត់ស្រក់ទឹកភ្នែក និងមានឆាកប្រយុទ្ធស៊ីសាច់ហុតឈាម ប្រកាប់ប្រចាក់គ្នាយ៉ាងសាហាវ ... ។ ពេលបានទស្សនាហើយ លោកអ្នកនឹងបាត់អស់នូវភាពតានតឹងក្នុងអារម្មណ៍ បន្សល់ទុកនូវតែភាពរីករាយ ទស្សនាហើយចង់ទស្សនាទៀត សំបុត្រទិញមួយថែមជូនមួយ ។
  - តើក្នុងអត្ថបទ ខ គេផ្សព្វផ្សាយពីអ្វី ?

    ចម្លើយ : ការលក់សម្លៀកបំពាក់ ។
  - តើគេប្រើប្រាស់សំនួនដូចម្តេចខ្លះ ?

    ចម្លើយ : នាំចូលសម្លៀកបំពាក់បុរសស្ត្រីពីបរទេស មានគុណភាពអន្តរជាតិ មិនក្លែងក្លាយ ស្លៀកពាក់យ៉ាងស្រស់សង្ហា ទំនើបទាន់សម័យ បញ្ចុះតម្លៃ ២០% និងផ្តល់ជូនសន្លឹកឆ្នោតផ្សងសំណាងមួយសន្លឹក ។
- គ្រូឱ្យសិស្សអានបច្ចេកទេសសម្រាប់ឃោសនាបញ្ចុះបញ្ចូលក្នុងសៀវភៅសិស្សទំព័រទី ១៧២ រួចសួរ ៖
  - ដើម្បីឃោសនាបញ្ចុះបញ្ចូល តើគេប្រើសំនួនអ្វីខ្លះ ?

    ចម្លើយ : សំនួនពាក្យអួតសរសើរគុណភាព សំនួនសរសើរអត្ថប្រយោជន៍និងសំនួនបញ្ជើចបញ្ជើ ។
  - តើសំនួនពាក្យអួតសរសើរគុណភាព គេប្រើពាក្យអ្វីខ្លះ ?

    ចម្លើយ : កំពូលវណ្ណកម្មថ្មី ល្អគ្មានពីរ មិនធ្លាប់មានពីមុនមក ពណ៌ធម្មជាតិមើលឃើញច្បាស់ ត្រជាក់ភ្នែក តារាងកល្បីៗកំពុងពេញនិយម គុណភាពអន្តរជាតិ ... ។
  - តើសំនួនសរសើរអត្ថប្រយោជន៍ គេប្រើពាក្យអ្វីខ្លះ ?

    ចម្លើយ : បាត់អស់នូវភាពតានតឹងក្នុងអារម្មណ៍ បន្សល់ទុកនូវតែភាពសប្បាយរីករាយ ស្លៀកពាក់ យ៉ាងស្រស់សង្ហា ទំនើបទាន់សម័យ ... ។
  - តើសំនួនបញ្ជើចបញ្ជើ គេប្រើពាក្យអ្វីខ្លះ ?

    ចម្លើយ : រំភើបទប់អារម្មណ៍មិនបាន កំប្លែងសើចចុកពោះ កំសត់ស្រក់ទឹកភ្នែក ប្រយុទ្ធស៊ីសាច់ហុតឈាម ប្រកាប់ប្រចាក់គ្នាយ៉ាងសាហាវ សំបុត្រទិញមួយថែមជូនមួយ ស្លៀកពាក់យ៉ាងស្រស់សង្ហា ទំនើបទាន់សម័យ និងផ្តល់ជូនសន្លឹកឆ្នោតផ្សងសំណាងមួយសន្លឹក ... ។

- តើប្រើបច្ចេកទេសអ្វីខ្លះ សម្រាប់ការបញ្ចុះបញ្ចូល ?

ចម្លើយ :

+ បង្ហាញឈ្មោះវត្ថុ ឬឈ្មោះអ្វីមួយដែលគួរឱ្យរីករាយ
+ បង្ហាញភាពចាំបាច់នៃវត្ថុ
+ ប្រើពាក្យទាក់ទាញប្រកបដោយភាពរំជើបរំជួល
+ ប្រើពាក្យបំផុសអារម្មណ៍ឱ្យរំភើប
+ បញ្ជាក់ពីគុណភាពដ៏ល្អនៃវត្ថុ ។

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងសមាជិកម្នាក់ម្តងៗ ហ៊ឺកហាត់និយាយសម្តីផ្ដាល់ខ្លួនដោយមិនមើលសៀវភៅ ។
- ជ្រើសរើសសមាជិកក្រុមនីមួយៗឡើងនិយាយដោយសម្តីផ្ដាល់ខ្លួនមិនមើលសៀវភៅ បង្ហាញសិស្សទាំងអស់ ។

គ. ការវាយតម្លៃ

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ ក្នុងសៀវភៅសិស្សទំព័រទី ១៧២
- គ្រូណែនាំក្រុមនីមួយៗ ឱ្យពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីទាក់ទាញអតិថិជនឱ្យមកគាំទ្រដូចខាងក្រោម ៖
  + ក្រុមទី ១ : ពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការសម្តែងភាពយន្ត
  + ក្រុមទី ២ : ពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការប្រគំតន្ត្រី
  + ក្រុមទី ៣ : ពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការសម្តែងមហោស្រពសិល្បៈ
  + ក្រុមទី ៤ : ពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការលក់ផលិតផលរូបចម្លាក់
  + ក្រុមទី ៥ : ពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការលក់ផលិតផលផ្ទាំងគំនូរ
  + ក្រុមទី ៦ : ពិភាក្សាតាក់តែងអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការលក់ផលិតផលសៀវភៅរឿង
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ រួចហ៊ឺកហាត់និយាយក្នុងក្រុម
- គ្រូឱ្យក្រុមនីមួយៗឡើងបង្ហាញលទ្ធផលការងារក្រុមខ្លួន
- គ្រូដឹកនាំសិស្សធ្វើការវាយតម្លៃនិងកែលំអ ។



ការឃោសនាបញ្ចុះបញ្ចូល

១. វត្ថុបំណង

- ប្រាប់ពីទម្រង់សំណួរមធ្យោបាយនិងបច្ចេកទេសនៃការឃោសនាបញ្ចុះបញ្ចូលបានត្រឹមត្រូវ
- សរសេរអត្ថបទបញ្ចុះបញ្ចូលបានត្រឹមត្រូវនិងមានប្រសិទ្ធភាព ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៧៣-១៧៤
- បំណែជាក់ស្តែង រូបថតផ្ទាំងផ្សព្វផ្សាយសម្រាប់ធ្វើការឃោសនា និងបំណែផ្សព្វផ្សាយផ្សេងៗ ។

៣. ព័ត៌មានជំនួយ

ដើម្បីជាជំនួយដល់សិស្សក្នុងការស្វែងយល់ខ្លឹមសារមេរៀនឱ្យកាន់តែច្បាស់និងដើម្បីជាជំនួយក្នុងការធ្វើលំហាត់ សូមលោកគ្រូអ្នកគ្រូប្រើប្រាស់បំណែជាក់ស្តែង រូបថតផ្ទាំងផ្សព្វផ្សាយសម្រាប់ធ្វើការឃោសនា និងបំណែផ្សព្វផ្សាយផ្សេងៗ ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើង "ការឃោសនាបញ្ចុះបញ្ចូល" ដាក់លើក្តារខៀន ហើយសួរសំណួរបំផុស ។
  - ដូចម្តេចហៅថា ការឃោសនាបញ្ចុះបញ្ចូល ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើគេឃោសនាបញ្ចុះបញ្ចូលដើម្បីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើគេឃោសនាបញ្ចុះបញ្ចូលដូចម្តេច ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សអានសេចក្តីពន្យល់ក្នុងសៀវភៅសិស្សទំព័រទី ១៧៣ រួចសួរសំណួរ ៖
  - តើគេឃោសនាបញ្ចុះបញ្ចូលតាមរយៈអ្វីខ្លះ ?

    ចម្លើយ : តាមរយៈវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ខិតប័ណ្ណ បដា ... ។
  - តើគេឃោសនាបញ្ចុះបញ្ចូលអំពីអ្វីខ្លះ ?

    ចម្លើយ : អំពីការផ្សព្វផ្សាយពាណិជ្ជកម្ម ការឃោសនានយោបាយ ការឃោសនាផ្សព្វផ្សាយការអប់រំជាដើម ។
  - តើគេឃោសនាបញ្ចុះបញ្ចូលដើម្បីអ្វីខ្លះ ?

    ចម្លើយ : ដើម្បីទាក់ទាញអតិថិជន ឬសមាជិកឱ្យគាំទ្រផលិតផល ឬអង្គការសមាគមផ្សេងៗ ។

- ដើម្បីឃោសនាបញ្ចុះបញ្ចូលឱ្យមានប្រសិទ្ធភាព តើឃោសនិកត្រូវធ្វើដូចម្តេចខ្លះ ?

  ចម្លើយ : ការប្រើប្រាស់មធ្យោបាយឃោសនាមានដូចជា វិទ្យុ ទូរទស្សន៍ ផ្ទាំងរូបភាព ខិតប័ណ្ណ បដា និងការប្រើប្រាស់សំនួនវោហារសព្ទល្អៗដូចជា សំនួនអួតសរសើរ សំនួនបញ្ចើចបញ្ចើជាដើម ដើម្បីទាក់អារម្មណ៍និងទឹកចិត្តឱ្យគេគាំទ្រ ។

ខ. ការអនុវត្ត

- គ្រូឱ្យសិស្សអានលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១៧៣-១៧៤ ជាក្រុម ។
- គ្រូចែកសិស្សជា ៥ក្រុម រួចបែងចែកកិច្ចការនិងណែនាំក្រុមនីមួយៗឱ្យធ្វើគម្រោងអត្ថបទដូចខាងក្រោម ៖
  + ទី ១ : សរសេរបដាផ្សព្វផ្សាយអំពីការសម្តែងសិល្បៈមហោស្រពអង្គរ
  + ទី ២ : សរសេរអត្ថបទផ្សាយពាណិជ្ជកម្មអំពីការលក់សៀវភៅនៅបណ្ណាគារ
  + ទី ៣ : សរសេរអត្ថបទផ្សាយអំពីការអប់រំសុខភាពទាក់ទងនឹងការជក់បារី
  + ទី ៤ : សរសេរអត្ថបទផ្សាយអំពីការគោរពច្បាប់ចរាចរណ៍
  + ទី ៥ : សរសេរអត្ថបទផ្សាយអំពីការហាមប្រើប្រាស់អាវុធជាតិផ្ទុះ ។
- គ្រូឱ្យក្រុមនីមួយៗសរសេរព្រាងគម្រោងទាក់ទងនឹងប្រធានខាងលើ ។
- គ្រូឱ្យក្រុមនីមួយៗប្តូរកិច្ចការគ្នាដើម្បីធ្វើការកែលំអ ។ ក្នុងការកែលំអ បើពិនិត្យឃើញថា កិច្ចការក្រុមដទៃមានកំហុសឬមានចំណុចខ្វះខាត ត្រូវឱ្យពិភាក្សារកចំណុចឯកភាពគ្នាជាមួយសាមីក្រុមជាមុនសិន មុននឹងធ្វើការកែលំអ ។
- គ្រូឱ្យក្រុមនីមួយៗប្រគល់កិច្ចការឱ្យម្ចាស់ដើមវិញ ។
- គ្រូឱ្យក្រុមនីមួយៗកែលំអគម្រោងឱ្យបានត្រឹមត្រូវ ។

គ. ការវាយតម្លៃ

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូណែនាំក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ ក្នុងសៀវភៅសិស្សទំព័រទី ១៧៣-១៧៤ ដោយប្រើគម្រោងខាងលើ
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាសរសេរអត្ថបទផ្សព្វផ្សាយទាក់ទងនឹងប្រធានបទនីមួយៗ
- បន្ទាប់ពីធ្វើកិច្ចការចប់ គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូនិងសិស្សធ្វើការបូកសរុបនិងកែលំអ ។



តថភាព

អ្វីទៅដែលហៅថា តថភាព ? តថភាព គឺជាការពិត ពីអតីតកាល ហើយត្រូវបានចងក្រងជាស្នាដៃឡើង ដើម្បីឆ្លុះបញ្ចាំងនូវប្រវត្តិ ឬបញ្ហាសង្គមនាសម័យណាមួយ តាមរយៈសិល្បវិធីរបស់អ្នកនិពន្ធ។ តថភាព ជាការបង្ហាញពីបទពិសោធនៃការរស់នៅរបស់មនុស្ស ពីសម័យកាលមួយឈានទៅរកសម័យកាលមួយទៀត ដើម្បីជាជោគជ័យក្នុងពេលបច្ចុប្បន្ន។ អត្ថិភាពសង្គមមួយ បើមិនបានគិត ឬពិចារណា ឬក៏មិនបានសិក្សាឱ្យបានល្អិតល្អន់នៃតថភាពទេនោះ ភាពជោគជ័យមានតិចតួចណាស់។ ដោយហេតុនេះហើយ ទើបអក្សរសិល្បមានតួនាទីយ៉ាងសំខាន់ ក្នុងសង្គមគ្រួសារនិងសង្គមជាតិឈានទៅរកជោគជ័យព្រមទាំងសុខសន្តិភាព។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	វិទ្យាសាស្ត្រ	វិទ្យាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	១៧៣	១៧៥
• បំណិន : លក្ខណៈតថៈនៅក្នុងអក្សរសិល្បខ្មែរ	២ម៉ោង	២ម៉ោង	១៧៤-១៧៥	១៧៦
• អំណានទី ១ : ប្រមូលកំណែន	២ម៉ោង	៤ម៉ោង	១៧៦-១៧៩	១៧៨
• វេយ្យាករណ៍ : ព្យញ្ជនៈផ្សំ	២ម៉ោង	២ម៉ោង	១៨០-១៨២	១៨២
• អំណានទី ២ : ជីវិតអន្ធការរបស់ប្រជាជនខ្មែរ	៣ម៉ោង	៤ម៉ោង	១៨៣-១៨៦	១៨៤
• ការស្តាប់ : រឿងទុរគត	០ម៉ោង	២ម៉ោង	១៨៧-១៩០	១៨៩
• និយាយ : បកស្រាយន័យសុភាសិតនិងពាក្យស្លោក	១ម៉ោង	២ម៉ោង	១៩១-១៩៣	១៩០
• សំណេរ : តែងសេចក្តីពិភាក្សា	២ម៉ោង	៤ម៉ោង	១៩៤-២០០	១៩២

១. សិក្សាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ៨ ទំព័រទី ១៧៥ បន្ទាប់មកគ្រូសរសេរចំណងជើងមេរៀន "តថភាព" ដាក់លើក្តារខៀនរួចសួរ :
  - តើដូចម្តេចដែលហៅថា "តថភាព" ?

    ចម្លើយ : តថភាព គឺជាការពិត ពីអតីតកាល ហើយត្រូវបានចងក្រងជាស្នាដៃឡើងដើម្បីឆ្លុះបញ្ចាំងនូវប្រវត្តិឬបញ្ហាសង្គមនាសម័យកាលណាមួយ តាមរយៈសិល្បវិធីរបស់អ្នកនិពន្ធ។

២. សិក្សាលើរូបភាព

- គ្រូឱ្យសិស្សសង្កេតមើលរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ១៧៥ រួចសួរ :
  - តើអ្នកឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

    ចម្លើយ : ចំពីមុខមានស្ពានមួយ ដែលជាស្ពានមិត្តភាពកម្ពុជា-ចិន សេកុង។ ស្ពាននេះមានខ្ពស់ប្រកបដោយសោភណភាពនិងគុណភាព។

លក្ខណៈតថៈនៅក្នុងអក្សរសិល្ប៍

១. វត្ថុបំណង

- ប្រាប់ពីបញ្ហត្តិលក្ខណៈតថៈក្នុងអក្សរសិល្ប៍បានច្បាស់លាស់
- បង្ហាញពីចំណងអ្នកនិពន្ធក្នុងការលើកយកតថភាពសង្គមមកឆ្លុះបញ្ចាំង
- បង្ហាញលក្ខណៈតថៈក្នុងស្នាដៃអក្សរសិល្ប៍នានាបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៧៦-១៧៧
- កំណាព្យមើលផែនដីខ្មែរ (សម័យប៉ុលពត)អ្នកនិពន្ធ ជួន ម៉ែន
- រឿងគូលីកំនែន អ្នកនិពន្ធ អ៊ឹម ថុក
- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធ សួន សុរិន្ទ ។

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- លោក-អ្នកគ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៧៦-១៧៧រួចសរសេរចំណងជើង "លក្ខណៈតថៈនៅក្នុងអក្សរសិល្ប៍"ដាក់លើក្តារខៀន ហើយសួរ :
  - តើអក្សរសិល្ប៍មានតួនាទីដូចម្តេច ?

    ចម្លើយ : អក្សរសិល្ប៍មានតួនាទីឆ្លុះបញ្ចាំងតថភាពសង្គម ។
  - តើតថភាពសង្គមដែលអ្នកនិពន្ធ លើកយកមកបង្ហាញមានអ្វីខ្លះ ?

    ចម្លើយ : គឺជាហេតុការណ៍សង្គមនាសម័យកាលណាមួយ ដែលអ្នកនិពន្ធបានលើកយកមកកែច្នៃជាមួយគំនិតផ្ទាល់ខ្លួនប្រកបទៅដោយសិល្បវិធីដើម្បីបង្កើតជាស្នាដៃនិម្មិតកម្មឡើង ។
  - តាមរយៈអត្ថបទនេះ តើមានលក្ខណៈតថៈយ៉ាងណាខ្លះ ?

    ចម្លើយ : តថភាពក្នុងសម័យប្រល័យពូជសាសន៍បានបង្ហាញដូចតទៅ :
    + តម្លៃជីវិតប្រជាជនក្នុងសង្គមប្រល័យពូជសាសន៍ស្មើនឹងដំឡូងមួយដុំ ស្ពៃមួយគុម្ព បាយក្រៀមមួយដៃ ។
    + បំផ្លាញសាសនា បំបិទសិទ្ធិសេរីភាពនៃការរស់នៅរបស់មនុស្ស ។
    + បើគេយកមនុស្សទៅសម្លាប់ គេប្រើពាក្យ "រៀនសូត្រ អប់រំ" ។

ខ. ការហ្វឹកហាត់

- ចែកជា ២ក្រុម ឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១៧៦-១៧៧ :

- ក្រុមទី ១ : កំណត់នូវលក្ខណៈតួអក្សរសិល្ប៍ក្នុងវគ្គទី ១ "សេចក្តីស្រេកឃ្លានបានបង្ខំចិត្តគំនិតរបស់សម ... ហើយក៏កញ្ឆក់កាបូបស្បែកក្រពើយកចេញពីដៃនៃស្ត្រីនោះភ្លាម" ។

ចម្លើយ : លក្ខណៈតួអក្សរសិល្ប៍ក្នុងវគ្គទី ១នេះគឺ :

+ ដោយសេចក្តីស្រេកឃ្លានមនុស្សបាត់បង់វិចារណញ្ញាណ (សមប្រៀបប្រួលផ្លាស់ប្តូរពីបាតដៃទៅខ្នងដៃភ្លាមៗ) ។
+ លក្ខណសម្បត្តិរបស់បុគ្គលអាស្រ័យនៅលើជីវភាពសុកសួស្តី (បុរសស្ត្រីនិងស្ត្រីទាំងពីរនាក់នេះតែងខ្លួនរៀបរយស្រគត់ស្រគំ មានលក្ខណៈបង្ហាញថា ជាអ្នកមានទ្រព្យសម្បត្តិសុកសួស្តី) ។
+ ដរាបណាក្រពះមិនទាន់ឆ្អែត មនុស្សមិនទាន់គិតដល់កិត្តិយសឡើយ (សមដើរសសៀរចូលទៅជិត ហើយក៏កញ្ឆក់កាបូបស្បែកក្រពើយកចេញពីដៃនៃស្ត្រីនោះភ្លាម) ។

- ក្រុមទី ២ : កំណត់នូវលក្ខណៈតួអក្សរសិល្ប៍ក្នុងវគ្គទី ២ (ក)"លីមនិងអន្ទិតថនបានដើរកាត់ភូមិនៅត្បូងដល់ចុងភូមិ ... យកតម្លៃឈ្នួលម្នាក់ ១៥០រៀល"

ចម្លើយ : លក្ខណៈតួអក្សរសិល្ប៍ក្នុងវគ្គទី ២ (ក)នេះគឺ :

+ សម័យអាណានិគមបារាំង មន្ត្រីដៃជើងបារាំងតែងគាបសង្កត់ ដើម្បីកេងយកចំណេញពីប្រជារាស្ត្រតាមរយៈកំណែន (ឆ្នាំនេះ រាជការបង្គាប់ឱ្យកេណ្ឌគួលី ១០០នាក់មួយលើកៗ ក្នុងមួយឃុំ ហើយនរណារឹងទទឹងបង្គាប់នេះ មេឃុំមានអំណាចណាស់ចាប់ដាក់ខ្នោះបញ្ជូនទៅសាលាស្រុក ទៅសាលាខេត្ត) ។
+ មន្ត្រីឃុំបានប្រព្រឹត្តអំពើពុករលួយតាមរយៈកំណែន (ផាន់បានចាត់ក្រុមប៉ូលីសឱ្យកេណ្ឌ ២០នាក់ ... អ្នក ២០នាក់នោះឃ្លាតពីផ្ទះមិនបានទេ ។ ... ផាន់បង្ខំឱ្យអ្នក ២០នាក់នោះបង់ប្រាក់វិញ) ។

គ. ការវាយតម្លៃ

- ឱ្យសិស្សកំណត់នូវលក្ខណតួអក្សរសិល្ប៍ក្នុងវគ្គទី ២ (ខ) "មេឃុំផាន់ ធ្វើជាបន្ទរខ្លាំងទៅដល់អ្នកក្រវេទនា ។ ... ទិញអីវ៉ាន់ជូនលោកប្រុសលោកស្រីខ្លះ ..." ។

ចម្លើយ : លក្ខណតួអក្សរសិល្ប៍ក្នុងវគ្គទី ២ (ខ)នេះគឺ :

+ មន្ត្រីឃុំតែងតែធ្វើប្រជាភិថុតិចំពោះប្រជារាស្ត្រ ដើម្បីផលប្រយោជន៍ខ្លួន (គាត់មិនយកប្រាក់ឈ្នួលភ្លាមទេ គាត់ធ្វើជាចេញប្រាក់ផ្ទាល់ខ្លួនគាត់ជួសមុនសិន ។ ... ក្នុងកំណែនមួយលើកៗបានធនធាន បានអំណាច បានក្តីដឹងគុណខ្លះពីអ្នកក្រវេទនា) ។
+ បក្សពួកនិយមក្នុងជួររដ្ឋអំណាចអាណានិគម (ផាន់ចែកទៅអ្នកភ្នាក់ងារគាត់ខ្លះ ទុកខ្លួនគាត់ខ្លះ ទិញអីវ៉ាន់ជូនលោកប្រុស លោកស្រីខ្លះ ...) ។



ប្រមូលកំណែន

១. ឥស្តុបំណង

- ប្រាប់ពីលក្ខណៈតួចរបស់រឿងបានត្រឹមត្រូវ
- បង្ហាញពីគំនិតសំខាន់បង្កប់កាលអាកាសនិងកាលកំណត់តែង
- វិភាគលក្ខណសម្បត្តិតួអង្គបានច្បាស់លាស់និងត្រឹមត្រូវ ។

២. សម្ភារបង្រៀន

- សៀវភៅសិស្សទំព័រទី ១៧៨-១៨១
- រឿងគូលីកំណែន អ្នកនិពន្ធ អ៊ឹម ថុក ។

៣. លំនាំបង្រៀន

ក. ត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ៨ ទំព័រទី ១៧៨ រួចសរសេរចំណងជើងអំណាន "ប្រមូលកំណែន" ដាក់លើក្តារខៀនរួចសួរ :
  - បើតាមអ្នកប៉ាន់ស្មានថាតើវគ្គ "ប្រមូលកំណែន" នេះនិយាយពីអ្វី ?

    ចម្លើយ : អាចនិយាយពីការកេណ្ឌប្រជារាស្ត្រយកទៅធ្វើការងារអ្វីមួយ ។
  - តើព្រឹត្តិការណ៍រឿងអាចកើតឡើងនៅសម័យណា ?

    ចម្លើយ : អាចកើតឡើងនៅសម័យអាណានិគមបារាំងនិងជប៉ុន ។
  - បើសង្កេតតាមរូបភាពវិញ តើអ្នកបានឃើញអ្វីខ្លះ ?

    ចម្លើយ : នៅចំពីមុខមានបុរសពីរនាក់ ម្នាក់ទំនងជាជនបរទេសមានឯកសណ្ឋានជាកងទ័ពអាចជាមេទ័ព ម្នាក់ទៀតអាចជាមន្ត្រីខ្មែរដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយជនបរទេសរូបនេះ ។ នៅខាងក្រោយមានគូលីកម្មករកំពុងធ្វើការងារសាងសង់អគារឬមូលដ្ឋានអ្វីមួយ ។
  - តើអ្នកយល់ដូចម្តេចចំពោះរូបភាពនិងចំណងជើងនៃអំណាចនេះ ?

    ចម្លើយ : ខ្ញុំយល់ថា នេះគឺជាទិដ្ឋភាពនៅការដ្ឋានមួយដែលក្រុមគូលីកំណែនត្រូវបានមន្ត្រីដែជើងអាណានិគមកេណ្ឌយកទៅធ្វើការងារ ។
- គ្រូឱ្យសិស្សធ្វើការសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ១៧៨ឬពាក្យគន្លឹះដដែទៀតក្នុងអំណាន ។

ខ. ការពង្រីកអំណាន

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៨១ :

  ចម្លើយ :

១. រឿងនេះដកស្រង់ចេញពីរឿងគូលីកំណែន វគ្គទី ៣ "ប្រមូលកំណែន"

២. អត្ថបទនេះចែកចេញជា ៤ វគ្គ ៖

- វគ្គទី ១ : "មាន់រងាវលើកទី ២ យាយម៉ុកភ្ញាក់ក្រោកឡើង ..... ទៅធ្វើជាមួយគេប្រយ័ត្នកុំមាត់ផ្តេសផ្តាស" ។

ព្រឹត្តិការណ៍វគ្គទី ១

+ យាយម៉ុករៀបចំស្បៀងអាហារទុកឱ្យលឹមចេញទៅធ្វើ ។

+ តាង៉ែតយាយម៉ុកនិយាយគ្នាពីអារម្មណ៍អាណិតកូនក្នុងការជាប់ជាកំណែន ។
+ ការផ្តាំផ្ញើរបស់យាយម៉ុក ពីស្បៀងដែលនាងហោងយកមកឱ្យលីម ។

- វគ្គទី ២ : "លីមនិងថន បានដើរកាត់ភូមិទៅតូង ..... មួយរយនាក់មានមិនដល់មួយផង" ។

ព្រឹត្តិការណ៍វគ្គទី ២

+ លីម ថន តាមុយ បណ្តើរគ្នាដើម្បីទៅជួបជុំក្រុមកំណែននៅផ្ទះមេឃុំផាន់ ។
+ តាមុយនិយាយពីល្បិចកេងប្រវ័ញ្ចលើក្រុមកំណែនរបស់មេឃុំផាន់ ។
+ សគុណដែលបានមកពីល្បិចកេងប្រវ័ញ្ចរបស់មេឃុំផាន់និងការបែងចែកផលទៅឱ្យបក្សពួកមេឃុំផាន់ ។

- វគ្គទី ៣ : "លីមនិងតាមុយបានជជែក..... ប្រយ័ត្ន ។ (តាមុយ បានទូន្មាន)" ។

ព្រឹត្តិការណ៍វគ្គទី ៣

+ មេឃុំផាន់បញ្ជូនគូលី ១០០នាក់ដោយមានប៉ូលីស ២នាក់ ដើម្បីបណ្តើរក្រុមកំណែនទៅសាលាស្រុក ។
+ ក្រុមកំណែនមកដល់ក្នុងវាលរបង មុខសាលាស្រុក និងក្រុមកំណែនដទៃទៀត ដែលអង្គុយតាមឃុំប្រកបដោយភាពតោកយ៉ាក ។
+ បាល័ដ្ឋស្រុក និងថីដោយទទួលភារៈខាងគ្រប់គ្រងកំណែននិងត្រួតពិនិត្យតាមរយៈបញ្ជីរបស់មេឃុំនីមួយៗ ។
+ បាល័ដ្ឋស្រុកបានសរសើរមេឃុំប្រមូលជនកំណែនបានច្រើន និងស្តីបន្ទោសនិងព្រមានចំពោះមេឃុំដែលប្រមូលកំណែនបានតិច ។
+ ការរិះគន់របស់លីមចំពោះមេឃុំ ដែលមានឥរិយាបថឱនលំទោននៅមុខបាល័ដ្ឋស្រុកនិងការគាំទ្រឥរិយាបថនេះរបស់តាមុយ ។
+ តាមុយរំលឹកដល់លីមឱ្យចេះប្រយ័ត្នពាក្យសម្តីរិះគន់ចំពោះមន្ត្រីអាណានិគម ។

- វគ្គទី ៤ : "លុះទទួលបញ្ជីនិងប្រមូលគូលីបាន ..... សង្គ្រាមជាស៊ីសមហាអាស៊ី" ។

+ លោកបាល័ដ្ឋ ថីដោយ និងប៉ូលីស ៥នាក់បញ្ជូនក្រុមកំណែនប្រមាណជា ២០០នាក់ទៅពោធិ៍ចិនតុង ។
+ សក្តិ ២ជប៉ុនទទួលស្វាគមន៍ចំពោះវត្តមានលោកបាល័ដ្ឋដែលបានប្រមូលកំណែនបានច្រើនដោយសន្យាឱ្យប្រឡង់ដៃសរសេរជាអក្សរជប៉ុនឱ្យចេញចូលមើលយន្តហោះឡើងចុះតាមចិត្ត ។
+ លោកបាល័ដ្ឋរីករាយនិងសន្យាថានឹងកេណ្ឌឱ្យច្រើនជាងនេះ នៅថ្ងៃក្រោយនិងជួយផ្តល់ស្លឹកឆ្មោតទៀត បើជប៉ុនត្រូវការ ។
+ ក្រុមគូលីត្រូវទាហានជប៉ុនឃុំនៅក្នុងបន្ទាយព័ទ្ធដោយរបងលួសបន្លា ឱ្យជីកដី ធ្វើផ្លូវយន្តហោះ ។

៣. ទំនាស់នៅក្នុងអត្ថបទនេះ

ក. ទំនាស់ក្នុងខ្លួន

+ តាង៉ែតយាយម៉ុក : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមានដោយការឈឺចាប់ចំពោះអំពើគាបសង្កត់របស់ពួកជាស៊ីសជប៉ុនក្នុងការកេណ្ឌកូនគាត់ទៅធ្វើជាគូលីកំណែន "អញមិនដាស់វាទេ អញចង់ទៅធ្វើគូលីជួសវាបើវាសុខចិត្ត" ។
+ លីម ថន តាមុយ : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមានដោយការឈឺចាប់ចំពោះអំពើកេងប្រវ័ញ្ចរបស់មេឃុំផាន់មកលើក្រុមកំណែន "...មេឃុំផាន់ ក្នុងកំណែនមួយលើកៗបានធនធាន បានអំណាច បានក្តីដឹងគុណខ្លះពីអ្នកក្រ ...ប្រាក់បានមកដោយវិធីនេះ ផាន់ចែកទៅអ្នកភ្នាក់ងារគាត់ខ្លះទុកខ្លួនគាត់ខ្លះ ទិញអីវ៉ាន់ជូនលោកប្រុសលោកស្រីខ្លះ..." ។
+ មេឃុំផាន់ មេឃុំស្វាយ : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមានដោយការភ័យខ្លាចនឹងអំណាចលោកបាល័ដ្ឋដែលសម្លុតគំរាមកំហែងចំពោះការប្រមូលកំណែនមិនបានតាមចំនួនកំណត់ ។

+ ក្រុមគូលីកំណែន : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមានដោយការនឹករលឹកដល់ក្រុមគ្រួសារព្រោះខ្លួនត្រូវពួកអាណានិគមកេណ្ឌទៅធ្វើគូលីរបស់ជប៉ុន ។

ខ. ទំនាស់ក្រៅខ្លួន

+ លឹម ថន តាមុយ ក្រុមកំណែន : ប្រឈមមុខនឹងមេឃុំជាន់ដោយការប្រើអំណាចគាបសង្កត់មកលើប្រជារាស្ត្រគោកចំបក់ (ជាទំនាស់រវាងតួអង្គនិងតួអង្គ) ។
+ តាង៉ែត យាយម៉ុក ប្រជារាស្ត្រនៅគោកចំបក់ : ប្រឈមមុខនឹងពួកជាស៊ីសជប៉ុនដោយគាបសង្កត់ទាំងផ្លូវកាយនិងផ្លូវចិត្តតាមរយៈមហិច្ឆតាវាតទីនិយមដើម្បីសេដ្ឋកិច្ច (ជាទំនាស់រវាងតួអង្គនឹងបញ្ហាសង្គម "សិទ្ធិសេរីភាពឯករាជ្យជាតិ") ។

៤. វិភាគតួអង្គ

ក. លឹម

+ គុណសម្បត្តិ : ពោរពេញទៅដោយលក្ខណៈវិជ្ជមាន ក្នុងការស្វែងយល់ពីបញ្ហាសង្គមដែលត្រូវស្ថិតនៅក្រោមការគាបសង្កត់របស់ពួកជាស៊ីសជប៉ុន ។ មិនតែប៉ុណ្ណោះ ចេះវិភាគស្ថានភាពសង្គមដែលគ្រប់គ្រងដោយនយោបាយជាស៊ីសជប៉ុននាសម័យកាលនោះ ព្រមទាំងមើលឃើញល្បិចកេងប្រវ័ញ្ចរបស់មន្ត្រីរាជការអាណានិគមនិយមមកលើប្រជារាស្ត្រដែលជាមូលហេតុនៃទុក្ខវេទនារបស់រាស្ត្រខ្មែរនាពេលនោះ ។
+ គុណវិបត្តិ : ទោះបីលឹមចេះវិភាគរាល់បញ្ហាចំពោះយ៉ាងណាក៏ដោយ ក៏លឹមនៅមានចំណុចខ្វះខាតខ្លះៗដោយខ្លួនពុំមានលទ្ធភាពក្នុងការរិះរកវិធីដើម្បីលើកកម្ពស់ជីវភាពគ្រួសារឱ្យបានប្រសើរ ។

ខ. មេឃុំជាន់

+ គុណសម្បត្តិ : ពុំមានទេ (ជាតួអង្គតាងឱ្យមន្ត្រីអាណានិគម) ។
+ គុណវិបត្តិ : ពោរពេញទៅដោយលក្ខណៈអវិជ្ជមាន អសកម្ម ក្នុងការអនុវត្តនយោបាយរបស់ពួកជាស៊ីសជប៉ុនជាហេតុនាំទុក្ខលំបាកគ្រប់យ៉ាងដល់ប្រជារាស្ត្រ ។ ដោយសារតែកម្មវិធីនយោបាយប្រមូលកំណែនរបស់ពួកជាស៊ីសជប៉ុន បានបង្កជាទុក្ខលំបាកពីរយ៉ាង គឺម្យ៉ាងធ្វើឱ្យប្រជារាស្ត្រខាតពេលវេលាធ្វើស្រែចំការ បាត់បង់កម្លាំងផលិត ដែលជាកម្លាំងស្នូលក្នុងការអភិវឌ្ឍជាតិ ។ ម្យ៉ាងទៀត ផ្តល់ឱកាសដល់ពួកមន្ត្រីឱកាសនិយម "ត្រីងៀតឆ្លៀតពង ត្រីក្នុងស៊ងឆ្លៀតបណ្តើរកូន ឫស្សីក្នុងក្បួនឆ្លៀតដុះទំពាំង" កេងប្រវ័ញ្ចប្រជារាស្ត្រតាមរយៈកំណែននោះទៀតផង ។ "ធម្មតាប្រាក់បានមកដោយវិធីនេះ ជាន់ចែកទៅអ្នកស្នាក់ងារគាត់ខ្លះ ទិញឥវ៉ាន់ជូនលោកប្រុសលោកស្រីខ្លះ ..." ។

គ. តាមុយ

+ គុណសម្បត្តិ : ចេះសង្កេតបញ្ហាសង្គមដែលគ្រប់គ្រងដោយពួកជាស៊ីសជប៉ុននិងមន្ត្រីអាណានិគមនិងល្បិចកេងប្រវ័ញ្ចរបស់ពួកមន្ត្រីអាណានិគមក្នុងនាមជាមនុស្សចាស់ជាច្រើនជំនាន់ ។
+ គុណវិបត្តិ : មានភាពអសកម្មដោយគិតថាអ្វីៗ សុទ្ធតែធ្វើទៅតាមច្បាប់ធម្មជាតិ គឺអ្នកធំត្រូវតែប្រកាន់ឫកក្អេងក្អាង ឯអ្នកតូចត្រូវឱនលំទោន លុតក្រាប ។

ឃ. លោកបាល័ដ្ឋ

+ គុណសម្បត្តិ : ពុំមានទេ (ជាតួអង្គតាងឱ្យមន្ត្រីអាណានិគម) ។
+ គុណវិបត្តិ : តំណាងឱ្យមន្ត្រីអាណានិគម ដែលគ្មានសីលធម៌ល្អក្នុងការគ្រប់គ្រងនិងដឹកនាំ ។ ដោយសារតែអំណាចបុណ្យសក្តិមិនញញើតនឹងប្រើឥរិយាបថអសីលធម៌ដោយការប្រមាថ មនុស្សដែលមានវ័យចាស់ជាងខ្លួននោះទេ ។

៥. អត្ថបទនេះបានឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាសម័យកាលជាស៊ីសជប៉ុន ។ ដោយវគ្គដកស្រង់នេះ បានឱ្យឃើញពីរបៀបគ្រប់គ្រងសង្គមត្រូវស្ថិតនៅក្រោមរដ្ឋអំណាចជប៉ុន ។ មន្ត្រីខ្មែរគ្រាន់តែជាអ្នកជួយបំពេញប្រយោជន៍ ជប៉ុនក្នុងការប្រមូលគូលី ដើម្បីយកទៅការដ្ឋានវាលយន្តហោះពោធិ៍ចិនតុង បម្រើមហិច្ឆតាសង្គ្រាមសេដ្ឋកិច្ចរបស់ពួកផាស៊ីសជប៉ុនតែប៉ុណ្ណោះ ។ ចំពោះអត្ថប្រយោជន៍ នៃវាលយន្តហោះនៅពេលនោះគឺសម្រាប់ជនជាតិខ្មែរពុំមានទេ សូម្បីតែចេញចូលមើលយន្តហោះឡើងចុះទាល់តែមានការអនុញ្ញាតពីសក្តិពីរជប៉ុនដែរ ។

៦. បានជាមានវត្តមានពួកជប៉ុននៅលើទឹកដីនៃប្រទេសកម្ពុជា មកពីជប៉ុនត្រូវការទីផ្សារ សម្រាប់លក់ផលិតផលខ្លួន ដែលការមានកំណើនខ្ពស់ គឺធ្វើយ៉ាងណាឱ្យវិស័យសេដ្ឋកិច្ចខ្លួនមានការរីកចម្រើន ។ ម្យ៉ាងទៀត ទីផ្សារនៅកម្ពុជា ជាទីផ្សារបស់អាណានិគមបារាំងតាំងពីឆ្នាំ ១៨៦៣រហូតមកដល់ឆ្នាំជប៉ុនចូលមកក្នុងប្រទេសកម្ពុជាក្នុងរវាង១៩៣៥រហូតមក ។ ដូចនេះមានតែធ្វើសង្គ្រាមទេ ទើបអាចដណ្តើមទីផ្សារពីបារាំងបាន ។

ចំពោះវត្តមានជប៉ុននៅលើទឹកដីខ្មែរនាពេលនោះបានផ្តល់ជា :

+ គុណសម្បត្តិចំពោះប្រជាជនកម្ពុជា : មានការអភិវឌ្ឍលើវិស័យគមនាគមន៍ផ្លូវអាកាសដែលកន្លងមកខ្មែរយើងមិនធ្លាប់មានឡើយ ។ សមិទ្ធផលនេះ អាចជាសញ្ញាណមួយឈានទៅរកការលើកកម្ពស់ជីវភាពប្រជារាស្ត្រខ្មែរលើវិស័យទេសចរណ៍នាពេលអនាគត ។
+ គុណវិបត្តិចំពោះប្រជាជនកម្ពុជា : នាពេលនោះបង្កឱ្យមានសង្គ្រាមរ៉ាំរ៉ៃ ដោយសារតែកងទ័ពសម្ព័ន្ធមិត្តជួយធ្វើអន្តរាគមន៍លើភាគីទាំងពីរ ។ ប្រជាជនខ្មែរខាតពេលវេលាកសាងនិងអភិវឌ្ឍជាតិ ព្រោះត្រូវបាត់បង់កម្លាំងពលកម្ម ដោយសារតែត្រូវជាប់កំណែន ។ ភាពក្រីក្រក្នុងសង្គមកាន់តែមានទំហំធំទៅៗ ដោយសារតែមានមន្ត្រីឆ្លៀតកេងយកប្រយោជន៍ពីកំណែនឱ្យសឹកជប៉ុន ។

គ. ការវាយតម្លៃ

- ឱ្យសិស្សសង្ខេបអត្ថបទឡើងវិញ

យាយម៉ុករៀបចំស្បៀងអាហារឱ្យលឹមចេញទៅកំណែន ដែលក្នុងនោះមានត្រីឆ្អើររបស់នាងហេង បានយកទុកឱ្យលឹមតាំងពីព្រលឹមមកម្ល៉េះ ។ អន្ទិតថន និងលឹម ក៏បាននាំគ្នាទៅផ្ទះតាមុយនៅឯចុងភូមិ ហើយក៏នាំគ្នាសំដៅទៅផ្ទះមេឃុំផាន់ ។ នៅផ្ទះតាមុយបាននិយាយពីរបៀបនៃការប្រមូលកំណែនរបស់រាជការអាណានិគមនិងវិធីកេងប្រវ័ញ្ចយកចំណេញពីគូលីរបស់មេឃុំផាន់ ។ លុះមកដល់មុខផ្ទះមេឃុំផាន់ហើយ គូលីកំណែនបានមកគ្រប់ចំនួន ១០០នាក់ ។ មេឃុំផាន់និងប៉ូលីសពីរនាក់ក៏បានបណ្តើរគូលីសំដៅទៅសាលាស្រុក ។ ក្រុមគូលីអង្គុយទៅតាមសង្កាត់ៗនៃឃុំនីមួយៗ ម្នាក់ៗ ស្លៀកខោស្មាប់ស្លៅលើជង្គង់អង្គុយឱ្យគេរាប់ក្បាលដូចជាអ្នកមានទោសធ្ងន់ ។ លោកបាល័ដ្ឋ បានត្រួតពិនិត្យចំនួនគូលីដោយស្តីបន្ទោសនិងគំរាមចំពោះមេឃុំដែលកេណ្ឌគូលីបានតិច ។ លុះក្រុមគូលីបានគ្រប់ចំនួនហើយលោកបាល័ដ្ឋនិងសហការីគាត់ ក៏បណ្តើរគូលីជាង ២០០០នាក់ទៅពោធិ៍ចិនតុង ។ សក្តិពីរជប៉ុនសរសើរលោកបាល័ដ្ឋដែលពូកែកេណ្ឌគូលីជួយទ័ពជប៉ុន ហើយសន្យាឱ្យប្រឡង់ដៃសរសេរជាអក្សរជប៉ុនដើម្បីចេញចូលមើលយន្តហោះឡើងចុះ ហើយលោកបាល័ដ្ឋសន្យានឹងផ្តល់ស្លឹកស្នាត បើជប៉ុនត្រូវការ ។ ឯក្រុមគូលីកំណែនត្រូវទាហានជប៉ុន ឃុំនៅក្នុងបន្ទាយរបងបន្លាលួសឱ្យជីកដីធ្វើផ្លូវយន្តហោះដីកថ្ម ។

ព្យញ្ជនៈផ្សំ

១. វត្ថុបំណង

- ប្រាប់ពីបញ្ហត្តិព្យញ្ជនៈផ្សំ
- បង្ហាញពីធាតុផ្សំនៃព្យញ្ជនៈនីមួយៗបានត្រឹមត្រូវ ។

២. សម្ភារបង្រៀន

- សៀវភៅសិស្សទំព័រទី ១៨២-១៨៣
- វេយ្យាករណ៍ថ្នាក់ទី ៥ និងទី ៨ បោះពុម្ពដោយក្រសួងអប់រំឆ្នាំ ១៩៨៣ ។

៣. ព័ត៌មានដំឡូយ

- សូមពិនិត្យប្រយ័ត្នច្រឡំត្រង់ចំណុចទី ៣ នៃ : ក. ការបង្ហាញ : ព្យញ្ជនៈផ្សំ អាចចូលផ្សំជាមួយព្យញ្ជនៈខ្យល់បី យ៉ាងគឺ ៖
  - ផ្សំនឹងព្យញ្ជនៈខ្យល់ "ស្ទះ" (ពួកអផង និងពួកអ៊ិផង)
  - ផ្សំនឹងព្យញ្ជនៈខ្យល់ "ច្រមុះ" (ពួកអផង និងពួកអ៊ិផង)
  - ផ្សំនឹងព្យញ្ជនៈខ្យល់ "បង្ហូរ" (ពួកអផង និងពួកអ៊ិផង)
- ចំពោះការចូលផ្សំនេះ ត្រូវទៅតាមរូបមន្តករណីទំនាញសូរផង ត្រូវទៅតាមករណីគ្មានទំនាញសូរផង តែករណីខ្លះទៀត ទំនាញសូរក៏មិនមែន ករណីគ្មានទំនាញសូរក៏មិនមែន ។
- កែសម្រួលក្នុងលំហាត់ "ក"សៀវភៅសិស្សទំព័រទី ១៨៣ ទៅជា : ចូរអ្នកជ្រើសរើសព្យញ្ជនៈផ្សំដូចខាងក្រោម ៖

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- លោកគ្រូ អ្នកគ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៨២-១៨៣រួចសរសេរចំណងជើង "ព្យញ្ជនៈផ្សំ"ដាក់លើក្តារខៀន ហើយសួរ :
  - អ្វីទៅដែលហៅថា "ព្យញ្ជនៈ" ?

    ចម្លើយ : ជាតួអក្សរដែលសម្រាប់ផ្សំជាមួយនឹងស្រៈ ។
  - តើ "ព្យញ្ជនៈ"អាចចូលផ្សំបានតែជាមួយស្រៈប៉ុណ្ណោះទេឬ ?

    ចម្លើយ : ព្យញ្ជនៈអាចចូលផ្សំជាមួយស្រៈនិងជាមួយព្យញ្ជនៈស្រៈ ។
  - បើ "ព្យញ្ជនៈ"ចូលផ្សំជាមួយស្រៈគេហៅថាព្យញ្ជនៈអ្វី ? ហើយចូលផ្សំជាមួយព្យញ្ជនៈវិញគេហៅថាព្យញ្ជនៈអ្វីដែរ ?

    ចម្លើយ : បើផ្សំជាមួយស្រៈគេហៅថា ព្យញ្ជនៈទោល ។ ដូចជា កើត = [ក + |អើ| + ត] "ក"ជាព្យញ្ជនៈទោល ។ តែបើផ្សំជាមួយព្យញ្ជនៈវិញគេហៅថាព្យញ្ជនៈផ្សំដូចជា គ្មាន = [គ + ម + |អា| + ន] "គ+ម"ជាព្យញ្ជនៈផ្សំ ។
- លោកគ្រូ អ្នកគ្រូឱ្យសិស្សអានឧទាហរណ៍ក្នុងសៀវភៅសិស្សទំព័រទី ១៨២-១៨៣ ។

- លោកគ្រូ អ្នកគ្រូសួរសំណួរដូចខាងក្រោម ៖
  - តើព្យញ្ជនៈផ្សំ អាចចូលផ្សំជាមួយព្យញ្ជនៈខ្យល់អ្វីខ្លះ ?

    ចម្លើយ : ព្យញ្ជនៈផ្សំអាចចូលផ្សំជាមួយ

    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ប្តូរ ផ្តល់ ផ្ទាញ់ ផ្ដា ផ្នក តួង ច្បា ស្តោ ឆ្កែ ក្បាល ក្តាន់ ខ្លី។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ៊" ៖ ផ្ទី ខ្ទស់ ខ្ទង់ ថ្ទាម ស្ពោះ។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" ៖ ផ្ទើ ផ្ទារ ថ្ទ ថ្ទូរ ស្នា ស្នាំ ឆ្ងល់ ក្មេង ក្មង ខ្ញុំ ក្ងាន ត្មោត ខ្មោច ខ្ចាយ។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ៊" + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" ៖ ភ្នំ ភ្ញី ភ្ញា ធ្ងួ។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ៖ ផ្សារ ខ្សែ។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" ៖ ផ្លូវ ថ្នា ឆ្វេង ខ្យល់។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ៊" + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" ៖ ព្រៃ ព្យួរ ធ្វើ ទ្រុង ត្រែ ធ្យូង ឈ្លឺ ជ្រៃ ឃ្លាល ឃ្លេ។
    + ព្យញ្ជនៈខ្យល់ច្រមុះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ម្ភាក់ ម្ខាង។
    + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" + ព្យញ្ជនៈខ្យល់ស្ទះ "អ៊" ៖ ម្ភៃ ម្ទេស។
    + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ៖ ម្ទិកម្ទ័ក់ ម្ទ៉ែ។
    + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" ៖ ម្ចាស់។
    + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ៖ ម្សៅ ម្ជូប ម្យ៉ាង។
    + ព្យញ្ជនៈខ្យល់ចម្រុះ "អ៊" + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" ៖ ម្ជូ ម្រេច។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ស្តី ស្បែ ស្តាយ ស្តា។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ៊" ៖ ស្ទែ។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" + ព្យញ្ជនៈខ្យល់ស្ទះ "អ៊" ៖ ស្តៅ ល្ពង។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" ៖ ស្មា ស្មា ស្ងោរ។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" ៖ ល្មម លូ។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" ៖ ស្វាយ ស្លាប ស្រា សាម។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ៖ ល្ងុង។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ក្មេងក្លាង ឆ្ងិនឆ្ងៅ ត្បូញត្អែរ ឆ្ងាល ប្អូន។
    + ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ផ្តោះ។
    + ព្យញ្ជនៈខ្យល់ច្រមុះ "អ៊" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ម្ហូម។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ៊" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ល្អិតល្អន ល្បី ល្ងាន។
    + ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ៖ ស្អកស្អា។
  - ដូចម្តេចដែលហៅថា ព្យញ្ជនៈផ្សំ ?

    ចម្លើយ : គឺជាសូររួមនៃព្យញ្ជនៈពីរ ឬបីដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ។

២. ការហ្វឹកហាត់

- ចែកជា ៣ក្រុម ឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ១៨៣ :
  - ក្រុមទី ១ : ជ្រើសរើសព្យញ្ជនៈផ្សំដែលមាននៅក្នុងលំហាត់ "ក" ៖

+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ខ្ពស់ ខ្ពង់ ថ្គាម ស្ពោះ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" តួង ស្ពោ ច្បារ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ជ្រៃ ឃ្មាល ឃ្លេ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ថ្ងូរ ឆ្នា ឆ្នាំ ឆ្ងល់ ក្មេង ក្ងុង
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ខ្សែ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ខ្យល់

- ក្រុមទី ២ : ជ្រើសរើសព្យញ្ជនៈផ្សំដែលមាននៅក្នុងលំហាត់ "ខ" ៖
+ ព្យញ្ជនៈខ្យល់ច្រមុះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ម្ជាក់ ម្ដែ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ក្រូ ឃ្លាត ធ្វើ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ក្ងុង ខ្ទោះ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ប្រើ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ប្រើ ប្រិត ប្រាក់ ខ្លាំង ក្លា
+ ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ស្រុក
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ធ្ងន់ ឈ្នួល
+ ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ល្អ

- ក្រុមទី ៣ : ប្រៀបធៀបនិយមន័យព្យញ្ជនៈផ្សំនិងព្យញ្ជនៈទោល ៖

ចម្លើយ : លំហាត់ទី ២

+ **ព្យញ្ជនៈទោល** : សូរសម្លេងដែលកើតឡើងមកពីដំណើរខ្យល់តាមបំពងសំឡេង បន្ទឹឡើងដោយមានទំនប់ប្រកបដោយភាពពុំច្បាស់លាស់ ។
+ **ព្យញ្ជនៈផ្សំ** : សូរបូរមនៃព្យញ្ជនៈពីរឬបីដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ ។

គ. ការវាយតម្លៃ

- ឱ្យសិស្សសិក្សាពាក្យ ១ព្យាង្គខាងក្រោមនេះ ដើម្បីបញ្ជាក់ថា ជាព្យញ្ជនៈផ្សំ ដែលផ្សំឡើងពីព្យញ្ជនៈខ្យល់ណាខ្លះ ?

ម្ខាង ព្យួរ អ្វី ថ្ពាល ខ្មត្ត ម្ដុំ ក្បាល ច្រើន ស្ទើរ ស្ពាប់ ស្ពៅ ខ្លី ត្រឹម ត្រួត គ្នា ថ្ពាក់ ស្រុក ។

ចម្លើយ :

+ ព្យញ្ជនៈខ្យល់ច្រមុះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ម្ខាង ម្ដុំ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ព្យួរ ស្ពៅ
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ថ្ពាល ថ្ពាក់
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" អ្វី ច្រើន ខ្លី ត្រឹម ត្រួត
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ខ្មត្ត
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ក្បាល
+ ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ស្ទះ "អ" ស្ទើរ
+ ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" ស្ពាប់
+ ព្យញ្ជនៈខ្យល់ស្ទះ "អ" + ព្យញ្ជនៈខ្យល់ច្រមុះ "អ" គ្នា
+ ព្យញ្ជនៈខ្យល់បង្ហូរ "អ" + ព្យញ្ជនៈខ្យល់បង្ហូរ "អ" ស្រុក



ជីវិតអន្តការរបស់ប្រជាជនខ្មែរ

១. វត្ថុបំណង

- ប្រាប់ពីគំនិតសំខាន់បង្កប់ កាលអាកាស កាលកំណត់តែង និងលក្ខណៈតឹៈបានត្រឹមត្រូវ
- វិភាគលក្ខណសម្បត្តិតួអង្គក្នុងរឿងបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៨៤-១៨៨
- មើលផែនដីខ្មែរ របស់លោក ជួន ម៉ែន ១៩៨០ ។

៣. លំដាប់បង្រៀន

ក. ត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ៨ទំព័រទី ១៨៤រួចសរសេរចំណងជើងអំណាន "ជីវិតអន្តការរបស់ប្រជាជនខ្មែរ"ដាក់លើក្តារខៀនរួចសួរ :
  - តើចំណងជើងនេះអាចនិយាយពីអ្វី ?

    ចម្លើយ : អាចនិយាយជីវិតប្រជារាស្ត្រខ្មែរនៅសម័យកម្ពុជាប្រជាធិបតេយ្យ ។
  - តាមរយៈចំណងជើងនេះ តើនៅសម័យនោះព្រឹត្តិការណ៍រឿងអាចកើតឡើងដូចម្តេចខ្លះ ?

    ចម្លើយ : មានការកាប់សម្លាប់ បង្អត់បាយ បង្ខំឱ្យធ្វើការជាទម្ងន់ ។
  - បើសង្កេតរូបភាពវិញ តើអ្នកបានឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

    ចម្លើយ : មានកុមារាកុមារី កំពុងឈរមើលកុមារីម្នាក់ដែលអានអក្សរនៅក្តារខៀន ។
  - តើអ្នកយល់យ៉ាងដូចម្តេចចំពោះរូបភាពនិងចំណងជើងនៃអំណាននេះ ?

    ចម្លើយ : ខ្ញុំយល់ថានេះគឺជាទិដ្ឋភាពមួយនៅសម័យកម្ពុជាប្រជាធិបតេយ្យដែលកុមារាកុមារីត្រូវសិក្សានៅក្រោមដើមឈើពុំមានឧបករណ៍សិក្សាត្រឹមត្រូវ ។
- គ្រូឱ្យសិស្សធ្វើការសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ១៨៤ឬពាក្យគន្លឹះដទៃទៀតក្នុងអំណាន ។

ខ. ការពង្រីកអំណាន

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៨៨ :

ចម្លើយ :

១. រឿងនេះដកស្រង់ចេញពីអត្ថបទដើមគឺ "មើលផែនដីខ្មែរ" ។

+ ជាបទកាកគតិ
+ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ
+ ឆ្នាំ ១៩៧៥ដល់ឆ្នាំ ១៩៧៩ ។

២. អត្ថបទនេះចែកចេញជា ៣គំនិតសំខាន់ :

- ផ្នែកទី ១ : "ផ្ទរភរអ្នកស្រែ .....មានភាពដូចគ្នា" ។
  + គំនិតសំខាន់ : ភាពខុសគ្នារវាងទ្រឹស្តីនិងការអនុវត្ត ។
- ផ្នែកទី ២ : "ដំឡូងមួយដុំ .....បោកប្រាស់សម្លាប់" ។
  + គំនិតសំខាន់ : ភាពផ្តាច់ការដោយការរំលោភសិទ្ធិក្នុងការរស់នៅរបស់ប្រជារាស្ត្រ ។
- វគ្គទី ៣ : "រៀនសូត្រមានន័យ .....ជាលទៅជាធ្ងន់" ។
  + គំនិតសំខាន់ : អត្ថន័យនៃពាក្យរៀនសូត្របួនយ៉ាង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៣. សិក្សាវគ្គដកស្រង់នេះ

- ពន្យល់ខ្លឹមសារនៃវគ្គដកស្រង់
  + វគ្គទី ១ : "ផ្ទរភរអ្នកស្រែ .....ខ្លោចអស់ព្រឹក្សាព្រៃ" ។ ការខកបំណងរបស់ប្រជារាស្ត្រចំពោះធម្មជាតិ ។
  + វគ្គទី ២ : "ពាក្យដូចទឹកឃ្មុំ .....លោកអស់តណ្ហា" ។ ភាពផ្ទុយគ្នារវាង ពាក្យសម្តី និងចិត្ត ។
  + វគ្គទី ៣ : "បំបាត់ព្រះធម៌ .....លែងស្គាល់សុចរិត" ។ លុបបំបាត់ពុទ្ធសាសនាលែងប្រកាន់ភាពសច្ចៈ ។
  + វគ្គទី ៤ : "ប្រើតែអំណាច .....ជាងមេឃនិងដី" ។ បែងចែកវណ្ណៈសង្គមមនុស្សពុំសមហេតុផល ។
- បដិវិធីក្នុងវគ្គដកស្រង់

វគ្គ	ខ្លឹមសារ	អង្គប្រឈម
"ផ្ទរភរអ្នកស្រែ ....ខ្លោចអស់ព្រឹក្សាព្រៃ" ។	មេឃមីរខ្មៅអែ ...មិនទៀងថាផេះ ...	ខ្មៅ (ភ្លៀង) ↔ ភ្លឺង (រាំងក្តៅហួតហែង)
"ពាក្យដូចទឹកឃ្មុំ ...លោកអស់តណ្ហា" ។	ពាក្យដូចទឹកឃ្មុំ តែចិត្តក្តៅងំ	ទឹកឃ្មុំ (ផ្អែមត្រជាក់) ↔ ក្តៅងំ (ចិត្តឈឺចាប់)
"បំបាត់ព្រះធម៌ ...លែងស្គាល់សុចរិត" ។	បំបាត់ព្រះធម៌ ថាធាតុមិនល្អ	សីលធម៌(កុសល) ↔ យកអំពើបាប
"ប្រើតែអំណាច ...ជាងមេឃនិងដី" ។	សម្តីតកម្លាច គ្មានមេត្តាចិត្ត	ការពិត ↔ ការមិនពិត

- វិធីជួន ផ្ចួន រណ្តំ
  + ផ្ទរភរអ្នកស្រែ សង្ឃឹមថាភ្លៀង
    មេឃមីរខ្មៅអែ មិនទៀងថាផេះ ខ្លោចអស់ព្រឹក្សាព្រៃ ។
    ហាក់រំលំប្រេះ ក្លាយជាភ្លឺងឆេះ
  + ពាក្យដូចទឹកឃ្មុំ ខ្ជូនពេញកិលេស
    តែចិត្តក្តៅងំ ស្មើរប្រេះបែកផ្ទៃ លោកអស់តណ្ហា ។
    ឆេះទាំងយប់ថ្ងៃ ហ៊ានឱ្យតម្លៃ

+ បំបាត់ព្រះធម៌ ថាធាតុមិនល្អ ប្រតិកិរិយា
ខ្ជូនពេញកិលេស អង់អាចមហិច្ឆតា កាន់ច្បាប់យក្សមារ
លែងស្គាល់សុចរិត ។
+ ប្រើតែអំណាច សម្លុតកម្លាច គ្មានមេត្តាចិត្ត
បែងចែកសង្គម តូចធំគ្មានក្រឹត្យ ឆ្ងាយគ្នាហួសពិត
ជាងមេឃនិងដី ។

- វិធីជួន : ដោយកវីចេះលើកយកសូរស្រៈ សូរព្យញ្ជនៈ មកដាក់ឱ្យចាប់ជួនគ្នា ។

ក. ជួនក្នុងល្បះ

+ ព្យ៤.១.១ ⟹ ព្យ៤.២.១ (ស្រែ ជួន អែ)
+ ព្យ៤.៣.១ ⟹ ព្យ៤.៥.១ (ប្រេះ ជួន ផេះ)
+ ព្យ៤.៣.១ ⟹ ព្យ២.៥.១ (ភ្លៀង ជួន ទៀង)

ខ. ជួនឆ្លងល្បះ

+ ព្យ ៤.៧.២ ⟹ ព្យ ៤.៣.៣ (តណ្ហា ជួន កិរិយា)

- វិធីផ្ទួន : ដោយកវីចេះលើកយកពាក្យ "អំណាច"ដែលជាពាក្យដដែលៗមកប្រើផ្ទួនគឺ ៖

+ ព្យ ៣និង ៤.៣ ⟹ ព្យ ៣និង ៤.៤ (អំណាច)

- វិធីរណ្តំ : ដោយកវីចេះលើកសូរស្រៈ សូរព្យញ្ជនៈ ទោល ព្យញ្ជនៈផ្សំ គឺ ៖

+ ព្យ ១.១.១ ⟼ ព្យ ២.១.១
ផ្គរ [.....] ⟼ ភរ [.....] (រណ្តំសូរស្រៈ [.....])
+ ព្យ ១.២.១ ⟼ ព្យ ២.២.១
មេឃ [me:k] ⟼ មីរ [mi:] (រណ្តំសូរព្យញ្ជនៈទោល [m])
+ ព្យ ៣.៧.១ ⟼ ព្យ ៤.៧.១
ព្រឹក [.....] ⟼ ព្រៃ [prei] (រណ្តំសូរបន្សំព្យញ្ជនៈ [pr])

៤. អត្ថបទនេះបានឆ្លុះបញ្ចាំងពីវិស័យដូចជា :

+ នយោបាយ : ការគ្រប់គ្រងប្រព្រឹត្តទៅដោយការគាបសង្កត់មកលើប្រជារាស្ត្រ។ ពួកគេអនុវត្តនយោបាយប្រល័យពូជសាសន៍ ពុំផ្តល់សិទ្ធិសេរីភាពជូនប្រជារាស្ត្រឡើយ ។
+ សេដ្ឋកិច្ច : ទោះបីកសិកម្ម ជាវិស័យមួយចាំបាច់ដែលពួកគេបានតម្រូវឱ្យប្រជារាស្ត្រត្រូវបង្កើនផលយ៉ាងណាក៏ដោយក៏វិស័យនេះពុំបានជួយទ្រទ្រង់ជីវភាពប្រជារាស្ត្របានល្អដែរ មានន័យថា ផលដំណាំពោរពាស ប៉ុន្តែពួកគេបង្អត់បាយ វាល់របបអាហារ ប្រជារាស្ត្រហូបមិនឆ្អែត បាក់កម្លាំង ហត់ហែវ ។
+ សង្គមកិច្ច : ការងារប្រព្រឹត្តទៅក្តៅគគុក ធ្វើការគ្មានថ្ងៃសម្រាក ពុំមានសុវត្ថិភាព រស់មួយថ្ងៃសម្រាប់មួយថ្ងៃ ដោយការភ័យខ្លាចនិងការសម្លាប់ ។ សុខភាពទ្រុឌទ្រោម គ្មានឱសថព្យាបាល រង់ចាំតែថ្ងៃស្លាប់ ។
+ វប្បធម៌ : វត្តអារាមក្លាយទៅជាគុក បាត់បង់អស់ប្រពៃណី ទំនៀមទម្លាប់ កម្មវិធីសិក្សាមិនជាក់លាក់ ។

៥. តាមរយៈការសិក្សាអត្ថបទនេះ ខ្ញុំឃើញពីស្ថានភាពសង្គមខ្មែរនាសម័យនោះដូចតទៅ :

+ បើតាមទ្រឹស្តីនៃពួកប្រល័យពូជសាសន៍ ឃើញថាល្អ គ្មានទ្រឹស្តីណាមួយល្អជាងឡើយតែការអនុវត្តផ្ទុយពីពីចរន្តនៃការវិវឌ្ឍសង្គម ។

+ អ្វីៗដើម្បីប្រជាជន តែធាតុពិតដើម្បីតែអង្គការពួកគេគ្មានគិតពីប្រជាជនឡើយ ។
+ ប្រជារាស្ត្របានទទួលផលមិនសមស្របនឹងកម្លាំងពលកម្មដែលខ្លួនបានធ្វើនោះឡើយ ។
+ បែងចែកវណ្ណៈប្រជាជនដែលជាជាតិសាសន៍ជាមួយគ្នា ដើម្បីងាយគ្រប់គ្រង ការពារផលប្រយោជន៍អង្គការ ។
+ បំភ័ន្តភ្នែកប្រជាជនឱ្យជឿជាក់លើនយោបាយប្រល័យពូជសាសន៍ខ្លួន ។
+ បិទបាំងនូវការទទួលខុសត្រូវចំពោះទោសឧក្រិដ្ឋខ្លួននិងបក្សពួកខ្លួន ។
+ ប្រើប្រាស់យុទ្ធសាស្ត្រដឹកនាំសង្គម "កម្ពុជាប្រជាធិបតេយ្យ" តាមតែមាត់ថា គ្មានគោលការណ៍ត្រឹមត្រូវច្បាស់ ។

៦. ចំពោះអំពើនៃបុគ្គលក្នុងអត្ថបទខាងលើនេះ មិនសក្តិសមជាបុគ្គលដែលមានមនុស្សធម៌ចំពោះប្រជារាស្ត្រខ្មែរទេ ។ ដោយហេតុថា អំពើដែលពួកគេបានប្រព្រឹត្ត :

+ ខុសនឹងផ្លូវសាសនា : ពួកគេកាប់សម្លាប់មិនប្រណី ដោយចោទថាជាខ្មាំង ។ អំពើបែបនេះខុសនឹងនិច្ចសីលនៃព្រះពុទ្ធសាសនា "បាណាតិបាតា"ហាមប្រមាថជីវិតសត្វ ។
+ ខុសនឹងផ្លូវច្បាប់ : កាប់សម្លាប់ចាប់ចងជាតិសាសន៍ខ្លួន មិនរើសមុខ ទាំងក្មេងទាំងចាស់ ។ ដោយគ្មានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងដោយមិនឈរលើមូលដ្ឋានច្បាស់ ។
+ ខុសនឹងផ្លូវសីលធម៌ : ពួកគេគ្មានមនោសញ្ចេតនាជាមនុស្សជាតិ ប្រព្រឹត្តអំពើព្រៃផ្សៃមិនខុសពីសត្វសាហាវឡើយ ។

គ. ការវាយតម្លៃ

- ឱ្យសិស្សសង្ខេបព្រឹត្តិការណ៍សំខាន់ៗដែលមានអត្ថន័យទាក់ទងនឹងការរំលោភសិទ្ធិទៅតាមផ្នែកដូចខាងក្រោម

ចម្លើយ :

ក. ផ្នែកទី ១ : "ផ្គរភរអ្នកស្រែ .....មានភាពដូចគ្នា" ។

- ព្រឹត្តិការណ៍សំខាន់
  + ការរំលោភសិទ្ធិលើផ្លូវស្មារតីគឺបំបាត់ព្រះពុទ្ធសាសនាមិនឱ្យគោរពបូជា ។
  + រើសអើងជាតិសាសន៍ដូចគ្នា ចែកវណ្ណៈសង្គម ។
  + អនុវត្តអំណាចផ្តាច់ការវាយកាប់សម្លាប់មិនរើសមុខ ។

ខ. ផ្នែកទី ២ : "ដំឡូងមួយដុំ .....បោកប្រាស់សម្លាប់" ។

- ព្រឹត្តិការណ៍សំខាន់
  + បង្អត់អាហារប្រជាជន ដោយគិតថាតម្លៃជីវិតស្មើនឹងដំឡូងមួយដុំ ស្មៅមួយគុម្ព បាយក្រៀមមួយដៃ ។
  + បំបិទសិទ្ធិជំនឿ សិទ្ធិបញ្ចេញមតិ ។
  + ពុំមានការព្យាបាលរក្សាសុខភាព ប្រជារាស្ត្រហួបមិនគ្រប់គ្រាន់ ។

គ. វគ្គទី ៣ : "រៀនសូត្រមានន័យ .....ដាលទៅជាធ្ងន់" ។

- ព្រឹត្តិការណ៍សំខាន់ : អត្ថន័យនៃការប្រើពាក្យរៀនសូត្រមាន ៤ យ៉ាង ៖
  + ពាក្យរៀនសូត្រទី ១គឺ "យកទៅសម្លាប់" ។
  + ពាក្យរៀនសូត្រទី ២គឺ "ស្តាប់បក្ស" ។
  + ពាក្យរៀនសូត្រទី ៣គឺ "ត្រូវប្តេជ្ញាចិត្តធ្វើឱ្យបាន" ។
  + ពាក្យរៀនសូត្រទី ៤គឺ "គាំទ្របក្ស" ។



ជីវិតទុគ៌តជន

១. ឥស្តុបំណង

- ប្រាប់ពីលក្ខណៈតួអង្គរបស់រឿងនិងតម្លៃអប់រំបានត្រឹមត្រូវ
- បង្ហាញពីសកម្មភាពរបស់តួអង្គក្នុងរឿងបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៨៩
- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ និពន្ធដោយ សួន សុរិន្ទ ។

៣. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀងទី ៨ ទំព័រទី ១៨៩ បន្ទាប់មកគ្រូសរសេរចំណងជើង " **រឿងជីវិតជនទុគ៌ត** " ដាក់លើក្តារខៀនរួចគ្រូសួរ :
  - តាមរយៈចំណងជើងនេះតើអ្នកយល់យ៉ាងដូចម្តេច ?

    ចម្លើយ : យល់ថាជននោះពិតជាកំសត់ ក្រីក្រលំបាកក្នុងជីវិតខ្លួន ។
  - បើសង្កេតរូបភាពវិញ តើអ្នកបានឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

    ចម្លើយ : បុរសម្នាក់កំពុងអង្គុយកាន់កាបូប នៅក្រោមគល់ឈើមួយ ហើយនៅខាងស្តាំរូបភាពមានបុរសស្ត្រីកំពុងបណ្តើរគ្នានៅក្នុងទីក្រុង ។
  - តើអ្នកយល់យ៉ាងដូចម្តេចចំពោះរូបភាពនិងចំណងជើងនៃអត្ថបទនេះ ?

    ចម្លើយ : ខ្ញុំយល់ថា បុរសនោះជាជនទុគតទំនងដូចជាយកបានកាបូបតាមវិធីណាមួយ ហើយបម្រុងនឹងបើកមើល ។
- សិក្សាពាក្យគន្លឹះ :
  - ខណៈ (ន) : ស្របក់រំពេច
  - យីហោ (ន) : គ្រឿងសម្គាល់ នាមដែលតាំងជាសម្គាល់របស់ឈ្មួញ
  - ក្តាប់ដៃណែន (កិ) : រួមក្រសោបចិទម្រាមដៃក្នុងអាការខឹងខ្លាំង
  - សួមយាចក (ន) : អ្នកសូមទានគេ ដើម្បីចិញ្ចឹមជីវិត ។
  - ស្រគត់ស្រគំ (គុ) : ដែលសម្រួមឥរិយាបថរម្យទម ។
  - ទុច្ចរិត (ន) : ដំណើរប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ។
- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៨៩ ដើម្បីត្រៀមឆ្លើយ ។
- អានអត្ថបទឱ្យសិស្សស្តាប់

[...] ខណៈនោះ សភាពបុរសហ៊ីហាម្នាក់ បានដើរចេញមកពីក្នុងហាង ដោយលក្ខណៈពេញទៅដោយការព្រហើនកោងកាច។ បុរសនេះឈប់ឈរទ្រឹង ក្នុងខណៈដែលឃើញសមឈរទើសផ្លូវចេញចូល ហើយក៏យកដៃច្រានដើមទ្រូងសមធ្វើឱ្យខ្ចាតចេញ។

" ចៀសចេញទៅ! " (បុរសនោះនិយាយ) "រូបរាងនៅរឹងប៉ឹងអញ្ចឹង កោតតែដើរសុំទានកើតដែរហ្ន៎! "។

រួចហើយទៅ សភាពបុរសនោះក៏ដើរតម្រង់ទៅរកឡានយន្តយីហោអាមេរិករបស់គេដែលចតចាំនៅចិញ្ចឹមថ្នល់ជិតហាងនោះ។ អ្នកបើកបររថយន្ត បានបើកទ្វារជូនបុរសនោះ។ សមខាំមាត់ហើយក្តាប់ដៃណែន។ សមគិតថា ខោអាវរហែករយ៉ឺរយ៉ៃ ធ្វើឱ្យអ្នកដទៃគិតថាខ្លួនជាស្នួមយាចកទាំងដែលខ្លួនមិនដែលសុំទានអ្នកណាបានមួយសេនសោះឡើយ..ឱហ្ន៎! មនុស្សយើងនេះគេមិនវាស់នៃអំពើល្អបរិសុទ្ធទេ គេបែរជាវាស់កម្រិតល្អដោយមាសប្រាក់កែវកង និងសំពត់អាវសាវស្បែទៅវិញ បើទុកជាអ្នកនោះប្រព្រឹត្តអាក្រក់យ៉ាងណាក៏ដោយ...

" អើហ្ន៎! " (សមគិតទាំងមួម៉ៅ) អញធ្វើជាមនុស្សល្អមកយូរយាយណាស់មកហើយ តែសេចក្តីល្អនោះ មិនដែលឱ្យផលអី ដល់អញសោះ អញត្រូវតែជួយខ្លួនអញឱ្យរួចពីសេចក្តីស្លាប់ ក្នុងគ្រានេះម្តងសិន "។

សេចក្តីស្រែកឃ្លានបានបង្ខំចិត្តគំនិតរបស់សម ឱ្យប្រែប្រួលផ្លាស់ប្តូរពីបាតដៃទៅជាខ្នងដៃភ្លាម។ ភ្នែកទាំងពីររបស់សមប្រែទៅជាក្រហមហើយស្រវាំងព្រិលៗ សមបានដើរចេញពីកន្លែងនោះ ហើយបានទៅដល់មុខរោងភាពយន្តតារា ដោយទឹកមុខស្រពោនក្រៀមក្រំ។ ពេលនោះគាប់ជួនជាភាពយន្តដល់ពេលចប់រឿង។ មនុស្សម្នាទាំងឡាយ ប្រជ្រៀតគ្នាចេញពីរោងភាពយន្តដល់ពេលចប់រឿង។ សមក្រឡេកមើលទៅឃើញបុរសស្ត្រី ក្នុងវ័យកណ្តាលពីរនាក់ កំពុងប្រជ្រៀតគ្នាចេញមកពីក្នុងរោងភាពយន្តដែរ។ បុរសនិងស្ត្រីទាំងពីរនាក់នេះ តែងខ្លួនរៀបរយស្រគត់ស្រគំ មានបែបភាពបង្ហាញឱ្យដឹងថា ជាអ្នកមានទ្រព្យសម្បត្តិសុកស្តួត។

ស្ត្រីមានរូបរាងធាត់បន្តិច ហើយនាងកាន់កាបូបស្បែកក្រពើនៅដៃ។ ខណៈនោះសមកាត់ចិត្តប្រព្រឹត្តនូវអំពើទុច្ចរិតភ្លាម ដោយនឹកជឿជាក់ថា នៅក្នុងកាបូបស្បែកក្រពើនោះ បើហោចណាស់ក៏គង់មានប្រាក់ល្មមនឹងជួយជីវិតខ្លួន ឱ្យបានរួចផុតពីការដាច់ពោះស្លាប់បានមួយពេលដែរ។

អំណាចនៃសេចក្តីអាក្រក់ថោកទាប បានកើតឡើងដល់ចិត្តគំនិតរបស់សមហើយ... សមដើរសរសៀរចូលទៅជិត ហើយក៏កញ្ឆក់កាបូបស្បែកក្រពើយកចេញពីដៃនៃស្ត្រីនោះភ្លាម។

" ជួយផង! ជួយផង! " ស្ត្រីនោះស្រែកឡើង " ចោរឆក់!

សមរត់យ៉ាងលឿនចូលទៅក្នុងសារមន្ទីរជាតិ... សមកំពុងតែប្រថុយខ្លួននឹងគុកច្រវាក់ ព្រោះការស្រែកឃ្លាន។ អ្នករត់ទាំងឡាយ គេរត់ប្រណាំងប្រជែងគ្នាយកឈ្នះ តែសមរត់ព្រោះឆក់ប្រាក់ ដើម្បីនឹងយកទៅទិញអាហារបរិភោគ ដែលប្រែសេចក្តីថា រត់ប្រណាំងនឹងការដាច់ពោះស្លាប់។ គ្រានោះជាគ្រាដំបូងបំផុតក្នុងជីវិត ដែលបើកឆាកនៃការប្រព្រឹត្តទុច្ចរិតខុសគន្លងច្បាប់។

ប្រជាជននិងភ្នាក់ងារប៉ូលីសបានរត់ដេញតាមក្រោយសម។ សមបានរត់កាត់ទៅខាងក្រោយសារមន្ទីរជាតិឆ្លងទៅដល់សាលារចនា។ សភាពងងឹតបានជួយឱ្យសម គេចខ្លួនរួចផុតពីការចាប់ចងយ៉ាងគួរឱ្យព្រឺខ្លួន។ សមបានចូលទៅសំងំពួននៅជិត

រោងថែវ ខាងក្រោយសាលារចនា ហើយបើកកាបូបហូតយកលុយទាំងអស់មកដាក់នៅក្នុងហោប៉ាវអាវ។ ក្រោយពេលបោះកាបូបចោលហើយ សមក៏ដើរចេញពីកន្លែងនោះភ្លាម។ សមបានរួចខ្លួននៅពេលដែលបានហែករបងអំពិលទឹកខាងជើងដើរចេញទៅ។

សមនឹកអៀនខ្មាសខ្លួនឯងយ៉ាងខ្លាំង ព្រោះនឹងដល់កំហុសដ៏ធ្ងន់របស់ខ្លួន សមធ្លាប់បានប្តេជ្ញាចិត្តថា បើទុកជាក្រលំបាកយ៉ាងណា ក៏សុខចិត្តតែពីប្រកាន់នូវសីលធម៌មិនប្រព្រឹត្តអាក្រក់ តែពេលនេះសមត្រូវធ្វើជាចោរឆក់របស់គេ ក៏ព្រោះសេចក្តីស្រេកឃ្លានយ៉ាងខ្លាំង ដែលធ្វើឱ្យសមអត់ទ្រាំមិនបាន ... អ្នកដែលមិនធ្លាប់អត់បាយ រមែងមិនដឹងថា សេចក្តីស្រេកឃ្លាននោះវាមានអានុភាពយ៉ាងណាឡើយ ... ។ [...]

(ដកស្រង់ចេញពីរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ វគ្គទី ១៤ "សីលធម៌និងដុំបាយ"

ទំព័រទី ១៤៥-១៤៨ លោកសួនសុរិន្ទ ឆ្នាំ ១៩៦១)

- ឱ្យសិស្សឆ្លើយនឹងសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៨៩ :

ចម្លើយ :

១. រឿងនេះចាត់ទុកជាប្រភេទអក្សសិល្ប៍ទំនើប ជាអក្សរសិល្ប៍ខេមរនិយម។

រឿងនេះកើតមានក្នុងប្រទេសខ្មែរនាឆ្នាំ ១៩៦០ នៅភ្នំពេញ រោងភាពយន្តតារា សារមន្ទីរជាតិ សាលារចនា ... ។

២. បានជាសមសម្រេចចិត្តឆក់កាបូបពីស្ត្រីរូបនោះមកពី :

- ផ្លូវចិត្ត មានការឈឺចាប់ចំពោះប្រមាថពីសំណាក់មនុស្សក្នុងសង្គមដូចគ្នា
  + "... ខោអាវរហែកឃ្មីរយ៉ៃ ធ្វើឱ្យអ្នកដទៃគិតថា ខ្លួនជាស្នួមយាចក ទាំងដែលខ្លួនមិនដែលសុំទានអ្នកណាបានមួយសេនសោះ ... "។
  + " អញធ្វើជាមនុស្សល្អមកយូរយារណាស់មកហើយ តែសេចក្តីល្អនោះ មិនដែលឱ្យផលអីដល់អញសោះ អញត្រូវតែជួយខ្លួនអញឱ្យរួចផុតពីសេចក្តីស្លាប់ ក្នុងគ្រានេះម្តងសិន "។
- ផ្លូវកាយ ដោយសារតែសេចក្តីស្រេកឃ្លាន ពុំអាចគ្រប់គ្រងខ្លួនឯងបាន :
  + សេចក្តីស្រេកឃ្លានបានបង្ខិំចិត្តគំនិតរបស់សម ឱ្យប្រែប្រួលផ្លាស់ប្តូរពីបាតដៃទៅជាខ្នងដៃភ្លាម ភ្នែកទាំងពីររបស់សមប្រែទៅជាក្រហម ហើយស្រវាំងព្រិលៗ។
  + សមកាត់ចិត្តប្រព្រឹត្តនូវអំពើទុច្ចរិតភ្លាម ដោយនឹកជឿ ជាក់ថានៅក្នុងកាបូបស្បែកក្រពើនោះ ហោចណាស់ក៏គង់មានប្រាក់ល្មមនឹងជួយជីវិតខ្លួន ឱ្យបានរួចផុតពីការដាច់ពោះស្លាប់បានមួយពេលដែរ។

៣. អំពើរបស់សមនៅពេលនោះ ពុំមែនជាអំពើដែលកើតចេញពីឆន្ទៈផ្ទាល់ខ្លួនទេ។

- ដោយហេតុថា :
  + មានការរើសអើងពីសង្គមមនុស្ស មិនបានឱ្យតម្លៃមនុស្សដូចគ្នា "ឱហ្ន៎! មនុស្សយើងនេះ គេមិនវាស់នៃអំពើល្អបរិសុទ្ធទេ គេវាស់នូវកិរិតល្អ ដោយមាសប្រាក់កែវកង និងសំពត់អាវសាវស្បៃ បើទុកជាអ្នកនោះប្រព្រឹត្តអាក្រក់យ៉ាងណាក៏ដោយ ..."។

+ នៅមានសម្បជញ្ញៈ និងមនសិការនៅឡើយ "សមនឹកអៀនខ្មាសខ្លួនឯងយ៉ាងខ្លាំង ព្រោះនឹកដល់កំហុសដ៏ធ្ងន់របស់ខ្លួន សមធ្លាប់បានប្តេជ្ញាចិត្តថា បើទុកជាក្រលំបាកយ៉ាងណាក៏សុខចិត្តតែពីប្រកាន់នូវសីលធម៌មិនប្រព្រឹត្តអាក្រក់ ..." ។

+ ពុំមែនអាជីពរបស់សមទេ ដើម្បីក្រពះមួយគ្រាតែប៉ុណ្ណោះ "...អ្នកដែលមិនធ្លាប់អត់បាយរមែងមិនដឹងថាសេចក្តីស្រេកឃ្លានេនោះមានអានុភាពយ៉ាងណាឡើយ" ។

៤. ដោយផ្អែកទៅលើតថភាពនៃរឿង សង្គមសម័យកាលនោះមានលក្ខណៈដូចតទៅ :

+ មានការរើសអើង មនុស្សមើលងាយមនុស្សផងគ្នា ។

+ ជីវភាពរវាងអ្នកមាននិងអ្នកក្រ មានគម្លាតដាច់ឆ្ងាយពីគ្នា ។

+ នៅមានភាពគ្មានការងារធ្វើ ។

៥. បានជាអ្នកនិពន្ធពោល "អ្នករត់ទាំងឡាយគេរត់ប្រណាំងប្រជែងគ្នាយករង្វាន់ តែសមរត់ព្រោះឆក់ប្រាក់ ដើម្បីនឹងយកទៅទិញអាហារបរិភោគ ដែលប្រៃសេចក្តីថា រត់ប្រណាំងនឹងការដាច់ពោះស្លាប់" : មកពីការរត់ប្រណាំងគ្នាយករង្វាន់ដោយសារតែម្នាក់ៗ មានក្តីសង្ឃឹមទៅលើលទ្ធផលដែលខ្លួននឹងទទួលយកបាន តាមរយៈសមត្ថភាពពេលខាងមុខ ។ រីឯសមពុំមានក្តីសង្ឃឹមដូចករណីកីឡាករទាំងនោះទេ គឺជាការប្រឹងប្រែងដើម្បីក្រពះនិងប្រឈមមុខច្បាប់ ។ ក្នុងពេលនោះ បើសមរត់មិនឈ្នះទេ សមត្រូវមានទោសនិងត្រូវអត់អាហារទទួលទាន ។

៦. គំនិតអ្នកនិពន្ធតាមរយៈខ្លឹមសារនៃរឿងនេះ (អត្ថបទដកស្រង់) :

+ ឱ្យចេះគោរពសិទ្ធិគ្នាទៅវិញទៅមក ។

+ តម្លៃមនុស្សមិនស្ថិតនៅលើសំបកខាងក្រៅនោះទេ ។

+ ជនទុគ៌តនិងអ្នកមានសុកសុម្ភសុទ្ធតែមានជីវិតដូចគ្នា ។

+ ការបាត់បង់អធ្យាស្រ័យជាកត្តានាំមកនូវទំនាស់ ។

ខ. ការវាយតម្លៃ

- ឱ្យសិស្សសង្ខេបរឿងឡើងវិញ :

ចម្លើយ : មានបុរសម្នាក់ដើរចេញពីហាងមួយ ពេលឃើញសមឈរទើសផ្លូវ ក៏យកដៃច្រានទ្រូងសម ហើយថាសមជាអ្នកដើរសុំទានគេ ។ សមខឹងខ្លាំងណាស់ ហើយគិតថា ខ្លួនមិនដែលសុំទានអ្នកណាបានមួយសេនសោះឡើយ បែរជាគេប្រមាថដូចនេះទៅវិញ ។ ដោយសារតែការឈឺចាប់នឹងការប្រមាថ ព្រមទាំងដោយសេចក្តីស្រេកឃ្លានផង សមក៏កាត់ចិត្តប្រព្រឹត្តនូវអំពើទុច្ចរិត ហើយក៏កញ្ឆក់កាបូបស្បែកក្រពើពីដៃស្ត្រីនោះ ។ ពេលឆក់បានហើយ សមក៏រត់យ៉ាងលឿនចូលទៅក្នុងសារមន្ទីរជាតិ ។ ប្រជាជន និងភ្នាក់ងារប៉ូលីសបានរត់ដេញតាមក្រោយសម តែសមរត់គេចខ្លួនរួចផុតពីការតាមប្រមាញ់នេះ ។ សម អៀនខ្មាសនិងអំពើរបស់ខ្លួន តែធ្វើម្តេចបើសេចក្តីស្រេកឃ្លាន ឬក៏អាចសេចក្តីស្លាប់មកបៀតបៀនដល់ខ្លួនហើយ ។



បកស្រាយន័យសុភាសិត និងពាក្យស្លោក

១. វត្ថុបំណង

- បកស្រាយន័យសុភាសិតនិងពាក្យស្លោកបានត្រឹមត្រូវ
- បកស្រាយន័យចំនិងន័យធៀបរបស់សុភាសិតបានត្រឹមត្រូវ
- ស្វែងរកហេតុផលមកគាំទ្រអត្ថន័យសុភាសិតនិងពាក្យស្លោកបានច្បាស់លាស់និងត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៩០

៣. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀន ៨ ទំព័រទី ១៩០ បន្ទាប់មកគ្រូសរសេរចំណងជើង "បកស្រាយន័យសុភាសិតនិងពាក្យស្លោក" ដាក់លើក្តារខៀនរួចគ្រូសួរ :
  - ដូចម្តេចដែលហៅថា សុភាសិត ? ចងក្រងឡើងដើម្បីអ្វី ?

    ចម្លើយ : ជាពាក្យ ឬកន្សោមពាក្យល្អពីរោះមានន័យសេចក្តីគ្រប់គ្រាន់ ។ ចងក្រងឡើងដើម្បីទុកទូន្មាន អប់រំដល់កូនចៅជំនាន់ក្រោយ ។
  - តើសុភាសិតមានអត្ថន័យទាក់ទងនឹងអ្វីខ្លះ ?

    ចម្លើយ : អត្ថន័យទាក់ទងនឹង សីលធម៌ ឱ្យប្រុងប្រយ័ត្នចំពោះសត្រូវ បទពិសោធន៍ជីវិត ... ។
  - តើអ្វីទៅដែលហៅថាពាក្យស្លោក ?

    ចម្លើយ : ជាទស្សនៈ ឬជាគោលគំនិតដែលបានលើកយកមកសម្រាប់អនុវត្តក្នុងសង្គមឱ្យរីកចម្រើន ។
  - តើពាក្យស្លោកនិងសុភាសិតមួយណាស្ថិតស្ថេរ ? ព្រោះអ្វី ?

    ចម្លើយ : ពាក្យស្លោកមិនស្ថិតស្ថេរទេ ព្រោះវាទៅតាមសង្គម ដែលមាននិន្នាការផ្សេងៗគ្នា ។ រីឯសុភាសិតវិញច្រើននៅស្ថិតស្ថេរ ព្រោះខ្លឹមសារ ឬអត្ថន័យរបស់វាមានលក្ខណៈត្រឹមត្រូវគ្រប់សម័យកាល ។
- គ្រូឱ្យសិស្សអានលំណែនាំនៃការបកស្រាយពាក្យស្លោកដែលមិនមានន័យធៀបក្នុងសៀវភៅសិស្សទំព័រទី ១៩០រួចសួរ
  - នៅពេលបកស្រាយពាក្យស្លោកនិងសុភាសិត តើអ្នកត្រូវស្គាល់ពីអ្វីខ្លះ ?

    ចម្លើយ : ត្រូវ ៖
    + ស្គាល់ប្រភេទសុភាសិតនិងពាក្យស្លោកនោះជាមុនសិន
    + ស្គាល់ភាពខុសគ្នារវាងសុភាសិតនិងពាក្យស្លោក
    + ស្គាល់ពីន័យត្រង់ (អត្ថានុរូប)និងន័យធៀប (អត្ថប្បដិរូប)របស់សុភាសិតនិងពាក្យស្លោក
    + ពន្យល់ដោយលើកឧទារណ៍និងអំណះអំណាងខ្លះយកមកការពារក្នុងការពន្យល់នេះ
    + ចេះពន្លេចឱ្យឃើញតម្លៃអប់រំដោយផ្សារភ្ជាប់ជាមួយតម្លៃក្នុងសង្គម ។
  - ចូរអ្នកឧទាហរណ៍សុភាសិតនិងពាក្យស្លោកដែលគ្មានន័យធៀប ។

    ចម្លើយ : សុភាសិត "ងាប់ខ្លួន សមសួនជាងងាប់កេរ្តិ៍ឈ្មោះ" : មានន័យថា បើគិតដល់ខ្លួននិងជីវិតខ្លួនពិតជាមានតម្លៃណាស់ ម្នាក់ៗសុទ្ធចង់រស់នៅតទៅទៀត ទោះបីជាប្រើមធ្យោបាយបែបណាក៏ដោយក៏សុខចិត្តធ្វើ

ដែរ ។ ប៉ុន្តែ បើសិនជាយើងគ្រាន់តែរស់ ដោយអាប់កេរ្តិ៍ឈ្មោះ ក៏រស់នៅគ្មានប្រយោជន៍អ្វីសោះឡើយ ជីវិតយើងក៏គ្មានន័យដែរ ។ កេរ្តិ៍ឈ្មោះល្អកើតឡើងដោយសារតែការប្រព្រឹត្តិអំពើល្អ ជាសកម្មភាពល្អ ដែលជាប្រយោជន៍ខ្លួនឯង ឬប្រយោជន៍សង្គមជាតិ ហើយបុគ្គលនោះ ក៏ត្រូវបានចាត់ទុកថាមានកេរ្តិ៍ឈ្មោះល្អ ចំណែកកេរ្តិ៍ឈ្មោះអាក្រក់វិញគឺសំដៅ "ងាប់កេរ្តិ៍ឈ្មោះ"នោះតែម្តង ។ យ៉ាងណាមិញ បុគ្គលដែលងាប់កេរ្តិ៍ឈ្មោះ សូម្បីតែខ្លួនមានអាយុជីវិតរស់នៅយូរអង្វែងយ៉ាងណាក៏ដោយក៏គ្មានតម្លៃអ្វីបន្តិចសោះឡើយ ។

ពាក្យស្លោក "ដើម្បីផលប្រយោជន៍ជាតិ ត្រូវហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួន"ជាគវាសនាបុគ្គលត្រូវផ្សារភ្ជាប់នឹងជោគវាសនាជាតិ បានសេចក្តីថា បើជាតិរស់យើងក៏រស់ បើជាតិស្លាប់យើងក៏ស្លាប់ ។ ដូច្នេះ ក្នុងនាមជាពលរដ្ឋក្នុងសង្គមត្រូវតែហ៊ានលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីជាតិ ទឹកដី និងឯករាជ្យជាតិ ។

ខ. ការនិយាយ

- គ្រូចែកសិស្សជា ២ក្រុម ឱ្យក្រុមនីមួយៗហ្វឹកហាត់បកស្រាយសុភាសិតនិងពាក្យស្លោក ដែលខ្លួនបានជ្រើសរើសរួចនៅទំព័រទី ១៩១ហើយសមាជិកក្រុមនីមួយៗត្រូវជួយកែលម្អគ្នាទៅវិញទៅមក ។
- គ្រូឱ្យសិស្សតំណាងក្រុមនីមួយៗ ឡើងបកស្រាយសុភាសិតដែលខ្លួនបានជ្រើសរើសរួចហើយ ។ គ្រូនិងសិស្សដទៃចូលរួមកែលម្អ ។

ចម្លើយ : ក្រុមទី ១ បកស្រាយសុភាសិត "ត្រីកំភ្លាញស្លាប់ព្រោះមាត់ ..." :

+ ន័យចំ : ត្រីកំភ្លាញជាត្រីមួយប្រភេទមានស្រកា រាងសំប៉ែត មានពុកមាត់វែង ។ ត្រីប្រភេទនេះ បើនៅទឹកបឹងឬត្រពាំងណារមែងមានពពុះមាត់ ហាក់ដូចជាសញ្ញាប្រាប់អ្នកនេសាទថា បឹងឬត្រពាំងនោះមានត្រីច្រើន ។ មានន័យថា ត្រីប្រភេទនេះងាយត្រូវគេនេសាទ ដោយសារតែពពុះមាត់ដែលតែងតែផុសជាញឹកញាប់ក្នុងបឹងត្រពាំងនោះ ។
+ ន័យធៀប : យ៉ាងណាមិញចំពោះមនុស្សដែលចូលចិត្តនិយាយស្តីប៉ប៉ាច់ប៉ប៉ោចច្រើនឥតប្រយោជន៍មិនត្រឹមតែធ្វើឱ្យខូចប្រយោជន៍ឬប៉ះពាល់ដល់ប្រយោជន៍អ្នកដទៃទៀតប៉ុណ្ណោះទេ តែថែមធ្វើឱ្យខូចប្រយោជន៍ខ្លួនផ្ទាល់ទៀតផង ។ អ្នកនិយាយនោះក៏វែងទទួលទោស ឬខាតលាភដោយសារតែសម្តីឥតប្រយោជន៍របស់ខ្លួននោះទៅវិញ ។
+ សរុប : ដូចនេះ ត្រីកំភ្លាញងាប់ព្រោះមាត់ ដែលជាសញ្ញាប្រាប់ដល់អ្នកនេសាទ ។ រីឯមនុស្សខ្លះទៀត ខូចប្រយោជន៍ ឬក៏ស្លាប់ក៏ព្រោះសម្តីដែលចូលចិត្តនិយាយរឿងឥតប្រយោជន៍ចាំបង្កទុក្ខដល់ខ្លួនឯងទៅវិញ ។

ចម្លើយ : ក្រុមទី ២ បកស្រាយពាក្យស្លោក "ការអប់រំ គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ" : មានន័យថា ការអប់រំ គឺជាវិធី ឬមួយជាមធ្យោបាយដ៏សំខាន់និងចាំបាច់ដែលជំរុញឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើន ។ ដោយហេតុថា ការអប់រំជាកត្តាចាំបាច់ ក្នុងការបណ្តុះបណ្តាលយុវជនឱ្យក្លាយទៅជាធនធានមនុស្សពិតប្រាកដ ប្រកបទៅដោយសីលធម៌និងមានចំណេះវិជ្ជាឬមុខជំនាញណាមួយពិតប្រាកដ ។ នៅពេលដែលគេបានទទួលការអប់រំស្របទៅតាមទេពកោសល្យរបស់ខ្លួនហើយ គេនឹងមានសមត្ថភាពចូលរួមកសាងនិងអភិវឌ្ឍជាតិ ជាពិសេសលើវិស័យសេដ្ឋកិច្ច ។ ជាមួយនោះ ប្រទេសជាតិនឹងមានភាពរុងរឿងជឿនលឿនជាមិនខាន ។

ជារួម ការអប់រំពិតជាកត្តាចម្បងនិងមានប្រសិទ្ធភាពបំផុត ក្នុងការរួមចំណែកអភិវឌ្ឍសង្គមជាតិ ។

គ. ការវាយតម្លៃ

- គ្រូចែកសិស្សជា ២ក្រុម ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់ រួចឱ្យសិស្សបកស្រាយសុភាសិត ៖

- ក្រុមទី ១ បកស្រាយសុភាសិត "ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក"
  + ន័យចំ : ធម្មតាកង់រទេះ គេតែងតែយកឈើវៀចទៅធ្វើជាដរាប ហើយទោះជាឈើនោះត្រង់ ក៏ឬវៀចបន្តិចបន្តួចពុំទាន់ដល់កម្រិតដែលនឹងអាចទៅជាកង់បាន ក៏គេត្រូវចាំងផ្សំយ៉ាងណាឱ្យទាល់តែឱ្យមានរង្វង់មូលដែលអាចធ្វើជាកង់បាន។ ប៉ុន្តែគេច្រើននិយមយកឈើដែល វៀច ង ស្រាប់ទៅធ្វើកង់ព្រោះឈើជំពូកនេះមានសាច់និងសរសៃរពត់មាំទៅតាមលំនាំធម្មជាតិស្រេចតែម្តង។ ចំណែកទូករទេះវិញ ជាឈើត្រង់ ហើយគេតែយកឈើត្រង់ស្រាប់ទៅធ្វើដែរ ទោះបីវៀចបន្តិចបន្តួច គេក៏តែងតែចាំងបំពត់តម្រង់ធ្វើឱ្យបានត្រង់ជាមុនសិន ទើបគេយកទៅធ្វើ។ ដូច្នេះ ឈើវៀច ក៏ដូចជាឈើត្រង់ដែរ សុទ្ធតែមានប្រយោជន៍ដូចគ្នា គ្រាន់តែមានមុខងារផ្សេងគ្នាតែប៉ុណ្ណោះ។
  + ន័យធៀប : ចំពោះឈើវៀច គឺសម្គាល់លក្ខណៈមនុស្សខូច កាច លង់ខ្លៅ។ រីឯឈើត្រង់ គឺសម្គាល់លក្ខណៈមនុស្សស្លូតបូត ទៀងត្រង់ មានចំណេះវិជ្ជា។ បុគ្គលទាំងពីរប្រភេទនេះ មាននិស្ស័យនិងទស្សនៈមិនដូចគ្នាទេ ហើយក៏មិនអាចចុះសម្រុងគ្នាបានដែរ។ ប៉ុន្តែអ្វីសំខាន់ ចំពោះការធ្វើការងារផ្សេងពួកគេត្រូវមានកិច្ចការផ្សេងពីគ្នា។ ប្រភេទបុគ្គលជាឈើវៀច អាចសមត្ថភាពប្រើជាកម្លាំងក្នុងកិច្ចការពារសត្រូវដូចជារបងដែរ។ ជួលកាលមនុស្សប្រភេទនេះ មានបំណិនប្រសប់ក្នុងការបំពេញការងារ និងមានភាពស្មោះត្រង់ចំពោះកិច្ចការនោះផង។ ចំពោះប្រភេទមនុស្សឈើត្រង់ ជាជនស្លូតត្រង់ មានចំណេះថ្លៃថ្នូរ សីលធម៌ស្អាតស្អំ គប្បីឱ្យគេបំពេញកិច្ចការណាសំខាន់ ឬចាំបាច់។ រីឯអ្នកដែលមានចំណេះវិញ គប្បីឱ្យគេធ្វើជាអ្នកដឹកនាំ ជាអ្នកទទួលខុសត្រូវកិច្ចការធំៗ ព្រោះគេជាមនុស្សចេះទទួលខុសត្រូវពិតប្រាកដ។ បើគេចេះប្រើមនុស្សបែបនេះ នាំឱ្យសង្គមជាតិមានរីកចម្រើនឆាប់រហ័ស។
  + សរុប : ដូចនេះ ទោះបីឈើវៀចក្តី ឬត្រង់ក្តី សុទ្ធតែមានប្រយោជន៍ដូចគ្នា តែការប្រើប្រាស់គឺអាស្រ័យគេចេះយកទៅច្នៃប្រឌិតស្របតាមទម្រង់ឬអត្ថន័យនៃសម្ភារៈទាំងនោះតែប៉ុណ្ណោះ។ ចំណែកមនុស្សខ្ជិល ខិលខូច និងមនុស្សឧស្សាហ៍មានចំណេះ ក៏សុទ្ធតែមានប្រយោជន៍ចំពោះសង្គមមនុស្សដែរឱ្យតែគេចេះប្រើមនុស្សទាំងនោះឱ្យស្របតាមជំនាញ និងឥរិយាបថនៃបុគ្គលនីមួយៗ។
- ក្រុមទី ២ បកស្រាយសុភាសិត "ត្រូវដំដែកក្នុងពេលដែកកំពុងក្តៅ"
  + ន័យចំ : មានន័យថា បើចង់ផលិតគ្រឿងប្រដាប់អ្វីមួយ ដែលធ្វើអំពីដែក ចាំបាច់គេត្រូវយកដែកនោះទៅដុតឱ្យក្តៅជាមុនសិន ទើបងាយស្រួលក្នុងការដំទៅតាមទម្រង់ផ្សេងៗ ដែលយើងចង់បាន។ តែបើសិនជាដែកនោះលែងក្តៅ យើងពិតជាបាត់បង់ឱកាសក្នុងការកែច្នៃដែកនោះឱ្យត្រូវទៅតាមបំណងដែលចង់បាននោះជាមិនខាន។
  + ន័យធៀប : មានន័យថា ការអប់រំមនុស្សក៏មិនខុសពីដំដែកដែរ គឺត្រូវការអប់រំទូន្មានមនុស្សនៅក្នុងវ័យក្មេងនៅឡើយ ទើបបានផលល្អប្រសើរ ព្រោះវ័យនេះងាយទទួលយកការអប់រំ ងាយស្តាប់ដំបូន្មាន។ ម្យ៉ាងទៀតវ័យនេះនាប់ទទួលបែបបទនិងទម្លាប់ល្អ ដោយនាប់ភ្លេចនូវអ្វីដែលអាក្រក់។
  + សរុប : ដូចនេះការដំដែកក្តៅនិងការអប់រំមនុស្ស ពិតជាស្ថិតក្នុងស្ថានភាពមួយដូចគ្នា គឺត្រូវចេះយកពេលវេលាដែលដែកកំពុងនៅក្តៅ និងមានវ័យក្មេង បើពុំនោះទេ ពួកគេនឹងមិនសម្រេចតាមបំណងឡើយ។

- ក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ ដោយសរសេរបកស្រាយ រួចនិយាយបកស្រាយសុភាសិតក្នុងក្រុមឱ្យបានស្ទាត់។
- បន្ទាប់ពីការសរសេរបកស្រាយរួច ត្រូវនិយាយសុភាសិតក្នុងក្រុមឱ្យបានស្ទាត់។
- គ្រូនិងសិស្សធ្វើការកែលម្អ។

តែងសេចក្តីបែបពិភាក្សា

១. វត្ថុបំណង

- ប្រាប់ពីគម្រោងតែងសេចក្តីបែបពិភាក្សាបានត្រឹមត្រូវ
- ចេះសរសេរតែងសេចក្តីបែបពិភាក្សាបានត្រឹមត្រូវ
- ការចេះស្វែងរកអំណះអំណាងក្នុងមតិស្រប មតិផ្ទុយតែងសេចក្តីបែបពិភាក្សា ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ១៩២-១៩៥

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀន "តែងសេចក្តីបែបពិភាក្សា" ដាក់លើក្តារខៀន រួចសួរ :
  - តើតែងសេចក្តីបែបពិភាក្សា ទាមទារឱ្យអ្នកធ្វើតែងសេចក្តី ត្រូវធ្វើយ៉ាងដូចម្តេចខ្លះ ?

    ចម្លើយ : ទាមទារឱ្យអ្នកធ្វើតែងសេចក្តីត្រូវម្តងនិយាយឱ្យស្របតាមមតិប្រធាន ម្តងនិយាយឱ្យផ្ទុយ ឬជំទាស់ពីមតិប្រធាន ។
  - តើប្រធានបែបពិភាក្សា ទាមទារធ្វើការបកស្រាយយ៉ាងដូចម្តេច ចំពោះមតិប្រធាន ?

    ចម្លើយ : ទាមទារឱ្យបកស្រាយចំពោះមតិប្រធានគឺ ៖
    + មតិស្រប : ត្រូវពន្យល់ឱ្យស្របតាមមតិប្រធាន ។
    + មតិផ្ទុយ : ត្រូវពន្យល់ជំទាស់ ឬប្រឆាំងនឹងមតិប្រធាន ។
    + ការពិភាក្សា : ការថ្លឹងថ្លែងវិនិច្ឆ័យរវាងមតិស្របនិងមតិផ្ទុយ ដើម្បីប្រមើលមើលរកចំណុចរួម និងចំណុចសមហេតុសមផលនៃមតិនីមួយៗ ។
    + ការសំយោគ គឺជាការផ្សំមតិរួមគ្នា ឬបំពេញគ្នាទៅវិញទៅមករវាងមតិស្របនិងមតិផ្ទុយ ។
- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្សទំព័រទី ១៩៥ ៖

  ចម្លើយ :

  ១. សេចក្តីអធិប្បាយខាងលើ មានបីផ្នែកធំៗគឺ : ផ្តើមសេចក្តី តួសេចក្តី និងបញ្ចប់សេចក្តី ។

  ២. សេចក្តីអធិប្បាយនេះ បានបកស្រាយប្រធានបទ "តថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន" ក្នុងរឿងគូលីកំណែន គ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំបានផ្តល់តម្លៃអប់រំដល់អ្នកសិក្សានោះទេ ។

  ៣. មូលហេតុដែលនាំឱ្យសំណេរនេះប្រើ ៖
  + សំនួនស្រប : "ជាការពិតណាស់ ..." មកពីសំនួននេះ ជាសំនួនគាំទ្រឱ្យមតិស្រប គឺគាំទ្រមតិប្រធាន ។
  + សំនួនបដិសេធ : "ផ្ទុយទៅវិញ ..." មកពីសំនួននេះ ជាសំនួនគាំទ្រឱ្យមតិផ្ទុយ គឺមិនគាំទ្រមតិប្រធាន ។

  ៤. ការប្រើសំនួន "ជារួម" ស្ថិតនៅក្នុងផ្នែកពិភាក្សានៃសេចក្តីអធិប្បាយ ។

៥. រាល់បំណកស្រាយទាំងនោះ សុទ្ធតែមានអំណះអំណាងគាំទ្រ ស្របទៅតាមគំនិតសំខាន់នីមួយៗ។ អំណះអំណាងទាំងនោះមាន ៖

ក. មតិស្របៈ អំណះអំណាងគាំទ្រ គឺតថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែនគ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំបានផ្តល់តម្លៃអប់រំដល់អ្នកសិក្សានោះទេ ព្រោះអ្នកនិពន្ធបានលើកយកប្រធានបទនៃទុក្ខវេទនារបស់ក្រុមគូលី(គំនិតសំខាន់)។

- មកប្រឌិតទៅតាមអារម្មណ៍ស្រមើស្រមៃរបស់ខ្លួន។
- ពុំមានលក្ខណៈដូចក្នុងសាច់រឿងទេ។
- ដោយចង់ពន្លេចន័យដល់អ្នកអាន បែរជាខិតខំបំផ្លើសឱ្យហួសពីការពិត។
- ការបង្ហាញបែបនេះពុំបានផ្តល់ការអប់រំដល់អ្នកអានឱ្យចេះតស៊ូ ការព្យាយាម រកវិធីដោះស្រាយក្នុងជីវិត។

ឧទាហរណ៍ : (សេចក្តីលម្អិតគាំទ្រ) ក្នុងរឿងគូលីកំណែន បានបង្ហាញពីតថភាពនៃក្រុមគូលីដែលត្រូវរាជការអាណានិគមជប៉ុនកេណ្ឌយកទៅធ្វើគូលីនៅការដ្ឋានវាលយន្តហោះពោធិ៍ចិនតុងដែលរងទុក្ខលំបាកដ៏ធ្ងន់ធ្ងរពេក គឺមានស្បៀងអាហារមិនសមស្របតាមកម្លាំងពលកម្ម (ប្រហុកដុត ត្រីងៀត អំបិល បុកក្រសាំង អំពិល ត្រីឆ្អើរ)។ ការគ្រប់គ្រងប្រមូលគូលីកំណែនគឺ

+ ការកេងប្រវ័ញ្ចរបស់មេឃុំផាន់ ដែលកេណ្ឌលើសពីមួយរយនាក់(ម្ភៃនាក់) តម្រូវទៅលើគ្រួសារណាដែលមានធុរៈចាំបាច់។
+ អ្នករឹងទទឹងនឹងបង្គាប់នេះ មេឃុំផាន់ចាប់ដាក់ខ្នោះ បញ្ជូនទៅសាលាស្រុក ទៅសាលាខេត្ត។
+ មេឃុំផាន់បានទទួលសំណូកយ៉ាងច្រើន តាមរយៈការជួលគូលីជំនួស បានទទួលប្រាក់ហាសិបរៀល។
+ ក្រុមគូលីអង្គុយតាមសង្កាត់ តាមឃុំ ក្បាលមីរដូចជាមានទោសធ្ងន់។
+ គេស្លៀកពាក់ខោស្មាប់ភ្លៅ លើជង្គង់បំណះយុល។

ខ. មតិផ្ទុយ : អំណះអំណាងគាំទ្រ គឺតថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែនមិនគ្រាន់តែជាតថភាពមួយនៅក្នុងរឿងទេ តែបានផ្តល់តម្លៃអប់រំដល់អ្នកសិក្សា ព្រោះក្នុងអក្សរសិល្ប៍មានតួនាទីក្នុងការឆ្លុះបញ្ចាំងពីតថភាព ដើម្បីអប់រំ(គំនិតសំខាន់)

- ឱ្យមើលឃើញពីទំនាស់រវាងផលប្រយោជន៍អ្នកកាន់អំណាចនិងផលប្រយោជន៍រាស្ត្រ។
- សមិទ្ធិផលវាលយន្តហោះបម្រើតែប្រយោជន៍អាណានិគមនិយម យុទ្ធសាស្ត្រសង្គ្រាមរបស់ផាស៊ីសជប៉ុន ប្រឆាំងនឹងបារាំង ដើម្បីសេដ្ឋកិច្ច។
- ឱ្យមើលឃើញពីវិធីកេងប្រវ័ញ្ចរបស់មន្ត្រីអាណានិគមមកលើប្រជារាស្ត្រ។
- ការបង្ហាញបែបនេះជាការអប់រំដល់អ្នកអានឱ្យចេះតស៊ូ ការព្យាយាមរកវិធីដោះស្រាយក្នុងជីវិត។

ឧទាហរណ៍ : (សេចក្តីលម្អិតគាំទ្រ) ក្នុងរឿងគូលីកំណែន បានតថភាពនៃក្រុមគូលី ដែលត្រូវរាជការអាណានិគមជប៉ុនដើម្បីអប់រំដូចតទៅ

+ មើលឃើញពីភាពអយុត្តិធម៌ក្នុងកំណែន ដោយគ្មានគិតពីសុខភាព ពីវ័យរបស់ពលករ(តាមុយចាស់ជរា ក្មេងមិនទាន់ពេញវ័យគឺនាយអ៊ូច អ្នកមានជំងឺគឺអន្ទិតអ៊ុនជាប់កំណែន ហើយត្រូវស្លាប់នៅការដ្ឋាន) ។
+ ធ្វើឱ្យរាស្ត្រខ្មែរកាន់តែក្រីក្រ ព្រោះគ្មានកម្លាំងពលកម្មធ្វើការងារក្នុងគ្រួសារ ។
+ ខ្មែររងទុក្ខដោយសារតែសង្គ្រាមផង និងដោយសារតែកំណែនផង។
+ ក្រុមគូលីត្រូវបាត់សិទ្ធិសេរីភាព(គ្មានសិទ្ធិបញ្ចេញមតិ ឬទស្សន:ខ្លួនបានឡើយ តាមុយបានហាមប្រាម) ។
+ មើលឃើញចំពោះភាពអសីលធម៌របស់មន្ត្រីអាណានិគម តែបែរជាលុតក្រាបនៅចំពោះមន្ត្រីបរទេសទៅវិញ (លោកបាល័ដ្ឋប្រើពាក្យអសុរោះដាក់មេឃុំផាន់ តែទន់ភ្លន់ចំពោះសក្តិពីរជប៉ុន) ។

គ. ពិភាក្សា : អំណះអំណាងគាំទ្រគឺតថភាពសង្គមក្នុងគូលីកំណែន ជាតថភាពតែក្នុងរឿងពុំបានផ្តល់ការអប់រំជាមតិមិនត្រឹមត្រូវព្រោះ

- រឿងនីមួយៗអ្នកនិពន្ធតែងផ្តិតយកតថភាពសម័យកាលណាមួយមកឆ្លុះបញ្ចាំង ។
- តាមរយៈការឆ្លុះបញ្ចាំងនេះ ជាការផ្តល់ពុទ្ធិ និងអប់រំតាមរយៈសិល្បវិធី ។
- ការប្រើសិល្បវិធីបែបនេះនាំឱ្យអ្នកអានខ្លះមិនយល់ពីបំណងអ្នកនិពន្ធ រីភាគមិនស៊ីជម្រៅបាត់តម្លៃស្នាដៃ ។

៦. កថាខណ្ឌចុងក្រោយ សំដៅទៅលើបញ្ចប់សេចក្តី ។ របៀបនិយាយមានដូចតទៅ ៖

ក. វាយតម្លៃមតិប្រធាន : មតិប្រធានមិនត្រឹមត្រូវទេ ព្រោះមើលរំលងមុខងារអក្សរសិល្ប៍ ភ្ជាប់តថៈដើម្បីអប់រំមនុស្សនិងដើម្បីមនុស្ស ។

ខ. មតិផ្ទាល់ខ្លួន : ផ្តល់ដល់អ្នកសិក្សាឱ្យចេះស្វែងយល់ពីមុខងារអក្សរសិល្ប៍និងសិល្បវិធីអ្នកនិពន្ធ ដើម្បីចេះវិភាគក្នុងស្នាដៃនីមួយៗ ។

៧. ការកត់សំគាល់ចុងក្រោយអំពីប្រធានបទ គឺតម្រូវឱ្យយើងធ្វើការវិនិច្ឆ័យចំពោះ "តថភាពនៃទុក្ខវេទនារបស់ក្រុមកំណែនគ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំបានផ្តល់តម្លៃអប់រំដល់អ្នកសិក្សានោះទេ" ។ ក្នុងចំណុចនេះមតិប្រធានហាក់ដូចជា សង្កត់ធ្ងន់ទៅលើតួនាទីនិងមុខងារនៃអក្សរសិល្ប៍ ។ ដោយហេតុថា ស្នាដៃល្អលុះត្រាតែបានផ្សារភ្ជាប់ជាមួយតថភាព និងសិល្បវិធីរបស់អ្នកនិពន្ធដែលតម្រូវ ។

- ឱ្យសិស្សអានកំណត់សំគាល់ក្នុងសៀវភៅសិស្សទំព័រទី ១៩៦ ។

ខ. ការអនុវត្ត

- ឱ្យសិស្សបង្កើតគម្រោងតែងសេចក្តីពិភាក្សាលម្អិតក្នុងសៀវភៅសិស្សទំព័រទី ១៩៦ :

ប្រធានទី ១ : មតិមួយពោលថា "ហាំ ប្រព្រឹត្តអំពើមនុស្សឃាតដោយសារតែស្ថានភាពគ្រួសារបង្ខំ" ។

គម្រោងតែង

១. ផ្តើមសេចក្តី

- លំនាំបញ្ហា : ដោយសារតែខ្លួនត្រូវការប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារ ហាំក៏សម្រេចចិត្តប្រព្រឹត្តអាក្រក់តាមផែនការរបស់ថៅកែ ... ។

- ចំណុលបញ្ហា : ដោយមើលឃើញជីវិតដ៏លំបាករបស់ហាំបែបនេះហើយទើបមានមតិមួយពោលថា "ហាំ ប្រព្រឹត្ត អំពើមនុស្សឃាត ដោយសារតែស្ថានភាពគ្រួសារបង្ខំ" ។
- ចំណោទបញ្ហា : តើមតិខាងលើនេះត្រឹមត្រូវឬទេ ?

២. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី : ដើម្បីជាជំនួយដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះ ប្រធានជាមុន ។
- ពន្យល់ពាក្យ :
  + អំពើមនុស្សឃាត : អំពើសម្លាប់មនុស្សដោយមានផែនការទុកជាមុន ។
  + ស្ថានភាពគ្រួសារបង្ខំ : ភាពចាំបាច់ដែលស្ថានភាពគ្រួសារតម្រូវឱ្យធ្វើដោយខានមិនបាន ។
- ពន្យល់ន័យ : មានន័យថា ការប្រព្រឹត្តអំពើសម្លាប់មនុស្សរបស់ហាំក្នុងរឿងថៅកែចិត្តចោរ ដោយសារតែការចាំបាច់ ដែលស្ថានភាពគ្រួសារតម្រូវឱ្យធ្វើដោយខានមិនបាន ។
- បកស្រាយ :

ក. **មតិស្រប** : "ហាំ ប្រព្រឹត្តអំពើមនុស្សឃាត ដោយសារតែស្ថានភាពគ្រួសារបង្ខំ" ព្រោះក្នុងស្ថានភាពគ្រួសាររបស់ហាំ នៅពេលនោះគឺត្រូវការប្រាក់ :

+ ឱ្យកូនបានចូលរៀននៅអនុវិទ្យាល័យ ។
+ ឱ្យប្រពន្ធបានព្យាបាលជំងឺ ។
+ ឱ្យម្តាយបានធ្វើបុណ្យមុនគាត់អនិច្ចកម្ម ។

ឧទាហរណ៍ : ក្នុងរឿងថៅកែចិត្តចោរ ដោយសារតែហាំជាមេគ្រួសារ ដូច្នេះខ្លួនត្រូវមានកាតព្វកិច្ចសំខាន់ក្នុងការរកប្រាក់មកផ្គត់ផ្គង់គ្រួសារ ក្រៅពីមុខអាជីពជាអ្នកបើកបររថយន្តឈ្នួលឱ្យថៅកែ ហាំក៏សុខចិត្តទទួលការងារមួយទៀតពីថៅកែ គឺបុកឡានថៅកែអុងប៉ាងហុងលី ដើម្បីបានប្រាក់មួយម៉ឺនរៀល ។ ផែនការនេះ បានបង្កឱ្យមានមនុស្សស្លាប់អស់បីនាក់និងរបួសមួយចំនួនទៀត ហើយគិញក៏តាមមករកចាប់ហាំដល់ផ្ទះ ។ ដូច្នេះបើខ្លួនបានប្រាក់មកផ្តល់ឱ្យ :

+ កូនបានចូលរៀន កូនលែងលង់ខ្លៅ ដូចខ្លួនទៀត ហើយគាត់មានឈ្មោះថា ជាឪពុកល្អ មានព្រហ្មវិហារធម៌ ចំពោះកូន ។
+ ប្រពន្ធបានជាសះស្បើយពីជំងឺ ព្រោះមីងយ៉ានឈឺដើមទ្រូងក្អកខេះៗ ទៅពេទ្យត្រូវទិញថ្នាក់ថាក់ គាត់នឹងមានឈ្មោះថា ជាប្តីល្អមានភក្តីភាព ។
+ ម្តាយបានធ្វើបុណ្យមុនគាត់ទទួលអនិច្ចកម្មគាត់មានឈ្មោះថា កូនកតញ្ញូចំពោះអ្នកមានគុណ ។

- សរុប : ដូចនេះ ហាំ ប្រព្រឹត្តិអំពើមនុស្សឃាត ដោយសារតែស្ថានភាពគ្រួសារបង្ខំពិតប្រាកដមែន ។
- សំណួរភ្ជាប់សេចក្តី : តើការប្រព្រឹត្តិអំពើមនុស្សឃាតរបស់ហាំពិតជាមកពីស្ថានភាពគ្រួសាបង្ខំមែនឬយ៉ាងណា ?

ខ. **មតិផ្ទុយ** : "ហាំ ប្រព្រឹត្តអំពើមនុស្សឃាត មិនមែនដោយសារតែស្ថានភាពគ្រួសារបង្ខំទេ" ព្រោះមនុស្សយើងម្នាក់ៗ ទោះបីមានកាតព្វកិច្ចក្នុងគ្រួសារយ៉ាងណាក៏ដោយ ក៏មិនត្រូវល្មើសនឹង :

+ ច្បាប់
+ សីលធម៌
+ សាសនា

ឧទាហរណ៍ : ក្នុងរឿងថៅកែចិត្តចោរ ហាំក្នុងនាមជាអ្នកបើកបរខ្លួនបានប្រព្រឹត្តខុសនឹង ៖

- ផ្លូវច្បាប់ :
  + បើកបរហួសល្បឿនកំណត់ បង្កគ្រោះថ្នាក់ដោយចេតនា "បើអាមួយម៉ោងមួយរយ ព្រលែងចំឆ្អឹងជំនីរ" ស្លាប់មនុស្សអស់បីនាក់និងរបួសមួយចំនួនទៀត ។
  + ចង់គេចវេះពីសំណាញ់ច្បាប់ ក្រោយពីខ្លួនបុកឡានហុងលីរួចមក "ឱ្យតែបានមួយម៉ឺនគេចប្រាវឥឡូវ បន្ទំប្តូរឈ្មោះ ..." ។
- ផ្លូវសាសនា :
  + ប្រមាថជីវិតមនុស្ស "បើមិនសម្លាប់គេ គោងទុកឱ្យគ្នាឯងស្លាប់ ... អាយុវាអស់ អ្នកណាដឹងធ្វើម៉េច" ។
  + បំពានត្រង់ "បាណាតិបាតា" ដែលព្រះពុទ្ធអង្គទ្រង់ហាម ។
- ផ្លូវសាសនា :
  + គ្មានមនោសញ្ចេតនាមនុស្សជាតិ បើអ្នកស្លាប់ជាម្តាយ ជាប្រពន្ធ ជាកូន តើគាត់មានអារម្មណ៍ដូចគ្រួសារជនរងគ្រោះដែរឬទេ ?
  + គ្មានមនសិការការងារ ក្បត់ឧត្តមគតិ ខ្វះសម្បជញ្ញៈ ដើម្បីតែប្រាក់វង្វេងបាត់បង់ស្មារតី "ស្រុកឥឡូវអីក្លឹង! គេកាប់ជ្រូកធ្វើបុណ្យ គេស៊ីសំណូកធ្វើបុណ្យ គេសំពះព្រះសង្ឃឱ្យគេស្រឡាញ់ ..." ។

គ. **ពិភាក្សា** : ការយល់ឃើញថា ហាំប្រព្រឹត្តអំពើមនុស្សឃាតដោយសារស្ថានភាពគ្រួសារបង្ខំ មិនត្រឹមត្រូវទេ ព្រោះថាមនុស្សម្នាក់ៗមិនមែនសុទ្ធតែធ្វើអ្វីមួយដោយមិនគិតពីហេតុផលនោះឡើយ ។ ការកសាងសេចក្តីសុខ លើសេចក្តីទុក្ខរបស់អ្នកដទៃជាការរំលោភបំពានបំពានសិទ្ធិចំពោះមនុស្សដូចគ្នា ។

៣. បញ្ចប់សេចក្តី

- វាយតម្លៃប្រធាន : មតិប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិតដែលមានលក្ខណៈជាបុគ្គលនិយម ឬអាត្មានិយម ... ។
- មតិផ្ទាល់ខ្លួន : តែមតិនេះ ក៏បានផ្តល់ជាបទពិសោធន៍ឱ្យយើងចេះត្រិះរិះពិចារណា មុននឹងធ្វើអ្វីមួយដែលជាផលប្រយោជន៍ខ្លួន ត្រូវគិតដល់អ្នកដទៃដើម្បីសេចក្តីសុខទាំងអស់គ្នានោះទើបជាការប្រសើរ ។

គ. ការវាយតម្លៃ

- ឱ្យសិស្សយកលំហាត់ទី ២ មកធ្វើការវាយតម្លៃដោយធ្វើជាគម្រោងតែង : សុភាសិតមួយចែងថា "ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់"

គម្រោងតែង

១. សេចក្តីផ្តើម

- លំនាំបញ្ហា : ជនជាតិខ្មែរ ជាជាតិសាសន៍មួយដែលមានមរតកវប្បធម៌ មានប្រាសាទ សិលាចារឹក អក្សរ ភាសា ឬជាពាក្យសុភាសិត ពាក្យអប់រំផ្សេងៗតាំងពីបុរាណកាលមក ។
- ចំណុលបញ្ហា : សុភាសិត "ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់" ជាពាក្យអប់រំមួយដែលជូនតាខ្មែរបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយធ្វើការសិក្សាត្រឹះរិះពិចារណាក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ។
- ចំណោទបញ្ហា : តើពំនោលខាងលើនេះត្រឹមត្រូវទាំងស្រុងឬទេ ?

២. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី : មុននឹងឈានចូលដល់ការបកស្រាយពំនោលខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន ។
- ពន្យល់ពាក្យ :
  + ស្លឹកឈើជ្រុះភាគច្រើន ជាស្លឹកឈើដែលទុំ ដែលជ្រុះតាមកាលវេលានៃស្លឹកនោះ ។
  + គល់ ជាប៉ែកដើមឈើខាងក្រោមជិតនឹងដី ។
- ពន្យល់ន័យ : ស្លឹកឈើទុំ តែកាលណាវាជ្រុះតែងតែជ្រុះនៅជិតៗជាប់គល់ជានិច្ច ។
- បកស្រាយ :

ក. **មតិស្រប** : ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់

- ន័យចំ : ស្លឹកឈើពេលជ្រុះមិនឆ្ងាយពីគល់ទេ ព្រោះ :
  + ពេលណាស្លឹកឈើទុំ វាក៏ជ្រុះទៅលើគល់ជានិច្ច មិនអាចហើរទៅទីណាឆ្ងាយនោះទេ ។
  + កម្លាំងនៃខ្យល់បក់ ពុំមានអានុភាពអាចបក់នាំឱ្យស្លឹកឈើនោះឱ្យចេញឆ្ងាយពីគល់បានទេ ។
  + គល់ឈើប្រភេទណា ស្លឹកឈើដែលជ្រុះនោះក៏មានប្រភេទដូចជាឈើនោះដែរ ។
- ន័យធៀប : ស្លឹកឈើជាកូន គល់ឈើជាត្រកូល ជាពូជពង្ស គឺកូនចៅមិនឃ្លាតឆ្ងាយពីត្រកូលខ្លួនឡើយ ព្រោះថា :
  + មានឈាមជ័រជាមួយគ្នា ។
  + មានខ្សែស្រឡាយពូជពង្សសាវតារដូចគ្នា ។
  + បានកើតចេញពីឪពុកម្តាយដែលជាអ្នកផ្តល់កំណើតឱ្យផ្ទាល់ ។
  + ពូជល្អ កូនក៏ល្អ ពូជអាក្រក់ កូនក៏អាក្រក់ដែរ "ពូជស្វាយផ្លែមកស្វាយ ពូជក្រូចផ្លែមកក្រូច" ។

ឧទាហរណ៍ :

  + ក្នុងសង្គម : បើពូជមន្ត្រី កូនក៏ជាមន្ត្រី បើពូជពាណិជ្ជករ កូនក៏ជាពាណិជ្ជករដែរ .... ។
  + ក្នុងអក្សរសិល្ប៍ : រឿងផ្កាស្រពោន ណៃសៀនជាឈ្មួញ ណៃស៊ីតជាកូនក៏ជាឈ្មួញដែរ ។
- សរុបមតិស្រប : ដូចនេះ ស្លឹកឈើពិតជាជ្រុះមិនឆ្ងាយពីគល់ពិតប្រាកដមែន ។
- សំណួរគ្លាប់សេចក្តី : តើស្លឹកឈើពិតជាជ្រុះមិនឆ្ងាយពីគល់គ្រប់ពេលវេលាមែន ឬយ៉ាងណា ?

ខ. មតិផ្ទុយ : ស្លឹកឈើជ្រុះឆ្ងាយពីគល់

- ន័យចំ : ស្លឹកឈើ ជ្រុះឆ្ងាយពីគល់ព្រោះថា :
  + ពេលណាស្លឹកឈើទុំ វាក៏ជ្រុះទៅឆ្ងាយដោយសារកម្លាំងខ្យល់បក់ ។
  + កម្លាំងខ្លាំងនៃខ្យល់ក៏មានអានុភាពអាចបក់នាំឱ្យស្លឹកឈើនោះឱ្យចេញឆ្ងាយពីគល់បាន ។
  + គល់ឈើប្រភេទណា មិនប្រាកដថាស្លឹកឈើដែលជ្រុះនោះមានប្រភេទដូចជាឈើនោះឡើយ ។
- ន័យធៀប : ស្លឹកឈើជាកូន គល់ឈើជាត្រកូល ជាពូជពង្សគឺកូនចៅអាចប្រាសចាកពីត្រកូលព្រោះថា :
  + មានឈាមជីរជាមួយគ្នា មែនតែមានគំនិតផ្សេងគ្នា ។
  + បានកើតចេញពីឪពុកម្តាយដែលជាអ្នកផ្តល់កំណើតឱ្យផ្ទាល់តែរូបរាងកាយ តែឪពុកម្តាយមិនអាចផ្តល់ចិត្តគំនិតដល់កូនបានទេ ។
  + ពូជល្អ មិនប្រាកដថាកូនល្អ ពូជអាក្រក់ មិនប្រាកដថាកូនអាក្រក់ទេ ។

ឧទាហរណ៍ :

+ ក្នុងសង្គម : បើពូជមន្ត្រី កូនក៏មិនប្រាកដជាមន្ត្រី បើពូជពាណិជ្ជករ កូនក៏មិនប្រាកដជាពាណិជ្ជករដែរ .... ។
+ ក្នុងអក្សរសិល្ប៍ : រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ សួនសុខជាឪពុក ជាកសិករ ឯសួនសមជាកូនធ្វើជាមេឃុំ ។

- សរុបមតិផ្ទុយ : ដូចនេះ ស្លឹកឈើប្រាកដជាអាចជ្រុះឆ្ងាយពីគល់ដែរ ។

គ. សំយោគ : ស្លឹកឈើប្រាកដជាមិនអាចជ្រុះឆ្ងាយពីគល់ ក្នុងករណីគ្មានខ្យល់បក់ តែអាចជ្រុះឆ្ងាយពីគល់ ក្នុងករណីដែលមានខ្យល់បក់ ។ ចំពោះមនុស្សវិញ ក្នុងករណីដែលកូនមានចរិតលក្ខណៈដូចជាឪពុកម្តាយដរាបណាកូននោះសេពគប់ត្រូវ (បណ្ឌិត) បានទទួលការអប់រំល្អពីឪពុកម្តាយពីគ្រូ ពីចាស់ព្រឹទ្ធាចារ្យ ។ ក្នុងករណីមិនមានចរិតលក្ខណៈ ដូចឪពុកម្តាយ គឺដោយសារកូននោះសេពគប់ខុស (ពាល)ពុំបានទទួលការអប់រំត្រឹមត្រូវទទួលឥទ្ធិពលតែពីសង្គមផ្ទាល់ហើយខ្វះភាពកក់ក្តៅក្នុងគ្រួសារ ... ។

៣. បញ្ចប់សេចក្តី

- វាយតម្លៃប្រធាន : មតិប្រធានមិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះឱ្យតម្លៃខ្ពស់តែទៅលើពូជពង្សវង្សត្រកូល ពុំបានឱ្យតម្លៃទៅលើឥទ្ធិពលនៃមជ្ឈដ្ឋានជុំវិញ ។
- មតិផ្ទាល់ខ្លួន : បានរួមចំណែកក្នុងការអប់រំ ឱ្យយើងស្គាល់ពីការរស់នៅក្នុងជីវិត ... ។



អក្សរសិល្ប៍បរទេស

ប្រជាជាតិទាំងអស់នៅលើពិភពលោកនេះ សុទ្ធតែបានរស់នៅលើភពផែនដីក្នុងបរិយាកាសមួយឯកភាពគ្នា ក្រោមមេឃតែមួយ ក្រោមពន្លឺព្រះអាទិត្យតែមួយ ហើយក៏បានទទួលឥទ្ធិពល ក្រឹត្យក្រមរួមពីធម្មជាតិ និងសង្គមផងដែរ ។

មេរៀននេះមានបំណងឱ្យសិស្សសិក្សាអំពីស្ថានភាពរស់នៅសកម្មភាពការងារការប្រកបរបរចិញ្ចឹមជីវិត ជំនឿសាសនា ទំនៀមទម្លាប់ប្រពៃណី វប្បធម៌របស់ជាតិសាសន៍នានាពីអតីតកាលដែលលើកយកមកបង្ហាញតាមរយៈអក្សរសិល្ប៍មួយចំនួន ។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិវាសាស្ត្រ	ទិវាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	២០១	១៩៧
• បំណិន : លក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍	១ម៉ោង	២ម៉ោង	២០២-២០៣	២០០
• អំណានទី ១ : អាពាហ៍ពិពាហ៍ខុងជឺ	២ម៉ោង	៤ម៉ោង	២០៤-២០៦	២០៣
• វេយ្យាករណ៍ : អំពីព្យាង្គ(សទ្ទនៅក្នុងព្យាង្គ)	០ម៉ោង	២ម៉ោង	២០៧-២១០	២០៧
• អំណានទី ២ : កិត្តិយស ឬស្នេហា	២ម៉ោង	៤ម៉ោង	២១១-២១៣	២១០
• ការស្តាប់ : អាប៉ាកុងបាត់ហឺបប្រាក់	២ម៉ោង	២ម៉ោង	២១៤-២១៧	២១៦
• ការនិយាយ : ការនិយាយសម្របសម្រួលក្នុងពិធីសំខាន់ៗ	២ម៉ោង	២ម៉ោង	២១៨-២២២	២១៧
• សំណេរ : បំពេញលិខិតផ្សេងៗ	២ម៉ោង	៣ម៉ោង	២២៣-២២៦	២២០

១. សិក្សាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សទំព័រទី ១៩៧ គ្រូសរសេរចំណងជើងមេរៀន"អក្សរសិល្ប៍បរទេស" រួចសួរ ៖
  - ដូចម្តេចហៅថា "អក្សរសិល្ប៍បរទេស" ?

    ចម្លើយ : គឺជាអក្សរសិល្ប៍របស់ប្រទេសនានាលើពិភពលោក ។

២. សិក្សាលើរូបភាព

- គ្រូឱ្យសិស្សសង្កេតរូបភាពមេរៀន រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

    ចម្លើយ : រូបជនបរទេសមានអឺរ៉ុប និងចិនសម័យបុរាណ ។
  - តើរូបភាពនេះ បានបង្ហាញពីលក្ខណៈជាតិដូចម្តេចខ្លះ ?

    ចម្លើយ : បានបង្ហាញពីលក្ខណៈជាតិអំពី សម្លៀកបំពាក់ អាកប្បកិរិយា ...ដែលតំណាងឱ្យជាតិនីមួយៗ ។

លក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍

១. វត្ថុបំណង

- ប្រាប់និយមន័យលក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍បានត្រឹមត្រូវ
- រកឃើញលក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍រឿងទុំទាវ រឿងជនកំណាញ់ស្វិតបានត្រឹមត្រូវ
- មានមនោសញ្ចេតនាចំពោះខ្លឹមសារស្នាដៃអក្សរសិល្ប៍មានលក្ខណៈអន្តរជាតិ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២០០-២០២
- អក្សរសិល្ប៍រឿងអង់ទីហ្គូនីរនារីក្រុងថែប រឿង ទុំទាវ និង រឿងជនកំណាញ់ស្វិត

៣. ព័ត៌មានជំនួយ

- សូមលោកគ្រូអ្នកគ្រូរកអក្សរសិល្ប៍ រឿងអង់ទីហ្គូនីរនារីក្រុងថែប ទុំទាវ រឿងជនកំណាញ់ស្វិត ដើម្បីប្រើប្រាស់ជាជំនួយដល់ការធ្វើលំហាត់ ។
- លោកគ្រូអ្នកគ្រូមិនបាច់ឱ្យសិស្សឆ្លើយសំណួរទី ១របស់លំហាត់ ក្នុងសៀវភៅសិស្សទំព័រទី ២០២ ព្រោះលំហាត់នេះខុស ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន "លក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍"
  - តើអ្នកធ្លាប់បានសិក្សាលក្ខណៈអក្សរសិល្ប៍អ្វីខ្លះ ?

    ចម្លើយ : លក្ខណៈជាតិនៃអក្សរសិល្ប៍ខ្មែរ អក្សរសិល្ប៍មានលក្ខណៈសង្គម លក្ខណៈប្រជាជន ... ។
  - តើគេចែកអក្សរសិល្ប៍ខ្មែរជាប៉ុន្មានចលនា ? ចលនាអ្វីខ្លះ ?

    ចម្លើយ : ឱ្យសិស្សមើលសៀវភៅសិស្សទំព័រ ១៩៨-១៩៩ ។
- ឱ្យសិស្សអាចសេចក្តីពន្យល់រួចសួរ ៖
  - តើចំណុចណាដែលថាអត្ថបទដកស្រង់នេះមានលក្ខណៈអន្តរជាតិ ?

    ចម្លើយ : គឺប្រពៃណីទុកដាក់សព មនោសញ្ចេតនាបងប្អូន (លក្ខណៈមនុស្ស) ។

ខ. ការហ្វឹកហាត់

- ឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្ស ៖

ចម្លើយ :

២. រឿងអាប៉ាកុង ជាស្នាដៃអក្សរសិល្ប៍របស់បារាំង ដែលមានតួអង្គអាប៉ាកុងជាមនុស្សកំណាញ់សិត គឺកំណាញ់ចំពោះអ្នកជុំវិញខ្លួនហើយក៏កំណាញ់ចំពោះខ្លួនឯងដែរ ។ អាប៉ាកុង ស្រឡាញ់លុយជាងអ្វីៗទាំងអស់ សូម្បីតែជីវិតគាត់ក៏មិនស្តាយដែរ ពោលគឺលុយមានតម្លៃជាងជីវិតទៅទៀត ។ ភាពកំណាញ់ដូចអាប៉ាកុងស្ទើរគ្រប់ទីកន្លែង ដូចជានៅកម្ពុជាយើងមានរឿងម៉ៅសិត រឿងលាកាក់បានហើយរបស់វៀតណាមជាដើម ។ ដូច្នេះ រឿងអាប៉ាកុងមានលក្ខណៈជាតិនៃអក្សរសិល្ប៍របស់បារាំង ហើយត្រូវបានគេផ្សព្វផ្សាយពេញពិភពលោក ទើបរឿងនេះបានទទួលស្គាល់វាថាជារឿងមានលក្ខណៈអន្តរជាតិ ។

- ឱ្យសិស្សកត់ត្រាចម្លើយត្រឹមត្រូវដាក់ក្នុងសៀវភៅ ។

គ. ការវាយតម្លៃ

- ដូចម្តេចដែលហៅថា អក្សរសិល្ប៍មានលក្ខណៈអន្តរជាតិ ?

ចម្លើយ : ក្នុងសៀវភៅសិស្សទំព័រ ២០២ ។

- តើចំណុចណាខ្លះដែលបញ្ជាក់ថា រឿងកិត្តិយស ឬស្នេហាមានលក្ខណៈអន្តរជាតិ ?

ចម្លើយ : មានក្នុងអត្ថបទអំណាន "កិត្តិយស ឬស្នេហា" ។



អាពាហ៍ពិពាហ៍ខុងជឺ

១. វត្ថុបំណង

- សិស្សវិភាគតួអង្គនិងវាយតម្លៃទស្សន:ខុងជឺបានត្រឹមត្រូវតាមរយៈអត្ថបទ
- បណ្តុះស្មារតីសិស្សឱ្យមានទឹកចិត្តសន្តោសមេត្តាមនុស្សដូចគ្នាតាមរយៈសកម្មភាពតួអង្គខុងជឺដែលមានក្នុងអត្ថបទដកស្រង់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្ស ទំព័រ ២០៣-២០៦

៣. ព័ត៌មានជំនួយ

- ទស្សន:វិជ្ជាខុងជឺ រៀបរៀងដោយលោក សុខ សុត្ថាល ឆ្នាំ ១៩៧២ ។

  ចំណុចកែតម្រូវ : អត្ថបទដកស្រង់នេះជាអំណានមិនមែនជាបំណិនទេ ។

៤. លំនាំបង្រៀន

ក. ត្រៀមអំណាន

- សរសេរចំណងជើងដាក់លើក្តារខៀនរួចបំផុសសំណួរ ៖
  - តើចំណងជើងអត្ថបទអំណាននិយាយពីអ្វី ?

    ចម្លើយ : អាពាហ៍ពិពាហ៍ខុងជឺ ។
  - តើខុងជឺជាជនជាតិអ្វី ?

    ចម្លើយ : ជនជាតិចិន និងជាទស្សនវិទូចិនដ៏ល្បីល្បាញ ។
  - ពាក្យថា "អាពាហ៍ពិពាហ៍ខុងជឺ"មានន័យដូចម្តេច ?

    ចម្លើយ : ការរៀបការរបស់ខុងជឺ ។
- សួរសំណួរទាក់ទងនឹងរូបភាព ៖
  - តើរូបភាពនេះបង្ហាញពីអ្វីខ្លះ ?

    ចម្លើយ : រូបមនុស្សស្រីកំពុងឱបគ្នា មនុស្សប្រុសម្នាក់ឈរមើល ដែលអ្នកនោះមានសម្លៀកបំពាក់បែបជនជាតិចិនពីបុរាណ ។
  - តើចំណងជើងនិងរូបភាពនេះមានការទាក់ទងគ្នាដូចម្តេចខ្លះ ?

    ចម្លើយ : ចំណងជើងអត្ថបទទាក់ទងនឹងរូបភាពគឺឈ្មោះខុងជឺជាជនជាតិចិន រីឯរូបភាពក៏មានលំនាំជាជនជាតិចិនពីបុរាណ ។ ដូច្នេះអត្ថបទនេះអាចនិយាយពីការរៀបការរបស់ខុងជឺ ។
- គ្រូឱ្យសិស្សធ្វើការសិក្សាពាក្យគន្លឹះក្នុងសៀវភៅសិស្សទំព័រទី ២០៣ ឬពាក្យគន្លឹះដដែទៀតក្នុងអំណាន ។

ខ. អំណាន

- ឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិន
- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្ស

- ឱ្យសិស្សអានអត្ថបទ (អានឮ ឬអានស្ងាត់តាមស្ថានភាពជាក់ស្តែង)

គ. ពង្រឹងអំណាន

- ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅ ៖

ចម្លើយ

១. តាមរយៈអត្ថបទនេះ សង្គមសម័យខុងជឺ គឺជាសង្គមសក្តិភូមិ ដែលពោរពេញទៅដោយការរំលោភសិទ្ធិមនុស្ស ប្រើមនុស្ស និងជួញដូរមនុស្សដូចសត្វធាតុ។ ជាទូទៅ មនុស្សដែលគេចាត់ទុកជាទំនិញត្រូវគេចាប់ដាក់ច្រវាក់។ ឯតម្លៃមនុស្សម្នាក់ស្មើនឹងអំបិល ១០នាឡិ (ប្រមាណ ៧គីឡូក្រាម)ប៉ុណ្ណោះ។

២. ចំណោមនារីក្នុងបាតសំពៅ ខុងជឺបានជ្រើសរើសនារីអ្នកទោសម្នាក់ ដែលគេបានដាក់ច្រវាក់ មានរូបអាក្រក់យកមកធ្វើជាប្រពន្ធ ព្រោះខុងជឺជាមនុស្សដែលមានគុណធម៌។ លោកមានចិត្តអាណិតអាសូរអ្នកមានទុក្ខ ពាក្យថារៀបការជាមួយនាងគឺដើម្បីរំដោះនាងពីទុក្ខវេទនា។ អំពើនេះ សបញ្ជាក់ថាខុងជឺជាមនុស្សប្រកបទៅដោយឧត្តមគតិ មានចិត្តសន្តោសប្រណី មិនរើសអើង ឬមិនប្រកាន់អតីតភាព។

៣. បកស្រាយវាចាខុងជឺ ៖

ក. "ធ្វើគុណទៅហើយ បើគេតបគុណមកវិញ ចាត់ទុកដូចជាពុំបានធ្វើគុណ" មានន័យថា សង្គមមិនអាចរស់នៅឯកោដាច់ពីគ្នាបានទេត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក តាមរយៈការជួយសង្គ្រោះគ្នាក្នុងគ្រាលំបាក។ ប៉ុន្តែក្នុងករណីដែលយើងបានធ្វើអំពើល្អទៅលើជនណាម្នាក់ ដើម្បីឱ្យអ្នកនោះធ្វើអំពើល្អណាមួយទៀតមកលើរូបយើងវិញ នោះមានន័យថា យើងនិងជននោះត្រូវចាត់ទុកថាស្មើគ្នា គ្មាននរណាម្នាក់ត្រូវគេជំពាក់គុណ ឬត្រូវសងគ្នាទៅវិញទៅមកឡើយ។

ខ. "ធ្វើគុណទៅហើយ ត្រឡប់ជាបានផលអាក្រក់មកវិញត្រូវទទួលយកការពិសោធដោយដៃពីរ" មនុស្សក្នុងសង្គមមានច្រើនប្រភេទ។ ដូចជាក្នុងពេលដែលមានគ្រោះ ឬផលវិបាកអ្វីមួយកើតឡើង ជននោះតែងអំពាវនាវដល់សប្បុរសជនមកជួយខ្លួន។ នៅពេលគេបានជួយសង្គ្រោះហើយ អ្នកជួយបែរជាជួបគុណវិបត្តិដោយអំពើល្អរបស់ខ្លួន ដូចពាក្យខ្មែរ មួយឃ្លាថា "ធ្វើគុណបានទោស"។ ក្នុងន័យឃ្លាខាងលើ លោក ខុងជឺ បានបកស្រាយថា អ្នកធ្វើគុណមិនចាំបាច់ខឹងតូចចិត្តអ្វីនោះទេ តែត្រូវទទួលយកទង្វើនោះមកធ្វើជាបទពិសោធន៍សម្រាប់ជីវិតរបស់ខ្លួនក្នុងការស្វែងយល់ពីមនុស្សដែលត្រូវទាក់ទងតទៅទៀត។

គ. "ធ្វើគុណហើយ បើវារលាយសូន្យទៅ ត្រូវបន្តការធ្វើគុណទៅទៀតប្រៀបដូចត្រី បើវាចឹកនុយអស់ហើយ គេត្រូវយកសន្ទូចបិទនុយថែមទៀត"។ ឃ្លានេះខុងជឺបញ្ជាក់អំពីអំពើល្អរបស់ខ្លួនត្រូវបាត់បង់ដោយប្រការណាមួយនោះ សប្បុរសជនមិនត្រូវបញ្ឈប់ ឬងាកចេញពីអំពើល្អនោះទេ តែត្រូវព្យាយាមធ្វើតទៅទៀត ព្រោះអំពើទាំងនោះជាអំពើត្រឹមត្រូវ។ ការព្យាយាមធ្វើអំពើល្អចំពោះមនុស្សអាក្រក់ គឺជាវិធីមួយបែប ដើម្បីកែប្រែមនុស្សអាក្រក់។ ដូច្នេះបើចង់បន្តយមនុស្សអាក្រក់ត្រូវតែព្យាយាមធ្វើអំពើល្អទៅលើអ្នកទាំងនោះ។

៤. សព្វថ្ងៃការជួញដូរមនុស្សត្រូវបានថយចុះជាលំដាប់ ដោយប្រជារាស្ត្រមានការយល់ដឹងខាងផ្លូវសីលធម៌ និងផ្លូវច្បាប់កាន់តែប្រសើរ។ ដើម្បីបំបាត់អំពើបែបនេះ យើងគប្បីសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ចូលរួមក្នុងសកម្មភាពភូមិឃុំសុវត្ថិភាព ជាពិសេសគោរពច្បាប់ទាំងអស់គ្នា។

- ឱ្យសិស្សចម្លងចម្លើយដាក់ក្នុងសៀវភៅ។

គ. ការវាយតម្លៃ

- ឱ្យសិស្សសង្ខេបអត្ថបទឡើងវិញ

ចម្លើយ : នៅតាមទន្លេលឿង គេឃើញទូកនេសាទជាច្រើនដឹកនាំទាសីល្អៗ ភោជន៍សាលី កំណាត់សំពត់សូត្រ យកទៅដូរឱ្យអ្នករស់នៅភាគខាងជើង ហើយនាំមកវិញនូវភោគទ្រព្យមានតម្លៃនិងទាសីល្អៗ នៅទីនោះមកលក់ឱ្យលោកម្ចាស់គ្រប់ស្រុក។ មកដល់ស្រុកលូ លោកម្ចាស់លូ ឈ្មួញគ្រប់គ្នាបានត្រូវម្ចាស់ផ្ទះបង្គាប់ឱ្យរៀបចំពិធីជប់លៀងយ៉ាងអធិកអធម រួចគេបញ្ចេញទាសីល្អៗមកបង្ហាញម្នាក់ម្តងៗឱ្យទស្សនិកជនមើល។ ខុងជីដែលមានមាឌខ្ពស់ស្រឡះ ដៃជើងមាំមួន តែសុភាពស្លូតបូតដូចអ្នកបួស។ ខុងជីនៅយាមសំពៅតាមបញ្ជារបស់លោកម្ចាស់ ហើយក៏បានឃើញស្រីម្នាក់មុខជាំខ្មៅ អាក្រាតខ្លួនទទេរ មានច្រវាក់ជាប់អវៈយវៈទាំងសងខាងនៅបាតសំពៅ។ តាចាស់ម្នាក់បានប្រាប់ខុងជីថា នាងនេះជាជនជាតិម៉ុងហ្គោលីទិញក្នុងតម្លៃអំបិល ១០នាឡិ។ នាងវង្វេងស្មារតីត្រូវគេដាក់ច្រវាក់ខ្លាចនាងរើរបស់ទ្រព្យ។ នាយភេត្រាអស់សំណើចនៅពេលដែលឃើញខុងជីយកសម្លៀកបំពាក់ទៅបិទបាំងរាងកាយនោះ ហើយឱ្យខុងជីជ្រើសស្រីដែលខ្លួនពេញចិត្តធ្វើជាប្រពន្ធ។ ខុងជីបានសុំនាងរូបអាក្រក់នោះមកធ្វើជាប្រពន្ធ ហើយនាំនាងទៅជួបនិងម្តាយរបស់ខ្លួន រួចម្តាយខុងជីបានខិតខំព្យាបាលនាងនោះតែមិនបានជាសះស្បើយឡើយ។ ខុងជីបានបង្រៀននាងឱ្យចេះធ្វើកិច្ចការដូចស្ត្រីដទៃទៀតក្នុងភូមិ និងបង្រៀនឱ្យចេះនិយាយអានភាសាចិន ច្រៀង សូត្រកំណាព្យជាដើម។ ថ្ងៃមួយនាងនោះបានលួចសេះខុងជីបំផ្ទាយទៅភ្នំទឹកកកប៉ែកអាគ្នេយ៍ក្នុងស្រុកចាន់តុង។ ខុងជីមិនខឹងនិងនាងទេ។ រាត្រីមួយនាងនោះបានត្រឡប់មកវិញដោយមានរូបសម្ផស្សស្រស់ស្អាត។ នាងគឺជាកូនស្រីមេកន្ទ្រាញភ្នំម្នាក់ជាតិម៉ុងហ្គោល។

- ទាក់ទងនឹងការជួញដូរមនុស្សនេះ តើនៅប្រទេសកម្ពុជាយើងមានច្បាប់ស្តីពីការលក់ដូរនិងអំពើធ្វើអាជីវកម្មលើមនុស្សដែរឬទេ ? ចូរបង្ហាញមាត្រាណាមួយដែលទាក់ទងអំពើពង្រត់មនុស្ស។

ចម្លើយ : នៅប្រទេសកម្ពុជាយើងមានច្បាប់ស្តីពីការលក់ដូរនិងអំពើធ្វើអាជីវកម្មលើមនុស្ស។ ច្បាប់នេះមាន ៥ ជំពូក និងមាន ១០មាត្រា។

- ជំពូកទី ២អំពើពង្រត់មនុស្សយកទៅលក់ ឬយកទៅធ្វើពេស្យាចារមាត្រា ៣ ៖
  + ជនណាអូសទាញមនុស្ស ទោះបីស្រី ឬប្រុស អនីតិជន ឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ វិធីលួងលោមសន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្ត ឬមិនសុខចិត្តដោយវិធីបង្ខិតបង្ខំគំរាមកំហែង ឬប្រើថ្នាំសណ្តំស្មារតី និងសតិអារម្មណ៍ដើម្បីពង្រត់យកទៅលក់ ឬយកទៅធ្វើពេស្យាចារជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំដល់ ១៥ឆ្នាំ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំដល់ ២០ឆ្នាំ។
  + អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញ ឬទទួលយកត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ។ ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ ឬមធ្យោបាយផ្សេងៗសម្រាប់ប្រព្រឹត្តបទល្មើស មធ្យោបាយផ្តល់ប្រាក់ ឬមធ្យោបាយដឹកជញ្ជូនសម្ភារៈនិងទ្រព្យសម្បត្តិប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

(ដកស្រង់ចេញពីឯកសារស្វែងយល់អំពីការប្រឆាំងរាល់អំពើហិង្សាទៅលើស្ត្រីភេទ និងច្បាប់របស់អង្គការកម្ពុជាដើមជួយស្ត្រីមានវិបត្តិទំព័រទី ៣៨-៣៩)។



អំពីព្យាង្គ(សទ្ធក្នុងព្យាង្គ)

១. វត្ថុបំណង

- សិស្សរៀបរាប់ពីនិយមន័យនៃព្យាង្គបានត្រឹមត្រូវ
- សិស្សរកឃើញទីតាំងនៃសទ្ធក្នុងព្យាង្គបានត្រឹមត្រូវតាមរយៈការលើកឧទាហរណ៍បញ្ជាក់ ។

២. សម្ភារបង្រៀន

- សៀវភៅសិស្សទំព័រ ២០៧ដល់ ២០៩

៣. ព័ត៌មានដំឡូយ

សៀវភៅវេយ្យាករណ៍ថ្នាក់ទី ៥ បោះពុម្ពឆ្នាំ ១៩៨១ និងវេយ្យាករណ៍ថ្នាក់ទី ៨ បោះពុម្ពឆ្នាំ ១៩៨៦ ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀន "អំពីព្យាង្គ" ដាក់លើក្តារខៀនហើយអានចំណងជើងរួចសួរ ៖
  - តើព្យាង្គជាអ្វី ?

    ចម្លើយ : គឺជាសូររួមនៃសទ្ធដែលបន្លឺឡើងតែមួយបន្សាយសំឡេង ។
- ឱ្យសិស្សអានសេចក្តីពន្យល់ ឧទាហរណ៍និងសំណួរក្នុងសៀវភៅ
  - តើព្យាង្គនីមួយៗផ្សំឡើងដោយសារអ្វីខ្លះ ?

    ចម្លើយ : ស្រៈ អក្សរកាត់ "ស"និងព្យញ្ជនៈ អក្សរកាត់ "ព" ។
  - តើព្យាង្គដែលមានក្នុងវេយ្យាករណ៍ខ្មែរមានទម្រង់ដូចម្តេចខ្លះ ?

    ចម្លើយ : ទម្រង់ ពស ពពស ពសព ពពសព ។
  - តើស្រៈនិងព្យញ្ជនៈដែលជាធាតុរបស់ព្យាង្គគេឱ្យឈ្មោះដូចម្តេច ?

    ចម្លើយ : សទ្ធ ។
  - ដូចម្តេចដែលហៅថា សទ្ធ ?

    ចម្លើយ : គឺជាសទ្ធទោល ឬផ្សំដែលមានធាតុមុខងារជាធាតុរបស់ព្យាង្គ ។ ក្នុងព្យាង្គនីមួយៗមានសទ្ធដើមព្យាង្គ (ជាសទ្ធព្យញ្ជនៈ) សទ្ធកណ្តាលព្យាង្គ(ភាគច្រើនដាច់ខាតជាស្រៈ) និងសទ្ធចុងព្យាង្គ(ព្យញ្ជនៈ) ។

ខ. ការហ្វឹកហាត់

- ឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្ស :

ចម្លើយ :

១. ព្យាង្គ គឺសូររួមនៃសទ្ទដែលបន្លឺឡើងតែមួយបន្សាយសំឡេង ។

ឧទាហរណ៍ : ចេក បី ដើម

២. ស្រង់ព្យាង្គពីក្នុងឃ្លះ "កង្កែបច្រៀងលេងសប្បាយពេលភ្លៀងរលឹម" ។

ចម្លើយ :

ច្រៀង លេង ពេល ភ្លៀង ។

៣. ពាក្យ "គោ មេ មួយ នឹម ភ្លួរ ស្រែ ស្ទូង ស្រូវ" គឺ

ក. សទ្ទដើមព្យាង្គ

- សទ្ទទោលទម្រង់ "ពស ឬពសព"

+ គោ < [គ] + [អោ] → [គ] ជាសទ្ទដើមព្យាង្គ

+ មេ < [ម] + [អេ] → [ម] ជាសទ្ទដើមព្យាង្គ

+ មួយ < [ម] + [អួ] + [យ] → [ម] ជាសទ្ទដើមព្យាង្គ

+ នឹម < [ន] + [អឹ] + [ម] → [ន] ជាសទ្ទដើមព្យាង្គ

- សទ្ទផ្សំទម្រង់ "ពពស ឬពពសព"

+ ភ្លួរ < [ភ្ល] + [អួ] + [រ] → [ភ្ល] ជាសទ្ទដើមព្យាង្គ

+ ស្រែ < [ស្រ] + [អែ] → [ស្រ] ជាសទ្ទដើមព្យាង្គ

+ ស្ទូង < [ស្ទ] + [អូ] + [ង] → [ស្ទ] ជាសទ្ទដើមព្យាង្គ

+ ស្រូវ < [ស្រ] + [អូ] + [វ] → [ស្រ] ជាសទ្ទដើមព្យាង្គ

ខ. សទ្ទកណ្តាលព្យាង្គ គឺជាសូរស្រៈក្នុងទម្រង់ "ពសព ឬ ពពសព"

+ មួយ < [ម] + [អួ] + [យ] → [អួ] ជាសទ្ទកណ្តាលព្យាង្គ

+ នឹម < [ន] + [អឹ] + [ម] → [អឹ] ជាសទ្ទកណ្តាលព្យាង្គ

+ ភ្លួរ < [ភ្ល] + [អួ] + [រ] → [អួ] ជាសទ្ទកណ្តាលព្យាង្គ

+ ស្ទូង < [ស្ទ] + [អូ] + [ង] → [អូ] ជាសទ្ទកណ្តាលព្យាង្គ

+ ស្រូវ < [ស្រ] + [អូ] + [វ] → [អូ] ជាសទ្ទកណ្តាលព្យាង្គ

គ. សទ្ទចុងព្យាង្គ គឺអាចជាសូរស្រៈ ឬសូរព្យញ្ជនៈ

- សូរស្រៈក្នុងទម្រង់ "ពស ឬពពស"

+ គោ < [គ] + [អោ] → [អោ] ជាសទ្ទចុងព្យាង្គ

+ មេ < [ម] + [អេ] → [អេ] ជាសទ្ទចុងព្យាង្គ

+ ស្រែ < [ស្រ] + [អែ] → [អែ] ជាសទ្ទចុងព្យាង្គ

- សូរព្យញ្ជនៈក្នុងទម្រង់ "ពសព ឬពពសព"

  + មួយ < [ម] + [អួ] + [យ] → [យ] ជាសទ្ធចុងព្យាង្គ

  + នឹម < [ន] + [អឺ] + [ម] → [ម] ជាសទ្ធចុងព្យាង

  + ភ្ជួរ < [ភ្ជ] + [អ៊ួ] + [រ] → [រ] ជាសទ្ធចុងព្យាង

  + ស្វួង < [ស្វ] + [អ៊ួ] + [ង] → [ង] ជាសទ្ធចុងព្យាង

  + ស្រូវ < [ស្រ] + [អូ] + [វ] → [វ] ជាសទ្ធចុងព្យាង្គ

៤. ជ្រើសរើសពាក្យ ១ព្យាង្គដែលមានក្នុងអត្ថបទរួចបង្ហាញ

ក. សទ្ធដើមព្យាង្គ

- ទម្រង់ ពស. ជា < [ជ] + [អា] → [ជ] សទ្ធដើមព្យាង្គ

  លួ < [ល] + [អ៊ួ] → [ល] សទ្ធដើមព្យាង្គ

- ទម្រង់ ពពស. គ្នា < [គ្ន] + [អា] → [គ្ន] សទ្ធដើមព្យាង្គ

  ថ្ងៃ < [ថ្ង] + [អៃ] → [ថ្ង] សទ្ធដើមព្យាង្គ

- ទម្រង់ ពសព. រៀប < [រ] + [អៀ] + [ប] → [រ] សទ្ធដើមព្យាង្គ

  បួស < [ប] + [អួ] + [ស] → [ប] សទ្ធដើមព្យាង្គ

- ទម្រង់ ពពសព. ម្ចាស់ < [ម្ច] + [អា] + [ស] → [ម្ច] សទ្ធដើមព្យាង្គ

  ឈ្នួញ < [ឈ្ន] + [អួ] + [ញ] → [ឈ្ន] សទ្ធដើមព្យាង្គ

ខ. សទ្ធកណ្តាលព្យាង្គ

- ទម្រង់ ពសព ពេល < [ព] + [អេ] + [ល] → [អេ] សទ្ធកណ្តាលព្យាង្គ

  កួន < [ក] + [អួ] + [ន] → [អួ] សទ្ធកណ្តាលព្យាង្គ

- ទម្រង់ ពពសព ស្នែង < [ស្ន] + [អែ] + [ង] → [អែ] សទ្ធកណ្តាលព្យាង្គ

  ម្នាក់ < [ម្ន] + [អា] + [ក] → [អា] សទ្ធកណ្តាលព្យាង្គ

គ. សទ្ធចុងព្យាង្គ

- ទម្រង់ ពស តែ < [ត] + [អែ] → [អែ] សទ្ធចុងព្យាង្គ

  គេ < [គ] + [អេ] → [អេ] សទ្ធចុងព្យាង្គ

- ទម្រង់ ពពស គ្រូ < [គ្រ] + [អ៊ូ] → [អ៊ូ] សទ្ធចុងព្យាង្គ

  ស្រី < [ស្រ] + [អី] → [អី] សទ្ធចុងព្យាង្គ

- ទម្រង់ ពសព លោក < [ល] + [អោ] + [ក] → [ក] សទ្ធចុងព្យាង្គ

  មាន < [ម] + [អា] + [ន] → [ន] សទ្ធចុងព្យាង្គ

- ទម្រង់ ពពសព ក្នុង < [ក្ន] + [អុ] + [ង] → [ង] សទ្ធចុងព្យាង្គ

  ម្តាយ < [ម្ត] + [អា] + [យ] → [យ] សទ្ធចុងព្យាង្គ

- ឱ្យសិស្សកត់ចម្លើយដាក់ក្នុងសៀវភៅ ។

គ. ការវាយតម្លៃ

- តើព្យាង្គមានទម្រង់ដូចម្តេចខ្លះ ?

ចម្លើយ : ព្យាង្គមានទម្រង់ ៖

+ ពស : ដី កា ហែ

+ ពសព : ដេក ចែក កើត

+ ពពស : ខ្មៅ គ្នា ផ្កា

+ ពពសព : ក្រោក ផ្តេក ខ្លោច

- ចូរជ្រើសរើសព្យាង្គទោលពីក្នុងឃ្លា៖ "ធ្វើគុណទៅហើយ ត្រឡប់បានផលអាក្រក់វិញត្រូវទទួលយកការពិសោធដោយដៃពីរ"ដោយប្រាប់សទ្ទចុងព្យាង្គទម្រង់ ពស និងពពស។

ចម្លើយ :

+ សទ្ទចុងព្យាង្គទម្រង់ ពស : ការ ដៃ

+ សទ្ទចុងព្យាង្គទម្រង់ ពពស : ធ្វើ

- សំណួរស្រាវជ្រាវ

- ចូររកសទ្ទនៅក្នុងពាក្យ "គុណ ហើយ ដោយ"

ចម្លើយ : សទ្ទនៅក្នុងពាក្យ ៖

+ គុណ គឺ [គ]+[អ៊ុ]+ [ណ]

+ ហើយ គឺ [ហ]+[អើ]+ [យ]

+ ដោយ គឺ [ដ]+[អោ]+ [យ]



កិត្តិយស ឬស្នេហា

១. ភក្តិចំណង

- សិស្សរៀបរាប់លក្ខណៈអក្សរសិល្ប៍បរទេស បរិយាកាសសង្គមបារាំងបានត្រឹមត្រូវ
- សិស្សវិភាគតួអង្គរ៉ូឌ្រិច និងនាងស៊ីម៉ែនតាមរយៈខ្លឹមសារអត្ថបទបានច្បាស់លាស់
- បណ្តុះស្មារតីជ្រើសរើសយកអ្វីមួយដែលសមស្របតាមរយៈសកម្មភាពតួអង្គក្នុងអត្ថបទបានច្បាស់លាស់ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២១០-២១៥ ។

៣. ព័ត៌មានដំឆ្លួយ

- រឿងឡឺស៊ីដ (កិត្តិយស ឬស្នេហា)ដែលប្រែសម្រួលជាភាសាខ្មែរបែបកំណាព្យដោយលោកអានឃុនឆ្នាំ ១៧៥៤ ។
- ប្រវត្តិនិងស្នាដៃរបស់អ្នកនិពន្ធគ័រណី

លោក គ័រណី មានស្រុកកំណើតនៅរូអង់ កើតនៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៦០៦ ក្នុងគ្រួសារគហបតីមួយ។ លោករៀនសូត្រឈ្លៀសវៃ ហើយទទួលបានរង្វាន់ជាញឹកញាប់។ ឆ្នាំ ១៦២៤ លោកបានជាប់ជាមេធាវីបម្រុងរាជការ។ លោកបានការពារក្តីតែម្តងគត់ក្នុងជីវិតរបស់គាត់។ ឆ្នាំ ១៦២៥ លោកបានសរសេរកំណាព្យជាលើកដំបូង ហើយបោះពុម្ពផ្សាយនៅឆ្នាំ ១៦៣២។ ឆ្នាំ ១៦២៩-១៦៣០ លោកបានប្រគល់ហាសកថាទី ១របស់លោកឈ្មោះ មេលីត ទៅឱ្យក្រុមសិល្បករម៉ុងដ៊ឺរី ដែលដំណើរកាត់តាមរូអង់ទៅសម្តែងនៅប៉ារីស។

- ស្នាដៃរបស់លោកមាន ៖
  - រឿង អូរ៉ាស់ (ទារុណកថា) ១៦៤០ (Horace)
  - រឿង ស៊ីណា (ទារុណកថា) ១៦៤១ (Cinna)
  - រឿង សួយរ៉ែណា (ទារុណកថា) ១៦៧៤ (Surena)
- លោកគ័រណីទទួលមរណភាពនៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៦៨៤នៅទីក្រុងប៉ារីស។
- សម្រួលសំណួរទី ៤ ក្នុងសៀវភៅសិស្សទំព័រទី ២០៩ មកជា ចូរជ្រើសរើសពាក្យ ១ព្យាង្គរួចបង្ហាញសទ្ទដើមព្យាង្គ... ។

៤. ឈានាំមង្រៀន

ក. ត្រៀមអំណាន

- សិក្សាចំណងជើង
  - តើចំណងជើង "កិត្តិយស ឬស្នេហា"មានន័យដូចម្តេចចំពោះអ្នក ?

    ចម្លើយ : ជាជម្រើសយកបានតែមួយដែលខ្ញុំជ្រើសរើសយក "កិត្តិយស" ។
  - តើពាក្យ "កិត្តិយស"មានន័យដូចម្តេច ?

    ចម្លើយ : យសស័ក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង ។
  - តើពាក្យ "ស្នេហា"មានន័យដូចម្តេច ?

    ចម្លើយ : សេចក្តីស្រឡាញ់ពេញចិត្ត ។

- សិក្សារូបភាព
  - តើអ្នកឃើញអ្វីខ្លះក្នុងរូបភាពនេះ ?

    ចម្លើយ : រូបបុរសម្នាក់កំពុងកាន់ដាវហុចឱ្យស្ត្រីម្នាក់ ។ ពួកគេមានសម្លៀកបំពាក់រចៀបជាពួកអឺរ៉ុប ។
  - តើចំណងជើងនិងរូបភាពមានទំនាក់ទំនងគ្នាដូចម្តេចខ្លះ ?

    ចម្លើយ : អ្នកទាំងពីរសុទ្ធតែមានការជ្រើសរើសដូចគ្នារវាងកិត្តិយស ឬស្នេហា
  - សិក្សាពាក្យគន្លឹះ (មានក្នុងសៀវភៅសិស្ស)

ខ. អំណាន

- ឱ្យសិស្សអានខ្លឹមសារអភិវឌ្ឍន៍បំណិន
- ឱ្យសិស្សអានសំណួរក្នុងសៀវភៅ
- ឱ្យសិស្សអានអត្ថបទ (អានស្ងាត់ ឬអានឮតាមស្ថានភាពជាក់ស្តែង)

គ. ពង្រឹងអំណាន

- ឱ្យសិស្សឆ្លើយសំណួរត្រឹមរិះ

  ចម្លើយ :

១. អត្ថបទដកស្រង់នេះជាប្រភេទល្ខោននាដ្យកថា ដកស្រង់ពីរឿង "កិត្តិយស ឬស្នេហា" ។ ស្ថិតនៅក្នុងឈុតទី ៣ ឆាកទី ៤ ។ មានតួអង្គ រ៉ូឌ្រីក នាងស៊ីម៉ែន និងអិលវៀរ ។

២. អត្ថបទដកស្រង់នេះស្ថិតនៅក្នុងសង្គមបរិយាកាសដែលពោរពេញដោយការប្រកួតប្រជែង ដណ្តើមមុខមាត់ និងការសងសឹកគ្នានៃពួកអភិជន ។

៣. វិភាគតួអង្គ

ក. រ៉ូឌ្រីក

- គុណសម្បត្តិ
  + មានចិត្តក្លាហាន ជាកូនកត្តញ្ញូ ហ៊ានសងសឹកជូនឪពុក ។
  + មានការជ្រើសរើសត្រឹមត្រូវគឺស្តារកិត្តិយសគ្រួសារ ។
  + មានចិត្តស្មោះចំពោះស្នេហានិងប្រទេសជាតិ ។
  + អាចរក្សាតម្លៃខ្លួនឯងផងនិងទាក់ទាញសេចក្តីស្រឡាញ់ពីសំណាក់អ្នកដទៃ ។ ហ៊ានធ្វើ គឺហ៊ានសារភាព ។
  + អាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនបាន តែមិនលុបបំបាត់សេចក្តីស្នេហានោះទេ ។ នេះគឺជាលក្ខណៈមនុស្សទូទៅ ។
- គុណវិបត្តិ : មានចរិតឆេវឆាវដោះស្រាយបញ្ហាដោយអំពើហិង្សា ។

ខ. នាងស៊ីម៉ែន

- គុណសម្បត្តិ
  + ជានារីស្រស់ស្អាត ទាំងកាយ-ចិត្ត ហើយស្មោះត្រង់ចំពោះស្នេហា ។
  + ជាកូនកត្តញ្ញូ ស្រឡាញ់កិត្តិយស ហើយក៏ចេះបែងចែករវាងអំពើល្អ និងអំពើអាក្រក់របស់អ្នកដែលនៅជុំវិញនាង ។
  + មានការជ្រើសរើសគូកំណាន់ដោយពិនិត្យល្អិតល្អន់បំផុត ។
- គុណវិបត្តិ : ចិត្តទន់ចំពោះមុខសត្រូវ ។

៤. អត្ថបទនេះបានបង្ហាញថាជាលក្ខណៈអក្សរសិល្ប៍សកល គឺតួអង្គទាំងអស់សុទ្ធតែបង្ហាញពីចរិតលក្ខណៈរបស់មនុស្ស ទូទៅ ។ តួយ៉ាងរ៉ូឌ្រីកនិងនាងស៊ីម៉ែន ទោះបីមានទំនាក់ទំនងរហូតដល់ស្លាប់រស់ដើម្បីរក្សាកិត្តិយសគ្រួសារវៀងខ្លួន តែគេទាំងពីរ ក៏នៅតែមិនបំភ្លេចនូវសេចក្តីស្នេហាដែលគេធ្លាប់មានចំពោះគ្នាឡើយ ។

៥. សង្ខេបអត្ថបទឱ្យទៅជាពាក្យរាយ : រ៉ូឌ្រីកបានមកជួបនាងស៊ីម៉ែនដើម្បីសារភាពទោសដែលបានសម្លាប់ឪពុកនាង ដោយប្រគល់ជីវិតរបស់ខ្លួនឱ្យនាងស៊ីម៉ែន គឺសុខចិត្តស្លាប់ក្រោមដៃរបស់នាងផ្ទាល់ ។ នៅពេលឃើញរ៉ូឌ្រីកហុចដាវឱ្យនាង នាងស៊ីម៉ែនមិនទទួលទេ តែនាងថា នាងនៅតែសងសឹកចំពោះឃាតករដែលសម្លាប់ឪពុកនាង ព្រោះនាងក៏ស្រឡាញ់កិត្តិយសដែរ ។ ទង្វើនេះធ្វើឱ្យរ៉ូឌ្រីកឈឺចាប់រឹតតែខ្លាំងថែមទៀត ។

- ឱ្យសិស្សកត់ចម្លើយចូលក្នុងសៀវភៅ ។

ឃ. ការវាយតម្លៃ

- ចូរសង្ខេបអត្ថបទដកស្រង់ខាងលើ ។
- សំណួរ
  - តើទំនាស់រវាងរ៉ូឌ្រីកនិងនាងស៊ីម៉ែនបណ្តាលមកពីអ្វី ?

    ចម្លើយ : រ៉ូឌ្រីកមានទំនាស់ជាមួយនាងស៊ីម៉ែនបណ្តាលមកពី ព្រះរាជាជ្រើសរើសលោកដុង យែក ធ្វើជាព្រះរាជគ្រូ ។ លោកតូម៉ាសដែលជាឪពុករបស់នាងស៊ីម៉ែនមិនសប្បាយចិត្តចំពោះការប្រទានរបស់ព្រះរាជាក៏ទះកំផ្លៀងឪពុករ៉ូឌ្រីក (ដុងយែក) ។ ដោយសារកិត្តិយសគ្រួសារឪពុករ៉ូឌ្រីកបញ្ជាឱ្យរ៉ូឌ្រីកសងសឹកជំនួសខ្លួន ។ រ៉ូឌ្រីក មានការរារែកចិត្តយ៉ាងខ្លាំងចំពោះរឿងនេះព្រោះកិត្តិយសគ្រួសារក៏សំខាន់ រីឯសេចក្តីស្នេហារបស់ខ្លួនចំពោះនាងស៊ីម៉ែនក៏ខ្លាំង ។ ទីបំផុត រ៉ូឌ្រីកជ្រើសរើសកិត្តិយសជាកតព្វកិច្ចកូនប្រុសត្រូវរក្សា ហើយក៏សម្លាប់គ័រម៉ាស ។ ចំណែកនាងស៊ីម៉ែនក៏ជ្រើសរើសកិត្តិយស ដោយទាមទារឱ្យព្រះរាជាចាប់ឃាតករមកប្រហារជីវិត ។ នាងមិនព្រមរៀបការជាមួយឃាតករដែលសម្លាប់ឪពុកនាងដែរ ។
  - ចូរបង្ហាញនិន្នាការរបស់អ្នកនិពន្ធរឿងកិត្តិយស ឬស្នេហា ។

    ចម្លើយ : ស្នាដៃអក្សរសិល្ប៍ គឺជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកនិពន្ធ ។ តាមរយៈអត្ថបទដកស្រង់ខាងលើ យើងអាចសន្និដ្ឋានបានថា លោកគ័រណី កំពុងស្ថិតក្នុងសង្គមមួយដែលមានការច្រណែននិន្នាឈ្នានីសគ្នា ។ បដិបក្ខទាំងសងខាងមានចរិតមានះក្រអឺតក្រទមមិនខ្លាចអំណាចអ្នកដឹកនាំ (ព្រះរាជា) ។ លោកគ័រណី មានគំនិតរិះគន់ពួកគហបតីជំនាន់នោះ ដែលប្រកួតប្រជែងអំណាចគ្នាមិនគោរពអ្នកដឹកនាំ ។ ក្រោយពីគាត់បានទះកំផ្លៀងដុងយ៉ែក ព្រះរាជាបានបញ្ជាឱ្យគាត់ទៅសុំទោសដុងយ៉ែក ។ គ័រម៉ាសមិនត្រឹមតែមិនសុំទោសដុងយ៉ែកទេ គឺថែមទាំងដើរប្រាប់គេឯងថា គាត់មិនសុំទោសដាច់ខាត ។ ចរិតមានះនេះបានដុតកម្តៅគ្រួសាររ៉ូឌ្រីក គឺរ៉ូឌ្រីកផ្ទាល់ឈានដល់ការសម្លាប់គ័រម៉ាស ។ ដូច្នេះ រឿងវ៉ាវរីករាលដាលកាន់តែធំ រហូតធ្វើឱ្យតួសង្ឃរមួយតួនេះស្ថិតក្នុងជីវិតសោកសៅ ។ រួមមកទំនោរអ្នកនិពន្ធ គឺរិះគន់សង្គមមនុស្សសម័យនោះដែលមានចរិតអាស្មិមានះយកឈ្នះរៀងខ្លួន ទីបំផុតគឺអ្នកទទួលរងទុក្ខគឺតួនថៅរបស់ខ្លួនឯង ។



រឿង អាប៉ាកុងបាត់ហិបប្រាក់

១. ឥរិយាបថ

- រៀបរាប់បានអំពីកាលអាកាសតាមរយៈអត្ថបទស្តាប់បានច្បាស់លាស់
- វិភាគតួអង្គនិងរកឃើញគំនិតសំខាន់តាមរយៈអត្ថបទស្តាប់បានត្រឹមត្រូវ ។

២. សម្ភារបង្រៀន

- សៀវភៅសិស្សទំព័រទី ២១៦

៣. ព័ត៌មានដំឡូយ

ជីវប្រវត្តិនិងស្នាដៃរបស់អ្នកនិពន្ធ ម៉ូលីយ៉ែ (១៦២២-១៦៧៣) ម៉ូលីយ៉ែ ជាអ្នកនិពន្ធរឿងកំប្លែងម្នាក់យ៉ាងល្បីល្បាញនៅសម័យតន្តីបារាំង ។ ឈ្មោះពិតប្រាកដរបស់គាត់ គឺ សង់ បាប់ទីសប៉ូកីឡាំង (Jean Baptiste Poqualin) ។ គាត់កើតនៅទីក្រុងប៉ារីស ក្នុងត្រកូលអភិជនអ្នកមានមធ្យមម្នាក់ ។ នៅពេលរៀនចប់ថ្នាក់មធ្យមសិក្សាហើយ គាត់បានចូលរៀននៅមហាវិទ្យាល័យច្បាប់ ដែលអាចឱ្យគាត់ក្លាយទៅជាចៅក្រមបាន ។ ប៉ុន្តែម៉ូលីយ៉ែមិនពេញចិត្តវិជ្ជាជីវៈនេះទេ គាត់បែរជាចូលចិត្តលេងល្ខោនទៅវិញ ទោះបីសង្គមបារាំងសម័យនោះមិនសូវឱ្យតម្លៃក៏ដោយ ។ ម៉ូលីយ៉ែជាអ្នកនិពន្ធផង ដើរតួខ្លួនឯងផង ។ ចាប់តាំងពីឆ្នាំ ១៦៥៩ ទៅ ។ រឿងរបស់គាត់បានទទួលការកោតសរសើរយ៉ាងខ្លាំង ។

ស្នាដៃល្បីៗរបស់ម៉ូលីយ៉ែមានដូចតទៅ ៖

- រឿងពួកនារីថ្លៃថ្នូរជម្លើយ (Les Preoieuses Ridioules ១៦៥៩)
- រឿងសាលាស្ត្រី (Ecole des femmes ១៦៦២)
- រឿងតាកទុហ្វ (Tartuffe ១៦៦៤)
- រឿងដុងសុង (Don Juan ១៦៦៥)
- រឿងជនស្អប់សង្គម (Le Misanthrope ១៦៦៥)
- រឿងជនកំណាញ់ (L'Avare ១៦៦៨)
- រឿងគហបតីអភិជន (Le Bour geois gentilhomme ១៦៧០)
- រឿងជំងឺសតិអារម្មណ៍ (Le malade imaginaire ១៦៧៣)

នៅឆ្នាំ ១៦៧៣ ពេលសម្តែងតួអាកង់ (Argan)ម៉ូលីយ៉ែដឹងខ្លួនថាមិនស្រួលខ្លាំង ។ ពីរបីម៉ោងក្រោយមកគាត់ក៏ដាច់ខ្យល់ស្លាប់ទៅ ។

(ដកស្រង់ពីសៀវភៅអក្សរសិល្ប៍បរទេសកម្រិត ៣ថ្នាក់ទី ៩ ទី ១០ របស់ក្រសួងអប់រំបោះពុម្ពឆ្នាំ ១៩៨៧)

៤. លំនាំបង្រៀន

ក. ការត្រៀមស្តាប់

- សរសេរចំណងជើង "អាប៉ាកុងបាត់ហិបប្រាក់" ដាក់លើក្តារខៀនរួចសួរ ៖
  - តើចំណងជើងអត្ថបទនេះនិយាយពីអ្វី ?

  ចម្លើយ : បុរសម្នាក់ឈ្មោះអាប៉ាកុងបាត់ហិបប្រាក់ (លុយ)
- ឱ្យសិស្សមើលរូបភាពរួចសួរសំណួរ ៖
  - តើអ្នកបានឃើញរូបភាពអ្វីខ្លះ ?

  ចម្លើយ : មនុស្សស្លៀកពាក់បែបបរទេសកំពុងរកអ្វីមួយនៅក្នុងផ្ទះរបស់ខ្លួន ។
  - តើចំណងជើងអត្ថបទមានទាក់ទងទៅនឹងរូបភាពយ៉ាណាខ្លះ ?

  ចម្លើយ : អាចទាក់ទងគ្នា គឺបុរសក្នុងរូបភាពនោះប្រហែលជាអាប៉ាកុងដែលកំពុងរកហិបប្រាក់របស់គាត់ ។
- សិក្សាពាក្យគន្លឹះមួយចំនួន
  - កំណប់ (ន) : របស់ដែលកប់ទុក កំណប់ប្រាក់ កំណប់មាស ។
  - ឆ្នក់ (កិ) : លួចឈ្មក់ ។
    (គុ) : ដែលលួចឈ្មក់ ដែលរកស៊ីដោយឆក់ ។
  - តុលាការ (ន) : ការថ្លឹង ការស្ទង់ មិនឱ្យមានល្អៀង ឬអ្នកស្ទង់តម្រង់សេចក្តី ។
  - បាវ (ន) : ខ្ចុំប្រុសស្រី ឥឡូវគេហៅថា "ឈ្នួល" ឬអ្នកបម្រើជាដើម ។
- ឱ្យសិស្សអានសំណួរត្រិះរិះ
- អានអត្ថបទឱ្យសិស្សស្តាប់

សង្ខេបរឿង ជនកំណាញ់ (L'Avare 1668)

អាប៉ាកុង ជាជនកំណាញ់មានអាយុជាង ៦០ឆ្នាំ ។ គាត់មានកូន ២នាក់ កូនប្រុសឈ្មោះ ក្លេអង់ និងកូនស្រីឈ្មោះ អេលីស ។ ក្លេអង់បានស្រឡាញ់នាងម៉ារីយ៉ាន ជាយុវនារីក្រីក្រគ្មានទ្រព្យសម្បត្តិ ។ រីឯអេលីសបានស្រឡាញ់វ៉ាលែរដែលជាលេខាធិការរបស់ឪពុកខ្លួន ។ អាប៉ាកុងបានកប់មាស ១ម៉ឺនដុំនៅក្នុងសួនច្បាររបស់គាត់ ។ អាប៉ាកុងចង់រៀបការក្លេអង់ជាមួយស្ត្រីមេម៉ាយចាស់ម្នាក់ដែលជាអ្នកមានទ្រព្យសម្បត្តិសុកសម្ភ ។ រីឯអេលីសវិញ គាត់ចង់រៀបការឱ្យបុរសពោះម៉ាយម្នាក់ឈ្មោះ អង់សែលមី ដែលត្រូវជាឪពុករបស់វ៉ាលែរ ។ អង់សែលមីជាឪពុកបង្កើតរបស់វ៉ាលែរនិងម៉ារីយ៉ាន ដែលបានបែកគ្នាកាលពីមានវិបត្តិមួយកាលពី ១៦ឆ្នាំមុន ។ ពិធីរៀបមង្គលការពីរបានប្រារព្ធឡើងដោយអង់សែលមីជាអ្នកចេញប្រាក់សព្វគ្រប់ទាំងអស់ ។

ឈុតទី ៥ ឆាកទី ៧

ឡាហ្វែសជាខ្ចុំបម្រើរបស់អាប៉ាកុងបានលួចយកកំណប់មាសរបស់អាប៉ាកុងដែលកប់នៅក្នុងសួនច្បារ ។ អាប៉ាកុងបានដឹងថាកំណប់មាសរបស់ខ្លួនត្រូវគេលួចបាត់ក៏មានអារម្មណ៍រវើរវាយនិយាយតែម្នាក់ឯង ។...

អាប៉ាកុង : (ស្រែកថា ចោរ! ចោរ! តាំងពីក្នុងសួនមក នៅក្បាលគាត់គ្មានមួកទេ)

ចោរ! ចោរ! ចោរប្លន់ខ្ញុំហើយ! គេសម្លាប់ខ្ញុំហើយ! ជួយផង ម្ចាស់ថ្លៃអើយជួយផង! ខ្ញុំងាប់ហើយ! ខ្ញុំដាច់ខ្យល់ស្លាប់ហើយ គេកាត់កខ្ញុំ គេលួចលុយខ្ញុំហើយ អ្នកណាឯចេះ ? លោកអើយវាភ្លាយទៅជាឯម៉េចទៅហើយ ? វាទៅណាហើយ ? វាពួនឯណា ? ធ្វើម៉េចឯចេះខ្ញុំ ដើម្បីរកវាឱ្យឃើញ រត់ទៅខាងណា ? ហើយខាងណាដែលមិនត្រូវរត់ទៅ ?

វាមាននៅឯណោះទេ ? នៅឯណោះទេដឹង ? នរណានោះ ? ចាប់វា! ឱ្យលុយអញមកវិញ អាមេប្លន់ (ចាប់ដៃខ្លួនឯង)។ អ៎! ខ្ញុំទេតើ វិលខួរហើយខ្ញុំ ខ្ញុំលែងដឹងខ្លួនថានៅឯណាហើយ លែងដឹងថាខ្ញុំនេះ ជាអ្នកណាកំពុងធ្វើអីហើយ។ ព្រះម្ចាស់ថ្លៃអើយ កំណប់លុយដ៏កំសត់អើយ ម្ចាលលុយដ៏កំសត់ ម្ចាលមិត្តជាទីស្នេហា គេបំបែកខ្ញុំពីអ្នក អត់ពីអ្នកទៅ ខ្ញុំបាក់ចន្ទល់ហើយ លែងមានអ្នកលួងលោម អស់ក្តីសប្បាយ អស់ផ្លូវហើយខ្ញុំ ជីវិតខ្ញុំអស់ន័យហើយនៅលើលោកនេះ! ឱ! កំណប់លុយគ្មានអ្នកខ្ញុំរស់នៅតទៅទៀតមិនកើតទេ។ ឃើញទេ ខ្ញុំហេវហើយ ខ្ញុំដាច់ខ្យល់ហើយ ខ្ញុំស្លាប់ហើយ គេកប់ខ្ញុំហើយ។ តើលោកអ្នកណាអាចប្រស់ខ្ញុំឱ្យរស់នៅឡើងវិញដោយយកហិបលុយមកប្រគល់ឱ្យខ្ញុំវិញបាន ? ឬក៏គ្រាន់តែប្រាប់ថាអ្នកណាយកទៅក៏បានដែរ ? ម៉េច! អ្នកណាថាម៉េច ? អត់អ្នកណាឆ្លើយសោះ ច្បាស់ជាគេឆ្មក់ចំពេលដែលខ្ញុំកំពុងឈ្លោះជាមួយអាកូនចម្ងួតរបស់ខ្ញុំហើយមើលទៅ។ ទៅ ខ្ញុំទៅប្តឹងតុលាការសិន ឱ្យមកកោះសួរផ្ទះ។ ឱ្យសួរទាំងបាវស្រី បាវប្រុស កូនប្រុស កូនស្រី ហើយឱ្យសួរទាំងខ្ញុំថែមទៀត។ ចុះមនុស្សមកពីណាក៏ច្រើនម្ល៉េះ ខ្ញុំមើលទៅអ្នកណាក៏សង្ស័យថាសុទ្ធតែជាចោរទាំងអស់។ ហ្ន៎ អ្នកណានិយាយស្អីហ្នឹង ? និយាយពីចោរលួចលុយខ្ញុំឬ ? អ្នកណាធ្វើអីក្តុងក្តាំងខាងលើ ? អាចោរខ្ញុំនៅឯណោះឬ ? ខ្ញុំសូមអង្វរ បើដឹងថាអាចោរនោះឯណាសូមមេត្តាជួយប្រាប់ខ្ញុំផង។ តិចវាពួនក្នុងចំណោមលោកអ្នកទៅ ? ខ្ញុំសួរ គិតតែមើលមកខ្ញុំសើចទៅវិញ ថប់តែចូលដៃចូលជើងនឹងអាចោរនោះទេ។ ទៅលឿនឡើង ទៅហៅពួកគិញ កងខ្នាន់ ធ្នូ មេស្រុក ពួកចៅក្រម ពួកពេជ្ឈឃាតឱ្យមកជួយខ្ញុំផង។ ខ្ញុំចង់ប្តឹងឱ្យគេពួរកមនុស្សទាំងអស់ ហើយបើនៅតែរកលុយខ្ញុំមិនឃើញ ខ្ញុំនឹងចងពួរកទាំងខ្លួនឯងថែមទៀត។

(រៀបសំរួលចេញពីរឿងជនកំណាញ់របស់អ្នកនិពន្ធម៉ូលីយ៉ែ ១៦២២-១៦៧៣)

(សៀវភៅអក្សរសិល្ប៍បរទេសកម្រិតទី ៣ ថ្នាក់ទី ៩ ឆ្នាំ ១៩៨៧ របស់ក្រសួងអប់រំ)

- ឱ្យសិស្សឆ្លើយសំណួរ

ចម្លើយ

១. អត្ថបទនេះដកស្រង់ចេញពីរឿង "ជនកំណាញ់"។ ឈុតទី ៥ ឆាកទី ៧។

២. អ្នកនិពន្ធឈ្មោះម៉ូលីយ៉ែ (ជនជាតិបារាំង)។

៣. ឈ្មោះតួអង្គក្នុងរឿងនេះ

- អាប៉ាកុង ជាឪពុករបស់នាងអេលីសនិងក្លេអង់
- ក្លេអង់ ជាបងរបស់នាងអេលីស
- អេលីស ជាសង្សាររបស់វ៉ាលែនិងជាប្អូនរបស់ក្លេអង់
- នាងម៉ារីយ៉ាន សង្សារក្លេអង់និងជាកូនរបស់អង់សែលមី
- វ៉ាលែ ជាលេខាធិការរបស់អាប៉ាកុងនិងសង្សាររបស់នាងអេលីស
- អង់សែលមី ជាបុរសពេះម៉ាយមានទ្រព្យសម្បត្តិនិងមានបំណងរៀបការជាមួយនាងអេលីស ហើយក៏ជាឪពុករបស់វ៉ាលែនិងនាងម៉ារីយ៉ាន។
- ឡាហ្វ្លែស ជាអ្នកបម្រើរបស់អាប៉ាកុង។

៤. វិភាគតួអង្គអាប៉ាកុង

- គុណសម្បត្តិ : បានចិញ្ចឹមបីបាច់ថែរក្សាកូនរហូតពេញវ័យនិងបានរៀបចំទុកដាក់កូនទាំងពីរឱ្យមានគូស្រករ។
- គុណវិបត្តិ
  + ជាមនុស្សកំណាញ់ស្វិត
  + ស្រឡាញ់ប្រាក់ជាងជីវិត ជាងសុភមង្គលកូនប្រុសស្រី

+ គ្មានទំនុកចិត្តលើខ្លួនឯង និងអ្នកជុំវិញខ្លួន
+ មានគំនិតលោភលន់មិនស្កប់ស្កល់

- សរុបមក អាប៉ាកុងជាមនុស្សឆ្កួតនឹងប្រាក់និងកំណាញ់ចំពោះខ្លួនឯង ។

៥. មនុស្សកំណាញ់មានសកម្មភាពឆ្គេឆ្គាច្រាស់ច្រាល់ មានចរិតលក្ខណៈរវើរវាយ ភ្លេចខ្លួនចំពោះរឿងផ្សេងៗតែមិនភ្លេចសោះឡើយពីរឿងប្រាក់ ។ ព្រួយបារម្ភតែពីរឿងទ្រព្យសម្បត្តិ ខ្លាចគេសុំ ខ្លាចគេយក ខ្លាចគេលួច ខ្លាចបាត់ ... ។ មនុស្សកំណាញ់គ្មានសេចក្តីសុខ សេចក្តីស្ងប់ក្នុងចិត្តឡើយ ។
វិធីដែលអាចជួយកាត់បន្ថយភាពកំណាញ់របស់មនុស្សបានគឺការឱ្យជាប្រចាំ ។ "សប្បុរស តែងឈ្នះអសប្បុរសជានិច្ច" ។

• ឱ្យសិស្សកត់ចម្លើយដាក់ក្នុងសៀវភៅ ។

គ. ការវាយតម្លៃ

- តើអត្ថបទដកស្រង់នេះនិយាយពីអ្វី ?

ចម្លើយ : និយាយពីអាប៉ាកុងកំពុងរកហិបប្រាក់ ។

• សំណួរធ្វើដាក់ពិន្ទុ

- តាមរយៈអត្ថបទដកស្រង់ តើរឿងជនកំណាញ់ជារឿងពិត ឬរឿងប្រឌិត ?

ចម្លើយ : រឿងជនកំណាញ់ ជារឿងប្រឌិតកំប្លែងសើចរិះគន់ (ហាសកថា) ។ ប្រឌិតតួអង្គអាប៉ាកុង សម្រាប់តំណាងឱ្យពួកគហបតីបារាំងសម័យនោះដែលឆ្កួតនឹងលុយ ហើយនេះក៏ជាតថភាពជាក់ស្តែងមួយរបស់មនុស្សកំណាញ់ដែលមាននៅគ្រប់ប្រទេស គ្រប់សង្គម និងគ្រប់សម័យកាល ។

- ចូរអធិប្បាយពីទស្សនៈរបស់អាប៉ាកុងស្តីពីរឿង "លុយ" ។

ចម្លើយ : ចំពោះអាប៉ាកុង "លុយ"ជាមិត្ត ជាចន្ទល់ទ្រទ្រង់ជីវិតគាត់ឱ្យរស់នៅបានតទៅទៀត ។ គ្មានលុយគាត់ពិតជាស្លាប់ "...កំណប់លុយដ៏កំសត់អើយ ម្ចាលលុយដ៏កំសត់ ម្ចាលមិត្តជាទីស្នេហា គេបំបែកខ្ញុំពីអ្នកហើយ អត់ពីអ្នកទៅ ខ្ញុំបាក់ចន្ទល់ហើយ លែងមានអ្នកលួងលោម អស់ក្តីសប្បាយ អស់ផ្លូវហើយខ្ញុំ ជីវិតខ្ញុំអស់ន័យហើយនៅលើលោកនេះ! ឱកំណប់លុយ គ្មានអ្នកខ្ញុំរស់នៅតទៅទៀតមិនកើតទេ ..." ។
ដោយសារ "លុយ"អាប៉ាកុងបានរវើរវាយចាប់ដៃខ្លួនឯងថាជាចោរឱ្យតុលាការសួរចម្លើយខ្លួន ហើយបើរក "លុយ" មិនឃើញ គាត់នឹងឱ្យគេព្យួរកទាំងខ្លួនគាត់ទៀត ។ ដោយសារលុយគាត់បានសង្ឃឹមមនុស្សគ្រប់គ្នានិងសង្ឃឹមខ្លួនឯងដែរ ។

ដូច្នេះ ទស្សនៈរបស់អាប៉ាកុង គឺ "លុយ"មានតម្លៃជាងជីវិតរបស់គាត់ទៅទៀត ។

• កិច្ចការស្រាវជ្រាវ

- ចូរបំផុសឱ្យឃើញសិល្បវិធីរបស់ម៉ូលីយ៉ែក្នុងឯកវាទដ៏រស់រវើកនិងប្រកបដោយហាសភាពនេះ ។ (តាមរយៈអត្ថបទដកស្រង់)

ចម្លើយ : ម៉ូលីយ៉ែ បានប្រើឯកវាទវិធីដ៏រស់រវើក ។ តាមរយៈពាក្យសម្តី កាយវិការ និងអាកប្បកិរិយាបានបង្ហាញពីភាពកំប្លុកកំប្លែងដែលធ្វើឱ្យអ្នកស្តាប់ទប់សំណើចពុំបាន ។ ពេលដឹងថាបាត់លុយ អាប៉ាកុងស្រែកថា "ចោរ! ចោរ! ចោរប្លន់ខ្ញុំហើយ! ...វាទៅណាហើយ ? វាពួនឯណា ? ធ្វើម៉េចឯចេះខ្ញុំដើម្បីរកវាឱ្យឃើញ! រត់ទៅខាងណា ? ហើយខាងណាដែលមិនត្រូវរត់ទៅ ?..." ។ ដូច្នេះ ស្នើតែគ្រប់ពាក្យសម្តីរបស់តួអង្គ ធ្វើឱ្យយើងមើលឃើញសកម្មភាពប្រកបដោយសិល្បវិធីខ្ពស់ក្នុងការទាក់ទាញចិត្តអ្នកអាន អ្នកស្តាប់ អ្នកទស្សនាឱ្យជក់ចិត្តជិតអារម្មណ៍ ។



សម្របសម្រួលក្នុងពិធីសំខាន់ៗ

១. ភត្តុបំណង

- សិស្សកំណត់ចំណុចសំខាន់ៗនៃការនិយាយសម្របសម្រួលបានជាក់លាក់
- សិស្សរៀបចំផែនការសំខាន់ៗនៃប្រធានបទមកនិយាយសម្របសម្រួលដែលអ្នកចូលរួមអាចទទួលយកបាន
- សិស្សមានការយោគយល់អធ្យាស្រ័យគ្នានិងនិយាយឱ្យអ្នកដទៃចូលចិត្តនៅក្នុងពិធីផ្សេងៗតាមការណែនាំក្នុងសៀវភៅមេរៀន ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២១៧ដល់ ២១៩

៣. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- សរសេរចំណងជើងដាក់លើក្តារខៀន "ការនិយាយសម្របសម្រួលក្នុងពិធីសំខាន់ៗ"
- សួរសំណួរបំផុស
  - តើអ្នកសម្របសម្រួលប្រកបដោយប្រសិទ្ធភាពត្រូវមានសមត្ថភាពផ្នែកណាខ្លះ ?

    ចម្លើយ : អ្នកសម្របសម្រួលត្រូវមានសមត្ថភាពដូចខាងក្រោម

    + ផ្នែកចំណេះដឹង
    + ផ្នែកឥរិយាបថ
    + ភាពប៉ិនប្រសប់
  - តើអ្នកសម្របសម្រួលត្រូវមានបំណិនដូចម្តេចខ្លះ ?

    ចម្លើយ : អ្នកសម្របសម្រួលត្រូវមានបំណិនដូចខាងក្រោម

    + ការប្រើពាក្យសម្តី
    + ការប្រើប្រាស់ពេលវេលា
    + សំយោគគឺការប្រមូលខ្លឹមសារពិភាក្សា
    + សន្និដ្ឋាននិងសរុប

ខ. ការនិយាយ

- ឱ្យសិស្សអានមេរៀននៅក្នុងសៀវភៅសិស្ស
- ឱ្យសិស្សនិយាយសម្របសម្រួលក្នុងអង្គពិភាក្សាលើប្រធានបទស្តីពី "បញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅទីក្រុងភ្នំពេញ"
- គ្រូជ្រើសរើសសិស្សម្នាក់ដែលមានភាពវាងវៃ ក្លាហាន មានសមត្ថភាព មានចំណេះដឹងទូទៅទូលាយ ធ្វើជាអ្នកសម្របសម្រួលគំរូ ។ បន្ទាប់មក ជ្រើសសិស្សពីរក្រុម ក្រុមនីមួយៗមានសមាជិក ៣នាក់ ដែលក្នុងនោះមានប្រធានក្រុមម្នាក់និង

លេខាកត់ត្រាម្នាក់ ។ ក្រុមទី ១ និងក្រុមទី ២ ត្រូវអង្គុយប្រឈមមុខគ្នា (មុខតុសិស្សក្នុងថ្នាក់) ។ រីឯអ្នកសម្របសម្រួលអង្គុយ(ឬឈរ)នៅចន្លោះក្រុមទាំងពីរបែរមុខទៅរកតុសិស្សទាំងអស់ ។ គ្រូត្រូវកំណត់ពេលវេលាឱ្យជាក់លាក់គឺ ១ម៉ោង ។

- អ្នកសម្របសម្រួល : សួស្តីមិត្តទាំងអស់ ថ្ងៃនេះយើងជួបជុំគ្នាដើម្បីពិភាក្សាលើប្រធានបទមួយស្តីពី "បញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅទីក្រុងភ្នំពេញ" ។ យើងមានរយៈពេលត្រឹម ១ម៉ោងដើម្បីផ្លាស់ប្តូរយោបល់គ្នា ។ ខ្ញុំសូមជម្រាបថា ហេតុដែលយើងលើកប្រធានបទនេះមកពិភាក្សា ក្នុងគោលបំណងឱ្យមិត្តទាំងអស់បានដឹងនូវចំណុចសំខាន់ៗ ៣គឺ
  + ទិដ្ឋភាពទូទៅនៃគ្រោះថ្នាក់ចរាចរណ៍
  + មូលហេតុដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍
  + ដំណោះស្រាយបញ្ហាគ្រោះថ្នាក់ចរាចរណ៍

ដើម្បីកុំឱ្យខាតពេលយូរខ្ញុំសូមអញ្ជើញក្រុមទី ១ឡើងបញ្ចេញមតិនិងបន្ទាប់មកសូមអញ្ជើញក្រុមទី ២សូមគោរពអញ្ជើញ

- ក្រុមទី ១ : សូមអរគុណអ្នកសម្របសម្រួលដែលបានផ្តល់ឱកាសឱ្យក្រុមខ្ញុំឡើងបញ្ចេញមតិ ។ បើតាមការស្រាវជ្រាវរបស់ខ្ញុំអំពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសកម្ពុជាយើង គឺនៅឆ្នាំ ២០០៧មានជនរងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដល់ទៅ ២៧ ៤០៣នាក់ ។ ក្នុងនោះការស្លាប់មាន ១ ៥៤៥នាក់និងរបួសធ្ងន់ ៧ ១៥០នាក់ ។ ជាពិសេសនៅរាជធានីភ្នំពេញ មានបញ្ហាគ្រោះថ្នាក់ចរាចរណ៍ច្រើនជាងគេ ។
- ក្រុមទី ២ : បញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅរាជធានីភ្នំពេញ ជាញឹកញាប់គឺភាគច្រើនអ្នកបើកបរម៉ូតូ ពោលគឺមនុស្សនេះតែម្តងជាអ្នកបង្កឡើង ហើយធ្វើឱ្យអ្នកឯទៀតដែលនៅជុំវិញគាត់ទទួលរងគ្រោះថ្នាក់នេះដែរ ដូចករណីអ្នកបើកម៉ូតូម្នាក់មិនបានប្រើភ្លើងបើកបន្ទីនៅពេលព្រលប់ បើកទៅបុកលោកយាយម្នាក់អាយុ ៧០ឆ្នាំ ឱ្យដួលស្លាប់នៅនឹងកន្លែង ។ អ្នកខ្លះទៀត ទទួលទានសុរាច្រើនស្រវឹង រួចគាត់បើកបររថយន្តរេពេញផ្លូវ ទៅបុកម៉ូតូកង់បី-ម៉ូតូបុរសស្ត្រីប្រពន្ធនិងកូនឱ្យទទួលរងគ្រោះទាំងអស់គ្នាកាលពីខែមុន ។
- អ្នកសម្រួល : អរគុណណាចំពោះការបញ្ចេញមតិរបស់មិត្តទាំងអស់ យើងឃើញថាគ្រោះថ្នាក់ចរាចរណ៍កើតមានពិតមែនហើយយើងមើលឃើញទៀតថាការរងគ្រោះមិនមែនតែអ្នកបើកបរទេ គឺវាបង្កដល់អ្នកដទៃដែលគាត់មិនដឹងខ្លួនឯងថាមានគ្រោះថ្នាក់ផងដែរ ។ ខ្ញុំសូមអធ្យាស្រ័យ ខ្ញុំសូមបន្ថែមចំណុចមួយដែលខ្ញុំបានដឹងនោះគឺថា តាមទិន្នន័យគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជាឆ្នាំ ២០០៦ គេបានឃើញថាអ្នករងគ្រោះថ្នាក់ចរាចរណ៍ភាគច្រើនជាយុវវ័យដែលមានអាយុចាប់ពី ១៥ទៅ ២០ឆ្នាំ ប្រហែលជា ៤០% ។ ក្នុងនាមអ្នកសម្របសម្រួល ខ្ញុំសូមអញ្ជើញក្រុមទី ១បង្ហាញអង្គពិភាក្សាអំពីបុព្វហេតុដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍បន្ថែមទៀត ។
- ក្រុមទី ១ : អរគុណ! បញ្ហាគ្រោះថ្នាក់ចរាចរណ៍មានបុព្វហេតុច្រើន ដូចក្រុមទី ២បានលើក ២ចំណុច ហើយអំបាញ់មិញគឺការបើកម៉ូតូគ្មានភ្លើងបំភ្លឺនៅពេលយប់និងអ្នកបើកឡានទទួលទានគ្រឿងស្រវឹង ។ ខ្ញុំក៏អាចរកឃើញទៀតដែរ គឺការបើកបរប្រជែងគ្នា ប្រណាំងគ្នា មិនគោរពច្បាប់ចរាចរណ៍ មិនបានត្រួតពិនិត្យយានយន្តមុននឹងបើកបរ ដូចជាភ្លើងសញ្ញា ចង្កៀងមុខក្រោយ ហ្វ្រាំង កង់ឡាន ម៉ូតូជាដើម ។

- អ្នកសម្របសម្រួល : ខ្ញុំគិតថាក្រុមទី ១ដូចជាផ្តល់ព័ត៌មានពុំទាន់គ្រប់គ្រាន់ទេ គួរតែក្រុមទី ២ជួយបំពេញបន្ថែមទៀត។
- ក្រុមទី ២ : អរគុណ! ដែលបានផ្តល់កិត្តិយសឱ្យខ្ញុំផ្តល់យោបល់បន្ថែម ខ្ញុំក៏បានឃើញដែរ គឺការបើកបរលើសល្បឿនកំណត់ដូចជាច្បាប់ថាឱ្យបើកត្រឹមតែ ២០គីឡូម៉ែត្រក្នុងមួយម៉ោងនៅកំណាត់ផ្លូវមួយ តែគាត់បើកលើសដល់ទៅ ៤០គីឡូម៉ែត្រក្នុងមួយម៉ោង ជាហេតុធ្វើឱ្យប៉ះទង្គិចនិងអ្នកបើកបរផ្សេងទៀត ម្យ៉ាងទៀត ការមិនយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកក៏ជាហេតុនាំឱ្យប៉ះទង្គិចគ្នា ការបើកបរគេចពីប៉ូលីសពិន័យក៏មានគ្រោះថ្នាក់ដែរ។
- អ្នកសម្របសម្រួល : ខ្ញុំសូមគាំទ្រការបញ្ចេញមតិរបស់ក្រុមទី ២ ដើម្បីបំពេញបន្ថែម ខ្ញុំសូមបញ្ជាក់ពីមូលហេតុមួយទៀតដែលធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍ដែរនោះ គឺការប្រើប្រាស់ទូរស័ព្ទដៃក្នុងពេលធ្វើដំណើរលើម៉ូតូនិងបើកបង្ហោសទិស ហើយនៅមានមូលហេតុជាច្រើនទៀតដែលខ្ញុំពុំអាចជម្រាបអស់។ ក្នុងនាមអ្នកសម្របសម្រួលខ្ញុំសូមអញ្ជើញក្រុមទី ១ឡើងបញ្ចេញយោបល់ថា បើយើងបានឃើញអ្នករងរបួសដោយគ្រោះថ្នាក់ចរាចរណ៍នៅកន្លែងណាមួយ តើយើងជួយគាត់ដោយរបៀបណា ? សូមអញ្ជើញ! បន្ទាប់មកក្រុមទី ២។
- ក្រុមទី ១ : អរគុណ! ប្រសិនបើយើងជួយអ្នករងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ យើងត្រូវចេះពីវិធីសង្គ្រោះបឋម គឺត្រូវសង្កត់ផ្ទាល់លើមុខរបួស បើអាចធ្វើបានត្រូវប្រើស្បៃ កន្សែង ស្រោមដៃឆ្នាស្ងិច ឬស្រោមដៃស្អាតទ្រាប់ដៃ។ បន្ទាប់មក រុំសង្កត់លើមុខរបួសដោយស្បៃ ឬក្រណាត់ស្អាត ២ដុំ បើនៅតែមានឈាមហូរទៀតរុំថែមមួយជាន់ទៀតលើបង់ទី ១ដោយមិនបាច់យកបង់ទី ១ចេញទេ។ បើនៅតែមានឈាមហូរទៀត យើងត្រូវប្រើដៃ ឬម្រាមដៃចាប់ត្រង់ចំណុចសរសៃឈាមដែលនៅជិតនោះ ដើម្បីឃាត់ឈាមមិនឱ្យហូរតទៅទៀត។
- ក្រុមទី ២ : សម្រាប់ក្រុមខ្ញុំ ខ្ញុំបានដឹងអំពីការការពារឆ្នឹងបាក់ ក្នុងគ្រោះថ្នាក់ចរាចរណ៍ តាមបែបសង្គ្រោះបន្ទាន់គឺយើងត្រូវកំណត់ ឬរកកន្លែងបាក់ឆ្អឹងឱ្យឃើញដូចជាកន្លែងមានស្នាមជាំ ហើម កន្លែងរងរបួស ឈឺចាប់បំផុតនៅកន្លែងដែលប៉ះពាល់នៅពេលធ្វើចលនា ... ជាដើម គឺនៅពេលនោះយើងត្រូវឱ្យជនរងគ្រោះនៅឱ្យស្ងៀម បើឆ្អឹងដៃបាក់ យើងត្រូវដោះនាឡិកា ចិញ្ចៀន និងសម្លៀកបំពាក់ចេញ ដើម្បីកុំឱ្យហើមទាន់រួចប្រើបន្ទះដែក ឬឈើអបដៃរួចចងសំពត់ ឬក្រមាពាក់លើកដើម្បីជួយទ្រដៃ។ បើឆ្អឹងជើងបាក់ យើងត្រូវប្រើបន្ទះដែក ឬឈើអបជើងរួចចងសំពត់ ឬក្រមាដើម្បីជួយទ្រជើង។ រក្សាជនរងគ្រោះឱ្យនៅនឹង ហើយទ្រកន្លែងរបួសជាដើម។
- អ្នកសម្របសម្រួល : មិត្តទាំងអស់ពិតជាមានការយល់ដឹងច្រើនពីការជួយជនរងគ្រោះក្នុងពេលមានគ្រោះថ្នាក់ចរាចរណ៍។ ខ្ញុំសូមអធ្យាស្រ័យបើខ្ញុំបន្ថែមចំណុចខ្លះដែលទាក់ទងនឹងការបញ្ឈប់កុំឱ្យឈាមហូរ គឺចំណុចមិនគួរធ្វើគឺបើមានវត្ថុជាប់ក្នុងមុខរបួសគេមិនត្រូវសង្កត់ផ្ទាល់លើវត្ថុនោះទេ មិនត្រូវដកវត្ថុនោះចេញទេ មិនត្រូវប្រើប្រជាប់ឃាត់ឈាមឡើយ តែត្រូវសង្កត់ក្បែរវត្ថុនោះឱ្យជាប់ហើយធ្វើឱ្យបង់រុំដែលមានសុវត្ថិភាពល្អ។ ចំពោះការការពារឆ្អឹងបាក់វិញគឺគេមិនត្រូវច្របាច់សើរៗលើកន្លែងរបួស ឬពន្លាតជើងបាក់ឱ្យត្រង់ ឬរំកិលជនរងគ្រោះដោយគ្មានការជួយ ឬសុំឱ្យជនរងគ្រោះរំកិលដោយខ្លួនឯង ឬធ្វើចលនាសន្លាក់នៅពីលើនិងពីក្រោមកន្លែងបាក់ឆ្អឹងនោះទេ។ នៅវិធីជាច្រើនទៀតដែលត្រូវជួយជនរងគ្រោះ ជាពិសេសត្រូវទូរស័ព្ទហៅរថយន្តសង្គ្រោះជាបន្ទាន់។ តែដោយសារពេលវេលាកាន់តែខ្លីទៅហើយនោះខ្ញុំសូមអញ្ជើញក្រុមនីមួយៗឡើងបន្តបន្ទាប់គ្នាដើម្បីនិយាយពីអ្វីដែលថា តើត្រូវធ្វើដូចម្តេចដើម្បីឱ្យមានសុវត្ថិភាពក្នុងការធ្វើដំណើរតាមផ្លូវ ? សូមអញ្ជើញក្រុមទី ១

- ក្រុមទី ១ : ដើម្បីសុវត្ថិភាពក្នុងការធ្វើដំណើរតាមផ្លូវ យើងត្រូវគោរពច្បាប់ចរាចរណ៍ គោរពភ្លើងនិងផ្លាកសញ្ញាចរាចរណ៍ ចេះប្រើប្រាស់ផ្លូវ និងសិទ្ធិអាទិភាព។ ជាពិសេស ត្រូវមានសុជីវធម៌និងអធ្យាស្រ័យចំពោះគ្នាទៅវិញទៅមកក្នុងការបើកបរ។
- ក្រុមទី ២ : មតិរបស់ខ្ញុំក៏មិនខុសពីក្រុមទី ១ដែរ គឺដើម្បីសុវត្ថិភាពទាំងអស់គ្នា គឺអ្នកបើកបរយានយន្តត្រូវទទួលខុសត្រូវចំពោះការបើកបររបស់ខ្លួន ជាពិសេសពេលធ្វើដំណើរតាមម៉ូតូត្រូវពាក់មួកសុវត្ថិភាព។
- អ្នកសម្របសម្រួល : អរគុណណាស់ចំពោះការបកស្រាយរបស់ក្រុមទាំងពីរសុទ្ធតែមានបំណងល្អ! យើងទាំងអស់គ្នាបានដឹងហើយថាជីវិតមនុស្សពុំមានដាក់លក់តាមទីផ្សារទេ ដូច្នេះការធ្វើដំណើរទោះជិតក្តីឆ្ងាយក្តីត្រូវមានការប្រុងប្រយ័ត្នជានិច្ច ដើម្បីបញ្ចៀសគ្រោះថ្នាក់។ បញ្ហាគ្រោះថ្នាក់ចរាចរណ៍ បើកើតមានលើគ្រួសារណាហើយ គ្រួសារនោះនិងមានការព្រួយបារម្ភពីអាយុជីវិត ការខាតបង់ទ្រព្យសម្បត្តិលុយកាក់ ខាតបង់ពេលវេលា ហើយជួនកាលអាចបាត់បង់ជីវិត របួសពិការផងក៏មាន។ កិច្ចពិភាក្សារបស់យើងថ្ងៃនេះឃើញថាមានការផ្តល់ផ្សណាស់ ហើយសុទ្ធតែជាគតិល្អៗសម្រាប់យុវវ័យ ក៏ដូចជាគ្រួសារ សហគមន៍យើងទាំងអស់ឱ្យចៀសផុតពីគ្រោះថ្នាក់ចរាចរណ៍បាន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមទាំងពីរជាថ្មីម្តងទៀតដែលបានខិតខំស្រាវជ្រាវ យកការចេះដឹងរបស់ខ្លួនមកលាតបង្ហាញអង្គពិភាក្សាប្រកបដោយសកម្មភាពរស់រវើកប្រទាក់ក្រឡាគ្នាពីចំណុចមួយទៅចំណុចមួយទៀត។ សូមអរគុណមិត្តទាំងអស់ដែលបានចូលរួមនិងយកចិត្តទុកដាក់ស្តាប់កិច្ចពិភាក្សានេះតាំងពីដើមដល់ចប់។

សូមជូនពរអ្នកទាំងអស់គ្នាឱ្យសមប្រកបតែនិងសុខសុវត្ថិភាពគ្រប់ទិវារាត្រី! ។ អរគុណ! ជម្រាបលា!

(រៀបសម្រួលពីសៀវភៅការអប់រំសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់ក្រសួងអប់រំយុវជននិងកីឡាសម្រាប់គ្រូថ្នាក់ទី ៧-៨-៩ឆ្នាំ ២០០៧)

- ណែនាំសិស្សឱ្យចេះនិយាយសម្របសម្រួលដូចលំហាត់នេះចំពោះលំហាត់ទី ១និងទី ៣ ។

លំហាត់ទី ១ "បញ្ហាទឹកស្អាតនៅប្រទេសកម្ពុជា"

គម្រោងនិយាយ

១. ទិដ្ឋភាពទូទៅ

+ និយមន័យទឹកស្អាត
+ ទឹកដែលប្រជាជនភាគច្រើនបានប្រើជាប្រចាំ (ឧទាហរណ៍ ទឹកទន្លេ ទឹកស្ទឹង បឹង អូរ ព្រែក ត្រពាំង អណ្តូង ...)

២. ការបំពុលទឹក (កង្វក់ទឹក)

(ឧទាហរណ៍ ការបោះកាកសំណល់ ការបន្ទោបង់ ...)

៣. រួមគ្នាការពារទឹកឱ្យស្អាតជានិច្ច

៤. សូមការគាំទ្រពីអាជ្ញាធរ ឃុំសង្កាត់ ស្រុក ខេត្ត រដ្ឋាភិបាល ...

លំហាត់ទី ៣ "បញ្ហាទទួលយកវប្បធម៌បរទេសមួយចំនួនរបស់យុវវ័យសម័យបច្ចុប្បន្ន" ។

គម្រោងនិយាយ

១. ទិដ្ឋភាពទូទៅ

+ និយមន័យវប្បធម៌ វប្បធម៌បរទេស
+ ការរីកចម្រើននៃបច្ចេកវិទ្យា (វីដេអូ ហ្វេសប៊ុក អ៊ិនធឺណិត ...)
+ ពុំមានការទប់ស្កាត់

២. ការទទួលយកវប្បធម៌បរទេស

+ ព័ត៌មានថ្មី ទំនើប
+ ការស្លៀកពាក់ និយាយស្តី
+ ការរាំ ច្រៀង ល្បែងកំសាន្ត ...

៣. ការទប់ស្កាត់វប្បធម៌បរទេស

+ យុវវ័យ ខ្លួនឯង (ជួយខ្លួនឯង)
+ គ្រួសារ សាលារៀន សហគមន៍ សង្គម
+ មន្ត្រីពាក់ព័ន្ធ ...

៤. ខ្មែរនីយកម្មវប្បធម៌បរទេសឱ្យទៅជាវប្បធម៌ជាតិ : បុណ្យសង្ឃរ ឱ្យទៅជាបុណ្យដឹងគុណមាតាបិតា ... ។



បំពេញលិខិតផ្សេងៗ

១. វត្ថុបំណង

- ប្រាប់ពីទម្រង់លិខិតប្រគល់និងទទួល លិខិតលក់ទំនិញ ជីវប្រវត្តិសង្ខេប សេចក្តីប្រកាសអះអាងផ្ទាល់ខ្លួន លិខិតរាយការណ៍របស់អ្នកដំណើរតាមយន្តហោះ និងសាលាកប័ត្រចូល-ចេញរបស់អ្នកដំណើរតាមយន្តហោះបានត្រឹមត្រូវតាមរយៈអត្ថបទគំរូ ។
- បំពេញសំណុំលិខិតផ្សេងៗ ក្នុងជីវភាពប្រចាំថ្ងៃបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២២០ដល់ទំព័រទី ២២៤

៣. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន រួចសួរ :
  - តើអ្នកធ្លាប់បំពេញសំណុំលិខិតអ្វីខ្លះ ?

  ចម្លើយ : ពាក្យសុំចូលរៀន ពាក្យសុំធ្វើអត្តសញ្ញាណប័ណ្ណ ... ។
- ឱ្យសិស្សអានអត្ថបទគំរូ

១. លិខិតប្រគល់និងទទួល

- តើក្នុងលិខិតប្រគល់និងទទួលមានចំណុចសំខាន់អ្វីខ្លះ ?

ចម្លើយ : ចំណុចសំខាន់នៃលិខិតប្រគល់និងទទួលគឺ

+ កាលបរិច្ឆេទ
+ ឈ្មោះ
+ ហត្ថលេខានិងឈ្មោះអ្នកប្រគល់និងអ្នកទទួល
+ ហត្ថលេខានិងឈ្មោះសាក្សី

២. លិខិតលក់ (ទំនិញ)

- តើក្នុងលិខិតលក់ (ទំនិញ)មានចំណុចសំខាន់អ្វីខ្លះ ?

ចម្លើយ : បំពេញឈ្មោះ មុខរបរបច្ចុប្បន្ន ទីលំនៅបច្ចុប្បន្ន លេខទូរស័ព្ទ ទំនិញដែលត្រូវលក់ ឈ្មោះអ្នកទិញ ... និងការធានាខុសត្រូវរបស់អ្នកលក់ ជាពិសេសគឺ កាលបរិច្ឆេទធ្វើលិខិត ស្នាមមេដៃអ្នកលក់ អ្នកទិញ និងសាក្សី ។

៣. ជីវប្រវត្តិសង្ខេប គឺជីវប្រវត្តិផ្ទាល់ខ្លួន

- តើជីវប្រវត្តិផ្ទាល់ខ្លួនមានចំណុចសំខាន់អ្វីខ្លះ ?

ចម្លើយ : តាមត្រកូលនិងនាមខ្លួន

+ សញ្ជាតិ

+ ថ្ងៃខែឆ្នាំកំណើត
+ មុខរបរនិងអាសយដ្ឋានបច្ចុប្បន្ន
+ កម្រិតវប្បធម៌
+ កម្រិតជំនាញ ឬបទពិសោធន៍
+ ស្ថានភាពគ្រួសារ
+ អំពីឪពុកម្តាយបង្កើត
+ អំពីបងប្អូនបង្កើត
+ រៀបរាប់អំពីការសិក្សាផ្ទាល់ខ្លួន
+ កិច្ចសន្យាទទួលខុសត្រូវចំពោះមុខច្បាប់
+ កាលបរិច្ឆេទនិងហត្ថលេខាឈ្មោះសាមីខ្លួន
+ អាសយដ្ឋានសម្រាប់ទាក់ទង

៤. សេចក្តីប្រកាសអះអាងផ្ទាល់ខ្លួន

- តើសេចក្តីប្រកាសអះអាងផ្ទាល់ខ្លួនមានចំណុចសំខាន់អ្វីខ្លះ ?

ចម្លើយ :

+ ឈ្មោះ
+ ពាក្យធានាអះអាង
+ កាលបរិច្ឆេទ
+ ហត្ថលេខានិងឈ្មោះអ្នកអះអាង
+ សាក្សី ហត្ថលេខានិងឈ្មោះ

៥. លិខិតរាយការណ៍អីវ៉ាន់របស់អ្នកដំណើរតាមយន្តហោះ

- តើលិខិតរាយការណ៍របស់អ្នកដំណើរតាមយន្តហោះមានចំណុចសំខាន់អ្វីខ្លះ ?

ចម្លើយ : លិខិតនេះមានពីរផ្នែកគឺ ផ្នែកខាងមុខ និងផ្នែកខាងខ្នង ។

ក. ផ្នែកខាងមុខ ចែកជា ៥ចន្លោះសម្រាប់បំពេញនិងផ្តល់ព័ត៌មាន

- ចន្លោះទី ១គឺបំពេញក្នុងប្រអប់

+ នាមត្រកូល
+ នាមខ្លួន
+ ភេទ
+ ថ្ងៃខែឆ្នាំកំណើត
+ លេខលិខិតឆ្លងដែន
+ សញ្ជាតិ
+ មុខរបរ
+ លេខយន្តហោះ
+ មកពី/ចេញ

- ចន្លោះទី ២ ប្រើសញ្ញា (✓)

☐ មានឥវ៉ាន់រាយការណ៍ ☐ គ្មានឥវ៉ាន់រាយការណ៍

សំគាល់ : បើមានឥវ៉ាន់សូមរាយការណ៍នៅផ្នែកខាងខ្នង

- ចន្លោះទី ៣ អ្នកមានរូបិយបណ្ណបរទេស រូបិយវត្ថុយកតាមខ្លួនលើសពី 10 000US ប្រើសញ្ញា (✓)

☐ មាន ☐ គ្មាន

- ចន្លោះទី ៤ សរសេរបំពេញ (ខ្ញុំសូមបញ្ជាក់ថា ការរាយការណ៍លើលិខិតនេះពិតជាត្រឹមត្រូវមែន)

+ ហត្ថលេខា

+ កាលបរិច្ឆេទ

- ចន្លោះទី ៥ ព័ត៌មាន (បើសិនអ្នកមានចម្ងល់ សូមសាកសួរមន្ត្រីគយ)

ខ. ផ្នែកខាងខ្នង ចែកជា ៣ចន្លោះ

- ចន្លោះទី ១ កំណត់សំគាល់

- ចន្លោះទី ២ តារាងអីវ៉ាន់ត្រូវរាយការណ៍គឺ

+ រាយឈ្មោះសម្ភារៈ

+ បរិមាណ

+ តម្លៃ

+ សម្រាប់មន្ត្រីគយ

- ចន្លោះទី ៣ ចែកជាពីរផ្នែក

+ ខាងឆ្វេង : លេខបង្កាន់ដៃអីវ៉ាន់និងកាលបរិច្ឆេទ

+ ខាងស្តាំ : កាលបរិច្ឆេទនិងឈ្មោះមន្ត្រីគយ រដ្ឋាករ

៦. សាលាកបត្រចូល-ចេញរបស់អ្នកដំណើរតាមយន្តហោះ

តើសលាកប័ត្រចូល-ចេញរបស់អ្នកដំណើរតាមយន្តហោះមានចំណុចសំខាន់អ្វីខ្លះ ?

ចម្លើយ : សាលាកប័ត្រនេះមាន ៤ផ្នែក គឺផ្នែកទី ១និងទី ៤ ផ្នែកទី ២និងទី ៣

- សាលាកប័ត្រនេះបត់ជាពីរផ្តត់ដែលផ្នែកទី ១គឺឈ្មោះប្រទេស និងផ្នែកទី ៤ជាកំណត់សំគាល់ដែលយើងមិនចាំបាច់បំពេញអ្វីទាំងអស់ ។

- ផ្នែកទី ២ គឺសាលកប័ត្រចូលដែលយើងត្រូវបំពេញ

+ នាមត្រកូល

+ នាមខ្លួន

+ កន្លែងកំណើត ភេទ (✓)

+ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ

+ លិខិតឆ្លងដែន

+ មធ្យោបាយធ្វើដំណើរ លេខយន្តហោះ នាវា រថយន្ត រថភ្លើង

+ មកពី

+ ប្រភេទ/លេខទិដ្ឋាការ កន្លែងផ្តល់

+ បំណងនៃការធ្វើដំណើរយៈពេលស្នាក់នៅ
+ អាសយដ្ឋាននៅកម្ពុជា ហត្ថលេខា(អ្នកដំណើរ)

- ផ្នែកទី ៣ សាលាកប័ត្រចេញ ដែលយើងត្រូវបំពេញ
  + នាមត្រកូល
  + នាមខ្លួន
  + កន្លែងកំណើត ភេទ
  + ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ
  + លិខិតឆ្លងដែន
  + មធ្យោបាយធ្វើដំណើរ យន្តហោះលេខ នាវា រថយន្ត រថភ្លើង
  + ឆ្ពោះទៅកាន់
  + ប្រភេទ/លេខទិដ្ឋាការ ថ្ងៃចេញដំណើរ
    សម្រាប់ពលរដ្ឋខ្មែរប៉ុណ្ណោះ
  + រយៈពេលស្នាក់នៅក្រៅប្រទេស
  + ប្រទេសស្នាក់នៅចុងក្រោយ
  + អន្តោប្រវេសន៍ ទេសចរណ៍/សួរសុខទុក្ខបងប្អូន ហត្ថលេខា(អ្នកកាន់សាលាកប័ត្រ)
    ផ្លូវការ ជំនួញ
    សិក្សា ធ្វើការ
    សម្រាប់សមត្ថកិច្ច

ខ. ការអនុវត្ត

ត្រូវឱ្យសិស្សចម្លងលិខិតម្តងមួយៗដាក់ក្នុងសៀវភៅរបស់សិស្ស រួចណែនាំបំពេញឱ្យបានត្រឹមត្រូវគ្រប់ចំណុច ។

គ. ការវាយតម្លៃ

- តើការសិក្សាអំពីការបំពេញលិខិតផ្សេងៗមានប្រយោជន៍សម្រាប់អ្នកឬទេ ?

  ចម្លើយ : មានប្រយោជន៍ណាស់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។

- នៅក្នុងលិខិតប្រគល់និងទទួល លិខិតលក់/ទំនិញ ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសអះអាងផ្ទាល់ខ្លួនសុទ្ធតែមានសាក្សី ។ តើសាក្សីមានប្រយោជន៍ ឬទេ ? តើត្រូវជ្រើសរើសសាក្សីបែបណា ?

  ចម្លើយ : សាក្សីជាមនុស្សមានប្រយោជន៍សម្រាប់ជួយជឿជាក់នូវអ្វីដែលយើងបានធ្វើក្នុងលិខិត ដើម្បីការពារហេតុការណ៍ដែលកើតឡើងជាយថាហេតុនាថ្ងៃមុខ ។ មនុស្សដែលត្រូវយកធ្វើជាសាក្សីជា

  + មនុស្សស្មោះត្រង់
  + មនុស្សដែលគេគោរព
  + ចាស់ទុំ បងប្អូន សាច់ញាតិ អ្នកជិតខាង ជាពិសេសមនុស្សដែលយើងស្គាល់ប្រវត្តិច្បាស់លាស់ ។



សុទិដ្ឋិនិយម

ការយល់ឃើញប្រសើរសុខស្រួល ការប្រកាន់យកតែអំពើល្អសុចរិត ដែលជាមាគ៌ានាំទៅរកសេចក្តីសុខចម្រើន ឬ ជាសេចក្តីសង្ឃឹមទៅលើកិច្ចការទាំងឡាយឆ្ពោះទៅរកតែអំពើល្អប្រសើរ គឺជុសចេញពីសុទិដ្ឋិនិយម។ អ្នកដែលប្រកបទៅដោយសុទិដ្ឋិនិយមតែងមានសេចក្តីសង្ឃឹមនិងទទួលជោគជ័យក្នុងរាកជីវិត។ ដូច្នេះមនុស្សគ្រប់រូប គប្បីប្រកាន់ខ្ជាប់នូវសុទិដ្ឋិនិយមដើម្បីឱ្យមានសុភង្គលក្នុងជីវិត។

មេរៀននេះ អ្នកនឹងបានសិក្សាអំពីគំនិតសុទិដ្ឋិនិយមមួយចំនួន អំពីសំយោគគំនិត លក្ខណៈអក្សរសិល្ប៍ ប្រភេទអក្សរសិល្ប៍ ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា តួអង្គ អ្នកនិពន្ធ កាលអាកាស កាលកំណត់តែង តម្លៃអប់រំ សង្គមបរិយាកាស ខ្លឹមសារអត្ថបទ សូរព្យាង្គ និងសំណេររបាយការណ៍។

សកម្មភាពបង្រៀន	រយៈពេល		លេខទំព័រ	
	ទិវាសាស្ត្រ	ទិវាសាស្ត្រសង្គម	សៀវភៅគ្រូ	សៀវភៅសិស្ស
• ការណែនាំមេរៀន	.....	.....	២២៧	២២៥
• អំណានទី ១ : រឿងគ្រូបង្រៀនស្រុកស្រែ	៣ម៉ោង	៤ម៉ោង	២២៨-២៣៥	២២៦
• ការនិយាយ : ការសំយោគគំនិត	០ម៉ោង	២ម៉ោង	២៣៦-២៣៨	២៣៥
• អំណានទី ២ : រឿងឪពុកក្មេករើសកួនប្រសា	២ម៉ោង	៤ម៉ោង	២៣៩-២៤១	២៣៧
• វេយ្យាករណ៍ : លក្ខណៈរបស់ព្យាង្គ	២ម៉ោង	២ម៉ោង	២៤២-២៤៥	២៤៣
• សំណេរ : របាយការណ៍	២ម៉ោង	៣ម៉ោង	២៤៦-២៥២	២៤៥

១. សិក្សាចំណងជើងមេរៀន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ១០ ទំព័រទី ២២៥ បន្ទាប់មកគ្រូសរសេរចំណងជើងមេរៀន "សុទិដ្ឋិនិយម" ដាក់លើក្តារខៀន រួចសួរ ៖
  - តើ "សុទិដ្ឋិនិយម" មានន័យដូចម្តេច ?

    ចម្លើយ : អាស្រ័យលើសិស្ស។
  - តើអំពើអ្វីខ្លះ ដែលគេចាត់ទុកថាជាអំពើ "សុទិដ្ឋិនិយម" ?

    ចម្លើយ : អាស្រ័យលើសិស្ស។

២. សិក្សាលើរូបតាង

- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ២២៥ រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស។
  - តើរូបភាពនេះ ចង់និយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស។

រឿង គ្រូបង្រៀនស្រុកស្រែ

១. វត្ថុបំណង

- បង្ហាញលក្ខណៈជាតិ លក្ខណៈមនុស្ស និងលក្ខណៈសង្គមនៃអក្សរសិល្ប៍ក្នុងរឿងគ្រូបង្រៀនស្រុកស្រែបានត្រឹមត្រូវ
- ប្រាប់ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា តម្លៃអប់រំ និងកាលអាកាសនៃរឿងគ្រូបង្រៀនស្រុកស្រែបានត្រឹមត្រូវ
- បកស្រាយពីសង្គមបរិយាកាសនៃរឿងគ្រូបង្រៀនស្រុកស្រែបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២២៦-២៣៤
- ឯកសារ រឿងគ្រូបង្រៀនស្រុកស្រែរបស់លោក អ៊ឹម ថុក ឆ្នាំ ១៩៥៧ ។

៣. ពត៌មានជំនួយ

ដោយក្នុងសៀវភៅសិស្សពុំមានលទ្ធភាពសរសេរអត្ថបទរឿងគ្រូបង្រៀនស្រុកស្រែទាំងមូលបាន ដូច្នេះសូមលោកគ្រូអ្នកគ្រូ រកឯកសារ រឿងគ្រូបង្រៀនស្រុកស្រែរបស់លោក អ៊ឹម ថុក ឆ្នាំ ១៩៥៧ ដើម្បីប្រើប្រាស់ជាជំនួយដល់ការឆ្លើយនិងសំណួររបស់សិស្ស ។

៤. ដំណាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ១០ ទំព័រទី ២២៦ បន្ទាប់មកគ្រូសរសេរចំណងជើងអំណាន "រឿងគ្រូបង្រៀនស្រុកស្រែ" ដាក់លើក្តារខៀន រួចសួរ ៖
  - តើអ្នកធ្លាប់បានអានរឿងគ្រូបង្រៀនស្រុកស្រែដែរ ឬទេ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើរឿង គ្រូបង្រៀនស្រុកស្រែជាស្នាដៃរបស់អ្នកនិពន្ធណា ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ចូរអ្នកសាកល្បងនិទានមើល ។

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូធ្វើការបូកសរុបគំនិតរបស់សិស្ស ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ២២៦ រួចសួរ
  - តើអ្នកឃើញអ្វីខ្លះ នៅក្នុងរូបភាពនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស
  - តើរូបភាពនេះ ចង់និយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស

- គ្រូសួរសំណួរឱ្យសិស្សប៉ាន់ស្មានខ្លឹមសារអត្ថបទ " រឿងគ្រូបង្រៀនស្រុកស្រែ " តើរឿងនេះ មានខ្លឹមសារដូចម្តេច ? សិស្សឆ្លើយតាមការយល់ឃើញរបស់ពួកគេ។ គ្រូសរសេរចម្លើយប៉ាន់ស្មានរបស់សិស្សដាក់លើក្តារខៀន ដើម្បីទុកផ្ទៀងផ្ទាត់ ។
- គ្រូឱ្យសិស្សរកពាក្យពិបាកនៅក្នុងអត្ថបទ រួចសរសេរពាក្យទាំងនោះនៅលើក្តារខៀន
- គ្រូឱ្យសិស្សអានការពន្យល់ពាក្យពិបាកទាំងនោះ នៅក្នុងសៀវភៅសិស្សទំព័រទី ២២៦-២២៧

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារត្រង់ចំណុច ខ អភិវឌ្ឍន៍បំណិនក្នុងស. ស. ទំព័រទី ២២៧ រួចសួរសំណួរដើម្បីទាញបម្រុងប្រយ័ត្នសិស្ស ។
  - តើនៅក្នុងអត្ថបទនេះគេត្រូវ ឱ្យអ្នកយល់ដឹងអំពីអ្វីខ្លះ ?

    ចម្លើយ : តួអង្គ លក្ខណៈអក្សរសិល្ប៍ ប្រភេទអក្សរសិល្ប៍ ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា កាលអាកាស សង្គមបរិយាកាស តម្លៃអប់រំ និងខ្លឹមសាររឿង) ។
- គ្រូឱ្យសិស្សអានសំណួរក្នុង ទំព័រទី ២៣៤រួចសួរសំណួរបញ្ជាក់ការចាប់អារម្មណ៍របស់សិស្ស ។
  - តើសំណួរទាំងអស់មានប៉ុន្មាន ? តើសំណួរនីមួយៗ ផ្តោតសំខាន់ទៅលើអ្វីខ្លះ ?
- គ្រូឱ្យសិស្សអានអត្ថបទក្នុងស. ស. ទំព័រទី ២២៧ ។

គ. ការពង្រឹងអំណាន

- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលម្អិតនៃអត្ថបទទាំងមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបាន លោក / អ្នកគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
  - តើពូព្រឿងនិងបងហាមរស់នៅឯណា ? តើពួកគាត់រស់នៅក្នុងលំនៅឋានដូចម្តេច ?

    ចម្លើយ : នៅភូមិគ ។ ពួកគាត់រស់នៅក្នុងផ្ទះមួយមានបណ្តោយប្រវែង ១០ម. ទទឹង ៥ម. បែងចែកជាពីរល្វែងនៅខាងក្រោមល្វែងខាងជើងមានផ្ទះបាយមួយ ហើយជាប់ផ្ទះបាយនេះមានទ្រុងជ្រូក ។
  - ចូររៀបរាប់ពីស្ថានភាពរបស់ពូព្រឿង ។

    ចម្លើយ : ពូព្រឿងចំណាស់ជាប់ ៥០ឆ្នាំ ភ្នែកគាត់ឈឺមើលអ្វីមិនឆ្ងាយ ។ រោគស្តឹកបានរួមរឹតគាត់ ឃាត់គាត់មិនឱ្យដើរកសុីក្រៅផ្ទះ ។ គាត់នៅចាំផ្ទះមើលថែទាំងកូនតូចៗបួននាក់ ។ គាត់មិនមែនជាអ្នកទម្រន់ដេកស្ងៀមឡើយ ។ នៅផ្ទះគាត់ឆ្លៀតដាំអំពៅ ស្លឹកត្រៃ ដំឡូងឈើ ចិញ្ចឹមជ្រូកពីរដំប និងមាន់បួនដប់សំបុក ... ។
  - ចូររៀបរាប់ពីស្ថានភាពរបស់បងហាម ។

    ចម្លើយ : បង ហាម មានអាយុ ៤០ឆ្នាំ ។ គាត់មានមាឌធំដំបង គាត់ជាទាហានជើងក្រហមចាស់ ។ គាត់ឈប់ធ្វើទាហានតាំងពីឆ្នាំ ១៩៤០ ហើយបានធ្វើកូនឆ្មាមុីន តូចក្នុងត្រាវ៉ូដែរ គាត់ធ្វើជាប៉ូរ៉ាល់ត្រួតថ្កល់ក្បែរផ្ទះគាត់ជាប់ជិតប្រាំឆ្នាំហើយ ។ គាត់បានឈប់ធ្វើនាមុីន ព្រោះគាត់បានប្រកែកនឹងមេការបារាំងដែលបានបន្ទោសគាត់មិនសមហេតុមិនសមផល ។ កាលនៅពេលទាមទារមតស៊ូដេញបារាំង បងហាមបានធ្វើជីវពល ។ ដោយធ្លាប់បានធ្វើទាហាន ជើងក្រហមគាត់បានឆាប់ចេះមួយពីរ ឆ្ងេងស្តាំ ត្រឡប់ក្រោយ ។ ដូច្នេះ គេចាត់តាំងជាមេកងជីវពល ។ ក្នុងខណៈនោះដូចអ្នកភូមិភាគច្រើន គាត់បានខ្វីលុយគេកាត់ខោ

អាវគគីរ ស្បែកជើងឃ្លុប និងទិញកាំភ្លើងឈើមួយ។ ស្រុកបានសន្តិភាពគាត់ក៏បានច្បាប់ទទួលកាន់កាំភ្លើងមួយពីសាលាស្រុកដើម្បីការពារភូមិគាត់។

- ចូរវៀបរាប់ពីស្ថានភាពរបស់អ្នកសន។

ចម្លើយ : អ្នក សន ជាប្រពន្ធរបស់បងហាម គាត់ជានារីមួយរូបឆ្នើមក្នុងការរកស៊ី។ ក្រៅពីធ្វើស្រែ គាត់ក៏បានឆ្លៀតលក់ទៀត។ រាល់ព្រឹកគាត់បានក្រោកពីមាន់រងាវ ផ្ទុកអង្ករដាក់ឡានយកទៅលក់ឯចម្ការទាល់ពេលត្រង់ជាក់ បានមកផ្ទះវិញ។ រាល់រសៀលម៉ោងពីរ គាត់បានទៅអុំស្មៅអង្ករ នៅម៉ាស៊ីនស្រូវខាងកើតថ្ពល់ទល់ព្រលប់មើលគ្នា មិនស្គាល់ទើបមកផ្ទះ។

- តើអ្នកណាមករកបងហាម ? តើពួកគេ មករកបងហាមដើម្បីអ្វី ?

ចម្លើយ : ប៉ូលីសមុយនិងថីដោយ។ ពួកគេមករកបងហាម ដើម្បីចាប់ខ្លួនគាត់។

- តើបងហាមធ្វើដូចម្តេចនៅពេលគេរកចាប់ខ្លួន ?

ចម្លើយ : គេចខ្លួន។

- តើនៅពេលអាចារ្យសមជួនបងហាមគេចខ្លួន ពេលយប់បានជួបនឹងអ្នកណា ?

ចម្លើយ : អន្ទិតឡឹង។

- តើបងហាមបានសួរអន្ទិតឡឹងដូចម្តេច ?

ចម្លើយ : ម៉េចអ្នកឡឹងមានផ្លូវទេ ភូមិឫស្សី បងប្អូនយើងសុខសប្បាយទេ !

- តើអន្ទិតឡឹងបានឆ្លើយដូចម្តេច ?

ចម្លើយ : សុខតែមិនសប្បាយទេ ដូចលោកបងឃើញស្រាប់ហើយគ្នាក្រណាស់ សព្វថ្ងៃនេះគ្មានបាយសុទ្ធស៊ីទេ គ្នាស៊ីបាយលាយពោត។

- តើអាចារ្យសមបានសួរបងហាមដូចម្តេច ?

ចម្លើយ : មើហ៎ហាមឯងបាននិយាយថាភូមិឫស្សីបានបើកភ្នែកខ្លួន តើមានអ្វីខ្លះ ខ្ញុំនៅជិតភូមិនេះដែរតែដូចជា វាមិនឃើញមានអ្វីខុសគេ។

- តើបងហាមបានឆ្លើយដូចម្តេច ?

ចម្លើយ : លោកបងអាចារ្យមិនដែលទៅបានជាអីចឹង។ កាលពីមុនខ្ញុំ និងប្អូនម៉ៅព្រមទាំងគ្រូៗបួនប្រាំនាក់ ទៀតបានជិះកង់លើភ្លឺទៅភូមិនោះ។ អ្នកស្រុកហៅមហាក្របានទទួលយើងដូចស្គាល់គ្នាប៉ុន្មានឆ្នាំមកហើយអីចឹង។ គេនិយាយប្រាប់យើងគ្រប់។ គេមិនដែលស្គាល់នាម៉ឺនមកភូមិគេទេ។ រាល់ឆ្នាំគេមានរឿងតែជាមួយសៃវៀនបឹង។ បងអាចារ្យដឹងទេ មេសៃវៀនបឹងបានចាត់អ្នកលេងប៉ាវកេបឹងឱ្យមក លើកមកកាប់ទ្រូ លបអ្នកស្រុក។ ថៅកែបឹងមានអ្នកលេងកាប់ៗចាក់ៗសម្លុតអ្នកស្រុកដែលដាក់ទ្រូ ដាក់លបបន្តិចបន្តួចគ្រាន់នឹងចិញ្ចឹមឆ្នាំង។ ថៅកែបឹងរំលោភអស្ចារ្យហើយ គេបានប្រកាន់ថាបឹងនេះ មានព្រំត្រឹមទឹកឡើងរហូតដល់មាត់ភូមិក្នុងស្រែ អ្នកស្រុក ... ។ រាល់ឆ្នាំអ្នកភូមិត្រូវមេសៃវៀនធ្វើបាប ហើយអ្នកលេងបឹងនោះកាចសាហាវមានអំណាចអស្ចារ្យ គេអាចសម្លាប់អ្នកភូមិបានគ្មានទោស។ គេបង្វែងដានបានទាំងអស់។ ថៅកែគេបានស្គាល់អស់លោកនាម៉ឺននៅខេត្តស្រុកស្រែច ... ។)

- តើបងហាមមានបកស្រាយដូចម្តេច ក្នុងការដោះទុក្ខកែប្រែការរស់នៅប្រជាជន ?

ចម្លើយ : ... ការដោះទុក្ខកែប្រែការរស់នៅប្រជាជនយើងគ្រប់គ្នា ជាការពិបាក ជាការយូរមិនឆាប់ដូចមាត់ទេ ព្រោះមនុស្សធ្វើមិនមែនទេវតាឯណាធ្វើជួសយើងទេ ... ។ យើងត្រូវអប់រំខ្លួនយើង និងអប់រំអ្នកភូមិ ឱ្យយល់ជឿលើកកម្លាំងខ្លួន ហើយឱ្យដឹងថាទាល់តែយើងរួមកម្លាំងសាមគ្គីបានយើងអាចទប់ទល់នឹងអ្នកលេងដៃជើងថៅកែមេសៃវៀនបាន។ នៅស្រុកស្រែជាមួយយើង វាអាងអ្នកលេង នៅទីក្រុងវាអាងទឹកប្រាក់ ... ។ បើដូច្នេះ បើយើងចង់រួចខ្លួន ចង់បានស្រួល ចង់បានយុត្តិធម៌ ទាល់តែអ្នកភូមិនេះចេះបម្រះកែប្រែខ្លួនឡើង។ ការរៀបចំភូមិឃុំ ជាការចាំបាច់ មុនគេបង្អស់ចំពោះក្រុមយើង។ ដោយហេតុនេះបានជាខ្ញុំយល់ឃើញថាដល់រួចរាល់ ឆ្នាំក្រោយៗនេះ យើងត្រូវតែឱ្យមានសិទ្ធិប្រជាជនរើសនាយកឃុំ ... ។ តែនាយកឃុំយើងមិនមែនតែមានភារៈដើរជិះជាន់សង្កត់សង្កិនរាស្ត្រដូចអាណានិគមនិយមបារាំងបង្កបង្កើតនោះទេ។ នាយកឃុំយើងជាតំណាងប្រជាជនភូមិ ហើយមានភារៈកែប្រែអ្នកភូមិពីក្តីវេទនាគ្មានអាវពាក់ ពីអំពើចោរកម្មពីការគំរាមកំហែង។

- តើបងហាមមានគោលការណ៍ដូចម្តេចខ្លះ ក្នុងការដោះទុក្ខកែប្រែការរស់នៅប្រជាជន ?

ចម្លើយ : យើងត្រូវមានគ្រោងការណ៍ដូចតទៅនេះ ៖

+ ខាងនយោបាយការពារ និងពង្រីកសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ ជាក់ស្តែងពិតៗឱ្យប្រជាជនអ្នកស្រែមានអំណាចបោះឆ្នោតជ្រើសរើសរបៀបគ្រប់គ្រងឃុំភូមិរបស់ខ្លួន។
+ ខាងសេដ្ឋកិច្ច បង្កើតផ្នែកសហការ ឬសមាគមកសិករនៅភូមិ ឃុំ ការពារផលដំណាំ ពោត ស្រូវ ស្ករ កុំឱ្យពួកថៅកែហាងឆេងមកវាយបន្ទោក យកចំណេញកប់ក្តោងដូចសព្វថ្ងៃ។ ម្យ៉ាងទៀតខាងបឹងព្រៃវិញ ប្រមូលប្រជាជនធ្វើសមាគមការពារផលធម្មជាតិទាំងនោះ ទុកចែកសម្រាប់គ្រប់គ្នាមិនឱ្យមេសៃវៀនក្តាប់ចំណេញរាប់សែនយកទៅជួលអ្នកលេងឱ្យមកធ្វើបាបអ្នកភូមិដូចសព្វថ្ងៃនេះទេ ... ។
+ ខាងសង្គមកិច្ច ចាត់តាំងឱ្យមានផ្នែកសមាគមនារី សមាគមយុវជន សមាគមអ្នកស្រែចម្ការ បង្កើតផ្ទះពេទ្យ ...
+ ខាងវប្បធម៌ ពង្រីក និងបង្កើតសាលារៀននៅគ្រប់ភូមិ គ្រប់វត្តឱ្យមានចំនួនគ្រប់គ្រាន់ដើម្បីគ្រប់ក្មេងបានរៀនសូត្រ។ បង្កើតសាលារៀនមនុស្សចាស់ ប្រុស ស្រីមិនចេះអក្សរ ... ឧបត្ថម្ភលោកគ្រូ បង្រៀនឱ្យជួយរៀបចំដាក់កម្មវិធីសិក្សារបៀបប្រជាធិបតេយ្យពិតប្រាកដ។ បង្កើតបណ្ណាល័យទិញសៀវភៅឱ្យប្រជាជនខ្ចីមើល ... ។

- តើអត្ថបទនេះដកស្រង់ពីណា ?

ចម្លើយ : ដកស្រង់និងកែសម្រួលពីសៀវភៅរឿងគ្រូបង្រៀនស្រុកស្រែរបស់លោក អ៊ឹម ថុក ឆ្នាំ ១៩៥៧ត្រង់វគ្គ ១និងវគ្គ ៤ទំព័រទី ១ដល់ ១៤ ។

- គ្រូឱ្យសិស្សឆ្លើយនិងសំណួរពីទី ១ ទី ២ ទី ៣ និងទី ៤ក្នុងសៀវភៅសិស្សទំព័រទី ២៣៤ ។

ចម្លើយ :

១. អត្ថបទអំណាននេះ មានតួអង្គចំនួន ៩នាក់ គឺបងហាម ពូព្រឿង អ្នកសន កូនពូព្រឿង ប៉ូលីសមុយ ថីដោយ គ្រូម៉ែង អាចារ្យសម អន្ទិតឡឹង។ សកម្មភាពតួអង្គនីមួយៗ ៖

+ បងហាម : បងហាម មានអាយុ ៤០ឆ្នាំ គាត់ជាទាហានជើងក្រហមចាស់។ គាត់បានឈប់ធ្វើទាហានតាំងពីឆ្នាំ ១៩៤០ ហើយបានធ្វើកូនឥម៉ឺនតូចក្នុងត្រាវ៉ូដែរ គាត់ធ្វើកាប៊ូវ៉ាល់ត្រួតថ្នល់ គរពាមក្បែរផ្ទះគាត់ជាប់ជិតប្រាំឆ្នាំហើយ។ គាត់បានឈប់ធ្វើឥម៉ឺន ព្រោះគាត់បានប្រកែកនឹងមេការបារាំងដែលបានបន្ទោសគាត់ មិនសមហេតុ

មិនសមផល។ កាលនៅពេលទាមទារតស៊ូដេញបារាំង បងហាម បានធ្វើជីវពល។ ដោយធ្លាប់បានធ្វើទាហានជើងក្រហមគាត់បានធ្វើជាមេកងជីវពល។ ស្រុកបានសន្តិភាព គាត់ក៏បានច្បាប់ទទួលកាន់កាំភ្លើងមួយពីសាលាស្រុកដើម្បីការពារភូមិគាត់។ បន្ទាប់មក បានរត់គេចពីការតាមចាប់របស់ប៉ូលីស ហើយបានជួយពន្យល់អន្ទិតឡឹង និងអាចារ្យសមពីរបៀបកែប្រែការរស់នៅរបស់ប្រជាជន ដើម្បីចៀសឱ្យផុតពីទុក្ខលំបាក។

+ ពូព្រឿង : ពូព្រឿងចំណាស់ជាប់ ៥០ឆ្នាំ ភ្នែកគាត់ឈឺមើលអ្វីមិនបានឆ្ងាយ។ រោគស្តឹកបានរោមរឹតគាត់ឃាត់គាត់មិនឱ្យដើររកស៊ីក្រៅផ្ទះ។ គាត់នៅចាំផ្ទះមើលថែទាំកូនតូចៗបួននាក់។ គាត់មិនមែនជាអ្នកទម្រន់ដេកស្ងៀមឡើយ។ នៅផ្ទះគាត់ឆ្លៀតត្រដាំអំពៅ ស្លឹកត្រៃ ដំឡូងឈើ ចិញ្ចឹមជ្រូកពីរដំប និងមាន់បួនដប់សំបុក
+ អ្នកសន : ប្រពន្ធបងហាមក្រៅពីរបរធ្វើស្រែចំការ គាត់ជាអ្នករកស៊ីដ៏ឆ្នើម
+ កូនពូព្រឿង : រត់ទៅប្រាប់អ្នកសនពីប៉ូលីសមុយនិងថីដោយមករក
+ ប៉ូលីសមុយ : អ្នកតាមរកចាប់បងហាម
+ ថីដោយ : អ្នកតាមរកចាប់បងហាម
+ គ្រូម៉ែង : អ្នកជូនបងហាមទៅជួបអាចារ្យសម
+ អាចារ្យសម : អ្នកជូនបងហាមគេចពីប៉ូលីស
+ អន្ទិតឡឹង : ទៅសួរសុខទុក្ខបងប្អូនឆ្លងទន្លេនៅភូមិឫស្សី ហើយបានជួបនឹងបងហាមនិងអាចារ្យសមក៏សួរដេញដោលពីរឿងកែប្រែការរស់នៅរបស់ប្រជាជនដើម្បីចៀសឱ្យផុតពីទុក្ខលំបាក។

២. តួអង្គឯកនិងតួអង្គរង

- តួអង្គឯក : បងហាមជាតួអង្គឯក តួអង្គបងហាម មានសកម្មភាពលេចធ្លោជាងគេ ហើយធ្វើសកម្មភាពសំខាន់ជាងគេនៅក្នុងរឿងដូចជា ត្រូវប៉ូលីសតាមចាប់ខ្លួន មានគំនិតរៀបចំកែប្រែរបៀបដឹកនាំក្នុងភូមិ ឃុំជាដើម ...។
- តួអង្គរង : ពូព្រឿង អ្នកសន កូនពូព្រឿង ប៉ូលីសមុយ ថីដោយ គ្រូម៉ែង អាចារ្យសម អន្ទិតឡឹង។ តួអង្គទាំងនេះធ្វើសកម្មភាពបន្ទាប់បន្សំក្នុងរឿងដូចជា ៖
  + ពូព្រឿង : នៅផ្ទះមើលក្មេង
  + អ្នកសន : ជាអ្នករកស៊ីធម្មតា
  + កូនពូព្រឿង : រត់ទៅប្រាប់អ្នកសនពីប៉ូលីសមុយនិងថីដោយមករក
  + ប៉ូលីសមុយ : អ្នកតាមរកចាប់បងហាម
  + ថីដោយ : អ្នកតាមរកចាប់បងហាម
  + គ្រូម៉ែង : អ្នកជូនបងហាមទៅជួបអាចារ្យសម
  + អាចារ្យសម : អ្នកជូនបងហាមគេចពីប៉ូលីស
  + អន្ទិតឡឹង : ទៅសួរសុខទុក្ខបងប្អូនឆ្លងទន្លេនៅភូមិឫស្សី ហើយបានជួបនឹងបងហាមនិងអាចារ្យសម។

៣. លក្ខណៈជាតិ លក្ខណៈមនុស្ស និងលក្ខណៈសង្គមនៃអក្សរសិល្ប៍ក្នុងរឿងគ្រូបង្រៀនស្រុកស្រែ ៖

- លក្ខណៈជាតិនៃអក្សរសិល្ប៍ក្នុងរឿងគ្រូបង្រៀនស្រុកស្រែ : រឿងគ្រូបង្រៀនស្រុកស្រែបានបង្ហាញពីលក្ខណៈជាតិយ៉ាងច្បាស់លាស់។ លក្ខណៈជាតិទាំងនេះបានបង្ហាញឡើងយ៉ាងជាក់ច្បាស់នៅក្នុងសាច់រឿងតាំងពីដើមរហូតដល់ចប់មានដូចជា ៖

+ ការប្រើប្រាស់ភាសាជាតិខ្មែរនៅក្នុងការតាក់តែងរឿង
+ ការបង្ហាញកំណាព្យ ចម្រៀង អាយ៉ៃរបស់ខ្មែរ
+ ការបង្ហាញប្រពៃណីទំនៀមទម្លាប់ខ្មែរមានការសួរសុខទុក្ខពេលឆ្លងទន្លេ ...
+ បង្ហាញទិដ្ឋភាពនៃរបបគ្រប់គ្រង នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ក្នុងសង្គមខ្មែរ ...
+ ការតស៊ូដើម្បីសិទ្ធិសេរីភាព ប្រជាធិបតេយ្យ ...
+ ការរៀបចំអង្គការ សមាគម ដើម្បីការពារផលប្រយោជន៍ប្រជាជន បុគ្គលិកសិក្សា ...
+ បង្ហាញតួអង្គមានមនសិកាជាតិស្នេហាជាតិ ដូចជាបងហាម ...

- លក្ខណៈមនុស្សនៃអក្សរសិល្ប៍ក្នុងរឿងគ្រូបង្រៀនស្រុកស្រែ : រឿងគ្រូបង្រៀនស្រុកស្រែ បង្ហាញពីស្ថានភាពរស់នៅជាក់ស្តែងរបស់ប្រជាជនខ្មែរនៅក្នុងសម័យកាលក្រោយទទួលឯករាជ្យពីអាណានិគមនិយមបារាំង ។ រឿងនេះ ចោទនិងដោះស្រាយពីបញ្ហាមនុស្សជាក់ស្តែងនៅក្នុងសង្គមខ្មែរមានដូចជា ៖
  + បញ្ហាជិះជាន់ គាបសង្កត់ កេងប្រវ័ញ្ច ប្រជាជនពីសំណាក់ពួកថៅកែ ពួកអ្នកមាន ...
  + ការបំផុសចលនាតស៊ូដើម្បីសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ
  + ការឃោសនាបោះឆ្នោត ...
- លក្ខណៈសង្គមនៃអក្សរសិល្ប៍ក្នុងរឿងគ្រូបង្រៀនស្រុកស្រែ : រឿងគ្រូបង្រៀនស្រុកស្រែ ឆ្លុះបញ្ចាំងពីសង្គមខ្មែរក្រោយពីទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង ។ ការគ្រប់គ្រងសង្គមនាពេលនោះ ពុំទាន់មានលក្ខណៈប្រជាធិបតេយ្យពេលលេញនៅឡើយ ។ យើងសង្កេតឃើញថា មានការបោះឆ្នោត តែនៅមានការគំរាមកំហែង គាបសង្កត់ បំបាត់សិទ្ធិសេរីភាព ។ ហេតុនេះហើយ ទើបក្រុមគ្រូបង្រៀនរួមនឹងតួអង្គហាមធ្វើការបំផុសបំផុលដើម្បីទទួលបាននូវសិទ្ធិសេរីភាព និងលិទ្ធិប្រជាធិបតេយ្យ ។ តួអង្គហាម មានគំនិតរៀបចំរបបគ្រប់គ្រងដើម្បីអភិវឌ្ឍសង្គមទាំងមូល សំដៅធ្វើឱ្យមានសិទ្ធិសេរីភាព លិទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហាសេដ្ឋកិច្ច សន្តិសុខ និងសង្គមកិច្ចជូនប្រជាជនទាំងមូល ... ។

៤. រឿងគ្រូបង្រៀនស្រុកស្រែ ជាប្រភេទប្រលោមអក្សរសិល្ប៍បែបនវកថា ព្រោះខ្លឹមសាររឿងទាក់ទងនឹងជីវភាពសង្គមដូចជា នយោបាយ ការជិះជាន់ ការគាបសង្កត់ ការអភិវឌ្ឍសង្គម ជីវភាពរស់នៅរបស់មនុស្សក្នុងសង្គម ... ។
ឧទាហរណ៍ : អ្នកភូមិដើមឫស្សីត្រូវពួកថៅកែ ជិះជាន់ គំរាមកំហែង ដូចសម្តីបងហាមពោល ៖ "លោកបងអាចារ្យមិនដែលទោបានជាអីចឹង" ។ កាលពីមុនខ្ញុំនិងប្អូនម៉ៅព្រមទាំងគ្រូៗ បួនប្រាំនាក់ ទៀតបានជិះកង់លើភ្លឺទៅភូមិនោះ ។ អ្នកស្រុកហៅ មហាក្របានទទួលយើងដូចស្គាល់គ្នាប៉ុន្មានឆ្នាំមកហើយអីចឹង ។ គេនិយាយប្រាប់យើងគ្រប់ ។ គេមិនដែលស្គាល់នាម៉ឺនមកភូមិគេទេ ។ រាល់ឆ្នាំគេមានរឿងតែជាមួយមេសៃវៀនបឹង ។ បងអាចារ្យដឹងទេ មេសៃវៀនបឹងបានចាត់អ្នកលេងប៉ាវកេបឹងឱ្យមកលើកកាប់ទ្រូ លបអ្នកស្រុក ។ ថៅកែបឹងមានអ្នកលេងកាប់ៗចាក់ៗសំឡុតអ្នកស្រុកស្រែដែលដាក់ទ្រូដាក់លបបន្តិចបន្តួចគ្រាន់នឹងចិញ្ចឹមឆ្នាំង ។ ថៅកែរំលោភអស្ចារ្យហើយ គេបានប្រកាន់ថា បឹងនេះមានព្រំត្រីមទឹកឡើងរហូតដល់មាត់ភូមិក្នុងស្រែអ្នកស្រុក ... ។ រាល់ឆ្នាំអ្នកភូមិត្រូវមេសៃវៀនធ្វើបាប ហើយអ្នកលេងបឹងនោះកាចសាហាវមានអំណាចអស្ចារ្យ គេអាចសម្លាប់អ្នកភូមិបានគ្មានទោស ។ គេបង្កែជានបានទាំងអស់ ។ ថៅកែគេបានស្គាល់អស់លោកនាម៉ឺននៅខេត្តស្រុកស្រែច ... ។

ឃ. ការវាយតម្លៃ

- គ្រូឱ្យសិស្សឆ្លើយនឹងសំណួរពីទី ៥ ទី ៦ និងទី ៧ក្នុងសៀវភៅសិស្សទំព័រទី ២៣៤ ជាក្រុម ឬបុគ្គល ។

ចម្លើយ :

៥. ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា តម្លៃអប់រំ និងកាលអាកាសនៃរឿងគ្រូបង្រៀនស្រុកស្រែ ៖

- ប្រធានរឿង : ការតស៊ូដើម្បីទាមទារសិទ្ធិសេរីភាពនិងប្រជាធិបតេយ្យ ។
- ចំណោទបញ្ហា :
  + ការគេចខ្លួនរបស់បងហាមពីការតាមចាប់របស់ប៉ូលីស
  + ការចង់រៀបចំការគ្រប់គ្រងភូមិ ឃុំប្រកបដោយប្រជាធិបតេយ្យ និងការអភិវឌ្ឍ
- មូលបញ្ហា : សកម្មភាពតស៊ូបំផុសចលនាមហាជននិងវិធានការបង្ក្រាបនិងរារាំងខ្សែរយៈចលនាមហាជន ។
- តម្លៃអប់រំ : ស្នាដៃរឿងគ្រូបង្រៀនស្រុកស្រែបានផ្តល់នូវការអប់រំ ទូន្មានដល់ជនានុជនក្នុងទស្សនៈលោកិយជីវិត និងសង្គមនយោបាយ ៖
  + ឱ្យស្អប់អំពើជិះជាន់សង្កត់សង្កិននៃរបបសង្គមចាស់
  + ឱ្យឆើបតស៊ូបំផុសបំផុលចលនាមហាជនឱ្យភ្ញាក់រឭកយល់ច្បាស់ពីរបបជិះជាន់
  + ឱ្យស្គាល់លទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពពិតប្រាកដ
  + ឱ្យគិតប្រយោជន៍ប្រជាជន ប្រយោជន៍សាធារណៈធំជាងប្រយោជន៍ផ្ទាល់ខ្លួន
  + ឱ្យហ៊ានលះបង់កម្លាំងកាយ ចិត្ត បញ្ញា ធនធាន ដើម្បីបុព្វហេតុជាតិ
  + ឱ្យមានសាមគ្គីភាពស្អិតរមួត ជួយឧបត្ថម្ភគ្នាទៅវិញទៅមក
  + ឱ្យចូលរួមក្នុងចលនាអក្ខរកម្មដើម្បីបំបាត់ភាពមិនចេះអក្សរ
  + ឱ្យចេះវិភាគកុំឱ្យជឿលើអបិយជំនឿហួសហេតុ
  + ឱ្យចេះកសាងខ្លួន កែប្រែខ្លួនទាន់ពេលវេលាដុសខាត់ឱ្យអស់នូវកម្ទេចសត្តិភូមិនិងអាណានិគម
  + បណ្តុះគំនិតសុទិដ្ឋិនិយម
- កាលអាកាស ៖
  + កាល : ដំណើររឿងប្រព្រឹត្តទៅក្រោយសម័យកាលទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងមាននៅក្នុងខែកក្កដា សីហា កញ្ញា ក្នុងពេលដែលប្រទេសកម្ពុជាឃោសនាបោះឆ្នោតប្រជែងយកឈ្នះរវាងគណៈបក្សនយោបាយ និងក្នុងពេលប្រជាជនកំពុងធ្វើស្រែចំការរដូវវស្សា ។
  + អាកាស : ដំណើររឿងប្រព្រឹត្តទៅនៅរោងម៉ាស៊ីនកិនស្រូវ ភូមិគ ភូមិប្រាសាទ ភូមិពាម ភូមិឫស្សី ភូមិដកគាំ គុកកំពង់ចាម ។

៦. សង្គមបរិយាកាសនៃរឿងគ្រូបង្រៀនស្រុកស្រែ : ដំណើររឿងប្រព្រឹត្តទៅក្រោយសម័យកាលទទួលឯករាជ្យពីអាណានិគមនិយមបារាំង ។ នៅសម័យកាលនោះ ប្រទេសកម្ពុជាយើងប្រកាន់យករបបប្រជាធិបតេយ្យ ដោយមានការរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រី ។ ក្នុងការបោះឆ្នោតនេះ មានការចូលរួមប្រកួតប្រជែងពីគណៈបក្សនយោបាយជាច្រើន ។ ការគ្រប់គ្រងប្រទេសនាសម័យកាលនោះ នៅពុំទាន់មានលទ្ធិប្រជាធិបតេយ្យពេញលេញនៅឡើយ ។ ហេតុនេះហើយទើបយើងសង្កេតឃើញថាមានបញ្ហាមួយចំនួននៅក្នុងសង្គមដូចជា ការជិះជាន់កេងប្រវ័ញ្ច គំរាមកំហែង ការបំបាត់សិទ្ធិសេរីភាព ... ។

៧. គំនិតសុទិដ្ឋិនិយមនៃរឿងគ្រូបង្រៀនស្រុកស្រែ ៖

- គំនិតក្នុងការកែប្រែការរស់នៅរបស់ប្រជាជនឱ្យចៀសផុតពីការជិះជាន់ កេងប្រវ័ញ្ច គំរាមកំហែង ដោយធ្វើឱ្យមានសិទ្ធិសេរីភាពនិងលទ្ធិប្រជាធិបតេយ្យ ... ។ គំនិតនេះបានបង្ហាញតាមរយៈតួអង្គបងហាម នៅពេលពន្យល់ អាចារ្យសម និងអន្ទិតឡឹង ៖ "ការដោះទុក្ខកែប្រែការរស់នៅប្រជាជនយើងគ្រប់គ្នា ជាការពិបាក ជាការយូរមិនរាប់ដូចមាត់ទេ ព្រោះមនុស្សធ្វើមិនមែនទេវតាឯណាធ្វើជួសយើងទេ ... ។ យើងត្រូវអប់រំខ្លួនយើង និងអប់រំអ្នកភូមិឱ្យយល់ជឿលើកម្លាំងខ្លួន ហើយឱ្យដឹងថាទាល់តែយើងរួមកម្លាំងសាមគ្គីគ្នាបានយើងអាចទប់ទល់នឹងអ្នកលេងដៃ ជើងថៅកែមេសៃវៀនបាន ។ នៅស្រុកស្រែជាមួយយើងវាអាងអ្នកលេងនៅទីក្រុងវាអាងទឹកប្រាក់ ... ។ បើដូច្នេះ បើយើងចង់រួចខ្លួនចង់បានស្រួល ចង់បានយុត្តិធម៌ ទាល់តែអ្នកភូមិនេះចេះបម្រាសកែប្រែខ្លួនឡើង ។ ការរៀបចំភូមិឃុំ ជាការចាំបាច់មុនគេបង្អស់ចំពោះក្រុមយើង ។ ដោយហេតុនេះ បានជាខ្ញុំយល់ឃើញថាជល់រួចរាល់ឆ្នាំក្រោយៗនេះ យើងត្រូវតែឱ្យប្រជាជនមានសិទ្ធិរើសនាយឃុំ .. ។ តែនាយកឃុំយើងមិនមែនមានភារៈដើរជិះជាន់សង្កត់សង្កិនរាស្ត្រដូចអាណានិគមនិយមបារាំងបង្កបង្កើតនោះទេ ។ នាយកឃុំយើងជាតំណាងប្រជាជននៅភូមិ ហើយមានភារៈកែប្រែអ្នកភូមិពីក្តីវេទនាគ្មានអាវពាក់ពីអំពើចោរកម្មពីការគំរាមកំហែង" ។

- គំនិតក្នុងការរៀបចំរបៀបគ្រប់គ្រងសង្គម ។ គំនិតនេះបានបង្ហាញតាមរយៈតួអង្គបងហាម នៅពេលសន្ទនាជាមួយអាចារ្យសមនិងអន្ទិតឡឹង ៖ "... យើងត្រូវមានគ្រោងការណ៍ដូចតទៅនេះ ៖"
  + ខាងនយោបាយការពារនិងពង្រីកសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ ជាក់ស្តែងពិតៗឱ្យប្រជាជនអ្នកស្រែមានអំណាចបោះឆ្នោតជ្រើសរើសរបៀបគ្រប់គ្រងឃុំភូមិរបស់ខ្លួន ។
  + ខាងសេដ្ឋកិច្ច បង្កើតផ្នែកសហការ ឬសមាគមកសិករ នៅភូមិឃុំ ការពារផលដំណាំពោត ស្រូវ ស្ករ កុំឱ្យពួកថៅកែហាងឆេងមកវាយបន្លោកយកចំណេញកប់ក្តោងដូចសព្វថ្ងៃ ។ ម្យ៉ាងទៀតខាងបឹងព្រៃវិញ ប្រមូលប្រជាជនធ្វើសមាគមការពារផលធម្មជាតិទាំងនោះទុកចែកសម្រាប់គ្រប់គ្នាមិនឱ្យមេសៃវៀនក្តាប់ចំណេញរាប់សែនយកទៅជួលអ្នកលេងឱ្យមកធ្វើបាបអ្នកភូមិដូចសព្វថ្ងៃនេះទេ ... ។
  + ខាងសង្គមកិច្ច ចាត់តាំងឱ្យមានផ្នែកសមាគមនារី សមាគមយុវជន សមាគមអ្នកស្រែចំការ បង្កើតផ្ទះពេទ្យ ... ។
  + ខាងវប្បធម៌ ពង្រីក និងបង្កើតសាលារៀននៅគ្រប់ភូមិ គ្រប់វត្ត ឱ្យមានចំនួនគ្រប់គ្រាន់ ដើម្បីគ្រប់ក្មេងបានរៀនសូត្រ ។ បង្កើតសាលារៀនមនុស្សចាស់ ប្រុសស្រីមិនចេះអក្សរ ... ឧបត្ថម្ភគ្រូបង្រៀនឱ្យជួយរៀបចំដាក់កម្មវិធីសិក្សារបៀបប្រជាធិបតេយ្យពិតប្រាកដ ។ បង្កើតបណ្ណាល័យទិញសៀវភៅឱ្យប្រជាជនខ្ចីមើល ... ។ បានប្រាកដជាបានគ្រាន់តែយូរនិងឆាប់ ។ កង់ប្រវត្តិសាស្ត្រសង្គមមនុស្សកំពុងតែវិលសំដៅទៅលទ្ធិប្រជាធិបតេយ្យប្រជាជនហើយគង់តែចក្រពត្តិអាមេរិកកាំងមកបង្វែ គំរាមកំហែងខ្លាស់យើងគ្រប់គ្នាយ៉ាងណាក៏ទប់មិនបានឡើយ បើមិនឆ្នាំនេះ ឆ្នាំក្រោយ ។ បើយើងធ្វើទាន់បាន កូនយើងធ្វើ ។ បើកូនយើងធ្វើមិនសម្រេច ចៅយើងមុខជាសម្រេច ។ បើភូមិឃុំយើងធ្វើមិនទាន់កើត ក៏ភូមិឃុំផ្សេងទៀតធ្វើបាន ។



ការនិយាយ : ការសំយោគគំនិត

១. វត្ថុបំណង

- ប្រាប់សំនួនសំខាន់ៗក្នុងការនិយាយសំយោគបានត្រឹមត្រូវ
- និយាយសំយោគបានត្រឹមត្រូវ
- មានទំនុកចិត្តក្នុងនិយាយសំយោគ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២៣៥-២៣៦
- ឯកសារបកស្រាយតែងសេចក្តីបែបពិភាក្សា ... ។

៣. ព័ត៌មានជំនួយ

ដើម្បីជាជំនួយដល់សិស្សក្នុងការស្វែងយល់ខ្លឹមសារមេរៀនឱ្យកាន់តែច្បាស់និងដើម្បីជាជំនួយក្នុងការធ្វើលំហាត់ សូមលោក/អ្នកគ្រូ ប្រើប្រាស់ឯកសារបកស្រាយតែងសេចក្តីបែបពិភាក្សា ។

៤. លំនាំបង្រៀន

ក. ការត្រៀមនិយាយ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ១០ ទំព័រទី ២៣៥ បន្ទាប់មកគ្រូសរសេរចំណងជើងការនិយាយ "ការសំយោគគំនិត" ដាក់លើក្តារខៀន រួចគ្រូសួរ ៖
  - ដូចម្តេចដែលហៅថា ការសំយោគគំនិត

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើគេធ្វើការសំយោគគំនិតដូចម្តេចខ្លះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សអានសេចក្តីពន្យល់ក្នុងសៀវភៅសិស្សទំព័រទី ២៣៥ នៅផ្នែកខាងលើរួចសួរសំណួរ ៖
  - ដូចម្តេចដែលហៅថា ការនិយាយសំយោគគំនិត ?

    ចម្លើយ : ការនិយាយសំយោគ គឺជាការប្រមូលផ្តុំគំនិត ព័ត៌មានព្រឹត្តិការណ៍ច្រើន ឬការបូកសរុបមតិយោបល់ទស្សនៈច្រើន មករួមបញ្ចូលគ្នា ។
  - តើគេធ្វើការសំយោគគំនិតដូចម្តេចខ្លះ ?

    ចម្លើយ : ការធ្វើសំយោគពេលខ្លះ អ្នកត្រូវទាញយកគំនិតទាំងអស់ដោយសារគំនិតទាំងនោះសុទ្ធតែត្រឹមត្រូវ និងពេលខ្លះទៀត អ្នកត្រូវទាញយកតែគំនិតមួយចំនួននិងចោលគំនិតខ្លះដែលពុំសមស្រប ។

ខ. ការនិយាយ

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗហាត់និយាយក្នុងក្រុម ។

- គ្រូឱ្យក្រុមនីមួយៗហ៊ឺកហាត់និយាយតាមអត្ថបទគំរូដោយមើលសៀវភៅ ។ សមាជិកក្រុមនីមួយៗត្រូវជួយកែលម្អគ្នាទៅវិញទៅមក ។ បន្ទាប់មក ជ្រើសរើសសមាជិកក្រុមនីមួយៗ ឡើងនិយាយតាមអត្ថបទគំរូដោយមើលសៀវភៅ បង្ហាញសិស្សទាំងអស់ ។ សមាជិកក្រុមដទៃទៀតជួយកែលម្អគ្នាទៅវិញទៅមក ។
- គ្រូសួរសំណួរទាក់ទងនឹងខ្លឹមសារលម្អិតរបស់អត្ថបទ ៖
  - តើតួអង្គទាំងអស់ពិភាក្សាអំពីប្រធានបទអ្វី ?

    ចម្លើយ : ការឈប់ជក់បារី ។
  - តើរក្សាបញ្ចេញយោបល់ដូចម្តេច ?

    ចម្លើយ : រក្សាបង្ហាញពីវិធីសាស្ត្រសម្រាប់ជួយអ្នកជក់បារី ឱ្យលះបង់ការជក់បារីដោយ ៖
    + សួរអ្នកជក់បារីគ្រប់ៗគ្នា បើសិនជាគាត់ចង់ឈប់ជក់ បើគាត់ពុំទាន់ចង់ឈប់ជក់ទេត្រូវពន្យល់គាត់ពីគ្រោះថ្នាក់និងការខាតបង់ទាំងឡាយដែលកើតឡើងពីការជក់បារីជាមុនសិន ។
    + ជួយផ្តល់យោបល់ដល់អ្នកជក់ដែលចង់ឈប់ជក់ រួចលើកទឹកចិត្តគាត់ឱ្យកំណត់កាលបរិច្ឆេទ ឈប់ជក់ ។
    + តាមដាននិងបន្តជួយពួកគាត់កុំឱ្យជក់បារីឡើងវិញ ។
  - តើបុស្បាបញ្ចេញយោបល់ដូចម្តេច ?

    ចម្លើយ : បុស្បាមានយោបល់បន្ថែម ខ្ញុំឯកភាពនឹងយោបល់នេះ ប៉ុន្តែខ្ញុំមានគំនិតខ្លះទៀតគឺ ៖
    + ការតាំងចិត្ត : ជាដំបូងត្រូវលើកទឹកចិត្តឱ្យមានការតាំងចិត្តយ៉ាងពិតប្រាកដក្នុងការសម្រេចចិត្តឈប់ជក់បារី ។ ចំណុចនេះ មានសារៈសំខាន់ណាស់ព្រោះអ្នកជក់បារីមិនអាចឈប់ជក់បានដោយគ្មានការតាំងចិត្តនោះទេ ។ កាលណាមានការតាំងចិត្តកាន់តែខ្លាំងក្លានោះជោគជ័យនៃការផ្តាច់បារីក៏កាន់តែជាក់លាក់ដែរ ។
    + កំណត់កាលបរិច្ឆេទច្បាស់លាស់ដើម្បីឈប់ជក់បារី : ត្រូវជួយគាត់ក្នុងការកំណត់កាលបរិច្ឆេទ ឈប់ជក់បារីឱ្យច្បាស់ ។ ត្រូវធ្វើភ្លាមៗតែម្តង ព្រោះការពន្យារពេលអាចធ្វើឱ្យការតាំងចិត្តធ្លាក់ចុះ ។ បន្ទាប់មក ឱ្យគាត់ចុះកាលបរិច្ឆេទនោះក្នុងខិតប័ណ្ណដោយមានចុះហត្ថលេខាផង ។

    ការត្រៀមខ្លួនឈប់ជក់បារីដោយ ៖
    + បោះចោលបារីនិងចានគោះបារីចោល
    + នៅឱ្យឆ្ងាយពីអ្នកជក់បារីព្រោះការឃើញគេជក់នាំឱ្យនឹកឃើញចង់ជក់ដែរ
    + ចៀសវាងកុំទទួលទានគ្រឿងស្រវឹង ឬកាហ្វេក្នុងដំណាក់កាលដំបូងនៃការឈប់ជក់បារី
    + គួរតែទទួលទានបន្លែនិងផ្លែឈើឱ្យបានច្រើន
    + ទទួលទានដំណេកឱ្យបានគ្រប់គ្រាន់និងហាត់ប្រាណឱ្យបានទៀងទាត់ដើម្បីឱ្យមានអារម្មណ៍ល្អ
    + សុំការគាំទ្រពីក្រុមគ្រួសារនិងមិត្តភក្តិ ។
  - តើ មុនី បញ្ចេញយោបល់ដូចម្តេច ?

    ចម្លើយ : មុនីមានយោបល់សំយោគគំនិតរបស់រក្សានិងបុស្បា ។
  - តើ មុនី ធ្វើសំយោគគំនិតដូចម្តេច ?

    ចម្លើយ : មុនីធ្វើសំយោគគំនិតដោយ ៖ "ខ្ញុំគិតថា យោបល់អ្នកទាំងពីរសុទ្ធល្អៗ សម្រាប់យកមកអនុវត្តក្នុងការជួយអ្នកជក់បារីឱ្យឈប់ជក់បារីបានដោយប្រើវិធី : សួរអ្នកជក់បារីគ្រប់ៗគ្នា បើសិនជាគាត់ចង់ឈប់ជក់

លើគាត់ពុំទាន់ចង់ឈប់ជក់ទេត្រូវពន្យល់គាត់ពីគ្រោះថ្នាក់និងការខាតបង់ទាំងឡាយដែលកើតឡើងពីការជក់បារីជាមុនសិន ។ ជួយផ្តល់យោបល់ដល់អ្នកដែលចង់ឈប់ជក់ រួចលើកទឹកចិត្តគាត់ឱ្យកំណត់កាលបរិច្ឆេទឈប់ជក់ ។ ត្រូវតាមដាននិងបន្តជួយពួកគាត់កុំឱ្យជក់បារីឡើងវិញ ។ ត្រូវលើកទឹកចិត្តឱ្យមានការតាំងចិត្តយ៉ាងពិតប្រាកដក្នុងការសម្រេចចិត្តឈប់ជក់បារី ។ ត្រូវត្រៀមខ្លួន ឈប់ជក់បារីដោយបោះចោលបារី និងចានគោះបារីចោល នៅឱ្យឆ្ងាយពីអ្នកជក់បារី ចៀសវាងកុំទទួលទានគ្រឿងស្រវឹង ឬកាហ្វេក្នុងដំណាក់កាលដំបូងនៃការឈប់ជក់បារី គួរតែទទួលទានបន្លែនិងផ្លែឈើឱ្យបានច្រើន ទទួលទានដំណេកឱ្យបានគ្រប់គ្រាន់និងហាត់ប្រាណឱ្យបានទៀងទាត់ ដើម្បីឱ្យមានអារម្មណ៍ល្អ សុំការគាំទ្រពីក្រុមគ្រួសារនិងមិត្តភក្តិ ។ យើងសង្ឃឹមថា គំនិតប្រកបដោយសុទិដ្ឋិនិយមទាំងនេះនឹងបានរួមចំណែកក្នុងការជួយឱ្យអ្នកជក់បារីឈប់ជក់បារីបាន" ។

- តើគេត្រូវធ្វើដូចម្តេច មុនពេលធ្វើសំយោគគំនិត ?

ចម្លើយ : មុនពេលធ្វើសំយោគ គេត្រូវញែករវាងគំនិត មតិយោបល់ទស្សនៈដែលដូចឬប្រហាក់ប្រហែលគ្នានិងគំនិតផ្សេងៗទៀត ។ ពេលធ្វើសំយោគ អ្នកត្រូវផ្តុំគំនិត មតិយោបល់ ទស្សនៈ ដែលដូចឬប្រហាក់ប្រហែលគ្នាដាក់មួយដុំៗ ។ បន្ទាប់មក អ្នកត្រូវធ្វើសេចក្តីសន្និដ្ឋានដោយទាញយកតែគំនិតត្រឹមត្រូវ ។ ចំណែកគំនិតផ្សេងៗទៀត អ្នកគ្រាន់តែអះអាងថាគឺជាការយល់ឃើញមួយ ។

- គ្រូចែកសិស្សជាក្រុមតូចៗ ។ ឱ្យក្រុមនីមួយៗចាត់តាំងសមាជិកម្នាក់ម្តងៗ ហ៊ឹកហាត់និយាយដោយប្រើសម្តីផ្ទាល់ខ្លួនមិនមើលសៀវភៅ ។ សមាជិកក្រុមនីមួយៗត្រូវជួយកែលម្អគ្នាទៅវិញទៅមក ។ បន្ទាប់មក ជ្រើសរើសមាជិកក្រុមនីមួយៗឡើងនិយាយដោយប្រើសម្តីផ្ទាល់ខ្លួនមិនមើលសៀវភៅបង្ហាញសិស្សទាំងអស់ ។ សមាជិកក្រុមដទៃទៀតជួយកែលម្អគ្នាទៅវិញទៅមក ។

គ. ការវាយតម្លៃ

- គ្រូចែកសិស្សជា ៤ក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូឱ្យក្រុមនីមួយៗ ពិភាក្សាធ្វើលំហាត់ក្នុងសៀវភៅសិស្សទំព័រទី ២៣៦
- គ្រូណែនាំក្រុមនីមួយៗ ឱ្យធ្វើសំយោគគំនិតក្នុងការពិភាក្សាលើប្រធានបទខាងក្រោម ៖
  + ក្រុមទី ១ : ធ្វើការសំយោគគំនិតក្នុងការពិភាក្សាលើប្រធានបទ "ការជ្រើសរើសអាជីពសម្រាប់អនាគត"
  + ក្រុមទី ២ : ធ្វើការសំយោគគំនិតក្នុងការពិភាក្សាលើប្រធានបទ "ការបង្កើតភ្ជួបសិក្សា"
  + ក្រុមទី ៣ : ធ្វើការសំយោគគំនិតក្នុងការពិភាក្សាលើប្រធានបទ "ការបង្កើតកម្មវិធីឥណទានទ្រទ្រង់សាលារៀន"
  + ក្រុមទី ៤ : ធ្វើការសំយោគគំនិតក្នុងការពិភាក្សាលើប្រធានបទ "ការបង្កើតក្រុមផ្សព្វផ្សាយអប់រំសុខភាព"
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ រួចហ៊ឹកហាត់និយាយក្នុងក្រុម
- គ្រូឱ្យក្រុមនីមួយៗឡើងបង្ហាញលទ្ធផលការងារក្រុមខ្លួន
- គ្រូដឹកនាំសិស្ស ធ្វើការវាយតម្លៃនិងកែលម្អ ។



រឿង ឪពុកក្មេកវើសកូនប្រសា

១. ឥស្តុបំណង

- ប្រាប់ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា កាលអាកាស និងសង្គមបរិយាកាសនៃរឿងឪពុកក្មេកវើសកូនប្រសាបានត្រឹមត្រូវ
- ប្រាប់តម្លៃអប់រំនៃរឿងឪពុកក្មេកវើសកូនប្រសាបានត្រឹមត្រូវ
- បង្ហាញគំនិតសុទិដ្ឋិនិយមនៃរឿងឪពុកក្មេកវើសកូនប្រសាបានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យចូលចិត្តសិក្សាស្រាវជ្រាវអក្សរសិល្ប៍ខ្មែរ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២៣៧
- ឯកសារ រឿងឪពុកក្មេកវើសកូនប្រសា

៣. ព័ត៌មានជំនួយ

សូមលោកគ្រូ/អ្នកគ្រូឱ្យសិស្សអានអត្ថបទរឿង ឪពុកក្មេកវើសកូនប្រសានៅផ្ទះជាមុន ដើម្បីសម្រួលពេលវេលាក្នុងការសិក្សា ។ ចំណែកសំណួរមួយចំនួនបើពុំមានពេលវេលាគ្រប់គ្រាន់ទេ សូមលោក/អ្នកគ្រូឱ្យសិស្សធ្វើនៅផ្ទះ ។

៤. លំនាំបង្រៀន

ក. ការត្រៀមអំណាន

- គ្រូឱ្យសិស្សបើកសៀវភៅត្រង់មេរៀនទី ១០ទំព័រទី ២៣៧ បន្ទាប់មកគ្រូសរសេរចំណងជើងអំណាន "រឿងឪពុកក្មេកវើសកូនប្រសា" ជាក់លើក្តារខៀន រួចសួរ ៖
  - តើរឿងឪពុកក្មេកវើសកូនប្រសាដកស្រង់ពីណា ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - ចូរអ្នកសាកល្បងនិទានលមើល ។

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូធ្វើការបូកសរុបគំនិតរបស់សិស្ស ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្សទំព័រទី ២៣៧ រួចសួរ ៖
  - តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
  - តើរូបភាពនេះចង់និយាយពីអ្វី ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូធ្វើការបូកសរុបគំនិតរបស់សិស្ស ។
- គ្រូសួរសំណួរឱ្យសិស្សប៉ាន់ស្មានខ្លឹមសារអត្ថបទ "រឿងឪពុកក្មេកវើសកូនប្រសា" : តើរឿងនេះ មានខ្លឹមសារដូចម្តេច ? សិស្សឆ្លើយតាមការយល់ឃើញរបស់ពួកគេ ។ គ្រូសរសេរចម្លើយប៉ាន់ស្មានរបស់សិស្សដាក់លើក្តារខៀនដើម្បីទុកធ្វើឯកផ្ទាត់ ។

- គ្រូឱ្យសិស្សរកពាក្យពិបាកនៅក្នុងអត្ថបទ រួចសរសេរពាក្យទាំងនោះនៅលើក្តារខៀន
- គ្រូឱ្យសិស្សអានការពន្យល់ពាក្យពិបាកទាំងនោះនៅក្នុងសៀវភៅសិស្សទំព័រទី ២២៦-២២៧ ។

ខ. អំណាន

- គ្រូឱ្យសិស្សអានខ្លឹមសារត្រង់ចំណុច ខ អភិវឌ្ឍន៍បំណិនក្នុងសៀវភៅសិស្សទំព័រទី ២៣៧ រួចសួរសំណួរដើម្បីទាញបម្រុងប្រយ័ត្នសិស្ស ៖
  - តើនៅក្នុងអត្ថបទនេះគេតម្រូវ ឱ្យអ្នកយល់ដឹងអំពីអ្វីខ្លះ ?

    ចម្លើយ : តួអង្គ ខ្លឹមសារអត្ថបទ ប្រភេទអក្សរសិល្ប៍ លក្ខណៈអក្សរសិល្ប៍ ប្រធានរឿង កាលអាកាស មូលបញ្ហា ចំណោទបញ្ហា សង្គមបរិយាកាស និងតម្លៃអប់រំនៃរឿង ។
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សទំព័រទី ២៤២ រួចសួរសំណួរបញ្ជាក់ពីការចាប់អារម្មណ៍របស់សិស្ស ៖
  - តើសំណួរទាំងអស់មានប៉ុន្មាន ?

    ចម្លើយ : សំណួរមានចំនួន ៦ ។
  - តើសំណួរនីមួយៗផ្តោតសំខាន់ទៅលើអ្វីខ្លះ ?

    ចម្លើយ : អាស្រ័យលើសិស្ស ។
- គ្រូឱ្យសិស្សអានអត្ថបទក្នុងសៀវភៅសិស្សទំព័រទី ២៣៨-២៤២ ។

គ. ការពង្រឹងអំណាន

- គ្រូសួរសំណួរទាក់ទងនឹងសេចក្តីលម្អិតនៃអត្ថបទទាំងមូល ។ ប្រសិនបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបាន លោក/អ្នកគ្រូឱ្យសិស្សអានវគ្គដែលមានចម្លើយឡើងវិញ ។
- គ្រូឱ្យសិស្សឆ្លើយនឹងសំណួរពីទី ១ ទី ២ និងទី ៣ក្នុងសៀវភៅសិស្សទំព័រទី ២៤២ ។

ចម្លើយ :

១. អត្ថបទរឿង ឪពុកក្មេករើសកូនប្រសា មានតួអង្គចំនួន ៥នាក់
- ឈ្មោះតួអង្គ : តា យាយ កូនក្រមុំ កំលោះរូបស្អាត និងកំលោះមានប្រាជ្ញា
- សកម្មភាពតួអង្គនីមួយៗ ៖
  + តា : ជ្រើសរើសកូនប្រសាដែលតមជេរម្តាយគេ ដោយប្រើល្បិចផ្សេងៗដូចជា ៖
    - ឱ្យកំលោះទី ១ និងកំលោះទី ២មកបម្រើដោយឱ្យភ្ជួរស្រែរហូតថ្មឃំ
    - ប្រើឧបាយកលផ្តាច់កូនស្រីពីកំលោះទី ២ ដោយឱ្យតាចូលក្នុងការុងមួយ និងការុងមួយទៀតជាក់អង្ករ ឱ្យកំលោះនោះរែកទៅកាប់អុសលើភ្នំ
    - ប្រើឧបាយកលដោយឱ្យតាធ្វើជាម្ចាស់ រីឯកំលោះនោះធ្វើជាឆ្កែដើម្បីទៅរកអណ្តើក
    - ប្រើឧបាយកលដោយឱ្យកំលោះនោះធ្វើជាម្ចាស់ រីឯតានោះធ្វើជាឆ្កែដើម្បីទៅរកអណ្តើក
    - ប្រើឧបាយកលចូលក្នុងការុងឱ្យកំលោះនោះរែកទៅផ្សារ ។
  + យាយ : ជួយរកឧបាយកលតាក្នុងការផ្តាច់កូនស្រីពីអ្នកកំលោះ
  + កូនក្រមុំ : អ្នករៀបចំបាយទឹកឱ្យកំលោះទី ១ និងកំលោះទី ២ ពេលមកបម្រើឪពុកម្តាយក្មេក
  + កំលោះទី ១ : មកបម្រើឪពុកម្តាយក្មេកក្នុងលក្ខខណ្ឌតមជេរម្តាយគេ ដោយភ្ជួរស្រែរហូតដល់ថ្មឃំតែទ្រាំមិនបានក៏ត្រូវតាយាយផ្តាច់កូន
  + កំលោះទី ២ : មកបម្រើឪពុកម្តាយក្មេកក្នុងលក្ខខណ្ឌតមជេរម្តាយគេ ហើយចេះរកឧបាយកលទប់ទល់ឈ្នះតាយាយរហូតបានកូនក្រមុំធ្វើជាប្រពន្ធ ។

២. ខ្លឹមសាររឿង ឪពុកក្មេកលើសកូនប្រសាគឺ ៖

- បង្ហាញពីទំនៀមទម្លាប់ក្នុងការជ្រើសរើសកូនប្រសានៅក្នុងសង្គមខ្មែរកាលពីបុរាណ មុននឹងក្លាយជាកូនប្រសាគេ កូនប្រុសត្រូវទៅបម្រើឪពុកម្តាយខាងកូនស្រីជាមុនសិន បើឪពុកម្តាយខាងស្រីពេញចិត្តទើបបានកូនស្រីគេមកធ្វើជាប្រពន្ធ បើឪពុកម្តាយខាងកូនស្រីមិនពេញចិត្តគេផ្តាច់វិញ ។
- ការប្រើប្រាស់ល្បិចកលរបស់តាយាយដើម្បីផ្តាច់កូនពីកំលោះទី ២
- ការប្រើប្រាស់ប្រាជ្ញារបស់កូនកំលោះទី ២ដើម្បីយកឈ្នះលើតាយាយ ។

៣. លក្ខណៈអក្សរសិល្ប៍និងប្រភេទអក្សរសិល្ប៍ ៖

- លក្ខណៈអក្សរសិល្ប៍ក្នុងរឿងឪពុកក្មេកលើសកូនប្រសា
  + លក្ខណៈមនុស្ស : បង្ហាញពីបញ្ហាមនុស្ស ចោទនិងដោះស្រាយបញ្ហារបស់មនុស្សជាក់ស្តែង ...
  + លក្ខណៈជាតិ : បង្ហាញពីប្រពៃណីទំនៀមទម្លាប់ខ្មែរនៅសម័យបុរាណ គឺឱ្យកូនប្រសាប្រុសទៅបម្រើឪពុកម្តាយក្មេកមុននឹងរៀបការ ... ។
  + លក្ខណៈសង្គម : បង្ហាញពីរបៀបរបបរស់នៅនិងទំនាក់ទំនងរបស់មនុស្សនៅក្នុងសង្គម ... ។
- ប្រភេទអក្សរសិល្ប៍នៃរឿងឪពុកក្មេកលើសកូនប្រសា : រឿងឪពុកក្មេកលើសកូនប្រសា ជាប្រភេទប្រលោមអក្សរសិល្ប៍ បែបព្រេងកថា ព្រោះខ្លឹមសាររឿងត្រូវបានអ្នកនិពន្ធប្រឌិតចងក្រង ដោយយករឿងរ៉ាវផ្សេងៗដូចជារឿងឈ្លោះប្រកែកគ្នា ជីវភាពរស់នៅរបស់មនុស្សក្នុងសង្គម ...ដើម្បីលើកមកជាសេចក្តីដំណាលទូន្មានប្រាប់អនុជន ។

ឃ. ការវាយតម្លៃ

- គ្រូឱ្យសិស្សឆ្លើយនឹងសំណួរពីទី ៥ ទី ៦ និងទី ៧ ក្នុងសៀវភៅសិស្សទំព័រទី ២៣៤ ។

៤. អំពីប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា កាលអាកាស និងសង្គមបរិយាកាសនៃរឿងឪពុកក្មេកលើសកូនប្រសា ៖

- ប្រធានរឿង : ការកែប្រែគំនិតឪពុកម្តាយក្មេកដែលយកប្រពៃណីទំនៀមទម្លាប់ មកកេងចំណេញលើកម្លាំងគេ ។
- ចំណោទបញ្ហា : ការប្រើឧបាយកលផ្សេងៗ ដើម្បីផ្តាច់កូនពីកំលោះទី ២ ។
- មូលបញ្ហា : ការប្រើប្រាជ្ញារបស់កំលោះទី ២ ទប់ទល់នឹងឧបាយកលរបស់តាយាយ ។
- កាលអាកាស : ការប្រើប្រាជ្ញារបស់កំលោះទី ២ទប់ទល់នឹងឧបាយកលរបស់តាយាយ ។
  + កាល : កាលពីព្រេងនាយ យប់ ព្រឹក ថ្ងៃ ...
  + អាកាស : ផ្ទះតាយាយ វាលស្រែ ជើងភ្នំ ...
- សង្គមបរិយាកាស : ដំណើររឿងប្រព្រឹត្តទៅនៅក្នុងសង្គមខ្មែរពីសម័យបុរាណដែលនៅសម័យនោះខ្មែរយើងប្រកាន់យកប្រពៃណីទំនៀមទម្លាប់ក្នុងការជ្រើសរើសគូស្រករឱ្យកូនប្រុសស្រី ដោយឱ្យកូនប្រុសទៅបម្រើឪពុកម្តាយខាងកូនស្រីជាមុនសិន បើឪពុកម្តាយខាងស្រីពេញចិត្តទើបបានកូនស្រីគេមកធ្វើជាប្រពន្ធ បើឪពុកម្តាយខាងកូនស្រីមិនពេញចិត្តគេផ្តាច់វិញ ។

៥. តម្លៃអប់រំនៃរឿងឪពុកក្មេកលើសកូនប្រសា ៖

- ការជ្រើសរើសកូនប្រសា ត្រូវមើលលើសមត្ថភាពជាធំ ...
- មិនត្រូវយកទំនៀមទម្លាប់ប្រពៃណី មកធ្វើជាខែលដើម្បីបោកប្រាស់ កេងចំណេញកម្លាំងញើសឈាមអ្នកដទៃ ...

៦. គំនិតសុទិដ្ឋិនិយម នៃរឿងឪពុកក្មេកលើសកូនប្រសា ៖

- កូនប្រុសត្រូវមានជំនឿលើខ្លួនឯង លើសមត្ថភាពខ្លួន ...
- មានប្រាជ្ញាឈ្លាសវៃជាកត្តានាំមកនូវជ័យជំនះក្នុងការដោះស្រាយបញ្ហា ...
- ត្រូវមានចិត្តអំណត់ តស៊ូ ព្យាយាមគ្រប់ពេលវេលា ... ។

លក្ខណៈរបស់ព្យាង្គ

១. វត្ថុបំណង

- ប្រាប់បញ្ជូតិព្យាង្គបើក ព្យាង្គបិង និងទម្រង់បានត្រឹមត្រូវ
- ប្រាប់បញ្ជូតិព្យាង្គវែង ព្យាង្គខ្លីបានត្រឹមត្រូវ
- ស្រង់ពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង ព្យាង្គខ្លីពីក្នុងកថាខណ្ឌបានត្រឹមត្រូវ
- រកពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង ព្យាង្គខ្លីបានត្រឹមត្រូវ
- បណ្តុះស្មារតីសិស្សឱ្យមានគំនិតអភិរក្សអក្សរសាស្ត្រជាតិ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២៤៣-២៤៤
- ឯកសារវេយ្យាករណ៍ថ្នាក់ទី ៥ របស់ក្រសួងអប់រំបោះពុម្ពឆ្នាំ ១៩៨៣។

៣. ព័ត៌មានជំនួយ

ដើម្បីជាជំនួយដល់សិស្សក្នុងការធ្វើលំហាត់ សូមលោក/អ្នកគ្រូរកឯកសារវេយ្យាករណ៍ថ្នាក់ទី ៥ របស់ក្រសួងអប់រំ បោះពុម្ពឆ្នាំ ១៩៨៣ និងដើម្បីឱ្យសិស្សយល់កាន់តែច្បាស់ សូមលោក/អ្នកគ្រូជាក់លំហាត់បន្ថែមទៀតឱ្យសិស្សធ្វើ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូឱ្យសិស្សបើកសៀវភៅសិស្សត្រង់មេរៀនទី ១០ទំព័រទី ២៤៣ បន្ទាប់មកគ្រូសរសេរចំណងជើងវេយ្យាករណ៍ "លក្ខណៈរបស់ព្យាង្គ"ដាក់លើក្តារខៀន រួចគ្រូសួរ ៖
  - ដូចម្តេចដែលហៅថា ព្យាង្គ ?

    ចម្លើយ : ព្យាង្គគឺជាសូររួមនៃសទ្ទដែលបន្លឺឡើងតែមួយបន្សាយសំឡេង។
- គ្រូឱ្យសិស្សអានសេចក្តីពន្យល់ក្នុងសៀវភៅសិស្សទំព័រទី ២៤៣ផ្នែកខាងលើ រួចគ្រូសួរ ៖
  - តើនៅក្នុងពាក្យខ្មែរមានប៉ុន្មានព្យាង្គ ?

    ចម្លើយ : មានមួយព្យាង្គ ឬពីរព្យាង្គ។
  - ចូររកឧទាហរណ៍ពាក្យដែលមានមួយព្យាង្គ ពាក្យដែលមានពីរព្យាង្គ។

    ចម្លើយ :

    + ពាក្យដែលមានមួយព្យាង្គ : កាប់ ភ្នំ ទាយ ចាំ....
    + ពាក្យដែលមានពីរព្យាង្គ : សាលា កង្កែប បំភ្លេច សរសេរ...
    + ពាក្យដែលមានបីព្យាង្គ : កញ្ចាញ់ចេក កំពឹងពួយ កញ្ជិងក កន្ទេះឡង់...
    + ពាក្យដែលមានបួនព្យាង្គ : គ្រលឹងគ្រលោង អំពិលអំពែក កន្ទាលត្រអាក កកែកករ ស្រវាស្រទេញ ក្រសាំងទំហំ ក្រវេមក្រវាម...។

- តើនៅក្នុងព្យាង្គនីមួយៗមានអ្វីខ្លះ ?

  ចម្លើយ : ក្នុងព្យាង្គនីមួយៗមាន សទ្ទដើមព្យាង្គ សទ្ទកណ្តាលព្យាង្គ និងសទ្ទចុងព្យាង្គ ។

- តើលក្ខណៈរបស់ព្យាង្គមានប៉ុន្មានបែប ? អ្វីខ្លះ ?

  ចម្លើយ : លក្ខណៈរបស់ព្យាង្គមានពីរបែបគឺ តាមមូលភេទ [អ-អ៊] និងតាមលក្ខណៈខ្យល់ ។

- គ្រូឱ្យសិស្សអានត្រង់ចំណុចទី ១ ក្នុងសៀវភៅសិស្សទំព័រទី ២៤៣ រួចគ្រូសួរ ៖

- តាមមូលភេទ [អ-អ៊] តើព្យាង្គមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

  ចម្លើយ : តាមមូលភេទ [អ-អ៊] ព្យាង្គមានពីរយ៉ាងគឺ ព្យាង្គពួក [អ] និងព្យាង្គពួក [អ៊] ។

- ដូចម្តេចដែលហៅថាព្យាង្គពួក [អ] ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

  ចម្លើយ : ព្យាង្គពួក [អ] គឺជាព្យាង្គដែលមានសញ្ញាព្យញ្ជនៈដើមព្យាង្គពួក [អ] ។

  ឧទាហរណ៍ : សំណាង កាយ ចាប់ ... ។

- ដូចម្តេចដែលហៅថាព្យាង្គពួក [អ៊] ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

  ចម្លើយ : ព្យាង្គពួក [អ៊] គឺជាព្យាង្គដែលមានសញ្ញាព្យញ្ជនៈដើមព្យាង្គពួក [អ៊] ។ ***ឧទាហរណ៍ :*** ជួប គង ញាតិ ... ។

- គ្រូឱ្យសិស្សអានត្រង់ចំណុចទី ២ ក្នុងសៀវភៅសិស្សទំព័រទី ២៤៣-២៤៤ រួចគ្រូសួរ ៖

- តាមលក្ខណៈខ្យល់ តើព្យាង្គមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

  ចម្លើយ : តាមលក្ខណៈខ្យល់ព្យាង្គមាន ៤ប្រភេទគឺ ព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លី ។

- ដូចម្តេចដែលហៅថាព្យាង្គបើក ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

  ចម្លើយ : ព្យាង្គបើក គឺជាព្យាង្គដែលមានស្រៈនៅក្នុងខាងចុង ។ ***ឧទាហរណ៍ :*** ស្រែ បើ គ្នា ... ។

- តើព្យាង្គបើកមានទម្រង់ដូចម្តេច ?

  ចម្លើយ : ព្យាង្គបើកមានទម្រង់ ពស ឬពពស ។

- ដូចម្តេចដែលហៅព្យាង្គបិទ ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

  ចម្លើយ : ព្យាង្គបិទ គឺជាព្យាង្គដែលមានព្យញ្ជនៈនៅខាងចុង ។ ឧទាហរណ៍ : បំពង់ អស់ ពេញ ។

- តើព្យាង្គបិទមានទម្រង់ដូចម្តេច ?

  ចម្លើយ : ព្យាង្គបិទមានទម្រង់ពសព ឬពពសព ។

- ដូចម្តេចដែលហៅថាព្យាង្គវែង ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

  ចម្លើយ : ព្យាង្គវែង គឺជាព្យាង្គដែលស្រៈវែង ។ ***ឧទាហរណ៍ :*** កូន ថា ស្មើ ... ។

- ដូចម្តេចដែលហៅថាព្យាង្គខ្លី ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

  ចម្លើយ : ព្យាង្គខ្លី គឺជាព្យាង្គដែលមានស្រៈខ្លី ។ ***ឧទាហរណ៍ :*** បុក តិច ទៅ ... ។

២. ការហ្វឹកហាត់

- គ្រូចែកសិស្សជាក្រុមតូចៗ ឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់ និងលេខាកត់ត្រាម្នាក់
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ទី ១ និងទី ២ ក្នុងសៀវភៅសិស្សទំព័រទី ២៤៤
- គ្រូណែនាំសិស្សពីរបៀបធ្វើលំហាត់ទី ១ និងទី ២ ក្នុងសៀវភៅទំព័រទី ២៤៤
- ក្រុមនីមួយៗពិភាក្សាធ្វើកិច្ចការ បន្ទាប់ពីពិភាក្សាធ្វើចប់ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូធ្វើការបូកសរុបនិងកែលម្អ ។

ចម្លើយ :

លំហាត់ទី ១

ពាក្យដែលមានព្យាង្គពួក[អ]	ពាក្យដែលមានព្យាង្គពួក[អ៊]
• **ល្បះ ក :** ត្រូវ បែប យ៉ាង ដើម្បី បុព្វ ហេតុ ការពារ បូរណភាព ដី ខ្លួន • **ល្បះ ខ :** ដែល សុទិដ្ឋិនិយម ក្នុង ការ ធ្វើ កិច្ចការ តែង ក្នុង ឆាក	• **ល្បះ ក :** យុវជន គ្រប់ រូប ហ៊ាន លះបង់ គ្រប់ ទឹក របស់ • **ល្បះ ខ :** មនុស្ស មាន ទទួល ជោគជ័យ ជីវិត

លំហាត់ទី ២

ពាក្យដែលមានព្យាង្គពួក[អ]ចំនួន ១០ពាក្យ	ពាក្យដែលមានព្យាង្គពួក[អ៊]ចំនួន ១០ពាក្យ
កំណើត ចំការ ក្សេមក្សាន្ត តុបតែង សប្បាយ កង្កែប ចម្បាំង ឆានៅ ដង្កៀប បណ្តោយ	គង្គា ឃ្មុំ ញញឹម ជញ្ជីង ឈ្នួញ ពីងពាង ទម្លាប់ និយាយ ទន្ទឹម ភ្នំ

គ. ការវាយតម្លៃ

- គ្រូសួរបញ្ជាក់ឡើងវិញ ៖
  - តាមមូលភេទ[អ-អ៊] តើព្យាង្គមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

    ចម្លើយ : តាមមូលភេទ[អ-អ៊] ព្យាង្គមានពីរប្រភេទគឺ ព្យាង្គពួក[អ]និងព្យាង្គពួក[អ៊] ។
  - ដូចម្តេចដែលហៅថាព្យាង្គពួក[អ] ?

    ចម្លើយ : ព្យាង្គពួក[អ] គឺជាព្យាង្គដែលមានសញ្ញាព្យញ្ជនៈដើមព្យាង្គពួក[អ] ។
  - ដូចម្តេចដែលហៅថាព្យាង្គពួក[អ៊] ?

    ចម្លើយ : ព្យាង្គពួក[អ៊] គឺជាព្យាង្គដែលមានសញ្ញាព្យញ្ជនៈដើមព្យាង្គពួក[អ៊] ។
  - តាមលក្ខណៈខ្យល់ តើព្យាង្គមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

    ចម្លើយ : តាមលក្ខណៈខ្យល់ព្យាង្គមាន ៤យ៉ាងគឺ ព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លី ។
  - ដូចម្តេចដែលហៅថាព្យាង្គបើក ?

    ចម្លើយ : ព្យាង្គបើក គឺជាព្យាង្គដែលមានស្រៈនៅក្នុងខាងចុង ។
  - តើព្យាង្គបើកមានទម្រង់ដូចម្តេច ?

    ចម្លើយ : ព្យាង្គបើកមានទម្រង់ ពស ឬពពស ។
  - ដូចម្តេចដែលហៅថាព្យាង្គបិទ ?

    ចម្លើយ : ព្យាង្គបិទគឺជាព្យាង្គដែលមានព្យញ្ជនៈនៅខាងចុង ។
  - តើព្យាង្គបិទមានទម្រង់ដូចម្តេច ?

    ចម្លើយ : ព្យាង្គបិទមានទម្រង់ពសព ឬពពសព ។

- ដូចម្តេចដែលហៅថាព្យាង្គវែង ?

  ចម្លើយ : ព្យាង្គវែង គឺជាព្យាង្គដែលស្រៈវែង ។

- ដូចម្តេចដែលហៅថាព្យាង្គខ្លី ?

  ចម្លើយ : ព្យាង្គខ្លី គឺជាព្យាង្គដែលមានស្រៈខ្លី ។

- គ្រូឱ្យសិស្សធ្វើលំហាត់ទី ៣ និងទី ៤ ក្នុងសៀវភៅសិស្សទំព័រទី ២៤៤ ៖
- ឱ្យសិស្សម្នាក់ៗធ្វើលំហាត់ទី ៣ និងទី ៤ ក្នុងសៀវភៅសិស្សទំព័រទី ២៤៤ដាក់ក្នុងសៀវភៅរៀងៗខ្លួន
- គ្រូណែនាំពីរបៀបធ្វើលំហាត់ទី ៣ និងទី ៤ ក្នុងសៀវភៅសិស្សទំព័រទី ២៤៤
- សិស្សធ្វើកិច្ចការរៀងៗខ្លួន
- បន្ទាប់ពីធ្វើលំហាត់ចប់ គ្រូប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ
- គ្រូធ្វើការកែលម្អនិងវាយតម្លៃ ។

ចម្លើយ :

លំហាត់ទី ៣

ពាក្យដែលមានព្យាង្គបើក	ពាក្យដែលមានព្យាង្គបិទ	ពាក្យដែលមានព្យាង្គវែង	ពាក្យដែលមានព្យាង្គខ្លី
ពោធិ៍កំបោរ ជា ដ៏ ស្នេហា ជ្រាលជ្រៅ នាំ ចលនា តស៊ូ ត្រួតត្រា លើ កម្ពុជា បូជា ដើម្បី រំដោះ ខ្មែរ សរសើរ ចាំ គំរូ នេះ ជា	វីរជន អង់អាច ក្លាហាន មាន ទឹក ចិត្ត ជាតិ យ៉ាង លោក បាន ដឹក ប្រឆាំង នឹង អាណានិគម និយម បារាំង ដែលត្រួត ប្រទេស បាន ជីវិត បុព្វហេតុ ប្រទេស ជាតិ ប្រជាជន គ្រប់ រូប គោរព កោត និង នៅ ចង វីរភាព ក្នុង ចិត្ត ជាប់ និច្ច	ពោធិ៍កំបោរ ជា ដ៏ អាច ក្លាហាន មាន ស្នេហា ជាតិ យ៉ាង ជ្រាល បាន លោក ចលនា តស៊ូ ដែល ត្រួតត្រា លើ ប្រទេស បូជា ជីវិត ដើម្បី ហេតុ ខ្មែរ ប្រទេស ប្រជាជន រូប គោរព កោត សរសើរ ចង គំរូ វីរភាព ជានិច្ច	ជន អង់អាច ទឹក ចិត្ត ជ្រៅ ដឹក ប្រឆាំង នឹង និគម និយម បារាំង ជីវិត បុព្វ គ្រប់ និង នៅ ក្នុង ចិត្ត ជាប់ និច្ច

លំហាត់ទី ៤

ពាក្យដែលមានព្យាង្គបើក	ពាក្យដែលមានព្យាង្គបិទ	ពាក្យដែលមានព្យាង្គវែង	ពាក្យដែលមានព្យាង្គខ្លី
ទិវា ចងចាំ វិថី មីនា ទីធ្លា ចំណេះ បង្គា សាមគ្គី រំដោះ តុលា ...	ទឹកកក និយាយ សប្បាយ បង្កង ចំណាយ ដេក បបួល បញ្ចេញ គ្រប់គ្រាន់ ក្បាល ...	លើក កណ្តាល ត្រកួន ពុទ្រា កកូរ ក្មេង បន្លឺ លឿង ចោរ បន្លែ ...	កប់ ព្រំ ដាំ ពាំង ទិញ កុក បឹង កែ បី សៅរ៍ ...

របាយការណ៍

១. វត្ថុបំណង

- ប្រាប់បញ្ញត្តិរបាយការណ៍បានត្រឹមត្រូវ
- ប្រាប់ប្រភេទនិងទម្រង់របាយការណ៍បានត្រឹមត្រូវ
- សរសេរព្រាង របាយការណ៍អង្គប្រជុំ និងផ្សេងៗបានត្រឹមត្រូវ ។

២. សម្ភារៈបង្រៀន

- សៀវភៅសិស្សទំព័រទី ២៤៥-២៤៨
- របាយការណ៍នៃអង្គប្រជុំជាក់ស្តែងផ្សេងៗ ... ។

៣. ព័ត៌មានដំណួយ

ដើម្បីជាជំនួយដល់សិស្សក្នុងការស្វែងយល់ខ្លឹមសារមេរៀនឱ្យកាន់តែច្បាស់និងដើម្បីជាជំនួយក្នុងការធ្វើលំហាត់ សូមលោក/អ្នកគ្រូ ប្រើប្រាស់របាយការណ៍នៃអង្គប្រជុំជាក់ស្តែងផ្សេងៗ ... ។

៤. លំនាំបង្រៀន

ក. ការបង្ហាញ

- គ្រូសរសេរចំណងជើងមេរៀនក្នុងសៀវភៅសិស្សទំព័រទី ២៤៥ផ្នែកខាងលើ រួចសួរ ៖
  - ដូចម្តេចដែលហៅថា របាយការណ៍ ?

    ចម្លើយ : របាយការណ៍ គឺជាការផ្តល់ព័ត៌មានអំពីបញ្ហាអ្វីមួយឱ្យគេបានដឹង ។
  - តើរបាយការណ៍មានប៉ុន្មានប្រភេទ ?

    ចម្លើយ : របាយការណ៍មានច្រើនប្រភេទដូចជា របាយការណ៍តាមជំនាញ របាយការណ៍អង្គប្រជុំ ឬរបាយការណ៍សិក្ខាសាលា របាយការណ៍កម្មវិធី ឬគម្រោង របាយការណ៍បេសកកម្ម ឬទស្សនៈកិច្ច របាយការណ៍ផ្ទាល់ខ្លួន ។ ល ។
  - តើគេធ្វើរបាយការណ៍នៅពេលណាខ្លះ ?

    ចម្លើយ : របាយការណ៍ខ្លះ ជាពិសេសរបាយការណ៍នៅតាមជំនាញស្ថាប័នផ្សេងៗ ត្រូវធ្វើឡើងយ៉ាងទៀងទាត់ប្រចាំសប្តាហ៍ ប្រចាំខែ ឬប្រចាំឆ្នាំ ។ របាយការណ៍ខ្លះទៀត ធ្វើទៅតាមពេលវេលាដែលគេអនុវត្តការងារអ្វីមួយដូចជា របាយការណ៍អង្គប្រជុំ បេសកកម្ម កម្មវិធីជាដើម ។
  - ក្នុងការសរសេររបាយការណ៍ តើត្រូវផ្តោតទៅលើអ្វីខ្លះ ?

    ចម្លើយ : ក្នុងការសរសេររបាយការណ៍ ត្រូវរៀបរាប់ឱ្យបានច្បាស់លាស់និងត្រឹមត្រូវជាក់ស្តែង អំពីព្រឹត្តិការណ៍ សភាពការណ៍ ហេតុការណ៍ និងលទ្ធផលការងារដែលបានអនុវត្ត ។
- គ្រូឱ្យសិស្សអានទម្រង់របាយការណ៍អង្គប្រជុំក្នុងសៀវភៅសិស្សទំព័រទី ២៤៥រួចសួរ ៖

- តើរបាយការណ៍អង្គប្រជុំចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

ចម្លើយ : របាយការណ៍អង្គប្រជុំចែកចេញជា ៣ផ្នែកគឺ ផ្តើមរបាយការណ៍ តួរបាយការណ៍ និងចុងបញ្ចប់របាយការណ៍ ។

- តើផ្តើមរបាយការណ៍អង្គប្រជុំចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

ចម្លើយ : ផ្តើមរបស់របាយការណ៍អង្គប្រជុំចែកចេញជា ២ផ្នែកគឺ ផ្នែកទី ១ប្រាប់ពីបាវចនាជាតិ ផ្នែកទី ២ប្រាប់ពីឈ្មោះស្ថាប័ននិងលេខរបស់របាយការណ៍ ។

- តើផ្នែកនីមួយៗមានខ្លឹមសារដូចម្តេចខ្លះ ?

ចម្លើយ : ផ្នែកនីមួយៗមានខ្លឹមសារ ៖

ផ្នែកទី ១ គឺបាវចនាជាតិមានខ្លឹមសារ

+ ព្រះរាជាណាចក្រកម្ពុជា
+ ជាតិ សាសនា ព្រះមហាក្សត្រ

ផ្នែកទី ២ គឺឈ្មោះស្ថាប័នមានខ្លឹមសារ

+ មន្ទីរ អយក. ខេត្ត ..... និងការិយាល័យ .....
+ លេខរបស់របាយការណ៍ ។

- តើតួរបស់របាយការណ៍អង្គប្រជុំចែកចេញជាប៉ុន្មានចំណុច ? អ្វីខ្លះ ?

ចម្លើយ : ចែកចេញជា ១១ចំណុចគឺ ចំណងជើង យោង កាលបរិច្ឆេទ ប្រធានអង្គប្រជុំ របៀបវារៈ សមាសភាពចូលរួម អវត្តមាន ខ្លឹមសារអង្គប្រជុំ ការសម្រេចរបស់អង្គប្រជុំ ពេលវេលាបញ្ចប់អង្គប្រជុំ ។

- តើផ្នែកនីមួយៗមានខ្លឹមសារដូចម្តេចខ្លះ ?

ចម្លើយ : ផ្នែកនីមួយៗមានខ្លឹមសារ ៖

+ ចំណងជើងរបាយការណ៍ : ប្រាប់ប្រធានបទនៃអង្គប្រជុំ (ស្តីពីការប្រជុំ .....)
+ យោង : ប្រាប់លិខិត ឬសេចក្តីជូនដំណឹងដើម្បីបើកអង្គប្រជុំ (យោងតាមលិខិតបង្គាប់ការលេខ ....របស់ .... ចុះថ្ងៃទី .....ខែ .....ឆ្នាំ .....)
+ កាលបរិច្ឆេទ : ប្រាប់ថ្ងៃខែឆ្នាំដែលបានបើកអង្គប្រជុំ (កាលពីថ្ងៃទី .....ខែ .....ឆ្នាំ .....មានបើកកិច្ចប្រជុំមួយ .....)
+ ប្រធានអង្គប្រជុំ : ប្រាប់ឈ្មោះប្រធានអង្គប្រជុំ (អង្គប្រជុំនេះប្រព្រឹត្តទៅក្រោមអធិបតីភាព .....)
+ របៀបវារៈ : ប្រាប់របៀបវារៈនៃអង្គប្រជុំ (កិច្ចប្រជុំនេះពិភាក្សាលើរបៀបវារៈ .....)
+ សមាសភាពចូលរួម : ប្រាប់វត្តមានអ្នកចូលរួម
+ អវត្តមាន : ប្រាប់ចំនួនអ្នកអវត្តមាន
+ ខ្លឹមសារអង្គប្រជុំ : ប្រាប់ខ្លឹមសារទាក់ទងនឹងប្រធានបទដែលបានលើកយកមកប្រជុំ
+ ការសម្រេចរបស់អង្គប្រជុំ : ប្រាប់ខ្លឹមសារដែលអង្គប្រជុំបានអនុម័តយកជាចុងក្រោយ
+ ពេលវេលាបញ្ចប់អង្គប្រជុំ : ប្រាប់ពេលវេលានៃការបញ្ចប់អង្គប្រជុំ (អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង .... ថ្ងៃទី .....ខែ .....ឆ្នាំជដែល) ។

- តើចុងបញ្ចប់របស់របាយការណ៍អង្គប្រជុំចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

ចម្លើយ : ចុងបញ្ចប់របស់របាយការណ៍អង្គប្រជុំចែកចេញជា ២ផ្នែកគឺ ផ្នែកទី ១ប្រាប់ពីកាលបរិច្ឆេទនៃការធ្វើរបាយការណ៍និងហត្ថលេខារបស់អ្នកធ្វើរបាយការណ៍និងផ្នែកទី ២ហត្ថលេខាឯកភាពរបស់ប្រធានអង្គប្រជុំ ។

- តើផ្នែកនីមួយៗមានខ្លឹមសារដូចម្តេចខ្លះ ?

ចម្លើយ : ផ្នែកនីមួយៗមានខ្លឹមសារ ៖

ផ្នែកទី ១ :

+ ធ្វើនៅ ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ .....
+ អ្នកធ្វើរបាយការណ៍
+ ហត្ថលេខានិងឈ្មោះ

ផ្នែកទី ២ :

+ បានឃើញនិងឯកភាព
+ ប្រធានការិយាល័យ
+ ហត្ថលេខានិងឈ្មោះ

- គ្រូឱ្យសិស្សអានទម្រង់របាយការណ៍អង្គប្រជុំប្រចាំខែក្នុងសៀវភៅសិស្សទំព័រទី ២៤៧ រួចសួរ ៖
  - តើរបាយការណ៍អង្គប្រជុំប្រចាំខែ ចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

    ចម្លើយ : របាយការណ៍អង្គប្រជុំប្រចាំខែចែកចេញជា ៣ផ្នែកគឺ ផ្តើមរបាយការណ៍ តួរបាយការណ៍ និងចុងបញ្ចប់របាយការណ៍ ។
  - តើផ្តើមរបាយការណ៍អង្គប្រជុំប្រចាំខែចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

    ចម្លើយ : ផ្តើមរបស់របាយការណ៍អង្គប្រជុំប្រចាំខែចែកចេញជា ២ផ្នែកគឺ ផ្នែកទី ១ប្រាប់ពីបាវចនាជាតិ ផ្នែកទី ២ ប្រាប់ពីឈ្មោះស្ថាប័ននិងលេខរបស់របាយការណ៍ ។
  - តើផ្នែកនីមួយៗមានខ្លឹមសារដូចម្តេចខ្លះ ?

    ចម្លើយ : ផ្នែកនីមួយៗមានខ្លឹមសារ ៖

    ផ្នែកទី ១ គឺបាវចនាជាតិមានខ្លឹមសារ

    + ព្រះរាជាណាចក្រកម្ពុជា
    + ជាតិ សាសនា ព្រះមហាក្សត្រ

    ផ្នែកទី ២ គឺឈ្មោះស្ថាប័នមានខ្លឹមសារ

    + មន្ទីរ អយក. ខេត្ត ..... និងការិយាល័យ .....
    + លេខរបស់របាយការណ៍ ។
  - តើតួរបស់របាយការណ៍អង្គប្រជុំប្រចាំខែចែកចេញជាប៉ុន្មានចំណុច ? អ្វីខ្លះ ?

    ចម្លើយ : ចែកចេញជា ៦ចំណុចគឺ ចំណងជើង កម្មវត្ថុ រយៈពេល លទ្ធផល សំណូមពរ ការសម្តែងការកិច្ចបញ្ចប់ ។
  - តើផ្នែកនីមួយៗមានខ្លឹមសារដូចម្តេចខ្លះ ?

ចម្លើយ : ផ្នែកនីមួយៗមានខ្លឹមសារ ៖

+ ចំណងជើងរបាយការណ៍ប្រាប់ពី

  របាយការណ៍ .....

  ប្រធានការិយាល័យ .....

  គោរពជូន

  ប្រធានមន្ទីរ អយក. ខេត្ត .....

+ កម្មវត្ថុ : ប្រាប់ពីកម្មវត្ថុនៃអង្គប្រជុំ (កម្មវត្ថុ : អំពីលទ្ធផលការងារ .....)
+ រយៈពេល : ប្រាប់រយៈពេលបំពេញការងារ (សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំមានកិត្តិយសសូមជំរាបលោក-លោកស្រី ប្រធានមេត្តាជ្រាបថា ចាប់តាំងពីថ្ងៃទី .....ខែ .....ឆ្នាំ .....រហូតដល់ថ្ងៃទី .....ខែ .....ឆ្នាំ .....មន្ត្រីរាជការនៅការិយាល័យ .....បានធ្វើកិច្ចការទទួលលទ្ធផលដូចតទៅ ៖)
+ លទ្ធផល : ប្រាប់លទ្ធផលការងារដែលសម្រេចបាន ៖

ក. ផ្នែកបុគ្គលិក : មានបុគ្គលិកចំនួន .....នាក់ ស្រីចំនួន .....នាក់ ដោយរៀបចំកិច្ចការអនុវត្តជាក្រុមគឺ ៖

+ ផ្នែក .....ចំនួន..... ស្រីចំនួន .....នាក់
+ ផ្នែក .....ចំនួន..... ស្រីចំនួន .....នាក់
+ ផ្នែក .....ចំនួន..... ស្រីចំនួន .....នាក់

ខ. លទ្ធផល

+ បានរៀបចំចុះធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន ..... ។
+ បានធ្វើ ..... ។
+ បានរៀបចំ ..... ។
+ សំណូមពរ : ប្រាប់ពីសំណូមពររបស់អង្គប្រជុំ ....
+ ការសម្តែងគារវកិច្ចបញ្ចប់ : ការសម្តែងសេចក្តីគោរពចំពោះអ្នកទទួលរបាយការណ៍ (សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ....)

- តើចុងបញ្ចប់របស់របាយការណ៍អង្គប្រជុំប្រចាំខែចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?

ចម្លើយ : ចុងបញ្ចប់របស់របាយការណ៍អង្គប្រជុំប្រចាំខែចែកចេញជា ២ផ្នែកគឺ ផ្នែកទី ១ប្រាប់ពីកាលបរិច្ឆេទនៃការធ្វើរបាយការណ៍និងហត្ថលេខាប្រធានអង្គភាពធ្វើរបាយការណ៍និងផ្នែកទី ២ប្រាប់ឈ្មោះអង្គភាពដែលត្រូវចម្លងជូន ។

- តើផ្នែកនីមួយៗមានខ្លឹមសារដូចម្តេចខ្លះ ?

ចម្លើយ : ផ្នែកនីមួយៗមានខ្លឹមសារ ៖

ផ្នែកទី ១

+ ធ្វើនៅ .....ថ្ងៃទី .....ខែ .....ឆ្នាំ .....
+ ប្រធានការិយាល័យ
+ ហត្ថលេខានិងឈ្មោះ

ផ្នែកទី ២

+ ចម្លងជូន .....

ខ. ការអនុវត្ត

- គ្រូឱ្យសិស្សអានលំហាត់ទី ១ក្នុងសៀវភៅសិស្សទំព័រទី ២៤៨ ។
- គ្រូឱ្យសិស្សអានលំណែនាំលំហាត់ទី ១ក្នុងសៀវភៅសិស្សទំព័រទី ២៤៨ រួចសួរ ៖

- តើលំហាត់នេះ តម្រូវឱ្យអ្នកធ្វើដូចម្តេច ?

ចម្លើយ : តម្រូវឱ្យយើងធ្វើការជាក្រុម ពិភាក្សាសរសេរប្រជុំស្តីពីការពង្រឹងរបស់ការិយាល័យអប់រំ យុវជន និង កីឡាស្រុក ។

- ការធ្វើគម្រោងអត្ថបទ ៖

- គ្រូចែកសិស្សជាក្រុមតូចៗ រួចណែនាំក្រុមនីមួយៗធ្វើលំហាត់ទី ១ ក្នុងសៀវភៅសិស្សទំព័រទី ២៤៨ ដូចខាងក្រោម

+ ការព្រាង : គ្រូឱ្យក្រុមនីមួយៗសរសេរព្រាងគម្រោងរបាយការណ៍ទាក់ទងនឹងលំហាត់ខាងលើ ។

ចម្លើយ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរ អយក. ខេត្ត .....

ការិយាល័យ .....

លេខ .....

របាយការណ៍

ស្តីពីការប្រជុំ .....

យោងតាមលិខិតបង្គាប់ការលេខ ..... របស់ ..... ចុះថ្ងៃទី ..... ខែ ..... ឆ្នាំ .....

កាលពីថ្ងៃទី ..... ខែ ..... ឆ្នាំ ..... នៅ ..... មានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាព

..... ។

- កិច្ចប្រជុំនេះពិភាក្សាលើរបៀបវារៈ

១. .....

២. .....

៣. .....

- សមាសសភាពចូលរួម

១. .....

២. .....

៣. .....

- អវត្តមាន

១. .....

២. .....

៣. .....

ជាកិច្ចចាប់ផ្តើមប្រធានអង្គប្រជុំបានលើកឡើងនូវ .....

..... ។

អង្គប្រជុំសម្រេចបាន ..... ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ ដដែល ។

ធ្វើនៅ ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ.....

អ្នកធ្វើរបាយការណ៍

បានឃើញនិងឯកភាព

ប្រធានការិយាល័យ

ហត្ថលេខានិងឈ្មោះ

ហត្ថលេខានិងឈ្មោះ

- ការកែលម្អ ៖
  - គ្រូឱ្យក្រុមនីមួយៗប្តូរកិច្ចការគ្នាដើម្បីធ្វើការកែលម្អ ។ ក្នុងការកែលម្អចើពិនិត្យឃើញថា កិច្ចការក្រុមដទៃមានកំហុស ឬមានចំណុចខ្វះខាត ត្រូវមកសិក្សារកចំណុចឯកភាពគ្នាជាមួយក្រុមដើមជាមុនសិនមុននឹងធ្វើការកែលម្អ ។
  - គ្រូឱ្យគ្រប់កិច្ចការនៃក្រុមនីមួយៗទៅម្ចាស់ដើមវិញ ។
- ការសរសេរសម្រេច : គ្រូឱ្យក្រុមនីមួយៗសរសេររបាយការណ៍ឱ្យបានត្រឹមត្រូវ ។

គ. ការវាយតម្លៃ

- គ្រូចែកសិស្សជាក្រុម រួចឱ្យក្រុមនីមួយៗចាត់តាំងតំណាងក្រុមម្នាក់និងលេខាកត់ត្រាម្នាក់
- គ្រូណែនាំឱ្យក្រុមនីមួយៗពិភាក្សាធ្វើលំហាត់ទី ២ក្នុងសៀវភៅសិស្សទំព័រទី ២៤៨ដោយប្រើគម្រោងខាងលើ
- គ្រូឱ្យក្រុមនីមួយៗពិភាក្សាសរសេររបាយការណ៍ប្រជុំបូកសរុបការងារប្រចាំខែរបស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ដើម្បីផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- បន្ទាប់ពីធ្វើកិច្ចការចប់ គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចម្លើយក្រុមខ្លួន
- គ្រូនិងសិស្សធ្វើការបូកសរុបនិងកែលម្អ ។

ចម្លើយ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរ អយក. ខេត្ត .....

ការិយាល័យ .....

លេខ .....

របាយការណ៍ប្រចាំខែ

ប្រធានការិយាល័យ .....

សូមគោរពជូន

ប្រធានមន្ទីរ អយក.ខេត្ត .....

កម្មវត្ថុ :អំពីលទ្ធផលការងារ ..... ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំមានកិត្តិយសូមជម្រាប លោក-លោកស្រីប្រធានមេត្តាជ្រាប ថាចាប់តាំងពីថ្ងៃទី ..... ខែ ..... ឆ្នាំ ..... រហូតដល់ថ្ងៃទី ..... ខែ ..... ឆ្នាំ ..... មន្ត្រីរាជការនៅការិយាល័យ ..... បានធ្វើកិច្ចការទទួលលទ្ធផលដូចតទៅ :

ក. ផ្នែកបុគ្គលិក

មានបុគ្គលិកចំនួន ..... នាក់ ស្រីចំនួន ..... នាក់ ដោយរៀបចំកិច្ចការអនុវត្តជាក្រុមគឺ :

១. ផ្នែក ..... ចំនួន ..... ស្រីចំនួន ..... នាក់

២. ផ្នែក ..... ចំនួន ..... ស្រីចំនួន ..... នាក់

៣. ផ្នែក ..... ចំនួន ..... ស្រីចំនួន ..... នាក់

ខ. លទ្ធផល

១. បានរៀបចំចុះធ្វើយុទ្ធនាការធានាការប្រមូលកុមារចូលរៀន ..... ។

២. បានធ្វើ ..... ។

៣. បានរៀបចំ ..... ។

គ. សំណូមពរ

.....

.....

.....

.....

..... ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើនេះ សូមលោកប្រធានជ្រាបជារបាយការណ៍ ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

ប្រធានការិយាល័យ

ហត្ថលេខានិងឈ្មោះ

ចម្លងជូន

១. .....

២. .....

៣. .....